អន្តរាយ ព្រោះហេតុប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាស តើដូចម្តេច ។ អន្តរាយទាំងនោះ ប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស ដើម្បីអន្តរាយដល់ធម៌ទាំងឡាយជាកុសល ។ ធម៌ទាំងឡាយជាកុសល តើដូចម្តេច ។ អន្តរាយទាំងឡាយនោះ ប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស ដើម្បីអន្តរាយដល់ធម៌ទាំងឡាយជាកុសលទាំងនេះ គឺសេចក្តីប្រតិបត្តិដោយប្រពៃ សេចក្តីប្រតិ-បត្តិដ៏សមគួរ សេចក្តីប្រតិបត្តិមិនជាសត្រូវ សេចក្តីប្រតិបត្តិសមគួរដល់អត្ត សេចក្តីប្រតិបត្តិតាមធម៌សមគួរដល់ធម៌ ភាពនៃបុគ្គលអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ភាពនៃបុគ្គលអ្នកមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ ភាពនៃបុគ្គលអ្នកដឹងប្រមាណក្នុងភោជន ការប្រកបរឿយៗនូវធម៌ជាគ្រឿងភ្ញាក់រលឹក សតិនិងសម្បជញ្ញៈ ការប្រកបរឿយ ៗ ក្នុងកិរិយាចម្រើនសតិ-ប្ឋដ្ឋាន ៤ ការប្រកបរឿយ ៗ ក្នុងកិរិយាចម្រើនសម្មប្ឋធាន ៤ ការប្រកបរឿយ ៗ ក្នុងកិរិយាចម្រើនឥទ្ធិបាទ ៤ ការប្រកបរឿយ ៗ ក្នុងកិរិយាចម្រើនឥន្ទ្រិយ ៥ ការប្រកបរឿយ ៗ ក្នុងកិរិយាចម្រើនពលៈ ៥ ការប្រកបរឿយ ៗ ក្នុងកិរិយាចម្រើនពោជ្ឌង្គ ៧ ការប្រកបរឿយ ៗ ក្នុងកិរិយាចម្រើនអដ្ឋង្គិកមគ្គដ៏ប្រសើរ ។

ឥមេសំ កុសលានំ ធម្មានំ បរិហានាយ អន្តរាយាយ សំវត្តន្តិ ។ ឯវំ បរិហានាយ សំវត្តន្តីតិ បរិស្សយា ។

កថំ តត្រាសយាតិ បរិស្សយា ។ តត្ថេតេ ចាបកា អកុសលា ធម្មា ឧប្បជ្ជន្តិ អត្តភាវសន្ទិស្សយា ។ យថា ពិលេ ពិលាសយា ចាណា សយន្តិ ឧកេ ឧកាសយា ចាណា សយន្តិ វនេ វនាសយា ចាណា សយន្តិ រុក្ខេ រុក្ខាសយា ចាណា សយន្តិ ឯវមេវ តត្ថេតេ ចាបកា អកុសលា ធម្មា ឧប្បជ្ជន្តិ អត្តភាវសន្ទិស្សយាតិ ឯវម្បិ តត្រាសយាតិ បរិស្សយា ។

រុត្តំ ហេតំ ភគវតា សាន្តេវាសិកោ ភិក្ខវេ ភិក្ខុ សាចរិយកោ ឧក្ខំ ន ជានុ វិហរតិ ។ ឥមញ្ច ភិក្ខវេ ភិក្ខុ សាន្តេវាសិកោ សាចរិយកោ ឧក្ខំ ន ជានុ វិហរតិ ។

អន្តរាយ ព្រោះហេតុប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាស យ៉ាងនេះ ។

អន្តរាយ ព្រោះហេតុអាស្រ័យ ក្នុងសរីរៈនោះ តើដូចម្តេច ។ ធម៌ទាំងឡាយដ៏លាមក ជាអកុសលនុ៎ះ អាស្រ័យនៅក្នុងអត្តភាព កើតឡើង ក្នុងសរីរៈនោះ ។ ពួកសត្ត្ব អាស្រ័យនៅក្នុងរន្ធ ដេកនៅក្នុងរន្ធ ពួកសត្ត្ব អាស្រ័យនៅក្នុងទឹក ដេកនៅក្នុងទឹក ពួកសត្ត្ব អាស្រ័យនៅក្នុងព្រៃ ដេកនៅក្នុងព្រៃ ពួកសត្ត្ব អាស្រ័យនៅលើដើមឈើ ដេកនៅលើដើមឈើ យ៉ាងណាមិញ ធម៌ទាំងឡាយដ៏លាមក ជាអកុសលនុ៎ះ អាស្រ័យនៅ ក្នុងអត្តភាព កើតឡើង ក្នុងសរីរៈនោះ យ៉ាងនោះដែរ ព្រោះហេតុនោះ អន្តរាយ ព្រោះអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះខ្ញុ៎ះ ។

សមដូចពាក្យនេះ ដែលព្រះមានព្រះភាគ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅជាមួយអន្តេវាសិក អ្នកនៅជាមួយអាចារ្យ រមែងនៅជាទុក្ខ មិនសប្បាយទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅជាមួយអន្តេវាសិក អ្នកនៅជាមួយអាចារ្យ រមែងនៅជាទុក្ខ មិនសប្បាយ តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ធម៌

ឥធ ភិក្ខវេ ភិក្ខុនោ ចក្ខុនា រូបំ ទិស្វា ឧប្បជ្ជន្តិ យេ ចាបកា អកុសលា ធម្មា សរសង្កប្បា សញ្ញោ-ជនីយា ត្យស្ស អន្តោ វសន្តិ អជ្ឌាស្សវន្តិ ចាបកា អកុសលា ធម្មាតិ តស្ស សាន្តោវាសិកោតិ វុច្ចតិ តេ ជំ សមុទាចរន្តិ ចាបកា អកុសលា ធម្មាតិ តស្ស សាចរិយកោតិ វុច្ចតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុនោ សោតេន សទ្ទំ សុត្វា ឃានេន គន្ធំ ឃាយិត្វា ជិវ្ហាយ រសំ សាយិត្វា កាយេន ផោដ្ឋព្ពំ ផុសិត្វា មនសា ធម្មំ វិញ្ញាយ ឧប្បជ្ជន្តិ យេ ចាបកា អកុសលា ធម្មា សរ-សង្កប្បា សញ្ញោជនីយា ត្យស្ស អន្តោ វសន្តិ អជ្ឌាស្ស-វន្តិ ចាបកា អកុសលា ធម្មាតិ តស្ស សាន្តោវាសិកោតិ វុច្ចតិ តេ ជំ សមុទាចរន្តិ ចាបកា អកុសលា ធម្មាតិ តស្ស សាចរិយកោតិ វុច្ចតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ សាន្តោវាសិកោ សាចរិយកោ ទុក្ខំ ន ជាសុ វិហរតីតិ ។

ទាំងឡាយដ៏លាមក ជាអកុសល ណា ជាសេចក្ដីត្រិះរិះ ដោយអំ-ណាច នៃកិរិយារលឹកឃើញ ជាទីតាំងនៃសំយោជន: កើតឡើងដល់ភិក្ខុ ក្នុងសាសនានេះ ព្រោះឃើញរូបដោយចក្ខុ ធម៌ទាំងឡាយដ៏លាមក ជាអកុសលនោះ រមែងនៅ រមែងជាប់តាមក្នុងសន្ដាន នៃភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ តថាគតហៅថា អ្នកនៅជាមួយអន្ដ-រ៉ាសិក ធម៌ទាំងឡាយដ៏លាមក ជាអកុសលនោះ រមែងត្រួតត្រាភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ តថាគតហៅថា អ្នកនៅជាមួយអាចារ្យ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ធម៌ទាំងឡាយដ៏លាមក ជាអកុសលណា ជាសេចក្ដីត្រិះរិះដោយកិរិយារលឹកឃើញ ជាទីតាំងនៃសំយោជន: កើតឡើងដល់ភិក្ខុ ព្រោះស្ដាប់សំឡេងដោយត្រចៀក ហិតក្លិនដោយច្រមុះ លិទ្ធរសដោយអណ្ដាត ប៉ះពាល់ផ្សព្វដោយកាយ ដឹងធម្មារម្មណ៍ដោយចិត្ត ធម៌ទាំងឡាយដ៏លាមក ជាអកុសលនោះ រមែងនៅ រមែងជាប់តាមក្នុងសន្ដានៃភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ តថាគតហៅថា អ្នកនៅជាមួយអន្ដរ៉ាសិក ធម៌ទាំងឡាយដ៏លាមក ជាអកុសលនោះ រមែងត្រួតត្រាភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ តថាគតហៅថា អ្នកនៅជាមួយអាចារ្យ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅជាមួយអន្ដរ៉ាសិក អ្នកនៅជាមួយអាចារ្យ រមែងនៅជាទុក្ខ មិនសប្បាយដោយប្រការយ៉ាងនេះឯង ។

ឯវម្ឫ តត្រាសយាតិ បរិស្សយោ ។

រុត្តំ ហោតំ ភគវតា តយោ មេ ភិក្ខវេ អន្តាមលា អន្តាអមិត្តា អន្តាសបត្តា អន្តាវធកា អន្តាបចូត្ថិកា ។ កតមេ តយោ ។ លោភោ ភិក្ខវេ អន្តាមលោ អន្ត-ាអមិត្តោ អន្តាសបត្តោ អន្តាវធកោ អន្តាបចូត្ថិកោ ទោសោ ភិក្ខវេ អន្តាមលោ អន្តាអមិត្តោ អន្តាសប-ត្តោ អន្តាវធកោ អន្តាបចូត្ថិកោ មោហោ ភិក្ខវេ អន្ត-ាមលោ អន្តាអមិត្តោ អន្តាសបត្តោ អន្តាវធកោ អន្ត-ាបចូត្ថិកោ ។ ឥមេ ខោ ភិក្ខវេ តយោ អន្តាមលា អន្ត-ាអមិត្តា អន្តាសបត្តា អន្តាវធកា អន្តាបចូត្ថិកាតិ ។

អនត្ថជនកោ លោភោ លោភោ ចិត្តប្បកោបនោ
ភយមន្តរតោ ជាតំ តំ ជនោ ជានាតិ ពុជ្ឈតិ
លុព្ធោ អត្ថំ ន ជានាតិ លុព្ធោ ធម្មំ ន បស្សតិ
អន្ធតមំ តទា ហោតិ យំ លោភោ សហតេ នរំ

អន្តរាយ ព្រោះហេតុអាស្រ័យ ក្នុងសរីរៈនោះ យ៉ាងនេះខ្ញុះ ។

មួយទៀត ពាក្យនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ៣ នេះ ជាមន្ទិលខាងក្នុង ជាអមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាបច្ចាមិត្តខាងក្នុង ។ ធម៌ទាំង-ឡាយ ៣ តើដូចម្តេចខ្ញុះ ។ ម្នាលភិក្ខុទាំងឡាយ លោភៈជាមន្ទិលខាងក្នុង ជាអមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាបច្ចាមិត្តខាងក្នុង ម្នាលភិក្ខុទាំងឡាយ ទោសៈ ជាមន្ទិលខាងក្នុង ជាអមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាបច្ចាមិត្តខាងក្នុង ម្នាលភិក្ខុទាំងឡាយ មោហៈជាមន្ទិលខាងក្នុង ជាអមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាបច្ចាមិត្តខាងក្នុង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ នេះឯង ជាមន្ទិលខាងក្នុង ជាអមិត្តខាងក្នុង ជាសត្រូវខាងក្នុងជាពេជ្ឈឃាតខាងក្នុង ជាបច្ចាមិត្តខាងក្នុង ។

លោភៈជាកិលេសញ៉ាំងសេចក្តីវិនាសឲ្យកើត លោភៈជាកិលេសញ៉ាំងចិត្តឲ្យកម្រើក ភ័យកើតហើយខាងក្នុង ជនរមែងមិនយល់ច្បាស់នូវភ័យនោះទេ បុគ្គលអ្នកលោភ រមែងមិនដឹងអត្ថ បុគ្គលអ្នកលោភ រមែងមិនឃើញធម៌ លោភៈគ្របសង្កត់ជនណា សេចក្តីងងឹតឈឹងសូន្យ (នៃជននោះ) ក៏រមែងមាន ក្នុងកាលនោះ

អនត្តជនោ ទោសោ ទោសោ ចិត្តប្ប្ឫកោបនោ
ភយមន្តរតោ ជាតំ តំ ជនো ជាវពុជ្ឈតិ
ការ្ហោ អត្ថំ ន ជានាតិ ការ្ហោ ធម្មំ ន បស្ឬតិ
អន្ធតមំ តទា ហោតិ យំ ការ្ហោ សហតេ ន្ឫ
អនត្តជនោ មោហោ មោហោ ចិត្តប្ប្ឫកោបនោ
ភយមន្តរតោ ជាតំ តំ ជនো ជាវពុជ្ឈតិ
ម្ហូ ជ្ហោ អត្ថំ ន ជានាតិ ម្ហូ ជ្ហោ ធម្មំ ន បស្ឬតិ
អន្ធតមំ តទា ហោតិ យំ មោហោ សហតេ ន្ឫ ។

ឯវម្ឬ តត្រាសយាតិ បរិស្ឬយោ ។

ឫ ហេតំ ភតវតា តយো ទោ មហារាជ បុរិសស្ឬ ធម្ម អជ្ឈត្តំ ឧប្ឬជ្ជមានা ឧប្ឬជ្ជន្តិ អហិតាយ ទុក្ខាយ អជ្ជាសុរិហារាយ ។ ការ្ហតមេ តយো ។ ការ្ហោ ទោ មហារាជ បុរិសស្ឬ ធម្ម អជ្ឈត្តំ ឧប្ឬជ្ជមានো ឧប្ឬជ្ជតិ

ទោស: ជាកិលេសញ្ចាំងសេចក្ដីវិនាសឲ្យកើត ទោស:ជាកិ-
លេសញ្ចាំងចិត្តឲ្យកម្រើក ភ័យកើតហើយខាងក្នុង ជនរមែង
មិនយល់ច្បាស់នូវភ័យនោះទេ បុគ្គលអ្នកក្រោធ រមែងមិន
ដឹងអត្ថ បុគ្គលអ្នកក្រោធ រមែងមិនឃើញធម៌ សេចក្ដីក្រោធ
គ្របសង្កត់ជនណា សេចក្ដីងងឹតឈឹងសូន្យ (នៃជននោះ)
ក៏រមែងមានក្នុងកាលនោះ ។ មោហ: ជាកិលេសញ្ចាំងសេចក្ដី
វិនាសឲ្យកើត មោហ:ជាកិលេសញ្ចាំងចិត្តឲ្យកម្រើក ភ័យ
កើតហើយខាងក្នុង ជនរមែងមិនយល់ច្បាស់ នូវភ័យនោះ
ទេ បុគ្គលអ្នកវង្វេង រមែងមិនដឹងអត្ថ បុគ្គលអ្នកវង្វេង
រមែងមិនឃើញធម៌ មោហ:គ្របសង្កត់ជនណា សេចក្ដី
ងងឹតឈឹងសូន្យ (នៃជននោះ) ក៏រមែងមាន ក្នុងកាលនោះ ។
អន្តរាយ ព្រោះហេតុអាស្រ័យ ក្នុងសរីរ:នោះ យ៉ាងនេះខ្ទះ ។

ន័យមួយទៀត ពាក្យនេះ ព្រះមានព្រះភាគត្រាស់ថា បពិត្រ
មហារាជ បុរិសធម៌ (ធម៌របស់បុរស) ៣ កាលកើតឡើងក្នុង
សន្ដាន រមែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ ដើម្បីការ
នៅមិនសប្បាយ ។ បុរិសធម៌ ៣ តើដូចម្ដេច ។ បពិត្រមហារាជ
លោក: ជាបុរិសធម៌ កាលកើតឡើងក្នុងសន្ដាន រមែងកើតឡើង

អហិតាយ ទុក្ខាយ អជ្ឌាសុវិហារាយ ឧោសោ ខោ មហារាជ បុរិសស្ស ឆម្ហោ អជ្ឌត្តំ ឧប្ផជ្ជមានោ ឧប្ផ-ជ្ជតិ អហិតាយ ទុក្ខាយ អជ្ឌាសុវិហារាយ មោហោ ខោ មហារាជ បុរិសស្ស ឆម្ហោ អជ្ឌត្តំ ឧប្ផជ្ជមានោ ឧប្ផជ្ជ-តិ អហិតាយ ទុក្ខាយ អជ្ឌាសុវិហារាយ ។ ឥមេ ខោ មហារាជ តយោ បុរិសស្ស ឆម្ហា អជ្ឌត្តំ ឧប្ផជ្ជមានា ឧប្ផជ្ជន្តិ អហិតាយ ទុក្ខាយ អជ្ឌាសុវិហារាយាតិ ។

លោភោ ឧោសោ ច មោហោ ច បុរិសំ ចាបចេតសំ

ហឹសន្តិ អត្តសម្ភូតា តចសារំវ សម្ផលន្តិ ។

ឯវម្ឆិ តត្រាសយាតិ បរិស្ឆយោ ។

រុត្តំ ហោតំ ភតវតា

ឦតោ ច ឧោសោ ច ឥតោនិទានា

អរតី រតិ លោមហំសោ ឥតោ ជាតោ

ឥតោ សមុដ្ឋាយ មនោវិតក្កា

ឥមារកា ឆក្ខ្ម៉ាមិវ ស្ឆជ្ជន្តីតិ ។

ដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ ដើម្បីការនៅមិនសប្បាយ បពិត្រមហា-
រាជ ទោសៈ ជាបុរិសធម៌ កាលកើតឡើងក្នុងសន្ដាន រមែងកើតឡើង
ដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ ដើម្បីការនៅមិនសប្បាយ បពិត្រមហា-
រាជ មោហៈ ជាបុរិសធម៌ កាលកើតឡើងក្នុងសន្ដាន រមែងកើតឡើង
ដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ ដើម្បីការនៅមិនសប្បាយ ។ បពិត្រ
មហារាជ បុរិសធម៌ ៣ នេះឯង កាលកើតឡើងក្នុងសន្ដាន រមែងកើត
ឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីជាទុក្ខ ដើម្បីការនៅមិនសប្បាយ ។

លោភៈ ទោសៈ និងមោហៈ កើតអំពីខ្លួន រមែងបៀតបៀន
នូវបុរស អ្នកមានចិត្ដអាក្រក់ ដូចជាឈើមានសំបកជាខ្ទឹម
(ឫស្សី) ដែលវិនាសដោយសារផ្ទៃរបស់ខ្លួន ។

អន្ដរាយ ព្រោះហេតុអាស្រ័យ ក្នុងសរីរៈនោះ យ៉ាងនេះខ្លះ ។
មួយវិញទៀត ពាក្យនោះ ព្រះមានព្រះភាគត្រាស់ថា

ភគ:និងទោសៈ មានអត្ដភាពនេះជាហេតុ សេចក្ដីមិនត្រេក
អរ និងសេចក្ដីត្រេកអរ និងការព្រឺពោម កើតអំពីអត្ដភាព
នេះ មនោវិតក្ក:ទាំងឡាយតាំងឡើងហើយ អំពីអត្ដភាព
នេះ លៃងទៅ (នូវចិត្ដ) ដូចជាកុមារចងបន្ទាយនូវក្អែក ។

ឯវម្បិ តត្រាសយាតិ បរិស្សយា ។

មទ្ទន្តេ នំ បរិស្សយាតិ តេ បរិស្សយា តំ បុគ្គលំ សហន្តិ បរិសហន្តិ អភិភវន្តិ អជ្ឈោត្ថរន្តិ បរិយាទិយន្តិ មទ្ទន្តីតិ មទ្ទន្តេ នំ បរិស្សយា ។

[២៣] តតោ នំ ទុក្ខមន្វេតីតិ តតោ តតោ បរិស្សយតោ តំ បុគ្គលំ ទុក្ខំ អន្វេតិ អនុគច្ឆតិ អន្វាយិកំ ហោតិ ជាតិទុក្ខំ អន្វេតិ អនុគច្ឆតិ អន្វាយិកំ ហោតិ ជរាទុក្ខំ អន្វេតិ អនុគច្ឆតិ អន្វាយិកំ ហោតិ ព្យាធិទុក្ខំ អន្វេតិ អនុគច្ឆតិ អន្វាយិកំ ហោតិ មរណទុក្ខំ អន្វេតិ អនុគច្ឆតិ អន្វាយិកំ ហោតិ សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខំ អន្វេតិ អនុគច្ឆតិ អន្វាយិកំ ហោតិ នេរយិកទុក្ខំ តិរច្ឆានយោនិកទុក្ខំ បិត្តិវិសយិកទុក្ខំ អន្វេតិ អនុគច្ឆតិ អន្វាយិកំ ហោតិ មានុសិកទុក្ខំ គព្ភោក្កន្តិមូលកទុក្ខំ គព្ភេ ឋិតិមូលកទុក្ខំ គព្ភាវុដ្ឋានមូលកទុក្ខំ ជាតស្សុបនិពន្ធិកទុក្ខំ ជាតស្ស បរាធេយ្យកទុក្ខំ អត្តុបក្កមទុក្ខំ បរុបក្កមទុក្ខំ អន្វេតិ

អន្តរាយ ព្រោះហេតុអាស្រ័យ ក្នុងសរីរៈនោះ យ៉ាងនេះខ្ទះ ។

ពាក្យថា អន្តរាយទាំងឡាយ រមែងញ៉ាំញៀបុគ្គលនោះ បានសេចក្តីថា អន្តរាយទាំងឡាយនោះ រមែងទន្ទ្រាន ជិះជាន់ គ្របសង្កត់ រួបរឹតបំផ្ទាញ ញៀញក់នូវបុគ្គលនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) អន្តរាយទាំងឡាយ រមែងញ៉ាំញៀបុគ្គលនោះ ។

[២៣] *ពាក្យថា ទុក្ខ រមែងជាប់តាមបុគ្គលនោះ ព្រោះអន្តរាយនោះ អធិប្បាយថា ទុក្ខ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម នូវបុគ្គលនោះ ព្រោះសេចក្តីអន្តរាយនោះ ។ គឺជាតិទុក្ខ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ជរាទុក្ខ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ព្យាធិទុក្ខ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម មរណទុក្ខ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ទុក្ខក្នុងនរក ទុក្ខក្នុងកំណើតតិរច្ឆាន ទុក្ខក្នុងបិត្តិវិស័យ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ទុក្ខក្នុងពួកមនុស្សទុក្ខមានកិរិយាចុះកាន់គភ៌ជាមូល ទុក្ខមានកិរិយាតាំងនៅក្នុងគភ៌ជាមូល ទុក្ខមានកិរិយាចេញចាកគភ៌ជាមូល ទុក្ខប្រកបដោយគ្រឿងចង(ថែទាំ) របស់សត្វដែលកើតហើយ ទុក្ខព្រោះអាស្រ័យអ្នកដទៃរបស់សត្វដែលកើតហើយ ទុក្ខព្រោះការព្យាយាមរបស់ខ្លួន ទុក្ខព្រោះការព្យាយាមរបស់អ្នកដទៃ រមែងជាប់តាម*

បឋមោ កាមសុត្តនិទ្ទេសោ

អនុគច្ឆតិ អទ្ធាយិកំ ហោតិ ទុក្ខទុក្ខំ អន្វេតិ អនុគច្ឆតិ អទ្ធាយិកំ ហោតិ សង្ខារទុក្ខំ វិបរិណាមទុក្ខំ ចក្ខុរោគោ សោតរោគោ ឃានរោគោ ជិវ្ហារោគោ កាយរោគោ សីសរោគោ កណ្ណរោគោ មុខរោគោ ទន្តរោគោ កាសោ សាសោ បិនាសោ ឌហោ ជរោ កុច្ឆិរោគោ មុច្ឆា បក្ខន្ទិកា សុលា វិសូចិកា កុដ្ឋំ គណ្ឌោ កិលាសោ សោសោ អបមារោ ទទ្ទុ កណ្ឌុ កច្ឆុ រខសា វិតច្ឆិកា លោហិតំ បិត្តំ មធុមេហោ អំសា បិឡកា ភគន្ទលា បិត្តសមុដ្ឋានា អាពាធា សេម្ហសមុដ្ឋានា អាពាធា វាតសមុដ្ឋានា អាពាធា សន្និបាតិកា អាពាធា ឧតុបរិណាមជា អាពាធា វិសមបរិហារជា អាពាធា ឱបក្កមិកា អាពាធា កម្មវិបាកជា អាពាធា សីតំ ឧណ្ហំ ជិឃច្ឆា បិបាសា ឧច្ចារោ បស្សាវោ ឌំសមកសវាតាតបសិរឹសបសម្ផស្សទុក្ខំ មាតុមរណទុក្ខំ បិតុមរណទុក្ខំ ភាតុមរណទុក្ខំ ភគិនីមរណទុក្ខំ បុត្តមរណទុក្ខំ ធីតុមរណទុក្ខំ ញាតិព្យសនទុក្ខំ ភោគព្យសនទុក្ខំ រោគព្យសនទុក្ខំ សីលព្យសនទុក្ខំ ទិដ្ឋិព្យសនទុក្ខំ

ទៅតាម ប្រព្រឹត្តតាម ទុក្ខទុក្ខ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម សង្ខារទុក្ខ វិបរិណាមទុក្ខ ពោគក្នុងភ្នែក ពោគក្នុងត្រចៀក ពោគក្នុងច្រមុះ ពោគក្នុងអណ្ដាត ពោគក្នុងកាយ ពោគក្នុងក្បាល ពោគត្រង់ស្វឹកត្រចៀក ពោគក្នុងមាត់ ពោគត្រង់ធ្មេញ ពោគក្អក ពោគហឺត ពោគក្រៅច្រមុះ ពោគគ្រុនក្តៅក្រហាយ ពោគរីងរៃ ពោគក្នុងពោះ ខ្យល់ចាប់ ពោគធ្លាក់ឈាម ចុកសៀត ចុះពាក ឃ្ងង់ ពោគពក ស្រែង ស្រកីអណ្ដែង ធ្ពត់ជ្រូក ដំណួចពិស រមាស់ កម ពោគអេះក្ងាយ ឃ្ងង់ដៃក មួលឈាម ពោគប្រមាត់ ប្រមេះទឹក បាយ ឫសដូងដុះ ក្អកឈាម ឫសដូងបាត អាពាធកើតអំពីប្រមាត់ អាពាធកើតអំពីស្លេស្ម អាពាធកើតអំពីខ្យល់ អាពាធកើតអំពីប្រជុំ (នៃខ្យល់ប្រ-មាត់ស្លេស្ម) អាពាធកើតអំពីការផ្ទាស់ប្តូររដូវ អាពាធកើតអំពីរក្សាឥរិយា-បថមិនស្មើគ្នា អាពាធកើតអំពីសេចក្តីព្យាយាមខ្លាំង អាពាធកើតអំពីផលកម្ម ត្រជាក់ ក្តៅ ឃ្លាន ស្រេក ឧច្ចារៈ បស្សាវៈ សម្ផស្សនៃរបោមមូស ខ្យល់ កម្តៅថ្ងៃ និងពស់តូចពស់ធំ ទុក្ខព្រោះកិរិយាស្ងាប់នៃមាតា ទុក្ខព្រោះកិរិយាស្ងាប់នៃបិតា ទុក្ខព្រោះកិរិយាស្ងាប់នៃបងប្អូនប្រុស ទុក្ខព្រោះកិរិយាស្ងាប់នៃបងប្អូនស្រី ទុក្ខព្រោះកិរិយាស្ងាប់នៃកូនប្រុស ទុក្ខព្រោះកិរិយាស្ងាប់កូនស្រី ទុក្ខព្រោះវិនាសញាតិ ទុក្ខព្រោះវិនាសភោគសម្បត្តិ ទុក្ខព្រោះវិនាសគឺរោគ ទុក្ខព្រោះវិនាសសីល ទុក្ខព្រោះវិនាសគឺទិដ្ឋិ

អន្ធេតិ អនុកច្ឆតិ អន្ធាយិកំ ហោតីតិ តតោ ជំ ពុក្ខ-
មន្ធេតិ ។

[២៤] ជាវ កិន្ធមិវោឧកន្តិ យថា កិន្ធ ជាវ ឧឧកំ
អន្ធាយិកំ[១] តតោ តតោ ឧឧកំ អន្ធេតិ អនុកច្ឆតិ
អន្ធាយិកំ ហោតិ បុរតោបិ ឧឧកំ អន្ធេតិ អនុកច្ឆតិ
អន្ធាយិកំ ហោតិ បច្ឆតោបិ ហេដ្ឋតោបិ បស្សតោបិ
ឧឧកំ អន្ធេតិ អនុកច្ឆតិ អន្ធាយិកំ ហោតិ ឯវមេវ
តតោ តតោ បរិស្សយតោ តំ បុគ្គលំ ពុក្ខ អន្ធេតិ
អនុកច្ឆតិ អន្ធាយិកំ ហោតិ ជាតិពុក្ខ អន្ធេតិ អនុកច្ឆតិ
អន្ធាយិកំ ហោតិ ។ បេ ។ ឧិដ្ឋិព្យសនពុក្ខ អន្ធេតិ
អនុកច្ឆតិ អន្ធាយិកំ ហោតីតិ ជាវ កិន្ធមិវោឧកំ ។
ឧេជាមា ភគវា

អពលា ជំ ពលីយន្តិ មន្ធេ ជំបរិស្សយា
តតោ ជំ ពុក្ខមន្ធេតិ ជាវ កិន្ធមិវោឧកន្តិ ។

---

១ ឱ. ឧទកំ អន្ធាយិកន្តិ ន ទិស្សតិ ។

រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម (នូវបុគ្គលនោះ) ហេតុនោះ (ទ្រង់ត្រាស់ថា) ទុក្ខរមែងជាប់តាមបុគ្គលនោះ ព្រោះអន្តរាយនោះ ។

[២៤] ពាក្យថា ដូចជាទឹកកាលជ្រាបចូល កាន់នាវាដែលបែកធ្លាយ សេចក្តីថា ទឹកប្រព្រឹត្តតាមទូក ដែលបែកធ្លាយ គឺទឹករមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ត្រង់ទីដែលធ្លាយនោះ ។ ទឹករមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ត្រង់ទីខាងមុខខ្ទះ ទឹករមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ត្រង់ទីខាងក្រោយខ្ទះ ត្រង់ទីខាងក្រោមខ្ទះ ត្រង់ទីខាងខ្ទះ យ៉ាងណាមិញ សេចក្តីទុក្ខរមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម នូវបុគ្គលនោះ ព្រោះសេចក្តីអន្តរាយនោះ ។ ជាតិទុក្ខ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ។ បេ ។ ទុក្ខព្រោះកិរិយាវិនាសគឺទិដ្ឋិ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ក៏យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) ដូចជាទឹកកាលជ្រាបចូល កាន់នាវាដែលបែកធ្លាយ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា

កិលេសមិនមានកម្ចាំងទាំងឡាយ រមែងសង្កត់សង្កិនបុគ្គលនោះ អន្តរាយទាំងឡាយ រមែងញាំញីបុគ្គលនោះ ទុក្ខរមែងជាប់តាមបុគ្គលនោះ ព្រោះអន្តរាយនោះ ដូចជាទឹកកាលជ្រាបចូល កាន់នាវាដែលបែកធ្លាយ ។

[២៥] តស្មា ជន្តុ សទា សតោ កាមានិ បរិវជ្ជយេ
តេ បហាយ តរេ ឱឃំ នាវំ សិត្វាវ បារគូ ។

[២៦] តស្មា ជន្តុ សទា សតោតិ តស្មាតិ តស្មា តំការណា តំហេតុ តប្បច្ចយា តំនិទានា(១) ឯតំ អាទីនវំ សម្បស្សមានោ កាមេសូតិ តស្មា ។ ជន្តូតិ សត្តោ នរោ មាណវោ បោសោ បុគ្គលោ ជីវោ ជាតុ ជន្តុ ឥន្ទគូ មនុជោ ។ សទាតិ សទា សព្វទា សព្វកាលំ និច្ចកាលំ ធុវកាលំ សតតំ សមិតំ អព្វោកិណ្ណំ បោខានុបោខំ(២) ឧទកុម្មិកជាតំ អវីចិ សន្តតិ សហិតំ ផុសិតំ បុរេភត្តំ បច្ឆាភត្តំ បុរិមយាមំ មជ្ឈិមយាមំ បច្ឆិមយាមំ កាឡេ ជុណ្ហេ វស្សេ ហេមន្តេ គិម្ហេ បុរិមេ វយោខន្ធេ មជ្ឈិមេ វយោខន្ធេ បច្ឆិមេ វយោខន្ធេ ។ សតោតិ ចតូហិ ការណេហិ សតោ កាយេ កាយានុបស្សនាសតិប្បដ្ឋានំ ភាវេន្តោ សតោ

១ តំនិទានន្តិបិ បាឋោ ។ ២ ម. បោង្ខានុបោង្ខំ ។

[២៥] ព្រោះហេតុនោះ ជនអ្នកមានស្មារតី គ្រប់កាល គប្បីរៀរស្រឡះនូវកាមទាំងឡាយ ជនលុះលះបង់កាមទាំងនោះ ទើបធ្វើងឱ្យ:បាន ដូចបុគ្គលអ្នកដល់ត្រើយ ព្រោះស្ពានវា ។

[២៦] អធិប្បាយពាក្យថា ព្រោះហេតុនោះ ជនអ្នកមានស្មារតី គ្រប់កាល ត្រង់ពាក្យថា ព្រោះហេតុនោះ គឺព្រោះហេតុដូច្នោះ ព្រោះដំណើរនោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះអំពើនោះជាហេតុ ជនកាលឃើញច្បាស់នូវទោសនុ៎ះ ក្នុងកាមទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុនោះ ។ ពាក្យថា ជន គឺ សត្វ នរ: មាណព បុរស បុគ្គល សត្វមានជីវិត សត្វមានជាតិ សត្វមានជរា សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ។ ពាក្យថា គ្រប់កាល គឺសព្វកាល រាល់វេលា អស់កាលទាំងពួង អស់កាលជានិច្ច អស់កាលដ៏ទៀងទាត់ បិតថេរ រឿយ ៗ ប៉ុកប៊ីន ញ៊ីកញ្ជាប់ មានសភាពដូចជារលកទឹក មិនដាច់ ជាប់ត ប្រព្រឹត្តទៅជាមួយគ្នា ប៉ះជាប់គ្នា កាលមុនកត្ត កាលក្រោយកត្ត យាមខាងដើម យាមកណ្ដាល យាមទីបំផុត ក្នុងកាលរនោច ខ្នើត រដូវ ហេមន្តរដូវ គិម្ហរដូវ គំនរវ័យខាងដើម គំនរវ័យកណ្ដាល គំនរវ័យទីបំផុត ។ ពាក្យថា មានសតិ គឺមានសតិ ដោយហេតុ ៤ យ៉ាង គឺមានសតិ កាលចម្រើនកាយានុបស្សនាសតិប្បដ្ឋាន ក្នុងកាយ ក្នុងវេទនាទាំងឡាយ

វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សនាសតិប្បដ្ឋានំ ភាវេន្តោ សតោ ។ អបរេហិបិ ចតូហិ ការណេហិ សតោ ។ បេ ។ សោ វុច្ចតិ សតោតិ តស្មា ជន្តុ សធ សតោ ។

[២៧] កាមានិ បរិវជ្ជយេតិ កាមានីតិ ឧទ្ធានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។ បេ ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។ បេ ។ ឥមេ វុច្ចន្តិ កិលេស-កាមា ។ កាមានិ បរិវជ្ជយេតិ ទ្វីហិ ការណេហិ កាមេ បរិវជ្ជេយ្យ វិក្ខម្ភនតោ វា សមុច្ឆេទតោ វា ។ កថំ វិក្ខម្ភនតោ កាមេ បរិវជ្ជេយ្យ ។ អដ្ឋិកង្កលូបមា កាមា អប្ប្ស្សាទដ្ឋេនាតិ បស្សន្តោ វិក្ខម្ភនតោ កាមេ បរិ-វជ្ជេយ្យ មំសបេសូបមា កាមា ពហុសាធារណដ្ឋេនាតិ បស្សន្តោ វិក្ខម្ភនតោ កាមេ បរិវជ្ជេយ្យ តិណុក្កូបមា កាមា អនុទហនដ្ឋេនាតិ បស្សន្តោ វិក្ខម្ភនតោ កាមេ បរិវជ្ជេយ្យ ។ បេ ។ ឧវសញ្ញានាសញ្ញាយតនសមា-បត្តឺ ភាវេន្តោបិ វិក្ខម្ភនតោ កាមេ បរិវជ្ជេយ្យ ។

ក្នុងចិត្ត មានសតិ កាលចម្រើនធម្មានុបស្សនាសតិប្បដ្ឋាន ក្នុងធម៌ទាំង-ឡាយ ។ មានសតិ ដោយហេតុ ៤ យ៉ាងដទៃទៀត ។ បេ ។ បុគ្គលនោះ លោកហៅថា អ្នកមានសតិ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុនោះ ជនអ្នកមានស្មារតី គ្រប់កាល ។

[២៧] អធិប្បាយពាក្យថា គប្បីវៀរស្រឡះ នូវកាមទាំងឡាយ ត្រង់ពាក្យថា កាម បើតាមឧទ្ទាន បានដល់កាម ២ យ៉ាង គឺវត្ថុកាម ១ កិលេសកាម ១ ។ បេ ។ ទាំងនេះ ហៅថា វត្ថុកាម ។ បេ ។ ទាំងនេះ ហៅថា កិលេសកាម ។ ពាក្យថា គប្បីវៀរស្រឡះនូវកាមទាំងឡាយ គឺគប្បីវៀរនូវកាម ដោយហេតុ ២ យ៉ាង គឺកិរិយាសង្កត់សង្កិន ១ កិរិយាផ្តាច់បង់ ១ ។ បុគ្គលវៀរកាម ដោយកិរិយាសង្កត់សង្កិន តើដូចម្តេច ។ បុគ្គលកាលឃើញថា កាមទាំងឡាយ មានឧបមាដូចរាងធ្នើ ដោយសេចក្តីថាមានសេចក្តីត្រេកអរតិច ឈ្មោះថា វៀរកាមដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយមានឧបមាដោយដុំសាច់ ដោយសេចក្តីថាជារបស់សាធារណ៍ ដល់សត្វមានប្រមាណច្រើន ឈ្មោះថាវៀរកាម ដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយ មានឧបមាដូចគប់ភ្លើងស្មៅ ដោយសេចក្តីថាដុតកម្តៅរឿយ ៗ ឈ្មោះថា វៀរកាម ដោយកិរិយាសង្កត់សង្កិន ។ បេ ។ កំពុងចម្រើននេវសញ្ញានា-សញ្ញាយតនសមាបត្តិក្តី ឈ្មោះថាវៀរកាម ដោយកិរិយាសង្កត់សង្កិន ។

ឯវํ វិក្ខម្ភនតោ កាមេ បរិវជ្ជេយ្យ ។ បេ ។ ឯវํ សមុ-ច្ឆេទតោ កាមេ បរិវជ្ជេយ្យាតិ កាមានិ បរិវជ្ជយេ ។

[២៨] តេ បហាយ តរេ ឱឃន្តិ តេតិ វត្ថុកាមេ បរិជានិត្វា កិលេសកាមេ បហាយ បជហិត្វា វិនោ-ទិត្វា ព្យន្តីការិត្វា អនភាវង្គមិត្វា កាមច្ឆន្ទនីវរណំ ប-ហាយ បជហិត្វា វិនោទិត្វា ព្យន្តីការិត្វា អនភាវង្គ-មិត្វា ព្យាបាទនីវរណំ ថីនមិទ្ធនីវរណំ ឧទ្ធច្ចកុក្កុច្ច-នីវរណំ វិចិកិច្ឆានីវរណំ បហាយ បជហិត្វា វិនោទិត្វា ព្យន្តីការិត្វា អនភាវង្គមិត្វា កាមោឃំ ភវោឃំ ទិដ្ឋោឃំ អវិជ្ជោឃំ តរេយ្យ ឧត្តរេយ្យ បតរេយ្យ សមតិក្ក-មេយ្យ វីតិវត្តេយ្យាតិ តេ បហាយ តរេ ឱឃំ ។

[២៩] ជាវํ សិត្វាវ ចារកូតិ យថា ករុកំ ជាវํ ភារិកំ ឧទកំ សញ្ជិត្វា ឱសិញ្ចិត្វា ឆឌ្ឌេត្វា លហុកាយ ជាវាយ ទិប្ប៎ លហុំ អប្ប៎ កសិរេនេវ ចារํ ឥច្ឆេយ្យ ឯវមេវ វត្ថុកាមេ បរិជានិត្វា កិលេសកាមេ បហា-យ បជហិត្វា វិនោទិត្វា ព្យន្តីការិត្វា អនភាវង្គមិត្វា

បុគ្គលវៀរកាម ដោយកិរិយាសង្កត់សង្កិន ដោយប្រការយ៉ាងនេះ ។ បេ ។ បុគ្គលវៀរកាម ដោយកិរិយាផ្តាច់បង់ ដោយប្រការយ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីវៀរស្រឡះ នូវកាមទាំងឡាយ ។

[២៨] *ពាក្យថា កាមទាំងនោះ ក្នុងបទថា ជនលុះលះបង់កាមទាំង-នោះ ទើបធ្វើងឱ្យ:បាន គឺជនកំណត់ដឹងនូវវត្ថុកាមទាំងឡាយ លះបង់ កម្ចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវកិលេសកាមទាំងឡាយ លះបង់ កម្ចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវកាមច្ឆន្ទនីវរណៈ លះបង់ កម្ចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចកុក្កុច្ចនីវរណៈ វិចិកិច្ឆានីវរណៈ គប្បីធ្វើង គប្បីធ្វើងឡើង គប្បីធ្វើងកាត់ ឈានកន្ទងប្រព្រឹត្តកន្ទងនូវឱ្យ:គឺកាម ឱ្យ:គឺកព ឱ្យ:គឺទិដ្ឋិ ឱ្យ:គឺអវិជ្ជា ហេតុនោះ (ទ្រង់ត្រាស់ថា) ជនលុះលះបង់កាមទាំងនោះ ទើបធ្វើងឱ្យ:បាន ។*

[២៩] *ពាក្យថា ដូចបុគ្គលអ្នកដល់ត្រើយ ព្រោះស្ពានវារ អធិប្បាយថា បុគ្គល បាច ស្ពារ ជះចោលនូវទឹកក្នុងនាវា មានគ្រឿងផ្ទុកដ៏ធ្ងន់ ហើយដល់ត្រើយធាប់រហ័ស មិនលំបាក ដោយសារនាវាស្រាលយ៉ាងណាមិញ បុគ្គលកំណត់ដឹងនូវវត្ថុកាមទាំងឡាយ លះបង់ កម្ចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវកិលេសកាមទាំងឡាយ*

កាមច្ឆន្ទនីវរណំ ព្យាបាទនីវរណំ ថីនមិទ្ធនីវរណំ ឧទ្ធច្ចកុក្កុច្ចនីវរណំ វិចិកិច្ឆានីវរណំ បហាយ ឋ-ហិត្វា វិនោទិត្វា ព្យន្តីការិត្វា អនភាវង្គមិត្វា ទ្វិប្បំ លហុំ អប្ឍកសិរេនេវ ចារំ តច្ឆេយ្យ ។ ចារំ រុច្ចតិ អមតំ និព្ឆានំ យោ សោ សព្ឆសង្ខារសមថো សព្ឆុបធិប្ឍដិនិ-ស្ឍគ្គো តណ្ហាក្ខយো វិរាគো និរោធោ និព្ឆានំ ចារំ តច្ឆេយ្យ ចារំ អធិតច្ឆេយ្យ ចារំ ផុសេយ្យ ចារំ សច្ឆិ-ការេយ្យ ។ ចារកូតិ យោបិ ចារំ តន្ត្ដុកាមោ សោបិ ចារកូ យោបិ ចារំ តច្ឆតិ សោបិ ចារកូ យោបិ ចារំ តតោ សោបិ ចារកូ ។ រុត្ដំ ហេតំ ភគ្ឍវតា តិណ្ណោ ចារតតោ ឋលេ តិដ្ឆតិ ព្រាហ្មណោតិ ។ ព្រាហ្មណោតិ ខោ ភិក្ខវេ អរហតោ ឯតំ អធិ-ឝ្ឍនំ សោ អភិញ្ញាចារកូ បរិញ្ញាចារកូ បហានចារកូ ភាវនាចារកូ សច្ឆិកិរិយាចារកូ សមាបត្ដិចារកូ អភិញ្ញា-ចារកូ សព្ឆធម្មានំ បរិញ្ញាចារកូ សព្ឆឧក្ខានំ បហាន-

លះបង់ កម្ចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវកាមច្ឆន្ទ-នីវរណៈ ព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចកុក្កុច្ចនីវរណៈ វិចិកិច្ឆា-នីវរណៈ ហើយដល់ត្រើយធាប់រហ័ស ដោយមិនលំបាក ក៏យ៉ាងនោះដែរ ។ អមតនិព្វាន ការរម្ងាប់សង្ខារទាំងពួង កិរិយាលះបង់កិលេសទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ (នៃកិលេស) ការចេញចាកតណ្ហា លោកពោលថា ត្រើយ បុគ្គលគប្បីដល់ត្រើយ បានត្រើយ ប៉ះពាល់ត្រើយ ធ្វើឲ្យជាក់ច្បាស់នូវត្រើយនោះ ។ ពាក្យថា បុគ្គលអ្នកដល់ត្រើយ គឺបុគ្គលណា ប្រាថ្នាដើម្បីទៅកាន់ត្រើយ បុគ្គលនោះ ឈ្មោះថា អ្នកទៅកាន់ត្រើយ បុគ្គលណា កំពុងទៅកាន់ត្រើយ បុគ្គលនោះ ឈ្មោះថាអ្នកទៅកាន់ត្រើយ បុគ្គលណាដល់ហើយ នូវត្រើយ បុគ្គលនោះ ឈ្មោះថា អ្នកទៅកាន់ត្រើយ ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ព្រាហ្មណ៍ឆ្ងងដល់ត្រើយ ឋិតនៅលើគោក ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រាហ្មណ៍ នេះជាឈ្មោះនៃព្រះអរហន្ត ព្រះអរហន្តនោះ ឈ្មោះថា អ្នកដល់ត្រើយដោយការត្រាស់ដឹង អ្នកដល់ត្រើយដោយការកំណត់ដឹង អ្នកដល់ត្រើយដោយការលះបង់ អ្នកដល់ត្រើយដោយការចម្រើន អ្នកដល់ត្រើយ ដោយការធ្វើឲ្យជាក់ច្បាស់ អ្នកដល់ត្រើយដោយសមាបត្តិ អ្នកដល់ត្រើយ ដោយការត្រាស់ដឹងធម៌ទាំងពួង អ្នកដល់ត្រើយដោយការ

ចារក្ខ សព្វក្កិលេសានំ ការជាចារក្ខ ចតុន្នំ អរិយ-
មគ្គានំ សច្ចិកិរិយាចារក្ខ និរោធស្ស សមាបត្តិចារក្ខ
សព្វសមាបត្តីនំ សោ វសិប្បត្តោ ចារមិប្បត្តោ អរិយស្មឹ
សីលស្មឹ វសិប្បត្តោ ចារមិប្បត្តោ អរិយស្មឹ សមាធិស្មឹ
វសិប្បត្តោ ចារមិប្បត្តោ អរិយាយ បញ្ញាយ វសិប្បត្តោ
ចារមិប្បត្តោ អរិយាយ វិមុត្តិយា សោ ចារគតោ ចារប្ប-
ត្តោ អន្តគតោ អន្តប្បត្តោ កោដិគតោ កោដិប្បត្តោ
បរិយន្តគតោ បរិយន្តប្បត្តោ វោសានគតោ វោសាន-
ប្បត្តោ តាណគតោ តាណប្បត្តោ លេណគតោ លេណ-
ប្បត្តោ សរណគតោ សរណប្បត្តោ អភយគតោ អភយ-
ប្បត្តោ អច្ចុតគតោ អច្ចុតប្បត្តោ អមតគតោ អមតប្ប-
ត្តោ និព្វានគតោ និព្វានប្បត្តោ សោ វុដ្ឋវាសោ ចិណ្ណច-
រណោ គតទ្ធោ គតទិសោ គតកោដិកោ ចាលិតព្រហ្ម-
ចរិយោ ឧត្តមទិដ្ឋិប្បត្តោ ភាវិតមគ្គោ បហីនក្កិលេសោ

កំណត់ដឹងទុក្ខទាំងពួង អ្នកដល់ត្រើយ ដោយការលះបង់កិលេសទាំង-ពួង អ្នកដល់ត្រើយ ដោយការចម្រើនអរិយមគ្គទាំង ៨ អ្នកដល់ត្រើយ ដោយការធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច: អ្នកដល់ត្រើយ ដោយការចូលទៅកាន់សមាបត្តិទាំងពួង ព្រះអរហន្តនោះដល់នូវភាពដ៏ស្អាត់ ដល់នូវឧត្តមភាពក្នុងសីលដ៏ប្រសើរ ដល់នូវភាពដ៏ស្អាត់ ដល់នូវឧត្តមភាពក្នុងសមាធិដ៏ប្រសើរ ដល់នូវភាពដ៏ស្អាត់ ដល់នូវឧត្តមភាព ក្នុងបញ្ញាដ៏ប្រសើរ ដល់នូវភាពដ៏ស្អាត់ ដល់នូវឧត្តមភាព ដោយវិមុត្តិដ៏ប្រសើរ ព្រះអរហន្តនោះ ឈ្មោះថា ទៅកាន់ត្រើយ ដល់ត្រើយ ទៅកាន់ទីបំផុត (នៃសង្ខារ) ដល់ទីបំផុត ទៅកាន់ទីខាងចុង ដល់ទីខាងចុង ទៅកាន់ទីបំផុតជុំវិញ ដល់ទីបំផុតជុំវិញ ទៅកាន់ទីអវសាន ដល់ទីអវសាន ទៅកាន់ទីពំនាក់ ដល់ទីពំនាក់ ទៅកាន់ទីពឹងពួន ដល់ទីពឹងពួន ទៅកាន់ទីជាទីពឹង ដល់ទីជាទីពឹង ទៅកាន់ទីមិនមានភ័យ ដល់ទីមិនមានភ័យ ទៅកាន់ទីមិនច្យុត ដល់ទីមិនច្យុត ទៅកាន់ទីមិនស្ងាប់ ដល់ទីមិនស្ងាប់ ទៅកាន់និព្វាន ដល់និព្វាន ព្រះអរហន្តនោះ មានធម៌ជាគ្រឿងអប់រំនៅស្រេចហើយ មានកិរិយាប្រព្រឹត្ត ប្រព្រឹត្តហើយ មានផ្លូវធ្វាយគឺសង្សារកន្ទ្ធងហើយ មានទិសគឺព្រះនិព្វានដល់ហើយ មានទីបំផុតនៃព្រះនិព្វានដល់ហើយ មានព្រហ្មចរិយធម៌រក្សាហើយ ដល់ហើយនូវការឃើញដ៏ឧត្តម មានមគ្គចម្រើនហើយ មានកិលេសលះបង់ហើយ មាន

បដិវិទ្ធាកុប្បោ សច្ឆិកតនិរោធោ ទុក្ខំ តស្ស បរិញ្ញាតំ សមុទយោ បហីនោ មគ្គោ ភាវិតោ និរោធោ សច្ឆិកតោ អភិញ្ញេយ្យំ អភិញ្ញាតំ បរិញ្ញេយ្យំ បរិញ្ញាតំ បហាតព្វំ បហីនំ ភាវេតព្វំ ភាវិតំ សច្ឆិកាតព្វំ សច្ឆិកតំ សោ ឧក្ខិត្តបលិឃោ សង្កិណ្ណបរិក្ខោ អព្វូឡ្ហេសិកោ និរគ្គឡោ អរិយោ បន្នទ្ធជោ បន្នភារោ វិសញ្ញុត្តោ បញ្ចង្គវិប្បហីនោ ឆឡង្គសមន្នាគតោ ឯការក្ខោ ចតុរាបស្សេនោ បនុណ្ណបច្ចេកសច្ចោ សមវយសដ្ឋេសនោ អនាវិលសង្កប្បោ បស្សទ្ធកាយសង្ខារោ សុវិមុត្តចិត្តោ សុវិមុត្តប្បញ្ញោ កេវលី វុសិតវា ឧត្តមបុរិសោ បរមបុរិសោ

អរហត្តផលជាធម្មជាតមិនកម្រើកត្រាស់ដឹងហើយ មាននិពោធគឺព្រះនិព្វាន ធ្វើឲ្យជាក់ច្បាស់ហើយ ទុក្ខព្រះអរហន្តនោះកំណត់ដឹងហើយ សមុទយៈ លះបង់ហើយ មគ្គចម្រើនហើយ និពោធធម៌បានធ្វើឲ្យជាក់ច្បាស់ហើយ ត្រាស់ដឹងហើយនូវហេតុដែលគួរត្រាស់ដឹង កំណត់ដឹងហើយនូវហេតុដែលគួរកំណត់ដឹង លះបង់ហើយនូវហេតុដែលគួរលះបង់ ចម្រើនហើយនូវហេតុដែលគួរចម្រើន ធ្វើឲ្យជាក់ច្បាស់ហើយនូវហេតុដែលគួរធ្វើឲ្យជាក់ច្បាស់ ។ ព្រះអរហន្តនោះ មានសសរគោល គឺអវិជ្ជាដកចេញហើយ មានស្នាមភ្ជុះគឺជាតិសង្សារលុបអស់ហើយ មានសសរខឿនគឺតណ្ហាដកចេញហើយ មិនមានគន្ធីះទ្វារ គឺឱរម្ភាគិយសំយោជន៍ ជាអរិយៈ មិនមានកិលេស មានទង់គឺមានះទម្ងាក់ហើយ មានគ្រឿងធ្ងន់[1]ទម្ងាក់ចេញហើយ ជាអ្នកប្រាសចាកកិលេស លះបង់អង្គ៥គឺនីវរណៈហើយ ប្រកបព្រមហើយដោយអង្គប្រាំមួយ[2] មានការរក្សាដោយធម៌តែមួយគឺសតិ មានធម៌ជាគ្រឿងពឹងផ្អែក៤ប្រការ មានទិដ្ឋិសច្ចដោយឡែកលះបង់ហើយ មានការស្វែងរកទាំងពួងលះបង់ហើយដោយប្រពៃ មានសេចក្ដីត្រិះរិះមិនមានល្អក់ មានកាយសង្ខារស្ងប់រម្ងាប់ហើយ មានចិត្តផុតស្រឡះហើយដោយប្រពៃ មានបញ្ញាផុតស្រឡះហើយដោយប្រពៃ ជាបុគ្គលបរិបូណ៌ មានព្រហ្មចរិយធម៌ប្រព្រឹត្តចប់ស្រេចហើយ ជាឧត្តមបុរស ជាបរមបុរស

---

១ ខន្ធភារៈ កិលេសភារៈ អភិសង្ខារភារៈ បញ្ចកាមគុណភារៈ មានភារៈ ។ ២ ភិក្ខុ មានសតិសម្បជញ្ញៈ ដោយអំណាចឧបេក្ខា កម្ចាត់បង់នូវសេចក្ដីថ្នាំងថ្នាក់ ឬ សោមនស្សក្នុងអារម្មណ៍ទាំង ៦ មានរូបារម្មណ៍ជាដើម ។ អដ្ឋកថា ។

ឋានប្បត្តិប្បត្តោ សោ នេវ អាចិនាតិ ន អបចិនាតិ អប-
ចិនិត្វា ឋិតោ នេវ ជហាតិ ន ឧចាឌិយតិ ជហិត្វា
ឋិតោ នេវ វិសិនេតិ ន ឧស្សិនេតិ វិសិនេត្វា ឋិតោ
នេវ វិធុនេតិ ន សន្ធុនេតិ វិធុនេត្វា ឋិតោ អសេក្ខ-
ន សីលក្ខន្ធេន សមន្នាគតត្តា ឋិតោ អសេក្ខេន
សមាធិក្ខន្ធេន អសេក្ខេន បញ្ញាខន្ធេន អសេក្ខេន
វិមុត្តិក្ខន្ធេន អសេក្ខេន វិមុត្តិញ្ញាណទស្សនក្ខន្ធេន
សមន្នាគតត្តា ឋិតោ សចំ ឋដិចាឌយិត្វា ឋិតោ ឯវं
សមតិក្កមិត្វា ឋិតោ កិលេសក្ខ្លឹ ឋរិយាឌយិត្វា ឋិតោ
អឋរិតមនតាយ ឋិតោ ឆ្ងាំ សមាធាយ ឋិតោ ឋុត្តិ-
ឋ្ឋដិសេវនតាយ ឋិតោ ឋេត្តាយ ចារិសុទ្ធិយា ឋិតោ
ការុណាយ ឋុឌិតាយ ឧបេក្ខាយ ចារិសុទ្ធិយា ឋិតោ
អចូន្ត្ចារិសុទ្ធិយា ឋិតោ អកម្ម្ញ្ញតាយ ចារិសុទ្ធិយា
ឋិតោ វិមុត្ត្ត្ត្ត ឋិតោ សន្ត្ត្ត ឋិតោ ខន្ធ្ឋ្ឋ ឋ្ឋ
ឋិតោ ជ្ជ ឋ្ឋ ឋ្ឋ ឋិតោ ឋ្ឋ ឋ្ឋ ឋ្ឋ ឋិតោ

ដល់នូវការដល់ដ៏ប្រសើរ ព្រះអរហន្តនោះ មិនសន្សំ មិនកម្ចាត់បង់ លោកនឹងធឹងព្រោះកម្ចាត់បង់ មិនលះបង់ មិនប្រកាន់ លោកនឹងធឹងព្រោះលះបង់ មិនចាក់ស្រេះ មិនតម្កើង (ដោយតណ្ហា និងមាន:) លោកនឹងធឹង ព្រោះមិនចាក់ស្រេះ មិនរំលត់ មិនបង្ក្នាត់ (នូវក្លើងគឺកិលេស) លោកនឹងធឹង ព្រោះរំលត់ លោកខ្ជាប់ខ្ជួន ព្រោះប្រកបដោយសីលក្ខន្ធជាអសេក្ខ: លោកខ្ជាប់ខ្ជួន ព្រោះប្រកបដោយសមាធិ-ក្ខន្ធជាអសេក្ខ: ដោយបញ្ញាខន្ធជាអសេក្ខ: ដោយវិមុត្តិក្ខន្ធជាអសេក្ខ: ដោយវិមុត្តិញ្ញាណទស្សនក្ខន្ធជាអសេក្ខ: លោកខ្ជាប់ខ្ជួន ព្រោះយល់ច្បាស់នូវសច្ចធម៌ លោកខ្ជាប់ខ្ជួន ព្រោះកន្ទ:ផុតយ៉ាងនេះ លោកខ្ជាប់ខ្ជួន ព្រោះរំលត់ក្លើងគឺកិលេស លោកខ្ជាប់ខ្ជួន ព្រោះមិនមានដំណើរតទៅទៀត លោកខ្ជាប់ខ្ជួន ព្រោះចាប់បាននូវកំពូល (ជ័យជម្នះ) លោកខ្ជាប់ខ្ជួន ព្រោះកិរិយាសេពនូវធម៌ជាគ្រឿងផុតស្រឡះ លោកខ្ជាប់ខ្ជួន ព្រោះមេត្តាជាគុណជាតិដ៏បរិសុទ្ធ លោកខ្ជាប់ខ្ជួន ព្រោះករុណា មុទិតា ឧបេក្ខា ជាគុណជាតិដ៏បរិសុទ្ធ លោកខ្ជាប់ខ្ជួន ព្រោះដល់ទីបំផុតនៃសេចក្តីបរិសុទ្ធ លោកខ្ជាប់ខ្ជួន ព្រោះសេចក្តីបរិសុទ្ធ មិនគួរដល់ការងារ (នៃតណ្ហាទិដ្ឋិមាន:) លោកខ្ជាប់ខ្ជួន ព្រោះផុតស្រឡះ លោកខ្ជាប់ខ្ជួន ព្រោះជាបុគ្គលសន្ដោស លោកខ្ជាប់ខ្ជួនក្នុងទីបំផុតនៃខន្ធ លោកខ្ជាប់ខ្ជួនក្នុងទីបំផុតនៃធាតុ លោកខ្ជាប់ខ្ជួនក្នុង

កតិបរិយេ្ហ បិតោ ឧបបត្តិបរិយេ្ហ បិតោ បដិសន្ធិ-
បរិយេ្ហ បិតោ ភវបរិយេ្ហ បិតោ សំសារបរិយេ្ហ
បិតោ វដ្ដបរិយេ្ហ បិតោ អន្តិមភវេ បិតោ អន្តិម-
សមុស្ឃយេ បិតោ អន្តិមទេហធរេ អរហា ។

តស្ឃាយំ បច្ឆិមកោ ភវោ ចរិមោយំ សមុស្ឃយោ
ជាតិមរណសំសារោ ន ត្ថិ តស្ឃ បុនព្ភវោតិ ។

ជាវំ សិត្ឃាវ ចារកូ ។ តេនាហ ភគវា

តស្ម ជន្តុ សទា សតោ កាមានិ បរិវជ្ជយេ
តេ បហាយ តរេ ឱឃំ ជាវំ សិត្ឃាវ ចារកូតិ ។

បឋមោ កាមសុត្តនិទ្ទេសោ និដ្ឋិតោ ។

ទីបំផុតនៃអាយតន: លោកខ្ជាប់ខ្ជួនក្នុងទីបំផុតនៃគតិ លោកខ្ជាប់ខ្ជួនក្នុងទីបំផុតនៃឧបបត្តិភព លោកខ្ជាប់ខ្ជួនក្នុងទីបំផុតនៃបដិសន្ធិ លោកខ្ជាប់ខ្ជួនក្នុងទីបំផុតនៃភព លោកខ្ជាប់ខ្ជួន ក្នុងទីបំផុតនៃសង្សារ លោកខ្ជាប់ខ្ជួនក្នុងទីបំផុតនៃវដ្ត: លោកខ្ជាប់ខ្ជួន ក្នុងភពជាទីបំផុត លោកខ្ជាប់ខ្ជួនក្នុងសរីរ: ជាទីប្រជុំក្នុងទីបំផុត ទ្រទ្រង់រាងកាយជាទីបំផុត ជាព្រះអរហន្ត ។

ភពនេះ ជាទីបំផុតរបស់ព្រះអរហន្តនោះ អត្តភាពនេះ ជាខាងក្រោយបង្អស់ ការអន្ទោលទៅដោយជាតិ និងមរណ: ភពថ្មី របស់ព្រះអរហន្តនោះ មិនមានទេ ។

ហេតុនោះ (ទ្រង់ត្រាស់ថា) ដូចជាបុគ្គលអ្នកដល់ត្រើយ ព្រោះស្គារនាវា ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ព្រោះហេតុនោះ ជនអ្នកមានស្មារតី គ្រប់កាល គប្បីរៀរស្រឡះ នូវកាមទាំងឡាយ ជនលុះលះបង់នូវកាមទាំង-នោះ ទើបធ្វើនឱយ:បាន ដូចបុគ្គលអ្នកដល់នូវ ត្រើយ ព្រោះស្គារនាវា ។

ចប់ កាមសុត្តនិទ្ទេស ទី ១ ។

ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

[៣០] សត្តោ គុហាយំ ពហុនាភិឆន្នោ
តិដ្ឋំ នរោ មោហនស្មឹ បគាឡ្ហោ
ទូរេ វិវេកា ហិ តថាវិធោ សោ
កាមា ហិ លោកេ ន ហិ សុប្បហាយា ។

[៣១] សត្តោ គុហាយំ ពហុនាភិឆន្នោតិ សត្តោតិ ហិ ខោ វុត្តំ ។ អបិច គុហា តាវ វត្តព្វា ។ គុហា វុច្ចតិ កាយោ ។ កាយោតិ វា គុហាតិ វា ទេហោតិ វា សន្ទេហោតិ វា នាវាតិ វា រថោតិ វា ធជោតិ វា វម្មិកោតិ វា និទ្ធន្តិ វា នគរន្តិ វា កុដីតិ[១] វា គណ្ឌោតិ វា កុម្ភោតិ វា កាយស្សេតំ[២] អធិវចនំ ។ សត្តោ គុហាយន្តិ គុហាយំ សត្តោ វិសត្តោ អាសត្តោ លគ្គោ លគ្គិតោ បលិពុទ្ធោ ។ យថា ភិត្តិខីលេ វា នាគទន្តេ វា ភណ្ឌំ សត្តំ វិសត្តំ អាសត្តំ លគ្គំ លគ្គិតំ បលិពុទ្ធំ ឯវមេវ គុហាយំ សត្តោ វិសត្តោ អាសត្តោ លគ្គោ លគ្គិតោ បលិពុទ្ធោ ។

---

១ ម. ធម្មិកោតិ វា នគរន្តិ វា និជន្តិ វា កុដីតិ វា ។ ២ ឱ. កុម្ភោតិ វា នាគោតិ វា កាយស្សេតំ ។ ម. កុម្ភោតិ វា នាគោតិ វា កាយស្សេតំ ។

គុហដ្ឋកសុត្តនិទ្ទេស ទី ២

[៣០] (ព្រះមានព្រះភាគត្រាស់ថា) នរជនណា កាលបិតនៅ ជាប់នៅក្នុងគុហា ត្រូវកិលេសដ៏ច្រើន បិទបាំងលិចចុះ ក្នុងមោហៈ (អារម្មណ៍ជាគ្រឿងវង្វេង) នរជនមានសភាពដូច្នោះនោះ រមែងបិតនៅក្នុងទីឆ្ងាយអំពីវិវេកដ្ឋិតកាមទាំងឡាយ ក្នុងលោក បុគ្គលមិនមែនលះបង់បានដោយងាយទេ ។

[៣១] អធិប្បាយពាក្យថា ជាប់នៅក្នុងគុហា ត្រូវកិលេសដ៏ច្រើនបិទបាំង ត្រង់ពាក្យថា ជាប់នៅ ព្រះអង្គពោលក៏ពិតហើយ ។ តែខ្ញុំសូមពោលត្រង់ពាក្យថា គុហា ជាមុនសិន ។ កាយ លោកហៅថាគុហា ។ ពាក្យថា កាយក្តី គុហាក្តី ទេហៈក្តី សន្ទេហៈក្តី នាវាក្តី រថក្តី ទង់ក្តី ដំបូកក្តី សម្បុកក្តី នគរក្តី កុដិក្តី បូសក្តី ក្អមក្តី នេះជាឈ្មោះនៃកាយ ។ ពាក្យថា ជាប់នៅក្នុងគុហា គឺជាប់នៅផ្សេង ៗ ជាប់ទួទៅ ទាក់នៅ ជ្ជក់នៅ ព័ន្ធព័ទ្ធនៅ ក្នុងគុហា ។ ភណ្ឌៈដែលជាប់នៅ ជាប់ផ្សេងៗ ជាប់ទួទៅ ទាក់នៅ ជ្ជក់នៅ ព័ន្ធព័ទ្ធនៅ ឲ្យដ៏ចម្រើង ដែលដោតនឹងជញ្ជាំងក្តី ឲ្យដ៏ដែកែវក្តី យ៉ាងណា នរជនជាប់នៅ ជាប់ផ្សេងៗ ជាប់ទួទៅ ទាក់នៅ ជ្ជក់នៅ ព័ន្ធព័ទ្ធនៅ ក្នុងគុហា ក៏យ៉ាងនោះដែរ ។

រុត្តំ ហោតំ ភគវតា រូបេ ខោ[1] យោ ឆន្ទោ យោ រាគោ យា នន្ទិ យា តណ្ហា យេ ឧបាយុបាទានា ចេតសោ អធិដ្ឋានាភិនិវេសានុសយា តត្រ[2] សត្តោ [2] តស្មា សត្តោតិ រុច្ចតីតិ[3] ។ សត្តោតិ លក្ខណាធិវចនន្តិ សត្តោ តុហាយំ ។ ពហុនាភិធន្ធោតិ ពហុកេហិ កិលេសេហិ ធន្ធោ រាគេន ធន្ធោ ទោសេន ធន្ធោ មោហេន ធន្ធោ កោធេន ធន្ធោ ឧបនាហេន ធន្ធោ មក្ខេន ធន្ធោ បឬ្ឆាសេន ធន្ធោ ឥស្សាយ ធន្ធោ មច្ឆរិយេន ធន្ធោ មាយាយ ធន្ធោ សាឋេយ្យេន ធន្ធោ ថម្ភេន ធន្ធោ សារម្ភេន ធន្ធោ មានេន ធន្ធោ អតិមានេន ធន្ធោ មទេន ធន្ធោ បមាទេន ធន្ធោ សព្វកិ្លលេសេហិ សព្វទុច្ចរិតេហិ សព្វទរថេហិ សព្វបរិឬ្ហាហេហិ សព្វសន្តាបេហិ សព្វាកុសលាភិសង្ខារេហិ ធន្ធោ ឧច្ចន្ធោ អាវុជោ ជិវុជោ ឱជុជោ បិហិតោ បដិច្ចន្ធោ បដិកុជ្ជិតោតិ សត្តោ តុហាយំ ពហុនាភិធន្ធោ ។

---

១ ម. រូបេ ខោ រាធ ។ ២ ឱ. ម. តត្រ សត្តោ តត្រ វិសត្តោ ។ ៣ ម. ឥតោ បរំ ផេទនាយ ខោ រាធ ។ លេ ។ សញ្ញាយ ខោ រាធ សង្ខារេសុ ខោ រាធ វិញ្ញាណេ ខោ រាធ យោ ឆន្ទោ យោ រាគោ យា នន្ទិ យា តណ្ហា យេ ឧបាយុបាទានា ចេតសោ អធិដ្ឋានាភិនិវេសានុ-សយា តត្រ សត្តោ តត្រ វិសត្តោ តស្មា សត្តោតិ រុច្ចតីតិ ទិស្សន្តិ ។

សមដូចព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា សេចក្តីពេញចិត្តណា តម្រេកណា សេចក្តីត្រេកត្រអាលណា សេចក្តីប៉ុនប៉ងណា សេចក្តីប្រកាន់ដោយឧបាយ ដែលមានការតាំងចិត្ត និងការប្រកាន់ជាអនុស័យណា ក្នុងរូប នរជនជាប់ក្នុងកិលេសនោះៗ ហេតុនោះ (លោកពោលថា) ជាប់នៅ ។ ពាក្យថា ជាប់នៅ ជាឈ្មោះនៃការជាប់ចំពាក់ ហេតុនោះ (ទ្រង់ត្រាស់ថា) ជាប់នៅក្នុងគុហា ។ ពាក្យថា ត្រូវកិលេសដ៏ច្រើន បិទបាំង គឺត្រូវកិលេសទាំងឡាយ ដ៏ច្រើនបិទបាំង គឺរាគៈបិទបាំង ទោសៈបិទបាំង មោហៈបិទបាំង កោធៈបិទបាំង ឧបនាហៈបិទបាំង មក្ខៈបិទបាំង បឡាសៈបិទបាំង ឥស្សាបិទបាំង មច្ឆរិយៈបិទបាំង មាយាបិទបាំង សាឋេយ្យៈបិទបាំង ថម្ភៈបិទបាំង សារម្ភៈបិទបាំង មានៈបិទបាំង អតិមានៈបិទបាំង មទៈបិទបាំង បមាទៈបិទបាំង កិ-លេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីអន្ទះអន្ទែងទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង អកុសលាភិសង្ខារទាំងពួង បិទបាំង ប្រក់ព្រំ ខ្ទប់ រាំង ហ៊ុំភ្ជិត គ្រប បង្ហួមផ្តាប់ហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ជាប់នៅក្នុងគុហា ត្រូវកិលេសដ៏ច្រើនបិទបាំង ។

ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

[៣២] តិដ្ឋំ ជហេ មោហានស្មឿ បកាឡ្ហោតិ តិដ្ឋំ ជហេតិ តិដ្ឋន្តោ ជហេ រត្តោ រាគវសេន តិដ្ឋតិ ទុដ្ឋោ ទោសវសេន តិដ្ឋតិ មូឡ្ហោ មោហវសេន តិដ្ឋតិ វិ-និពន្ធោ មានវសេន តិដ្ឋតិ បរាមដ្ឋោ ទិដ្ឋិវសេន តិដ្ឋតិ វិក្ខេបគតោ ឧទ្ធច្ចវសេន តិដ្ឋតិ អនិដ្ឋង្គតោ វិចិកិច្ឆា-វសេន តិដ្ឋតិ ថាមគតោ អនុសយវសេន តិដ្ឋតីតិ ឯវម្ឪ តិដ្ឋំ ជហេ ។

រុត្តំ ហេតំ ភគវតា សន្តិ ភិក្ខវេ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមុបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ សន្តិ ភិក្ខវេ សោតវិញ្ញេយ្យា សទ្ទា ឃានវិញ្ញេយ្យា គន្ធា ជិវ្ហាវិញ្ញេយ្យា រសា កាយវិញ្ញេយ្យា ផោដ្ឋព្ពា មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា

[៣២] *អធិប្បាយពាក្យថា នរជនកាលបិតនៅ លិចចុះក្នុងមោហៈ ត្រង់ពាក្យថា នរជនកាលបិតនៅ បានដល់នរជនកាលដំអក់ គឺត្រេកត្រអាលដោយអំណាចរាគៈ ហើយដំអក់ ប្រទូស្តដោយអំណាចទោសៈ ហើយដំអក់ រវើរវាយដោយអំណាចមោហៈ ហើយដំអក់ ជាប់ក្នុងអារម្មណ៍ផ្សេង ១ ដោយអំណាចមានៈ ហើយដំអក់ ស្ទាបអង្អែលដោយអំណាចទិដ្ឋិ ហើយដំអក់ រាយមាយដោយអំណាចឧទ្ធច្ចៈ ហើយដំអក់ មិនដល់នូវសេចក្តីចូលចិត្ត ដោយអំណាចវិចិកិច្ឆា ហើយដំអក់ មានកម្លាំងដោយអំណាចអនុស័យ ហើយដំអក់ នរជនកាលបិតនៅ យ៉ាងនេះខ្លះ ។*

សមដូចព្រះពុទ្ធដីកានេះ ដែលព្រះមានបុណ្យត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រូបទាំងឡាយគប្បីដឹងច្បាស់ដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួររីករាយ បើភិក្ខុត្រេកអរ រីករាយនឹងរូបនោះហើយ រមែងដំអក់ក្នុងសេចក្តីប្រាថ្នាមិនខាន ម្នាលភិក្ខុទាំងឡាយ សំឡេងទាំងឡាយ ដែលគប្បីដឹងច្បាស់ដោយត្រចៀក ក្លិនទាំងឡាយ ដែលគប្បីដឹងច្បាស់ដោយច្រមុះ រសទាំងឡាយ ដែលគប្បីដឹងច្បាស់ដោយអណ្តាត ផ្សព្វទាំងឡាយ ដែលគប្បីដឹងច្បាស់ដោយកាយ ធម្មារម្មណ៍ទាំងឡាយ ដែលគប្បីដឹងច្បាស់ដោយចិត្ត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់

កាមុបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតីតិ ។ ឯវម្បិ តិដ្ឋំ ជហេ ។

វុត្តំ ហេតំ ភគវតា រូបូបាយំ វា ភិក្ខវេ វិញ្ញាណំ តិដ្ឋមានំ តិដ្ឋតិ រូបារម្មណំ រូបប្បតិដ្ឋំ នន្ទូបសេចនំ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជតិ វេទនូបាយំ វា ភិក្ខវេ សញ្ញូបាយំ វា ភិក្ខវេ សង្ខារូបាយំ វា ភិក្ខវេ វិញ្ញាណំ តិដ្ឋមានំ តិដ្ឋតិ សង្ខារារម្មណំ សង្ខារប្បតិដ្ឋំ នន្ទូបសេចនំ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជតីតិ ។ ឯវម្បិ តិដ្ឋំ ជហេ ។

វុត្តំ ហេតំ ភគវតា កពឡីការេ ចេ ភិក្ខវេ អាហារេ អត្ថិ រាគោ អត្ថិ នន្ទិ អត្ថិ តណ្ហា បតិដ្ឋិតំ តត្ថ វិញ្ញាណំ វិរូឡ្ហំ យត្ថ បតិដ្ឋិតំ វិញ្ញាណំ វិរូឡ្ហំ អត្ថិ តត្ថ នាមរូបស្សាវក្កន្តិ យត្ថ អត្ថិ នាមរូបស្សាវក្កន្តិ អត្ថិ តត្ថ សង្ខារានំ វុឌ្ឍិ យត្ថ អត្ថិ សង្ខារានំ វុឌ្ឍិ អត្ថិ តត្ថ អាយតឹ

ប្រកបដោយកាម គួររីករាយ បើភិក្ខុត្រេកអរ រីករាយ នឹងអារម្មណ៍នោះហើយ រមែងជំអក់ ក្នុងសេចក្ដីប្រាថ្នា មិនខាន ។ នរជនកាលបិតនៅ យ៉ាងនេះខ្ទះ ។

មួយទៀត ព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វិញ្ញាណមានរូបជាឧបាយក្ដី មានរូបជាអារម្មណ៍ តាំងនៅក្នុងរូប សេពនូវសេចក្ដីត្រេកអរ កាលសម្ងំ រមែងសម្ងំ (ក្នុងអារម្មណ៍នោះ) ក៏ដល់នូវសេចក្ដីចម្រើន លូតលាស់ ធំទូលាយ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណមានវេទនាជាឧបាយក្ដី ម្នាលភិក្ខុទាំងឡាយ វិញ្ញាណមានសញ្ញាជាឧបាយក្ដី ម្នាលភិក្ខុទាំងឡាយ វិញ្ញាណមានសង្ខារជាឧបាយក្ដី មានសង្ខារជាអារម្មណ៍ តាំងនៅក្នុងសង្ខារ សេពសេចក្ដីត្រេកអរ កាលសម្ងំ រមែងសម្ងំ (ក្នុងអារម្មណ៍នោះ) ដល់នូវសេចក្ដីចម្រើន លូតលាស់ ធំទូលាយ ។ នរជនកាលបិតនៅ យ៉ាងនេះខ្ទះ ។

ន័យមួយទៀត ព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើមានភគ: មានសេចក្ដីត្រេកអរ មានតណ្ហា ក្នុងកវឡិङ្ការាហារ វិញ្ញាណតាំងនៅលូតលាស់ក្នុងទីណា វិញ្ញាណតាំងនៅលូតលាស់ ក្នុងទីនោះ ការចុះកាន់នៃនាមរូប មានក្នុងទីណា ការចុះកាន់នៃនាមរូប ក៏មានក្នុងទីនោះ សេចក្ដីចម្រើនឡើង នៃសង្ខារទាំងឡាយ មានក្នុងទីណា សេចក្ដីចម្រើនឡើងនៃសង្ខារទាំងឡាយ ក៏មានក្នុងទីនោះ

បុនព្ភវាភិនិព្វត្តិ យត្ថ អត្ថិ អាយតឹ បុនព្ភវាភិនិព្វត្តិ អត្ថិ តត្ថ អាយតឹ ជាតិជរាមរណំ យត្ថ អត្ថិ អាយតឹ ជាតិជរាមរណំ សសោកន្តំ ភិក្ខវេ សរជំ សឧបា-យាសន្តិ វទាមិ ផស្សេ ចេ ភិក្ខវេ អាហារេ មនោ-សញ្ចេតនាយ ចេ ភិក្ខវេ អាហារេ វិញ្ញាណេ ចេ ភិក្ខវេ អាហារេ អត្ថិ រាគោ អត្ថិ នន្ទិ អត្ថិ តណ្ហា បតិដ្ឋិតំ តត្ថ វិញ្ញាណំ វិរូឡ្ហំ យត្ថ បតិដ្ឋិតំ វិញ្ញាណំ វិរូឡ្ហំ អត្ថិ តត្ថ នាមរូបស្សាវក្កន្តិ យត្ថ អត្ថិ នាមរូប-ស្សាវក្កន្តិ អត្ថិ តត្ថ សង្ខារានំ វុឌ្ឍិ យត្ថ អត្ថិ សង្ខារានំ វុឌ្ឍិ អត្ថិ តត្ថ អាយតឹ បុនព្ភវាភិនិព្វត្តិ យត្ថ អត្ថិ អា-យតឹ បុនព្ភវាភិនិព្វត្តិ អត្ថិ តត្ថ អាយតឹ ជាតិជរាមរណំ យត្ថ អត្ថិ អាយតឹ ជាតិជរាមរណំ សសោកន្តំ ភិក្ខវេ សរជំ សឧបាយាសន្តិ វទាមីតិ ។ ឯវម្បិ តិដ្ឋំ នរោ ។

មោហនស្មឹ បគាឡ្ហោតិ មោហនា វុច្ចន្តិ បញ្ចកាម-គុណា ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយ-

ការកើតឡើង នៃភពថ្មីតទៅ មានក្នុងទីណា ការកើតឡើង នៃភពថ្មីតទៅ ក៏មានក្នុងទីនោះ ជាតិ ជរា មរណៈ តទៅ មានក្នុងទីណា ជាតិ ជរា មរណៈ តទៅ មានក្នុងទីនោះ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវជាតិ ជរា មរណៈ នោះថា ប្រកបដោយសេចក្ដីសោក ប្រកបដោយធូលី ប្រកបដោយសេចក្ដីចង្អៀតចង្អល់ ម្នាលភិក្ខុទាំងឡាយ បើក្នុងផស្សាហារ ម្នាលភិក្ខុទាំងឡាយ បើក្នុងមនោសញ្ចេតនាហារ ម្នាលភិក្ខុទាំងឡាយ បើមានរាគៈ មានសេចក្ដីត្រេកអរ មានតណ្ហា ក្នុងវិញ្ញាណាហារ វិញ្ញាណ តាំងនៅ ដុះដាលឡើង ក្នុងទីណា វិញ្ញាណក៏តាំងនៅដុះដាល ក្នុងទីនោះ ការចុះកាន់នៃនាមរូប មានក្នុងទីណា ការចុះកាន់នៃនាមរូប ក៏មានក្នុងទីនោះ សេចក្ដីចម្រើននៃសង្ខារទាំងឡាយ មានក្នុងទីណា សេចក្ដីចម្រើននៃសង្ខារទាំងឡាយ ក៏មានក្នុងទីនោះ ការកើតនៃភពថ្មីតទៅ មានក្នុងទីណា ការកើតនៃភពថ្មីតទៅ ក៏មានក្នុងទីនោះ ជាតិ ជរា មរណៈ តទៅ មានក្នុងទីណា ជាតិ ជរា មរណៈ តទៅ ក៏មានក្នុងទីនោះ ម្នាលភិក្ខុទាំងឡាយ តថាគត ពោល នូវជាតិ ជរា មរណៈ នោះថា ប្រកបដោយសេចក្ដីសោក ប្រកបដោយធូលី ប្រកបដោយសេចក្ដីចង្អៀតចង្អល់ ។ នរជន កាលឋិតនៅ យ៉ាងនេះខ្លះ ។

ពាក្យថា លិចចុះក្នុងមោហៈ សេចក្ដីថា កាមគុណ ៥ ហៅថា មោហៈ បានដល់រូបដែលដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត

រូបា កាមុបសញ្ហិតា រជនីយា សោតវិញ្ញេយ្យា សទ្ទា ឃានវិញ្ញេយ្យា គន្ធា ជិវ្ហាវិញ្ញេយ្យា រសា កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមុបសញ្ហិតា រជនីយា ។ កឹការណា មោហនា វុច្ចន្តិ បញ្ច កាមគុណា ។ យេភុយ្យេន ទេវមនុស្សា បញ្ចសុ កាមគុណេសុ មុយ្ហន្តិ សម្មុយ្ហន្តិ សម្បមុយ្ហន្តិ មូឡ្ហា សម្មូឡ្ហា សម្បមូឡ្ហា អវិជ្ជាយ អន្ធីកតា អាវុតា និវុតា ឱផុតា បិហិតា បដិច្ឆន្នា បដិកុជ្ជិតា តំ ការណា មោហនា វុច្ចន្តិ បញ្ច កាមគុណា ។ មោហនស្មឹ បគាឡ្ហោតិ មោហនស្មឹ បគាឡ្ហោ ឱគាឡ្ហោ អជ្ឈោគាឡ្ហោ និមុគ្គោតិ តិដ្ឋំ នរោ មោហនស្មឹ បគាឡ្ហោ ។

[៣៣] ទូរេ វិវេកា ហិ តថាវិធោ សោតិ វិវេកាតិ តយោ វិវេកា កាយវិវេកោ ចិត្តវិវេកោ ឧបធិវិវេកោ ។

កតមោ កាយវិវេកោ ។ ឥធ ភិក្ខុ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ កាយេន ច វិវិត្តោ វិហរតិ សោ ឯកោ គច្ឆតិ ឯកោ តិដ្ឋតិ ឯកោ

មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួររីករាយ សំឡេងដែលគប្បីដឹងដោយត្រចៀក ក្លិនដែលគប្បីដឹងដោយច្រមុះ រសដែលគប្បីដឹងដោយអណ្ដាត ផ្សព្វដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួររីករាយ ។ កាមគុណ ៥ លោកហៅថា មោហៈ តើព្រោះហេតុអ្វី ។ ទេវតានិងមនុស្សដោយច្រើន រវៃង កេ្ងចស្មារតី ភាន់ភាំងគំនិត ក្នុងកាមគុណទាំង ៥ ជាអ្នករវៃង កេ្ងចស្មារតី ភាន់ភាំងគំនិត ត្រូវអវិជ្ជាធ្វើឲ្យងងឹត ខ្ទប់ រាំង ហ៊ុំ ក្ងិត គ្រប បង្ក្រួម ផ្ដាប់ហើយ ព្រោះហេតុនោះ កាមគុណទាំង ៥ លោកហៅថា មោហៈ ។ ត្រង់ពាក្យថា លិចចុះក្នុងមោហៈ គឺចូលទៅ ផ្ដាប់ចុះ ចូលទៅស៊ីប់ ជ្រមុជចុះ ក្នុងមោហៈ ហេតុនោះ (ទ្រង់ត្រាស់ថា) នរជន កាលបិតនៅ លិចចុះ ក្នុងមោហៈ ។

[៣៣] *អធិប្បាយពាក្យថា នរជនមានសភាពដូច្នេះនោះ (បិតនៅ) ក្នុងទីធ្វាយអំពីវិវេក ត្រង់ពាក្យថា វិវេក បានដល់វិវេក ៣ គឺ កាយវិវេក ១ ចិត្តវិវេក ១ ឧបធិវិវេក ១ ។*

កាយវិវេក តើដូចម្ដេច ។ ភិក្ខុ ក្នុងសាសនានេះ គប់រកសេនាសនៈស្ងាត់ គឺ ព្រៃ គល់ឈើ ភ្នំ ល្អាង គុហា ព្រៃស្ម-សាន ព្រៃធ្វាយ ទីវាល និងគំនរចំបើង ជាអ្នកនៅ ស្ងប់ស្ងាត់ដោយកាយ ភិក្ខុនោះ ទៅម្នាក់ឯង ឈរម្នាក់ឯង អង្គុយម្នាក់ឯង

ជិសីឧតិ ឯកោ សេយ្យំ កប្បេតិ ឯកោ តាមំ បិណ្ហាយ
បវិសតិ ឯកោ បដិក្កមតិ ឯកោ រហោ ជិសីឧតិ
ឯកោ ចង្កមំ អធិដ្ឋាតិ ឯកោ ចរតិ វិហរតិ ឥរិយតិ
វត្តតិ ចាលេតិ យបេតិ យាបេតិ អយំ កាយវិវេកោ ។
    កតមោ ចិត្តវិវេកោ ។ បឋមំ ឈានំ សមាបន្នស្ស
នីវរណេហិ ចិត្តំ វិវិត្តំ ហោតិ ទុតិយំ ឈានំ សមាបន្នស្ស
វិតក្កវិចារេហិ ចិត្តំ វិវិត្តំ ហោតិ តតិយំ ឈានំ
សមាបន្នស្ស បីតិយា ចិត្តំ វិវិត្តំ ហោតិ ចតុត្ថំ ឈានំ
សមាបន្នស្ស សុខទុក្ខេហិ ចិត្តំ វិវិត្តំ ហោតិ អាកា-
សានញ្ចាយតនំ សមាបន្នស្ស រូបសញ្ញាយ បដិឃ-
សញ្ញាយ នានត្តសញ្ញាយ ចិត្តំ វិវិត្តំ ហោតិ វិញ្ញាណ-
ញ្ចាយតនំ សមាបន្នស្ស អាកាសានញ្ចាយតន-
សញ្ញាយ ចិត្តំ វិវិត្តំ ហោតិ អាកិញ្ចញ្ញាយតនំ
សមាបន្នស្ស វិញ្ញាណញ្ចាយតនសញ្ញាយ ចិត្តំ វិវិត្តំ
ហោតិ នេវសញ្ញានាសញ្ញាយតនំ សមាបន្នស្ស អាកិ-
ញ្ចញ្ញាយតនសញ្ញាយ ចិត្តំ វិវិត្តំ ហោតិ សោតាបន្នស្ស
សក្កាយទិដ្ឋិយា វិចិកិច្ឆាយ សីលព្ពតបរាមាសា

ដេកម្នាក់ឯង ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតម្នាក់ឯង ត្រឡប់មកវិញ ម្នាក់ឯង អង្គុយនៅក្នុងទីស្ងាត់ម្នាក់ឯង អធិដ្ឋានទីចង្ក្រមម្នាក់ឯង ត្រាច់ទៅ នៅ (ញ្ជាំងឥរិយាបថ) ឲ្យប្រព្រឹត្តទៅ ប្រព្រឹត្ត រក្សា (ឥរិយាបថ) ប្រព្រឹត្តទៅ ដើរទៅ ម្នាក់ឯង នេះ ឈ្មោះថា កាយវិវេក ។

ចិត្តវិវេក តើដូចម្តេច ។ ភិក្ខុចូលបឋមជ្ឈាន ចិត្តស្ងាត់ចាកនីវរណៈទាំងឡាយ ភិក្ខុចូលទុតិយជ្ឈាន ចិត្តស្ងាត់ចាកវិតក្កៈនិងវិចារៈ ចូលតតិយជ្ឈាន ចិត្តស្ងាត់ចាកបីតិ ភិក្ខុចូលចតុត្ថជ្ឈាន ចិត្តស្ងាត់ចាកសុខនិងទុក្ខ ភិក្ខុចូលអាកាសានញ្ចាយតនជ្ឈាន ចិត្តស្ងាត់ចាករូបសញ្ញា បដិឃសញ្ញា នានត្តសញ្ញា ភិក្ខុចូលវិញ្ញាណញ្ចាយតនជ្ឈាន ចិត្តស្ងាត់ចាកអាកាសានញ្ចាយតនសញ្ញា ភិក្ខុចូលអាកិញ្ចញ្ញាយតនជ្ឈាន ចិត្តស្ងាត់ចាកវិញ្ញាណញ្ចាយតនសញ្ញា ភិក្ខុចូលនេវសញ្ញានាសញ្ញាយត-នជ្ឈាន ចិត្តស្ងាត់ ចាកអាកិញ្ចញ្ញាយតនសញ្ញា ភិក្ខុដល់សោតៈ ចិត្តស្ងាត់ ចាកសក្កាយទិដ្ឋិ ចាកវិចិកិច្ឆា ចាកសីលព្វតបរាមាសៈ

ទិដ្ឋានុសយា វិចិកិច្ឆានុសយា តទេកដ្ឋេហិ ច កិលេសេហិ ចិត្តំ រិត្តំ ហោតិ សកទាគាមិស្ស ឱឡារិកា កាមរាគសញ្ញោជនា បដិឃសញ្ញោជនា ឱឡារិកា កាមរាគានុសយា បដិឃានុសយា តទេកដ្ឋេហិ ច កិលេសេហិ ចិត្តំ រិត្តំ ហោតិ អនាគាមិស្ស អណុសហគតា កាមរាគសញ្ញោជនា បដិឃសញ្ញោជនា អណុសហគតា កាមរាគានុសយា បដិឃានុសយា តទេកដ្ឋេហិ ច កិលេសេហិ ចិត្តំ រិត្តំ ហោតិ អរហតោ រូបរាគា អរូបរាគា មានា ឧទ្ធច្ចា អវិជ្ជាយ មានានុសយា ភវរាគានុសយា អវិជ្ជានុសយា តទេកដ្ឋេហិ ច កិលេសេហិ ពហិទ្ធា ច សព្វនិមិត្តេហិ ចិត្តំ រិត្តំ ហោតិ អយំ ចិត្តវិវេកោ ។

កតមោ ឧបធិវិវេកោ ។ ឧបធិ វុច្ចន្តិ កិលេសា ច ខន្ធា ច អភិសង្ខារា ច ។ ឧបធិវិវេកោ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ អយំ ឧបធិវិវេកោ ។

ចាកទិដ្ឋានុស័យ ចាកវិចិកិច្ឆានុស័យ និងកិលេសដែលបិតនៅជាមួយនឹងកិលេសទាំងនោះ ភិក្ខុដល់សកទាគামិ ចិត្តស្ងាត់ចាកកាមរាគសញ្ញោ-ជនៈ ចាកបដិឃសញ្ញោជនៈ ដ៏គ្រោតគ្រាតផង ចាកកាមរាគានុស័យ ចាកបដិឃានុស័យ យ៉ាងគ្រោតគ្រាត ចាកកិលេសទាំងឡាយដែលបិតនៅជាមួយនឹងកិលេសទាំងនោះផង ភិក្ខុដល់អនាគামិ ចិត្តស្ងាត់ចាកកាមរាគសញ្ញោជនៈ ចាកបដិឃសញ្ញោជនៈយ៉ាងល្អិតផង ចាកកាម-រាគានុស័យ ចាកបដិឃានុស័យ យ៉ាងល្អិតផង ចាកកិលេសទាំងឡាយដែលបិតនៅជាមួយគ្នា នឹងកិលេសទាំងនោះផង ភិក្ខុដល់ព្រះអរហត្ត ចិត្តស្ងាត់ចាករូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យផង ចាកកិលេសទាំងឡាយ ដែលបិតនៅជាមួយនឹងកិលេសទាំងនោះផង ចាកនិមិត្តគ្រប់យ៉ាងខាងក្រៅផង នេះ ឈ្មោះថា ចិត្តវិវេក ។

ឧបធិវិវេក តើដូចម្តេច ។ កិលេសទាំងឡាយ ខន្ធទាំងឡាយ និងអភិសង្ខារទាំងឡាយ លោក ហៅថា ឧបធិ ។ អមតនិព្វាន លោកហៅថា ឧបធិវិវេក បានដល់ការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់ (កង់ទុក្ខ) ការចេញចាកតណ្ហា នេះ ឈ្មោះថា ឧបធិវិវេក ។

កាយវិវេកោ ច រូបកជ្ជកាយានំ នេក្ខម្មាភិរតានំ ចិត្តវិវេកោ ច បរិសុទ្ធចិត្តានំ បរមវោទានប្បត្តានំ ឧបធិវិវេកោ ច និរុបធីនំ បុគ្គលានំ វិសង្ខារគតានំ ។ ទូរេ វិវេកា ហីតិ យោ សោ ឯវំ គុហាយំ សត្តោ ឯវំ ពហុកេហិ កិលេសេហិ ឆន្នោ ឯវំ មោហនស្មឹ បគាឡ្ហោ សោ កាយវិវេកាបិ ទូរេ ចិត្តវិវេកាបិ ទូរេ ឧបធិវិវេកាបិ ទូរេ វិទូរេ សុវិទូរេ ន សន្តិកេ ន សាមន្តា អនាសន្នេ អនុបកដ្ឋេ[១] ។ តថាវិធោតិ តថាវិធោ តាទិសោ តស្សណ្ឋិតោ តប្បការោ តប្បដិភាគោ យោ សោ មោហនស្មឹ បគាឡ្ហោតិ ទូរេ វិវេកា ហិ តថាវិធោ សោ ។

[៣៤] កាមា ហិ លោកេ ន ហិ សុប្បហាយាតិ កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។

---

១ ម. វិវេកដ្ឋេ ។

កាយវិវេក (កើតមាន) ដល់ពួកបុគ្គលដែលចេញចាកពួក ត្រេកអរ ក្នុងការចេញចាកកាមផង ចិត្តវិវេក (កើតមាន) ដល់ពួកបុគ្គលដែលមាន ចិត្តបរិសុទ្ធ ដល់នូវសេចក្ដីផ្ទរផង់ក្រៃលែងផង ឧបធិវិវេក (កើតមាន) ដល់ពួកបុគ្គលដែលមិនមានកិលេស ដល់នូវព្រះនិព្វាន ដែលប្រាស ចាកសង្ខារផង ។

ពាក្យថា ក្នុងទីធ្វាយអំពីវិវេក បានដល់នរជនណា ជាប់ចំពាក់ ក្នុងគុហាយ៉ាងនេះ ត្រូវពួកកិលេសដ៏ច្រើនបិទបាំងយ៉ាងនេះ លិចចុះ ក្នុងមោហៈយ៉ាងនេះ នរជននោះ (ឈ្មោះថាឋិតនៅ) ក្នុងទីធ្វាយ អំពី កាយវិវេកផង ក្នុងទីធ្វាយអំពីចិត្តវិវេកផង ក្នុងទីធ្វាយ ធ្វាយពេក ធ្វាយពេកណាស់ មិនមែនជិត មិនមែននៅក្បែរ មិនមែននៅប្រកៀក ឃ្លាតអំពីឧបធិវិវេកផង ។ ពាក្យថា មានសភាពដូច្នោះ គឺមានប្រការ ដូច្នោះ ប្រាកដដូច្នោះ ឋិតនៅដោយអាការនោះ ឋិតនៅដោយប្រការ នោះ ជាចំណែកនៃប្រការនោះ ដែលលិចចុះក្នុងមោហៈនោះ ហេតុ នោះ (ទ្រង់ត្រាស់ថា) នរជនមានសភាពដូច្នោះនោះ (ឋិតនៅ) ក្នុង ទីធ្វាយអំពីវិវេក ។

[៣៦] អធិប្បាយពាក្យថា ដ្ឋិតកាមទាំងឡាយ ក្នុងលោក បុគ្គលមិនមែនលះបង់បានដោយងាយទេ ត្រង់ពាក្យថា កាម បើតាម ឧទ្ទាន បានដល់ កាម ២ យ៉ាង គឺ វត្ថុកាម ១ កិលេសកាម ១ ។

កតមេ វត្ថុកាមា ។ មនាបិកា រូបា មនាបិកា សទ្ទា មនាបិកា គន្ធា មនាបិកា រសា មនាបិកា ផោដ្ឋព្វា អត្ថរណា បាបុរណា ទាសីទាសា អជេឡកា កុក្កុដសូករា ហត្ថិគវាស្សវឡវា ខេត្តំ វត្ថុ ហិរញ្ញំ សុវណ្ណំ គាមនិគមរាជធានិយោ រដ្ឋញ្ច ជនបទោ ច កោសោ ច កោដ្ឋាគារញ្ច យង្កិញ្ចិ រជនីយវត្ថុ វត្ថុកាមា ។ អបិច អតីតា កាមា អនាគតា កាមា បច្ចុប្បន្នា កាមា អជ្ឈត្តា កាមា ពហិទ្ធា កាមា អជ្ឈត្តពហិទ្ធា កាមា ហីនា កាមា មជ្ឈិមា កាមា បណីតា កាមា អាបាយិកា កាមា មានុសិកា កាមា ទិព្វា កាមា បច្ចុបដ្ឋិតា កាមា និម្មិតា កាមា បរនិម្មិតា កាមា បរិគ្គហិតា កាមា អបរិគ្គហិតា កាមា មមាយិតា កាមា អមមាយិតា កាមា សព្វេបិ កាមាវចរា ធម្មា សព្វេបិ រូបាវចរា ធម្មា សព្វេបិ អរូបាវចរា ធម្មា តណ្ហាវត្ថុកា តណ្ហារម្មណា កាមនីយដ្ឋេន រជនីយដ្ឋេន មទនីយដ្ឋេន កាមា ឥមេ វុច្ចន្តិ វត្ថុកាមា ។

វត្ថុកាម តើដូចម្តេច ។ រូបជាទីគាប់ចិត្ត សំឡេងជាទីគាប់ចិត្ត ក្លិនជាទីគាប់ចិត្ត រសជាទីគាប់ចិត្ត ផ្សព្វជាទីគាប់ចិត្ត កម្រាល គ្រឿងស្មៀកពាក់ ខ្ញុំស្រី ខ្ញុំប្រុស ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះ លា ស្រែ ចម្ការ ប្រាក់ មាស ស្រុក និគម រាជធានី ដែនជនបទ បន្ទាយ ឃ្លាំង និងវត្ថុដែលគួរត្រេកអរ ណាមួយ ហៅថា វត្ថុកាម ។ មួយទៀត កាមទាំងឡាយជាអតីត កាមទាំងឡាយជាអនាគត កាមទាំងឡាយជាបច្ចុប្បន្ន កាមទាំងឡាយជាខាងក្នុង កាមទាំងឡាយជាខាងក្រៅ កាមទាំងឡាយ ទាំងខាងក្នុងខាងក្រៅ កាមទាំងឡាយថោកទាប កាមទាំងឡាយជាកណ្តាល កាមទាំងឡាយដ៏ឧត្តម កាមទាំងឡាយមានក្នុងអបាយ កាមទាំងឡាយមានក្នុងមនុស្ស កាមទាំងឡាយជាទិព្ធ កាមទាំងឡាយ ដែលតាំងឡើងឯង កាមទាំងឡាយ ដែលខ្ជូននិម្មិត កាមទាំងឡាយ ដែលអ្នកដទៃនិម្មិត កាមទាំងឡាយ ដែលគេហួងហែង កាមទាំងឡាយដែលគេមិនហួងហែង កាមទាំងឡាយ ដែលគេប្រកាន់ថារបស់អញ កាមទាំងឡាយ ដែលគេមិនប្រកាន់ថារបស់អញ ពួកធម៌ជាកាមាវចរទាំងអស់ក្តី ពួកធម៌ជារូបាវចរទាំងអស់ក្តី ពួកធម៌ជាអរូបាវចរទាំងអស់ក្តី ដែលជាវត្ថុនៃតណ្ហា ជាអារម្មណ៍នៃតណ្ហា ឈ្មោះថា កាម ដោយអត្ថថាគួរប្រាថ្នា ដោយអត្ថថាគួរត្រេកអរ ដោយអត្ថថាជាហេតុញ៉ាំងសេចក្តីស្រវឹងឲ្យកើត ទាំងនេះ ហៅថា វត្ថុកាម ។

ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

កតមេ កិលេសកាមា ។ ឆន្ទោ កាមោ រាគោ
កាមោ ឆន្ទរាគោ កាមោ សង្កប្បោ កាមោ រាគោ
កាមោ សង្កប្បរាគោ កាមោ យោ កាមេសុ កាម-
ច្ឆន្ទោ កាមរាគោ កាមនន្ទិ កាមតណ្ហា កាមស្នេហោ
កាមបរិឡាហោ កាមមុច្ឆា កាមជ្ឈោសានំ កាមោ-
ឃោ កាមយោគោ កាមុចាជានំ កាមច្ឆន្ទនីវរណំ
អន្ធសំ កាម តេ មូលំ សង្កប្បា កាម ជាយសិ
ន តំ សង្កប្បយិស្សាមិ ឯវំ កាម ន ហេហិសិ ។
ឥមេ វុច្ចន្តិ កិលេសកាមា ។ លោកោតិ អចាយ-
លោកោ មនុស្សលោកោ ទេវលោកោ ខន្ធលោកោ
ធាតុលោកោ អាយតនលោកោ ។ កាមា ហិ លោកោ
ន ហិ សុប្បហាយាតិ កាមា ហិ លោកោ ទុប្បហាយា

កិលេសកាម តើដូចម្តេច ។ សេចក្តីពេញចិត្ត ឈ្មោះថា កាម សេចក្តីត្រេកអរ ឈ្មោះថា កាម សេចក្តីត្រេកអរមានកម្ទាំង ឈ្មោះថា កាម សេចក្តីត្រិះរិះ ឈ្មោះថា កាម តម្រេក ឈ្មោះថា កាម សេចក្តីត្រេកអរដោយការត្រិះរិះ ឈ្មោះថាកាម បានដល់សេចក្តីពេញចិត្តគឺកាម សេចក្តីត្រេកអរគឺកាម សេចក្តីត្រេកត្រអាលគឺកាម សេចក្តីប្រាថ្នាគឺកាម សេចក្តីស្រឡាញ់គឺកាម សេចក្តីក្តៅក្រហាយ គឺកាម ការជ្រប់គឺកាម សេចក្តីចូលចិត្តមាំគឺកាម អន្ទង់គឺកាម យោគៈគឺកាម ឧបាទានគឺកាម នីវរណៈគឺកាមចន្ទៈ ក្នុងកាមទាំងឡាយ (និងពាក្យ ដែលព្រះមានព្រះភាគត្រាស់ថា)

ម្នាលកាម តថាគតបានឃើញដើមកំណើតអ្នកហើយ ម្នាលកាម អ្នកឯងកើតអំពីសេចក្តីត្រិះរិះ តថាគត មិនត្រិះរិះចំពោះអ្នកទៀតទេ ម្នាលកាម កាលបើយ៉ាងនេះ អ្នកនឹងមិនមានឡើយ ។

ទាំងនេះ លោកហៅថា កិលេសកាម ។ ពាក្យថា ក្នុងលោក គឺ ក្នុងអបាយលោក ក្នុងមនុស្សលោក ក្នុងទេវលោក ក្នុងខន្ធលោក ក្នុងធាតុលោក ក្នុងអាយតនលោក ។ ពាក្យថា ដ្ឋិត កាមទាំង-ឡាយ ក្នុងលោក បុគ្គលមិនមែនលះបង់បាន ដោយងាយទេ បានសេចក្តីថា ដ្ឋិតកាមទាំងឡាយ ក្នុងលោក គេលះបង់បានដោយក្រ

ទុច្ចជា ទុប្បរិច្ចជា ទុន្និម្មទយា ទុព្ពិនិវេឋយា ទុត្តរា ទុប្បតរា ទុស្សមតិក្កមា ទុព្វីតិវត្តាតិ កាមា ហិ លោកេ ន ហិ សុប្បហាយា ។ តេនាហ ភគវា

សត្តោ គុហាយំ ពហុនាភិឆន្នោ
តិដ្ឋំ នរោ មោហនស្មឹ បគាឡ្ហោ
ទូរេ វិវេកា ហិ តថាវិធោ សោ
កាមា ហិ លោកេ ន ហិ សុប្បហាយាតិ ។

[៣៥] ឥច្ឆានិទានា ភវសាតពទ្ធា[១]

តេ ទុប្បមុញ្ចា ន ហិ អញ្ញមោក្ខា
បច្ឆា បុរេ វាបិ អបេក្ខមានា
ឥមេវ កាមេ បុរិមេវ ជប្បំ ។

---

១ កត្ថចិ បោត្ថកេ ភវសាតពទ្ធាតិ បាឋោ ទិស្សតិ ។

ចោះបង់បានដោយក្រ លះលែងបានដោយក្រ ញាំញីបានដោយក្រ ដោះស្រាយបានដោយក្រ ធ្វង់បានដោយក្រ ធ្វង់កាត់បានដោយក្រ កន្ទ្រង់បានដោយក្រ រំលង់បានដោយក្រ ហេតុនោះ (ទ្រង់ត្រាស់ថា) កាមទាំងឡាយក្នុងលោក បុគ្គលមិនមែនលះបង់បានដោយងាយទេ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

នរជនកាលបិតនៅ ជាប់នៅក្នុងគុហា ត្រូវកិលេសដ៏ច្រើន បិទបាំង លិចចុះក្នុងមោហ: នរជនមានសភាពដូច្នោះ នោះ (បិតនៅ) ក្នុងទីឆ្ងាយអំពីវិវេក ដ្ឋិតកាមទាំងឡាយ ក្នុងលោក បុគ្គលមិនមែនលះបង់បានដោយងាយទេ ។

[៣៥] ពួកសត្វទាំងនោះ មានសេចក្ដីប្រាថ្នាជាហេតុ ជាប់ចំពាក់ដោយសេចក្ដីត្រេកអរក្នុងការចម្រើន អាឡោះអាល័យ ក្នុងកាល ជាខាងក្រោយ ឬក្នុងកាលមុន ប្រាថ្នានូវកាមទាំងនេះ ឬនូវកាម ក្នុងកាលមុន រមែងរួចបានដោយក្រ ទាំងញ្ជាំងបុគ្គលដទៃឲ្យរួចមិនបាន ។

[៣៦] ពាក្យថា មានសេចក្ដីប្រាថ្នាជាហេតុ ជាប់ចំពាក់ ដោយ

ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

[៣៦] ឥច្ឆានិជានា ភវសាតពន្ធាតិ ឥច្ឆាតិ រុច្ចតិ តណ្ហា យោ ភវោ សាភវោ អនុនយោ អនុរោធោ ឆន្ទិ ឆន្ទិភវោ ចិត្តស្ស សាភវោ ឥច្ឆា មុច្ឆា អជ្ឌោ-សានំ ភេជោ បលិភេជោ[១] សង្ហោ បង្ហោ ឯជា មា-យា ជនិកា សញ្ជនី សិព្ពិនី ជាលិនី សរិតា វិ-សត្តិកា សុត្តំ វិសជា អាយូហនី ទុតិយា បណិធិ ភវនេត្តិ វនំ វនថো សន្ថវោ ស្នេហោ អបេក្ខា បដិ-ពន្ធា អាសា អាសីសនា អាសីសិតត្តំ រូបាសា សន្ធា-សា ឥន្ធាសា រសាសា ផោដ្ឋព្ពាសា លាភាសា ធនា-សា បុត្តាសា ជីវិតាសា ជប្ជា បជប្ជា អភិជប្ជា ជប្ជា ជប្ជនា ជប្ជិតត្តំ លោលុប្ជា លោលុប្ជាយ-នា លោលុប្ជាយិតត្តំ បុថុ ញ្ចិ ឥតា សាធុ ឥមត្តា

---

១ ម. ពោធោ បលិពោធោ ។

គុហដ្ឋកសុត្តនិទ្ទេស ទី ២

សេចក្តីត្រេកអរក្នុងការចម្រើន អធិប្បាយថា តណ្ហា លោកហៅថា សេចក្តីប្រាថ្នា បានដល់ តម្រេក តម្រេកមានកម្លាំង សេចក្តីកួចកាន់ សេចក្តីត្រេកអរ សេចក្តីរីករាយ សេចក្តីរីករាយនិងតម្រេក តម្រេកដ៏មានកម្លាំងរបស់ចិត្ត សេចក្តីប្រាថ្នា សេចក្តីជ្រប់ចុះ កិរិយាងប់ចុះ សេចក្តីចំពាក់ចិត្ត សេចក្តីចំពាក់មាំ គ្រឿងជាប់ ភក់ កិរិយាស្វែងរក ការលាក់ពុត កិលេសជាតិជាគ្រឿងញ៉ាំងសត្វឲ្យកើត ជាគ្រឿងញ៉ាំងទុក្ខឲ្យកើត ជាគ្រឿងចាក់ស្រែះ កិលេសជាតិដូចជាសំណាញ់ ជាគ្រឿងហូរទៅ ផ្សាយទៅ ក្រសៃ គឺតណ្ហា កិលេសជាតិដ៏ទូលាយ ជាគ្រឿងញ៉ាំងអាយុឲ្យវិនាស (របស់សត្វ) ជាគម្រប់ពីរ ជាគ្រឿងតម្កល់ទុក ជាគ្រឿងនាំសត្វទៅកាន់ភព កិលេសជាតិដូចជាព្រៃធំ ដូចជាព្រៃតូច សេចក្តីស្និទ្ធស្នាល សេចក្តីស្នេហា សេចក្តីអាល័យ សេចក្តីជាប់ជំពាក់ សេចក្តីប៉ុនប៉ង សេចក្តីនឹកជញ្ជឹង ភាពនៃចិត្តនឹកជញ្ជឹង បំណងរូប បំណងសំឡេង បំណងក្លិន បំណងរស បំណងផ្សព្វ បំណងលាភ បំណងទ្រព្យ បំណងកូន បំណងជីវិត ការជាប់ ការជាប់ទូទៅ ការជាប់ក្រៃលែង ការជាប់ កិរិយាជាប់ ភាពនៃចិត្តជាប់ ការជក់ស្អិត កិរិយាជក់ស្អិត ភាពនៃចិត្តជក់ស្អិត ភាពនៃចិត្តរឡ្ចិបរឡ្ចប់ ភាពនៃចិត្តប្រាថ្នាខ្លាំងក្លា

អជម្ម្ហកោ វិសមលោកោ ជិកន្ត្ថ ជិកាមជា បត្ថជា
ឧិហជា សម្ឆត្ថជា កាមតណ្ហា ភវតណ្ហា វិភវតណ្ហា
រូបតណ្ហា អរូបតណ្ហា ជិរោជតណ្ហា រូបតណ្ហា សទ្ទ-
តណ្ហា ឧន្ធតណ្ហា រសតណ្ហា ផោដ្ឋព្ធតណ្ហា ជម្ម្ហតណ្ហា
ឧិយោ យោកោ ឧន្ត្ថ ឧចាជានំ អារ្ជណំ ជីវ្ជណំ
ជជនំ ពន្ធនំ ឧបក្ជិលេសោ អនុសយោ បរិយុដ្ឋានំ
លតា ជ្ជវិជ្ជ ជុក្ខមូលំ ជុក្ខជិជានំ ជុក្ខប្ជកជ្ជ មារជា-
សោ មារពជ្ជិសំ មារ្ជិសយោ តណ្ហាជនី តណ្ហាជាលំ
តណ្ហាឧន្ធលំ តណ្ហាសមុន្ត្ថ អកិជ្ជ លោកោ អកុ-
សលមូលំ ។ ឥជ្ជានិជានាតិ ឥជ្ជានិជានា[1] ឥជ្ជាហេ-
តុកា ឥជ្ជាបជ្ជយា ឥជ្ជាការណា ឥជ្ជាបភវាតិ ឥជ្ជានិ-
ជានា ។ ភវសាតពន្ធាតិ ឯកំ ភវសាតំ សុខ ជេជនា ។

---

១ ម. ឥជ្ជានិទានកា ។

តម្រេកមិនត្រូវតាមធម៌ សេចក្តីលោភមិនស្មើ សេចក្តីអាល័យ កិលេស-ជាតិជាទីអាល័យ សេចក្តីប្រាថ្នា សេចក្តីស្រឡាញ់ សេចក្តីប្រាថ្នាគ្រប់យ៉ាង ចំណង់ក្នុងកាម ចំណង់ក្នុងសេចក្តីចម្រើន ចំណង់ក្នុងសេចក្តីវិនាស ចំណង់ក្នុងរូប ចំណង់ក្នុងអរូប ចំណង់ក្នុងនិរោធ ចំណង់ក្នុងរូប ចំណង់ក្នុងសំឡេង ចំណង់ក្នុងក្លិន ចំណង់ក្នុងរស ចំណង់ក្នុងផ្សព្វ ចំណង់ក្នុងធម៌ អន្ទង់ គ្រឿងប្រកបទុក គ្រឿងដោតក្រង គ្រឿងប្រកាន់ កិរិយាវាវាំង កិរិយាទប់ កិរិយាប្រក់ កិរិយាចង កិរិយាសៅហ្មង កិរិយាដេកត្រាំ កិរិយាស្នាក់ វល្លិគឺតណ្ហា សេចក្តីប្រាថ្នាផ្សេង ៗ ឫសគល់នៃសេចក្តីទុក្ខ ហេតុនៃសេចក្តីទុក្ខ ដែនកើតនៃសេចក្តីទុក្ខ អន្ទាក់នៃមារ សន្ទូចនៃមារ វិស័យនៃមារ ស្ទឹងគឺតណ្ហា បណ្តាញគឺតណ្ហា ដងដោយគឺតណ្ហា សមុទ្ទគឺតណ្ហា អកិណ្ណា លោកៈ ឫសគល់នៃអកុសល ។ ពាក្យថា មានសេចក្តីប្រាថ្នាជាហេតុ គឺមានសេចក្តីប្រាថ្នាជានិទាន មានសេចក្តីប្រាថ្នាជាហេតុ មានសេចក្តីប្រាថ្នាជាបច្ច័យ មានសេចក្តីប្រាថ្នាជាការណ៍ មានសេចក្តីប្រាថ្នាជាដែនកើតមុន ហេតុនោះ (ទ្រង់ត្រាស់ថា) មានសេចក្តីប្រាថ្នាជាហេតុ ។ ពាក្យថា ជាប់ចំពាក់ដោយសេចក្តីត្រេកអរក្នុងការចម្រើន គឺសេចក្តីត្រេកអរក្នុងការចម្រើន ១ គឺសុខវេទនា ។

ទ្វេ ភវសាតានិ សុខា ច វេទនា ឥដ្ឋញ្ច វត្ថុ ។ តីណិ ភវសាតានិ យោព្វញ្ញំ អាភេក្យំ ជីវិតំ ។ ចត្តារិ ភវ-សាតានិ លាភោ យសោ បសំសា សុខំ ។ បញ្ច ភវ-សាតានិ មាតាបិតា ឫជា មាតាបិតា សច្ចា មាតាបិតា ឥន្ទ្រា មាតាបិតា រសា មាតាបិតា ផោដ្ឋព្ពា ។ ឆ ភវសា-តានិ ចក្ខុសម្ផស្សោ សោតសម្ផស្សោ ឃានសម្ផស្សោ ជិវ្ហា-សម្ផស្សោ កាយសម្ផស្សោ មនោសម្ផស្សោ ។ ភវសាត-ពន្ធាតិ[1] សុខាយ វេទនាយ ពន្ធា[2] ឥដ្ឋស្មឹ វត្ថុស្មឹ ពន្ធា យោព្វញ្ញេ ពន្ធា អាភេក្យេ ពន្ធា ជីវិតេ ពន្ធា លា-ភេ ពន្ធា យសេ ពន្ធា បសំសាយ ពន្ធា សុខេ ពន្ធា មាតាបិតូសុ ឫជូសុ ពន្ធា សច្ចេសុ ឥន្ទ្រេសុ រសេសុ មាតាបិតូសុ ផោដ្ឋព្ពេសុ ពន្ធា ចក្ខុសម្ផស្សាយ ពន្ធា សោតសម្ផស្សាយ ឃានសម្ផស្សាយ ជិវ្ហាសម្ផស្សាយ កា-យសម្ផស្សាយ មនោសម្ផស្សាយ ពន្ធា រាគិពន្ធា អាពន្ធា លត្តា លត្តិតា បលិពុទ្ធាតិ ឥច្ឆានិទានា ភវសាតពន្ធា ។

---

១ ម. ឥសន្ទ្ធោ នត្ថិ ។ ២ ម. វេទនាយ សាតពន្ធា ។

គុហដ្ឋកសុត្តនិទ្ទេស ទី ២

សេចក្ដីត្រេកអរ ក្នុងការចម្រើន ២ គឺសុខវេទនា ១ វត្ថុជាទីប្រាជ្ញា ១ ។ សេចក្ដីត្រេកអរ ក្នុងការចម្រើន ៣ គឺភាពនៅក្មេង ១ ការមិនមានរោគ ១ ជីវិត ១ ។ សេចក្ដីត្រេកអរ ក្នុងការចម្រើន ៤ គឺលាភ ១ យស ១ សេចក្ដីសរសើរ ១ សុខ ១ ។ សេចក្ដីត្រេកអរ ក្នុងការចម្រើន៥ គឺរូបជាទីគាប់ចិត្ត ១ សំឡេងជាទីគាប់ចិត្ត ១ ក្លិនជាទីគាប់ចិត្ត ១ រសជាទីគាប់ចិត្ត ១ ផ្សព្វជាទីគាប់ចិត្ត ១ ។ សេចក្ដីត្រេកអរ ក្នុងការចម្រើន ៦ គឺចក្ខុសម្បទា ១ សោតសម្បទា ១ ឃានសម្បទា ១ ជិវ្ហាសម្បទា ១ កាយសម្បទា ១ មនោសម្បទា ១ ។ ពាក្យថា ជាប់ចំពាក់ដោយសេចក្ដីត្រេកអរ ក្នុងការចម្រើន គឺជាប់ក្នុងសុខវេទនា ជាប់ក្នុងវត្ថុជាទីប្រាជ្ញា ជាប់ក្នុងភាពនៅក្មេង ជាប់ក្នុងការមិនមានរោគ ជាប់ក្នុងជីវិត ជាប់ក្នុងលាភ ជាប់ក្នុងយស ជាប់ក្នុងសេចក្ដីសរសើរ ជាប់ក្នុងសុខ ជាប់ក្នុងរូបជាទីគាប់ចិត្ត ក្នុងសំឡេង ក្នុងក្លិន ក្នុងរស ជាប់ក្នុងផ្សព្វជាទីគាប់ចិត្ត ជាប់ក្នុងចក្ខុសម្បទា ជាប់ចំពាក់ ជាប់ដោយអាការផ្សេង ៗ ស្ងិត ទាក់ ជ្ពក់ ព័ន្ធពន្ធ ក្នុងសោតសម្បទា ឃានសម្បទា ជិវ្ហាសម្បទា កាយសម្បទា មនោសម្បទា ហេតុនោះ (ទ្រង់ត្រាស់ថា) មានសេចក្ដីប្រាជ្ញាជាហេតុ ជាប់ចំពាក់ដោយសេចក្ដីត្រេកអរ ក្នុងការចម្រើន ។

[៤៣] ហីនា ឧភ មចុមុខេ លបន្តីតិ ហីនា ឧភតិ ហីនេន កាយកម្មេន សម្ផ្ផាកតាតិ ហីនា ។ ហីនេន វចីកម្មេន សមន្ធាកតាតិ ហីនា ។ ហីនេន មនោកម្មេន សមន្ធាកតាតិ ហីនា ។ ហីនេន ចា-ណាតិចាតេន សមន្ធាកតាតិ ហីនា ។ ហីនេន អទិន្ន-ទានេន ។ ហីនេន កាមេសុមិច្ឆាចារេន ។ ហីនេន មុសាវាទេន ។ ហីនាយ ឥសុណាយ ភាចាយ ។ ហីនាយ ផរុសាយ ភាចាយ ។ ហីនេន សម្ផ្ផ្ឌ-ប្ប-ឡាបេន ។ ហីនាយ អភិជ្ឌាយ ។ ហីនេន ព្យាបាទេន ។ ហីនាយ មិច្ឆាទិដ្ឋិយា ។ ហីនេហិ សង្ខ្ហារេហិ ។

រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា លុះក្នុងតណ្ហា គឺនៅក្នុងតណ្ហា ទៅតាមតណ្ហា ផ្សាយទៅតាមតណ្ហា លិចចុះក្នុងតណ្ហា ជ្រាក់ក្នុងតណ្ហា (ត្រូវតណ្ហា) គ្របសង្កត់ហើយ មានចិត្ត (ត្រូវតណ្ហា) សង្កត់សង្កិនហើយ ។ ពាក្យថា កពទាំងឡាយ បានដល់ កាមកព រូបកព អរូបកព ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកសត្វនេះ ដែលលុះក្នុងអំណាចតណ្ហា ក្នុងកពទាំងឡាយ ។

[៥៣] អធិប្បាយពាក្យថា នរជនទាំងឡាយ ថោកទាប រមែងយំរៀបរាប់ ក្នុងមាត់នៃមច្ចុ ត្រង់ពាក្យថា នរជនទាំងឡាយថោកទាប គឺនរជនថោកទាប ព្រោះហេតុជាអ្នកប្រកបដោយកាយកម្ម ដ៏ថោកទាប ។ នរជនថោកទាប ព្រោះហេតុជាអ្នកប្រកបដោយវចីកម្ម ដ៏ថោកទាប ។ នរជនថោកទាប ព្រោះហេតុជាអ្នកប្រកបដោយមនោកម្ម ដ៏ថោកទាប ។ នរជនថោកទាប ព្រោះហេតុជាអ្នកប្រកបដោយបាណាតិបាត ដ៏ថោកទាប ។ ដោយអទិន្នាទាន ដ៏ថោកទាប ។ ដោយកាមេសុមិច្ឆាចារដ៏ថោកទាប ។ ដោយមុសាវាទ ដ៏ថោកទាប ។ ដោយបិសុណាវាចា ដ៏ថោកទាប ។ ដោយផរុសវាចា ដ៏ថោកទាប ។ ដោយសម្ផប្បលាបៈ ដ៏ថោកទាប ។ ដោយអភិជ្ឌា ដ៏ថោកទាប ។ ដោយព្យាបាទ ដ៏ថោកទាប ។ ដោយមិច្ឆាទិដ្ឋិ ដ៏ថោកទាប ។ ដោយសង្ខារទាំងឡាយ ដ៏ថោកទាប ។

ហីនេហិ បញ្ចហិ កាមគុណេហិ ។ ហីនេហិ បញ្ច-
ហិ នីវរណេហិ ។ ហីនាយ ចេតនាយ ។ ហីនាយ
បត្ថនាយ ។ ហីនាយ បណិធិយា សមន្ថ្នាគតាតិ ហីនា
និហីនា ឧមកា លាមកា ជតុក្ខ្លា បរិត្តាតិ ហីនា
ជរា ។ មចុ្ចមុខេ លបន្ដីតិ មចុ្ចមុខេ មារមុខេ មរណ-
មុខេ មចុ្ចប្ឍត្ដា មចុ្ចសម្ឍត្ដា មចុ្ចចាគតា មារប្ឍត្ដា
មារសម្ឍត្ដា មារុចាគតា មរណប្ឍត្ដា មរណសម្ឍត្ដា
មរណុចាគតា លបន្ដិ លាលបន្ដិ សោចន្ដិ កិលមន្ដិ
បរិដេវន្ដិ ឧរត្ដាឍ្ឍ ក្ខន្ធ្ដិ សម្មោហំ អាបជ្ជន្ដីតិ
ហីនា ជរា មចុ្ចមុខេ លបន្ដិ ។

[៥៤] អរីតតណ្ហាសេ ភវាភវេសូតិ តណ្ហាតិ
រូបតណ្ហា ។ បេ ។ ធម្មតណ្ហា ។ ភវាភវេសូតិ
ភវាភវេ កម្មភវេ បុនព្ភវេ កាមភវេ កម្មភវេ
កាមភវេ បុនព្ភវេ រូបភវេ កម្មភវេ រូបភវេ
បុនព្ភវេ អរូបភវេ កម្មភវេ អរូបភវេ បុនព្ភវេ

ដោយកាមគុណទាំង ៥ ដ៏ថោកទាប ។ ដោយនីវរណៈទាំង ៥ ដ៏ថោកទាប ។ ដោយចេតនា ដ៏ថោកទាប ។ ដោយសេចក្តីប្រាថ្នា ដ៏ថោកទាប ។ នរជនថោកទាប ថោកទាបពេក ទន់ទាប លាមក អាក្រក់ កម្ទេចកម្ទី ព្រោះហេតុជាអ្នកប្រកបដោយការតម្កល់ចិត្ត ដ៏ថោកទាប ហេតុនោះ (ទ្រង់ត្រាស់ថា) នរជនទាំងឡាយថោកទាប ។ ពាក្យថា រមែងយំរៀបរាប់ ក្នុងមាត់នៃមច្ចុ សេចក្តីថា ពួកជនដល់នូវមច្ចុ ដល់ព្រមនូវមច្ចុ ចូលទៅរកមច្ចុ ដល់នូវមារ ដល់ព្រមនូវមារ ចូលទៅរកមារ ដល់នូវមរណៈ ដល់ព្រមនូវមរណៈ ចូលទៅរកមរណៈ រមែងយំ យំរៀបរាប់ សោសោក លំបាក ខ្សឹកខ្ជួល គក់ទ្រូង ដល់នូវសេចក្តីវង្វេង ក្នុងមាត់នៃមច្ចុ ក្នុងមាត់នៃមារ ក្នុងមាត់នៃមរណៈ ហេតុនោះ (ទ្រង់ត្រាស់ថា) នរជនទាំងឡាយថោកទាប រមែងយំរៀបរាប់ ក្នុងមាត់នៃមច្ចុ ។

[៥៦] អធិប្បាយពាក្យថា មិនទាន់កន្ធងនូវតណ្ហា ក្នុងកពតូចនិងកពធំទាំងឡាយ ត្រង់ពាក្យថា តណ្ហា បានដល់ រូបតណ្ហា ។ បេ ។ ធម្មតណ្ហា ។ ពាក្យថា ក្នុងកពតូចនិងកពធំទាំងឡាយ គឺក្នុងកម្មកពបុនព្ភព ឈ្មោះថាក្នុងកពតូចនិងកពធំ គឺថាក្នុងកាមកព ឈ្មោះកម្មកពក្នុងកាមកព ឈ្មោះបុនព្ភព ក្នុងរូបកព ឈ្មោះកម្មកព ក្នុងរូបកព ឈ្មោះបុនព្ភព ក្នុងអរូបកព ឈ្មោះកម្មកព ក្នុងអរូបកព ឈ្មោះបុនព្ភព

បុនប្បុនំ ភវេ បុនប្បុនំ គតិយា បុនប្បុនំ ឧបបត្តិយា បុនប្បុនំ បដិសន្ធិយា បុនប្បុនំ អត្តភាវាភិនិព្វត្តិយា ។ អវីតតណ្ហាសេតិ អវីតតណ្ហា អវិគតតណ្ហា អច្ចត្ត-តណ្ហា អវន្តតណ្ហា អមុត្តតណ្ហា អប្បហីនតណ្ហា អប្បដិនិស្សដ្ឋតណ្ហាតិ អវីតតណ្ហាសេ ភវាភវេសុ ។ តេនាហ ភគវា

បស្សាមិ លោកេ បរិផន្ទមានំ
បជំ ឥមំ តណ្ហគតំ ភវេសុ
ហីនា នរា មច្ចុមុខេ លបន្តិ
អវីតតណ្ហាសេ ភវាភវេសូតិ ។

[៨៥] មមាយិតេ បស្សថ ផន្ទមានេ
មច្ឆេវ អប្បោទកេ ខីណសោតេ
ឯតម្បិ ទិស្វា អមមោ ចរេយ្យ
ភវេសុ អាសត្តិមកុព្វមានោ ។

[៨៦] មមាយិតេ បស្សថ ផន្ទមានេតិ មមត្តាតិ ទ្វេ មមត្តា តណ្ហាមមត្តញ្ច ទិដ្ឋិមមត្តញ្ច ។

គឺថា ក្នុងការកើតរឿយ ៗ ការទៅរឿយ ៗ ឧបបត្តិរឿយ ៗ បដិសន្ធិ
រឿយ ៗ ការញុំងអត្តភាព ឲ្យកើតឡើងរឿយ ៗ ។ ពាក្យថា មិនកន្ទ្ធ
តណ្ហា គឺ មិនកន្ទ្ធតណ្ហា មិនប្រាសចាកតណ្ហា មានតណ្ហាមិនឃ្ងាត
ចេញ មានតណ្ហាមិនខ្ជាក់ចោល មិនរួចចាកតណ្ហា មិនលះបង់តណ្ហា
មិនរលាស់ចោលតណ្ហា ហេតុនោះ (ទ្រង់ត្រាស់ថា) មិនកន្ទ្ធតណ្ហា
ក្នុងភពតូចនិងភពធំទាំងឡាយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

តថាគតឃើញនូវពួកសត្វនេះ ដែលលុះក្នុងអំណាចតណ្ហា
ក្នុងភពទាំងឡាយ កំពុងញាប់ញ័រក្នុងលោក នរជនទាំង-
ឡាយថោកទាប មិនកន្ទ្ធតណ្ហា ក្នុងភពតូចនិងភពធំ
ទាំងឡាយ រមែងយំរៀបរាប់ ក្នុងមាត់នៃមច្ចុ ។

[៥៥] អ្នកទាំងឡាយ ចូរមើលពួកសត្វដែលមានសេចក្តីអាល័យ
កំពុងញាប់ញ័រ ដូចពួកត្រីក្នុងទីមានទឹកតិច ទាំងមានខ្សែ
ទឹកអស់ហើយ បុគ្គលមិនមានអាល័យ លុះឃើញទោស
នេះហើយ គប្បីប្រព្រឹត្ត មិនធ្វើការជាប់ចំពាក់ ក្នុងភព
ទាំងឡាយ ។

[៥៦] អធិប្បាយពាក្យថា អ្នកទាំងឡាយ ចូរមើលពួកសត្វ ដែល
មានសេចក្តីអាល័យ កំពុងញាប់ញ័រ ត្រង់ពាក្យថា អាល័យ បានដល់
អាល័យ ២ យ៉ាង អាល័យគឺតណ្ហា ១ អាល័យគឺទិដ្ឋិ ១ ។

កតមំ តណ្ហាមមត្តំ ។ យាវតា តណ្ហាសង្ខ្យា-
តេន សីមកតំ មរិយាទិកតំ ឱធិកតំ បរិយន្តិកតំ
បរិក្ខិត្តំ មមាយិតំ ឥទំ មមំ ឯតំ មមំ ឯត្តកំ មមំ
ឯត្តាវតា មមំ មម រូបា សទ្ទា គន្ធា រសា ផោដ្ឋ-
ព្វា អត្ថរណា បាបុរណា ទាសីទាសា អជេឡកា
កុក្កុដសូករា ហត្ថិគវាស្សវឡវា ខេត្តំ វត្ថុ ហិរញ្ញ
សុវណ្ណំ គាមនិគមរាជធានិយោ រដ្ឋញ្ច ជនបទោ ច
កោសោ ច កោដ្ឋាគារញ្ច កេវលម្បិ មហាបឋវី
តណ្ហាវសេន មមាយតិ យាវតា អដ្ឋសតតណ្ហាវិបរីតំ
ឥទំ តណ្ហាមមត្តំ ។

កតមំ ទិដ្ឋិមមត្តំ ។ រីសតិវត្ថុកា សក្កាយទិដ្ឋិ
ទសវត្ថុកា មិច្ឆាទិដ្ឋិ ទសវត្ថុកា អន្តគ្គាហិកា ទិដ្ឋិ យា
ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារោ ទិដ្ឋិវិសូកា-
យិកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសញ្ញោជនំ គាហោ បដិគ្គាហោ
អភិនិវេសោ បរាមាសោ កុម្មគ្គោ មិច្ឆាបថោ មិច្ឆត្តំ
តិត្ថាយតនំ វិបរិយេសគ្គាហោ វិបរីតគ្គាហោ វិបល្លា-
សគ្គាហោ មិច្ឆាគាហោ អយាថាវកស្មឹ យាថាវកន្តិ
គាហោ យាវតា ទ្វាសដ្ឋី ទិដ្ឋិគតានិ ឥទំ ទិដ្ឋិមមត្តំ ។

អាល័យគឺតណ្ហា តើដូចម្តេច ។ កំណត់ដែន កំណត់ទី កំណត់ជួរ កំណត់ជុំវិញ ការហួងហែង ការអាល័យ ដោយចំណែកនៃតណ្ហា មានប្រមាណណាថា នេះរបស់អញ នុ៎ះរបស់អញ ប៉ុណ្ណោះរបស់អញ មានប្រមាណប៉ុណ្ណោះរបស់អញ រូប: សទ្ទ: គន្ធ: រស: ផោដ្ឋព្ព: របស់អញ គ្រឿងកម្រាល គ្រឿងស្មៀកពាក់ ខ្ញុំស្រី ខ្ញុំប្រុស ពពែ ចៀម មាន់ ជ្រូ ដំរី គោ សេះ លា ស្រែ ចម្ការ ប្រាក់ មាស ស្រុក និគម រាជធានី ដែន ជនបទ បន្ទាយ ឃ្លាំងរបស់អញ សូម្បីបុគ្គលប្រកាន់ផែនដីធំទាំងអស់ ដោយអំណាចនៃតណ្ហាទាំងតណ្ហាវិបរីត ១០៨ ជាកំណត់ នេះ ឈ្មោះថា អាល័យគឺតណ្ហា ។

អាល័យគឺទិដ្ឋិ តើដូចម្តេច ។ សក្កាយទិដ្ឋិ មានវត្ថុ ២០ មិច្ឆា-ទិដ្ឋិ មានវត្ថុ ១០ អន្តគ្គាហិកទិដ្ឋិ មានវត្ថុ ១០ ទិដ្ឋិណា មានសភាពយ៉ាងនេះ ដំណើរគឺទិដ្ឋិ ការសាំញ៉ាំគឺទិដ្ឋិ ផ្លូវលំបាកគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ ការញាប់ញ័រគឺទិដ្ឋិ សញ្ញោជន:គឺទិដ្ឋិ ការកាន់ ការប្រកាន់ ប្រកាន់មាំ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ភាពខុស កំពង់និងអណ្តូង ការកាន់ដោយការស្វែងរកខុស ការប្រកាន់វិបរីត ការវិបល្វាស ការកាន់ខុស ការប្រកាន់ក្នុងវត្ថុមិនពិត ថាជារបស់ពិត ទិដ្ឋិទាំង ៦២ ទាំងប៉ុន្មាន នេះ ឈ្មោះថា អាល័យគឺទិដ្ឋិ ។

មមាយិតេ បស្សថ ផន្ទមានេតិ មមាយិតវត្ថុអច្ឆេទសង្កិនោបិ ផន្ទន្តិ អច្ឆិជ្ជន្តេបិ ផន្ទន្តិ អច្ឆិន្នេបិ ផន្ទន្តិ មមាយិតវត្ថុវិបរិណាមសង្កិនោបិ ផន្ទន្តិ វិបរិណាមន្តេបិ ផន្ទន្តិ វិបរិណតេបិ ផន្ទន្តិ សម្ផន្ទន្តិ[១] វិប្ផន្ទន្តិ វេធន្តិ បវេធន្តិ សម្បវេធន្តិ[២] ឯវំ ផន្ទមានេ សម្ផន្ទមានេ វិប្ផន្ទមានេ វេធមានេ បវេធមានេ សម្បវេធមានេ បស្សថ ទក្ខថ ឱលោកេថ និជ្ឈាយថ ឧបបរិក្ខថាតិ មមាយិតេ បស្សថ ផន្ទមានេ ។

[៨៧] មច្ឆេវ អប្បោទកេ ខីណសោតេតិ យថា មច្ឆា អប្បោទកេ បរិត្តោទកេ ឧទកបរិយាទានេ កាកេហិ វា កុលលេហិ វា ពលាកេហិ វា បរិបាតិយមានា ឧក្ខិបិយមានា ខជ្ជមានា ផន្ទន្តិ សម្ផន្ទន្តិ វិប្ផន្ទន្តិ វេធន្តិ បវេធន្តិ សម្បវេធន្តិ ឯវមេវ បជា មមាយិតវត្ថុអច្ឆេទសង្កិនោបិ ផន្ទន្តិ

១ ឱ. ម. បផន្ទន្តិ សម្ផន្ទន្តិ ។ ២ ឱ. ម. វេធន្តិ បវេធន្តិ សម្បវេធន្តិ ។

ពាក្យថា ចូរមើលពួកសត្វដែលមានសេចក្តីអាល័យ កំពុងតែញាប់ញ័រ សេចក្តីថា ពួកនរជនមានសេចក្តីរង្គៀស ក្នុងការដណ្តើមយកវត្ថុ ដែលខ្ជូនអាល័យ ញាប់ញ័រខ្លះ កាលគេកំពុងដណ្តើមយក ញាប់ញ័រខ្លះ កាលវត្ថុដែលគេដណ្តើមយកហើយ ញាប់ញ័រខ្លះ មានសេចក្តីរង្គៀស ក្នុងការប្រែប្រួល នៃវត្ថុដែលខ្ជូនអាល័យ ញាប់ញ័រខ្លះ កាលវត្ថុដែលកំពុងប្រែប្រួល ញាប់ញ័រខ្លះ កាលវត្ថុដែលប្រែប្រួលហើយ ញាប់ញ័រខ្លះ ញាប់ញ័រខ្លាំង ញាប់ញ័រផ្សេង ៗ រន្ធត់ រន្ធត់ខ្លាំង រន្ធត់ដោយអាការទាំងពួង អ្នកទាំងឡាយ ចូរមើល ចូរឃើញ ចូរក្រឡេកមើល ចូរសម្ងឹងមើល ចូរពិចារណាមើល នូវពួកសត្វកំពុងញាប់ញ័រ ញាប់ញ័រដោយអាការទាំងពួង ញាប់ញ័រផ្សេងៗ រន្ធត់ រន្ធត់ខ្លាំង រន្ធត់ដោយអាការទាំងពួង យ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកទាំង-ឡាយ ចូរមើលពួកសត្វដែលមានសេចក្តីអាល័យ កំពុងញាប់ញ័រ ។

[៥៧] ពាក្យថា ដូចពួកត្រី ក្នុងទីមានទឹកតិច ទាំងមានខ្សែទឹកអស់ហើយ សេចក្តីថា ពួកត្រីក្នុងទីមានទឹកតិច មានទឹកស្ពួចស្ដើង មានទឹកអស់ហើយ ត្រូវពួកអ្នកក្តី ពួកត្រដក់ក្តី ពួកកុកក្តី ហៀតហៀនចឹកលើកឡើង ពាំស៊ី ក៏ញាប់ញ័រ ញាប់ញ័រសព្វ ញាប់ញ័រផ្សេង ៗ រន្ធត់ រន្ធត់ខ្លាំង រន្ធត់សព្វសាច់ យ៉ាងណាមិញ ពួកសត្វដែលមានសេចក្តីរង្គៀស ក្នុងការដណ្តើមយកវត្ថុដែលខ្ជូនអាល័យ ញាប់ញ័រខ្លះ

អច្ចិជ្ជន្តេបិ ផន្ទន្តិ អច្ចិន្ទេបិ ផន្ទន្តិ មមាយិតវត្ថុវិបរិ-ណាមសញ្ញិនោបិ ផន្ទន្តិ វិបរិណាមន្តេបិ ផន្ទន្តិ វិបរិ-ណាតេបិ ផន្ទន្តិ សម្ផន្ទន្តិ វិប្ផន្ទន្តិ វេធេន្តិ បវេធេន្តិ សម្ផវេធេន្តីតិ មច្ចេ អប្ផោ ឧកាទីណាសោតេ ។

[៤៨] ឯតម្ឫ ជិស្ស អមមោ ចវេយ្យាតិ ឯតំ អាទី-ណវំ ជិស្ស បស្ឫិត្ថ តុលយិត្ថ តីរយិត្ថ វិការយិត្ថ វិភ-ត្តំ ឥត្ថ មមត្តេសូតិ ឯតម្ឫ ជិស្ស ។ អមមោ ចវេ-យ្យាតិ មមត្តាតិ ទ្វេ មមត្តា តណ្ហាមមត្តញ្ច ទិដ្ឋិមម-ត្តញ្ច ។ បេ ។ ឥទំ តណ្ហាមមត្តំ ។ បេ ។ ឥទំ ទិដ្ឋិម-មត្តំ ។ តណ្ហាមមត្តំ បហាយ ទិដ្ឋិមមត្តំ បដិនិស្សជ្ជិត្ថ ចក្ខុំ អមមាយន្តោ សោតំ អមមាយន្តោ ឃានំ អមមា-យន្តោ ជិវ្ហំ អមមាយន្តោ កាយំ អមមាយន្តោ មនំ អមមាយន្តោ ១ូបេ សទ្ទេ គន្ធេ រសេ ផោដ្ឋព្ពេ ១ុលំ ១ណ្ហ អាវាសំ លាភំ យសំ បសំសំ សុខំ ចីវរំ បិណ្ឌាចាតំ សេនាសនំ ១ិលានប្ប្ចយ១ិសជ្ជបរិ១្ខារ

កាលគេកំពុងដណ្តើម ញាប់ញ័រខ្លះ កាលវត្ថុដែលគេ ដណ្តើមហើយ ញាប់ញ័រខ្លះ មានសេចក្តីរង្គៀសក្នុងការប្រែប្រួលនៃវត្ថុដែលខ្លួនអាល័យ ញាប់ញ័រខ្លះ កាលវត្ថុដែលកំពុងប្រែប្រួល ញាប់ញ័រខ្លះ កាលវត្ថុដែលប្រែប្រួលហើយ ញាប់ញ័រខ្លះ ញាប់ញ័រសព្វ ញាប់ញ័រផ្សេង ។ រន្ធត់ រន្ធត់ខ្លាំង រន្ធត់សព្វសាច់ ក៏យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) ដូចពួកត្រីក្នុងទីមានទឹកតិច ទាំងមានខ្សែទឹកអស់ហើយ ។

[៥៨] ពាក្យថា បុគ្គលមិនមានអាល័យ លុះឃើញទោសនេះ ហើយ គប្បីប្រព្រឹត្ត គឺឃើញ មើល ថ្វីង ពិចារណា សម្តែងឲ្យច្បាស់ ធ្វើឲ្យប្រាកដ នូវទោសនេះ ក្នុងអាល័យទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ឃើញទោសនេះ ។ ពាក្យថា អាល័យ ក្នុងបទថា បុគ្គលមិនមានអាល័យ គប្បីប្រព្រឹត្ត បានដល់អាល័យ ២ អាល័យគឺតណ្ហា ១ អាល័យគឺទិដ្ឋិ ១ ។ បេ ។ នេះ អាល័យគឺតណ្ហា ។ បេ ។ នេះ អាល័យគឺទិដ្ឋិ ។ បុគ្គលលះអាល័យគឺតណ្ហា រលាស់ចោលអាល័យ គឺទិដ្ឋិ មិនប្រកាន់ចក្ខុ មិនប្រកាន់សោត: មិនប្រកាន់ឃាន: មិនប្រកាន់ជិវ្ហា មិនប្រកាន់កាយ មិនប្រកាន់ចិត្ត មិនប្រកាន់ មិនទទួល មិនស្ទាបអង្អែល មិនប្រកាន់ស្អិត នូវរូប សំឡេង ក្លិន រស ផ្សព្វ ទាំងឡាយ ត្រកូល ពួក អាវាស លាភ យស សេចក្តីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសន: បរិក្ខារគឺថ្នាំ ជាបច្ច័យដល់ជំងឺ

កាមធាតុं រូបធាតុं អរូបធាតុं កាមភវं រូបភវं អរូបភវं សញ្ញាភវं អសញ្ញាភវं នេវសញ្ញានាសញ្ញាភវं ឯកវោការភវं ចតុវោការភវं បញ្ចវោការភវं អតីតं អនាគតं បច្ចុប្បន្នं ឥជ្ឌសុតមុត្តវិញ្ញាតព្ពេ ធម្មេ អមមាយន្តោ អត្តណ្ហន្តោ អបរាមសន្តោ អនភិនិវិសន្តោ ចរេយ្យ វិហរេយ្យ ឥរិយេយ្យ វត្តេយ្យ ចាលេយ្យ យបេយ្យ យាបេយ្យាតិ ឯតម្ហិ ឋិស្វា អមមោ ចរេយ្យ ។

[៤៩] ភវេសុ អាសត្តិមកុព្ពមានោតិ ភវេសូតិ កាមភវេ រូបភវេ អរូបភវេ ។ អាសត្តិ រុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឌា លោភោ អកុសលមូលं ។ ភវេសុ អាសត្តិមកុព្ពមានោតិ ភវេសុ អាសត្តឺ អកុព្ពមានោ ឆន្ទं បេមं រាគं ១ឦ អកុព្ពមានោ អជ្ឌនយមានោ អសញ្ជនយមានោ អនិព្ពត្តយមានោ អនភិនិព្ពត្តយមានោតិ ភវេសុ អាសត្តិមកុព្ពមានោ ។

កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព អតីត អនាគត បច្ចុប្បន្ន ធម៌ដែលគេគប្បីឃើញ ឮ ប៉ះពាល់ ឬដឹង គប្បីប្រព្រឹត្ត គប្បីនៅ ដោយសូប់ស្ងាត់ គប្បីញ៉ាំងឥរិយាបថឲ្យប្រព្រឹត្តទៅ គប្បីញ៉ាំងឥរិយាបថឲ្យកើតឡើង គប្បីរក្សាឥរិយាបថ គប្បីបំពេញឥរិយាបថ គប្បីបង្ក្រាប់ឥរិយាបថ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលអ្នកមិនមានអាល័យ លុះឃើញទោសនេះ ហើយ គប្បីប្រព្រឹត្ត ។

[៥៩] ពាក្យថា ក្នុងភពទាំងឡាយ ក្នុងបទថា មិនធ្វើការជាប់ចំពាក់ ក្នុងភពទាំងឡាយ គឺ ក្នុងកាមភព រូបភព អរូបភព ។ តណ្ហា លោកហៅថា ការជាប់ចំពាក់ បានដល់សេចក្តីត្រេកអរ សេចក្តីរីករាយ ដ៏មានកម្លាំង ។ បេ ។ អកិញ្ចា លោក: អកុ-សលមូល ។ ពាក្យថា មិនធ្វើការជាប់ចំពាក់ ក្នុងភពទាំងឡាយ បានសេចក្តីថា មិនធ្វើការជាប់ចំពាក់ ក្នុងភពទាំងឡាយ មិនធ្វើសេចក្តីពេញចិត្ត សេចក្តីស្រឡាញ់ សេចក្តីត្រេកអរ សេចក្តីអត់-ធន់ មិនឲ្យកើត មិនឲ្យកើតព្រម មិនបង្កើត មិនបង្កើតចំពោះ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនធ្វើការជាប់ចំពាក់ ក្នុងភពទាំងឡាយ ។

តេនាហ ភគវា

មមាយិតេ បស្សថ ផន្ទមានេ
មច្ឆេវ អប្បោទកេ ខីណសោតេ
ឯតម្បិ ទិស្វា អមមោ ចរេយ្យ
ភវេសុ អាសត្តិមកុព្វមានោតិ ។

[៦០] ឧភោសុ អន្តេសុ វិនេយ្យ ឆន្ទំ
ផស្សំ បរិញ្ញាយ អនានុគិទ្ធោ
យទត្តគរហី តទកុព្វមានោ
ន លិម្បតី(១) ទិដ្ឋសុតេសុ ធីរោ ។

[៦១] ឧភោសុ អន្តេសុ វិនេយ្យ ឆន្ទន្តិ អន្តាតិ ផស្សោ ឯកោ អន្តោ ផស្សសមុទយោ ទុតិយោ អន្តោ ។ អតីតោ ឯកោ អន្តោ អនាគតោ ទុតិយោ អន្តោ ។ សុខា វេទនា ឯកោ អន្តោ ទុក្ខា វេទនា ទុតិយោ អន្តោ ។ នាមំ ឯកោ អន្តោ រូបំ ទុតិយោ អន្តោ ។ ឆ អជ្ឈត្តិកានិ អាយតនានិ ឯកោ អន្តោ ឆ ពាហិរានិ អាយតនានិ ទុតិយោ អន្តោ ។ សក្កាយោ ឯកោ អន្តោ សក្កាយសមុទយោ ទុតិយោ អន្តោតិ ។

១ ន លិប្បតីតិបិ បាឋោ ។

ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

អ្នកទាំងឡាយ ចូរមើលពួកសត្ត្ব ដែលមានសេចក្តីអាល័យ កំពុងញាប់ញ័រ ដូចពួកត្រីក្នុងទីមានទឹកតិច ទាំងមានខ្សែ ទឹកអស់ហើយ បុគ្គលមិនមានអាល័យ លុះឃើញទោស នេះហើយ គប្បីប្រព្រឹត្ត មិនធ្វើការជាប់ចំពាក់ ក្នុងភព ទាំងឡាយ ។

[៦០] អ្នកប្រាជ្ញ រមែងបន្ទោបង់នូវសេចក្តីពេញចិត្ត ក្នុងទីបំផុត ទាំងពីរ រមែងកំណត់ដឹងផស្ស: ហើយជាអ្នកមិនជាប់ចំពាក់ ជាអ្នកតិះដៀលអំពើណាដោយខ្លួនឯង តែងមិនធ្វើអំពើនោះ មិនប្រឡាក់ក្នុងអារម្មណ៍ទាំងឡាយ ដែលខ្លួនឃើញហើយ ឮហើយឡើយ ។

[៦១] អធិប្បាយពាក្យថា រមែងបន្ទោបង់នូវសេចក្តីពេញចិត្តក្នុងទី បំផុត ទាំងពីរ ត្រង់ពាក្យថា ទីបំផុត គឺផស្ស: ជាទីបំផុតទី ១ ហេតុដែលកើតផស្ស: ជាទីបំផុតទី ២ ។ អតីតកាល ជាទីបំផុតទី ១ អនាគតកាល ជាទីបំផុតទី ២ ។ សុខវេទនា ជាទីបំផុតទី ១ ទុក្ខវេទនា ជាទីបំផុតទី ២ ។ នាម ជាទីបំផុតទី ១ រូប ជាទីបំផុតទី ២ ។ អាយតន: ខាងក្នុង ៦ ជាទីបំផុតទី ១ អាយតន:ខាងក្រៅ ៦ ជាទីបំផុតទី ២ ។ សក្កាយ: ជាទីបំផុតទី ១ ហេតុជាដែនកើតនៃសក្កាយ: ជាទីបំផុតទី ២ ។

ឆន្ទោតិ យោ កាមេសុ កាមច្ឆន្ទោ កាមរាគោ កាម-
នន្ទិ កាមតណ្ហា កាមស្នេហោ កាមបរិឡាហោ
កាមមុច្ឆា កាមជ្ឌោសានំ កាមោឃោ កាមយោ-
គោ កាមុចាជានំ កាមច្ឆន្ទនីវរណំ ។ ឧភោសុ
អន្តេសុ វិនេយ្យ ឆន្ទន្តិ ឧភោសុ អន្តេសុ ឆន្ទំ វិនេយ្យ
បជិវិនេយ្យ បជហេយ្យ វិនោនេយ្យ ព្យន្តីករេយ្យ
អនភាវន្តមេយ្យាតិ ឧភោសុ អន្តេសុ វិនេយ្យ ឆន្ទំ ។

[៦២] ផស្សំ បរិញ្ញាយ អនានុតិជ្ឌោតិ ផស្សោតិ
ចក្ខុសម្ផស្សោ សោតសម្ផស្សោ ឃានសម្ផស្សោ
ជិវ្ហាសម្ផស្សោ កាយសម្ផស្សោ មនោសម្ផស្សោ អធិ-
វចនសម្ផស្សោ បដិឃសម្ផស្សោ សុខវេទនីយោ សម្ផ-
ស្សោ ទុក្ខវេទនីយោ សម្ផស្សោ អទុក្ខមសុខវេទនី-
យោ សម្ផស្សោ កុសលោ ផស្សោ អកុសលោ
ផស្សោ អព្យាកតោ ផស្សោ កាមាវចរោ ផស្សោ
រូបាវចរោ ផស្សោ អរូបាវចរោ ផស្សោ សុញ្ញតោ
ផស្សោ អនិមិត្តោ ផស្សោ អប្ឌណិហិតោ ផស្សោ

ពាក្យថា សេចក្តីពេញចិត្ត បានដល់សេចក្តីពេញចិត្តគឺកាម សេចក្តី-ត្រេកអរគឺកាម សេចក្តីរីករាយគឺកាម ចំណង់គឺកាម សេចក្តីស្រឡាញ់គឺកាម សេចក្តីក្តៅក្រហាយគឺកាម សេចក្តីងល់ងប់គឺកាម សេចក្តីជ្រុលជ្រប់គឺកាម អន្ទង់គឺកាម យោគៈគឺកាម ឧបាទានគឺកាម នីវរណៈគឺកាមច្ឆន្ទៈ ក្នុងកាមទាំងឡាយ ។ ពាក្យថា រមែងបន្ទោបង់ នូវសេចក្តីពេញចិត្តក្នុងទីបំផុតទាំងពីរ បានសេចក្តីថា រមែងបន្ទោបង់ បន្ទោបង់ចំពោះ លះបង់ កម្ចាត់បង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវសេចក្តីពេញចិត្តក្នុងទីបំផុតទាំងពីរ ហេតុនោះ (ទ្រង់ត្រាស់ថា) រមែងបន្ទោបង់សេចក្តីពេញចិត្ត ក្នុងទីបំផុតទាំងពីរ ។

[៦២] អធិប្បាយពាក្យថា រមែងកំណត់ដឹងផស្សៈ ហើយជាអ្នកមិនជាប់ចំពាក់ ត្រង់ពាក្យថា ផស្សៈ បានដល់ចក្ខុសម្ផស្សៈ សោត-សម្ផស្សៈ ឃានសម្ផស្សៈ ជិវ្ហាសម្ផស្សៈ កាយសម្ផស្សៈ មនោ-សម្ផស្សៈ អធិវចនសម្ផស្សៈ បដិឃសម្ផស្សៈ សុខវេទនីយសម្ផស្សៈ ទុក្ខវេទនីយសម្ផស្សៈ អទុក្ខមសុខវេទនីយសម្ផស្សៈ កុសលផស្សៈ អកុសលផស្សៈ អព្យាកតផស្សៈ កាមាវចរផស្សៈ រូបាវចរផស្សៈ អរូបាវចរផស្សៈ សុញ្ញតផស្សៈ អនិមិត្តផស្សៈ អប្បណិហិតផស្សៈ

លោកិយោ ផស្សោ លោកុត្តរោ ផស្សោ អតីតោ ផស្សោ អនាគតោ ផស្សោ បច្ចុប្បន្នោ ផស្សោ យោ ឯវរូបោ ផស្សោ ផុសនា សម្ផុសនា សម្ផុសិតត្តំ អយំ វុច្ចតិ ផស្សោ ។ ផស្សំ បរិញ្ញាយាតិ ផស្សំ តីហិ បរិញ្ញាហិ បរិជានិត្វា ញាតបរិញ្ញាយ តិរណបរិញ្ញាយ បហានបរិញ្ញាយ ។

កតមា ញាតបរិញ្ញា ។ ផស្សំ ជានាតិ អយំ ចក្ខុសម្ផស្សោ អយំ សោតសម្ផស្សោ អយំ ឃានសម្ផស្សោ អយំ ជិវ្ហាសម្ផស្សោ អយំ កាយសម្ផស្សោ អយំ មនោសម្ផស្សោ អយំ អធិវចនសម្ផស្សោ អយំ បដិឃសម្ផស្សោ អយំ សុខវេទនីយោ ផស្សោ អយំ ទុក្ខវេទនីយោ ផស្សោ អយំ អទុក្ខមសុខវេទនីយោ ផស្សោ អយំ កុសលោ ផស្សោ អយំ អកុសលោ ផស្សោ អយំ អព្យាកតោ ផស្សោ អយំ កាមាវចរោ ផស្សោ អយំ រូបាវចរោ ផស្សោ អយំ អរូបាវចរោ ផស្សោ អយំ សុញ្ញតោ ផស្សោ អយំ អនិមិត្តោ ផស្សោ អយំ អប្បណិហិតោ ផស្សោ

លោកិយផស្ស: លោកុត្តរផស្ស: អតីតផស្ស: អនាគតផស្ស: បច្ចុប្បន្នផស្ស: ការប៉ះពាល់ អាការនៃការប៉ះពាល់ ការពាល់ត្រូវព្រម ភាពនៃការពាល់ត្រូវព្រម ណា មានសភាពយ៉ាងនេះ នេះ ហៅថា ផស្ស: ។ ពាក្យថា កំណត់ដឹងផស្ស: គឺកំណត់ដឹងផស្ស: ដោយ បរិញ្ញា ៣ គឺ ញាតបរិញ្ញា ១ តីរណបរិញ្ញា ១ បហានបរិញ្ញា ១ ។ ញាតបរិញ្ញា តើដូចម្តេច ។ (ភិក្ខុក្នុងសាសនានេះ) ដឹងនូវ ផស្ស: គឺដឹង ឃើញថា នេះ ចក្ខុសម្ផស្ស: នេះ សោតសម្ផស្ស: នេះ ឃានសម្ផស្ស: នេះ ជិវ្ហាសម្ផស្ស: នេះ កាយសម្ផស្ស: នេះ មនោសម្ផស្ស: នេះ អធិវចនសម្ផស្ស: នេះ បដិឃសម្ផស្ស: នេះ សុខវេទនីយផស្ស: នេះ ទុក្ខវេទនីយផស្ស: នេះ អទុក្ខមសុខវេទនីយ-ផស្ស: នេះ កុសលផស្ស: នេះ អកុសលផស្ស: នេះ អព្យាកតផស្ស: នេះ កាមាវចរផស្ស: នេះ រូបាវចរផស្ស: នេះ អរូបាវចរផស្ស: នេះ សុញ្ញតផស្ស: នេះ អនិមិត្តផស្ស: នេះ អប្បណិហិតផស្ស:

អយំ លោកិយោ ផស្សោ អយំ លោកុត្តរោ ផស្សោ អយំ អតីតោ ផស្សោ អយំ អនាគតោ ផស្សោ អយំ បច្ចុប្បន្នោ ផស្សោតិ ជានាតិ បស្សតិ អយំ ញាតបរិញ្ញា ។

កតមា តីរណបរិញ្ញា ។ ឯវំ ញាតំ កត្វា ផស្សំ តីរេតិ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្ល-តោ អឃតោ អាពាធតោ បរតោ បលោកតោ ឲ្យ-តិតោ ឧបទ្ទវតោ ភយតោ ឧបសគ្គតោ ចលតោ បភង្គុតោ អទ្ធុវតោ អត្តាណតោ អលេណតោ អស-រណតោ រិត្តតោ តុច្ឆតោ សុញ្ញតោ អនត្តតោ អាទី-នវតោ វិបរិណាមធម្មតោ អសារកតោ អឃមូលតោ វធកតោ វិភវតោ សាសវតោ សង្ខតតោ មារាមិស-តោ ជាតិធម្មតោ ជរាធម្មតោ ព្យាធិធម្មតោ មរណ-ធម្មតោ សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មតោ សង្ខ្លិលេសិកធម្មតោ សមុទយតោ អត្ថង្គមតោ អស្សាទតោ អាទីនវតោ និស្សរណតោ តីរេតិ អយំ តីរណបរិញ្ញា ។

នេះ លោកិយផស្ស: នេះ លោកុត្តរផស្ស: នេះ អតីតផស្ស: នេះ អនាគតផស្ស: នេះ បច្ចុប្បន្នផស្ស: នេះ ឈ្មោះថា ញាតបរិញ្ញា ។

តិរណបរិញ្ញា តើដូចម្តេច ។ (ភិក្ខុក្នុងសាសនានេះ) លុះធ្វើនូវការដឹងយ៉ាងនេះហើយ ពិចារណាផស្ស: គឺពិចារណាថា មិនទៀងថាជាទុក្ខ ជាពោគ ជាបូស ជាព្រួញ ជាសេចក្តីលំបាក ជាអាពាធ ជារបស់អ្នកដទៃ ជារបស់ទ្រុឌទ្រោម ជាចង្រៃ ជាឧបទ្រព ជាភ័យ ជាឧបស័គ្គ ជារបស់ញាប់ញ័រ ជារបស់ពុករលួយ ជារបស់មិនយឺនយូរ ជារបស់គ្មានទីពឹង គ្មានទីជ្រក គ្មានទីរលឹក ជារបស់ទទេ ជារបស់រលីងធេង ជារបស់សោះសូន្យ មិនមែនជារបស់ខ្លួន ជាទោស ជារបស់ប្រែប្រួលធម្មតា ជារបស់ឥតខ្វីម ជាឫសនៃទុក្ខ ជាពេជ្ឈឃាត គ្មានសេចក្តីចម្រើន ប្រកបដោយអាសវៈ មានបច្ច័យតាក់តែង ជាអាមិសៈនៃមារ មានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា មានមរណៈជាធម្មតា មានសោក: បរិទេវ: ទុក្ខ: ទោមនស្ស: ឧបាយាសៈជាធម្មតា ប្រកបដោយគ្រឿងសៅហ្មងជាធម្មតា ជារបស់កើតឡើង ជារបស់វិនាសទៅវិញ ជារបស់គួរត្រេកអរ ជាទោស ជាគ្រឿងរលាស់ចេញ នេះ ឈ្មោះថា តិរណបរិញ្ញា ។

កតមា បហានបរិញ្ញា ។ ឯវំ តិរយិត្វា ផស្ស ឆន្ទរាគំ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវ- គ្គ-មេតិ ។ រុត្តំ ហេតំ ភគវតា យោ ភិក្ខវេ ផស្ស-ឆន្ទរាគោ តំ បជហថ ឯវំ សោ ផស្ស-បហីនោ ភវិស្សតិ ឧច្ឆិន្ទមូលោ តាលាវត្ថុ-កតោ អនភាវ-ង្គ-តោ អាយតឹ អនុ-ប្ប-ាទ-ធ-ម្មោ ។ អយំ បហានបរិញ្ញា ។

ផ-ស្ស-ំ ប-រ-ិ-ញ-ា-យ-ា-ត-ិ ផ-ស្ស-ំ ឥ-ម-ា-ហ-ិ ត-ីហ-ិ ប-រ-ិ-ញ-ា-ហ-ិ ប-រ-ិ-ជ-ា-ន-ិ-ត្វ-ា ។ អ-ជ-ា-ន-ុ-ក-ិ-ន-្ទ-ោ-ត-ិ ក-េ-ន-ោ រ-ុ-ច-្ច-ត-ិ ត-ណ្ហ-ា-យ-ោ ភ-ា-ត-ោ ស-ា-ភ-ា-ត-ោ ។ ប-េ ។ អ-ក-ិ-ញ្ច-ា ល-ោ-ភ-ោ អ-ក-ុ-ស-ល-ម-ូ-ល-ំ ។ យ-ស-្ស-ោ ក-េ-ន-ោ ប-ហ-ីន-ោ ស-ម-ុ-ច-្ឆ-ិ-ន-្ទ-ោ រ-ូ-ប-ស-ន-្ត-ោ ប-ដ-ិ-ប-្ប-ស-្ស-ទ-្ធ-ោ អ-ភ-ព-្ព-ុ-ប-្ប-ត-្ត-ិ-ក-ោ ញ-ា-ណ-ាគ-្គ-ិ-ន-ា ឌ-ឌ-្ឍ-ា ស-ោ រ-ុ-ច-្ច-ត-ិ អ-ត-ិ-ទ-្ធ-ោ ។ ស-ោ រ-ូ-ប-េ អ-ត-ិ-ទ-្ធ-ោ ស-ទ-្ទ-េ អ-ត-ិ-ទ-្ធ-ោ ត-ន-្ទ-េ អ-ត-ិ-ទ-្ធ-ោ រ-ស-េ អ-ត-ិ-ទ-្ធ-ោ ផ-ោ-ដ-្ឋ-ព-្ព-េ អ-ត-ិ-ទ-្ធ-ោ ក-ុ-ល-េ ត-ណ-ោ

បហានបរិញ្ញា តើដូចម្តេច ។ (ភិក្ខុក្នុងសាសនានេះ) លុះពិចារណាយ៉ាងនេះហើយ ក៏លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវឆន្ទរាគក្នុងផស្សៈ ។ សមដូចជាព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឆន្ទរាគណា ក្នុងផស្សៈទាំង-ឡាយ អ្នកទាំងឡាយ ចូរលះបង់ឆន្ទរាគនោះចេញ កាលបើធ្វើយ៉ាងនេះបាន ផស្សៈនោះ ឈ្មោះថា អ្នកទាំងឡាយ បានលះបង់ហើយ ផ្តាច់ផ្តិលឫសគល់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាមិនមានទីកើតនៃដើមត្នោត ធ្វើមិនឲ្យកើតមាន ធ្វើឲ្យជាធម៌លែងកើត តទៅទៀតហើយ ។ នេះ ឈ្មោះថា បហានបរិញ្ញា ។

ពាក្យថា កំណត់ដឹងផស្សៈហើយ គឺកំណត់ដឹងផស្សៈ ដោយបរិញ្ញាទាំង ៣ នេះ ។ ពាក្យថា មិនជាប់ចំពាក់ អធិប្បាយថា តណ្ហា លោកហៅថា ការជាប់ចំពាក់ បានដល់សេចក្តីត្រេកអរ សេចក្តីត្រេកអរមានកម្លាំង ។ បេ ។ អកិញ្ចា លោកៈ អកុសលមូល ។ ការជាប់ចំពាក់ទុំ៖ បុគ្គលណាបានលះបង់ហើយ បានផ្តាច់ផ្តិលហើយ បានរម្ងាប់ហើយ បានរលាស់ចោលហើយ ធ្វើមិនឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមិនជាប់ចំពាក់ ។ បុគ្គលនោះ មិនជាប់ចំពាក់ក្នុងរូប មិនជាប់ចំពាក់ក្នុងសំឡេង មិនជាប់ចំពាក់ក្នុងក្លិន មិនជាប់ចំពាក់ក្នុងរស មិនជាប់ចំពាក់ក្នុងផ្សព្វ មិនជាប់ចំពាក់ក្នុងត្រកូល

អាវាសេ លាភេ យសេ បសំសាយ សុខេ ចីវរ-
បិណ្ឌាចាតេ សេនាសនេ គិលានប្បច្ចយភេសជ្ជ-
វិក្ខារេ កាមធាតុយា រូបធាតុយា អរូបធាតុយា
កាមភវេ រូបភវេ អរូបភវេ សញ្ញាភវេ អសញ្ញាភវេ
នេវសញ្ញានាសញ្ញាភវេ ឯកវោការភវេ ចតុវោការ-
ភវេ បញ្ចវោការភវេ អតីតេ អនាគតេ បច្ចុប្បន្នេ
ជិដ្ឋសុតមុតវិញ្ញាតព្វេសុ ធម្មេសុ អតិន្ធោ អតណ្ហិតោ
អមុច្ឆិតោ អនជ្ឌោបន្នោ រីតរាគោ វិគតរាគោ ចត្ត-
រាគោ វន្តរាគោ មុត្តរាគោ បហីនរាគោ បដិនិស្ស-
ដ្ឋរាគោ រីតភវោ វិគតភវោ ចត្តភវោ វន្តភវោ
មុត្តភវោ បហីនភវោ បដិនិស្សដ្ឋភវោ និច្ឆាតោ
និព្ពុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន
អត្តនា វិហរតីតិ ផស្សំ បរិញ្ញាយ អនានុកិន្ធោ ។

[៦៣] យទត្ថិ ករហិ តទកុព្ពមានោតិ យទត្ថិ យំ
អត្តនា ករហាតិ ។ ទ្វីហិ ការណេហិ អត្តានំ ករហាតិ
ការតត្តា ច អការតត្តា ច ។

ពួក អាវាស លាភ យស សេចក្តីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ គ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យដល់ជំងឺ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវ-សញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព អតីត អនាគត បច្ចុប្បន្ន ក្នុងធម៌ទាំងឡាយដែលឃើញ ឮ ប៉ះពាល់ ឬគប្បីដឹង មិនធ្លាក់ចុះ មិនជ្រុលជ្រប់ មិនងាប់ងប់ មានការជាប់ចំពាក់កន្ទ្ធងហើយ មានការជាប់ចំពាក់ទៅប្រាសហើយ មានការជាប់ជំពាក់លះហើយ មានការជាប់ចំពាក់ខ្ជាក់ចេលហើយ មានការជាប់ចំពាក់រួចហើយ មានការជាប់ចំពាក់លះបង់ហើយ មានការជាប់ចំពាក់រលាស់ចេលហើយ មានរាគៈកន្ទ្ធងហើយ មានរាគៈទៅប្រាសហើយ មានរាគៈលះហើយ មានរាគៈខ្ជាក់ចេលហើយ មានរាគៈរួចស្រឡះហើយ មានរាគៈលះបង់ហើយ មានរាគៈរលាស់ចេលហើយ មិនមានសេចក្តីប្រាថ្នា មានទុក្ខរលត់ហើយ មានសេចក្តីត្រជាក់ ទទួលចំពោះសេចក្តីសុខ សម្រេចនៅដោយចិត្តដ៏ប្រសើរ ហេតុនោះ (ទ្រង់ត្រាស់ថា) កំណត់ដឹងផស្សៈហើយ ជាអ្នកមិនជាប់ចំពាក់ ។

[៦៣] *អធិប្បាយពាក្យថា* តិះដៀលអំពើណាដោយខ្លួនឯង មិនធ្វើអំពើនោះ ត្រង់ពាក្យថា *អំពើណា* គឺតិះដៀលអំពើណាដោយខ្លួនឯង ។ *តិះដៀលខ្លួន* ព្រោះហេតុ ២ យ៉ាង គឺព្រោះអំពើដែលខ្លួនធ្វើហើយ និង

កថំ កតត្តា ច អកតត្តា ច អត្តានំ ករហតិ ។ កតំ មេ កាយទុច្ចរិតំ អកតំ មេ កាយសុចរិតន្តិ អត្តានំ ករហតិ ។ កតំ មេ វចីទុច្ចរិតំ អកតំ មេ វចីសុចរិតន្តិ អត្តានំ ករហតិ ។ កតំ មេ មនោ-ទុច្ចរិតំ អកតំ មេ មនោសុចរិតន្តិ អត្តានំ ករហតិ ។ កតោ មេ ចាណាតិចាតោ អកតា មេ ចាណាតិចា-តា វេរមណីតិ អត្តានំ ករហតិ ។ កតំ មេ អទិន្នា-ទានំ អកតា មេ អទិន្នាទានា វេរមណីតិ អត្តានំ ករហតិ ។ កតោ មេ កាមេសុ មិច្ឆាចារោ អក-តា មេ កាមេសុ មិច្ឆាចារា វេរមណីតិ អត្តានំ ករ-ហតិ ។ កតោ មេ មុសាវាទោ អកតា មេ មុសា-វាទា វេរមណីតិ អត្តានំ ករហតិ ។ កតា មេ បិសុ-ណា វាចា អកតា មេ បិសុណាយ វាចាយ វេរម-ណីតិ អត្តានំ ករហតិ ។ កតា មេ ផរុសា វាចា អក-តា មេ ផរុសាយ វាចាយ វេរមណីតិ អត្តានំ ករហតិ ។

អំពើដែលខ្លួន មិនបានធ្វើហើយ ។

តិះដៀលខ្លួនឯង ព្រោះអំពើដែលខ្លួនធ្វើហើយ និងអំពើដែលខ្លួនមិនបានធ្វើហើយ តើដូចម្តេច ។ បុគ្គល តិះដៀលខ្លួនឯងថា កាយទុច្ចរិត អាត្មាអញបានធ្វើហើយ កាយសុចរិត អាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងថា វចីទុច្ចរិត អាត្មាអញបានធ្វើហើយ វចីសុចរិត អាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងថា មនោ-ទុច្ចរិត អាត្មាអញបានធ្វើហើយ មនោសុចរិត អាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងថា បាណាតិបាត អាត្មាអញបានធ្វើហើយ ការវៀរចាកបាណាតិបាត អាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងថា អទិន្នា-ទាន អាត្មាអញបានធ្វើហើយ ការវៀរចាកអទិន្នាទាន អាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងថា កាមេសុមិច្ឆាចារ អាត្មាអញបានធ្វើហើយ ការវៀរចាកកាមេសុមិច្ឆាចារ អាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងថា មុសាវាទ អាត្មាអញបានធ្វើហើយ ការវៀរចាកមុសាវាទ អាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងថា បិសុណា-វាចា អាត្មាអញបានធ្វើហើយ ការវៀរចាកបិសុណាវាចា អាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងថា ផរុសវាចា អាត្មាអញបានធ្វើហើយ ការវៀរចាកផរុសវាចា អាត្មាអញ មិនបានធ្វើទេ ។

កតោ មេ សម្ផប្ផលាបោ អកតា មេ សម្ផប្ប-
លាបា វេរមណីតិ អត្ថាំ ករហតិ ។ កតា មេ
អភិជ្ឌា អកតា មេ អនភិជ្ឌាតិ អត្ថាំ ករហតិ ។
កតោ មេ ព្យាបាទោ អកតោ មេ អព្យាបាទោតិ
អត្ថាំ ករហតិ ។ កតា មេ មិច្ឆាទិដ្ឋិ អកតា មេ
សម្មាទិដ្ឋីតិ អត្ថាំ ករហតិ ។ ឯវំ កតត្តា ច
អកតត្តា ច អត្ថាំ ករហតិ ។ អថវា សីលេសុម្ហិ
ន បរិបូរិការីតិ អត្ថាំ ករហតិ ។ ឥន្ទ្រិយេសុម្ហិ
អគុត្តទ្វារោតិ អត្ថាំ ករហតិ ។ ភោជនេ អមត្តញ្ញុ-
ម្ហីតិ អត្ថាំ ករហតិ ។ ជាគរិយំ អននុយុត្តោម្ហីតិ
អត្ថាំ ករហតិ ។ ន សតិសម្ផជ្ជេន សមន្នាគ-
តោម្ហីតិ អត្ថាំ ករហតិ ។ អការិតា មេ ចត្តារោ
សតិប្ផ្ឋានាតិ អត្ថាំ ករហតិ ។ អការិតា មេ
ចត្តារោ សម្ផប្ផធានាតិ អត្ថាំ ករហតិ ។ អការិតា
មេ ចត្តារោ ឥទ្ធិបាទាតិ អត្ថាំ ករហតិ ។
អការិតានិ មេ បញ្ចិន្ទ្រិយានីតិ អត្ថាំ ករហតិ ។

តិះដៀលខ្លួនឯងថា សម្ផប្ផលាបៈ អាត្មាអញបានធ្វើហើយ ការវៀរចាកសម្ផប្ផលាបៈ អាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងថា អកិញ្ចា អាត្មាអញបានធ្វើហើយ អនកិញ្ចា អាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងថា ព្យាបាទ អាត្មាអញបានធ្វើហើយ អព្យាបាទ អាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងថា មិច្ឆាទិដ្ឋិ អាត្មាអញបានធ្វើហើយ សម្មាទិដ្ឋិ អាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯង ព្រោះអំពើដែលខ្លួនបានធ្វើហើយ និងអំពើដែលខ្លួន មិនបានធ្វើហើយ យ៉ាងនេះឯង ។ ម្យ៉ាងទៀត បុគ្គលតិះដៀលខ្លួនឯងថា អាត្មាអញជាអ្នកមិនបានធ្វើឲ្យពេញលេញ ក្នុងសីលទាំងឡាយ ។ តិះដៀលខ្លួនឯងថា អាត្មាអញជាអ្នកមិនបានគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ។ តិះដៀលខ្លួនឯងថា អាត្មាអញជាអ្នកមិនដឹងប្រមាណក្នុងភោជន ។ តិះដៀលខ្លួនឯងថា អាត្មាអញជាអ្នកមិនប្រកបរឿយ ៗ នូវការភ្ញាក់រឭក ។ តិះដៀលខ្លួនឯងថា អាត្មាអញជាអ្នកមិនប្រកបដោយសតិសម្ផជញ្ញៈ ។ តិះដៀលខ្លួនឯងថា សតិប្ផដ្ឋានទាំង ៤ អាត្មាអញមិនបានចម្រើនទេ ។ តិះដៀលខ្លួនឯងថា សម្ផប្ផធានទាំង ៤ អាត្មាអញមិនបានចម្រើនទេ ។ តិះដៀលខ្លួនឯងថា ឥទ្ធិបាទទាំង ៤ អាត្មាអញមិនបានចម្រើនទេ ។ តិះដៀលខ្លួនឯងថា ឥន្ទ្រិយទាំង ៥ អាត្មាអញមិនបានចម្រើនទេ ។

អការិតានិ មេ បញ្ញ ពលានីតិ អត្ថានំ តរហតិ ។ អការិតា មេ សត្ត ពោជ្ឌ ង្គាតិ អត្ថានំ តរហតិ ។ អការិតោ មេ អរិយោ អដ្ឌ ង្គិកោ មគ្គោតិ អត្ថានំ តរហតិ ។ ឧ ក្ខ ំ មេ អ ប រ ិ ញ្ ញ ាត ន្ តិ អ ត្ថ ានំ ត រ ហ ត ិ ។ សមុ ឧ យ ោ ម េ អ ប ្ ប ហ ី ណ ោ ត ិ អ ត ្ ថ ានំ ត រ ហ ត ិ ។ មគ្គោ មេ អការិតោតិ អត្ថានំ តរហតិ ។ និ រ ោ ធ ោ ម េ អ ស ច ្ ឆ ិ ក ត ោ ត ិ អ ត ្ ថ ានំ ត រ ហ ត ិ ។ ឯ រ ំ ក ត ត ្ ថ ា ច អ ក ត ត ្ ថ ា ច អ ត ្ ថ ានំ ត រ ហ ត ិ ។ ឯ រ ំ អ ត ្ ត ក ា ម ី យ ំ ក ម ្ ម ំ អ ក ុ ព ្ ព ម ា ណ ោ អ ជ ន យ ម ា ណ ោ អ ស ញ ្ ជ ន - យ ម ា ណ ោ អ ន ិ ព ្ ព ត ្ ត យ ម ា ណ ោ អ ន ភ ិ ន ិ ព ្ ព ត ្ ត យ ម ា ណ ោ ត ិ យ ឧ ត ្ ត ក ា ម ី ត ឧ ក ុ ព ្ ព ម ា ណ ោ ។

[៦៤] ន លិ ម ្ ព ត ី ជ ិ ដ ្ ឋ ស ុ ត េ ស ុ ជ ី ព ោ ត ិ ។ ទ្វេ លេ ច ា ត ណ ្ ហ ា ល េ ច ោ ច ជ ិ ដ ្ ឋ ិ ល េ ច ោ ច ។ ប េ ។ អ យ ំ ត ណ ្ ហ ា ល េ ច ោ ។ ប េ ។ អ យ ំ ជ ិ ដ ្ ឋ ិ ល េ ច ោ ។

តិះដៀលខ្លួនឯងថា ពលៈទាំង ៥ អាត្មាអញមិនបានចម្រើនទេ ។ តិះដៀលខ្លួនឯងថា ពោជ្ឌង្គទាំង ៧ អាត្មាអញមិនបានចម្រើនទេ ។ តិះដៀលខ្លួនឯងថា អរិយមគ្គប្រកបដោយអង្គ ៨ អាត្មាអញមិនបានចម្រើនទេ ។ តិះដៀលខ្លួនឯងថា ទុក្ខ អាត្មាអញមិនបានកំណត់ទេ ។ តិះដៀលខ្លួនឯងថា សមុទយៈ អាត្មាអញមិនបានលះបង់ទេ ។ តិះដៀលខ្លួនឯងថា មគ្គ អាត្មាអញមិនបានចម្រើនទេ ។ តិះដៀលខ្លួនឯងថា និរោធ អាត្មាអញមិនបានធ្វើឲ្យជាក់ច្បាស់ទេ ។ តិះដៀលខ្លួនឯង ព្រោះអំពើដែលបានធ្វើហើយ និងអំពើដែលខ្លួនមិនបានធ្វើហើយ យ៉ាងនេះឯង ។ អ្នកប្រាជ្ញមិនធ្វើ គឺមិនឲ្យកើត មិនឲ្យកើតព្រម មិនបង្កើត មិនបង្កើតចំពោះនូវអំពើដែលគួរតិះដៀលខ្លួន យ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកប្រាជ្ញ ជាអ្នកតិះដៀលអំពើណាដោយខ្លួនឯង តែងមិនធ្វើអំពើនោះ ។

[៦២] *អធិប្បាយពាក្យថា អ្នកប្រាជ្ញមិនប្រឡាក់ក្នុងអារម្មណ៍ទាំងឡាយដែលខ្លួនឃើញហើយ ឮហើយ ត្រង់ពាក្យថា ការប្រឡាក់ បានដល់ការប្រឡាក់ ២ ការប្រឡាក់គឺតណ្ហា ១ ការប្រឡាក់គឺទិដ្ឋិ ១ ។ បេ ។ នេះ ឈ្មោះថាការប្រឡាក់គឺតណ្ហា ។ បេ ។ នេះ ឈ្មោះថាការប្រឡាក់គឺទិដ្ឋិ ។*

ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

ជីវោតិ ជីវោ បណ្ឌិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវី ។ ជីវោ តណ្ហាលេបំ បហាយ ទិដ្ឋិលេបំ បដិនិស្សជ្ជិត្វា ទិដ្ឋេ ន លិម្ពតិ សុតេ ន លិម្ពតិ មុតេ ន លិម្ពតិ វិញ្ញាតេ ន លិម្ពតិ ន សំលិម្ពតិ ន ឧបលិម្ពតិ អលិត្តោ អសំលិត្តោ អនុបលិត្តោ និក្ខន្តោ និស្សដ្ឋោ វិប្ប មុត្តោ វិសញ្ញុត្តោ វិមរិយា-ទិកតេន[1] ចេតសា វិហរតីតិ ន លិម្ពតី ទិដ្ឋសុ-តេសុ ជីវោ ។ តេនាហ ភគវា

ឧភោសុ អន្តេសុ វិនេយ្យ ឆន្ទំ
ផស្សំ បរិញ្ញាយ អនានុតិជ្ឌោ
យទត្ថករហី តទកុព្ជមានោ
ន លិម្ពតី ទិដ្ឋសុតេសុ ជីវោតិ ។

---

១ ម. វិបរិយាទិកតេន ។

អ្នកមានប្រាជ្ញា បណ្ឌិត អ្នកមានការដឹងសព្វ អ្នកមានការត្រាស់ដឹង អ្នកមានញាណ អ្នកមានប្រាជ្ញាភ្ជឿច្បាស់ អ្នកមានប្រាជ្ញាជាគ្រឿងទម្លាយ បង់នូវកិលេស ឈ្មោះថា អ្នកប្រាជ្ញ ។ អ្នកប្រាជ្ញបានលះបង់ នូវការ ប្រឡាក់គឺតណ្ហា រលាស់ចោលនូវការប្រឡាក់គឺទិដ្ឋិ មិនប្រឡាក់ក្នុង អារម្មណ៍ដែលឃើញហើយ មិនប្រឡាក់ក្នុងអារម្មណ៍ ដែលឮហើយ មិន ប្រឡាក់ក្នុងអារម្មណ៍ ដែលទទួលហើយ មិនប្រឡាក់ មិនសៅហ្មង មិន ចូលទៅជិតលាបក្នុងអារម្មណ៍ ដែលដឹងច្បាស់ហើយ គឺជាអ្នកមិនប្រឡាក់ មិនសៅហ្មង មិនចូលទៅជិតលាប ឃ្វាតចេញ រលាស់ចេញ រួចស្រឡះ ប្រាសចេញ សម្រេចនៅដោយចិត្ត ដែលប្រាសចាកដែនគឺកិលេស ហេតុ នោះ (ទ្រង់ត្រាស់ថា) អ្នកប្រាជ្ញ មិនប្រឡាក់ ក្នុងអារម្មណ៍ ដែលខ្លួន ឃើញហើយ ឮហើយ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

អ្នកប្រាជ្ញ រមែងបន្ទោបង់នូវសេចក្តីពេញចិត្ត ក្នុងទីបំផុត
ទាំងពីរ រមែងកំណត់ដឹងផស្សៈ ហើយជាអ្នកមិនជាប់ចំពាក់
ជាអ្នកតិះដៀលអំពើណាដោយខ្លួនឯង តែងមិនធ្វើអំពើនោះ
មិនប្រឡាក់ក្នុងអារម្មណ៍ ដែលខ្លួនឃើញហើយឮហើយ ។

[៦៥] សញ្ញំ បរិញ្ញា វិតរេយ្យ ឱឃំ
បរិក្ខីណសេ មុនិ នោបលិត្តោ
អត្ថង្គតស្ស ចរមប្ជមត្ថោ
ជាសីសតី លោកមិមំ បរញ្ច ។

[៦៦] សញ្ញំ បរិញ្ញា វិតរេយ្យ ឱឃន្តិ សញ្ញាតិ កាមសញ្ញា ព្យាបាទសញ្ញា វិហឹសាសញ្ញា នេក្ខម្ម-សញ្ញា អព្យាបាទសញ្ញា អវិហឹសាសញ្ញា រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា ធម្មសញ្ញា យា ឯវ្ហេ សញ្ញា សញ្ជានតា សញ្ជា-និតត្តំ អយំ ឧច្ចតិ សញ្ញា ។ សញ្ញំ បរិញ្ញាតិ សញ្ញ តីហិ បរិញ្ញាហិ បរិជានិត្វា ញាតបរិញ្ញាយ តីរណ-បរិញ្ញាយ បហានបរិញ្ញាយ ។

កតមា ញាតបរិញ្ញា ។ សញ្ញ ជានាតិ អយំ កាមសញ្ញា អយំ ព្យាបាទសញ្ញា អយំ វិហឹសាសញ្ញ អយំ នេក្ខម្មសញ្ញ អយំ អព្យាបាទសញ្ញ អយំ អវិហឹសាសញ្ញ អយំ រូបសញ្ញ អយំ សទ្ទសញ្ញ អយំ គន្ធសញ្ញ អយំ រសសញ្ញ អយំ ផោដ្ឋព្វសញ្ញ

[៦៥] *មុនិ កំណត់ដឹងសញ្ញាហើយ គប្បីធ្វើដ្ឋិយៈបាន ជាអ្នក*
មិនប្រឡាក់ ក្នុងសេចក្ដីហួងហែងទាំងឡាយ ជាអ្នកមាន
ព្ពួញដកឡើងហើយ ប្រព្រឹត្តមិនប្រហែស មិនប្រាថ្នានូវ
លោកនេះ និងលោកដទៃ ។

[៦៦] *អធិប្បាយពាក្យថា កំណត់ដឹងសញ្ញាហើយ គប្បីធ្វើដ្ឋិយៈបាន ត្រង់ពាក្យថា សញ្ញា បានដល់កាមសញ្ញា ព្យាបាទសញ្ញា វិហឹសាសញ្ញា នេក្ខម្មសញ្ញា អព្យាបាទសញ្ញា អវិហឹសាសញ្ញា រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា ធម្មសញ្ញា សេចក្ដីសម្គាល់ អាការនៃសេចក្ដីសម្គាល់ ភាពនៃអារម្មណ៍ ដែលបុគ្គលសម្គាល់ ណា មានសភាព យ៉ាងនេះ នេះលោកហៅថា សញ្ញា ។ ពាក្យថា កំណត់ដឹងនូវសញ្ញា គឺ កំណត់ដឹង នូវសញ្ញា ដោយបរិញ្ញា ៣ គឺ ញាតបរិញ្ញា ១ តីរណបរិញ្ញា ១ បហានបរិញ្ញា ១ ។*

ញាតបរិញ្ញា តើដូចម្ដេច ។ ភិក្ខុដឹងនូវសញ្ញា គឺ ដឹង ឃើញថា នេះកាមសញ្ញា នេះព្យាបាទសញ្ញា នេះវិហឹសាសញ្ញា នេះនេក្ខម្ម-សញ្ញា នេះអព្យាបាទសញ្ញា នេះអវិហឹសាសញ្ញា នេះរូបសញ្ញា នេះសទ្ទសញ្ញា នេះគន្ធសញ្ញា នេះរសសញ្ញា នេះផោដ្ឋព្វសញ្ញា

អយំ ធម្មសញ្ញាតិ ជានាតិ បស្សតិ អយំ ញាតបរិញ្ញា ។

កតមា តីរណបរិញ្ញា ។ ឯវំ ញាតំ កត្វា សញ្ញ តីរេតិ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្ល-តោ អឃតោ អាពាធតោ បរតោ បលោកតោ ឲ្ជ-តិតោ ឧបទ្ទវតោ ភយតោ ឧបសគ្គតោ ចលតោ បភង្គុតោ ។ បេ ។ សមុទយតោ អត្ថង្គមតោ អស្ស-ទតោ អាទីនវតោ និស្សរណតោ តីរេតិ អយំ តីរណបរិញ្ញា ។

កតមា បហានបរិញ្ញា ។ ឯវំ តីរេត្វា សញ្ញាយ ឆន្ទរាគំ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវ-ម្ភេតិ ។ រុត្តំ ហេតំ ភគវតា យោ ភិក្ខវេ សញ្ញាយ ឆន្ទរាគោ តំ បជហថ ឯវំ សា សញ្ញា បហីនា ភវិស្សតិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវ-ម្ភតា អាយតឹ អនុប្ប្ទ្ធ-ធម្មាតិ ។ អយំ បហានបរិញ្ញា ។

នេះធម្មសញ្ញា ដូច្នេះ នេះ ឈ្មោះថា ញាតបរិញ្ញា ។

តិរណបរិញ្ញា តើដូចម្តេច ។ (ភិក្ខុ) លុះធ្វើនូវការដឹងយ៉ាងនេះហើយ ពិចារណានូវសញ្ញាគឺពិចារណាថា មិនទៀង ថាជាទុក្ខ ជារោគ ជាពក ជាព្រួញ ជាសេចក្តីលំបាក ជាអាពាធ ជារបស់បុគ្គលដទៃ ជារបស់វិនាស ជាចង្រៃ ជាឧបទ្រព ជាភ័យ ជាឧបស័គ្គ ជារបស់ក្រៀម ជារបស់ពុករលួយ ។ បេ ។ ជាគ្រឿងកើតឡើង ជាគ្រឿងដល់នូវសេចក្តីវិនាស ជាគ្រឿងត្រេកអរ ជាទោស ជាការរលាស់ចេញ នេះ ឈ្មោះថា តិរណបរិញ្ញា ។

បហានបរិញ្ញា តើដូចម្តេច ។ (ភិក្ខុ) លុះពិចារណា យ៉ាងនេះហើយ ក៏លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានឆន្ទរាគក្នុងសញ្ញា ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ ឆន្ទរាគណាក្នុងសញ្ញា អ្នកទាំងឡាយ ចូរលះបង់ឆន្ទរាគនោះចេញ កាលបើធ្វើយ៉ាងនេះបាន សញ្ញានោះ ឈ្មោះថាអ្នកទាំង-ឡាយលះបង់ហើយ ផ្តាច់ផ្តិលឫសគល់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ធ្វើឲ្យលែងកើតមាន ធ្វើឲ្យជាធម៌លែងកើតតទៅទៀត ។ នេះ ឈ្មោះថា បហានបរិញ្ញា ។

សញ្ញំ បរិញ្ញាតិ សញ្ញំ ឥមាហិ តីហិ បរិញ្ញាហិ បរិជានិត្វា ។ វិតរេយ្យ ឱឃន្តិ កាមោឃំ ភវោឃំ ទិដ្ឋោឃំ អវិជ្ជោឃំ វិតរេយ្យ ឧត្តរេយ្យ បតរេយ្យ សមតិក្កមេយ្យ វីតិវត្តេយ្យាតិ សញ្ញំ បរិញ្ញា វិតរេយ្យ ឱឃំ ។

[៦៧] បរិគ្គហេសុ មុនិ នោបលិត្តោតិ បរិគ្គហាតិ ទ្វេ បរិគ្គហា តណ្ហាបរិគ្គហោ ច ទិដ្ឋិបរិគ្គហោ ច ។ បេ ។ អយំ តណ្ហាបរិគ្គហោ ។ បេ ។ អយំ ទិដ្ឋិបរិគ្គហោ ។ មុនីតិ មោនំ វុច្ចតិ ញាណំ យា បញ្ញា បជានានា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ តេន ញាណេន សមន្នាគតោ មុនិ មោនប្បត្តោតិ ។ តីណិ មោនេយ្យានិ កាយមោនេយ្យំ វចីមោនេយ្យំ មនោមោនេយ្យំ ។

កតមំ កាយមោនេយ្យំ ។ តិវិធានំ កាយទុច្ចរិតានំ បហានំ កាយមោនេយ្យំ ។ តិវិធំ កាយសុចរិតំ កាយមោនេយ្យំ ។ កាយារម្មណំ ញាណំ កាយមោនេយ្យំ ។ កាយបរិញ្ញា កាយមោនេយ្យំ ។

ពាក្យថា កំណត់ដឹងសញ្ញា គឺកំណត់ដឹងសញ្ញាដោយបរិញ្ញា ៣ នេះ ។ ពាក្យថា គប្បីធ្វើឱ្យ:បាន គឺគប្បីធ្វើ ធ្វើឡើង កន្ទ្ធ ប្រព្រឹត្តកន្ទ្ធ នូវកាមោឃ: ភវោឃ: ទិដ្ឋោឃ: អវិជ្ជោឃ: ហេតុ នោះ (ទ្រង់ត្រាស់ថា) កំណត់ដឹងសញ្ញាហើយ គប្បីធ្វើឱ្យ:បាន ។

[៦៧] អធិប្បាយពាក្យថា មុនិ ជាអ្នកមិនប្រឡាក់ក្នុងសេចក្តីហួងហែងទាំងឡាយ ត្រង់ពាក្យថា សេចក្តីហួងហែងទាំងឡាយ បានដល់ សេចក្តីហួងហែង ២ គឺ សេចក្តីហួងហែងគឺតណ្ហា ១ សេចក្តីហួងហែងគឺទិដ្ឋិ ១ ។ បេ ។ នេះ ឈ្មោះថា សេចក្តីហួងហែងគឺតណ្ហា ។ បេ ។ នេះ ឈ្មោះថា សេចក្តីហួងហែងគឺទិដ្ឋិ ។ ពាក្យថា មុនិ អធិប្បាយថា ការដឹង លោកហៅថា មោន: បានដល់បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការសន្សំធម៌ ការយល់ឃើញត្រូវ មុនិ ប្រកបព្រមដោយការដឹងនោះ ឈ្មោះថា អ្នកដល់នូវមោន: ។ មោនេយ្ យ:មាន ៣ គឺ កាយមោនេយ្ យ: ១ វចីមោនេយ្ យ: ១ មនោមោនេយ្ យ: ១ ។

កាយមោនេយ្ យ: តើដូចម្តេច ។ ការលះបង់កាយទុច្ចរិត ៣ យ៉ាង ឈ្មោះថា កាយមោនេយ្ យ: ។ កាយសុចរិត ៣ យ៉ាង ឈ្មោះថា កាយ-មោនេយ្ យ: ។ ញាណមានកាយជាអារម្មណ៍ ឈ្មោះថា កាយមោ-នេយ្ យ: ។ ការកំណត់ដឹងកាយ ឈ្មោះថា កាយមោនេយ្ យ: ។

បរិញ្ញាសហគតោ មគ្គោ កាយមោនេយ្យំ ។ កាយេ ឆន្ទរាគស្ស បហានំ កាយមោនេយ្យំ ។ កាយសង្ខារនិរោធោ ចតុត្ថជ្ឌានសមាបត្តិ កាយមោនេយ្យំ ។ ឥទំ កាយមោនេយ្យំ ។

កតមំ វចីមោនេយ្យំ ។ ចតុព្វិធានំ វចីទុច្ចរិតានំ បហានំ វចីមោនេយ្យំ ។ ចតុព្វិធំ វចីសុចរិតំ វចីមោនេយ្យំ ។ វាចាវម្មណំ ញាណំ វចីមោនេយ្យំ ។ វាចាបរិញ្ញា វចីមោនេយ្យំ ។ បរិញ្ញាសហគតោ មគ្គោ វចីមោនេយ្យំ ។ វាចាយ ឆន្ទរាគស្ស បហានំ វចីមោនេយ្យំ ។ វចីសង្ខារនិរោធោ ទុតិយជ្ឌានសមាបត្តិ វចីមោនេយ្យំ ។ ឥទំ វចីមោនេយ្យំ ។

កតមំ មនោមោនេយ្យំ ។ តិវិធានំ មនោទុច្ចរិតានំ បហានំ មនោមោនេយ្យំ ។ តិវិធំ មនោសុចរិតំ មនោមោនេយ្យំ ។ ចិត្តាវម្មណំ ញាណំ មនោមោនេយ្យំ ។ ចិត្តបរិញ្ញា មនោមោនេយ្យំ ។ បរិញ្ញាសហគតោ មគ្គោ មនោមោនេយ្យំ ។ ចិត្តេ ឆន្ទរាគស្ស បហានំ មនោមោនេយ្យំ ។

មគ្គប្រព្រឹត្តទៅមួយអន្ទើ ដោយការកំណត់ដឹង ឈ្មោះថា កាយមោ-នេយ្យ: ។ ការលះបង់ធន្ទរាគក្នុងកាយ ឈ្មោះថា កាយមោនេយ្យ: ។ ចតុត្ថជ្ឌានសមាបត្តិ ដែលរំលត់កាយសង្ខារ ឈ្មោះថា កាយមោ-នេយ្យ: ។ នេះ ឈ្មោះថា កាយមោនេយ្យ: ។

វចីមោនេយ្យ: តើដូចម្តេច ។ ការលះបង់វចីទុច្ចរិត ៤ យ៉ាង ឈ្មោះថា វចីមោនេយ្យ ។ វចីសុចរិត ៤ យ៉ាង ឈ្មោះថា វចីមោនេយ្យ: ។ ញាណមានវាចាជាអារម្មណ៍ ឈ្មោះថា វចីមោនេយ្យ: ។ ការកំណត់ដឹងវាចា ឈ្មោះថា វចីមោនេយ្យ: ។ មគ្គប្រព្រឹត្តទៅមួយអន្ទើដោយការកំណត់ដឹង ឈ្មោះថា វចីមោនេយ្យ: ។ ការលះបង់ធន្ទរាគក្នុងវាចា ឈ្មោះថា វចីមោនេយ្យ: ។ ទុតិយជ្ឌានសមាបត្តិ ដែលរំលត់វចីសង្ខារ ឈ្មោះថា វចីមោនេយ្យ: ។ នេះ ឈ្មោះថា វចីមោនេយ្យ: ។

មនោមោនេយ្យ: តើដូចម្តេច ។ ការលះបង់មនោទុច្ចរិត ៣ យ៉ាង ឈ្មោះថា មនោមោនេយ្យ: ។ មនោសុចរិត ៣ យ៉ាង ឈ្មោះថា មនោមោនេយ្យ: ។ ញាណមានចិត្តជាអារម្មណ៍ ឈ្មោះថា មនោ-មោនេយ្យ: ។ ការកំណត់ដឹងចិត្ត ឈ្មោះថា មនោមោនេយ្យ: ។ មគ្គ ប្រព្រឹត្តទៅមួយអន្ទើ ដោយការកំណត់ដឹង ឈ្មោះថា មនោមោ-នេយ្យ: ការលះបង់ធន្ទរាគក្នុងចិត្ត ឈ្មោះថា មនោមោនេយ្យ: ។

ចិត្តសង្ខារនិរោធោ សញ្ញាវេទយិតនិរោធសមាបត្តិ
មនោមោនេយ្យំ ។ ឥទំ មនោមោនេយ្យំ ។

កាយមុនី វាចាមុនី មនោមុនិមនាសវោ
មុនី មោនេយ្យសម្បន្នោ អាហុ សព្វប្បហាយិនំ ។
កាយមុនី វាចាមុនី មនោមុនិមនាសវោ
មុនី មោនេយ្យសម្បន្នោ អាហុ និន្ហាតចាបកំ ។

ឥមេហិ តីហិ មោនេយ្យេហិ ធម្មេហិ សមន្នាគតា ធ មុនយោ អាគារមុនយោ អនាគារមុនយោ សេក្ខ-មុនយោ អសេក្ខមុនយោ បច្ចេកមុនយោ មុនិមុន-យោ[1] ។ កតមេ អាគារមុនយោ ។ យេ តេ អា-គារិកា ឧជ្ជបជា រាជ្ញាតសាសនា ឥមេ អាគារមុន-យោ ។ កតមេ អនាគារមុនយោ ។ យេ តេ បព្វជិតា ឧជ្ជបជា រាជ្ញាតសាសនា ឥមេ អនាគារ-មុនយោ ។ សត្ត សេក្ខា សេក្ខមុនយោ ។ អរហន្តោ អសេក្ខមុនយោ ។ បច្ចេកពុទ្ធា បច្ចេកមុនយោ ។ មុនិមុនយោ រុច្ចន្តិ តថាគតា អរហន្តោ សម្មាសម្ពុទ្ធា ។

---

១ ម. ធម្មមុនិនោ អាគារមុនិនោ អានាគារមុនិនោ សេខមុនិនោ អសេខមុនិនោ បច្ចេកមុនិនោ មុនិមុនិនោតិ ។

សញ្ញាវេទយិតនិរោធសមាបត្តិ ដែលរំលត់ចិត្តសង្ខារ ឈ្មោះថា មនោ-មោនេយ្យ: ។ នេះ ឈ្មោះថា មនោមោនេយ្យ: ។

អ្នកប្រាជ្ញទាំងឡាយ បានពោលនូវកាយមុនិ វាចាមុនិ មនោមុនិ អនាសវមុនិ អ្នកបរិបូណ៌ដោយមោនេយ្យធម៌ ថាជាអ្នកលះបង់បាបទាំងអស់ ។ អ្នកប្រាជ្ញទាំងឡាយ បានពោលនូវកាយមុនិ វាចាមុនិ មនោមុនិ អនាសវ-មុនិ អ្នកបរិបូណ៌ ដោយមោនេយ្យធម៌ ថាជាអ្នកលាងជម្រះបាបហើយ ។

មុនិដែលប្រកបដោយមោនេយ្យធម៌ ៣ នេះមាន ៦ គឺអាគារមុនិ ១ អនាគារមុនិ ១ សេក្ខមុនិ ១ អសេក្ខមុនិ ១ បច្ចេកមុនិ ១ មុនិមុនិ ១ ។ ពួកអាគារមុនិ តើដូចម្តេច ។ បុគ្គលទាំងឡាយណា ជាអ្នកនៅគ្រប់គ្រងផ្ទះ ឃើញបទគឺព្រះនិព្វាន ដឹងច្បាស់សាសនា បុគ្គលទាំងឡាយនេះ ឈ្មោះថា អាគារមុនិ ។ ពួកអនាគារមុនិ តើដូចម្តេច ។ បុគ្គលទាំងឡាយណា ជាអ្នកបួស ឃើញបទគឺព្រះនិព្វាន ដឹងច្បាស់សាសនា បុគ្គលទាំងឡាយនេះ ឈ្មោះថា អនាគារមុនិ ។ សេក្ខបុគ្គល ៧ ពួក ឈ្មោះថា សេក្ខមុនិ ។ ព្រះអរហន្តទាំងឡាយ ឈ្មោះថា អសេក្ខមុនិ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ឈ្មោះថា បច្ចេកមុនិ ។ ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ លោកហៅថា មុនិមុនិ ។

ន មោនេន មុនិ ហោតិ មូឡ្ហរូបោ អវិទ្ទសុ យោ ច តុលំវ បគ្គយ្ហ វរមាទាយ បណ្ឌិតោ បាបានិ បរិវជ្ជេតិ សោ មុនិ តេន សោ មុនិ យោ មុនាតិ ឧភោ លោកេ មុនិ តេន បវុច្ចតិ ។

អសតញ្ច សតញ្ច ញត្វា ធម្មំ
អជ្ឈត្តំ ពហិទ្ធា ច សព្វលោកេ
ទេវមនុស្សេហិ ឬជិតោ
យោ សោ សង្គជាលមតិច្ច សោ មុនិ ។

លេបាតិ ទ្វេ លេបា តណ្ហាលេបោ ច ទិដ្ឋិលេបោ ច ។ បេ ។ អយំ តណ្ហាលេបោ ។ បេ ។ អយំ ទិដ្ឋិលេបោ ។ មុនិ តណ្ហាលេបំ បហាយ ទិដ្ឋិលេបំ បដិនិស្សជ្ជិត្វា បរិក្ខីណេសុ ន លិម្ពតិ ន សំលិម្ពតិ ន ឧបលិម្ពតិ អលិត្តោ អសំលិត្តោ អនុបលិត្តោ និក្ខន្តោ និស្សដ្ឋោ វិប្ប មុត្តោ វិសញ្ញុត្តោ វិមរិយាទិ-កតេន ចេតសា វិហរតីតិ បរិក្ខីណេសុ មុនិ ឧបលិត្តោ ។

បុគ្គលមានសភាពជាអ្នកលូងខ្ចៅ មិនចេះដឹង មិនមែនឈ្មោះ ថា មុនិ ដោយការស្ងៀមទេ លុះតែបុគ្គលណា ជាបណ្ឌិត កាន់យកធម៌ដ៏ប្រសើរ ហើយវៀរបង់បាបទាំងឡាយ ដូចជា បុគ្គលអ្នកកាន់ជញ្ជីង បុគ្គលនោះ ឈ្មោះថា មុនិ ដោយហេតុ នោះ បុគ្គលណាដឹងប្រយោជន៍ទាំងពីរ ក្នុងលោក បុគ្គលនោះ ឈ្មោះថា មុនិ បុគ្គលដែលលោកហៅថា មុនិ ដោយហេតុនោះ ។

បុគ្គលណា ដឹងធម៌របស់ពួកអសប្បុរសផង ពួកសប្ប-
រសផង ខាងក្នុងផង ខាងក្រៅផង ក្នុងលោកទាំងអស់
ជាបុគ្គលដែលទេវតានិងមនុស្ស បូជាហើយ បានកន្ធង
បណ្ដាញគឺគ្រឿងចំពាក់ បុគ្គលនោះ ឈ្មោះថា មុនិ ។

ពាក្យថា ការប្រឡាក់ បានដល់ការប្រឡាក់ ២ គឺ ការប្រឡាក់គឺ តណ្ហា ១ ការប្រឡាក់គឺទិដ្ឋិ ១ ។ បេ ។ នេះ ឈ្មោះថា ការប្រឡាក់គឺ តណ្ហា ។ បេ ។ នេះ ឈ្មោះថា ការប្រឡាក់គឺទិដ្ឋិ ។ មុនិលះបង់ការ ប្រឡាក់គឺតណ្ហា រលាស់ចោលការប្រឡាក់គឺទិដ្ឋិ មិនប្រឡាក់ មិន ជាប់ មិនចូលទៅប្រឡាក់ ក្នុងសេចក្ដីហួងហែងទាំងឡាយ គឺជាអ្នក មិនប្រឡាក់ មិនជាប់ មិនចូលទៅប្រឡាក់ ឃ្លាតចេញ រលាស់ ចេញ រួចស្រឡះ ប្រាសចេញ សម្រេចដោយចិត្តដែលប្រាសចាកដែន គឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) មុនិ មិនប្រឡាក់ក្នុងសេចក្ដី ហួងហែងទាំងឡាយ ។

[៦៨] អព្ភុគ្គសល្លោ ចរមប្បមត្តោតិ សល្លន្តិ សត្តសល្លានិ រាគសល្លំ ទោសសល្លំ មោហសល្លំ មានសល្លំ ទិដ្ឋិសល្លំ សោកសល្លំ កថំកថាសល្លំ ។ យស្សេតានិ សល្លានិ បហីនានិ សមុច្ឆិន្នានិ វូបសន្តានិ បដិប្បស្សទ្ធានិ អភព្វុប្បត្តិកានិ ញាណគ្គិនា ទឌ្ឍានិ សោ វុច្ចតិ អព្ភុគ្គសល្លោ អព្ភូហិតសល្លោ ឧទ្ធដសល្លោ សមុទ្ធដសល្លោ ឧប្បាដិតសល្លោ សមុប្បាដិតសល្លោ ចត្តសល្លោ វន្តសល្លោ មុត្តសល្លោ បហីនសល្លោ បដិនិស្សដ្ឋសល្លោ និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតីតិ អព្ភុគ្គសល្លោ ។ ចរន្តិ ចរន្តោ វិហរន្តោ ឥរិយន្តោ វត្តេន្តោ បាលេន្តោ យបេន្តោ យាបេន្តោ ។ អប្បមត្តោតិ សក្កច្ចការី សាតច្ចការី អដ្ឋិតការី អនោលីនវុត្តិកោ អនិក្ខិត្តច្ឆន្ទោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។

[៦៨] *អធិប្បាយពាក្យថា មានព្រួញដកហើយ ប្រព្រឹត្តមិនប្រមាទ ត្រង់ពាក្យថា ព្រួញ បានដល់ព្រួញ ៧ គឺ ព្រួញគឺរាគៈ ព្រួញគឺទោសៈ ព្រួញគឺមោហៈ ព្រួញគឺមានៈ ព្រួញគឺទិដ្ឋិ ព្រួញគឺសោក ព្រួញគឺសេចក្តីសង្ស័យ ។ ព្រួញទាំងឡាយនេះ បុគ្គលណាបានលះបង់ហើយ បានផ្តាច់ផ្តិលហើយ បានរម្ងាប់ហើយ បានគ្របសង្កត់ហើយ មិនគួរឲ្យកើតបាន បានដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមានព្រួញដកហើយ មានព្រួញកើចឡើងហើយ មានព្រួញគាស់ឡើងហើយ មានព្រួញរំលើងឡើងហើយ មានព្រួញហូតឡើងហើយ មានព្រួញហូតឡើងព្រមហើយ មានព្រួញលះចេញហើយ មានព្រួញខ្ជាក់ចោលហើយ មានព្រួញរួចស្រឡះហើយ មានព្រួញលះបង់ហើយ មានព្រួញរលាស់ចោលហើយ មិនមានសេចក្តីស្រេកឃ្វាន មានទុក្ខរលត់ហើយ មានសេចក្តីត្រជាក់ ទទួលសុខ សម្រេចនៅដោយចិត្តដ៏ប្រសើរ ហេតុនោះ ទ្រង់ត្រាស់ថា មានព្រួញដកឡើងហើយ ។ ពាក្យថា ប្រព្រឹត្ត គឺចរទៅ នៅ ដើរទៅ រក្សា ត្រាច់ទៅ ញ៉ាំងឥរិយាបថឲ្យត្រាច់ទៅ ។ ពាក្យថា មិនប្រហែស គឺធ្វើគោរព ធ្វើរឿយ ៗ ធ្វើមិនឈប់ ប្រព្រឹត្តមិនធូរថយ មិនទម្ងាក់ចោលនូវឆន្ទៈ មិនដាក់ធុរៈចោល ក្នុងកុសលធម៌ទាំងឡាយ ។*

កថាហំ អបរិបូរំ វា សីលក្ខន្ធំ បរិបូរេយ្យំ បរិបូរំ វា សីលក្ខន្ធំ តត្ត តត្ត បញ្ញាយ អនុក្តណ្ហោយ្យន្តិ យោ តត្ត ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សុក្ក្ឍ ច អប្ផដិវានី ច សតិសម្ផជញ្ញេ អាតប្ផ្ យ បធានំ អធិដ្ឋានំ អនុយោគោ អប្ផមាទោ កុសលេសុ ធម្មេសុ ។ កថាហំ អបរិបូរំ វា សមាធិក្ខន្ធំ បរិបូ-រេយ្យំ បរិបូរំ វា សមាធិក្ខន្ធំ តត្ត តត្ត បញ្ញាយ អនុក្តណ្ហោយ្យន្តិ ។ បេ ។ កុសលេសុ ធម្មេសុ ។ កថាហំ អបរិបូរំ វា បញ្ញាខន្ធំ វិមុត្តិក្ខន្ធំ វិមុត្តិ-ញ្ញាណទស្សនក្ខន្ធំ បរិបូរេយ្យំ បរិបូរំ វា វិមុត្តិ-ញ្ញាណទស្សនក្ខន្ធំ តត្ត តត្ត បញ្ញាយ អនុក្ត-ណ្ហោយ្យន្តិ យោ តត្ត ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សុក្ក្ឍ ច អប្ផដិវានី ច សតិ-សម្ផជញ្ញេ អាតប្ផ្ យ បធានំ អធិដ្ឋានំ អនុយោ-គោ អប្ផមាទោ កុសលេសុ ធម្មេសុ ។

សេចក្ដីពេញចិត្ត ការព្យាយាម ការឧស្សាហ៍ សេចក្ដីប្រឹងប្រែង ការមិនប្រព្រឹត្តត្រឡប់វិញ សតិសម្បជញ្ញៈ ការព្យាយាមដុតកម្ដៅកិលេស ការព្យាយាមដ៏ឧត្តម អធិដ្ឋាននិងការប្រកបរឿយ ៗ ណា ក្នុងកុសលធម៌ទាំងឡាយនោះ ថា ធ្វើម្ដេចហ្ន៎ អាត្មាអញនឹងបំពេញសីលក្ខន្ធដែលមិនទាន់ពេញលេញ ឬនឹងអនុគ្រោះសីលក្ខន្ធ ដែលពេញលេញស្រាប់ហើយ ដោយបញ្ញា ក្នុងកិច្ចនោះ ៗ ដូច្នេះ នេះ ឈ្មោះថា ការមិនប្រហែស ក្នុងកុសលធម៌ទាំងឡាយ ។ ថា ធ្វើម្ដេចហ្ន៎ អាត្មាអញនឹងបំពេញសមាធិក្ខន្ធ ដែលមិនទាន់ពេញលេញ ឬនឹងអនុគ្រោះសមាធិក្ខន្ធ ដែលពេញលេញស្រាប់ហើយ ដោយបញ្ញា ក្នុងកិច្ចនោះ ៗ ។ បេ ។ ក្នុងកុសលធម៌ទាំងឡាយ ។ សេចក្ដីពេញចិត្ត ការព្យាយាម ការឧស្សាហ៍ សេចក្ដីប្រឹងប្រែង ការមិនប្រពឹត្តត្រឡប់វិញ សតិសម្បជញ្ញៈ ការព្យាយាមដុតកម្ដៅកិលេស ការព្យាយាមដ៏ឧត្តម អធិដ្ឋាននិងការប្រកបរឿយ ៗ ណា ក្នុងកុសលធម៌ទាំងឡាយនោះ ថា ធ្វើម្ដេចហ្ន៎ អាត្មាអញ គប្បីបំពេញបញ្ញាខន្ធ វិមុត្តិក្ខន្ធ វិមុត្តិញ្ញាណទស្សនក្ខន្ធ ដែលមិនទាន់ពេញលេញ ឬនឹងអនុគ្រោះវិមុត្តិញ្ញាណទស្សនក្ខន្ធ ដែលពេញលេញស្រាប់ហើយ ដោយបញ្ញា ក្នុងកិច្ចនោះ ៗ ដូច្នេះ នេះ ឈ្មោះថា ការមិនប្រហែស ក្នុងកុសលធម៌ទាំងឡាយ ។

កថាហំ អបរិញ្ញាតំ វា ទុក្ខំ បរិជានេយ្យំ អប្បហីនេ វា កិលេសេ បជហេយ្យំ អភាវិតំ វា មគ្គំ ភាវេយ្យំ អសច្ឆិកតំ វា និរោធំ សច្ឆិករេយ្យន្តិ យោ តត្ថ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្ប-ដិវានី ច សតិសម្បជញ្ញញ្ច អាតប្បំ បធានំ អធិដ្ឋា-នំ អនុយោគោ អប្បមាទោ កុសលេសុ ធម្មេសុតិ អត្ថិ្វឡ្ហសល្លោ ចរមប្បមត្តោ ។

[៦៩] នាសីសតី លោកមិមំ បរញ្ចាតិ ឥមំ លោកំ នាសីសតិ សកត្តភាវំ បរលោកំ នាសី-សតិ បរត្តភាវំ ។ ឥមំ លោកំ នាសីសតិ សក-រូបវេទនាសញ្ញាសង្ខារវិញ្ញាណំ បរលោកំ នាសីសតិ បររូបវេទនាសញ្ញាសង្ខារវិញ្ញាណំ ។ ឥមំ លោកំ នាសីសតិ ឆ អជ្ឈត្តិកានិ អាយតនានិ បរលោកំ នាសីសតិ ឆ ពាហិរានិ អាយតនានិ ។ ឥមំ លោកំ នាសីសតិ មនុស្សលោកំ បរលោកំ នាសីសតិ ទេវលោកំ ។ ឥមំ លោកំ នាសីសតិ កាមធាតុំ បរលោកំ នាសីសតិ រូបធាតុំ អរូបធាតុំ ។

សេចក្តីពេញចិត្ត ការព្យាយាម ការឧស្សាហ៍ សេចក្តីប្រឹងប្រែង ការមិនប្រព្រឹត្តត្រឡប់វិញ សតិសម្បជញ្ញៈ ការព្យាយាមដុតកម្តៅកិលេស ការព្យាយាមដ៏ឧត្តម អធិដ្ឋាននិងការប្រកបរឿយៗ ណា ក្នុងកុសលធម៌ទាំងឡាយនោះថា ធ្វើម្តេចហ្ន៎ អាត្មាអញនឹងកំណត់ដឹងទុក្ខ ដែលមិនបានកំណត់ដឹងហើយ នឹងលះបង់កិលេសទាំងឡាយ ដែលមិនទាន់លះ នឹងចម្រើនមគ្គដែលមិនទាន់ចម្រើន ឬនឹងធ្វើឲ្យជាក់ច្បាស់នូវនិរោធដែលមិនទាន់ធ្វើឲ្យជាក់ច្បាស់ ដូច្នេះ នេះឈ្មោះថា ការមិនប្រហែសក្នុងកុសលធម៌ទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) មានព្ជួញដកហើយ ប្រព្រឹត្តមិនប្រហែស ។

[៦៩] ពាក្យថា មិនប្រាថ្នានូវលោកនេះ និងលោកដទៃ សេចក្តីថា មិនប្រាថ្នាលោកនេះ គឺអត្តភាពរបស់ខ្លួន មិនប្រាថ្នាលោកដទៃ គឺអត្តភាពដទៃ ។ មិនប្រាថ្នាលោកនេះគឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណរបស់ខ្លួន មិនប្រាថ្នាលោកដទៃ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណដទៃ ។ មិនប្រាថ្នាលោកនេះ គឺអាយតនៈខាងក្នុង ៦ មិនប្រាថ្នាលោកដទៃ គឺអាយតនៈខាងក្រៅ ៦ ។ មិនប្រាថ្នាលោកនេះ គឺមនុស្សលោក មិនប្រាថ្នាលោកដទៃ គឺទេវលោក ។ មិនប្រាថ្នាលោកនេះ គឺកាមធាតុ មិនប្រាថ្នាលោកដទៃ គឺរូបធាតុនិងអរូបធាតុ ។

ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

ឥមំ លោកំ ជានាតិ កាមធាតុំ រូបធាតុំ បរលោកំ ជានាតិ អរូបធាតុំ ។ បុន ឥតិ វា ឧបបត្តិ វា បដិសន្ធិ វា ភវោ វា វដ្ដំ វា ជានាតិ ន ឥច្ឆតិ ន សាធិយតិ ន បត្ថេតិ ន ឋិហេតិ ជាភិជ្ឌតីតិ ជានាតិ លោកមិមំ បរញ្ច ។ តេនាហ ភគវា

សញ្ញ្ហ បរិញ្ញា វិតរេយ្យ ឱឃំ
បរិក្ខហេសូ មុនិ ឧោបលិត្តោ
អព្ជ្ជ្ឌ្ជ្ជ្ជ្ជ្ជ ចរមប្ជ្ជ្ជ្ជ
ជានាតី លោកមិមំ បរញ្ចាតិ ។

ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ និដ្ឋិតោ ។

គុហដ្ឋកសុត្តនិទ្ទេស ទី ២

មិនប្រាថ្នាលោកនេះ គឺកាមធាតុ រូបធាតុ មិនប្រាថ្នាលោកដទៃ គឺអរូប-ធាតុ ។ មិនប្រាថ្នា មិនត្រូវការ មិនត្រេកអរ មិនប៉ុនប៉ង មិនស្រឡាញ់ មិនជាប់ចិត្ត នូវគតិ ឧបបត្តិ បដិសន្ធិ ភព សំសារ ឬវដ្ដ: ទៀតទេ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនប្រាថ្នានូវលោកនេះ និងលោកដទៃ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

មុនិកំណត់ដឹងសញ្ញាហើយ គប្បីធ្វើនិយ:បាន ជាអ្នកមិនប្រឡាក់ ក្នុងសេចក្ដីហួងហែងទាំងឡាយ ជាអ្នកមានព្ងួញដកឡើងហើយ ប្រព្រឹត្តមិនប្រហែស មិនប្រាថ្នានូវលោកនេះនិងលោកដទៃ ។

ចប់ គុហដ្ឋកសុត្តនិទ្ទេស ទី ២ ។

តតិយោ ទុដ្ឋដ្ឋកសុត្តនិទ្ទេសោ

[៧០] វទន្តិ វេ ទុដ្ឋមនាបិ[១] ឯកេ
អញ្ញេបិ[២] វេ សច្ចមនា វទន្តិ
វាទញ្ច ជាតំ មុនិ នោ ឧបេតិ
តស្មា មុនី នត្ថិ ខិលោ កុហិញ្ចិ ។

[៧១] វទន្តិ វេ ទុដ្ឋមនាបិ ឯកេតិ តេ តិត្ថិយា ទុដ្ឋមនា បទុដ្ឋមនា វិរុទ្ធមនា បដិវិរុទ្ធមនា អាហតមនា បច្ចាហតមនា អាឃាដិតមនា បច្ចាឃាដិតមនា វទន្តិ ឧបវទន្តិ ភគវន្តញ្ច ភិក្ខុសង្ឃញ្ច អភូតេនាតិ វទន្តិ វេ ទុដ្ឋមនាបិ ឯកេ ។

[៧២] អញ្ញេបិ វេ សច្ចមនា វទន្តីតិ យេ តេសំ តិត្ថិយានំ សទ្ទហន្តា ឱកប្បេន្តា អធិមុច្ចន្តា សច្ចមនា សច្ចសញ្ញិនោ ភូតមនា ភូតសញ្ញិនោ តថមនា

១ ម. ទុមនាបិ ។ ២ ម. អថោបិ ។

ទុដ្ឋដ្ឋកសុត្តនិទ្ទេស ទី ៣

[៧០] (ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា) តិរ្ថិយពួកខ្លះ មានចិត្តខឹង ហើយជេរ ពួកជនឯទៀត មានចិត្តជឿថាមែន រមែងជេរ តាម តែព្រះពុទ្ធជាមុនិ មិនអើពើនូវវាទៈ ដែលកើត ហើយ ព្រោះហេតុនោះ បង្ហោលគឺកិលេស របស់ព្រះ ពុទ្ធជាមុនិ មិនមានក្នុងទីណាទេ ។

[៧១] ពាក្យថា តិរ្ថិយពួកខ្លះ មានចិត្តខឹងហើយជេរ គឺពួកតិរ្ថិយ ទាំងនោះ មានចិត្តខឹង មានចិត្តប្រទូស្ត មានចិត្តអាក់អន់ មានចិត្ត អាក់អន់តប មានចិត្តបៀតបៀន មានចិត្តបៀតបៀនតប មានចិត្ត គុំកួន មានចិត្តគុំកួនតប ហើយជេរប្រទេច នូវព្រះមានព្រះភាគនិង ព្រះភិក្ខុសង្ឆ ដោយហេតុមិនពិត ហេតុនោះ (ទ្រង់ត្រាស់ថា) តិរ្ថិយ ពួកខ្លះ មានចិត្តខឹង ហើយជេរ ។

[៧២] ពាក្យថា ពួកជនឯទៀត មានចិត្តជឿថាមែន រមែងជេរតាម គឺពួកជនណា ជឿ ជឿស៊ប់ ចុះចិត្តស៊ប់ តាមពាក្យ នៃតិរ្ថិយ ទាំងនោះ មានចិត្តជឿថាមែន មានសេចក្តីសម្គាល់ថាមែន មានចិត្ត ជឿប្រាកដ មានសេចក្តីសម្គាល់ថា ប្រាកដ មានចិត្តថាទៀងទាត់

ឥមសញ្ញោ យាថាវមនា យាថាវសញ្ញោ អវិបរី-
ឥមនា អវិបរីតសញ្ញោ វេទន្តិ ឧបវេទន្តិ ភគវន្តញ្ច
ភិក្ខុសង្ឆញ្ច អភូតេនាតិ អញ្ញេបិ វ សចូមនា
វេទន្តិ ។

[៧៣] ឋានញ្ច ជានំ មុនិ នោ ឧបេតីតិ សោ
ឋានោ ជានោ ហោតិ សញ្ញោ និព្ធត្តោ អភិនិព្ធត្តោ
ចាតុភូតោ ឋតោ ឃោសោ អក្ខោសោ ឧបឋានោ
ភគវតោ ច ភិក្ខុសង្ឆស្ស ច អភូតេនាតិ ឋានញ្ច
ជានំ ។ មុនិ នោ ឧបេតីតិ មុនីតិ មោនំ វុច្ចតិ
ញាណំ យា បញ្ញា បជានន ។ បេ ។ អមោហោ
ធម្មវិចយោ សម្មាទិដ្ឋិ តេន ញាណេន សមន្ជាគតោ
មុនិ មោនប្ឋត្តោ ។ បេ ។ សង្ខ្លជ្ជាលមតិចូ សោ
មុនីតិ ។ យោ ឋានំ ឧបេតិ សោ ទ្ធីហិ ការណេហិ
ឋានំ ឧបេតិ ។ ការកោ ការកតាយ ឋានំ ឧបេតិ ។

មានសេចក្តីសម្គាល់ថាទៀងទាត់ មានចិត្តថាពិត មានសេចក្តីសម្គាល់ថាពិត មានចិត្តថាមិនប្រែប្រួល មានសេចក្តីសម្គាល់ថាមិនប្រែប្រួល ហើយជេរប្រទេច នូវព្រះមានព្រះភាគ និងព្រះភិក្ខុសង្ឆ ដោយហេតុមិនពិត ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកជនឯទៀត មានចិត្តជឿថាមែន រមែងជេរតាម ។

[*៧៣*] *ពាក្យថា ព្រះពុទ្ធជាមុនិ រមែងមិនអើពើនូវវាទ: ដែលកើតឡើង គឺវាទ:នោះកើត កើតព្រម កើតហើយ កើតចំពោះហើយ កើតប្រាកដហើយ ជាវាទ:លាន់កងរំពងអំពីសំណាក់បុគ្គលដទៃ ជាពាក្យជេរប្រទេច នូវព្រះមានព្រះភាគនិងព្រះភិក្ខុសង្ឆ ដោយហេតុមិនពិត ហេតុនោះ (ទ្រង់ត្រាស់ថា) នូវវាទ:ដែលកើតហើយ ។ ពាក្យថា ព្រះពុទ្ធជាមុនិ រមែងមិនអើពើ សេចក្តីថា ញាណ លោកហៅថា មោន: បានដល់ប្រាជ្ញា ការដឹងច្បាស់ ។ បេ ។ សេចក្តីមិនវង្វេង ការពិចារណាធម៌ សេចក្តីឃើញត្រូវ ព្រះពុទ្ធជាមុនិ ប្រកបដោយញាណនោះ ឈ្មោះថា ទ្រង់ដល់នូវមោន:។ បេ ។ ព្រះមានព្រះភាគនោះកន្ទ្ធងនូវបណ្តាញគឺសេចក្តីជាប់ ទើបឈ្មោះថា មុនិ ។ បុគ្គលណាអើពើនូវវាទ: បុគ្គលនោះ រមែងអើពើនូវវាទ: ដោយហេតុ ២ យ៉ាង ។ គឺបុគ្គលអ្នកបង្ក្តទោស រមែងអើពើនូវវាទ: ព្រោះភាពនៃខ្លួនជាអ្នកបង្ក្តទោស ១ ។*

អថវា រុច្ចមានោ ឧបវជ្ជិយមានោ កុប្ផតិ ញ្ជាបជ្ជតិ បតិដ្ឋិយតិ កោបញ្ច ទោសញ្ច អប្ផច្ចយញ្ច ចាតុកៈ-ហោតិ អការកោម្ហីតិ ។ យោ ភាគំ ឧបេតិ សោ ឥមេហិ ទ្វីហិ ការណេហិ ភាគំ ឧបេតិ ។ មុនិ ទ្វីហិ ការណៈ-ហិ ភាគំ ន ឧបេតិ ។ អការកោ[១] អការកតាយ ភាគំ ន ឧបេតិ ។ អថវា រុច្ចមានោ ឧបវជ្ជិយមានោ ន កុប្ផតិ ន ញ្ជាបជ្ជតិ ន បតិដ្ឋិយតិ ន កោបញ្ច ទោសញ្ច អប្ផច្ចយញ្ចេ ចាតុកហោតិ អការកោម្ហីតិ ។ មុនិ ឥមេហិ ទ្វីហិ ការណេហិ ភាគំ ន ឧបេតិ ន ឧបកច្ឆតិ ន កណ្ហាតិ ន បរាមសតិ ន អភិនិវិ-សតីតិ ភាគញ្ច ជាតំ មុនិ នោ ឧបេតិ ។

[៧៤] តស្មា មុនី ជត្តិ ទ្វិលោ ការហិញ្ជ្ជិតិ តស្មាតិ តស្មា តំការណា តំហេតុ តប្ផច្ចយា តំនិទានា មុនិ-នោ អាហារចិត្តតា ទ្វីលជាតតាបិ ជត្តិ ។ បញ្ចបិ ចេតោទ្វីលា ជត្តិ តយោបិ ទ្វីលា ជត្តិ ភាគទ្វីលោ

---

១ ម. ឯត្ថន្តរេ មុនីតិ ទិស្សតិ ។

មួយទៀត បុគ្គលត្រូវគេស្តី គេតិះដៀល រមែងខឹង គុំកួន តបត ធ្វើសេចក្តីក្រោធផង ទោស:ផង សេចក្តីអាក់អន់ផង ឲ្យប្រាកដថា អញជាអ្នកមិនបង្ក្គទោស ១ ។ បុគ្គលណារមែងអើពើនូវវាទ: បុគ្គលនោះរមែងអើពើនូវវាទ: ដោយហេតុ ២ នេះឯង ។ ព្រះពុទ្ធជាមុនិ រមែងមិនអើពើនូវវាទ: ដោយហេតុ ២ យ៉ាង ។ គឺព្រះពុទ្ធជាអ្នកមិនបង្ក្គទោស រមែងមិនអើពើនូវវាទ: ព្រោះភាពនៃព្រះអង្ក្ គជាអ្នកមិនបង្ក្គទោស ១ ។ មួយទៀត ព្រះពុទ្ធ កាលគេស្តី គេតិះដៀល រមែងមិនខឹង មិនគុំកួន មិនតបត ទាំងមិនធ្វើសេចក្តីក្រោធផង ទោស:ផង សេចក្តីអាក់អន់ផង ឲ្យប្រាកដថា អញជាអ្នកមិនបង្ក្គទោស ១ ។ ព្រះពុទ្ធជាមុនិ រមែងមិនអើពើ មិនរវល់ មិនកាន់យក មិនប៉ះពាល់ មិនប្រកាន់ទុកនូវវាទ: ដោយហេតុ ២ នេះឯង ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រះពុទ្ធជាមុនិ រមែងមិនអើពើនូវវាទ: ដែលកើតហើយ ។

[៣២] *អធិប្បាយពាក្យថា ព្រោះហេតុនោះ បង្ក្គាលគឺកិលេសរបស់ព្រះពុទ្ធជាមុនិ មិនមានក្នុងទីណាទេ ត្រង់ពាក្យថា ព្រោះហេតុនោះ គឺព្រោះដំណើរនោះ ព្រោះការណ៍នោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ព្រះពុទ្ធជាមុនិ មិនមានព្រះហឫទ័យត្រូវកិលេសបៀតបៀន ឬបង្ក្គាលគឺកិលេសកើតហើយទេ ។ ចេតោខីល: (បង្ក្គាលគឺកិលេសរបស់ចិត្ត) ៥ យ៉ាង ក៏មិនមាន ខីល: ៣ យ៉ាង គឺរាគខីល:*

ឧោសទីលោ មោហទីលោ ឧត្តិ ឧ សន្តិ ឧ សំវិជ្ជតិ ឧុបលព្ភតិ បហីនោ សមុច្ឆិន្នោ រូបសន្ដោ បដិប្ឋស្ស-ន្ធោ អភព្ធុប្ឋត្ដិកោ ញ្ជាណក្ដិនា ឧន្ដ្ជោ ឧុហិញ្ជ៌តិ ។ ឧុហិញ្ជ៌ ឧិម្ដ្ជិចិ ឧកត្ដ្ជចិ អជ្ជ្ជត្ដ្ជំ វ ពហិទ្ធា វ អជ្ជ្ជត្ដ-ពហិទ្ធា ១ាតិ ១ស្ម ១ុនី ឧត្ដ្ជ ១ិលោ ឧុហិញ្ជ៌ ។ ១េនាហ ១ឧ១ា

> ១ឧន្ដ្ជ ១ ១ុជ្ជ១ជ្ជ១ិ ១ឧ
> ១ញ្ជ្ជ១ិ ១ ១ ១ុ១ជ ១ឧន្ដ្ជ
> ១ឧ១ ១ជ្ជ ១ ១ុ១ ១ ១ ១ ១
> ១ស្ម ១ុនី ឧត្ដ្ជ ១ិលោ ឧុហិញ្ជ៌តិ ។

[៧៥] ១ឧ១ញ្ជ្ជ ១ិ១ជ្ជ ១ឧ១ ១ ១ ១ ១ ១

> ១ ១ ១ ១ ១ ១ ១ ១ ១ ១
> ១ ១ ១ ១ ១ ១ ១ ១ ១ ១
> ១ ១ ១ ១ ១ ១ ១ ១ ១ ១
> ១ ១ ១ ១ ១ ១ ១ ១ ១ ១ ។

[៧៦] ១ឧ១ញ្ជ្ជ ១ិ១ជ្ជ ១ឧ១ ១ ១ ១ ១ ១ ១ ១ ១ ១

ទោសខីណ: មោហខីណ: មិនមាន អង្គឺមាន ឥតមាន លៃងកើតមាន គឺព្រះពុទ្ធជាមុនិ បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ សូប់រម្ងាប់ មិនគួរដល់ការកើតទៀត ដុតដោយភ្លើងគឺញាណហើយ ។ ពាក្យថា ក្នុងទីណាមួយ គឺក្នុងកន្លែងណាមួយ ក្នុងតំបន់ណាមួយ ក្នុងទីខ្ញុះ ខាងក្នុងក្តី ខាងក្រៅក្តី ទាំងខាងក្នុងខាងក្រៅក្តី ហេតុដូច្នោះ (ទ្រង់ត្រាស់ថា) ហេតុនោះ បង្គោលគឺកិលេស របស់ព្រះពុទ្ធជាមុនិ មិនមានក្នុងទីណាទេ ។ ហេតុនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

តិរ្ថិយពួកខ្ញុះ មានចិត្តខឹង ហើយជេរ ពួកជនឯទៀត មានចិត្តជឿថាមែន រមែងជេរតាម តែព្រះពុទ្ធជាមុនិ មិនអើពើ នូវវាទ:ដែលកើតហើយ ព្រោះហេតុនោះ បង្គោលគឺកិលេស របស់ព្រះពុទ្ធជាមុនិ មិនមានក្នុងទីណាទេ ។

[៣៥] *បុគ្គលគប្បីកន្ធងនូវទិដ្ឋិរបស់ខ្លួន ដោយប្រការដូចម្តេចបាន*

បុគ្គល ដែលត្រូវសេចក្តីប្រាថ្នាដឹកនាំ ឋិតនៅស៊ប់ ក្នុងសេចក្តីពេញចិត្ត រមែងធ្វើនូវទិដ្ឋិទាំងឡាយ ឲ្យគ្រប់គ្រាន់ដោយខ្លួនឯង ដឹងយ៉ាងណា ក៏ពោលយ៉ាងនោះ ។

[៣៦] *ពាក្យថា បុគ្គលគប្បីកន្ធងនូវទិដ្ឋិរបស់ខ្លួនដោយប្រការដូចម្តេចបាន*

តិត្ថិយា សុន្ទរឹ បរិព្វាជិកំ ហន្ត្វា សមណានំ សក្យ-
បុត្តិយានំ អវណ្ណំ បកាសយិត្វា ឯវំ ឯតំ លាភំ យសំ
សក្ការសម្មានំ បច្ចាហរិស្សាមាតិ ឯវំទិដ្ឋិកា ឯវំខន្តិ-
កា ឯវំរុចិកា ឯវំលទ្ធិកា ឯវំអជ្ឈាសយា ឯវំអធិប្បា-
យា តេ ជាសត្តិំសុ សកំ ទិដ្ឋឹ សកំ ខន្តឹ សកំ
រុចឹ សកំ លទ្ធឹ សកំ អជ្ឈាសយំ សកំ អធិប្បា-
យំ អតិក្កមិតុំ ។ អថខោ ស្វេវ អយសោ តេ បច្ចា-
គតោតិ ឯវម្បិ សកញ្ហិ ទិដ្ឋឹ កថមច្ចយេយ្យ ។
អថវា សស្សតោ លោកោ ឥទមេវ សច្ចំ មោឃ-
មញ្ញន្តិ យោ សោ ឯវំវាទោ សោ សកំ ទិដ្ឋឹ សកំ
ខន្តឹ សកំ រុចឹ សកំ លទ្ធឹ សកំ អជ្ឈាសយំ សកំ
អធិប្បាយំ កថំ អច្ចយេយ្យ អតិក្កមេយ្យ សមតិក្ក-
មេយ្យ វីតិវត្តេយ្យ ។ តំ កិស្ស ហេតុ ។ តស្ស
សា ទិដ្ឋិ តថា សមត្តា សមាទិន្នា គហិតា បរាមដ្ឋា

អធិប្បាយថា ពួកតិរ្ថិយណា មានទិដ្ឋិយ៉ាងនេះ មានសេចក្ដីគួរយ៉ាងនេះ មានសេចក្ដីពេញចិត្តយ៉ាងនេះ មានលទ្ធិយ៉ាងនេះ មានអធ្យាស្ស័យយ៉ាងនេះ មានសេចក្ដីប៉ុនប៉ងយ៉ាងនេះថា ពួកយើងនឹងសម្ងាប់នាងសុន្ទរីបរិព្វ-ជិកា ហើយប្រកាសទោស របស់ពួកសមណសក្យបុត្តិយ៍ កាលបើធ្វើយ៉ាងនេះ ពួកយើងនឹងប្រមូលយកនូវលាភ យស សក្ការ: និងសេចក្ដីរាប់អាន ទុ:ះបាន ទើបពួកតិរ្ថិយទាំងនោះ មិនអាចនឹងកន្ទ្ធងនូវទិដ្ឋិរបស់ខ្លួន សេចក្ដីគួររបស់ខ្លួន សេចក្ដីពេញចិត្តរបស់ខ្លួន លទ្ធិរបស់ខ្លួន អធ្យាស្ស័យរបស់ខ្លួន សេចក្ដីប៉ុនប៉ងរបស់ខ្លួនបានឡើយ ។ តាមពិតការមិនមានយសនោះឯង ក៏ត្រឡប់មកដល់ពួកតិរ្ថិយនោះវិញទេ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលគប្បីកន្ទ្ធងនូវទិដ្ឋិរបស់ខ្លួនដោយប្រការដូចម្ដេចបាន យ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលណាមានវាទ:យ៉ាងនេះថា លោក គឺអត្តភាព ទៀងទាត់ ការឃើញនេះឯងជាការពិត ការឃើញដទៃជាមោឃ: បុគ្គលនោះ គប្បីកន្ទ្ធង ឈានកន្ទ្ធង កន្ទ្ធងផុត ប្រព្រឹត្តកន្ទ្ធង នូវទិដ្ឋិរបស់ខ្លួន សេចក្ដីគួររបស់ខ្លួន សេចក្ដីពេញចិត្តរបស់ខ្លួន លទ្ធិរបស់ខ្លួន អធ្យាស្ស័យរបស់ខ្លួន សេចក្ដីប៉ុនប៉ងរបស់ខ្លួន ដោយប្រការដូចម្ដេចបាន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ (ព្រោះថា) ទិដ្ឋិនោះ ដែលបុគ្គលនោះធ្វើឲ្យពេញលេញ សមាទាន កាន់យក ស្ទាបអង្អែល

អកិនិវិដ្ឋា អជ្ឌោសិតា អធិមុត្តាតិ ឯវម្ឪ សកញ្ហិ ជិដ្ឋឺ ភជមចូយេយ្យ ។ សស្ឪតោ លោកោ អសស្ឪ-តោ លោកោ អន្តវា លោកោ អនន្តវា លោកោ តំ ជីវំ តំ សរីរំ អញ្ញ ជីវំ អញ្ញ សរីរំ ហោតិ តថា-គតោ បរម្ឪណា ន ហោតិ តថាគតោ បរម្ឪណា ហោតិ ច ន ច ហោតិ តថាគតោ បរម្ឪណា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្ឪណា ឥជមេវ សចំ មោឃមញ្ញន្តិ យោ សោ ឯវ១ាជោ សោ សកំ ជិដ្ឋឺ សកំ ១ន្ត្ឺ សកំ ១ុ១ឺ សកំ ១ន្ធ្ឺ សកំ អជ្ឌា-សយំ សកំ អធិ១ាយំ ភជ១ំ អ១ូយេយ្យ អតិ១ាមេ-យ្ឪ សមតិ១ាមេយ្ឪ ១ីតិ១ាតេយ្ឪ ។ តំ ១ិ១ស្ឪ ហេតុ ។ ឥ១ស្ឪ ១ា ជិដ្ឋិ ឥ១ា ១ាមតា ១ាមាជ្ជ ១ហ្ជ ១ាតា ១ាមជ្ជ អ១ិ១ិ១ិ១ា អ១ូ១ាសិ១ា អ១ិ១ុ១ាតិ ១ាម្ឪ ១ាកញ្ជ ជ ជ ជ ១ាជ១ាមជ្ជ ។

ទុដ្ឋដ្ឋកសុត្តនិទ្ទេស ទី ៣

ឋិតនៅស៊ីប់ ជ្រុលជ្រប់ ចុះចិត្តស៊ីប់ហើយ ដោយប្រការដូច្នេះ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលគប្បីកន្ធង់នូវទិដ្ឋិរបស់ខ្លួន ដោយប្រការដូចម្តេចបាន យ៉ាងនេះខ្លះ ។ បុគ្គលណាមានវាទៈយ៉ាងនេះថា លោកទៀងទាត់ លោកមិនទៀងទាត់ លោកមានទីបំផុត លោកមិនមានទីបំផុត ជីវិតនោះ សរីរៈនោះ ជីវិតដទៃ សរីរៈដទៃ សត្វស្លាប់ទៅ រមែងកើតទៀត សត្វស្លាប់ទៅ រមែងមិនកើតទៀត សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះ សត្វស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ការឃើញនេះឯង ជាការពិត ការឃើញដទៃជាមោឃៈ បុគ្គលនោះ គប្បីកន្ធង់ ឈានកន្ធង់ កន្ធង់ផុត ប្រព្រឹត្តកន្ធង់នូវទិដ្ឋិរបស់ខ្លួន សេចក្តីគួររបស់ខ្លួន សេចក្តីពេញចិត្តរបស់ខ្លួន លទ្ធិរបស់ខ្លួន អធ្យាស្រ័យរបស់ខ្លួន សេចក្តីប៉ុនប៉ងរបស់ខ្លួន ដោយប្រការដូចម្តេចបាន ។ ដំណើរនោះ តើព្រោះហេតុដូចម្តេច ។ (ព្រោះថា) ទិដ្ឋិនោះ ដែលបុគ្គលនោះធ្វើឲ្យពេញលេញ សមាទាន កាន់យកស្ទាបអង្អែល ឋិតនៅស៊ីប់ ជ្រុលជ្រប់ ចុះចិត្តស៊ីប់ហើយដូច្នោះ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលគប្បីកន្ធង់នូវទិដ្ឋិរបស់ខ្លួន ដោយប្រការដូចម្តេចបាន យ៉ាងនេះខ្លះ ។

នេះឈ្មោះថា ការអែបនៃបគឺទិដ្ឋិ ។ បុគ្គលនោះ លះបង់ការអែបនៃបគឺតណ្ហា រលាស់ចេញនូវការអែបនៃបគឺទិដ្ឋិ ឈ្មោះថា អ្នកមិនមានការអែបនៃប ព្រោះលះបង់ការអែបនៃបគឺតណ្ហាហើយ ព្រោះរលាស់ចេញនូវការអែបនៃបគឺទិដ្ឋិហើយ ។ បុគ្គលនោះ គប្បីលុះដោយរាគ:ដូចម្តេច លុះដោយទោស:ដូចម្តេច លុះដោយមោហ:ដូចម្តេច លុះដោយមាន:ដូចម្តេច លុះដោយទិដ្ឋិដូចម្តេច លុះដោយឧទ្ធច្ច:ដូចម្តេច លុះដោយវិចិកិច្ឆាដូចម្តេច លុះដោយអនុសយក្កិលេសទាំងឡាយដូចម្តេចកើត ថាជាអ្នកត្រេកអរក្តី ថាជាអ្នកខឹងក្តី ថាជាអ្នកវង្វេងក្តី ថាជាអ្នកជាប់ចំពាក់ក្តី ថាជាអ្នកស្ទាបអង្អែលក្តី ថាជាអ្នកដល់នូវការរាយមាយក្តី ថាជាអ្នកដល់នូវការមិនជាប់ស្រេចក្តី ថាជាអ្នកដល់នូវកម្ទាំងក្តី ។ អកិសង្ខារទាំងនោះ បុគ្គលមានប្រាជ្ញាកម្ចាត់លះបង់ហើយ បុគ្គលនោះ គប្បីទៅកាន់គតិទាំងឡាយ ថាជាបុគ្គលទៅកើតក្នុងនរកក្តី ថាទៅកើតក្នុងកំណើតតិរច្ឆានក្តី ថាទៅកើតក្នុងបិត្តិវិស័យក្តី ថាជាមនុស្សក្តី ថាជាទេវតាក្តី ថាមានរូបក្តី ថាមិនមានរូបក្តី ថាមានសញ្ញាក្តី ថាមិនមានសញ្ញាក្តី ថាមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនក្តី ដោយហេតុដូចម្តេចកើត ព្រោះអកិសង្ខារទាំងឡាយ លោកលះបង់ហើយ ។

សោ ហេតុ នត្ថិ បច្ចយោ នត្ថិ ការណំ នត្ថិ យេន គច្ឆេយ្យាតិ ស កេន គច្ឆេយ្យ អនូបយោ សោ ។ តេនាហ ភគវា

ធោនស្ស ហិ នត្ថិ កុហិញ្ចិ លោកេ
បកប្បិតា ទិដ្ឋិ ភវាភវេសុ
មាយញ្ច មានញ្ច បហាយ ធោនោ
ស កេន គច្ឆេយ្យ អនូបយោ សោតិ ។

[១០៤] ឧបយោ ហិ ធម្មេសុ ឧបេតិ វាទំ
អនូបយំ កេន កថំ វទេយ្យ
អត្តំ និរត្តំ ន ហិ តស្ស អត្ថិ
អធោសិ សោ ទិដ្ឋិមិធេវ សព្វំ ។

[១០៥] ឧបយោ ហិ ធម្មេសុ ឧបេតិ វាទន្តិ ឧបយោតិ ទ្វេ ឧបយា តណ្ហូបយោ ច

បុគ្គលមានប្រាជ្ញាកម្ចាត់ គប្បីទៅដោយហេតុណា ហេតុនោះមិនមាន បច្ច័យមិនមាន ការណ៍មិនមានទេ ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលមានប្រាជ្ញាកម្ចាត់នោះ គប្បីលុះដោយកិលេសដូចម្តេចកើត ព្រោះ លោកមិនមានការអែបនៃប ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ទិដ្ឋិដែលគេកំណត់ហើយក្នុងកពតូចកពធំ ក្នុងលោកណាមួយ នៃបុគ្គលមានប្រាជ្ញាកម្ចាត់ មិនមានទេ បុគ្គលមានប្រាជ្ញា កម្ចាត់នោះ លះបង់មាយាផង មានះផង តើនឹងលុះដោយ កិលេសដូចម្តេចកើត ព្រោះលោកមិនមានការអែបនៃប ។

[១០៦] *បុគ្គលមានកិលេសជាគ្រឿងអែបនៃប រមែងអើពើនឹងវាទ: ក្នុងធម៌ទាំងឡាយ ជនគប្បីពោលនូវបុគ្គលមិនមានការអែប នៃប ដោយកិលេសណាដូចម្តេចបាន ព្រោះអត្តទិដ្ឋិ (ការ ឃើញថាមានខ្លួន) និរត្តទិដ្ឋិ (ការឃើញថាមិនមានខ្លួន) នៃ ព្រះអរហន្តនោះមិនមានទេ ព្រះអរហន្តនោះ បានលាងនូវ ទិដ្ឋិទាំងអស់ ក្នុងលោកនេះហើយ ។*

[១០៥] *អធិប្បាយពាក្យថា បុគ្គលមានកិលេស ជាគ្រឿងអែបនៃប រមែងអើពើនឹងវាទ: ក្នុងធម៌ទាំងឡាយ ត្រង់ពាក្យថា កិលេសជាគ្រឿង អែបនៃប បានខាង ការអែបនៃប ២ យ៉ាង គឺ ការអែបនៃបគឺតណ្ហា ១*

និជ្ជូបយោ ច ។ បេ ។ អយំ តណ្ហាបយោ ។ បេ ។ អយំ និជ្ជូបយោ ។ តស្ស តណ្ហាបយោ អប្បហីនោ និជ្ជូបយោ អប្បដិនិស្សដ្ឋោ តណ្ហាបយស្ស អប្បហី-នត្តា និជ្ជូបយស្ស អប្បដិនិស្សដ្ឋត្តា ធម្មេសុ រាជំ ឧបេតិ រត្តោតិ វា តុដ្ឋោតិ វា មូឡ្ហោតិ វា វិនិពន្ធោតិ វា បរាមដ្ឋោតិ វា វិក្ខេបគតោតិ វា អនិដ្ឋង្គតោតិ វា ថាមគតោតិ វា ។ តេ អភិសង្ខារា អប្បហីនា អភិសង្ខារានំ អប្បហីនត្តា គតិយា រាជំ ឧបេតិ នេរយិកោតិ វា តិរច្ឆានយោនិកោតិ វា បិត្តិវិសយិ-កោតិ វា មនុស្សោតិ វា ទេវោតិ វា រូបីតិ វា អរូបីតិ វា សញ្ញីតិ វា អសញ្ញីតិ វា នេវសញ្ញីនាស-ញ្ញីតិ វា រាជំ ឧបេតិ ឧបគច្ឆតិ គណ្ហាតិ បរាមសតិ អភិនិវីសតីតិ ឧបយោ ហិ ធម្មេសុ ឧបេតិ រាជំ ។

ទុដ្ឋដ្ឋកសុត្តនិទ្ទេស ទី ៣

ការអែបនៃបគឺទិដ្ឋិ ១ ។បេ។ នេះឈ្មោះថា ការអែបនៃបគឺតណ្ហា ។ បេ ។ នេះឈ្មោះថា ការអែបនៃបគឺទិដ្ឋិ ។ បុគ្គលនោះ មិនទាន់លះបង់ការអែបនៃបគឺតណ្ហា មិនទាន់រលាស់ចោលការអែបនៃបគឺទិដ្ឋិ រមែងអើពើនូវវាទ: ក្នុងធម៌ទាំងឡាយថា ជាអ្នកត្រេកអរក្តី ថាជាអ្នកខឹងក្តី ថាជាអ្នកវង្វេងក្តី ថាជាអ្នកជាប់ចំពាក់ក្តី ថាជាអ្នកស្ទាបអង្អែលក្តី ថាជាអ្នកដល់នូវការរាយមាយក្តី ថាជាអ្នកដល់នូវការមិនដាច់ស្រេចក្តី ថាជាអ្នកដល់នូវកម្ទាំងក្តី ព្រោះការអែបនៃបគឺតណ្ហា ខ្ជួនមិនទាន់លះបង់ ព្រោះការអែបនៃបគឺទិដ្ឋិ ខ្ជួនមិនទាន់រលាស់ចេញ ។ អកិសង្ខារទាំងនោះ បុគ្គលមិនទាន់លះបង់ហើយ បុគ្គលរមែងអើពើនូវវាទ:ដោយគតិ ព្រោះអកិសង្ខារទាំងឡាយដែលខ្ជួនមិនទាន់លះបង់ គឺរមែងដល់ ចូលទៅជិត ប្រកាន់ ស្ទាបអង្អែល ជាប់ចំពាក់នូវវាទ:ថា ជាអ្នកកើតក្នុងនរកក្តី កើតក្នុងកំណើតតិរច្ឆានក្តី កើតក្នុងបិត្តិវិស័យក្តី ជាមនុស្សក្តី ជាទេវតាក្តី មានរូបក្តី មិនមានរូបក្តី មានសញ្ញាក្តី មិនមានសញ្ញាក្តី មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលមានកិលេសជាគ្រឿងអែបនៃប រមែងអើពើនូវវាទ:ក្នុងធម៌ទាំង-ឡាយ ។

[១០៦] អនូបយំ កេន កថំ វទេយ្យាតិ ឧប-
យោតិ ទ្វេ ឧបយា តណ្ហូបយោ ច ទិដ្ឋូបយោ ច
។ បេ ។ អយំ តណ្ហូបយោ ។ បេ ។ អយំ ទិដ្ឋូប-
យោ ។ តស្ស តណ្ហូបយោ បហីនោ ទិដ្ឋូបយោ បដិ-
និស្សដ្ឋោ តណ្ហូបយស្ស បហីនត្តា ទិដ្ឋូបយស្ស
បដិនិស្សដ្ឋត្តា អនូបយំ កេន រាគេន វទេយ្យ កេន
ទោសេន វទេយ្យ កេន មោហេន វទេយ្យ កេន
មានេន វទេយ្យ កាយ ទិដ្ឋិយា វទេយ្យ កេន
ឧទ្ធច្ចេន វទេយ្យ កាយ វិចិកិច្ឆាយ វទេយ្យ កេហិ
អនុសយេហិ វទេយ្យ រត្តោតិ វា ទុដ្ឋោតិ វា មូឡ្ហោតិ
វា វិនិពទ្ធោតិ វា បរាមដ្ឋោតិ វា វិក្ខេបគតោតិ វា
អនិដ្ឋង្គតោតិ វា ថាមគតោតិ វា ។ តេ អភិសង្ខារា
បហីនា អភិសង្ខារានំ បហីនត្តា គតិយោ កេន វទេ-
យ្យ នេរយិកោតិ វា ។ បេ ។ នេវសញ្ញីនាសញ្ញីតិ វា ។

[១០៦] *អធិប្បាយពាក្យថា ជនគប្បីពោលនូវបុគ្គលមិនមានការអែបនែបដោយកិលេសណា ដូចម្តេចបាន ត្រង់ពាក្យថា ការអែបនែប បានដល់ការអែបនែប ២ គឺការអែបនែបគឺតណ្ហា ១ ការអែបនែបគឺទិដ្ឋិ ១ ។ បេ ។ នេះឈ្មោះថា ការអែបនែបគឺតណ្ហា ។ បេ ។ នេះឈ្មោះថា ការអែបនែបគឺទិដ្ឋិ ។ បុគ្គលនោះលះបង់ការអែបនែបគឺតណ្ហា រលាស់ចោលការអែបនែបគឺទិដ្ឋិ ព្រោះការអែបនែបគឺតណ្ហា លោកលះបង់ហើយ ព្រោះការអែបនែបគឺទិដ្ឋិលោករលាស់ចេញហើយ ជនគប្បីពោលនូវបុគ្គលមិនមានកិលេសជាគ្រឿងអែបនែប ដោយរាគ:ដូចម្តេច គប្បីពោលដោយទោស:ដូចម្តេច គប្បីពោលដោយមោហ:ដូចម្តេច គប្បីពោលដោយមានៈដូចម្តេច គប្បីពោលដោយទិដ្ឋិដូចម្តេច គប្បីពោលដោយឧទ្ធច្ច:ដូចម្តេច គប្បីពោលដោយវិចិកិច្ឆាដូចម្តេច គប្បីពោលដោយអនុស័យទាំងឡាយដូចម្តេច ថាជាអ្នកត្រេកអរក្តី ថាជាអ្នកខឹងក្តី ថាជាអ្នកវង្វេងក្តី ថាជាអ្នកជាប់ចំពាក់ក្តី ថាជាអ្នកស្ទាបអង្អែលក្តី ថាជាអ្នកដល់នូវការរាយមាយក្តី ថាជាអ្នកដល់នូវការមិនជាប់ស្រេចក្តី ថាជាអ្នកដល់នូវកម្ទាំងក្តី ។ អកិសង្ខារទាំងនោះ បុគ្គលនោះ លះបង់ហើយ ជនគប្បីពោលនូវគតិទាំងឡាយថា ជាអ្នកកើតក្នុងនរកដូច្នេះក្តី ។ បេ ។ មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនដូច្នេះក្តី ដោយហេតុដូចម្តេចបាន ព្រោះអកិសង្ខារទាំងឡាយ លោកលះបង់ហើយ ។*

សោ ហេតុ នត្ថិ បច្ចយោ នត្ថិ ការណំ នត្ថិ យេន វទេយ្យ កាជេយ្យ កណេយ្យ ជីបយេយ្យ វោហ-រេយ្យាតិ អត្តបយំ កេន កថំ វទេយ្យ ។

[១០៧] អត្តំ និរត្តំ ន ហិ តស្ស អត្ថីតិ អត្តាតិ សស្សតទិដ្ឋិ នត្ថិ និរត្តាតិ ឧច្ឆេទទិដ្ឋិ នត្ថិ អត្តាតិ គហិតំ នត្ថិ និរត្តាតិ មុញ្ចិតព្វំ នត្ថិ ។ យស្សត្ថិ គហិតំ តស្សត្ថិ មុញ្ចិតព្វំ យស្សត្ថិ មុញ្ចិតព្វំ តស្សត្ថិ គហិតំ ។ គហណមុញ្ចនំ សមតិក្កន្តោ អរហា វុឌ្ឍិបរិហានី វីតិវត្តោ ។ សោ វុដ្ឋវាសោ ចិណ្ណចរណោ ។ បេ ។ នត្ថិ តស្ស បុនព្ភវោតិ អត្តំ និរត្តំ ន ហិ តស្ស អត្ថិ ។

[១០៨] អធោសិ សោ ទិដ្ឋិមិធេវ សព្វន្តិ តស្ស ទ្វាសដ្ឋី ទិដ្ឋិគតានិ បហីនានិ សមុច្ឆិន្នានិ

ជនគប្បីពោល សម្តែង និយាយ បំភ្ញ ១ បញ្ចេញ ដោយហេតុណា ហេតុនោះមិនមាន បច្ច័យមិនមាន ការណ៍មិនមាន ហេតុនោះ (ទ្រង់ត្រាស់ថា) ជនគប្បីពោល នូវបុគ្គលមិនមានការអែបនែប ដោយ កិលេសណា ដូចម្តេចបាន ។

[១០៧] អធិប្បាយពាក្យថា អត្តទិដ្ឋិនិងនិរត្តទិដ្ឋិ នៃបុគ្គលនោះ មិនមានទេ ត្រង់ពាក្យថា អត្តទិដ្ឋិ គឺសស្សតទិដ្ឋិ មិនមាន ពាក្យថា និរត្តទិដ្ឋិ គឺឧច្ឆេទទិដ្ឋិ ក៏មិនមាន បានសេចក្តីថា ការប្រកាន់ថាខ្លួន មិនមាន ការគួរដោះថាមិនមែនខ្លួន ក៏មិនមាន ។ ការប្រកាន់របស់បុគ្គលណាមាន ការគួរដោះរបស់បុគ្គលនោះក៏មាន ការគួរដោះរបស់បុគ្គលណាមាន ការប្រកាន់របស់បុគ្គលនោះក៏មាន ។ ព្រះអរហន្ត កន្ទ្ធ១ផុត ការប្រកាន់ និ១ការដោះ ហើយប្រព្រឹត្តកន្ទ្ធ១នូវសេចក្តីចម្រើននិ១សេចក្តីវិនាស ។ ព្រះអរហន្តនោះ មានព្រហ្មចរិយៈនៅហើយ មានធម៌ជាគ្រឿ១ប្រព្រឹត្ត ប្រព្រឹត្តហើយ ។ លេ ។ ព្រះអរហន្តនោះ មិនមានភពថ្មីទៀតទេ ហេតុនោះ (ទ្រង់ត្រាស់ថា) អត្តទិដ្ឋិ (ការឃើញថាមានខ្លួន) និរត្តទិដ្ឋិ (ការឃើញថាមិនមានខ្លួន) នៃបុគ្គលនោះ មិនមានទេ ។

[១០៨] ពាក្យថា បុគ្គលនោះបានលាន១នូវទិដ្ឋិទាំ១អស់ ក្នុ១លោកនេះហើយ សេចក្តីថា ទិដ្ឋិទាំ១ ៦២ បុគ្គលនោះ លះបង់ ផ្តាច់ផ្តិល

រូបសន្ធានិ បដិច្ចសមុប្ផន្នានិ អភពុប្ផត្តិកានិ ញាណ-ក្ខិជ្ជ ជ ឆ្ឌ្ឌានិ ។ សោ សព្ពំ ជិដ្ឋិកតំ ឥជេ អជ្ជេសិ ជុនិ សន្ធុនិ ជិន្ធុនិ បជ្ជហិ វិជ្ជោជ្ជេសិ ព្យន្ធីអកាសិ អជ្ជការ ជ្ជមេសីតិ អជ្ជេសិ សោ ជិដ្ឋិមិជ្ជេ សព្ពំ ។ ត្ជាហ ភ្ជ

ឧបយោ ហិ ជម្ជេសុ ឧបេតិ ឋ្ជ
អជ្ជបយំ ភ្ជេ ភ្ជ ជ្ជ ឋ្ជ
អត្ជ ជ ជ ជ ហ ត ស អ
អ ជ ជ ជ ជ ជ ។

ត ត ជ ជ ទ ជ ជ ជ ជ ជ ។

រម្ងាប់ សូប់រម្ងាប់ ធ្វើមិនគួរដល់ការកើតទៀត ដុតដោយភ្លើងគឺញាណ ហើយ ។ បុគ្គលនោះ បានលាង កម្ចាត់បង់ កម្ចាត់ដាច់ស្រឡះ កម្ចាត់ដោយមិនសល់ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើត មាន នូវទិដ្ឋិទាំងអស់ក្នុងលោក ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គល នោះ បានលាងនូវទិដ្ឋិទាំងអស់ ក្នុងលោកនេះហើយ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

បុគ្គលមានកិលេសជាគ្រឿងអែបនែប រមែងអើពើនូវវាទ: ក្នុងធម៌ទាំងឡាយ ជនគប្បីពោល នូវបុគ្គលមិនមានការអែប នែប ដោយកិលេសណាដូចម្តេចបាន ព្រោះអត្តទិដ្ឋិ (ការ ឃើញថាមានខ្លួន) និវត្តទិដ្ឋិ (ការឃើញថាមិនមានខ្លួន) នៃបុគ្គលនោះ មិនមានទេ បុគ្គលនោះបានលាងនូវទិដ្ឋិ ទាំងអស់ ក្នុងលោកនេះហើយ ។

ចប់ ទុដ្ឋដ្ឋកសុត្តនិទ្ទេស ទី ៣ ។

ចតុត្ថោ សុទ្ធដ្ឋកសុត្តនិទ្ទេសោ

[១០៩] បស្ឆាមិ សុទ្ធំ បរមំ អរោគំ

ជិវ្ហេន សំសុទ្ធិ ជរស្ស ហោតិ

ឯវាភិជានំ បរមន្តិ ញត្វា

សុទ្ធានុបស្សីតិ បច្ចេតិ ញាណំ ។

[១១០] បស្ឆាមិ សុទ្ធំ បរមំ អរោគន្តិ បស្ឆាមិ សុទ្ធន្តិ បស្ឆាមិ សុទ្ធំ ឧក្ខាមិ សុទ្ធំ ឱលោកេមិ សុទ្ធំ ជិឌ្ឍាយាមិ សុទ្ធំ ឧបបរិក្ខាមិ សុទ្ធំ ។ បរមំ អរោគន្តិ បរមំ អរោគ្យប្បត្តំ ខេមប្បត្តំ តាណប្បត្តំ លេណប្បត្តំ សរណប្បត្តំ ឋាយនប្បត្តំ អភយប្បត្តំ អច្ចុតប្បត្តំ អមតប្បត្តំ និព្ពានប្បត្តន្តិ បស្ឆាមិ សុទ្ធំ បរមំ អរោគំ ។

សុទ្ធដ្ឋកសុត្តនិទ្ទេស ទី ៤

[១០៩] (ព្រះមានព្រះភាគត្រាស់ថា) អាត្មាអញឃើញ (នូវរូប) ដ៏បរិសុទ្ធ ឧត្តម មិនមានរោគ សេចក្តីបរិសុទ្ធ ដ៏ប្រពៃ របស់នរជន រមែងកើតមាន ដោយសាររូបដែលខ្លួនឃើញ បុគ្គលពាល អ្នកឃើញរឿយ ៗ នូវការបរិសុទ្ធ កាលដឹងច្បាស់យ៉ាងនេះ រមែងយល់ថា (ការឃើញនេះ)ឧត្តម ហើយជឿនូវការឃើញនោះ ថាជាញាណ ។

[១១០] *អធិប្បាយពាក្យថា* អាត្មាអញឃើញ (នូវរូប) ដ៏បរិសុទ្ធ ឧត្តម មិនមានរោគ ត្រង់ពាក្យថា អាត្មាអញឃើញ (នូវរូប) ដ៏បរិសុទ្ធ គឺ អាត្មាអញឃើញ (រូប) បរិសុទ្ធ មើល (រូប) បរិសុទ្ធ ក្រឡេក មើល (រូប) បរិសុទ្ធ សម្ងឹងមើល (រូប) បរិសុទ្ធ សង្កេតមើល (រូប) បរិសុទ្ធ ។ ពាក្យថា ឧត្តម មិនមានរោគ គឺឧត្តម ដល់នូវភាពមិន មានរោគ ដល់នូវសេចក្តីក្សេម ដល់នូវទីជ្រក ដល់នូវទីពឹងពំនាក់ ដល់នូវទីរលឹក ដល់នូវការប្រព្រឹត្តទៅខាងមុខ ដល់នូវការមិនមានភ័យ ដល់នូវភាពទៀងទាត់ ដល់នូវអមត: ដល់នូវភាពប្រាសចាកតណ្ហា ហេតុនោះ (ទ្រង់ត្រាស់ថា) អាត្មាអញឃើញ (នូវរូប) បរិសុទ្ធ ឧត្តម មិនមានរោគ ។

[១១១] ឥជ្ជេន សំសុទ្ធិ ជរស្ស ហោតីតិ ចក្ខុ-
វិញ្ញាណេន រូបឧស្សនេន ជរស្ស សុទ្ធិ វិសុទ្ធិ
បរិសុទ្ធិ មុត្តិ វិមុត្តិ បរិមុត្តិ ហោតិ ជរេ សុជ្ឈតិ
វិសុជ្ឈតិ បរិសុជ្ឈតិ មុចូតិ វិមុចូតិ បរិមុចូតីតិ ឥជ្ជេន
សំសុទ្ធិ ជរស្ស ហោតិ ។

[១១២] ឯវាភិជានំ បរមន្តិ ញត្វាតិ ឯវំ អភិជាន-
ន្តោ អាជានន្តោ វិជានន្តោ បដិវិជានន្តោ បដិវិជ្ឌ-
ន្តោ ឥទំ បរមំ អក្ខំ សេដ្ឋំ វិសេដ្ឋំ ចាមោក្ខំ ឧត្តមំ
បវរន្តិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវ-
យិត្វា វិភូតំ កត្វាតិ ឯវាភិជានំ បរមន្តិ ញត្វា ។

[១១៣] សុទ្ធានុបស្សីតិ បជ្ជេតិ ញាណន្តិ យោ
សុទ្ធំ បស្សតិ សោ សុទ្ធានុបស្សី ។ បជ្ជេតិ ញាណន្តិ
ចក្ខុវិញ្ញាណេន រូបឧស្សនំ ញាណន្តិ បជ្ជេតិ មត្តោតិ

[១១១] ពាក្យថា សេចក្តីបរិសុទ្ធដ៏ប្រពៃ របស់នរជន រមែងកើតមាន ដោយសាររូប ដែលខ្ជួនឃើញ សេចក្តីថា សេចក្តីស្អាត សេចក្តីស្អាតវិសេស សេចក្តីបរិសុទ្ធ ការផុត ការផុតស្រឡះ ការផុតដោយជុំវិញ របស់នរជន រមែងកើតមាន ឬនរជន ស្អាត ស្អាតវិសេស បរិសុទ្ធ ផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយសារការឃើញរូប ដោយចក្ខុវិញ្ញាណ ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្តីបរិសុទ្ធ ដ៏ប្រពៃ របស់នរជន រមែងកើតមាន ដោយសាររូប ដែលខ្ជួនឃើញ ។

[១១២] ពាក្យថា បុគ្គលពាលកាលដឹងច្បាស់យ៉ាងនេះ រមែងយល់ថា (ការឃើញនេះ) ឧត្តម គឺកាលដឹងចំពោះ ដឹងទូទៅ ដឹងវិសេស ដឹងច្បាស់ ចាក់ធ្ងុះចំពោះយ៉ាងនេះ រមែងយល់ ដឹង ថ្វឹងមើល ពិចារណាឃើញ យល់ច្បាស់ ធ្វើឲ្យប្រាកដថា ការឃើញនេះ ថ្លៃថ្នូ លើសលុបប្រសើរ ប្រសើរវិសេស ចម្បង ឧត្តម ក្រៃលែង ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលពាលកាលដឹងច្បាស់យ៉ាងនេះ រមែងយល់ថា (ការឃើញនេះ) ឧត្តម ។

[១១៣] ពាក្យថា អ្នកឃើញរឿយ ៗ នូវការបរិសុទ្ធ រមែងជឿ (នូវការឃើញនោះ) ថាជាញាណ សេចក្តីថា បុគ្គលណា ឃើញនូវសេចក្តីបរិសុទ្ធ បុគ្គលនោះឈ្មោះថា អ្នកឃើញរឿយ ៗ នូវសេចក្តីបរិសុទ្ធ ។ ពាក្យថា ជឿ (នូវការឃើញនោះ) ថាជាញាណ គឺជឿនូវការឃើញរូប ដោយចក្ខុវិញ្ញាណ ថាជាញាណ ជឿថាជាមគ្គ

បច្ចេតិ បថោតិ បច្ចេតិ ជិយ្យានន្តិ បច្ចេតីតិ សុទ្ធានុបស្សីតិ បច្ចេតិ ញាណំ ។ តេនាហ ភគវា

បស្ស្ចាមិ សុទ្ធំ បរមំ អរោគំ
ជិដ្ឋេន សំសុទ្ធិ ជរស្ស ហោតិ
ឯវាភិជានំ បរមន្តិ ញត្វា
សុទ្ធានុបស្សីតិ បច្ចេតិ ញាណន្តិ ។

[១១៤] ជិដ្ឋេន ចេ សុទ្ធិ ជរស្ស ហោតិ
ញាណេន វ សោ បជហាតិ ទុក្ខំ
អញ្ញេន សោ សុជ្ឈតិ សោបធីសោ
ជិជ្ជី ហិ ន ចាវ តថា វជានំ ។

[១១៥] ជិដ្ឋេន ចេ សុទ្ធិ ជរស្ស ហោតីតិ ចក្ខុ-
ញ្ញាណេន រូបទស្សនេន ចេ ជរស្ស សុទ្ធិ វិសុទ្ធិ បរិសុទ្ធិ មុត្តិ វិមុត្តិ បរិមុត្តិ ហោតិ ជរោ សុជ្ឈតិ វិសុជ្ឈតិ បរិសុជ្ឈតិ មុច្ចតិ វិមុច្ចតិ បរិមុច្ចតីតិ ជិដ្ឋេន ចេ សុទ្ធិ ជរស្ស ហោតិ ។

ជឿថាជាផ្លូវ ជឿថាជាគ្រឿងដឹកនាំ ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកឃើញរឿយ ៗ នូវសេចក្ដីបរិសុទ្ធ ជឿ (នូវការឃើញនោះ) ថាជាញាណ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

> អាត្មាអញឃើញ (នូវរូប) ដ៏បរិសុទ្ធ ឧត្តម មិនមានរោគ សេចក្ដីបរិសុទ្ធ ដ៏ប្រពៃ របស់នរជន រមែងមាន ដោយសារ (រូប) ដែលខ្លួនឃើញ បុគ្គលពាលអ្នកឃើញរឿយ ៗ នូវការបរិសុទ្ធ កាលដឹងច្បាស់យ៉ាងនេះ រមែងយល់ថា (ការឃើញនោះ) ឧត្តម ហើយជឿ (នូវការឃើញនោះ) ថាជាញាណ ។

[១១៦] បើសេចក្ដីបរិសុទ្ធ របស់នរជន កើតមាន ដោយសាររូបដែលខ្លួនឃើញ ឬនរជននោះលះបង់ទុក្ខ គឺរួចចាកទុក្ខ ដោយសារញាណបាន នរជនអ្នកមានឧបធិក្លេសនោះ ឈ្មោះថាបរិសុទ្ធ ដោយផ្លូវដទៃ ព្រោះថា ទិដ្ឋិរមែងប្រាប់នូវបុគ្គល អ្នកពោលដូច្នោះនោះ ។

[១១៧] ពាក្យថា បើសេចក្ដីបរិសុទ្ធ របស់នរជនកើតមាន ដោយសាររូប ដែលខ្លួនឃើញ គឺសេចក្ដីស្អាត ស្អាតវិសេស បរិសុទ្ធិ ការផុតផុតស្រឡះ ផុតដោយជុំវិញ របស់នរជន កើតមាន ឬនរជនស្អាត ស្អាតវិសេស បរិសុទ្ធ ផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយសារការឃើញរូប ដោយចក្ខុវិញ្ញាណ ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) បើសេចក្ដីបរិសុទ្ធ របស់នរជន កើតមាន ដោយសាររូប ដែលខ្លួនឃើញ ។

[១១៦] ញាណេន វា សោ បជហាតិ ទុក្ខន្តិ ចក្ខុវិញ្ញាណេន រូបឧស្សរេន ចេ នហ ជាតិទុក្ខំ បជហាតិ ជរាទុក្ខំ បជហាតិ ព្យាធិទុក្ខំ បជហាតិ មរណទុក្ខំ បជហាតិ សោកបរិទេវទុក្ខទោមនស្ស-ចាយាសទុក្ខំ បជហាតីតិ ញាណេន វា សោ បជហាតិ ទុក្ខំ ។

[១១៧] អញ្ញេន សោ សុជ្ឈតិ សោបធីកោតិ អញ្ញេន អសុទ្ធិមក្ខេន មិច្ឆាបដិបទាយ អនិយ្យានប-ថេន អញ្ញត្រ សតិប្បដ្ឋានេហិ អញ្ញត្រ សម្ម្ប្បធានេហិ អញ្ញត្រ ឥទ្ធិបាទេហិ អញ្ញត្រ ឥន្ទ្រិយេហិ អញ្ញត្រ ពលេហិ អញ្ញត្រ ពោជ្ឈង្គេហិ អញ្ញត្រ អរិយា អដ្ឋង្គិ-កា មគ្គា នហ សុជ្ឈតិ វិសុជ្ឈតិ បរិសុជ្ឈតិ មុចូតិ វិមុចូតិ បរិមុចូតិ ។ សោបធីកោតិ សរាគោ សទោសោ សមោហោ សមានោ សតណ្ហោ សទិដ្ឋិ សកិលេសោ សឧបាទានោតិ អញ្ញេន សោ សុជ្ឈតិ សោបធីកោ ។

[១១៦] *ពាក្យថា ឬនរជននោះ លះបង់ទុក្ខដោយសារញ្ញាណបាន គឺបើនរជន លះបង់ជាតិទុក្ខ លះបង់ជរាទុក្ខ លះបង់ព្យាធិទុក្ខ លះបង់មរណទុក្ខ លះបង់សោកទុក្ខ បរិទេវទុក្ខ ទុក្ខទុក្ខ ទោមនស្សទុក្ខ ឧបាយាសទុក្ខ ដោយសារការឃើញរូប ដោយចក្ខុវិញ្ញាណ ហេតុនោះ (ទ្រង់ត្រាស់ថា) ឬនរជននោះ លះបង់ទុក្ខ គឺរួចចាកទុក្ខ ដោយសារញ្ញាណបាន ។*

[១១៧] *ពាក្យថា នរជនអ្នកមានឧបធិក្លិសនោះ ឈ្មោះថាបរិសុទ្ធ ដោយផ្លូវដទៃ សេចក្ដីថា នរជនរមែងស្អាត ស្អាតវិសេស បរិសុទ្ធ ផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយផ្លូវមិនបរិសុទ្ធដទៃ ដោយបដិបទាខុស ដោយគន្ធងមិនមែនជាទីដឹកនាំ ក្រៅអំពីសតិប្ឋាន ក្រៅអំពីសម្ម្ចប្ធាន ក្រៅអំពីឥទ្ធិបាទ ក្រៅអំពីឥន្ទ្រិយ ក្រៅអំពីពល: ក្រៅអំពីពោជ្ឈង្គ ក្រៅអំពីអដ្ឋង្គិកមគ្គដ៏ប្រសើរ ។ ពាក្យថា មានឧបធិ-ក្លិសៈ គឺប្រកបដោយរាគ: ប្រកបដោយទោស: ប្រកបដោយមោហ: ប្រកបដោយមានៈ ប្រកបដោយតណ្ហា ប្រកបដោយទិដ្ឋិ ប្រកបដោយកិលេស ប្រកបដោយឧបាទាន ហេតុនោះ (ទ្រង់ត្រាស់ថា) នរជនអ្នកមានឧបធិក្លិសនោះ ឈ្មោះថា បរិសុទ្ធ ដោយផ្លូវដទៃ ។*

[១១៨] ទិដ្ឋី ហិ ន ចាវ តថា វជានន្តិ សាវ ទិដ្ឋិ
តំ បុគ្គលំ ចាវនតិ ឥតិចាយំ បុគ្គលោ មិច្ឆាទិដ្ឋិកោ
វិបរីតទស្សនោតិ ។ តថា វជានន្តិ តថា វនន្តំ ឆេទេន្តំ
ឆណន្តំ ឌីបយន្តំ ហេមវន្តំ សស្សតោ លោកោ
ឥទមេវ សច្ចំ មោឃមញ្ញន្តិ តថា វនន្តំ ឆេទេន្តំ
ឆណន្តំ ឌីបយន្តំ ហេមវន្តំ អសស្សតោ លោកោ
អន្តវា លោកោ អនន្តវា លោកោ តំ ជីវំ តំ សរីរំ
អញ្ញំ ជីវំ អញ្ញំ សរីរំ ហោតិ តថាគតោ បរម្មរណា
ន ហោតិ តថាគតោ បរម្មរណា ហោតិ ច ន ច
ហោតិ តថាគតោ បរម្មរណា នេវ ហោតិ ន ន
ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃ-
មញ្ញន្តិ តថា វនន្តំ ឆេទេន្តំ ឆណន្តំ ឌីបយន្តំ ហេ-
មវន្តន្តិ ទិដ្ឋី ហិ ន ចាវ តថា វជានំ ។ តេនាហ ភគវា

ទិដ្ឋេន ចេ សុទ្ធិ នរស្ស ហោតិ
ញាណេន វ សោ បជហាតិ ទុក្ខំ
អញ្ញេន សោ សុជ្ឈតិ សោបជីកោ
ទិដ្ឋី ហិ ន ចាវ តថា វជានន្តិ ។

[១១៨] ពាក្យថា ព្រោះថាទិដ្ឋិរមែងប្រាប់នូវបុគ្គល អ្នកពោលដូច្នោះនោះ សេចក្ដីថា ទិដ្ឋិនោះឯង រមែងប្រាប់បុគ្គលនោះដូច្នេះថា បុគ្គលនេះជាមិច្ឆាទិដ្ឋិ មានសេចក្ដីយល់ផ្ទុយ ។ ពាក្យថា ពោលដូច្នោះ គឺពោលថ្ងៃ ពណ៌នា ពន្យល់ ពោលប្រកាន់ដោយប្រការដូច្នោះ គឺពោលថ្ងៃ ពណ៌នា ពន្យល់ ពោលប្រកាន់ដោយប្រការដូច្នោះថា លោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ពោលថ្ងៃ ពណ៌នា ពន្យល់ ពោលប្រកាន់ ដោយប្រការដូច្នោះថា លោកមិនទៀង លោកមានទីបំផុត លោកមិនមានទីបំផុត ជីវៈនោះ សរីរៈនោះ ជីវៈដទៃ សរីរៈដទៃ សត្វស្លាប់ហើយ កើតទៀត សត្វស្លាប់ហើយ មិនកើតទៀត សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះថា ទិដ្ឋិរមែងប្រាប់នូវបុគ្គល អ្នកពោលដូច្នោះនោះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> *បើសេចក្ដីបរិសុទ្ធ របស់នរជន កើតមាន ដោយសាររូប ដែលខ្លួនឃើញ ឬនរជននោះ លះបង់ទុក្ខដោយញាណបាន នរជនអ្នកមានឧបធិក្លិសនោះ រមែងបរិសុទ្ធ ដោយផ្លូវដទៃ ព្រោះថា ទិដ្ឋិរមែងប្រាប់ នូវបុគ្គលអ្នកពោលដូច្នោះនោះ ។*

[១១៩] ន ព្រាហ្មណោ អញ្ញតោ សុទ្ធិមាហ
ទិដ្ឋេ សុតេ សីលវតេ មុតេ វា
បុញ្ញេ ច បាបេ ច អនូបលិត្តោ
អត្តញ្ជហោ នយិធ បកុព្វមានោ ។

[១២០] ន ព្រាហ្មណោ អញ្ញតោ សុទ្ធិមាហ ទិដ្ឋេ សុតេ សីលវតេ មុតេវាតិ នាតិ បដិក្ខេបោ ។ ព្រាហ្មណោតិ សត្តន្នំ ធម្មានំ ពាហិតត្តា ព្រាហ្មណោ សក្កាយទិដ្ឋិ ពាហិតា ហោតិ វិចិកិច្ឆា ពាហិតា ហោតិ សីលព្វតបរាមាសោ ពាហិតោ ហោតិ រាគោ ពាហិតោ ហោតិ ទោសោ ពាហិតោ ហោតិ មោហោ ពាហិតោ ហោតិ មានោ ពាហិតោ ហោតិ ។ ពាហិតស្ស ហោន្តិ បាបកា អកុសលា ធម្មា សង្កិលេសិកា បោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតឹ ជាតិជរាមរណីយា ។

ពាហេត្វា សព្វបាបកានិ (សភិយាតិ ភគវា)
វិមលោ សាធុសមាហិតោ ឋិតត្តោ

[១១៩] ព្រាហ្មណ៍ មិនពោលនូវសេចក្តីបរិសុទ្ធ ព្រោះផ្លូវដទៃ ព្រោះអារម្មណ៍ដែលឃើញ ឬឮ ព្រោះសីលនិងវត្ត ឬព្រោះអារម្មណ៍ដែលប៉ះពាល់ឡើយ ទាំងជាអ្នកមិនជាប់នៅ ក្នុងបុណ្យនិងបាប ជាអ្នកលះបង់នូវអត្តា ជាអ្នកលែងធ្វើ ក្នុងលោកនេះ ។

[១២០] *អធិប្បាយពាក្យថា ព្រាហ្មណ៍ មិនពោលនូវសេចក្តីបរិសុទ្ធ ព្រោះផ្លូវដទៃ ព្រោះអារម្មណ៍ដែលខ្លួនឃើញ ឬឮ ព្រោះសីលនឹងវត្ត ឬព្រោះអារម្មណ៍ ដែលប៉ះពាល់ឡើយ ត្រង់ពាក្យថា មិន គឺជាពាក្យបដិសេធ ។ ពាក្យថា ព្រាហ្មណ៍ គឺបុគ្គលដែលឈ្មោះថា ព្រាហ្មណ៍ ព្រោះបន្សាត់បង់ នូវធម៌ ៧ គឺ ជាអ្នកបន្សាត់បង់សក្កាយទិដ្ឋិ បន្សាត់បង់វិចិកិច្ឆា បន្សាត់បង់សីលព្វតបរាមាស: បន្សាត់បង់រាគ: បន្សាត់បង់ទោស: បន្សាត់បង់មោហ: បន្សាត់បង់មាន: ។ លោកបន្សាត់បង់អកុលសធម៌ទាំង-ឡាយដ៏លាមក ជាធម៌ប្រកបដោយសេចក្តីសៅហ្មងព្រម មានកិរិយានាំសត្វឲ្យកើតទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានផលជាទុក្ខ ជាបច្ច័យរបស់ជាតិ ជរា និងមរណ: តទៅទៀត ។*

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសកិយ:) បុគ្គលណា ដែលបន្សាត់ចោល នូវធម៌ដ៏លាមកទាំងពួង ជាអ្នកមានមន្ទិលទៅប្រាសហើយ មានចិត្តតម្កល់មាំ ដោយប្រពៃ

សំសារមតិចុ ភោវលី សោ

អនិស្សិតោ តានិ បវុច្ចតេ ស ព្រហ្ម ។

ន ព្រាហ្មណោ អញ្ញតោ សុទ្ធិមាហាតិ ព្រាហ្មណោ អញ្ញេន អសុទ្ធិមក្ខេន មិច្ឆាបដិបជ្ជាយ អនិយ្យានប-ថេន អញ្ញត្រ សតិប្បដ្ឋានេហិ អញ្ញត្រ សម្មប្បជ-ានេហិ អញ្ញត្រ ឥទ្ធិចានេហិ អញ្ញត្រ ឥន្ទ្រិយេហិ អញ្ញត្រ ពលេហិ អញ្ញត្រ ពោជ្ឈង្គេហិ អញ្ញត្រ អ-រិយា អដ្ឋង្គិកា មគ្គា សុទ្ធិ វិសុទ្ធិ បរិសុទ្ធិ មុត្តិ វិ-មុត្តិ បរិមុត្តិ ជាហ ន ភាវេតិ ន ភណ្ណតិ ន ជីព-យតិ ន ហារតីតិ ន ព្រាហ្មណោ អញ្ញតោ សុទ្ធិ-មាហ ។ ជិដ្ឋ សុតេ សីលវតេ មុតេ ភាតិ សន្តេកេ សមណាព្រាហ្មណា ជិដ្ឋសុទ្ធិកា តេ ឯកច្ចានំ រ្ជ្ជានំ ឧស្សនំ មង្គលំ បច្ចេន្តិ ឯកច្ចានំ រ្ជ្ជានំ ឧស្សនំ អមង្គលំ បច្ចេន្តិ ។

មានចិត្តនឹងធឹង កន្ទ្ធងហើយនូវសំសារ បុគ្គលនោះ ឈ្មោះថា ជាអ្នកមានកិច្ច សម្រេចអស់ហើយ ជាអ្នកមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) ជាតាទិបុគ្គល បុគ្គលនោះ លោកហៅថា ព្រាហ្មណ៍ ។

ពាក្យថា ព្រាហ្មណ៍ មិនពោលនូវសេចក្តីបរិសុទ្ធ ព្រោះផ្លូវដទៃ គឺ ព្រាហ្មណ៍ មិនពោល មិនថ្លែង មិនពណ៌នា មិនពន្យល់ មិនពោលប្រកាន់ នូវសេចក្តីស្អាត ស្អាតវិសេស សេចក្តីបរិសុទ្ធ ការផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយផ្លូវមិនបរិសុទ្ធដទៃ ដោយមិច្ឆាបដិ-បទា ដោយគន្ទ្ធង មិនជាទីដឹកនាំ ក្រៅចាកសតិប្បដ្ឋាន ក្រៅចាកសម្មប្បធាន ក្រៅចាកឥទ្ធិបាទ ក្រៅចាកឥន្ទ្រិយ ក្រៅចាកពល: ក្រៅចាកពោជ្ឈង្គ: ក្រៅចាកអដ្ឋង្គិកមគ្គដ៏ប្រសើរ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រាហ្មណ៍ មិនពោលនូវសេចក្តីបរិសុទ្ធ ព្រោះផ្លូវដទៃ ។ ពាក្យថា ព្រោះអារម្មណ៍ដែលខ្លួនឃើញ ឬឮ ព្រោះសីលនិងវ័ត ឬព្រោះអារម្មណ៍ដែលប៉ះពាល់ឡើយ សេចក្តីថា មានសមណព្រាហ្មណ៍ពួកខ្លះ ប្រកាន់សេចក្តីបរិសុទ្ធដោយសារូប ដែលឃើញ សមណព្រាហ្មណ៍ទាំងនោះ ជឿនូវការឃើញរូបទាំងឡាយខ្លះ ថាជាមង្គល ជឿនូវការឃើញរូបទាំងឡាយខ្លះ ថាមិនមែនជាមង្គល ។

កតមេសំ រូចានំ ឧស្សនំ មជ្ជលំ បច្ចេន្តិ ។ តេ កាលតោ រុដ្ឋហិត្វា អភិមជ្ជលកតានិ រូចានិ បស្សន្តិ ឱតសកុណ្ណ[1] បស្សន្តិ បុស្សវេឌ្ឍវលញ្ជ បស្សន្តិ ឥត្ថិនិត្តិ បស្សន្តិ ឥមារិកំ ១ន្ទ អាវេបេត្វា ឥច្ឆន្តំ បស្សន្តិ បុណ្ណាយដ បស្សន្តិ ពេហិតមច្ចំ បស្សន្តិ អាជញ្ញ បស្សន្តិ អាជញ្ញរថ បស្សន្តិ ឧសភ បស្សន្តិ ពោកបិលំ បស្សន្តិ ឯវរូចានំ រូចានំ ឧស្សនំ មជ្ជលំ បច្ចេន្តិ ។

កតមេសំ រូចានំ ឧស្សនំ អមជ្ជលំ បច្ចេន្តិ ។ បលាលបុញ្ជ បស្សន្តិ ឥក្ខាយដ បស្សន្តិ រិត្តយដ បស្សន្តិ ឆដ បស្សន្តិ ឆក្ខសមណ្ណ បស្សន្តិ ១ារ បស្សន្តិ ១ារយានំ បស្សន្តិ ឯកយុត្តយានំ បស្សន្តិ ១ាណ្ណ បស្សន្តិ ១ុណ្ណ បស្សន្តិ ១ញ្ជ បស្សន្តិ បក្ខ្ហតំ[2] បស្សន្តិ ជិណ្ណ១ំ បស្សន្តិ ១ាធិ១ំ បស្សន្តិ មតំ បស្សន្តិ ឯវរូចានំ រូចានំ ឧស្សនំ អមជ្ជលំ បច្ចេន្តិ ។

---

១ ម. ១ាបសកុណ្ណ ។ ២ ម. បក្ខ្ហ១ាទ ។

សមណព្រាហ្មណ៍ទាំងឡាយពួកខ្លះ ជឿនូវការឃើញរូបទាំងឡាយ ដូចម្តេច ថាជាមង្គល ។ សមណព្រាហ្មណ៍ទាំងនោះ ក្រោកឡើង អំពីព្រលឹម ឃើញនូវរូបទាំងឡាយ ដែលសន្មតថាជាមង្គលដ៏ក្រៃលែង គឺឃើញសត្វត្រចៀកកាំ ឃើញដើមញ្ជៅដែលដុះ ដោយបុស្សនក្ខត្តឫក្ស ឃើញស្ត្រីមានគភ៌ ឃើញបុគ្គលកំពុងបញ្ជិះនាងកុមារិកាលើ-ក ដើរទៅ ឃើញក្អមមានទឹកពេញ ឃើញត្រីឆ្ពិន ឃើញសេះអាជានេយ្យ ឃើញ រថដែលទឹម ដោយសេះអាជានេយ្យ ឃើញគោឧសភ ឃើញមេគោ ក្រហម ក៏ប្រកាន់ជឿនូវការឃើញរូបទាំងឡាយ មានសភាពយ៉ាងនេះ ថាជាមង្គល ។

សមណព្រាហ្មណ៍ទាំងឡាយ ពួកខ្លះ ជឿនូវការឃើញរូបទាំង-ឡាយដូចម្តេច ថាមិនមែនជាមង្គល ។ សមណព្រាហ្មណ៍ ទាំងនោះ ឃើញគំនរចំបើង ឃើញផ្ទាំងខ្ញាញ់ ឃើញផ្ទាំងទទេ ឃើញស្ត្រីរបាំ ឃើញស្រមណ៍អាក្រាត ឃើញលា ឃើញយាន ដែលទឹមដោយលា ឃើញយាន ដែលទឹមដោយសត្វពាហនៈម្ខាង ឃើញមនុស្សខ្វាក់ ឃើញមនុស្សកៃង ឃើញមនុស្សខ្ជក ឃើញមនុស្សខ្ជិន ឃើញ មនុស្សជរា ឃើញមនុស្សឈឺ ឃើញមនុស្សស្លាប់ ក៏ប្រកាន់ជឿនូវការ ឃើញរូបទាំងឡាយ មានសភាពយ៉ាងនេះ ថាមិនមែនជាមង្គល ។

ឥមេ តេ សមណព្រាហ្មណា ឧច្ឆេទសុទ្ធិកា តេ ឧច្ឆេទ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ បញ្ញេន្តិ ។

សន្តេកេ សមណព្រាហ្មណា សុតសុទ្ធិកា តេ ឯកច្ចានំ សទ្ធានំ សវនំ មង្គលំ បញ្ញេន្តិ ឯកច្ចានំ សទ្ធានំ សវនំ អមង្គលំ បញ្ញេន្តិ ។

កតមេសំ សទ្ធានំ សវនំ មង្គលំ បញ្ញេន្តិ ។ តេ កាលតោ រុដ្ឋហិត្វា អកិមង្គលកតានិ សទ្ធានិ សុ-ណន្តិ វឌ្ឍាតិ វ វឌ្ឍមានាតិ វ បុណ្ណាតិ វ បុស្សាតិ វ អសេ្ឋកាតិ វ សុមនាតិ វ សុនក្ខត្តាតិ វ សុមង្គលាតិ វ សិរីតិ វ សិរីវឌ្ឍាតិ វ ឯវរូបានំ សទ្ធានំ សវនំ មង្គលំ បញ្ញេន្តិ ។

កតមេសំ សទ្ធានំ សវនំ អមង្គលំ បញ្ញេន្តិ ។

សមណព្រាហ្មណ៍ទាំងឡាយនេះ ប្រកាន់សេចក្ដីបរិសុទ្ធដោយសាររូប ដែលឃើញ សមណព្រាហ្មណ៍ទាំងនោះ តែងជឿថា សេចក្ដីស្អាត ស្អាតវិសេស សេចក្ដីបរិសុទ្ធ ការផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយសាររូបដែលឃើញ ។

មានសមណព្រាហ្មណ៍ពួកខ្លះ ប្រកាន់សេចក្ដីបរិសុទ្ធដោយសំឡេង ដែលឮ សមណព្រាហ្មណ៍ទាំងនោះ ជឿនូវការឮសំឡេងទាំងឡាយខ្លះ ថាជាមង្គល ជឿនូវការឮសំឡេងទាំងឡាយខ្លះ ថាមិនមែនជាមង្គល ។

សមណព្រាហ្មណ៍ទាំងឡាយពួកខ្លះ រមែងជឿនូវការឮសំឡេង ទាំងឡាយដូចម្ដេច ថាជាមង្គល ។ សមណព្រាហ្មណ៍ទាំងឡាយនោះ ក្រោកឡើងអំពីព្រលឹម ឮសំឡេងទាំងឡាយ ដែលសន្ធតថាជាមង្គល ដ៏ក្រៃលែង ដូចឮថាចម្រើនក្ដី កំពុងចម្រើនក្ដី ពេញក្ដី សក្ដី មិន មានសោកក្ដី មានចិត្តល្អក្ដី នក្ខត្តឫក្សល្អក្ដី មង្គលល្អក្ដី សិរីក្ដី ចម្រើនដោយសិរីក្ដី ក៏ប្រកាន់ជឿ នូវការឮសំឡេងទាំងឡាយ មាន សភាពយ៉ាងនេះ ថាជាមង្គល ។

សមណព្រាហ្មណ៍ទាំងឡាយ ពួកខ្លះ ជឿនូវការឮសំឡេងទាំង-ឡាយដូចម្ដេច ថាមិនមែនជាមង្គល ។

កាណោតិ វា កុណីតិ វា ខញ្ជោតិ វា បក្ខហតោតិ វា ជិណ្ណកោតិ វា ព្យាធិកោតិ វា មតោតិ វា ឆិន្នន្តិ វា ភិន្នន្តិ វា ឧឌ្ឍន្តិ វា នដ្ឋន្តិ វា នត្ថីតិ វា ឯវរូបានំ សទ្ទានំ សវនំ អមង្គលំ បច្ចេន្តិ ។ ឥមេ តេ សមណព្រាហ្មណា សុតសុទ្ធិកា តេ សុតេន សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ បច្ចេន្តិ ។

សន្តេកេ សមណព្រាហ្មណា សីលសុទ្ធិកា តេ សីលមត្តេន សញ្ញមមត្តេន សំវរមត្តេន អវីតិក្កមមត្តេន សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ បច្ចេន្តិ ។ សមណមុណ្ឌិកាបុត្តោ ឯវមាហ ចតូហិ ខោ អហំ ថបតិ[១] ធម្មេហិ សមន្នាគតំ បុរិសបុគ្គលំ បញ្ញាបេមិ សម្បន្នកុសលំ បរមកុសលំ ឧត្តមប្បត្តិប្បត្តំ សមណំ អយោជ្ឈំ ។ កតមេហិ ចតូហិ[១] ។ ឥធ ថបតិ ន កាយេន បាបកម្មំ ករោតិ ន បាបិកំ វាចំ ភាសតិ

១ ម. គហបតិ ។

សមណព្រាហ្មណ៍ទាំងនោះ ឮពាក្យថា មនុស្សខ្វាក់ក្តី ក្ងែងក្តី ខ្ជកក្តី ខ្ជិនក្តី ជរាក្តី ឈឺក្តី ស្វាប់ក្តី ដាច់ក្តី បែកក្តី ឆេះក្តី វិនាសក្តី មិនមានក្តី ក៏ប្រកាន់ជឿនូវការឮសំឡេង មានសភាពយ៉ាងនេះ ថាមិនមែនជាមង្គល ។ សមណព្រាហ្មណ៍ទាំងនេះ អ្នកប្រកាន់សេចក្តីបរិសុទ្ធដោយសំឡេងដែលឮ គឺសមណព្រាហ្មណ៍ទាំងនោះ ជឿនូវសេចក្តីស្អាត ស្អាតវិសេស ស្អាតជុំវិញ ការផុត ផុតស្រឡះ ផុតដោយជុំវិញ ព្រោះសំឡេងដែលឮ ។

មានសមណព្រាហ្មណ៍ពួកខ្លះ ប្រកាន់សេចក្តីបរិសុទ្ធដោយសីល សមណព្រាហ្មណ៍ទាំងនោះ តែងជឿថាសេចក្តីស្អាត ស្អាតវិសេស ស្អាតជុំវិញ ការផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយហេតុត្រឹមតែសីល ត្រឹមតែការសង្រួម ត្រឹមតែការរារាំង ត្រឹមតែការមិនប្រព្រឹត្តកន្ទង ។ សមណមុណ្ឌិកាបុត្រ បានពោលយ៉ាងនេះថា ម្នាលជាងឈើ ខ្ញុំតែងបញ្ញត្ត នូវបុរសបុគ្គល ដែលប្រកបដោយធម៌ទាំងឡាយ ៤ យ៉ាង ថាជាបុគ្គលមានកុសលបរិបូណ៌ មានកុសលដ៏ឧត្តម ជាបុគ្គលដល់ហើយនូវធម៌ ដែលគេគប្បីដល់ដ៏ឧត្តម ជាសមណៈមិនមានបរាជ័យ ។ ធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលជាងឈើ បុរសបុគ្គលក្នុងលោកនេះ មិនធ្វើនូវអំពើលាមកដោយកាយ ១ មិនពោលនូវវាចាដ៏លាមក ១

ន ចាបកំ សង្កប្បំ សង្កប្បេតិ ន ចាបកំ អាជីវំ អាជីវតិ ។ ឥមេហិ ខោ អហំ ថបតិ ចតូហិ ធម្មេហិ សមន្នាគតំ បុរិសបុគ្គលំ បញ្ញាបេមិ សម្បន្នកុសលំ បរមកុសលំ ឧត្តមប្បត្តិប្បត្តំ សមណំ អយោជ្ឈំ ។ ឯវមេវ សន្តេកេ សមណព្រាហ្មណា សីលសុទ្ធិកា តេ សីលមត្តេន សញ្ញមមត្តេន សំវរមត្តេន អវីតិក្កមមត្តេន សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ បច្ចេន្តិ ។

សន្តេកេ សមណព្រាហ្មណា វត្តសុទ្ធិកា តេ ហត្ថិវត្តិកា វា ហោន្តិ អស្សវត្តិកា វា ហោន្តិ គោវត្តិកា វា ហោន្តិ កុក្កុរវត្តិកា វា ហោន្តិ កាកវត្តិកា វា ហោន្តិ វាសុទេវវត្តិកា វា ហោន្តិ ពលទេវវត្តិកា វា ហោន្តិ បុណ្ណភទ្ទវត្តិកា វា ហោន្តិ មណិភទ្ទវត្តិកា វា ហោន្តិ អគ្គិវត្តិកា វា ហោន្តិ នាគវត្តិកា វា ហោន្តិ សុបណ្ណវត្តិកា វា ហោន្តិ យក្ខវត្តិកា វា ហោន្តិ អសុរវត្តិកា វា ហោន្តិ គន្ធព្វវត្តិកា វា ហោន្តិ មហារាជវត្តិកា វា ហោន្តិ ចន្ទវត្តិកា វា ហោន្តិ

មិនត្រិះរិះនូវសេចក្ដីត្រិះរិះដ៏លាមក ១ មិនចិញ្ចឹមជីវិតដោយការចិញ្ចឹមជីវិតដ៏លាមក ១ ម្នាលជាងឈើ ខ្ញុំតែងបញ្ញត្តនូវបុរសបុគ្គល ដែលប្រកបដោយធម៌ ៤ នេះឯង ថាជាបុគ្គល មានកុសលដ៏បរិបូណ៌ មានកុសលដ៏ឧត្តម ជាបុគ្គលដល់ហើយនូវធម៌ ដែលបុគ្គលគប្បីដល់ដ៏ឧត្តម ជាសមណៈ មិនមានបរាជ័យ ។ មានសមណព្រាហ្មណ៍ពួកខ្លះ ជាអ្នកប្រកាន់នូវសេចក្ដីបរិសុទ្ធដោយសីល សមណព្រាហ្មណ៍ទាំងនោះ រមែងជឿសេចក្ដីស្អាត ស្អាតវិសេស ស្អាតជុំវិញ ការផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយហេតុត្រឹមតែសីល ត្រឹមតែការសង្រួម ត្រឹមតែការរារាំង ត្រឹមតែការមិនប្រព្រឹត្តកន្ទ្ធ យ៉ាងនេះឯង ។

មានសមណព្រាហ្មណ៍ពួកខ្លះ ជាអ្នកប្រកាន់ នូវសេចក្ដីបរិសុទ្ធដោយវត្ត សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកប្រព្រឹត្តវត្តដំរីក៏មាន ប្រព្រឹត្តវត្តសេះក៏មាន ប្រព្រឹត្តវត្តគោក៏មាន ប្រព្រឹត្តវត្តឆ្កែក៏មាន ប្រព្រឹត្តវត្តក្អែកក៏មាន ប្រព្រឹត្តវត្តរបស់វាសុទេពក៏មាន ប្រព្រឹត្តវត្តរបស់ពលទេពក៏មាន ប្រព្រឹត្តវត្តរបស់បុណ្ណភទ្ទក៏មាន ប្រព្រឹត្តវត្តរបស់មណិភទ្ទក៏មាន ប្រព្រឹត្តវត្តក្ងើងក៏មាន ប្រព្រឹត្តវត្តនាគក៏មាន ប្រព្រឹត្តវត្តគ្រុទក៏មាន ប្រព្រឹត្តវត្តយក្ខក៏មាន ប្រព្រឹត្តវត្តអសុរក៏មាន ប្រព្រឹត្តវត្តគន្ធព្វក៏មាន ប្រព្រឹត្តវត្តមហារាជក៏មាន ប្រព្រឹត្តវត្តព្រះចន្ទ្រក៏មាន

សុរិយវត្តិកា វ ហោន្តិ ឥន្ទវត្តិកា វ ហោន្តិ ព្រហ្ម-
វត្តិកា វ ហោន្តិ ទេវវត្តិកា វ ហោន្តិ ឥសិវត្តិកា វ
ហោន្តិ ។ ឥមេ តេ សមណព្រាហ្មណា វត្តសុទ្ធិកា
តេ វត្តេន សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ
បច្ចេន្តិ ។

សន្តេកេ សមណព្រាហ្មណា មុតសុទ្ធិកា ។
តេ កាលតោ រុដ្ឋហិត្វា បបរឹ អាមសន្តិ ហរិតំ អា-
មសន្តិ តោមយំ អាមសន្តិ ឆកណ្ឌំ អាមសន្តិ ជាលំ
អក្កមន្តិ តិលវាហំ អាមសន្តិ បុស្សតិលំ ខាទន្តិ
បុស្សតេលំ មក្ខេន្តិ បុស្សទន្តកដ្ឋំ ខាទន្តិ បុស្ស-
មត្តិកាយ ឧហាយន្តិ បុស្សសាដកំ និវាសេន្តិ បុស្ស-
វេដ្ឋនំ វេដ្ឋន្តិ ។ ឥមេ តេ សមណព្រាហ្មណា មុត-
សុទ្ធិកា តេ មុតេន សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ
វិមុត្តឹ បរិមុត្តឹ បច្ចេន្តិ ។

ន ព្រាហ្មណោ អញ្ញតោ សុទ្ធិមាហ

ប្រព្រឹត្តវត្តព្រះអាទិត្យក៏មាន ប្រព្រឹត្តវត្តព្រះឥន្ទ្រក៏មាន ប្រព្រឹត្តវត្ត ព្រះព្រហ្មក៏មាន ប្រព្រឹត្តវត្តទេព្តាក៏មាន ប្រព្រឹត្តវត្តសំពះទិសក៏មាន ។ សមណព្រាហ្មណ៍ទាំងឡាយនេះ ជាអ្នកប្រកាន់សេចក្ដីបរិសុទ្ធដោយវត្ត សមណព្រាហ្មណ៍ទាំងនោះ រមែងជឿសេចក្ដីស្អាត ស្អាតវិសេស ស្អាតជុំវិញ ការផុត ផុតស្រឡះ ផុតដោយជុំវិញ ព្រោះវត្ត ។

មានសមណព្រាហ្មណ៍ពួកខ្លះ អ្នកប្រកាន់សេចក្ដីបរិសុទ្ធដោយ អារម្មណ៍ដែលប៉ះពាល់ ។ សមណព្រាហ្មណ៍ទាំងនោះ ក្រោកឡើង អំពីព្រលឹម ស្នាបប្រឹចពី ស្នាបស្មៅស្រស់ ស្នាបអាចម៍គោ ស្នាប អណ្ដើក ជាន់នូវបណ្ដាញ(ដែក) ស្នាបរនេះដែលពេញដោយលូ ស៊ីលូ ដែលជាមង្គល លាបប្រេងមង្គល ស៊ីឈើស្ងួនមង្គល ងូតដោយដីស្អិត មង្គល ស្ងៀកសំពត់មង្គល ជួតឈ្នួតមង្គល ។ សមណព្រាហ្មណ៍ទាំងនេះ ជាអ្នកប្រកាន់សេចក្ដីបរិសុទ្ធ ដោយអារម្មណ៍ដែលប៉ះពាល់ សមណ-ព្រាហ្មណ៍ទាំងនោះ រមែងជឿ សេចក្ដីស្អាត ស្អាតវិសេស ស្អាតជុំវិញ ការផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយអារម្មណ៍ដែលប៉ះពាល់ ។

ពាក្យថា ព្រាហ្មណ៍មិនពោលនូវសេចក្ដីបរិសុទ្ធ ព្រោះផ្ទូវដទៃ

ជិដ្ឋេ សុតេ សីលវតេ មុតេ វាតិ ព្រាហ្មណោ ជិដ្ឋ-
សុទ្ធិយាបិ សុទ្ធឹ ជាហ សុតសុទ្ធិយាបិ សុទ្ធឹ ជាហ
សីលសុទ្ធិយាបិ សុទ្ធឹ ជាហ វត្តសុទ្ធិយាបិ សុទ្ធឹ
ជាហ មុតសុទ្ធិយាបិ សុទ្ធឹ ជាហ ន ឆាទេតិ ន
ឆណតិ ន ឧបយតិ ន ហាបេតីតិ ន ព្រាហ្មណោ
អញ្ញតោ សុទ្ធិមាហ ជិដ្ឋេ សុតេ សីលវតេ មុតេ វា ។

[១២១] បុញ្ញ ច ចាបេ ច អនូបលិត្តោតិ បុញ្ញ
វុច្ចតិ យន្តិ ញ្ចិ ញ្ចិ តេជាតុកំ កុសលាភិសង្ខារំ ។ អ-
បុញ្ញ[1] វុច្ចតិ សព្ពំ អកុសលំ ។ យតោ បុញ្ញាភិ-
សង្ខារេ ច អបុញ្ញាភិសង្ខារេ ច អានេញ្ជាភិសង្ខា-
រេ ច បហីនា ហោន្តិ ឧច្ឆិន្នមូលា តាលាវត្ថុកតា

១ ម. អយំ ។

ព្រោះអារម្មណ៍ដែលឃើញក្តី ដែលឮក្តី ព្រោះសីលនិងវត្តក្តី ព្រោះអារម្មណ៍ដែលប៉ះពាល់ក្តី បានសេចក្តីថា ព្រាហ្មណ៍មិនពោលនូវសេចក្តីបរិសុទ្ធ ដោយសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញផង មិនពោលនូវសេចក្តីបរិសុទ្ធ ដោយសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឮផង មិនពោលនូវសេចក្តីបរិសុទ្ធ ដោយសេចក្តីបរិសុទ្ធ ព្រោះសីលផង មិនពោលនូវសេចក្តីបរិសុទ្ធ ដោយសេចក្តីបរិសុទ្ធ ព្រោះវត្តផង មិនពោល មិនថ្លែង មិនពណ៌នា មិនពន្យល់ មិននិយាយ នូវសេចក្តីបរិសុទ្ធិ ដោយសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលប៉ះពាល់ផង ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) ព្រាហ្មណ៍មិនពោល នូវសេចក្តីបរិសុទ្ធ ដោយផ្លូវដទៃ ព្រោះអារម្មណ៍ដែលឃើញក្តី ដែលឮក្តី ព្រោះសីលនិងវត្តក្តី ព្រោះអារម្មណ៍ដែលប៉ះពាល់ក្តី ។

[១២១] ពាក្យថា មិនជាប់នៅក្នុងបុណ្យនិងបាប មានសេចក្តីថា កុសលាភិសង្ខារណាមួយ ដែលឲ្យបដិសន្ធិក្នុងត្រៃធាតុ លោកហៅថា បុណ្យ ។ អកុសលទាំងអស់ លោកហៅថា បាប ។ កាលណាបុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារនិងអានេញ្ជាភិសង្ខារ ដែលព្រាហ្មណ៍លះបង់ហើយ ផ្តាច់ឫសចោលហើយ ធ្វើមិនឲ្យមានទីកើតដូចជាដើមត្នោត

អនភាវង្កតា អាយតឹ អនុប្បាទធម្មា ឯត្តាវតា ច បុញ្ញេ ច ចាបេ ច ន លិម្បតិ ន សំលិម្បតិ ន ឧបលិម្បតិ អលិត្តោ អសំលិត្តោ អនុបលិត្តោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ បុញ្ញេ ច ចាបេ ច អនូបលិត្តោ ។

[១២២] អត្តញ្ជហោ នយិធ បកុព្វមានោតិ អត្តញ្ជហោតិ អត្តទិដ្ឋិជហោ ។ អត្តញ្ជហោតិ គាហជហោ ។ អត្តញ្ជហោតិ តណ្ហាវសេន ទិដ្ឋិវសេន គហិតំ បរាមដ្ឋំ អភិនិវិដ្ឋំ អជ្ឈោសិតំ អធិមុត្តំ សព្វំ[១] តំ ចត្តំ ហោតិ វន្តំ មុត្តំ បហីនំ បដិនិស្សដ្ឋំ ។ នយិធ បកុព្វមានោតិ បុញ្ញាភិសង្ខារំ វា អបុញ្ញាភិសង្ខារំ វា អានេញ្ជាភិសង្ខារំ វា អកុព្វមានោ អជនយមានោ អសញ្ជនយមានោ អនិព្វត្តយមានោ អនភិនិព្វត្តយមានោតិ អត្តញ្ជហោ នយិធ បកុព្វមានោ ។ តេនាហ ភគវា

១ ម. សព្វស្ស ។

ដល់នូវភាពតាំងនៅមិនបាន មានសភាពមិនកើតតទៅទៀត ក្នុងកាលណា ព្រាហ្មណ៍ឈ្មោះថា មិនជាប់ មិនជាប់ព្រម មិនជាប់មាំ ជាអ្នកមិនប្រឡាក់ មិនប្រឡាក់ព្រម មិនចូលទៅប្រឡាក់ ស្ទុះចេញ លះបង់ រួចស្រឡះ ប្រាសចេញ មានចិត្តប្រាសចាកកិលេសដូចជាទំនប់ជាដើម ក្នុងបុណ្យនិងបាប ព្រោះហេតុប៉ុណ្ណោះ ក្នុងកាលនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនជាប់នៅក្នុងបុណ្យនិងបាប ។

[១២២] ពាក្យថា ជាអ្នកលះបង់នូវអត្តា លៃងធ្វើក្នុងលោកនេះ អធិប្បាយថា អ្នកលះបង់នូវអត្តទិដ្ឋិ ឈ្មោះថា អ្នកលះបង់នូវអត្តា ។ អ្នកលះបង់នូវសេចក្តីប្រកាន់ ឈ្មោះថា អ្នកលះបង់នូវអត្តា ។ វត្ថុណា ដែលគេប្រកាន់ បបោសអង្ហែល ត្រេកអរចំពោះ ចុះចិត្ត ចុះចិត្តស៊ប់ហើយ ដោយអំណាចតណ្ហា ដោយអំណាចទិដ្ឋិ វត្ថុទាំងអស់នោះ ព្រាហ្មណ៍ បានកម្ចាត់ ខ្ជាក់ចោល ផុត លះបង់ រលាស់ចោលហើយ ឈ្មោះថា អ្នកលះបង់នូវអត្តា ។ ពាក្យថា លៃងធ្វើក្នុងលោកនេះ គឺមិនធ្វើ មិនឲ្យកើត មិនឲ្យកើតព្រម មិនបង្កើត មិនបង្កើតចំពោះ នូវបុញ្ញាភិសង្ខារក្តី នូវអបុញ្ញាភិសង្ខារក្តី នូវអានេ-ញ្ជាភិសង្ខារក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកលះបង់នូវអត្តាលៃងធ្វើក្នុងលោកនេះ ។ ហេតុនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

ន ព្រាហ្មណោ អញ្ញតោ សុទ្ធិមាហ
ទិដ្ឋេ សុតេ សីលវតេ មុតេ វា
បុញ្ញេ ច ចាបេ ច អនូបលិត្តោ
អត្តញ្ជហោ ឧយិធ បកុព្ធមានោតិ ។

[១២៣] បុរិមំ បហាយ អបរំ សិតាសេ
ឯជានុគា តេ ន តរន្តិ សង្គំ
តេ ឧក្ខហាយន្តិ និរស្សជន្តិ
ភវីវ សាខំ បមុខំ ភហាយ ។

[១២៤] បុរិមំ បហាយ អបរំ សិតាសេតិ បុរិមំ សន្តានំ បហាយ អបរំ សន្តានំ និស្សិតា បុរិមំ ឆម្ភក្ខានំ បហាយ អបរំ ឆម្ភក្ខានំ និស្សិតា បុរិមំ ភណ្ដំ បហាយ អបរំ ភណ្ដំ និស្សិតា បុរិមំ ទិដ្ឋិ បហាយ អបរំ ទិដ្ឋិ និស្សិតា បុរិមំ បដិបទំ បហាយ អបរំ បដិបទំ និស្សិតា បុរិមំ មក្ខំ បហាយ អបរំ មក្ខំ និស្សិតា សន្ទិស្សិតា អលីនា ឧបគតា អជ្ឈ-សិតា អធិមុត្តាតិ បុរិមំ បហាយ អបរំ សិតាសេ ។

ព្រាហ្មណ៍ មិនពោលនូវសេចក្តីបរិសុទ្ធ ដោយផ្លូវដទៃ ព្រោះអារម្មណ៍ដែលឃើញក្តី ដែលឮក្តី ព្រោះសីលនិងវត្តក្តី ព្រោះអារម្មណ៍ដែលប៉ះពាល់ក្តី ទាំងមិនជាប់នៅក្នុងបុណ្យ និងបាប ជាអ្នកលះបង់នូវអត្តា លែងធ្វើក្នុងលោកនេះ ។

[១២៣] ជនណា ជាអ្នកលង់តាមការញ្ជាប់ញ័រ លះបង់វត្ថុមុន អាស្រ័យវត្ថុក្រោយ ជននោះ នឹងធ្វងនូវការជាប់ចំពាក់ មិនបានទេ ជននោះ តែងប្រកាន់ តែងលះបង់ ដូចជាស្វាតោងមែកឈើចំពោះមុខ ។

[១២៤] ពាក្យថា លះបង់វត្ថុមុន ហើយអាស្រ័យវត្ថុក្រោយ គឺលះបង់សាស្តាមុន មកពឹងផ្អែកនឹងសាស្តាក្រោយ លះបង់ធម៌ដែលសាស្តាប្រាប់មុន មកអាស្រ័យធម៌ដែលសាស្តាប្រាប់ក្រោយ លះបង់ពួកមុន មកអាស្រ័យពួកក្រោយ លះបង់ទិដ្ឋិមុន មកអាស្រ័យទិដ្ឋិក្រោយ លះបង់បដិបទាមុន មកអាស្រ័យបដិបទាក្រោយ លះបង់មគ្គមុន ហើយអាស្រ័យ អាស្រ័យព្រម ជាប់នៅ ជក់នៅ ចុះចិត្ត ចុះចិត្តស៊ប់នូវមគ្គក្រោយ ហេតុនោះ (ទ្រង់ត្រាស់ថា) តែងលះបង់វត្ថុមុន អាស្រ័យវត្ថុក្រោយ ។

[១២៥] ឯជានុគា តេ ន តរន្តិ សង្គន្តិ ឯជា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ ឯជានុគាតិ ឯជានុគា ឯជានុគតា ឯជានុសដា ឯជាយាបន្នា បតិតា អភិភូ-តា បរិយាទិន្នចិត្តា ។ ន តរន្តិ សង្គន្តិ រាគសង្គំ ទោស-សង្គំ មោហសង្គំ មានសង្គំ ទិដ្ឋិសង្គំ កិលេសសង្គំ ទុច្ចរិតសង្គំ ន តរន្តិ ន ឧត្តរន្តិ ន បតរន្តិ ន សមតិ-ក្កមន្តិ ន វីតិវត្តន្តីតិ ឯជានុគា តេ ន តរន្តិ សង្គំ ។

[១២៦] តេ ឧគ្គហាយន្តិ និរស្សជន្តីតិ សត្ថារំ គណ្ហន្តិ តំ មុញ្ចិត្វា អញ្ញំ សត្ថារំ គណ្ហន្តិ ធម្មក្ខានំ គណ្ហន្តិ តំ មុញ្ចិត្វា អញ្ញំ ធម្មក្ខានំ គណ្ហន្តិ គណំ គណ្ហន្តិ តំ មុញ្ចិត្វា អញ្ញំ គណំ គណ្ហន្តិ ទិដ្ឋឹ គណ្ហន្តិ តំ មុញ្ចិត្វា អញ្ញំ ទិដ្ឋឹ គណ្ហន្តិ បដិបទំ គណ្ហន្តិ តំ មុញ្ចិត្វា អញ្ញំ បដិបទំ គណ្ហន្តិ មគ្គំ គណ្ហន្តិ

[១២៥] ពាក្យថា ជនណាជាអ្នកលង់តាមការញាប់ញ័រ... ជននោះ នឹងធ្វើនូវការជាប់ចំពាក់មិនបានទេ អធិប្បាយថា តណ្ហាហៅថាការញាប់ញ័រ បានខាង តម្រេក តម្រេកខ្លាំង ។ បេ ។ អកិញ្ចាលោកៈ អកុសលមូល ។ ពាក្យថា ជាអ្នកលង់តាមការញាប់ញ័រ គឺជាអ្នកប្រព្រឹត្តតាមការញាប់ញ័រ ទៅតាមការញាប់ញ័រ ផ្សាយទៅតាមការញាប់ញ័រ ដល់នូវការញាប់ញ័រ ធ្លាក់ចុះ គ្របសង្កត់ មានចិត្តរួបរឹតដោយការញាប់ញ័រ ។ ពាក្យថា នឹងធ្វើនូវការជាប់ចំពាក់ មិនបានទេ គឺនឹងធ្វើមិនបាន ធ្វើឡើងមិនបាន ធ្វើមិនផុត មិនកន្ធងព្រម មិនប្រព្រឹត្តកន្ធង នូវការចំពាក់គឺរាគៈ ការចំពាក់គឺទោសៈ ការចំពាក់គឺមោហៈ ការចំពាក់គឺមានៈ ការចំពាក់គឺទិដ្ឋិ ការចំពាក់គឺកិលេស ការចំពាក់គឺទុច្ចរិត ហេតុនោះ (ទ្រង់ត្រាស់ថា) ជនណា ជាអ្នកលង់តាមការញ្ជាប់ញ័រ ជននោះ នឹងធ្វើនូវការជាប់ចំពាក់មិនបានទេ ។

[១២៦] ពាក្យថា ជនទាំងនោះ តែងប្រកាន់ តែងលះបង់ សេចក្តីថា ប្រកាន់យកនូវសាស្តា លះបង់នូវសាស្តានោះ ហើយប្រកាន់សាស្តាដទៃវិញ ប្រកាន់ធម៌ដែលសាស្តាប្រាប់ លះបង់ធម៌ដែលសាស្តាប្រាប់នោះ ហើយប្រកាន់ធម៌ដទៃដែលសាស្តាប្រាប់វិញ ប្រកាន់ពួក លះបង់ពួកនោះហើយ ប្រកាន់ពួកដទៃវិញ ប្រកាន់ទិដ្ឋិ លះបង់ទិដ្ឋិនោះ ហើយប្រកាន់ទិដ្ឋិដទៃវិញ ប្រកាន់បដិបទា លះបង់បដិបទានោះ ហើយប្រកាន់បដិបទាដទៃវិញ

តំ មុញ្ចិត្វា អញ្ញំ មក្ខំ កណ្ហន្តិ កណ្ហន្តិ ច មុញ្ចន្តិ ច អាឌិយន្តិ ច និរស្សជន្តិ ចាតិ តេ ឧក្ខហាយន្តិ និរស្សជន្តិ ។

[១២៧] ឥមិនា សាខំ បមុខំ ឥហាយាតិ យថា មក្ខិកោ អរញ្ញេ បវនេ ចរមានោ សាខំ ឥណ្ហាតិ តំ មុញ្ចិត្វា អញ្ញំ សាខំ ឥណ្ហាតិ តំ មុញ្ចិត្វា អញ្ញំ សាខំ ឥណ្ហាតិ ឯវមេវ ឥធ សមណ ព្រាហ្មណា ឥធ ទិដ្ឋិ-គតានិ ឥណ្ហន្តិ ច មុញ្ចន្តិ ច អាឌិយន្តិ ច និរស្សជន្តិ ចាតិ ឥមិនា សាខំ បមុខំ ឥហាយ ។ តេនាហ ភគវា

បុរិមំ បហាយ អបរំ សិតាសេ
ឯជានុគា តេ ន តរន្តិ សង្គំ
តេ ឧក្ខហាយន្តិ និរស្សជន្តិ
ឥមិនា សាខំ បមុខំ ឥហាយាតិ ។

[១២៨] សយំ សមាទាយ វតានិ ជន្តុ
ឧច្ចាវចំ ឥច្ចតិ សញ្ញសត្តោ
ឥទ្ធា ច[1] ហេ ឥហ សមេច្ច ធម្មំ
ន ឧច្ចាវចំ ឥច្ចតិ ភូរិបញ្ញោ ។

---

១ ឱ. ឥទ្ធា ។

ប្រកាន់មគ្គ លះបង់មគ្គនោះ ហើយប្រកាន់មគ្គដទៃវិញ ប្រកាន់ផង លះបង់ផង ប្រកាន់យកផង លៃងចោលផង ហេតុនោះ (ទ្រង់ត្រាស់ថា) ជនទាំងនោះ តែងប្រកាន់ តែងលះបង់ ។

[១២៧] ពាក្យថា ដូចជាស្វាគោងមែកឈើចំពោះមុខ សេចក្តីថា ស្វាកាលត្រាច់ទៅក្នុងព្រៃតូចព្រៃធំ តែងគោងមែកឈើ លៃងនូវមែកឈើនោះចោល ហើយគោងមែកឈើដទៃ លៃងមែកឈើនោះចោល ហើយគោងមែកឈើដទៃវិញ យ៉ាងណា ពួកសមណព្រាហ្មណ៍ ផ្តេសផ្តាស តែងប្រកាន់ផង លះបង់ផង កាន់យកផង លៃងចោលផង នូវទិដ្ឋិផ្តេសផ្តាស ក៏យ៉ាងនោះដែរ ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) ដូចជាស្វាគោងមែកឈើចំពោះមុខ ព្រោះហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> ជនណា ជាអ្នកលង់តាមការញ្ជាប់ញ័រ លះបង់វត្ថុមុន អាស្រ័យវត្ថុក្រោយ ជននោះ នឹងធ្វើនូវការជាប់ចំពាក់មិនបាន ជននោះ តែងប្រកាន់ តែងលះបង់ ដូចជាស្វា គោងមែកឈើចំពោះមុខ ។

[១២៨] ជនសមាទាននូវវត្តទាំងឡាយ ដោយខ្លួនឯង ជាអ្នកជាប់ក្នុងសញ្ញា តែងទៅរកវត្ថុខ្ពស់ទាប ឯអ្នកប្រាជ្ញ មានបញ្ញាដូចផែនដី ត្រាស់ដឹងនូវធម៌ដោយវេទទាំងឡាយ មិនទៅរកវត្ថុខ្ពស់ទាបទេ ។

[១២៩] សយំ សមាធាយ វតានិ ជន្តូតិ សយំ សមាធាយាតិ សាមំ សមាធាយ ។ វតានីតិ ហត្ថិវត្តំ វា អស្សវត្តំ វា គោវត្តំ វា ការុក្ការវត្តំ វា ការការវត្តំ វា សុនេរវត្តំ វា ពលនេរវត្តំ វា បុណ្ណភទ្ទវត្តំ វា មណិភទ្ទវត្តំ វា អគ្គិវត្តំ វា ជាតវត្តំ វា សុបណ្ណវត្តំ វា យក្ខវត្តំ វា អសុរវត្តំ វា ។ បេ ។ ឥសិវត្តំ វា អាធាយ សមាធាយ អាឥយិត្វា សមាឥយិត្វា ឧណ្ហិត្វា បរាម-សិត្វា អភិនិវិសិត្វា ។ ជន្តូតិ សត្តា ជនា ។ បេ ។ មនុជោតិ សយំ សមាធាយ វតានិ ជន្តុ ។

[១៣០] ឧច្ចាវចំ ឧច្ចតិ សញ្ញសត្តោតិ សត្តារតោ សត្តារំ ឧច្ចតិ ធម្មក្ខានតោ ធម្មក្ខានំ ឧច្ចតិ ឧណ្ណតោ ឧណ្ណំ ឧច្ចតិ ឥដ្ឋិយា ឥដ្ឋី ឧច្ចតិ បដិបជ្ជតោ បដិបជ្ជំ ឧច្ចតិ មក្ខតោ មក្ខំ ឧច្ចតិ ។ សញ្ញសត្តោតិ ការ-សញ្ញាយ ព្យាបាទសញ្ញាយ វិហឹសាសញ្ញាយ ឥដ្ឋិ-សញ្ញាយ សត្តោ វិសត្តោ អាសត្តោ លគ្គោ លគ្គិតោ បលិពុទ្ធោ ។ យថា ភិត្តិខីលេ វា ជាតរូបេ វា ភណ្ឌេ សត្តំ វិសត្តំ អាសត្តំ លគ្គំ លគ្គិតំ បលិពុទ្ធំ ឯវមេវ

[១២៩] អធិប្បាយពាក្យថា ជនសមាទាន នូវវត្ថុទាំងឡាយ ដោយខ្លួនឯង ត្រង់ពាក្យថា សមាទានដោយខ្លួនឯង គឺកាន់យកព្រម ដោយខ្លួនឯង ។ ពាក្យថា វត្ថុទាំងឡាយ សេចក្ដីថា កាន់យក កាន់ យកព្រម ប្រកាន់ ប្រកាន់ព្រម ក្ជកាន់យក ប

កាមសញ្ញាយ ព្យាបាទសញ្ញាយ វិហឹសាសញ្ញាយ ទិដ្ឋិសញ្ញាយ សត្តោ វិសត្តោ អាសត្តោ លគ្គោ លគ្គិតោ បលិពុទ្ធោតិ ឧច្ចាវចំ គច្ឆតិ សញ្ញសត្តោ ។

[១៣១] វិទ្វា ច វេទេហិ សមេច្ច ធម្មន្តិ វិទ្វាតិ វិទ្វា វិជ្ជាគតោ ញាណី ពុទ្ធិមា វិភាវី មេធាវី ។ វេទេហីតិ វេទា វុច្ចន្តិ ចតូសុ មគ្គេសុ ញាណំ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ ធម្មវិចយសម្ពោជ្ឈង្គោ វីមំសា វិបស្សនា សម្មាទិដ្ឋិ ។ តេហិ វេទេហិ ជាតិជរាមរណស្ស អន្តគតោ អន្តប្បត្តោ កោដិគតោ កោដិប្បត្តោ បរិយន្តគតោ បរិយន្តប្បត្តោ វោសានគតោ វោសានប្បត្តោ តាណគតោ តាណប្បត្តោ លេណគតោ លេណប្បត្តោ សរណគតោ សរណប្បត្តោ អភយគតោ អភយប្បត្តោ អច្ចុតគតោ អច្ចុតប្បត្តោ អមតគតោ អមតប្បត្តោ និព្វានគតោ និព្វានប្បត្តោ ។

បុគ្គលអ្នកចំពាក់ ចំពាក់ធ្នាក់ ចំពាក់ចាក់ស្រែះ ជ្ជក់ ទាក់ជាប់មាំហើយ ក្នុងកាមសញ្ញា ព្យាបាទសញ្ញា វិហឹសាសញ្ញា ទិដ្ឋិសញ្ញា ក៏យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) ជនអ្នកជាប់នៅក្នុងសញ្ញា តែងទៅរកវត្ថុខ្ពស់ទាប ។

[១៣១] *អធិប្បាយពាក្យថា អ្នកប្រាជ្ញ ត្រាស់ដឹងនូវធម៌ដោយវេទទាំងឡាយ ត្រង់ពាក្យថា អ្នកប្រាជ្ញ គឺអ្នកដឹង អ្នកប្រកបដោយវិជ្ជា អ្នកមានញាណ អ្នកមានប្រាជ្ញា មានបញ្ញាជាគ្រឿងធ្ងុះយល់ មានបញ្ញាជាគ្រឿងថ្លឹង ។ ញាណ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល ធម្មវិចយ-សម្ពោជ្ឌង្គ វីមំសា វិបស្សនា សម្មាទិដ្ឋិ ក្នុងមគ្គទាំងឡាយ ៤ លោកហៅថា វេទ ក្នុងបទថា ដោយវេទទាំងឡាយ ។ បុគ្គលដល់នូវទីបំផុត សម្រេចនូវទីបំផុត ដល់នូវចុង សម្រេចនូវចុង ដល់នូវទីបំផុតដោយជុំវិញ សម្រេចនូវទីបំផុតដោយជុំវិញ ដល់នូវទីអវសាន សម្រេចនូវទីអវសាន នៃជាតិ ជរានិងមរណៈ ដល់ហើយនូវទីជ្រកកោន សម្រេចនូវទីជ្រកកោន ដល់នូវទីពួន សម្រេចនូវទីពួន ដល់នូវទីពឹងទីរឭក សម្រេចនូវទីពឹងទីរឭក ដល់នូវទីមិនមានភ័យ សម្រេចនូវទីមិនមានភ័យ ដល់នូវទីមិនច្យុត សម្រេចនូវទីមិនច្យុត ដល់នូវអមតៈ សម្រេចនូវអមតៈ ដល់នូវព្រះនិព្វាន សម្រេចនូវព្រះនិព្វាន ដោយវេទទាំងនោះ ។*

វេជានំ វ អន្តកតោតិ វេជកូ ។ វេជេហិ វ អន្ត-
កតោតិ វេជកូ ។ សត្តន្នំ ធម្មានំ វិជិតត្តា វេជកូ
សក្កាយទិដ្ឋិ វិជិតា ហោតិ វិចិកិច្ឆា វិជិតា ហោតិ
សីលព្ពតុបាទានានិ វិជិតានិ ហោតិ រាគោ វិជិតោ
ហោតិ ទោសោ វិជិតោ ហោតិ មោហោ វិជិតោ
ហោតិ មានោ វិជិតោ ហោតិ ។ វិជិតស្ស ហោន្តិ
ចាបកា អកុសលា ធម្មា សង្ខ្លិលេសិកា ចោជោត្ត-
រិកា សនរ ទុក្ខវិបាកា អាយតឹ ជាតិជរាមរណីយា ។

វេជានិ វិជេយ្ យ គោវលានិ (សកិយាតិ ភគវា)
សមណានំ យានិ ឥត្តិ ព្រាហ្មណានំ
សព្ពវេជនានុ រីតរាគោ
សព្ពំ វេជមតិចុ វេជកូ សោ ។

សមេចុ ធម្មន្តិ សមេចុ អភិសមេចុ ធម្មំ ។ សព្ពេ
សង្ខារ អនិច្ចាតិ សមេចុ អភិសមេចុ ធម្មំ ។ សព្ពេ
សង្ខារ ទុក្ខាតិ សមេចុ អភិសមេចុ ធម្មំ ។ សព្ពេ
ធម្មា អនត្តាតិ សមេចុ អភិសមេចុ ធម្មំ ។

មួយទៀត បុគ្គលដល់នូវទីបំផុតនៃវេទទាំងឡាយ ឈ្មោះថា វេទគូ-បុគ្គល ។ បុគ្គលដល់នូវទីបំផុតដោយវេទទាំងឡាយ ឈ្មោះថា វេទគូ-បុគ្គល ។ បុគ្គលដែលឈ្មោះថា វេទគូ ព្រោះដឹងច្បាស់នូវធម៌ទាំង-ឡាយ ៧ ប្រការ គឺ ជាអ្នកដឹងច្បាស់សក្កាយទិដ្ឋិ ១ ដឹងច្បាស់វិចិកិច្ឆា ១ ដឹងច្បាស់សីលព្វតបរាមាស: ១ ដឹងច្បាស់រាគ: ១ ដឹងច្បាស់ទោស: ១ ដឹងច្បាស់មោហ: ១ ដឹងច្បាស់មានៈ ១ ។ អកុសលធម៌ទាំងឡាយ ដ៏លាមក ប្រកបដោយសេចក្តីសៅហ្មងព្រម ជាធម៌ញ៉ាំងសត្វឲ្យកើតក្នុងភពថ្មីទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ ជាធម៌មានសេចក្តីទុក្ខជាផល ជាបច្ច័យរបស់ជាតិ ជរានិងមរណៈតទៅទៀត វេទគូ-បុគ្គល ដឹងច្បាស់ហើយ ។

(ព្រះមានព្រះភាគ ត្រាស់ថា ម្នាលសកិយ:) បុគ្គលណា ពិចារណាហើយ នូវវេទទាំងអស់ របស់ពួកសមណ-ព្រាហ្មណ៍ជាអ្នកប្រាសចាកតម្រេក ក្នុងវេទទាំងពួង កន្ទង នូវវេទទាំងពួង បុគ្គលនោះ ឈ្មោះថា វេទគូបុគ្គល ។

ពាក្យថា ត្រាស់ដឹងនូវធម៌ គឺត្រាស់ដឹង ត្រាស់ដឹងចំពោះ នូវធម៌ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា សង្ខារទាំងពួង មិនទៀង ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា សង្ខារទាំងពួងជាទុក្ខ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា ធម៌ទាំងពួងជាអនត្តា ។

អវិជ្ជាបច្ចយា សង្ខារាតិ សមេច្ច អភិសមេច្ច ឆម្ចំ ។ សង្ខារប្បច្ចយា វិញ្ញាណន្តិ សមេច្ច អភិសមេច្ច ឆម្ចំ ។ វិញ្ញាណប្បច្ចយា នាមរូបន្តិ ។ នាមរូបប្បច្ចយា សឬាយតនន្តិ ។ សឬាយតនប្បច្ចយា ផស្សោតិ ។ ផស្សប្បច្ចយា វេទនាតិ ។ វេទនាបច្ចយា តណ្ហាតិ ។ តណ្ហាបច្ចយា ឧចាទានន្តិ ។ ឧចាទានប្បច្ចយា ភវោតិ ។ ភវប្បច្ចយា ជាតីតិ ។ ជាតិប្បច្ចយា ជរា-មរណន្តិ សមេច្ច អភិសមេច្ច ឆម្ចំ ។ អវិជ្ជានិរោធា សង្ខារនិរោធោតិ សមេច្ច អភិសមេច្ច ឆម្ចំ ។ ស-ង្ខារនិរោធា វិញ្ញាណនិរោធោតិ សមេច្ច អភិសមេច្ច ឆម្ចំ ។ វិញ្ញាណនិរោធា នាមរូបនិរោធោតិ ។ នាមរូប-និរោធា សឬាយតននិរោធោតិ ។ សឬាយតននិរោធា ផស្សនិរោធោតិ ។ ផស្សនិរោធា វេទនានិរោធោតិ ។ វេទនានិរោធា តណ្ហានិរោធោតិ ។ តណ្ហានិរោធា ឧចាទាននិរោធោតិ ។ ឧចាទាននិរោធា ភវនិរោ-ធោតិ ។ ភវនិរោធា ជាតិនិរោធោតិ ។ ជាតិនិរោធា ជរាមរណនិរោធោតិ សមេច្ច អភិសមេច្ច ឆម្ចំ ។

ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា សង្ខារទាំងឡាយ (កើត) ព្រោះអវិជ្ជា ជាបច្ច័យ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា វិញ្ញាណ (កើត) ព្រោះសង្ខារ ជាបច្ច័យ ។ នាមនិងរូប (កើត) ព្រោះវិញ្ញាណ ជាបច្ច័យ ។ អាយតនៈ ៦ (កើត) ព្រោះនាមរូប ជាបច្ច័យ ។ ផស្សៈ (កើត) ព្រោះអាយតនៈ ៦ ជាបច្ច័យ ។ វេទនា (កើត) ព្រោះផស្សៈ ជាបច្ច័យ ។ តណ្ហា (កើត) ព្រោះវេទនា ជាបច្ច័យ ។ ឧបាទាន (កើត) ព្រោះតណ្ហាជាបច្ច័យ ។ ភព (កើត) ព្រោះឧបាទាន ជាបច្ច័យ ។ ជាតិ (កើត) ព្រោះភព ជាបច្ច័យ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា ជរានិងមរណៈ (កើត) ព្រោះជាតិ ជាបច្ច័យ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា កិរិយារលត់សង្ខារ ព្រោះការរលត់អវិជ្ជា ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា កិរិយារលត់វិញ្ញាណ ព្រោះការរលត់សង្ខារ ។ កិរិយារលត់នាមនិងរូប ព្រោះការរលត់វិញ្ញាណ ។ កិរិយារលត់អាយតនៈ ៦ ព្រោះការរលត់នាមនិងរូប ។ កិរិយារលត់ផស្សៈ ព្រោះការរលត់អាយតនៈ ៦ ។ កិរិយារលត់វេទនា ព្រោះការរលត់ផស្សៈ ។ កិរិយារលត់តណ្ហា ព្រោះការរលត់វេទនា ។ កិរិយារលត់ឧបាទាន ព្រោះការរលត់តណ្ហា ។ កិរិយារលត់ភព ព្រោះការរលត់ឧបាទាន ។ កិរិយារលត់ជាតិ ព្រោះការរលត់ភព ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា កិរិយារលត់ជរានិងមរណៈ ព្រោះការរលត់ជាតិ ។

ឥធ ពុក្ខន្តិ សមេចុ អភិសមេចុ ធម្មំ ។ អយំ ពុក្ខ-
មុនយោតិ ។ អយំ ពុក្ខនិរោធោតិ ។ អយំ ពុក្ខនិរោធ-
គាមិនី បដិបទាតិ សមេចុ អភិសមេចុ ធម្មំ ។ ឥមេ
អាសវាតិ សមេចុ អភិសមេចុ ធម្មំ ។ អយំ អាសវ-
សមុនយោតិ ។ អយំ អាសវនិរោធោតិ ។ អយំ អាស-
វនិរោធគាមិនី បដិបទាតិ សមេចុ អភិសមេចុ ធម្មំ ។
ឥមេ ធម្មា អភិញ្ញេយ្យាតិ ។ ឥមេ ធម្មា បរិញ្ញេយ្យាតិ ។
ឥមេ ធម្មា បហាតព្វាតិ ។ ឥមេ ធម្មា ភាវេតព្វាតិ ។
ឥមេ ធម្មា សច្ឆិកាតព្វាតិ សមេចុ អភិសមេចុ
ធម្មំ ។ ឆន្ទំ ផស្សាយតនានំ សមុនយញ្ច អត្ថង្គមញ្ច
អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច សមេចុ អភិ-
សមេចុ ធម្មំ ។ បញ្ចន្នំ ឧចាគានក្ខន្ធានំ សមុនយញ្ច
អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច
សមេចុ អភិសមេចុ ធម្មំ ។ ចតុន្នំ មហាភូតានំ
សមុនយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច
និស្សរណញ្ច សមេចុ អភិសមេចុ ធម្មំ ។ យង្កិញ្ចិ
សមុនយធម្មំ សព្វន្តំ និរោធធម្មន្តិ សមេចុ អភិ-
សមេចុ ធម្មន្តិ ឯត្ថ ច ឯតេហិ សមេចុ ធម្មំ ។

ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា នេះទុក្ខ ។ នេះជាហេតុនាំឲ្យកើតទុក្ខ ។ នេះជាការរលត់ទុក្ខ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា នេះជាបដិបទាទៅកាន់ការរលត់ទុក្ខ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា នេះពួកអាសវៈ ។ នេះជាហេតុនាំឲ្យកើតអាសវៈ ។ នេះជាការរំលត់អាសវៈ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះ នូវធម៌ថា នេះបដិបទាទៅកាន់ការរំលត់អាសវៈ ។ នេះពួកធម៌គួរត្រាស់ដឹង ។ នេះពួកធម៌គួរកំណត់ដឹង ។ នេះពួកធម៌គួរលះបង់ ។ នេះពួកធម៌គួរចម្រើន ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា នេះពួកធម៌គួរធ្វើឲ្យជាក់ច្បាស់ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ គឺហេតុឲ្យកើតផង ឲ្យរលត់ផង សេចក្ដីរីករាយផង ទោសផង រលាស់ចេញផង នៃផស្សាយ-តនៈ ៦ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ គឺហេតុឲ្យកើតផង ឲ្យរលត់ផង សេចក្ដីរីករាយផង ទោសផង រលាស់ចេញផង នៃឧបាទាន-ក្ខន្ធ ៥ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ គឺហេតុឲ្យកើតផង ឲ្យរលត់ផង សេចក្ដីរីករាយផង ទោសផង រលាស់ចេញផង នៃមហាភូត ៤ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា វត្ថុណាមួយ មានកិរិយាកើតឡើងជាធម្មតា វត្ថុទាំងពួងនោះ មានកិរិយារលត់ទៅវិញជាធម្មតា ហេតុនោះ (ទ្រង់ត្រាស់ថា) ឯអ្នកប្រាជ្ញត្រាស់ដឹងនូវធម៌ ដោយវេទទាំងឡាយ ។

[១៣២] ន ឧច្ចាវចំ កច្ចតិ ភូរិប្បញ្ញោតិ ន សត្ថារតោ សត្ថារំ កច្ចតិ ន ធម្មក្ខានតោ ធម្មក្ខានំ កច្ចតិ ន គណតោ គណំ កច្ចតិ ន ឋិដ្ឋិយា ឋិដ្ឋឿ កច្ចតិ ន បដិបជ្ជាយ បដិបជ្ជំ កច្ចតិ ន មត្តតោ មត្តំ កច្ចតិ ។ ភូរិប្បញ្ញោតិ មហាបញ្ញោ បុថុប្បញ្ញោ ហាសប្បញ្ញោ ជវនប្បញ្ញោ តិក្ខប្បញ្ញោ និព្វេធិកប្ប-ញ្ញោ ។ ភូរី វុច្ចតិ បឋវី ។ តាយ បឋវីសមាយ បញ្ញាយ វិបុលាយ វិត្ថតាយ សមន្ថាតតោតិ ន ឧច្ចាវចំ កច្ចតិ ភូរិប្បញ្ញោ ។ តេនាហ ភគវា

សយំ សមាធាយ រតានិ ជន្តុ
ឧច្ចាវចំ កច្ចតិ សញ្ញសត្តោ
វិទ្ធា ច វេទេហិ សមេច្ច ធម្មំ
ន ឧច្ចាវចំ កច្ចតិ ភូរិប្បញ្ញោតិ ។

[១៣៣] ស សព្វធម្មេសុ វិសេនិភូតោ
យន្ត្ថិញ្ចិ ឋិដ្ឋំ សុតំ មុតំ វា

[១៣២] ពាក្យថា មានបញ្ញាដូចផែនដី មិនទៅរកវត្ថុ ខ្ពស់និងទាប គឺ មិនចេញ អំពីសាស្តា ទៅរកសាស្តា មិនចេញ អំពីធម៌ដែលសាស្តាប្រាប់ ទៅរកធម៌ដែលសាស្តាប្រាប់ មិនចេញ អំពីពួកទៅរកពួក មិនចេញអំពីទិដ្ឋិទៅរកទិដ្ឋិ មិនចេញ អំពីបដិបទាទៅរកបដិបទា មិនចេញ អំពីមគ្គ ទៅរកមគ្គ ។ ពាក្យថា មានបញ្ញាដូចផែនដី គឺ មានបញ្ញាច្រើន មានបញ្ញាក្រាស់ មានបញ្ញាស្រស់ មានបញ្ញារហ័ស មានបញ្ញាមុត មានបញ្ញាជាគ្រឿងទម្លាយបង់ នូវកិលេស ។ ប្រឹថពី ហៅថា ផែនដី ។ អ្នកប្រាជ្ញប្រកបព្រមហើយដោយបញ្ញាដ៏ទូលាយ លាតផ្សាយស្មើ ដោយប្រឹថពីនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) មានបញ្ញាដូចផែនដី មិនទៅរកវត្ថុខ្ពស់ទាប ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ជនសមាទាននូវវត្ថុទាំងឡាយ ដោយខ្លួនឯង ជាអ្នកជាប់
នៅក្នុងសញ្ញា តែងទៅរកវត្ថុខ្ពស់ទាប ឯអ្នកប្រាជ្ញមាន
បញ្ញាដូចផែនដី ត្រាស់ដឹងនូវធម៌ ដោយវេទទាំងឡាយ
មិនទៅរកវត្ថុខ្ពស់និងទាបទេ ។

[១៣៣] អ្នកប្រាជ្ញនោះ ជាអ្នកមានសេនាទៅប្រាសហើយ
ក្នុងធម៌ទាំងពួងទាំងឡាយ គឺអារម្មណ៍ណាមួយ ដែល
លោកឃើញហើយក្តី ឮហើយក្តី ប៉ះពាល់ហើយក្តី

តមេវ ឧស្សី វិរជំ ចរន្តំ

កោនីធ លោកស្មិ វិកប្បយេយ្យ ។

[១៣៤] ស សព្វធម្មេសុ វិសេនិភូតោ យង្កិញ្ចិ ទិដ្ឋំវ សុតំ មុតំ វាតិ សេនា វុច្ចតិ មារសេនា ។ កាយទុច្ចរិតំ មារសេនា វចីទុច្ចរិតំ មារសេនា មនោទុច្ចរិតំ មារសេនា រាគោ មារសេនា ទោសោ មារសេនា មោហោ មារសេនា កោធោ ឧបនាហោ ។ បេ ។ សព្វាកុសលាភិសង្ខារា មារសេនា ។ វុត្តំ ហេតំ ភគវតា

កាមា តេ បឋមា សេនា ទុតិយាតិ វុច្ចតិ

តតិយា ខុប្បិបាសា តេ ចតុត្ថី តណ្ហា បវុច្ចតិ

បញ្ចមំ ថីនមិទ្ធន្តេ ឆដ្ឋា ភិរូ បវុច្ចតិ

ជនគប្បីកំណត់ នូវអ្នកប្រាជ្ញ ជាអ្នកឃើញ អ្នកមានដំបូលបើកហើយ កំពុងប្រព្រឹត្តនោះឯង ដោយកិលេសដូចម្តេចក្នុងលោកនេះបាន ។

[១៣៤] ពាក្យថា អ្នកប្រាជ្ញនោះ ជាអ្នកមានសេនាទៅប្រាសហើយ ក្នុងធម៌ទាំងពួងទាំងឡាយ គឺអារម្មណ៍ណាមួយ ដែលលោកឃើញហើយក្តី ឮហើយក្តី ប៉ះពាល់ហើយក្តី អធិប្បាយថា សេនារបស់មារ លោកហៅថា សេនា ។ កាយទុច្ចរិត ជាមារសេនា វចីទុច្ចរិត ជាមារសេនា មនោទុច្ចរិត ជាមារសេនា រាគ: ជាមារសេនា ទោស: ជាមារសេនា មោហ: ជាមារសេនា កោធ: ឧបនាហ: ។ បេ ។ អកុសលាកិសង្ខារទាំងអស់ ជាមារសេនា ។ ដូចពាក្យដែលព្រះមានព្រះភាគ ត្រាស់ដូច្នេះថា

កាម ជាសេនាទី ១ របស់អ្នក សេចក្តីមិនត្រេកអរ (ក្នុងធម៌ជាកុសល) លោកហៅថា សេនាទី ២ សេចក្តីស្រេកឃ្ងាន ជាសេ-នាទី ៣ របស់អ្នក តណ្ហា លោកហៅថា សេនាទី ៤ ថីនមិទ្ធ: ជាសេនាទី ៥ របស់អ្នក សេចក្តីខ្ជាច លោកហៅថា សេនាទី ៦

សត្តមី វិចិកិច្ឆា តេ មក្ខោ ថម្ភោ តេ អដ្ឋមោ
លាភោសិ លោកោ សក្ការោ មិច្ឆាលទ្ធោ ច យោ យសោ
យោ ចត្តានំ សមុក្កំសេ បរេ ច អវជានតិ
ឯសា នមុចិ តេ សេនា កណ្ហស្សា ភិប្បហារិណី
ន នំ អសូរោ ជិនាតិ ជេត្វា ច លភតេ សុខន្តិ ។

យតោ ចតូហិ អរិយមគ្គេហិ សព្វា ច មារសេនា សព្វេ ច បដិសេនិករា កិលេសា ជិតា ច បរាជិតា ច ភគ្គា វិប្បលុគ្គា[១] បរម្មុខា សោ វុច្ចតិ វិសេនិភូតោ ។ សោ ទិដ្ឋេ វិសេនិភូតោ សុតេ វិសេនិភូតោ មុតេ វិសេនិភូតោ វិញ្ញាតេ វិសេនិភូតោតិ ស សព្វធម្មេសុ វិសេនិភូតោ យត្កិញ្ចិ ទិដ្ឋំ វ សុតំ មុតំ វា ។

១ ឱ. ម. វិប្បលុត្តា ។

វិចិកិច្ឆា ជាសេនាទី ៧ របស់អ្នក ការលុបគុណ និងសេចក្ដីរឹងត្អឹង ជាសេនាទី ៨ របស់អ្នក លាភ សេចក្ដីសរសើរ និងសក្ការៈ (ជាសេនាទី ៩) យសដែលបុគ្គលបានមកដោយការខុស បុគ្គលដែលលើកតម្កើងខ្លួនឯង ទាំងមើលងាយអ្នកដទៃ (នេះជា) សេនាទី ១០ ម្នាលមារ នេះជាសេនារបស់អ្នកឯងដែលមានធម៌ខ្មៅ ជាសេនាតែងបៀតបៀន (នូវពួកសមណៈព្រាហ្មណ៍) បុគ្គលមិនក្ងៀវក្ងា មិនអាចឈ្នះនូវសេនានោះទេ (លុះតែបុគ្គលក្ងៀវក្ងា) ទើបឈ្នះហើយបានសុខ ។ កាលណា មារសេនាទាំងពួង និងកិលេសជាសត្រូវទាំងពួង ដែលបុគ្គលណា ឈ្នះ ផ្ចាញ់ បំបាក់ កម្ទេច ធ្វើឲ្យមានមុខងាកចេញ ដោយអរិយមគ្គទាំង ៤ បានហើយ បុគ្គលនោះ លោកហៅថា អ្នកមានសេនាទៅប្រាសហើយ ។ បុគ្គលនោះមានសេនាទៅប្រាស ក្នុងអារម្មណ៍ដែលឃើញ មានសេនាទៅប្រាស ក្នុងអារម្មណ៍ដែលឮ មានសេនាទៅប្រាស ក្នុងអារម្មណ៍ដែលប៉ះពាល់ មានសេនាទៅប្រាស ក្នុងអារម្មណ៍ដែលដឹង ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកប្រាជ្ញនោះ មានសេនាទៅប្រាសហើយ ក្នុងធម៌ទាំងពួងទាំងឡាយ គឺអារម្មណ៍ណាមួយ ដែលលោកឃើញហើយក្ដី ឮហើយក្ដី ប៉ះពាល់ហើយក្ដី ។

[១៣៥] តមេវ ទស្សី វិវដំ ចរន្តន្តិ តមេវ សុទ្ធទស្សី វិសុទ្ធទស្សី បរិសុទ្ធទស្សី វោទាតទស្សី បរិយោទាតទស្សី ។ អថវា សុទ្ធទស្សនំ វិសុទ្ធទស្សនំ បរិសុទ្ធទស្សនំ វោទាតទស្សនំ បរិយោទាតទស្សនំ ។ វិវដន្តិ តណ្ហាឆទនំ កិលេសឆទនំ អវិជ្ជាឆទនំ ។ តានិ ឆទនានិ វិវដានិ ហោន្តិ វិទ្ធំសិតានិ ឧគ្ឃាតិតានិ សមុគ្ឃាតិតានិ បហីនានិ សមុច្ឆិន្នានិ វូបសន្តានិ បដិប្បស្សទ្ធានិ អភព្វុប្បត្តិកានិ ញាណគ្គិនា ទឌ្ឍានិ ។ ចរន្តន្តិ ចរន្តំ វិចរន្តំ ឥរិយន្តំ វត្តន្តំ បាលេន្តំ យបេន្តំ យាបេន្តន្តិ តមេវ ទស្សី វិវដំ ចរន្តំ ។

[១៣៦] កោនីធ លោកស្មិ វិកប្បយេយ្យាតិ កប្បាតិ ទ្វេ កប្បា តណ្ហាកប្បោ ច ទិដ្ឋិកប្បោ ច ។ បេ ។ អយំ តណ្ហាកប្បោ ។ បេ ។ អយំ ទិដ្ឋិកប្បោ ។

[១៣៥] ពាក្យថា អ្នកឃើញ អ្នកមានដំបូលបើកហើយ កំពុងប្រព្រឹត្តនោះឯង គឺអ្នកឃើញការស្អាត អ្នកឃើញការស្អាតវិសេស អ្នកឃើញការបរិសុទ្ធ អ្នកឃើញការហ្មត់ចត់ អ្នកឃើញការផ្ទរផង ។ ឬថា អ្នកមានសេចក្តីយល់ស្អាត អ្នកមានសេចក្តីយល់ស្អាតវិសេស អ្នកមានសេចក្តីយល់បរិសុទ្ធ អ្នកមានសេចក្តីយល់ហ្មត់ចត់ អ្នកមានសេចក្តីយល់ផ្ទរផង់ ។ ពាក្យថា អ្នកមានដំបូលបើកហើយ សេចក្តីថា ដំបូលគឺតណ្ហា ដំបូលគឺកិលេស ដំបូលគឺអវិជ្ជា ។ គ្រឿងប្រក់ទាំងនោះ លោកបើក កម្ចាត់បង់ បំផ្ទាញចោល ដករំលើងចោល លះបង់ ផ្តាច់បង់ សូប់រម្ងាប់ ធ្វើមិនគួរឲ្យកើត ដុតដោយភ្លើងគឺញាណហើយ ។ ពាក្យថា កំពុងប្រព្រឹត្ត គឺ កំពុងត្រាច់ទៅ កំពុងត្រាច់ទៅផ្សេង ។ កំពុងសម្រេចឥរិយាបថ កំពុងប្រព្រឹត្ត កំពុងរក្សា កំពុងរស់នៅ កំពុងញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅ ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកឃើញ អ្នកមានដំបូលបើកហើយ កំពុងប្រព្រឹត្តនោះឯង ។

[១៣៦] អធិប្បាយពាក្យថា គប្បីកំណត់ដោយកិលេស ដូចម្តេច ក្នុងលោកនេះ ត្រង់ពាក្យថា កំណត់ បានដល់ការកំណត់មាន ២ គឺ ការកំណត់ គឺតណ្ហា ១ ការកំណត់ គឺទិដ្ឋិ ១ ។ បេ ។ នេះ ការកំណត់ គឺតណ្ហា ។ បេ ។ នេះ ការកំណត់ គឺទិដ្ឋិ ។

តស្ស តណ្ហាកប្បោ បហីនោ ទិដ្ឋិកប្បោ បដិនិស្សដ្ឋោ តណ្ហាកប្បស្ស បហីនត្តា ទិដ្ឋិកប្បស្ស បដិនិស្សដ្ឋត្តា យេន រាគេន កប្បេយ្យ យេន ទោសេន កប្បេយ្យ យេន មោហេន កប្បេយ្យ យេន មានេន កប្បេយ្យ កាយ ទិដ្ឋិយា កប្បេយ្យ យេន ឧទ្ធច្ចេន កប្បេយ្យ កាយ វិចិកិច្ឆាយ កប្បេយ្យ យេហិ អនុសយេហិ កប្បេយ្យ រត្តោតិ វា ទុដ្ឋោតិ វា មូឡ្ហោតិ វា វិនិពទ្ធោតិ វា បរាមដ្ឋោតិ វា វិក្ខេបគតោតិ វា អនិដ្ឋង្គតោតិ វា ថាមគតោតិ វា ។ តេ អភិសង្ខារា បហីនា អភិសង្ខារានំ បហីនត្តា គតិយោ យេន កប្បេយ្យ នេរយិកោតិ វា តិរច្ឆានយោនិកោតិ វា បិត្តិវិសយិកោតិ វា មនុស្សោតិ វា ទេវោតិ វា រូបីតិ វា អរូបីតិ វា សញ្ញីតិ វា អសញ្ញីតិ វា នេវសញ្ញីនាសញ្ញីតិ វា ។ សោ ហេតុ នត្ថិ

ការកំណត់គឺតណ្ហា អ្នកប្រាជ្ញនោះ បានលះបង់ហើយ ការកំណត់គឺទិដ្ឋិ អ្នកប្រាជ្ញនោះ បានរលាស់ចោលហើយ ព្រោះលោកលះបង់ នូវការកំណត់គឺតណ្ហា ព្រោះលោករលាស់ចោល នូវការកំណត់គឺទិដ្ឋិ ជន គប្បីកំណត់ដោយរាគៈដូចម្តេច គប្បីកំណត់ដោយទោសៈដូចម្តេច គប្បីកំណត់ដោយមោហៈដូចម្តេច គប្បីកំណត់ដោយមានៈដូចម្តេច គប្បីកំណត់ដោយទិដ្ឋិដូចម្តេច គប្បីកំណត់ដោយឧទ្ធច្ចៈដូចម្តេច គប្បីកំណត់ដោយវិចិកិច្ឆាដូចម្តេច គប្បីកំណត់ដោយអនុស័យទាំងឡាយដូចម្តេចបាន ថា លោក នៅត្រេកត្រអាលក្តី នៅប្រទូស្តក្តី នៅវង្វេងក្តី នៅជាប់ចំពាក់ក្តី នៅបណ្ដោសអង្អែលក្តី ដល់នូវការរាយមាយក្តី ដល់នូវការមិនដាច់ស្រេចក្តី ដល់នូវកម្ទាំងក្តី ។ អកិសង្ខារទាំងនោះ អ្នកប្រាជ្ញនោះ លះបង់ហើយ ព្រោះលោកលះអកិសង្ខារហើយ ជន គប្បីកំណត់ នូវគតិទាំងឡាយថា លោក ទៅកើតក្នុងនរកក្តី កើតក្នុងកំណើតតិរច្ឆានក្តី កើតក្នុងប្រេតវិស័យក្តី ជាមនុស្សក្តី ជាទេវតាក្តី ព្រហ្មមានរូបក្តី ព្រហ្មឥតរូបក្តី ព្រហ្មមានសញ្ញាក្តី ព្រហ្មឥតសញ្ញាក្តី ព្រហ្មមានសញ្ញា ក៏មិនមែន មិនមានសញ្ញាក៏មិនមែនក្តី ដោយប្រការដូចម្តេចបាន ។ មិនមានហេតុ

បច្ចយោ នត្ថិ ការណំ នត្ថិ យេន កប្បេយ្យ វិកប្បេយ្យ វិកប្បំ អាបជ្ជេយ្យ ។ លោកស្មិន្តិ អបាយលោកេ មនុស្សលោកេ ទេវលោកេ ខន្ធលោកេ ធាតុលោកេ អាយតនលោកេតិ កោជីធ លោកស្មិ វិកប្បយេយ្យ ។ តេនាហ ភគវា

ស សព្វធម្មេ សុវិសេនិភូតោ
យង្កិញ្ចិ ទិដ្ឋំវ សុតំ មុតំ វា
តមេវ ទស្សឹ វិវដំ ចរន្តំ
កោជីធ លោកស្មិ វិកប្បយេយ្យាតិ ។

[១៣៧] ន កប្បយន្តិ ន បុរេក្ខរោន្តិ
អច្ចន្តសុទ្ធីតិ ន តេ វទន្តិ
អាទានគន្ថំ គថិតំ វិសជ្ជ
អាសំ ន កុព្វន្តិ កុហិញ្ចិ លោកេ ។

[១៣៨] ន កប្បយន្តិ ន បុរេក្ខរោន្តីតិ កប្បាតិ ទ្វេ កប្បា តណ្ហាកប្បោ ច ទិដ្ឋិកប្បោ ច ។ បេ ។ អយំ តណ្ហាកប្បោ ។ បេ ។

មិនមានបច្ច័យ មិនមានទំនង ជាហេតុល្មមឲ្យជន គប្បីកំណត់ គប្បីកំណត់ទុក គប្បីដល់នូវការកំណត់ទុកបានឡើយ ។ ពាក្យថា ក្នុងលោក គឺ ក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) ជន គប្បីកំណត់ ដោយកិលេសដូចម្តេច ក្នុងលោកនេះបាន ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

អ្នកប្រាជ្ញនោះ មានសេនាទៅប្រាសហើយ ក្នុងធម៌ទាំងពួងទាំងឡាយ គឺអារម្មណ៍ណាមួយ ដែលលោកឃើញហើយ ក្តី ឮហើយក្តី ប៉ះពាល់ហើយក្តី ជនគប្បីកំណត់នូវអ្នកប្រាជ្ញ ជាអ្នកឃើញ មានដំបូលបើកហើយ កំពុងប្រព្រឹត្ត នោះឯង ដោយកិលេសដូចម្តេច ក្នុងលោកនេះបាន ។

[១៣៧] *ព្រះខីណាស្រពទាំងឡាយនោះ មិនកំណត់ មិនធ្វើឲ្យជាប្រធាន មិនពោលថា (ទិដ្ឋិ) មានសេចក្តីបរិសុទ្ធជាទីបំផុត កាត់គ្រឿងចងស្រែះគឺសេចក្តីប្រកាន់ ដែលចងស្រែះហើយ មិនធ្វើនូវបំណង ក្នុងលោកណាមួយ ។*

[១៣៨] *អធិប្បាយពាក្យថា មិនកំណត់ មិនធ្វើឲ្យជាប្រធាន ត្រង់ពាក្យថា កំណត់ បានដល់ការកំណត់ ២ គឺ ការកំណត់គឺតណ្ហា ១ ការកំណត់គឺទិដ្ឋិ ១ ។ បេ ។ នេះ ការកំណត់គឺតណ្ហា ។ បេ ។*

អយំ ទិដ្ឋិកប្បោ ។ តេសំ តណ្ហាកប្បោ បហីនោ ទិដ្ឋិកប្បោ បដិនិស្សដ្ឋោ តណ្ហាកប្បស្ស បហីនត្តា ទិដ្ឋិកប្បស្ស បដិនិស្សដ្ឋត្តា តណ្ហាកប្បំ វា ទិដ្ឋិកប្បំ វា ន កប្បេន្តិ ន ជនេន្តិ ន សញ្ជនេន្តិ ន និព្វត្តេន្តិ នាភិនិព្វត្តេន្តីតិ ន កប្បយន្តិ ។ ន បុរេក្ខរោន្តីតិ ទ្វេ បុរេក្ខារា តណ្ហាបុរេក្ខារោ ច ទិដ្ឋិបុរេក្ខារោ ច ។ បេ ។ អយំ តណ្ហាបុរេក្ខារោ ។ បេ ។ អយំ ទិដ្ឋិបុរេក្ខារោ ។ តេសំ តណ្ហាបុរេក្ខារោ បហីនោ ទិដ្ឋិបុរេក្ខារោ បដិនិស្សដ្ឋោ តណ្ហាបុរេក្ខារស្ស បហីនត្តា ទិដ្ឋិបុរេក្ខារស្ស បដិនិស្សដ្ឋត្តា ន តណ្ហំ វា ទិដ្ឋឹ វា បុរតោ កត្វា ចរន្តិ ន តណ្ហាធជា ន តណ្ហាកេតូ ន តណ្ហាធិបតេយ្យា ន ទិដ្ឋិធជា ន ទិដ្ឋិកេតូ ន ទិដ្ឋាធិបតេយ្យា ន តណ្ហាយ វា ទិដ្ឋិយា វា បរិវារិតា ចរន្តីតិ ន កប្បយន្តិ ន បុរេក្ខរោន្តិ ។

ព្រះអរហន្តលោកនឹងធឹង ព្រោះជាអ្នកលះបង់ហើយ តើដូចម្តេច ។ ព្រះអរហន្ត លះបង់ ខ្ជាក់ចោល រួចស្រឡះ លះចោល រលាស់ចោលហើយ នូវរាគៈ ។ ព្រះអរហន្ត លះបង់ ខ្ជាក់ចោល រួចស្រឡះ លះចោល រលាស់ចោលហើយ នូវទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ អកុសលាភិសង្ខារទាំងអស់ ព្រះអរហន្ត លោកនឹងធឹង ព្រោះជាអ្នកលះបង់ហើយ យ៉ាងនេះ ។

ព្រះអរហន្តលោកនឹងធឹង ព្រោះជាអ្នកធ្ងងហើយ តើដូចម្តេច ។ ព្រះអរហន្ត ធ្ងងកាមោយៈ ធ្ងងភវោយៈ ធ្ងងទិដ្ឋោយៈ ធ្ងងអវិជ្ជោយៈ ធ្ងងធ្ងងផុត ធ្ងងស្រឡះ កន្ទ្ងង កន្ទ្ងងផុត កន្ទ្ងងហួស នូវផ្លូវគឺសង្សារទាំងអស់ ព្រះអរហន្តនោះ លោកមានកិរិយានៅ នៅស្រេចហើយ មានការប្រ-ព្រឹត្ត ប្រព្រឹត្តហើយ ។ បេ ។ ភពថ្មីទៀត នៃព្រះអរហន្តនោះ មិនមានទេ ហេតុនោះ ព្រះអរហន្តលោកនឹងធឹង ព្រោះជាអ្នកធ្ងងហើយ យ៉ាងនេះ ។

ព្រះអរហន្តលោកនឹងធឹង ព្រោះជាអ្នករួចហើយ តើដូចម្តេច ។ ចិត្តរបស់ព្រះអរហន្ត រួច រួចស្រឡះ រួចផុតស្រឡះ ចាករាគៈ ។

ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ ។ មោហា ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ ។ កោធា ឧបនាហា មក្ខា បឡាសា ឥស្សាយ មច្ឆរិយា មាយាយ សាឋេយ្យា ថម្ភា សារម្ភា មានា អតិមានា មទា បមាទា សព្ព-ក្កិលេសេហិ សព្វទុច្ចរិតេហិ សព្វទរថេហិ សព្វបរិ-ឡាហេហិ សព្វសន្តាបេហិ សព្វាកុសលាភិសង្ខារេ-ហិ ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ ឯវំ អរហា មុត្តាវីតិ តាទិ ។

កថំ អរហា តំនិទ្ទេសា តាទិ ។ អរហា សីលេ សតិ សីលវាតិ តំនិទ្ទេសា តាទិ ។ សទ្ធាយ សតិ សទ្ធោតិ តំនិទ្ទេសា តាទិ ។ វីរិយេ សតិ វីរិយវាតិ តំនិ-ទ្ទេសា តាទិ ។ សតិយា សតិ សតិមាតិ តំនិទ្ទេសា តាទិ ។ សមាធិស្មឹ សតិ សមាហិតោតិ តំនិទ្ទេសា តាទិ ។ បញ្ញាយ សតិ បញ្ញវាតិ តំនិទ្ទេសា តាទិ ។

ចិត្តលោក រួច រួចស្រឡះ រួចផុតស្រឡះ ចាកទោស: ។ ចិត្តលោក រួច រួចស្រឡះ រួចផុតស្រឡះ ចាកមោហ: ។ ចិត្តលោក រួច រួចស្រឡះ រួចផុតស្រឡះ ចាកកោធ: ឧបនាហ: មក្ខ: បឡាស: ឥស្សា មច្ឆរិយ: មាយា សាឋេយ្យ: ថម្ភ: សារម្ភ: មានៈ អតិមានៈ មទ: បមាទ: កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ អកុសលាភិសង្ខារទាំងអស់ ព្រះអរហន្តលោកនឹងធឹង ព្រោះជាអ្នករួចហើយ យ៉ាងនេះ ។

ព្រះអរហន្តលោកនឹងធឹង ព្រោះការសម្តែងចេញនូវហេតុនោះ តើដូចម្តេច ។ ព្រះអរហន្តលោកនឹងធឹង ព្រោះការសម្តែងចេញនូវហេតុនោះថា កាលបើសីលមាន លោកជាអ្នកមានសីល ។ លោកនឹងធឹង ព្រោះការសម្តែងចេញនូវហេតុនោះថា កាលបើសទ្ធាមាន លោកជាអ្នកមានសទ្ធា ។ លោកនឹងធឹង ព្រោះការសម្តែងចេញនូវហេតុនោះថា កាលបើវីរិយ:មាន លោកជាអ្នកមានវីរិយ: ។ លោកនឹងធឹង ព្រោះការសម្តែងចេញនូវហេតុនោះថា កាលបើសតិមាន លោកជាអ្នកមានសតិ ។ លោកនឹងធឹង ព្រោះការសម្តែងចេញនូវហេតុនោះថា កាលបើសមាធិមាន លោកជាអ្នកមានសមាធិ ។ លោកនឹងធឹង ព្រោះការសម្តែងចេញនូវហេតុនោះថា កាលបើបញ្ញាមាន លោកជាអ្នកមានបញ្ញា ។

វិជ្ជាយ សតិ តេវិជ្ជោតិ តំនិទ្ទេសា តានិ ។ អភិ-ញ្ញាយ សតិ ឆឬភិញ្ញោតិ តំនិទ្ទេសា តានិ ។ ឯវំ អរហា តំនិទ្ទេសា តានីតិ ចារដ្ដោ ន បច្ចេតិ តានិ ។ តេនាហ ភគវា

ន ភាយ្ជយន្តិ ន បុរេក្ខ្ជរោន្តិ
ឆម្ភាបិ តេសំ ន ឋជិច្ជិតាសេ
ន ព្រាហ្មណោ សីលវតេន នេយ្យោ
ចារដ្ដោ ន ឋច្ចេតិ តានីតិ ។

ឋញ្ចមោ ឋរមដ្ដកសុត្តនិទ្ទេសោ និដ្ដិតោ ។

លោកនឹងធឹង ព្រោះការសម្តែងចេញនូវហេតុនោះថា កាលបើវិជ្ជាមាន លោកជាអ្នកមានវិជ្ជាបីប្រការ ។ លោកនឹងធឹង ព្រោះការសម្តែងចេញនូវហេតុនោះថា កាលបើអកិញ្ចាមាន លោកជាអ្នកមានអកិញ្ចាប្រាំមួយ ព្រះអរហន្តលោកនឹងធឹង ព្រោះការសម្តែងចេញនូវហេតុនោះយ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) លោកដល់ត្រើយហើយ ជាអ្នកនឹងធឹង មិនត្រឡប់មកវិញទេ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ព្រះអរហន្តទាំងឡាយ មិនតែងតាំង មិនធ្វើឲ្យជាប្រធានដ្ឋិតធម៌ទាំងឡាយ លោកមិនទទួលយកទេ ព្រាហ្មណ៍មិនមែនសីលវត្ត ដឹកនាំបានទេ លោកដល់ត្រើយហើយ ជាអ្នកនឹងធឹង មិនត្រឡប់មកវិញឡើយ ។

ចប់ បរមដ្ឋកសុត្តនិទ្ទេស ទី ៥ ។

ឆដ្ឋោ ជរាសុត្តនិទ្ទេសោ

[១៨១] អប្បំ វត ជីវិតំ ឥទំ
ឱរំ វស្សសតាបិ មិយ្យតិ
យោ ចេបិ អតិច្ច ជីវតិ
អថខោ សោ ជរាសាបិ មិយ្យតិ ។

[១៨២] អប្បំ វត ជីវិតំ ឥធន្តិ ជីវិតន្តិ អាយុ ឋិតិ យាបនា យាបនា ឥរិយនា វត្តនា ចាលនា ជីវិតំ ជីវិតិន្ទ្រិយំ ។ អបិច ទ្វីហិ ការណេហិ អប្បកំ ជីវិតំ ថោកំ ជីវិតំ ឋិតិបរិត្តតាយ ឯ អប្បកំ ជីវិតំ សរសេបរិត្តតាយ ឯ អប្បកំ ជីវិតំ ។

ឯកមំ ឋិតិបរិត្តតាយ អប្បកំ ជីវិតំ ។ អតីតេ ចិត្តក្ខណេ ជីវិត្ថ ន ជីវតិ ន ជីវិស្សតិ ។ អនាគតេ ចិត្តក្ខណេ ជីវិស្សតិ ន ជីវតិ ន ជីវិត្ថ ។ បច្ចុប្បន្នេ ចិត្តក្ខណេ ជីវតិ ន ជីវិត្ថ ន ជីវិស្សតិ ។

ជីវិតំ អត្តភាវោ ច សុខទុក្ខា ច កេវលា
ឯកចិត្តសមាយុត្តា លហុសោ វត្តតិក្ខណោ

ជរាសុត្តនិទ្ទេស ទី ៦

[១៨១] (ព្រះមានព្រះភាគត្រាស់ថា) ជីវិតនេះ តិចណាស់ រមែងស្ងាប់ខាងអាយ អំពីមួយរយឆ្នាំ បើបុគ្គលណា រស់នៅកន្ទងហួស (ពីមួយរយឆ្នាំ) ទៅ បុគ្គលនោះ គង់ស្ងាប់ព្រោះជរាពុំខាន ។

[១៨២] អធិប្បាយពាក្យថា ជីវិតនេះតិចណាស់ ត្រង់ពាក្យថា ជីវិត គឺអាយុ ការតាំងនៅ ការរស់នៅ ការញ៉ាំងអត្តភាពឲ្យរស់នៅ ការដើរទៅ ការប្រព្រឹត្តទៅ ការរក្សាជីវិត ជីវិតិន្ទ្រិយ ។ មួយទៀត ជីវិតតិច ជីវិតស្ហុចស្ដើង ដោយហេតុពីរ គឺជីវិតតិច ព្រោះជាធម្មជាតតាំងនៅតិច ១ ជីវិតតិច ព្រោះកិច្ចរបស់ខ្លួនតិច ១ ។

ជីវិតតិច ព្រោះធម្មជាតតាំងនៅតិច តើដូចម្ដេច ។ សត្វដែលរស់នៅហើយ ក្នុងខណៈចិត្តជាអតីត មិនកំពុងរស់នៅ ក្នុងបច្ចុប្បន្ន នឹងមិនរស់នៅ ក្នុងអនាគតទេ ។ សត្វនឹងរស់នៅ ក្នុងខណៈចិត្តជាអនាគត មិនកំពុងរស់នៅ ក្នុងបច្ចុប្បន្ន មិនរស់នៅហើយ ក្នុងអតីតទេ ។ សត្វកំពុងរស់នៅក្នុងខណៈចិត្ត ជាបច្ចុប្បន្ន មិនបានរស់នៅហើយ ក្នុងអតីត នឹងមិនរស់នៅ ក្នុងអនាគតទេ ។

ជីវិត អត្តភាព សុខនិងទុក្ខទាំងអស់ ប្រកបដោយ
ខណៈចិត្តតែមួយ ព្រោះខណៈ ប្រព្រឹត្តទៅរហ័ស

ចូឡាសីតិសហស្សានិ　　កប្ប តិដ្ឋន្តិ យេ ឥធ
ន ត្វេវ តេបិ ជីវន្តិ　　ទ្វីហិ ចិត្តេហិ សមាហិតា[1]
យេ និរុទ្ធា មរន្តស្ស　　តិដ្ឋមានស្ស វា ឥធ
សព្វេ សទិសា ខ្ឌា　　ឋិតា អប្ឋដិសន្ធិកា
អនន្តរា ច យេ ភគ្គា　　យេ ច ភគ្គា អនាគតា
ឋិតន្តរេ និរុទ្ធានំ　　ឯសម្ចុ ន ត្ថិ លក្ខណោ
អនិព្ឋត្ថេន ន ជាតោ　　បច្ចុប្ឋន្នេ ន ជីវតិ
ចិត្តភង្គមតោ លោកោ　　បញ្ញត្តិ ឥសិ ត្ថិយ
យថា និន្ន ឧវត្តន្តិ　　ឆន្ទេន ឧរិណាមិតា
អច្ឆិន្ទ្ធារ[2] ឧ ត្ថ ន្តិ　　ឧ ឧ ឧ ឧ ឧ ឧ
ឧ ឧ ឧ ឧ ឧ ឧ　　ឧ ឧ ឧ ឧ ឧ ឧ
ឧ ឧ ឧ ឧ ឧ ឧ　　ឧ ឧ ឧ ឧ ឧ ឧ

---

1. ម. ឧ ឧ ឧ ។ ២ ម. ឧ ឧ ឧ ។

ពួកទេវតាណា ឋិតនៅអស់ ៨២ ពាន់កប្ប ទេវតាទាំងនោះ មិនមែនប្រកបដោយចិត្ត ២ ហើយរស់នៅទេ ខន្ធទាំងឆ្នាយ ណា របស់បុគ្គលដែលស្លាប់ទៅក្តី រស់នៅក្តី រលត់ហើយ ក្នុងលោកនេះ ខន្ធទាំងអស់នោះ ក៏ដូចគ្នា ទៅបដិសន្ធិ ទៀតមិនបាន ខន្ធទាំងឆ្នាយណា ដែលកន្ធងទៅជាលំដាប់ បែកធ្លាយហើយផង ខន្ធទាំងឆ្នាយណា ជាអនាគត នឹងបែកធ្លាយផង សេចក្តីផ្សេងគ្នានៃខន្ធទាំងឆ្នាយ ជាបច្ចុប្បន្ន ដែលរលត់ហើយ ក្នុងចន្លោះ នៃខន្ធទាំងពីរនោះ រមែងមិនមានក្នុងលក្ខណៈ សត្វលោក ដែលកើតហើយដោយអនា-គតក្ខន្ធ ដែលមិនទាន់កើត មិនឈ្មោះថា រស់នៅហើយ ទាំងមិនឈ្មោះថា កំពុងរស់នៅក្នុងខន្ធជាបច្ចុប្បន្នទេ សត្វលោកស្លាប់ ដោយការបែកធ្លាយនៃចិត្ត (នេះជា) បញ្ញត្តិនៃបរមត្ត ការប្រែប្រួលទៅដោយធន្ធ: ដូចជាទីទាប រមែងប្រព្រឹត្តទៅ ដូច្នោះ វេទនាទាំងឆ្នាយ មានសឆ្ឆាយតន:ជាបច្ច័យ មានវារ:មិនដាច់ តែងប្រព្រឹត្តទៅ ខន្ធទាំងឆ្នាយ ដែលបែកធ្លាយហើយ ក៏មិនដល់នូវការតម្កល់ទុក គំនរនៃខន្ធ ក្នុងអនាគត ក៏មិនមាន ខន្ធទាំងឆ្នាយ ដែលកើតឡើងហើយ រមែងឋិតនៅ ដូចគ្រាប់ស្ពៃ ដែលឋិតនៅ លើចុងដែកស្រួច

ឆដ្ឋោ ជរាសុត្តនិទ្ទេសោ

និព្វត្តានញ្ច ជម្មានំ   ភង្គោ នេសំ បុរេក្ខតោ
បលោកជម្មា តិដ្ឋន្តិ   ចោរាណោហិ អមិស្សិតា
អទស្សនតោ អាយន្តិ   ភគ្គា គច្ឆន្តិទស្សនំ
វិជ្ជុប្បាទោវ អាកាសេ   ឧប្បជ្ជន្តិ វយន្តិ ចាតិ ។

ឯវំ បិតិបរិត្តតាយ អប្បកំ ជីវិតំ ។

កាថំ សរសបរិត្តតាយ អប្បកំ ជីវិតំ ។ អស្សាសុបនិពទ្ធំ ជីវិតំ បស្សាសុបនិពទ្ធំ ជីវិតំ អស្សាសប្បស្សាសុបនិពទ្ធំ ជីវិតំ មហាភូតុបនិពទ្ធំ ជីវិតំ ឧស្មូបនិពទ្ធំ ជីវិតំ កាវឡិង្ការាហារុបនិពទ្ធំ ជីវិតំ វិញ្ញាណុបនិពទ្ធំ ជីវិតំ ។ មូលម្បិ ឥមេសំ ទុព្វលំ ។ បុព្វហេតូបិ ឥមេសំ ទុព្វលា ។ យេបិ បច្ចយា តេបិ ទុព្វលា ។ យេបិ បភវិកា តេបិ ទុព្វលា ។ សហាភូបិ ឥមេសំ ទុព្វលា ។ សម្បយោគាបិ ឥមេសំ ទុព្វលា ។ សហជាបិ ឥមេសំ ទុព្វលា ។

ជរាសុត្តនិទ្ទេស ទី ៦

កាលបើខន្ធទាំងឡាយ កើតឡើងហើយ ការបែកធ្លាយនៃ ខន្ធទាំងនោះ ក៏ឋិតនៅក្នុងខាងមុខ សការៈដែលត្រូវវិនាស ទាំងឡាយ (ខន្ធ) កំពុងឋិតនៅ មិនច្រឡូកច្រឡំដោយ ខន្ធចាស់ទេ រមែងមកអំពីទីមើលមិនឃើញ លុះបែកធ្លាយ ហើយ តែងទៅកាន់ទីមើលមិនឃើញវិញ រមែងកើតឡើង ផង រមែងវិនាសទៅផង ដូចជាផ្ទេកបន្ទោរឲ្ជដ៏អាកាស ។ ជីវិតតិច ព្រោះការឋិតនៅតិច យ៉ាងនេះ ។

ជីវិតតិច ព្រោះកិច្ចរបស់ខ្លួនតិច តើដូចម្តេច ។ ជីវិតជាប់ទាក់ទង ដោយដង្ហើមចូល ជីវិតជាប់ទាក់ទងដោយដង្ហើមចេញ ជីវិតជាប់ទាក់ ទងដោយដង្ហើមចូលនិងដង្ហើមចេញ ជីវិតជាប់ទាក់ទងដោយមហាភូត-រូប ជីវិតជាប់ទាក់ទងដោយកេ្ងងធាតុ ជីវិតជាប់ទាក់ទងដោយអាហារជា ពំនួត ជីវិតជាប់ទាក់ទងដោយវិញ្ញាណ ។ ឫសគល់របស់ធម៌ទាំងនេះ មានកម្ទាំងថយ ។ បុព្ជហេតុទាំងឡាយរបស់ធម៌ទាំងនេះ ក៏មានកម្ទាំង ថយ ។ សូម្បីពួកធម៌ណាជាបច្ជ័យ ធម៌ទាំងនោះ ក៏មានកម្ទាំងថយ ។ សូម្បីពួកធម៌ណា ជាប្រភព ធម៌ទាំងនោះ ក៏មានកម្ទាំងថយ ។ ពួកធម៌ដែលកើត ជាមួយនឹងធម៌ទាំងនេះ ក៏មានកម្ទាំងថយ ។ ពួក ធម៌ប្រកបជាមួយគ្នា នឹងធម៌ទាំងនេះ ក៏មានកម្ទាំងថយ ។ ធម៌ ដែលកើតឡើង ជាមួយគ្នានឹងធម៌ទាំងនេះ ក៏មានកម្ទាំងថយ ។

យាបិ បយោជិកា សាបិ ទុព្ពលា ។ អញ្ញមញ្ញំ និច្ចទុព្ពលា ឥមេ ។ អញ្ញមញ្ញំ អនុវត្តិតា ឥមេ ។ អញ្ញមញ្ញំ បរិធារយន្តិ ឥមេ ។ អញ្ញមញ្ញស្ស ហិ ឧត្តិ តាយិតា ។ ន ចាបិ ឋបេន្តិ អញ្ញមញ្ញិមេ ។ យោបិ និព្វត្តកោ សោ ន វិជ្ជតិ ។ ន ច កេនចិ កោចិ ហាយតិ ។ ភង្គព្យា(១) ច ឥមេ ហិ សព្វសោ ។ បុរិមេហិ បភាវិតា ឥមេ ។ យេបិ បភាវិតា តេ បុរេ មតា ។ បុរិមាបិច បច្ឆិមាបិច អញ្ញមញ្ញំ ន កទាចិ អទ្ទសំសុតិ ។ ឯវំ សរសបរិត្តតាយ អប្បកំ ជីវិតំ ។

អបិច ចាតុម្មហារាជិកានំ ទេវានំ ជីវិតំ ឧបា-ទាយ មនុស្សានំ អប្បកំ ជីវិតំ បរិត្តកំ ជីវិតំ ថោកំ ជីវិតំ ខណិកំ ជីវិតំ លហុកំ ជីវិតំ ឥត្តរំ ជីវិតំ អ-នទ្ធនីយំ ជីវិតំ ន ចិរដ្ឋិតិកំ ជីវិតំ ។ តាវត្តឹសានំ ទេវានំ ។ យាមានំ ទេវានំ ។ តុសិតានំ ទេវានំ ។ និម្មានរតីនំ ទេវានំ ។ បរនិម្មិតវសវត្តីនំ ទេវានំ ។ ព្រហ្មកាយិកានំ ទេវានំ ជីវិតំ ឧបាទាយ មនុស្សានំ អប្បកំ ជីវិតំ បរិត្តកំ ជីវិតំ ថោកំ ជីវិតំ ខណិកំ

១. ម. គន្តព្វា ។

ធម្មជាតិណាជាគ្រឿងប្រកប ធម្មជាតិនោះ ក៏មានកម្ទាំងថយ ។ ធម៌ទាំងនេះ មានកម្ទាំងថយជានិច្ចដល់គ្នានិងគ្នា ។ ធម៌ទាំងនេះ មិនឱនរកគ្នានិងគ្នា ។ ធម៌ទាំងនេះ ញ៉ាំងគ្នានិងគ្នាឲ្យធ្លាក់ចុះ ។ ព្រោះមិនបានជាទីពឹងដល់គ្នានិងគ្នា ។ មួយទៀត ធម៌ទាំងនេះ មិនតម្កល់ទុកនូវគ្នានិងគ្នា ។ សូម្បីធម៌ណា ជាអ្នកបង្កើត ធម៌នោះ ក៏មិនមាន ។ ធម៌ណាមួយ មិនមែនវិនាស ដោយធម៌ណាមួយទេ ។ ព្រោះថា ធម៌ទាំងនេះ បែកធ្លាយទៅដោយប្រការទាំងពួង ។ ធម៌ទាំងនេះ កើតហើយ ព្រោះហេតុនិងបច្ច័យអំពីមុន ។ ហេតុនិងបច្ច័យទាំងឡាយណាដែលឲ្យកើតមុន ហេតុនិងបច្ច័យទាំងនោះ ក៏ស្ងាប់មុនទៅហើយ ។ ធម៌ទាំងឡាយខាងដើមនិងខាងចុង មិនបានឃើញគ្នានិងគ្នា ក្នុងកាលណាមួយឡើយ ។ ជីវិតតិច ព្រោះកិច្ចរបស់ខ្លួនតិច យ៉ាងនេះ ។

មួយទៀត ពួកមនុស្ស មានជីវិតតិច ជីវិតស្ពួចស្តើង ជីវិតខ្ចី ជីវិតមានក្នុងមួយខណៈ ជីវិតរហ័ស ជីវិតធាប់ ជីវិតមិនមាំមួន ជីវិតមិនបិតនៅយូរ បើប្រៀបធ្ងឹមនឹងជីវិត របស់ពួកទេវតាជាន់ចាតុម្មហារ-ជិកា ។ របស់ពួកទេវតាជាន់តាវត្តិង្ស ។ របស់ទេវតាជាន់យាមៈ ។ របស់ទេវតាជាន់តុសិត ។ របស់ទេវតាជាន់និម្មានរតី ។ របស់ទេវតា ជាន់បរនិម្មិតវសវត្តី ។ ពួកមនុស្ស មានជីវិតតិច ជីវិតស្ពួចស្តើង ជីវិតថោកថយ ជីវិតមានក្នុងមួយខណៈ

ជីវិតំ លហុកំ ជីវិតំ ឥត្តរំ ជីវិតំ អនេ្ធនីយំ ជីវិតំ ន ចិរដ្ឋិតិកំ ជីវិតំ ។ រុត្តំ ហេតំ ភគវតា អប្ប មិទំ ភិក្ខវេ មនុស្ឃានំ អាយុ គមនីយោ សម្ប រាយោ មន្ទាយ ផោដ្ឋព្ពំ កត្តព្ពំ កុសលំ ចរិតព្ពំ ព្រហ្មចរិយំ ជត្តិ ជាតស្ស អមរណំ យោ ភិក្ខវេ ចិរំ ជីវតិ សោ វស្ឃសតំ អប្ប ំ វ ភិយ្យោ

អ ប្ប មាយុ មនុស្ឃានំ ហិ ឍ្ឍ យ្ យ ំ សុ ចោ រិ សោ
ចរ យ្យ ិ ត្ត សី សោ ជ ត្ត ិ ម ចុ ស្ឃ ជ ាត ម ោ
អ ចូ យ ន្ត ិ អ ហោ រ ត្ត ា ជ ីវ ិ ត ំ ឧ ប រ ុ ជ ្ឌ ត ិ
អ ាយ ុ ទ ីយ ត ិ ម ច ្ច ាន ំ ក ុ ន ្ន ទ ី ន ំ ว ឧ ទ ក ន ្ត ិ ។

អ ប ្ប ំ ว ត ជ ីវ ិ ត ំ ส ខ ំ ។

[១៨៣] ឯ រ ំ ว ស ្ឃ ស ត ា ប ិ ម ិ យ ្ យ ត ី ត ិ ก ล ล ก า-
ล េ ป ิ ช ว ต ิ ม ว ต ิ อ ន ฺ ต ร ช า ย ต ิ ว ิ ป ฺ ป ล ุ ช ฺ ช ต ิ ។ อ ม ฺ พุ-
ข ก า ล ป ิ ช ว ต ิ ม ว ต ิ อ น ฺ ต ร ช า ย ต ิ ว ิ ป ฺ ป ล ุ ช ฺ ช ต ิ ។
ป ท ส ิ ก า ล ป ิ ช ว ต ิ ม ว ต ิ อ น ฺ ต ร ช า ย ต ิ ว ิ ป ฺ ป ล ุ ช ฺ ช ต ิ ។

ជីវិតរហ័ស ជីវិតធាប់ ជីវិតមិនមាំមួន ជីវិតមិនបិតនៅយូរ បើប្រៀបផ្ទឹមនឹងជីវិតរបស់ទេវតាព្រហ្មកាយិក: ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាយុរបស់ពួកមនុស្សនេះ តិច បរលោកពួកសត្វត្រូវទៅដោយពិត បុគ្គលគប្បីប ះពាល់ដោយបញ្ញា គប្បីធ្វើកុសល គប្បីប្រព្រឹត្តព្រហ្មចរិយ: (ព្រោះថា) សត្វដែលកើតហើយ មិនមែនជាមិនស្លាប់ទេ ម្នាលភិក្ខុទាំងឡាយ បុគ្គលណារស់នៅអស់កាលយូរ បុគ្គលនោះ គប្បីរស់នៅ ១០០ ឆ្នាំ តិចពីមួយរយឆ្នាំ ឬច្រើនជាង ១០០ ឆ្នាំ ។

> អាយុរបស់ពួកមនុស្ស តិច បុរសល្អគប្បីនឿយណាយ នឹងអាយុនោះ គប្បីប្រព្រឹត្តដូចជាបុគ្គល ដែលភ្ជើងឆេះក្បាលដំណើរមិនមកនៃមច្ចុ មិនមានទេ ថ្ងៃនិងយប់តែងកន្ទងទៅ ជីវិតក៏ស្រកស្រុតទៅដែរ អាយុរបស់ពួកសត្វ រមែងអស់ទៅ ដូចជាទឹកនៃស្ទឹងតូចទាំងឡាយ ។

ហេតុនេះ (ទ្រង់ត្រាស់ថា) ជីវិតនេះ តិចណាស់ ។

[១៨៣] ពាក្យថា សត្វរមែងស្លាប់ខាងអាយអំពីមួយរយឆ្នាំ អធិប្បាយថា សត្វរមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងកាលជាកលល: ក៏មាន ។ សត្វរមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងកាលជាអម្ពុទ: ក៏មាន ។ សត្វរមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងកាល ជាបេសិ ក៏មាន ។

ឃនកាលេបិ ចវតិ មរតិ អន្តរធាយតិ វិប្ផលុជ្ជតិ ។ បញ្ចសាទកាលេបិ ចវតិ មរតិ អន្តរធាយតិ វិប្ផលុ-ជ្ជតិ ។ ជាតិមត្តោបិ ចវតិ មរតិ អន្តរធាយតិ វិប្ផលុជ្ជតិ ។ បសូតិឃរេបិ ចវតិ មរតិ អន្តរធាយតិ វិប្ផលុជ្ជតិ ។ អឌ្ឍមាសិកោបិ ចវតិ មរតិ អន្តរធា-យតិ វិប្ផលុជ្ជតិ ។ មាសិកោបិ ចវតិ មរតិ អន្តរ-ធាយតិ វិប្ផលុជ្ជតិ ។ ទ្វិមាសិកោបិ តិមាសិកោបិ ចតុម្មាសិកោបិ បញ្ចមាសិកោបិ ចវតិ មរតិ អន្តរ-ធាយតិ វិប្ផលុជ្ជតិ ។ ឆមាសិកោបិ សត្តមាសិកោបិ អដ្ឋមាសិកោបិ ឧនវមាសិកោបិ ឧនសមាសិកោបិ សំវច្ឆរិកោបិ ចវតិ មរតិ អន្តរធាយតិ វិប្ផលុជ្ជតិ ។ ទ្វិវស្សិកោបិ តិវស្សិកោបិ ចតុវស្សិកោបិ បញ្ចវ-ស្សិកោបិ ឆវស្សិកោបិ សត្តវស្សិកោបិ អដ្ឋវស្សិ-កោបិ ឧនវីសវស្សិកោបិ ឧនសវស្សិកោបិ រីសតិវស្សិ-កោបិ តឹសវស្សិកោបិ ចត្តាឡីសវស្សិកោបិ បញ្ញា-សវស្សិកោបិ សដ្ឋីវស្សិកោបិ សត្ត្ដតិវស្សិកោបិ អសីតិវស្សិកោបិ ឧតិវស្សិកោបិ ចវតិ មរតិ អន្តរ-ធាយតិ វិប្ផលុជ្ជតីតិ ឱរំ វស្សសតាបិ មិយ្យតិ ។

សត្វមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងកាល ជាឃនៈ ក៏មាន ។ សត្វមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងកាល ជាបញ្ចសាខា ក៏មាន ។ សត្វគ្រាន់តែមានកំណើត ច្យុត ស្លាប់ បាត់បង់ វិនាសទៅវិញ ក៏មាន ។ សត្វមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងផ្ទះជាទីប្រសូត ក៏មាន ។ សត្វកើតបានកន្ទុះខែច្យុត ស្លាប់ បាត់បង់ វិនាសទៅវិញ ក៏មាន ។ សត្វកើតបាន ១ ខែ ច្យុត ស្លាប់ បាត់បង់ វិនាសទៅវិញ ក៏មាន ។ សត្វកើតបាន ២ ខែខ្ទះ បាន ៣ ខែខ្ទះ បាន ៤ ខែខ្ទះ បាន ៥ ខែខ្ទះ ច្យុត ស្លាប់ បាត់បង់ វិនាសទៅវិញ ក៏មាន ។ សត្វកើតបាន ៦ ខែខ្ទះ ៧ ខែខ្ទះ ៨ ខែខ្ទះ ៩ ខែខ្ទះ ១០ ខ្ទះ ១ ឆ្នាំខ្ទះ ច្យុត ស្លាប់ បាត់បង់ វិនាសទៅវិញ ក៏មាន ។ សត្វកើតបាន ២ ឆ្នាំខ្ទះ ៣ ឆ្នាំខ្ទះ ៤ ឆ្នាំខ្ទះ ៥ ឆ្នាំខ្ទះ ៦ ឆ្នាំខ្ទះ ៧ ឆ្នាំខ្ទះ ៨ ឆ្នាំខ្ទះ ៩ ឆ្នាំខ្ទះ ១០ ឆ្នាំខ្ទះ ២០ ឆ្នាំខ្ទះ ៣០ ឆ្នាំខ្ទះ ៤០ ឆ្នាំខ្ទះ ៥០ ឆ្នាំខ្ទះ ៦០ ឆ្នាំខ្ទះ ៧០ ឆ្នាំខ្ទះ ៨០ ឆ្នាំខ្ទះ ៩០ ឆ្នាំខ្ទះ ច្យុត ស្លាប់ បាត់បង់ វិនាសទៅវិញ ក៏មាន ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលមែងស្លាប់ខាងអាយ អំពីមួយរយឆ្នាំ ។

ឆដ្ឋោ ជរាសុត្តនិទ្ទេសោ

[១៨៤] យោ ចេបិ អតិចូ ជីវតីតិ យោ វស្ស-
សតំ អតិក្កមិត្វា ជីវតិ សោ ឯកំ វ វស្សំ ជីវតិ
ទ្វេ វ វស្សានិ ជីវតិ តីណិ វ វស្សានិ ជីវតិ
ចត្តារិ វ វស្សានិ ជីវតិ បញ្ច វ វស្សានិ ជីវតិ
ទស វ វស្សានិ ជីវតិ វីសតិ វ វស្សានិ ជីវតិ
តឹស វ វស្សានិ ជីវតិ ចត្តាឍ្ឍីសំ វ វស្សានិ
ជីវតីតិ យោ ចេបិ អតិចូ ជីវតិ ។

[១៨៥] អថខោ សោ ជរសាបិ មិយ្យតីតិ យតា
ជិណ្ណោ ហោតិ វុឍ្ឍោ មហាលូកោ អទ្ធគតោ វយោ-
អនុប្ឍត្តោ ខណ្ឌទន្តោ បលិតកេសោ វិលូនំ ខលិត-
សិរោ វលីនំ តិលកាហតគត្តោ ឱ្ហាយ ភត្តោ ទណ្ឌាប-
ភាយនោ សោ ជាយបិ ចរតិ មរតិ អន្ត្ថជាយតិ
វិប្ឍលុជ្ជតិ ។

ជត្តុ មរណម្ហា មោក្ខោ

ជលានមិវ បណ្ណានំ ចាតោ បតនតោ ភយំ
ឯវំ ជាតានមច្ចានំ និច្ចំ មរណតោ ភយំ

ជរាសុត្តនិទ្ទេស ទី ៦

[១៨២] ពាក្យថា បើបុគ្គលណា រស់នៅកន្ទ្ធងហួសទៅ គឺ បុគ្គលណា រស់នៅកន្ទ្ធងមួយរយឆ្នាំ បុគ្គលនោះ រស់នៅអស់ ១ ឆ្នាំក្តី រស់នៅអស់ ២ ឆ្នាំក្តី រស់នៅអស់ ៣ ឆ្នាំក្តី រស់នៅអស់ ៤ ឆ្នាំក្តី រស់នៅអស់ ៥ ឆ្នាំក្តី រស់នៅអស់ ១០ ឆ្នាំក្តី រស់នៅអស់ ២០ ឆ្នាំក្តី រស់នៅអស់ ៣០ ឆ្នាំក្តី រស់នៅអស់ ៤០ ឆ្នាំក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) បើបុគ្គលណា រស់នៅកន្ទ្ធងហួសទៅ ។

[១៨៣] ពាក្យថា បុគ្គលនោះ គង់ស្ងាប់ ព្រោះជរាពុំខាន អធិប្បាយថា កាលណា បុគ្គលចាស់ ចម្រើនដោយវ័យ មានអាយុច្រើនកន្ទ្ធងកាល ជ្រុលចូលក្នុងបច្ឆិមវ័យ មានធ្មេញបាក់ សក់ស្កូវ ក្បាលធក ក្បាលថ្ពែក ស្បែកជ្រួញជ្រីវ មានខ្ជូនរទុះដោយប្រជ្រុយ ខ្នងកោង ក្ងក់ កាន់ឈើច្រត់ បុគ្គលនោះ គង់ច្យុត ស្ងាប់ បាត់បង់ វិនាស ព្រោះជរា ។

ការរួចចាកមរណៈ មិនមានទេ សត្វទាំងឡាយ ដែលកើត ហើយ តែងមានភ័យអំពីមរណៈជានិច្ច ដូចជាផ្ទៃឈើទុំ ទាំងឡាយ តែងមានភ័យអំពីការជ្រុះចុះ ក្នុងវេលាព្រឹក

យថាបិ កុម្ភការស្ស កតា មត្តិកភាជនា
សព្វេ ភេទបរិយន្តា[១] ឯវំ មច្ចានជីវិតំ
ទហរា ច មហន្តា ច យេ ពាលា យេ ច បណ្ឌិតា
សព្វេ មច្ចុវសំ យន្តិ សព្វេ មច្ចុបរាយនា
តេសំ មច្ចុបរេតានំ គច្ឆតំ បរលោកតោ
ន បិតា តាយតេ បុត្តំ ញាតី វា បន ញាតកេ
បេក្ខតញ្ញេវ ញាតីនំ បស្ស លាលប្បតំ បុថុ
ឯកមេកោវ មច្ចានំ គោវជ្ឈោ វិយ និយ្យតិ
ឯវំ អព្ភាហតោ លោកោ មច្ចុនា ច ជរាយ ចាតិ ។

អថវា សោ ជរសាបិ មិយ្យតិ ។ តេនាហ ភគវា

អប្បំ វត ជីវិតំ ឥទំ
ឱរំ វស្សសតាបិ មិយ្យតិ
យោ ចេបិ អតិច្ច ជីវតិ
អថខោ សោ ជរសាបិ មិយ្យតីតិ ។

១ ឱ. ម. ភេទនបរិយន្តា ។

ភាជន៍ដី ដែលកុម្ភការធ្វើហើយ ទាំងអស់ មានការបែក ធ្លាយជាទីបំផុត យ៉ាងណា ជីវិត របស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ពួកជនណា ទាំងក្មេង ទាំងចាស់ ទាំង ពាល ទាំងបណ្ឌិត ពួកជនទាំងអស់នោះ រមែងលុះអំ-ណាចនៃមច្ចុ ពួកជនទាំងអស់ មានមច្ចុប្រព្រឹត្តទៅខាងមុខ កាលពួកជនទាំងនោះ ដែលមច្ចុគ្របសង្កត់ ទៅកាន់បរ-លោក បិតាពឹងបុត្តមិនបាន ឬថាពួកញាតិពឹងពួកញាតិក៏ មិនបាន អ្នកចូរមើលចុះ កាលពួកញាតិកំពុងសម្លឹងមើល កំពុងយំរៀបរាប់ច្រើន សត្វលោក ដែលត្រូវមច្ចុនិងជរា បំផ្លាញហើយ ដូចជាបណ្ដាសត្វទាំងឡាយ គោមួយៗ ដែលគេត្រូវនាំទៅសម្លាប់ ។

ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះគង់ស្ងាប់ ព្រោះជរាពុំខាន ។

ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ជីវិតនេះ តិចណាស់ រមែងស្ងាប់ខាងអាយ អំពីមួយរយឆ្នាំ បើបុគ្គលណា រស់នៅកន្ទងហួស (ពីមួយរយឆ្នាំ) ទៅ បុគ្គលនោះ គង់ស្ងាប់ ព្រោះជរាពុំខាន ។

ឆដ្ឋោ ជរាសុត្តនិទ្ទេសោ

[១៨៦] សោចន្តិ ជនា មមាយិតេ
ន ហិ សន្តិ និច្ចា បរិក្ខារា
វិនាការសន្តមេវិទំ
ឥតិ ឌិស្វា ជនការមារសេ ។

[១៨៧] សោចន្តិ ជនា មមាយិតេតិ ជនាតិ ខត្តិយា ច ព្រាហ្មណា ច វេស្សា ច សុទ្ទា ច គហដ្ឋា ច បព្ជិ-តា ច ទេវា ច មនុស្សា ច ។ មមត្តាតិ ទ្វេ មមត្តា តណ្ហាមមត្តញ្ច ទិដ្ឋិមមត្តញ្ច ។ បេ ។ ឥទំ តណ្ហាមមត្តំ ។ បេ ។ ឥទំ ទិដ្ឋិមមត្តំ ។ មមាយិតវត្ថុអច្ឆេទសង្ខ-ញោបិ សោចន្តិ អច្ឆិជ្ជន្តេបិ សោចន្តិ អច្ឆិន្នេបិ សោ-ចន្តិ មមាយិតវត្ថុបរិណាមសង្ខ្លោបិ សោចន្តិ វិបរិ-ណាមន្តេបិ សោចន្តិ វិបរិណាតេបិ សោចន្តិ កិលមន្តិ បរិទេវន្តិ ឧរត្តាឬ្យ ក្ខន្ទន្តិ សម្មោហំ អាបជ្ជន្តីតិ សោចន្តិ ជនា មមាយិតេ ។

ជរាសុត្តនិទ្ទេស ទី ៦

[១៨៦] ពួកជន រមែងសោកស្តាយ ចំពោះវត្ថុដែលហួងហែង ការហួងហែងទាំងឡាយ ពុំមែនជាការទៀងទាត់ទេ វត្ថុនេះ មានសភាពព្រាត់ប្រាសដោយពិត បុគ្គលកាលឃើញដូច្នេះ ហើយ មិនគួរនៅគ្រប់គ្រងផ្ទះឡើយ ។

[១៨៧] អធិប្បាយពាក្យថា ពួកជន រមែងសោកស្តាយ ចំពោះវត្ថុដែលហួងហែង ត្រង់ពាក្យថា ពួកជន បានដល់ ពួកក្សត្រិយ៍ ព្រាហ្មណ៍ វេស្ស: សុទ្ទ: គ្រហស្ថ បព្វជិត ទេវតា មនុស្ស ។ ពាក្យថា ការហួងហែង បានដល់ការហួងហែង ២ គឺការហួងហែងគឺតណ្ហា ១ ការហួងហែងគឺទិដ្ឋិ ១ ។ បេ ។ នេះការហួងហែងគឺតណ្ហា ។ បេ ។ នេះការហួងហែងគឺទិដ្ឋិ ។ ពួកជនជាអ្នកមានសេចក្តីរង្គៀស ដោយការដណ្តើមយកវត្ថុដែលហួងហែង រមែងសោកស្តាយ ក៏មាន សោកស្តាយចំពោះវត្ថុដែលគេកំពុងដណ្តើមយក ក៏មាន សោកស្តាយចំពោះវត្ថុដែលគេដណ្តើមយកហើយ ក៏មាន ពួកជន មានសេចក្តីរង្គៀសដោយការប្រែប្រួលចាកវត្ថុដែលហួងហែង រមែងសោកស្តាយ ក៏មាន សោកស្តាយចំពោះវត្ថុដែលកំពុងប្រែប្រួល ក៏មាន សោកស្តាយចំពោះវត្ថុដែលប្រែប្រួលហើយ ក៏មាន រមែងលំបាក ខ្សឹកខ្សួល គក់ទ្រូង ដល់នូវការវង្វេង ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកជន រមែងសោកស្តាយ ចំពោះវត្ថុដែលហួងហែង ។

[១៨៨] ន ហិ សន្តិ ជិច្ចា បរិក្ខហាតិ បរិក្ខហាតិ ទ្វេ បរិក្ខហា តណ្ហាបរិក្ខហោ ច ជិដ្ឋិបរិក្ខហោ ច ។ បេ ។ អយំ តណ្ហាបរិក្ខហោ ។ បេ ។ អយំ ជិដ្ឋិបរិក្ខហោ ។ តណ្ហាបរិក្ខហោ អជិច្ចា សង្ខ្លោ បដិចូសមុប្ផន្នោ ខយធម្មោ វយធម្មោ វិភតធម្មោ ជិរោធធម្មោ វិបរិណាមធម្មោ ។ ជិដ្ឋិបរិក្ខហោ អជិច្ចា សង្ខ្លោ បដិចូសមុប្ផន្នោ ខយធម្មោ វយធម្មោ វិភតធម្មោ ជិរោធធម្មោ វិបរិណាមធម្មោ ។ រុត្តំ ហេតំ ភគវតា បស្ឃថ ណោ តុម្ហេ ភិក្ខវេ តំ បរិក្ខហំ យ្វាយំ បរិក្ខហោ ជិច្ចា ជុរោ សស្ឃតោ អវិបរិណាមធម្មោ សស្ឃតិសមំ តថេវ បស្ឃតីតិ ។ ណោ ហេតំ ភន្តេ ។ សាធុ ភិក្ខវេ អហម្ឃិ ខោ ឯតំ ភិក្ខវេ បរិក្ខហំ ន សមនុបស្ឃាមិ យ្វាយំ បរិក្ខហោ ជិច្ចា ជុរោ សស្ឃតោ អវិបរិណាមធម្មោ សស្ឃតិសមំ តថេវ បស្ឃតីតិ ។

[១៨៨] *អធិប្បាយពាក្យថា ការហួងហែងទាំងឡាយ ពុំមែនជាការទៀងទាត់ទេ ត្រង់ពាក្យថា ការហួងហែង បានដល់ការហួងហែង ២ គឺការហួងហែងគឺតណ្ហា ១ ការហួងហែងគឺទិដ្ឋិ ១ ។ បេ ។ នេះការហួងហែងគឺតណ្ហា ។ បេ ។ នេះការហួងហែងគឺទិដ្ឋិ ។ ការហួងហែងគឺតណ្ហា ជាសភាពមិនទៀង ដែលបច្ច័យតាក់តែង កើតឡើង ព្រោះអាស្រ័យ (បច្ច័យ) មានការអស់ទៅជាធម្មតា វិនាសទៅជាធម្មតា ប្រាសទៅជាធម្មតា រលត់ទៅជាធម្មតា ប្រែប្រួលទៅជាធម្មតា ។ ការហួងហែងគឺទិដ្ឋិ ជាសភាពមិនទៀង ដែលបច្ច័យតាក់តែង កើតឡើង ព្រោះអាស្រ័យ (បច្ច័យ) មានការអស់ទៅជាធម្មតា វិនាសទៅជាធម្មតា ប្រាសទៅជាធម្មតា រលត់ទៅជាធម្មតា ប្រែប្រួលទៅជាធម្មតា ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគ ត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ធ្លាប់ឃើញការហួងហែង ដែលជាសភាពទៀង មាំមួន ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅ ស្មើដោយសស្សតិវត្ថុ ដូច្នោះដែរឬ ។ បពិតព្រះអង្គដ៏ចម្រើន ដំណើរនុ៎ះ យើងខ្ញុំមិនធ្លាប់ឃើញទេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ប្រពៃហើយ ម្នាលភិក្ខុទាំងឡាយ តថាគត ក៏ពិចារណាមិនឃើញនូវការហួងហែងនុ៎ះ ដែលជាសភាពទៀង មាំមួន ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅស្មើដោយសស្សតិវត្ថុ ដូច្នោះដែរ ។*

បរិគ្គហា និច្ចា ធុវា សស្សតា អវិបរិណាមធម្មា នត្ថិ ន សន្តិ ន សំវិជ្ជន្តិ នុបលព្ភន្តីតិ ហិ សន្តិ និច្ចា បរិគ្គហា ។

[១៨៩] វិនាភាវសន្តមេវិទន្តិ នានាភាវេ វិនាភាវេ អញ្ញថាភាវេ សន្តេ សំវិជ្ជមានេ[១] ឧបលព្ភិយមានេ ។ វុត្តំ ហេតំ ភគវតា អលំ អានន្ទ មា សោចិ មា បរិទេវិ ននុ ឯតំ អានន្ទ មយា បដិកច្ចេវ[២] អក្ខាតំ សព្វេហេវ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ អញ្ញថាភាវោ តំ កុតេត្ថ អានន្ទ លព្ភា យន្តំ ជាតំ ភូតំ សង្ខតំ បលោកធម្មំ តំ វត មា បលុជ្ជីតិ នេតំ ឋានំ វិជ្ជតីតិ ។ បុរិមានំ បុរិមានំ ខន្ធានំ ធាតូនំ អាយតនានំ វិបរិណាមញ្ញថាភាវា បច្ឆិមា បច្ឆិមា ខន្ធា ច ធាតុយោ ច អាយតនានិ ច បវត្តន្តីតិ វិនាភាវសន្តមេវិទំ ។

---

១ ម. សំវិជ្ជមានេ អត្ថិ ។ ២ បដិគេច្ចវាតិបិ បាឋោ ។

ការហួងហែងទាំងឡាយ ជាសភាពទៀង មាំមួន ឋិតថេរ មិនប្រែប្រួលជាធម្មតា ឥតមាន មិនដែលមាន មិនមានប្រាកដ មិនកើតមានទេ ហេតុនោះ (ទ្រង់ត្រាស់ថា) ការហួងហែងទាំងឡាយ ពុំមែនជាការទៀងទាត់ទេ ។

[១៨៥] ពាក្យថា វត្ថុនេះមានសភាពព្រាត់ប្រាសដោយពិត គឺ ការៈផ្សេងៗ ការៈព្រាត់ប្រាស ការៈទៅជាយ៉ាងដទៃ កាលមាន កាលកាន់ព្រម កាលកើតមាន ។ សមដូចពាក្យនេះ ដែលព្រះមានបុណ្យត្រាស់ហើយថា ម្នាលអានន្ទ មិនគួរទេ អ្នកកុំសោក កុំខ្សឹកខ្សួលឡើយ ម្នាលអានន្ទ ក្រែងតថាគតបានពោលហើយ ក្នុងកាលមុន នូវពាក្យនេះថា ការៈផ្សេងៗ ការៈព្រាត់ប្រាស ការៈជាយ៉ាងដទៃ ចាកសត្វនិងសង្ខារទាំងពួង ជាទីស្រឡាញ់ពេញចិត្តដូច្នេះឬ ម្នាលអានន្ទ បុគ្គលគប្បីបាន នូវហេតុនោះ ក្នុងសត្វនិងសង្ខារទាំងនោះ អំពីទីណាថា វត្ថុណាកើតហើយ ប្រាកដហើយ តាក់តែងហើយ មានកិរិយាវិនាសជាធម្មតា ឱ្ហ៎ៗ! វត្ថុនោះ កុំវិនាសឡើយ ដំណើរនោះមិនសមហេតុទេ ។ ព្រោះ សេចក្តីប្រែប្រួលជាយ៉ាងដទៃ របស់ខន្ធ ធាតុ អាយតនៈ ដែលមានក្នុងកាលមុន ។ ខន្ធ ធាតុ អាយតនៈ ដែលមានក្នុងកាលខាងក្រោយៗ ក៏រមែងប្រព្រឹត្តទៅ (ដូចគ្នា) ហេតុនោះ (ទ្រង់ត្រាស់ថា) វត្ថុនេះមានសភាពព្រាត់ប្រាសដោយពិត ។

[១៩០] ឥតិ ជិស្វា ជាការមារសេតិ ឥតីតិ បជ-
ស្ជិ បជសំសត្តោ បជចារិបូរ[1] អក្ខារសមវាយោ
ព្យញ្ជនសិលិដ្ឋតា បជាជុបុព្ជកមេតំ ឥតីតិ ។ ឥតិ
ជិស្វា បស្ជ្ជិត្វា តុលយិត្វា តីរយិត្វា វិការយិត្វា វិភូ-
តំ កត្វា មមត្តេស្ជតិ ឥតិ ជិស្វា ។ ជាការមារសេតិ
សពុ្ជ ឃរាវាសបលិពោជំ ជិន្ជិត្វា បុត្តជារបលិពោជំ
ជិន្ជិត្វា ញាតិបលិពោជំ ជិន្ជិត្វា មិត្តាមចូបលិពោជំ
ជិន្ជិត្វា សន្ជ្ជិជិបលិពោជំ ជិន្ជិត្វា កេសមស្ជ្ជុ ឱហា-
រេត្វា កាសាយានិ វត្ថានិ អជ្ជាជេត្វា អការស្ម្ជ អ-
ជការិយំ បជ្ជជិត្វា អាកិញ្ជនការ ឧបកជ្ជ ឯកោ
ចរេយ្ស វិហរេយ្ស ឥរិយេយ្ស វត្តេយ្ស ចាលេយ្ស
យបេយ្ស យាបេយ្សាតិ ឥតិ ជិស្វា ជាការមារសេ ។
តេជាហ ភគវា

សោចន្តិ ជនា មមាយិតេ
ន ហិ សន្តិ និជ្ជា បរិគ្ជហា

---

១ ម. បទ ជារិបូរី ។

[១៩០] *អធិប្បាយពាក្យថា បុគ្គលឃើញដូច្នេះហើយ មិនគួរនៅគ្រប់គ្រងផ្ទះឡើយ ត្រង់ពាក្យថា ដូច្នេះ គឺជាពាក្យភ្ជាប់បទ ជាពាក្យជាប់ទាក់ទងដោយបទ ជាពាក្យញុំងបទឲ្យពេញ ជាពាក្យប្រជុំដោយអក្ខរៈ ជាបទសម្រួលព្យញ្ជនៈ ពាក្យថា ដូច្នេះ នេះ ជាលំដាប់នៃបទ ។ បុគ្គលឃើញ យល់ ច្បីង ពិចារណា យល់ច្បាស់ ធ្វើឲ្យប្រាកដ ក្នុងវត្ថុដែលហួងហែង ដូច្នេះហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលឃើញដូច្នេះហើយ ។ ពាក្យថា មិនគួរនៅគ្រប់គ្រងផ្ទះ គឺគប្បីកាត់បលិពោធ ក្នុងឃរាវាសគ្រប់យ៉ាង កាត់បលិពោធ ក្នុងបុត្តភរិយា កាត់បលិពោធក្នុងពួកញាតិ កាត់បលិពោធក្នុងមិត្តនិងអាមាត្យ កាត់បលិពោធក្នុងការសន្សំ ហើយកោរសក់និងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ (ចេញ) ចាកផ្ទះ ហើយបួសដោយភេទជាបុគ្គលមិនមានផ្ទះ ដល់នូវភាពមិនមានកង្វល់ ត្រាច់ទៅ នៃបនៅ សម្រេចសម្រាន្ត ប្រព្រឹត្ត រក្សា សម្រួល រស់នៅតែម្នាក់ឯង ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលឃើញដូច្នេះហើយ មិនគួរនៅគ្រប់គ្រងផ្ទះឡើយ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា*

ពួកជន រមែងសោកស្តាយ ចំពោះវត្ថុដែលហួងហែង
ការហួងហែងទាំងឡាយ ពុំមែនជាការទៀងទាត់ទេ

វិនាភាវសន្តមេវិទំ
ឥតិ ទិស្វា នាគារមាវសេតិ ។

[១៩១] មរណេនបិ តំ បហីយតិ
យំ បុរិសោ មមយិទន្តិ មញ្ញតិ
ឯតម្បិ វិទិត្វា បណ្ឌិតោ
ន មមត្តាយ នមេថ មាមកោ ។

[១៩២] មរណេនបិ តំ បហីយតីតិ មរណន្តិ យា តេសំ តេសំ សត្តានំ តម្ហា តម្ហា សត្តនិកាយា ចុតិ ចវនតា[១] ភេទោ អន្តរធានំ មច្ចុ មរណំ កាលកិរិយា ខន្ធានំ ភេទោ កឡេវរស្ស និក្ខេបោ ជីវិតិន្ទ្រិយស្សុបច្ឆេទោ ។ តន្តិ រូបគតំ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ ។ បហីយតីតិ បហីយតិ ជហីយតិ វិជហីយតិ អន្តរធាយតិ វិប្បលុជ្ជតិ ។ ភាសិតម្បិ ហេតំ

បុព្វេវ មច្ចំ វិជហន្តិ ភោគា
មច្ចោវ នេ បុព្វតរំ ជហាតិ
អសស្សតា ភោគិនោ កាមកាមិ

១ ម. ចវនតា ខន្ធានំ ។

វត្ថុនេះ មានសភាពព្រាត់ប្រាសដោយពិត បុគ្គលឃើញ ដូច្នេះហើយ មិនគួរនៅគ្រប់គ្រងផ្ទះឡើយ ។

[១៩១] បុរសសម្គាល់នូវខន្ធបញ្ចក:ណាថា នេះរបស់អញ ខន្ធ-បញ្ចក:នោះ រមែងសាបសូន្យ ដោយមរណ: បណ្ឌិត ជាអ្នកវាប់អាន ដឹងច្បាស់ដំណើរនុ៎ះហើយ មិនគប្បីបង្អោន ទៅក្នុងសេចក្ដីហួងហែងឡើយ ។

[១៩២] អធិប្បាយពាក្យថា ខន្ធបញ្ចក:នោះ រមែងសាបសូន្យ ដោយ មរណ: ត្រង់ពាក្យថា មរណ: បានដល់ ការច្យុត ការឃ្លាត ការ បែកធ្លាយ ការបាត់បង់ មច្ចុ មរណ: កាលกิริยา ការបែកធ្លាយខន្ធ ការដាក់ចោលសាកសព ការផ្ដាច់បង់ជីវិតិន្ទ្រិយ ចាកសត្តនិកាយ នោះ ๆ របស់សត្វទាំងឡាយនោះ ๆ ។ ពាក្យថា ខន្ធបញ្ចក:នោះ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ។ ពាក្យថា សាបសូន្យ គឺសាបសូន្យ លះបង់ ចោះបង់ បាត់ទៅ វិនាសទៅ ។

សមដូចភាសិតនេះថា

ភោគ:ទាំងឡាយ រមែងលះបង់នូវសត្វក្នុងកាលមុន ก็มาน សត្វលះបង់ភោគ:ទាំងនោះ មុនជាងទៅទៀត ก็มาน នៃអ្នកប្រាថ្នាកាម ពួកជនអ្នកមានភោគ: មិនទៀងទេ

តស្មា ន សោចាមហំ សោកកាលេ
ឧដេតិ អាឬតិ ឬតិ ចង្ហោ
អត្ថំ ឥមេត្វាន បលេតិ សុរិយោ
ឋិតា មយា សត្ថុក លោកធម្ម
តស្មា ន សោចាមហំ សោកកាលេតិ ។

មរណេនបិ តំ បហីយតិ ។

[១៩៣] យំ បុរិសោ មមយិតន្តិ មញ្ញតីតិ យន្តិ រូបតតំ វេទនាតតំ សញ្ញាតតំ សង្ខារតតំ វិញ្ញាណ-តតំ ។ បុរិសោតិ សង្ខា សមញ្ញា បញ្ញត្តិ លោក-ហេហាហេ ជាមំ ជាមកម្ម ជាមដេយ្យ និរុត្តិ ព្យញ្ជនំ អភិលាបោ ។ មមយិតន្តិ មញ្ញតីតិ តណ្ហាមញ្ញនាយ មញ្ញតិ ទិដ្ឋិមញ្ញនាយ មញ្ញតិ មានមញ្ញនាយ មញ្ញតិ កិលេសមញ្ញនាយ មញ្ញតិ ឧទ្ធវិតមញ្ញនាយ មញ្ញតិ បយោគមញ្ញនាយ មញ្ញតិ វិបាកមញ្ញនាយ មញ្ញតីតិ យំ បុរិសោ មមយិតន្តិ មញ្ញតិ ។

ព្រោះហេតុនោះ ទើបខ្ញុំមិនសោកស្តាយ ក្នុងកាលដែលគួរ
សោកស្តាយ ព្រះចន្ទ រះឡើងពេញវង់ លិចទៅ ព្រះ
អាទិត្យរះឡើងហើយអស្តង្គតទៅ នៃអ្នកជាសត្រូវ លោក-
ធម៌ទាំងឡាយ ខ្ញុំដឹងច្បាស់ហើយ ព្រោះហេតុនោះ ខ្ញុំ
ទើបមិនសោកស្តាយ ក្នុងកាលដែលគួរសោកស្តាយ ។

ហេតុនោះ (ទ្រង់ត្រាស់ថា) ខន្ធបញ្ចក:រមែងសាបសូន្យដោយមរណ: ។

[១៩៣] អធិប្បាយពាក្យថា បុរសសម្គាល់នូវខន្ធបញ្ចក:ណាថា នេះរបស់អញ ត្រង់ពាក្យថា ខន្ធបញ្ចក:ណា គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ។ ពាក្យថា បុរស គឺ ការពាប់ ឈ្មោះ បញ្ញត្តិ លោក-ហោការ នាម អំពើរបស់នាម ពាក្យទ្រទ្រង់ទុកនូវនាម ភាសា ព្យញ្ជន: ការហៅរក ។ ពាក្យថា សម្គាល់ថា នេះរបស់អញ គឺសម្គាល់ក្នុងការ សម្គាល់ដោយតណ្ហា សម្គាល់ក្នុងការសម្គាល់ដោយទិដ្ឋិ សម្គាល់ក្នុង ការសម្គាល់ដោយមានះ សម្គាល់ក្នុងការសម្គាល់ ដោយកិលេស សម្គាល់ក្នុងការសម្គាល់ដោយទុច្ចរិត សម្គាល់ក្នុងការសម្គាល់ដោយ បយោគ: សម្គាល់ក្នុងការសម្គាល់ដោយវិបាក ហេតុនោះ (ទ្រង់ត្រាស់ ថា) បុរសសម្គាល់ខន្ធបញ្ចក:ណាថា នេះរបស់អញ ។

ឆដ្ឋោ ជរាសុត្តនិទ្ទេសោ

[១៩៤] ឯតម្ហិ ឋិតិ្វា[1] បណ្ហិតោតិ ឯតំ អាធី-
ជវំ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិការយិត្វា
វិភូតំ កត្វា មមត្តេសូតិ ឯតម្ហិ ឋិតិ្វា ។ បណ្ហិ-
តោតិ[2] ពុទ្ធិមា ញាណី វិការី មេធាវីតិ ឯតម្ហិ ឋិ-
ឋិត្វា[3] បណ្ហិតោ ។

[១៩៥] ន មមត្តាយ ន មេថ មាមកោតិ
មមត្តាតិ ទ្វេ មមត្តា តណ្ហាមមត្តញ្ច ទិដ្ឋិម-
មត្តញ្ច ។ បេ ។ ឥទំ តណ្ហាមមត្តំ ។ បេ ។ ឥទំ
ទិដ្ឋិមមត្តំ ។ មាមកោតិ ពុទ្ធមាមកោ ធម្មមាមកោ
សង្ឆមាមកោ សោ ភគវន្តំ មមាយតិ ភគវា តំ
បុគ្គលំ បរិគ្គណ្ហាតិ ។ រុត្តំ ហេតំ ភគវតា យេ តេ
ភិក្ខវេ ភិក្ខូ ភុហា ថទ្ធា[4] លចា ឆដ្ឋ ឧទ្ធច្ចា
អសមាហិតា ន មេ តេ ភិក្ខវេ ភិក្ខូ មាមកា

---

១ ម. ឯតំ ឋិទិត្វាន ។ ២ ម. បណ្ហិតោ ធីរោ បណ្ហិតោ បញ្ញវា ។ ៣ ម. ឯតំ ឋិទិត្វាន ។
៤ ម. ពទ្ធា ។

ជរាសុត្តនិទ្ទេស ទី ៦

[១៩៦] ពាក្យថា បណ្ឌិតដឹងច្បាស់ដំណើរនុ៎ះ គឺ ដឹង ស្គាល់ ច្បាស់ ត្រិះរិះ ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដនូវទោសនុ៎ះ ក្នុងវត្ថុដែលហួងហែងទាំងឡាយ ហេតុនោះ(ទ្រង់ត្រាស់ថា) ដឹងច្បាស់ដំណើរនុ៎ះ ។ ពាក្យថា បណ្ឌិត គឺអ្នកមានប្រាជ្ញា មានញាណ មានបញ្ញាភ្ញឹកប្រាស់ មានបញ្ញាធ្ងុះធ្ងាយ ហេតុនោះ (ទ្រង់ត្រាស់ថា) បណ្ឌិតដឹងច្បាស់ដំណើរនុ៎ះ ។

[១៩៧] អធិប្បាយពាក្យថា ជាអ្នកវាប់អាន មិនគប្បីបង្ហោនទៅក្នុងសេចក្ដីហួងហែងឡើយ ត្រង់ពាក្យថា សេចក្ដីហួងហែង បានដល់សេចក្ដីហួងហែង ២ គឺ សេចក្ដីហួងហែងគឺតណ្ហា ១ សេចក្ដីហួងហែងគឺទិដ្ឋិ ១ ។ បេ ។ នេះ សេចក្ដីហួងហែងគឺតណ្ហា ។ បេ ។ នេះ សេចក្ដីហួងហែងគឺទិដ្ឋិ ។ ពាក្យថា អ្នកវាប់អាន គឺអ្នកវាប់អានព្រះពុទ្ធ អ្នកវាប់អានព្រះធម៌ អ្នកវាប់អានព្រះសង្ឆ បុគ្គលនោះ តែងវាប់អានព្រះមានព្រះភាគ ព្រះមានព្រះភាគ ក៏ទ្រង់វាប់អានបុគ្គលនោះ ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគ ត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា ជាអ្នកកុហក មានចិត្តរឹងត្អឹង ចរចាហួសហេតុ មានការជាប់ចំពាក់ ជាអ្នកធ្ងើងធ្ងែ មានចិត្តមិនតាំងមាំ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុទាំងនោះ មិនមែនវាប់អានតថាគតទេ

អបគតា ច តេ ភិក្ខូ[១] ឥមស្មា ធម្មវិនយា ន ច តេ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជន្តិ យេ ច ខោ តេ ភិក្ខវេ ភិក្ខូ និក្កុហា និល្លបា ធីរា អថទ្ធា[២] សុសមាហិតា តេ ខោ មេ ភិក្ខវេ ភិក្ខូ មាមកា អនបគតា ច តេ ភិក្ខូ ឥមស្មា ធម្មវិនយា តេ ច ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជន្តីតិ ។

កុហា ថទ្ធា លបា សិង្គី ឧន្នឡា អសមាហិតា
ន តេ ធម្មេ វិរូហន្តិ សម្មាសម្ពុទ្ធទេសិតេ
និក្កុហា និល្លបា ធីរា អថទ្ធា សុសមាហិតា
តេ វេ ធម្មេ វិរូហន្តិ សម្មាសម្ពុទ្ធទេសិតេ ។

ន មមត្តាយ ឯមេថ មាមកោតិ មាមកោ តណ្ហាមមត្តំ បហាយ ទិដ្ឋិមមត្តំ បដិនិស្សជ្ជិត្វា មមត្តាយ

១ ម. តេ ភិក្ខវេ ភិក្ខូ ។ ២ ម. អពទ្ធា ។

មួយទៀត ភិក្ខុទាំងនោះ ប្រាសចាកធម៌វិន័យនេះហើយ ភិក្ខុទាំងនោះ មិនដល់នូវការចម្រើន លូតលាស់ ធំទូលាយ ក្នុងធម៌វិន័យនេះទេ ម្នាលភិក្ខុទាំងឡាយ លុះតែពួកភិក្ខុណា មិនកុហក មិនចរចាហួសហេតុ មានប្រាជ្ញាខ្ជាប់ខ្ជួន មិនរឹងត្អឹង មានចិត្តតាំងមាំល្អ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះឯង ឈ្មោះថា អ្នកកាប់អានតថាគត មួយទៀត ភិក្ខុទាំងនោះ មិនប្រាសចាកធម៌វិន័យនេះទេ ភិក្ខុទាំងនោះ ដល់នូវសេចក្តីចម្រើន លូតលាស់ ធំទូលាយ ក្នុងធម៌វិន័យនេះ ។

ពួកភិក្ខុណា ជាអ្នកកុហក រឹងត្អឹង ចរចាហួសហេតុ មានការជាប់ចំពាក់ ធ្នើងធ្នែ មានចិត្តមិនតាំងមាំ ភិក្ខុទាំងនោះ មិនលូតលាស់ ក្នុងធម៌ ដែលព្រះសម្មាសម្ពុទ្ធសម្តែងទេ ពួកភិក្ខុណា ជាអ្នកមិនកុហក មិនចរចាហួសហេតុ មានប្រាជ្ញាខ្ជាប់ខ្ជួន មិនរឹងត្អឹង មានចិត្តតាំងមាំល្អ ភិក្ខុទាំងនោះ ទើបលូតលាស់ ក្នុងធម៌ ដែលព្រះសម្មាសម្ពុទ្ធសម្តែងហើយ ។

ពាក្យថា បណ្ឌិតជាអ្នកកាប់អាន មិនគប្បីបង្ហោនទៅ ក្នុងសេចក្តីហួងហែង បានសេចក្តីថា បុគ្គលអ្នកកាប់អាន (ព្រះរត្នត្រ័យ) គប្បីលះបង់សេចក្តីហួងហែងគឺតណ្ហា រលាស់ចោលសេចក្តីហួងហែង គឺទិដ្ឋិ

ន នមេយ្យ ន ឱនមេយ្យ ន តន្និន្នោ អស្ស ន តប្បោណោ ន តប្បព្ភារោ ន តទធិមុត្តោ ន តទាធិបតេយ្យោតិ ន មមត្តាយ នមេថ មាមកោ ។ តេនាហ ភគវា

មរណេនបិ តំ បហីយតិ
យំ បុរិសោ មមយិទន្តិ មញ្ញតិ
ឯតម្បិ វិទិត្វា បណ្ឌិតោ
ន មមត្តាយ នមេថ មាមកោតិ ។

[១៩៦] សុបិនេន យថាបិ សង្គតំ
បដិពុទ្ធោ បុរិសោ ន បស្សតិ
ឯវម្បិ បិយាយិតំ ជនំ
បេតំ កាលកតំ ន បស្សតិ ។

[១៩៧] សុបិនេន យថាបិ សង្គតន្តិ សង្គតំ សមាគ-តំ សមាហិតំ សន្និបតិតន្តិ សុបិនេន យថាបិ សង្គតំ ។

ហើយមិនបង្ហោនទៅ មិនបន្ទន់ទៅ ក្នុងសេចក្តីហួងហែង ជាអ្នកមិនឱនទៅរកសេចក្តីហួងហែងនោះ មិនងាកទៅរកសេចក្តីហួងហែងនោះ មិនឈមទៅរកសេចក្តីហួងហែងនោះ មិនចុះចិត្តស៊ប់ទៅរកសេចក្តីហួងហែងនោះ មិនយកសេចក្តីហួងហែងនោះជាធំ ហេតុនោះ (ទ្រង់ត្រាស់ថា) បណ្ឌិតជាអ្នករាប់អាន មិនគប្បីបង្ហោនទៅ ក្នុងសេចក្តីហួងហែង ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

> បុរសសម្គាល់ខន្ធបញ្ចក:ណាថា នេះរបស់អញ ខន្ធបញ្ចក:នោះ រមែងសាបសូន្យដោយមរណ: បណ្ឌិតជាអ្នករាប់អានដឹងច្បាស់ដំណើរនុ៎ះហើយ មិនគប្បីបង្ហោនទៅក្នុងសេចក្តីហួងហែងឡើយ ។

[១៩៦] បុរសភ្ញាក់ឡើងហើយ មិនឃើញអារម្មណ៍ ដែលចួបប្រទះដោយការយល់សប្តិ យ៉ាងណា បុគ្គលមិនឃើញជនជាទីស្រឡាញ់ ដែលធ្វើមរណកាល ទៅកាន់បរលោកហើយ ក៏យ៉ាងនោះដែរ ។

[១៩៧] ពាក្យថា អារម្មណ៍ដែលចួបប្រទះដោយការយល់សប្តិ យ៉ាងណា គឺចួបប្រទះ កប់ប្រសព្ធ រួមគ្នា ចួបជុំគ្នា ហេតុនោះ (ទ្រង់ត្រាស់ថា) អារម្មណ៍ដែលចួបប្រទះ ដោយការយល់សប្តិ យ៉ាងណា ។

[១៩៨] បដិពុទ្ធោ បុរិសោ ន បស្សតីតិ យថា បុរិ-
សោ សុបិនកតោ ចន្ទំ បស្សតិ សុរិយំ បស្សតិ មហា-
សមុទ្ទំ បស្សតិ សិនេរុបព្ពតរាជំ បស្សតិ ហត្ថឺ បស្សតិ
អស្សំ បស្សតិ រថំ បស្សតិ បត្តឺ បស្សតិ សេនាព្យូហំ
បស្សតិ អារាមរាមណេយ្យកំ បស្សតិ វនរាមណេយ្យ-
កំ បស្សតិ ភូមិរាមណេយ្យកំ បស្សតិ ចោក្ខ្មណី-
រាមណេយ្យកំ បស្សតិ បដិពុទ្ធោ ន កិញ្ចិ បស្ស-
តីតិ បដិពុទ្ធោ បុរិសោ ន បស្សតិ ។

[១៩៩] ឯវម្ឫ បិយាយិតំ ជនន្តិ ឯវន្តិ ឱបម្ម-
សម្ឬដិទ្ធានជា ។ បិយាយិតំ ជនន្តិ បិយាយិតំ ម-
មាយិតំ ជនំ មាតរំ វា បិតរំ វា ភាតរំ វា ភគិនឺ វា
បុត្តំ វា ធីតរំ វា មិត្តំ វា អមច្ចំ វា ញាតិសាលោហិតំ
វាតិ ឯវម្ឫ បិយាយិតំ ជនំ ។

[២០០] ឬតំ ការាលកតំ ន បស្សតីតិ ឬតា រុច្ចន្តិ
មតា ការាលកតា ។ ន បស្សតិ ន ជក្ខតិ ជានិកច្ឆតិ
ន ១ន្ធតិ ន បដិលភតីតិ ឬតំ ការាលកតំ ន បស្សតិ ។
ត្ថជាហ ភគវា

[១៩៨] ពាក្យថា បុរសភ្ញាក់ឡើងហើយ មិនឃើញ សេចក្តីថា បុរសអ្នកយល់សប្តិឃើញព្រះចន្ទ្រ ឃើញព្រះអាទិត្យ ឃើញមហាសមុទ្រ ឃើញស្តេចភ្នំសិនេរុ ឃើញដំរី ឃើញសេះ ឃើញរថ ឃើញពលថ្មើរជើង ឃើញសេនាព្យូហៈ ឃើញសួនច្បារជាទីត្រេកអរ ឃើញព្រៃជាទីត្រេកអរ ឃើញផែនដីជាទីត្រេកអរ ឃើញស្រះបោក្ខរណីជាទីត្រេកអរ ភ្ញាក់ឡើងហើយ ក៏មិនឃើញអ្វីសោះ យ៉ាងណា ហេតុនោះ (ទ្រង់ត្រាស់ថា) បុរសភ្ញាក់ឡើងហើយមិនឃើញ ។

[១៩៩] ពាក្យថា ក៏យ៉ាងនោះដែរ របស់បទថា ជនជាទីស្រឡាញ់ ក៏យ៉ាងនោះដែរ គឺជាវាចាផ្តល់ដោយសេចក្តីឧបមា ។ ពាក្យថា ជនជាទីស្រឡាញ់ គឺជនដែលស្រឡាញ់ ដែលរាប់អាន ទោះជាមាតាក្តី បិតាក្តី បងប្អូនប្រុសក្តី បងប្អូនស្រីក្តី បុត្តក្តី ធីតាក្តី មិត្រក្តី អាមាត្យក្តី ញាតិសាលោហិតក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) ជនជាទីស្រឡាញ់ ក៏យ៉ាងនោះដែរ ។

[២០០] ពាក្យថា បុគ្គលមិនឃើញជន ដែលធ្វើមរណកាលទៅកាន់បរលោកហើយ សេចក្តីថា ពួកជនស្លាប់ ធ្វើមរណកាលហើយ លោកហៅថា អ្នកទៅកាន់បរលោក ។ បុគ្គលមិនឃើញ មិនចួប មិនប្រទះ មិនបាន ឥតបាន ហេតុនោះ (ទ្រង់ត្រាស់ថា) មិនឃើញជន ដែលធ្វើមរណ-កាលទៅកាន់បរលោកហើយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ឆដ្ឋោ ជរាសុត្តនិទ្ទេសោ

សុបិនេន យថាបិ សង្គតំ
បដិពុទ្ធো បុរិសো ន បស្សតិ
ឯវម្ពិ បិយាយិតំ ជនំ
បេតំ កាលកតំ ន បស្សតីតិ ។

[២០១] ឌិដ្ឋាបិ សុតាបិ តេ ជនា
យេសំ នាមមិទំ បវុច្ចតិ
នាមមេវាវសិស្សតិ
អក្ខេយ្យំ បេតស្ស ជន្តុនោ ។

[២០២] ឌិដ្ឋាបិ សុតាបិ តេ ជនាតិ ឌិដ្ឋាតិ យេ ចក្ខុវិញ្ញាណាភិសម្ភូតា ។ សុតាតិ យេ សោតវិញ្ញា-ណាភិសម្ភូតា ។ តេ ជនាតិ ខត្តិយា ច ព្រាហ្មណា ច វេស្សា ច សុទ្ទា ច គហដ្ឋា ច បព្ជិតា ច ទេវា ច មនុស្សា ចាតិ ឌិដ្ឋាបិ សុតាបិ តេ ជនា ។

[២០៣] យេសំ នាមមិទំ បវុច្ចតីតិ យេសន្តិ យេសំ ខត្តិយានំ ព្រាហ្មណានំ វេស្សានំ សុទ្ទានំ គហដ្ឋានំ បព្ជិតានំ ទេវានំ មនុស្សានំ ។ នាមន្តិ សង្ខា សមញ្ញា បញ្ញត្តិ លោកវោហារោ នាមំ

បុរសភ្ញាក់ឡើងហើយ មិនឃើញអារម្មណ៍ដែលចូលប្រទះ ដោយការយល់សប្តិ យ៉ាងណា បុគ្គលមិនឃើញ ជនជាទីស្រឡាញ់ ដែលធ្វើមរណកាល ទៅកាន់បរលោកហើយ ក៏យ៉ាងនោះដែរ ។

[២០១] *នាមនេះ របស់ពួកជនណា ដែលគេតែងពោល ពួកជននោះ គេឃើញខ្ជះ ឮខ្ជះ នាមហ្នឹងឯងរបស់សត្វទៅកាន់បរលោក ដែលគេគួរហៅបាន រមែងសល់នៅ ។*

[២០២] *អធិប្បាយពាក្យថា ពួកជននោះ គេឃើញខ្ជះ ឮខ្ជះ ត្រង់ពាក្យថា គេឃើញ គឺពួកជនណា ដែលចូលប្រទះ ដោយចក្ខុវិញ្ញាណ ។ ពាក្យថា ឮ គឺពួកជនណា ដែលចូលប្រទះ ដោយសោតវិញ្ញាណ ។ ពាក្យថា ពួកជននោះ គឺក្សត្រិយ៍ ព្រាហ្មណ៍ វេស្ស: សុទ្ទ: គ្រហស្ថ បព្វជិត ទេវតា និង មនុស្ស ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកជននោះ គេឃើញខ្ជះ ឮខ្ជះ ។*

[២០៣] *អធិប្បាយពាក្យថា នាមនេះ របស់ពួកជនណា ដែលគេតែងពោល ត្រង់ពាក្យថា របស់ពួកជនណា គឺរបស់ពួកក្សត្រិយ៍ ព្រាហ្មណ៍ វេស្ស: សុទ្ទ: គ្រហស្ថ បព្វជិត ទេវតា មនុស្ស ណា ។ ពាក្យថា នាម គឺការរាប់ ឈ្មោះ បញ្ញត្តិ លោកវោហារ នាម*

ឆាមកម្មំ ឆាមជេយ្យំ ឆិរុត្តិ ព្យញ្ជនំ អភិលាបោ ។ បវុច្ចតីតិ កថិយតិ ភណិយតិ ទីបិយតិ វោហារិយតីតិ យេសំ ឆាមមិទំ បវុច្ចតិ ។

[២០៤] ឆាមមេវាវសិស្សតិ អក្ខេយ្យន្តិ រូបគតំ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ បហីយតិ ជហីយតិ វិជហីយតិ អន្តរធាយតិ វិប្បលុជ្ជតិ ឆាមមេវាវសិស្សតិ ។ អក្ខេយ្យន្តិ អក្ខាតុំ កថេតុំ ភណិតុំ ទីបយិតុំ វោហារិតុន្តិ ឆាមមេវាវសិស្សតិ អក្ខេយ្យំ ។ បេតស្ស ជន្តុនោតិ បេតស្សាតិ មតស្ស កាលកតស្ស ។ ជន្តុនោតិ សត្តស្ស នរស្ស មាណវស្ស បោសស្ស បុគ្គលស្ស ជីវស្ស ជាតុស្ស ជន្តុស្ស ឥន្ទគុស្ស[១] មនុជស្សាតិ អក្ខេយ្យំ បេតស្ស ជន្តុនោ ។ តេនាហ ភគវា

ទិដ្ឋាបិ សុតាបិ តេ ជនា
យេសំ ឆាមមិទំ បវុច្ចតិ
ឆាមមេវាវសិស្សតិ
អក្ខេយ្យំ បេតស្ស ជន្តុនោតិ ។

១ ម. ហិន្ទគុស្ស ។

អំពើរបស់នាម ពាក្យទ្រទ្រង់ទូវនាម ភាសា ញ្ញាណ: ការហៅរក ។ ពាក្យថា គេតែងពោល គឺ គេតែងសម្តែង តែងនិយាយ តែងបំភ្ញឹ តែងបញ្ចេញ ហេតុនោះ (ទ្រង់ត្រាស់ថា) នាមនេះ របស់ពួកជនណា ដែលគេតែងពោល ។

[២០៤] ពាក្យថា នាមហ្នឹងឯងដែលគួរហៅបាន រមែងសល់នៅ សេចក្តីថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលឃ្លាតចេញ លះចេញស្រឡះ បាត់បង់ វិនាស តែនាមរមែងសល់នៅ ។ ពាក្យថា គួរហៅបាន គឺ គួរពោល សម្តែង បំភ្ញឹ បញ្ចេញបាន ហេតុនោះ (ទ្រង់ត្រាស់ថា) នាមហ្នឹងឯង ដែលគួរហៅបាន រមែងសល់នៅ ។ ពាក្យថា ទៅកាន់បរលោក របស់បទថា របស់សត្វទៅកាន់បរលោក គឺ សត្វស្លាប់ ផ្ងើមរណកាលហើយ ។ ពាក្យថា របស់សត្វ គឺរបស់សត្វ នរ: មាណព បុរស បុគ្គល សត្វមានជីវ: សត្វមានជាតិ សត្វមានជរា សត្វទៅដោយឥន្ទ្រិយ សត្វមានជាតិអំពីមនុស្ស ហេតុនោះ(ទ្រង់ត្រាស់ថា) របស់សត្វទៅកាន់បរលោក ដែលគួរហៅបាន ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

> *នាមនេះ របស់ពួកជនណា ដែលគេតែងពោល ពួកជន នោះ គេឃើញខ្ញុះ ឮខ្ញុះ នាមហ្នឹងឯងរបស់សត្វ ទៅកាន់ បរលោក ដែលគេគួរហៅបាន រមែងសល់នៅ ។*

ឆដ្ឋោ ជរាសុត្តនិទ្ទេសោ

[២០៥] សោកបរិទេវមច្ឆរំ
ន ជហន្តិ កិញ្ចា មមាយិតេ
តស្មា មុនយោ បរិក្តហំ
ហិត្វា អចរឹសុ ខេមទស្ស៊ិនោ ។

[២០៦] សោកបរិទេវមច្ឆរំ ន ជហន្តិ កិញ្ចា មមា-
យិតេតិ សោកោតិ ញាតិព្យសនេន វា ផុដ្ឋស្ស
ភោគព្យសនេន វា ផុដ្ឋស្ស រោគព្យសនេន វា ផុដ្ឋស្ស
សីលព្យសនេន វា ផុដ្ឋស្ស ទិដ្ឋិព្យសនេន វា ផុដ្ឋស្ស
អញ្ញតរញ្ញតរេន វា ព្យសនេន សមន្ឋាគតស្ស អញ្ញត-
រញ្ញតរេន វា ទុក្ខធម្មេន ផុដ្ឋស្ស សោកោ សោ-
ចនា សោចិតត្តា អន្តោ សោកោ អន្តោ បរិសោកោ
អន្តោឌាហោ អន្តោបរិឌាហោ ចេតសោ បរិដ្ឌាយនា
ចោមនស្សំ សោកសល្លំ ។ បរិទេវោតិ ញាតិព្យ-
សនេន វា ផុដ្ឋស្ស ។ បេ ។ ទិដ្ឋិព្យសនេន វា

ជរាសុត្តនិទ្ទេស ទី ៦

[២០៥] ពួកជនអ្នកប្រាជ្ញ រមែងមិនលះបង់នូវសេចក្តីសោក សេចក្តីខ្សឹកខ្សួល និងសេចក្តីកំណាញ់ ក្នុងវត្ថុ ដែលហួងហែង ព្រោះហេតុនោះ មុនិទាំងឡាយ ជាអ្នកឃើញ សេចក្តីក្សេម បានប្រព្រឹត្តលះបង់សេចក្តីហួងហែងចេញ ។

[២០៦] *អធិប្បាយពាក្យថា ពួកជនអ្នកប្រាជ្ញ រមែងមិនលះបង់ សេចក្តីសោក សេចក្តីខ្សឹកខ្សួល និងសេចក្តីកំណាញ់ ក្នុងវត្ថុដែលហួងហែង ត្រង់ពាក្យថា សេចក្តីសោកគឺការសោក ការសោកស្តាយ ភាពនៃចិត្តសោកស្តាយ សោកខាងក្នុង ស្តាយស្រណោះខាងក្នុង ក្តៅក្រហាយខាងក្នុង ក្តៅពោលរាលខាងក្នុង ជ្រប់ ស្រពោនចិត្ត ទោមនស្ស សរគឺសោក របស់សត្ត្ব ដែលត្រូវសេចក្តីវិនាសញាតិប៉ះពាល់ក្តី សេចក្តីវិនាសភោគ:ប៉ះពាល់ក្តី សេចក្តីវិនាសគឺរោគប៉ះពាល់ក្តី សេចក្តីវិនាសសីលប៉ះពាល់ក្តី សេចក្តីវិនាសទិដ្ឋិប៉ះពាល់ក្តី ប្រកបដោយសេចក្តីវិនាសណាមួយក្តី ទុក្ខធម៌ណាមួយប៉ះពាល់ក្តី ។ ពាក្យថា សេចក្តីខ្សឹកខ្សួល គឺការយំ ការយំរៀបរាប់ អាការយំ អាការយំរៀបរាប់ ភាពនៃការយំ ភាពនៃការយំរៀបរាប់ ការនិយាយ ការពោលឥតប្រយោជន៍ ការពោលរវើរវាយ ការពោលរឿយៗ អាការជាទីពោលរឿយៗ ភាពនៃការពោលរឿយៗ របស់សត្ត្ব ដែលត្រូវសេចក្តីវិនាសញាតិប៉ះពាល់ក្តី ។ បេ ។*

ផុដ្ឋស្ស អញ្ញតរញ្ញតរេន វា ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន វា ទុក្ខធម្មេន វា ផុដ្ឋស្ស អាទេវោ បរិទេវោ អាទេវនា បរិទេវនា អាទេវិតត្តំ បរិទេវិតត្តំ វាចា បលាបោ វិប្បលាបោ លាលប្បោ លាលប្បាយនា លាលប្បាយិតត្តំ ។ មច្ឆរិយន្តិ បញ្ច មច្ឆរិយានិ អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ ធម្មមច្ឆរិយំ យំ ឯវរូបំ មច្ឆរិយំ មច្ឆរាយនា មច្ឆរាយិតត្តំ វេវិច្ឆំ កទរិយំ កដុកញ្ចុកតា អគ្គហិតត្តំ ចិត្តស្ស ឥទំ វុច្ចតិ មច្ឆរិយំ ។ អបិច ខន្ធមច្ឆរិយំបិ មច្ឆរិយំ ធាតុមច្ឆរិយំបិ មច្ឆរិយំ អាយតនមច្ឆរិយំបិ មច្ឆរិយំ គាហោ ឥទំ វុច្ចតិ មច្ឆរិយំ ។ គេធោ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ មមត្តាតិ ទ្វេ មមត្តា តណ្ហាមមត្តញ្ច ទិដ្ឋិមមត្តញ្ច ។ បេ ។ ឥទំ តណ្ហាមមត្តំ ។ បេ ។ ឥទំ ទិដ្ឋិមមត្តំ ។ មមាយិតវត្ថុអច្ឆេទសង្កិនោបិ សោចន្តិ អច្ឆិជ្ជន្តេបិ សោចន្តិ អច្ឆិន្នេបិ សោចន្តិ មមាយិតវត្ថុវិបរិណាមសង្កិនោបិ

សេចក្តីវិនាសទិដ្ឋិប៉ះពាល់ក្តី ប្រកបដោយសេចក្តីវិនាសណាមួយក្តី ទុក្ខ-ធម៌ណាមួយប៉ះពាល់ក្តី ។ ពាក្យថា សេចក្តីកំណាញ់ បានដល់សេចក្តីកំណាញ់ ៥ យ៉ាង គឺសេចក្តីកំណាញ់អាវាស ១ សេចក្តីកំណាញ់ត្រកូល ១ សេចក្តីកំណាញ់លាភ ១ សេចក្តីកំណាញ់វណ្ណៈ ១ សេចក្តីកំណាញ់ធម៌ ១ សេចក្តីកំណាញ់ អាការកំណាញ់ ភាពនៃការកំណាញ់ សេចក្តីប្រាថ្នាផ្សេងៗ ស្នូកន្ទ្រឹស ភាពនៃចិត្តរួញ ភាពនៃការមិនយកចិត្តគេ ណាមានសភាពយ៉ាងនេះ នេះ ហៅថា សេចក្តីកំណាញ់ ។ មួយទៀត សេចក្តីកំណាញ់ខន្ធ ក៏ឈ្មោះថាសេចក្តីកំណាញ់ សេចក្តីកំណាញ់ធាតុ ក៏ឈ្មោះថា សេចក្តីកំណាញ់ សេចក្តីកំណាញ់អាយតនៈ ក៏ឈ្មោះថាសេចក្តីកំណាញ់ ការគិតតែកាន់យក នេះលោកហៅថា សេចក្តីកំណាញ់ ។ តណ្ហា លោកហៅថា ការចង់បាន បានដល់តម្រេក តម្រេកខ្លាំង ។ បេ ។ ការសម្ងឹងរំពៃ លោកៈ អកុសលមូល ។ ពាក្យថា ការហួងហែង បានដល់ការហួងហែង ២ គឺ ការហួងហែងគឺតណ្ហា ១ ការហួងហែងគឺទិដ្ឋិ ១ ។ បេ ។ នេះការហួងហែងគឺតណ្ហា ។ បេ ។ នេះ ការហួងហែងគឺទិដ្ឋិ ។ ពួកជនមានសេចក្តីរង្គៀស ដោយការដណ្តើមយកវត្ថុដែលហួងហែង សោកស្តាយក៏មាន សោកស្តាយវត្ថុដែលគេកំពុងដណ្តើមយក ក៏មាន សោកស្តាយវត្ថុដែលគេដណ្តើមយកហើយ ក៏មាន ពួកជន មានសេចក្តីរង្គៀសដោយការប្រែប្រួល នៃវត្ថុដែលហួងហែង

សោចន្តិ វិបរិណាមន្តេបិ សោចន្តិ វិបរិណាតេបិ សោចន្តិ ។ មមាយិតវត្ថុអច្ឆេទសង្ខ្លោនេបិ បរិទេវន្តិ អច្ឆិជ្ជន្តេបិ បរិទេវន្តិ អច្ឆិន្នេបិ បរិទេវន្តិ ។ មមាយិ-តវត្ថុវិបរិណាមសង្ខ្លោនេបិ បរិទេវន្តិ វិបរិណាមន្តេបិ បរិទេវន្តិ វិបរិណាតេបិ បរិទេវន្តិ ។ មមាយិតវត្ថុំ រក្ខន្តិ គោបេន្តិ បរិក្ខណ្ហន្តិ មមាយិតន្តិ មច្ចរាយន្តិ ។ មមាយិតស្មឹ វត្ថុស្មឹ សោចន្តិ សោកំ ន ជហន្តិ បរិទេវំ ន ជហន្តិ មច្ឆរិយំ ន ជហន្តិ តេជំ ន ជហន្តិ ឧប្ផជហន្តិ ន វិនោទេន្តិ ន ញ្ញត្តីកភោន្តិ ន អនភាវង្គមេន្តីតិ សោកបរិទេវមច្ឆរំ ន ជហន្តិ ឥមិ មមាយិតេ ។

[២០៧] តស្មា មុនយោ បរិក្ខហ៎ ហិត្វា អចរីសុ ខេមទស្សិនោតិ តស្មាតិ តស្មា តំការណា តំហេតុ តប្ផច្ចយា តំនិទានា ឯតំ

រមែងសោកស្តាយ ក៏មាន សោកស្តាយវត្ថុដែលកំពុងប្រែប្រួល ក៏មាន សោកស្តាយវត្ថុដែលប្រែប្រួលហើយ ក៏មាន ។ អ្នកមានសេចក្តីរង្គៀសដោយការដណ្តើមយកវត្ថុដែលហួងហែង ខ្សឹកខ្សួល ក៏មាន ខ្សឹកខ្សួលនឹងវត្ថុដែលគេកំពុងដណ្តើមយកក៏មាន ខ្សឹកខ្សួលនឹងវត្ថុដែលគេដណ្តើមយកហើយក៏មាន អ្នកមានសេចក្តីរង្គៀសដោយការប្រែប្រួល នៃវត្ថុដែលហួងហែង ខ្សឹកខ្សួលក៏មាន ខ្សឹកខ្សួលនឹងវត្ថុដែលកំពុងប្រែប្រួលក៏មាន ខ្សឹកខ្សួលនឹងវត្ថុ ដែលប្រែប្រួលហើយក៏មាន ។ ពួកជនរមែងរក្សា គ្រប់គ្រងកួចកាន់ ហួងហែង កំណាញ់វត្ថុដែលហួងហែង ។ ពួកជនរមែងសោកស្តាយ វត្ថុដែលហួងហែង មិនលះបង់សេចក្តីសោក មិនលះបង់សេចក្តីខ្សឹកខ្សួល មិនលះបង់សេចក្តីកំណាញ់ មិនលះបង់ មិនលះចោល មិនបន្ទោបង់ មិនធ្វើឲ្យវិនាស មិនធ្វើឲ្យដល់នូវការមិនកើតមានសេចក្តីប្រាថ្នា ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកជនអ្នកប្រាថ្នា រមែងមិនលះបង់នូវសេចក្តីសោក សេចក្តីខ្សឹកខ្សួល និងសេចក្តីកំណាញ់ ក្នុងវត្ថុដែលហួងហែង ។

[២០៧] អធិប្បាយពាក្យថា ព្រោះហេតុនោះ មុនិទាំងឡាយជាអ្នកឃើញសេចក្តីក្សេម បានប្រព្រឹត្ត លះបង់សេចក្តីហួងហែងចេញ ត្រង់ពាក្យថា ព្រោះហេតុនោះ គឺព្រោះដូច្នោះ ព្រោះដំណើរនោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ

អាជីវំ សម្បស្សមានោ មមត្តេសូតិ តស្មា ។ មុនយោតិ មោនំ វុច្ចតិ ញាណំ យា បញ្ញា បជានា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ តេន ញាណេន សមន្នាគតា មុនយោ មោនប្បត្តា ។ តីណិ មោនេយ្យានិ កាយមោនេយ្យំ វចីមោនេយ្យំ មនោមោនេយ្យំ ។ បេ ។ សង្គជាលមតិច្ច សោ មុនិ ។ បរិគ្គហោតិ ទ្វេ បរិគ្គហា តណ្ហាបរិគ្គហោ ច ទិដ្ឋិបរិគ្គហោ ច ។ បេ ។ អយំ តណ្ហាបរិគ្គហោ ។ បេ ។ អយំ ទិដ្ឋិបរិគ្គហោ ។ មុនយោ តណ្ហាបរិគ្គហំ បហាយ ទិដ្ឋិបរិគ្គហំ បដិនិស្សជ្ជិត្វា អចរីសុ វិចរីសុ[១] ឥរិយឹសុ វត្តឹសុ ចាលឹសុ យបឹសុ យាបឹសុ ។ ខេមទស្សិនោតិ ខេមំ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វុបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។ ខេមទស្សិនោតិ ខេមទស្សិនោ តាណទស្សិនោ

១ ម. វិហរីសុ ។

មុនិកាលឃើញច្បាស់ នូវទោសនុ៎ះ ក្នុងវត្ថុដែលហួងហែងទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុនោះ ។ ពាក្យថា មុនិទាំងឡាយ សេចក្តីថា ញាណ ហៅថា មោនៈ បានខាងប្រាជ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ សេចក្តីយល់ឃើញត្រូវ មុនិទាំងឡាយ ប្រកបដោយញាណនោះ ដល់ហើយនូវការដឹង ។ មោនេយ្យៈ មាន ៣ គឺកាយមោនេយ្យៈ វចីមោនេយ្យៈ មនោមោនេយ្យៈ ។ បេ ។ បុគ្គលណាកន្ទងបង់បណ្តាញគឺគ្រឿងជាប់ចំពាក់ បុគ្គលនោះ ហៅថាមុនិ ។ ពាក្យថា សេចក្តីហួងហែង បានដល់សេចក្តីហួងហែង ២ គឺសេចក្តីហួងហែងគឺតណ្ហា ១ សេចក្តីហួងហែងគឺទិដ្ឋិ ១ ។ បេ ។ នេះ សេចក្តីហួងហែងគឺតណ្ហា ។ បេ ។ នេះ សេចក្តីហួងហែងគឺទិដ្ឋិ ។ មុនិទាំងឡាយ លះបង់សេចក្តីហួងហែងគឺតណ្ហា រលាស់ចោលសេចក្តីហួងហែងគឺទិដ្ឋិ បានរង្គាត់ទៅ ត្រាច់ទៅ ដើរទៅ សម្រេច ប្រព្រឹត្ត រក្សាចិញ្ចឹម ទំនុកបម្រុង ។ ពាក្យថា អ្នកឃើញសេចក្តីក្សេម សេចក្តីថា អមតនិព្វាន លោកហៅថា សេចក្តីក្សេម បានខាងការរម្ងាប់សង្ខារទាំង-ពួង ការរលាស់ចេញនូវឧបធិទាំងពួង ការអស់ទៅនៃតណ្ហា សេចក្តីនឿយណាយ សេចក្តីរលត់ ព្រះនិព្វាន ។ ពាក្យថា អ្នកឃើញសេចក្តីក្សេម បានសេចក្តីថា អ្នកឃើញសេចក្តីក្សេម អ្នកឃើញទីជ្រកកោន

លេណានុប្បត្តោ សរណានុប្បត្តោ អភយានុប្បត្តោ អច្ចុតានុប្បត្តោ អមតានុប្បត្តោ និព្វានានុប្បត្តោតិ តស្មា មុនយោ បរិគ្គហំ ហិត្វា អចរឹសុ ខេមទស្សិ-នោ ។ តេនាហ ភគវា

សោកបរិទេវមច្ឆរំ

ន ជហន្តិ គិទ្ធា មមាយិតេ

តស្មា មុនយោ បរិគ្គហំ

ហិត្វា អចរឹសុ ខេមទស្សិនោតិ ។

[២០៨] បដិលីនចរស្ស ភិក្ខុនោ

ភជមានស្ស វិវិត្តមាសនំ

សាមគ្គិយមាហុ តស្ស តំ

យោ អត្តានំ ភវនេ ន ទស្សយេ ។

[២០៩] បដិលីនចរស្ស ភិក្ខុនោតិ បដិលីនចរា វុច្ចន្តិ សត្ត សេក្ខា អរហា បដិលីនោ ។ កិំការណា បដិលីនចរា វុច្ចន្តិ សត្ត សេក្ខា ។ តេ តតោ តតោ ចិត្តំ បដិលីនេន្តា បដិកុដ្ដេន្តា[១] បដិវដ្ដេន្តា សន្និរុទ្ធន្តា

១ ម. បដិកុដ្ដេន្តា ។

ជរាសុត្តនិទ្ទេស ទី ៦

អ្នកឃើញទីពឹងពួន អ្នកឃើញទីពឹង អ្នកឃើញទីមិនមានភ័យ អ្នកឃើញទីមិនច្យុត អ្នកឃើញអមត: អ្នកឃើញព្រះនិព្វាន ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុនោះ មុនិទាំងឡាយ ជាអ្នកឃើញសេចក្តីក្សេម បានប្រព្រឹត្តលះបង់សេចក្តីហួងហែង ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ពួកជនអ្នកប្រាជ្ញ រមែងមិនលះបង់នូវសេចក្តីសោក សេចក្តីខ្សឹកខ្សួល និងសេចក្តីកំណាញ់ ក្នុងវត្ថុដែលហួងហែង ព្រោះហេតុនោះ មុនិទាំងឡាយ ជាអ្នកឃើញសេចក្តីក្សេម បានប្រព្រឹត្តលះបង់សេចក្តីហួងហែងចេញ ។

[២០៨] *អ្នកប្រាជ្ញទាំងឡាយ ពោលអំពើនោះថាជាសាមគ្គី របស់ភិក្ខុអ្នកប្រព្រឹត្តរួញថយ គប់រកអាសនៈស្ងាត់ ដែលមិនបង្ហាញខ្លួនក្នុងទីកើត ។*

[២០៩] *ពាក្យថា របស់ភិក្ខុអ្នកប្រព្រឹត្តរួញថយ អធិប្បាយថា សេក្ខបុគ្គល ៧ លោកហៅថាអ្នកប្រព្រឹត្តរួញថយ ឯព្រះអរហន្ត ជាអ្នកប្រព្រឹត្តរួញថយហើយ ។ សេក្ខបុគ្គល ៧ ពួក លោកហៅថា អ្នកប្រព្រឹត្តរួញថយ ព្រោះហេតុអ្វី ។ សេក្ខបុគ្គល ៧ ពួកនោះ ញ៉ាំងចិត្តឲ្យរួញថយ ឲ្យខ្ជិ ឲ្យវិលវិញ អំពីអារម្មណ៍នោះ ។ ខ្ជប់ សង្កត់សង្កិន*

សន្ធិក្ខណ្ហាត្តា សន្ធិវារត្តា រក្ខិត្តា គោបេត្តា ចរន្តិ[1] វិហរន្តិ ឥរិយន្តិ វត្តេន្តិ ចាលេន្តិ យបេន្តិ យាបេន្តិ ។ ចក្ខុទ្វារេ ចិត្តំ បដិលីនេត្តា បដិកុដ្ដេត្តា បដិវត្តេត្តា សន្ធិរុទ្ធត្តា សន្ធិក្ខណ្ហាត្តា សន្ធិវារត្តា រក្ខិត្តា គោបេត្តា ចរន្តិ វិហរន្តិ ឥរិយន្តិ វត្តេន្តិ ចាលេន្តិ យបេន្តិ យាបេន្តិ ។ សោតទ្វារេ ចិត្តំ ឃានទ្វារេ ចិត្តំ ជិវ្ហាទ្វារេ ចិត្តំ កាយទ្វារេ ចិត្តំ មនោទ្វារេ ចិត្តំ បដិលីនេត្តា បដិកុដ្ដេត្តា បដិវត្តេត្តា សន្ធិរុទ្ធត្តា សន្ធិក្ខណ្ហាត្តា សន្ធិវារត្តា រក្ខិត្តា គោបេត្តា ចរន្តិ វិហរន្តិ ឥរិយន្តិ វត្តេន្តិ ចាលេន្តិ យបេន្តិ យាបេន្តិ ។ យថា កុក្កុដបត្តំ វា ឧហារុឧទ្ធលំ វា អក្ខិម្ហិ បក្ខិត្តំ ហោតិ បដិលីយតិ បដិកុដ្ដតិ បដិវត្តតិ ន សម្ផសារិយតិ ឯវមេវ តេ តតោ តតោ ចិត្តំ បដិលីនេត្តា បដិកុដ្ដេត្តា បដិវត្តេត្តា សន្ធិរុទ្ធត្តា សន្ធិក្ខណ្ហាត្តា សន្ធិវារត្តា រក្ខិត្តា គោបេត្តា ចរន្តិ វិហរន្តិ ឥរិយន្តិ វត្តេន្តិ ចាលេន្តិ យបេន្តិ យាបេន្តិ ចក្ខុទ្វារេ ចិត្តំ សោតទ្វារេ ចិត្តំ ឃានទ្វារេ ចិត្តំ ជិវ្ហាទ្វារេ ចិត្តំ កាយទ្វារេ ចិត្តំ

---

1 ម. ចរន្តិ វិចរន្តិ ។

ភាវនា រក្សា គ្រប់គ្រង ត្រាច់ទៅ សម្រេចឥរិយាបថ សម្រាន្តចិត្ត ប្រព្រឹត្តទៅ រក្សា ចិញ្ចឹម ទំនុកបម្រុង ។ សេក្ខបុគ្គលទាំងនោះ ញ៉ាំងចិត្តក្នុងចក្ខុទ្វារឲ្យរួញថយ ឲ្យខ្ជូរ ឲ្យវិលវិញ ខ្ជប់ សង្កត់សង្កិន ភាវនា រក្សា គ្រប់គ្រង ត្រាច់ទៅ សម្រេចឥរិយាបថ សម្រាន្តចិត្ត ប្រព្រឹត្តទៅ រក្សា ចិញ្ចឹម ទំនុកបម្រុង ។ ញ៉ាំងចិត្តក្នុងសោតទ្វារ ញ៉ាំងចិត្តក្នុងឃានទ្វារ ញ៉ាំងចិត្តក្នុងជិវ្ហាទ្វារ ញ៉ាំងចិត្តក្នុងកាយទ្វារ ញ៉ាំងចិត្តក្នុងមនោទ្វារ ឲ្យរួញថយ ឲ្យខ្ជូរ ឲ្យវិលវិញ ខ្ជប់ សង្កត់សង្កិន ភាវនា រក្សា គ្រប់គ្រង ត្រាច់ទៅ សម្រេចឥរិយាបថ សម្រាន្ត ចិត្ត ប្រព្រឹត្តទៅ រក្សា ចិញ្ចឹម ទំនុកបម្រុង ។ ស្ងាបមាន់ ឬទង សរសៃ ដែលគេជាក់ក្នុងភ្លើង រមែងរួញ ខ្ជូរ វិលវិញ មិនលា យ៉ាងណាមិញ សេក្ខបុគ្គលទាំងនោះ ញ៉ាំងចិត្តឲ្យរួញថយ ឲ្យខ្ជូរ ឲ្យវិលវិញ អំពីអារម្មណ៍នោះ ។ ខ្ជប់ សង្កត់សង្កិន ភាវនា រក្សា គ្រប់គ្រង ត្រាច់ទៅ សម្រេចឥរិយាបថ សម្រាន្តចិត្ត ប្រព្រឹត្តទៅ រក្សា ចិញ្ចឹម ទំនុកបម្រុង ក៏យ៉ាងនោះដែរ ញ៉ាំងចិត្តក្នុងចក្ខុទ្វារ ញ៉ាំងចិត្តក្នុងសោត-ទ្វារ ញ៉ាំងចិត្តក្នុងឃានទ្វារ ញ៉ាំងចិត្តក្នុងជិវ្ហាទ្វារ ញ៉ាំងចិត្តក្នុងកាយទ្វារ

មនោទ្វារេ ចិត្តំ បដិលីនេន្តា បដិកុដ្ដេន្តា បដិវដ្ដេន្តា សន្និរុទ្ធន្តា សន្និគ្គណ្ហន្តា សន្និវារេន្តា រក្ខន្តា គោបេន្តា ចរន្តិ វិហរន្តិ ឥរិយន្តិ វត្តេន្តិ បាលេន្តិ យបេន្តិ យាបេន្តិ ។ តំការណា បដិលីនចរា វុច្ចន្តិ សត្ត សេក្ខា ។ ភិក្ខុនោតិ កល្យាណបុថុជ្ជនស្ស វា ភិក្ខុនោ សេក្ខស្ស វា ភិក្ខុនោតិ បដិលីនចរស្ស ភិក្ខុនោ ។

[២១០] ភជមានស្ស វិវិត្តមាសនន្តិ អាសនំ វុច្ចតិ យត្ថ និសីទតិ មញ្ចោ បីឋំ ភិសិ តដ្ដិកា ចម្មខណ្ឌោ តិណសន្ថារោ បណ្ណសន្ថារោ បលាសសន្ថារោ[១] ។ តំ អាសនំ អសប្បាយរូបទស្សនេន វិត្តំ[២] វិវិត្តំ បវិវិត្តំ អសប្បាយសទ្ទស្សវនេន វិត្តំ[៣] វិវិត្តំ បវិវិត្តំ អសប្បាយគន្ធឃាយនេន អសប្បាយរសសាយនេន អសប្បាយផោដ្ឋព្វផុសនេន អសប្បាយេហិ បញ្ចហិ កាមគុណេហិ វិត្តំ វិវិត្តំ បវិវិត្តំ ។ តំ អាសនំ ភជតោ សម្ភជតោ សេវតោ និសេវតោ សំសេវតោ បដិសេវតោតិ ភជមានស្ស វិវិត្តមាសនំ ។

---

១ ឱ. ម. បលាលសន្ថារោ ។ ២. ៣. ម. រិត្តំ ។

ញ៉ាំងចិត្តក្នុងមនោទ្វារ ឲ្យរួញថយ ឲ្យខ្ជិ ឲ្យវិលវិញ ខ្ជប់ សង្កត់ សង្កិន ការាំង រក្សា គ្រប់គ្រង ត្រាច់ទៅ សម្រេចឥរិយាបថ សម្រាន្តចិត្ត ប្រព្រឹត្ត រក្សា ចិញ្ចឹម ទំនុកបម្រុង ។ ព្រោះហេតុនោះ សេក្ខបុគ្គល ៧ ពួក លោកហៅថា អ្នកប្រព្រឹត្តរួញថយ ។ ពាក្យថា របស់ភិក្ខុ គឺរបស់ភិក្ខុជាកល្យាណបុថុជ្ជនក្តី ភិក្ខុជាសេក្ខៈក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) របស់ភិក្ខុអ្នកប្រព្រឹត្តរួញថយ ។

[២១០] ពាក្យថា គប់រកអាសនៈស្ងាត់ សេចក្តីថា ភិក្ខុអង្គុយក្នុងទីណា ទីនោះលោកហៅថាអាសនៈ គឺព្រៃ តាំង ពួក កន្ទេល ចម្ម១ណ្ណ កម្រាលស្មៅ កម្រាលស្លឹកឈើ កម្រាលចំបើង ។ អាសនៈនោះ ជាទីស្ងាត់ ស្ងាត់ច្រៀប ស្ងាត់ឈឹង ចាកការឃើញរូបមិនជាទីសប្បាយ ស្ងាត់ ស្ងាត់ច្រៀប ស្ងាត់ឈឹង ចាកការឮសំឡេងមិនជាទីសប្បាយ ស្ងាត់ ស្ងាត់ច្រៀប ស្ងាត់ឈឹង ចាកការធុំក្លិនមិនជាទីសប្បាយ ចាកការលិទ្ធភ្ជក្សរសមិនជាទីសប្បាយ ចាកការពាល់ត្រូវផ្សព្វមិនជាទីសប្បាយ ចាកកាមគុណទាំង ៥ មិនជាទីសប្បាយ ។ កាលគប់រក គប់ប្រសព្ធ សេពគប់ អាស្រ័យ ចូលចិត្ត ផ្ចេកផ្ចិត ចំពោះអាសនៈនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) គប់រកអាសនៈស្ងាត់ ។

[២១១] សាមក្ខិយមាហុ តស្ស តំ យោ អត្តានំ ភវនេ ន ឧស្សយេតិ សាមក្ខិយាតិ តិស្សោ សាមក្ខិ-យោ ឥណសាមក្ខី ធម្មសាមក្ខី អនភិនិព្ពត្តិសាមក្ខី ។

ឥតមា ឥណសាមក្ខី ។ ពហូ ចេបិ ភិក្ខូ ស-មត្តា សម្ភោគមានា អវិរុទ្ធមានា ទីឃរត្តមកតា អញ្ញ-មញ្ញំ បិយចក្ខូហិ សម្ផស្សន្តា វិហរន្តិ អយំ ឥណ-សាមក្ខី ។

ឥតមា ធម្មសាមក្ខី ។ ចត្តារោ សតិប្ផ្ឋានា ចត្តារោ សម្មប្ផ្ឋានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ តេ ឯកតោ បក្ខន្ទន្តិ បសីទន្តិ សម្ផតិដ្ឋន្តិ វិមុច្ចន្តិ ន តេសំ ធម្មានំ វិវោ វិប្ផ្ផារោ អត្ថិ អយំ ធម្មសាមក្ខី ។

ឥតមា អនភិនិព្ពត្តិសាមក្ខី ។ ពហូ ចេបិ ភិក្ខូ អនុបាទិសេសាយ និព្ពានធាតុយា បរិនិព្ពាយន្តិ ន តេសំ និព្ពានធាតុយា ឱនត្តំ[1] វា បុណ្ណត្តំ វា បញ្ញា-យតិ អយំ អនភិនិព្ពត្តិសាមក្ខី ។

---

១ ឱ. ម. ឧនត្តំ ។

[២១១] អធិប្បាយពាក្យថា អ្នកប្រាជ្ញទាំងឡាយ ពោលអំពីនោះ ថាជាសាមគ្គីរបស់ភិក្ខុ ដែលមិនបង្ហាញខ្លួនក្នុងទីកើត ត្រង់ពាក្យថា សាមគ្គី បានដល់សាមគ្គី ៣ យ៉ាង គឺ គណសាមគ្គី ធម្មសាមគ្គី អនភិនិព្ពត្តិសាមគ្គី ។

គណសាមគ្គី តើដូចម្តេច ។ បើភិក្ខុទាំងឡាយ ច្រើនរូប ព្រមព្រៀងគ្នា មានសេចក្តីស្មោះសរនឹងគ្នា មិនទាស់ទែងគ្នា មានសភាពហាក់ដូចទឹក ដែលលាយដោយទឹកដោះស្រស់ សម្លឹងមើលគ្នានិងគ្នាដោយចក្ខុជាទីស្រឡាញ់ នេះ ឈ្មោះថា គណសាមគ្គី ។

ធម្មសាមគ្គី តើដូចម្តេច ។ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធម៌ទាំងនោះ រមែងលឿនទៅ ថ្វាស្អាត តាំងនៅល្អ រួចស្រឡះក្នុងទីជាមួយគ្នា ការជជែក ការទាស់ទែងនៃធម៌ទាំងនោះ រមែងមិនមាន នេះឈ្មោះថា ធម្មសាមគ្គី ។

អនភិនិព្ពត្តិសាមគ្គី តើដូចម្តេច ។ បើភិក្ខុទាំងឡាយ ច្រើនរូប បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ការខ្ជះខាត ឬការពេញក្នុងនិព្វានធាតុ នៃភិក្ខុទាំងនោះក៏មិនប្រាកដ នេះ ឈ្មោះថា អនភិនិព្ពត្តិសាមគ្គី ។

ភវនេតិ នេរយិកានំ និរយោ ភវនំ តិរច្ឆានយោ-និកានំ តិរច្ឆានយោនិ ភវនំ បិត្តិវិសយិកានំ បិត្តិវិ-សយោ ភវនំ មនុស្សានំ មនុស្សលោកោ ភវនំ ទេវានំ ទេវលោកោ ភវនំ ។ សាមក្ខិយមាហុ តស្ស តំ យោ អត្តានំ ភវនេ ន ឧស្សយេតិ តស្សេសា សាមក្ខី ឯតំ ឆន្នំ ឯតំ បដិរូបំ ឯតំ អនុច្ឆវិកំ ឯតំ អនុលោមំ យោ ឯវំ បដិបន្នោ[1] និរយេ អត្តានំ ន ឧស្សេយ្យ តិរច្ឆានយោនិយា អត្តានំ ន ឧស្សេយ្យ បិត្តិវិសយេ អត្តានំ ន ឧស្សេយ្យ មនុស្សលោកេ អត្តានំ ន ឧស្សេយ្យ ទេវលោកេ អត្តានំ ន ឧស្សេយ្យា-តិ ឯវមាហុ ឯវមាហំសុ ឯវំ ភណន្តិ ឯវំ ទីបយន្តិ ឯវំ ហេមវន្តីតិ សាមក្ខិយមាហុ តស្ស តំ យោ អត្តានំ ភវនេ ន ឧស្សយេ ។ តេនាហ ភគវា

បដិលីនចរស្ស ភិក្ខុនោ
ភជមានស្ស វិវិត្តមាសនំ
សាមក្ខិយមាហុ តស្ស តំ
យោ អត្តានំ ភវនេ ន ឧស្សយេតិ ។

---

១ ម. បដិច្ចន្ទ ។

ជរាសុត្តនិទ្ទេស ទី ៦

ពាក្យថា ក្នុងទីកើត គឺនរកជាទីកើតរបស់ពួកសត្វនរក កំណើតតិរច្ឆានជាទីកើតរបស់ពួកសត្វ ក្នុងកំណើតតិរច្ឆាន បិត្តិវិស័យជាទីកើតរបស់ពួកសត្វក្នុងបិត្តិវិស័យ មនុស្សលោកជាទីកើតរបស់ពួកមនុស្ស ទេវ-លោកជាទីកើតរបស់ពួកទេវតា ។ ពាក្យថា អ្នកប្រាជ្ញទាំងឡាយពោលអំពើនោះថាជាសាមគ្គីរបស់ភិក្ខុដែលមិនបង្ហាញខ្លួនក្នុងទីកើត បានសេចក្តីថា ភិក្ខុណាប្រតិបត្តិយ៉ាងនេះ ឈ្មោះថា មិនគប្បីបង្ហាញខ្លួនក្នុងនរក មិនបង្ហាញខ្លួនក្នុងកំណើតតិរច្ឆាន មិនបង្ហាញខ្លួនក្នុងបិត្តិវិស័យ មិនបង្ហាញខ្លួនក្នុងមនុស្សលោក មិនបង្ហាញខ្លួនក្នុងទេវលោក អំពើនុ៎ះឈ្មោះថាសេចក្តីព្រមព្រៀង នុ៎ះឈ្មោះថាជាទីបិទបាំង នុ៎ះឈ្មោះថាជាទីសមរម្យ នុ៎ះឈ្មោះថាជាទីសមគួរ នុ៎ះឈ្មោះថាជាទីសមសួន របស់ភិក្ខុនោះ អ្នកប្រាជ្ញទាំងឡាយ ពោលហើយយ៉ាងនេះ បានពោលហើយយ៉ាងនេះ រមែងសម្តែងយ៉ាងនេះ និយាយយ៉ាងនេះ បំភ្ញីយ៉ាងនេះ បញ្ជេញយ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកប្រាជ្ញទាំងឡាយ ពោលអំពើនោះ ថាជាសាមគ្គីរបស់ភិក្ខុដែលមិនបង្ហាញខ្លួនក្នុងទីកើត ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

> អ្នកប្រាជ្ញទាំងឡាយ ពោលអំពើនោះ ថាជាសាមគ្គី របស់ភិក្ខុ អ្នកប្រព្រឹត្តរួញថយ គប់រកអាសនៈស្ងាត់ ដែលមិនបង្ហាញខ្លួន ក្នុងទីកើត ។

[២១២] សព្វត្ត មុនិ អនិស្សិតោ
ន បិយំ កុព្វតិ នោបិ អប្បិយំ
តស្មឺ បរិនេវមច្ចរំ
បណ្ណេ ភរិ យថា ន លិម្ពតិ ។

[២១៣] សព្វត្ត មុនិ អនិស្សិតោតិ សព្វំ រុច្ចតិ ទ្វាទសាយតនានិ ចក្ខុ ចេវ រូបា ច សោតញ្ច សទ្ទា ច ឃានញ្ច គន្ធា ច ជិវ្ហា ច រសា ច កាយោ ច ផោដ្ឋព្ពា ច មនោ ច ធម្មា ច ។ មុនីតិ មោនំ រុច្ចតិ ញាណំ យា បញ្ញា បជានណា ។ បេ ។ សង្ខ្យាលមតិ ច សោ មុនិ ។ អនិស្សិតោតិ ទ្វេ និស្សយា តណ្ហានិស្សយោ ច ទិដ្ឋិនិស្សយោ ច ។ បេ ។ អយំ តណ្ហានិស្សយោ ។ បេ ។ អយំ ទិដ្ឋិនិស្សយោ ។ មុនិ តណ្ហានិស្សយំ បហាយ ទិដ្ឋិនិស្សយំ បដិនិស្សជ្ជិត្វា ចក្ខុំ អនិស្សិតោ សោតំ អនិស្សិតោ ឃានំ អនិស្សិតោ ជិវ្ហំ អនិស្សិតោ កាយំ អនិស្សិតោ មនំ អនិស្សិតោ រូបេ សទ្ទេ គន្ធេ រសេ ផោដ្ឋព្ពេ ធម្មេ ការ-ណំ ឋានំ អាវាសំ លាភំ យសំ បសំសំ សុខំ

[២១២] *មុនិមិនអាស្រ័យនៅ ក្នុងវត្ថុទាំងពួង មិនធ្វើសេចក្ដីស្រឡាញ់ ទាំងមិនធ្វើសេចក្ដីស្អប់ (ចំពោះសត្វនិងសង្ខារ) សេចក្ដីខ្សឹកខ្សួល និងសេចក្ដីកំណាញ់ មិនជាប់នៅក្នុងមុនិនោះ ដូចជាវារិ មិនជាប់នៅលើស្លឹក (ឈូក) ។*

[២១៣] *ពាក្យថា មុនិ មិនអាស្រ័យនៅក្នុងវត្ថុទាំងពួង អធិប្បាយថា វត្ថុទាំងពួង លោកពោលសំដៅយកអាយតនៈ ១២ គឺ ភ្នែក ១ រូប ១ ត្រចៀក ១ សំឡេង ១ ច្រមុះ ១ ក្លិន ១ អណ្ដាត ១ រស ១ កាយ ១ ផ្សព្ទ ១ ចិត្ត ១ ធម៌ ១ ។ ពាក្យថា មុនិ សេចក្ដីថា ញាណ ហៅថា មោនៈ គឺប្រាជ្ញា ការដឹងច្បាស់ ។ បេ ។ បុគ្គលណា កន្ទងបង់នូវបណ្ដាញ គឺគ្រឿងជាប់ចំពាក់ បុគ្គលនោះ ឈ្មោះថា មុនិ ។ ពាក្យថា មិនអាស្រ័យនៅ បានដល់និស្សរ័យ ២ យ៉ាង គឺ តណ្ហានិស្សរ័យ ១ ទិដ្ឋិនិស្សរ័យ ១ ។ បេ ។ នេះតណ្ហានិស្សរ័យ ។ បេ ។ នេះទិដ្ឋិនិស្សរ័យ ។ មុនិលះបង់តណ្ហានិស្សរ័យ រលាស់ចោលទិដ្ឋិនិស្សរ័យ មិនអាស្រ័យចក្ខុ មិនអាស្រ័យសោតៈ មិនអាស្រ័យឃានៈ មិនអាស្រ័យជិវ្ហា មិនអាស្រ័យកាយ មិនអាស្រ័យចិត្ត មិនអាស្រ័យរូប សំឡេង ក្លិន រស ផ្សព្ទ ធម្មារម្មណ៍ ត្រកូល គណៈ អាវាស លាភ យស សេចក្ដីសរសើរ សុខ*

ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ កាមធាតុំ រូបធាតុំ អរូបធាតុំ កាមភវំ រូបភវំ អរូបភវំ សញ្ញាភវំ អសញ្ញាភវំ នេវសញ្ញានាសញ្ញាភវំ ឯកវោការភវំ ចតុវោការភវំ បញ្ចវោការភវំ អតីតំ អនាគតំ បច្ចុប្បន្នំ ទិដ្ឋសុតមុតវិញ្ញាតព្ពេ ធម្មេ អនិស្សិតោ អសន្និស្សិតោ អនលីនោ អនុបគតោ អនជ្ឈោសិតោ អនធិមុត្តោ និក្ខន្តោ និស្សដ្ឋោ[1] វិប្ប-មុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ សព្ពន្ត មុនិ អនិស្សិតោ ។

[២១៤] ន បិយំ ករុតិ នោបិ អប្បិយន្តិ បិ-យាតិ ទ្វេ បិយា សត្តា វ សង្ខារា ។

ករតមេ សត្តា បិយា ។ ឥធ យស្ស តេ ហោន្តិ អត្តកាមា ហិតកាមា ផាសុកាមា យោគក្ខេមកា-មា មាតា វ បិតា វ ភាតា វ ភគិនី វ បុត្តោ វ ធីតា វ មិត្តា វ អមច្ចា វ ញាតី វ សាលោ-ហិតា វ ឥមេ សត្តា បិយា ។

---

1 ម. និស្សដ្ឋោ ។

ចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យ គិលានប្បច្ចយភេ-
សជ្ជបរិក្ខារ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព
សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព
ចតុវោការភព បញ្ចវោការភព អារម្មណ៍ជាអតីត អនាគត បច្ចុប្បន្ន
អារម្មណ៍ដែលឃើញ ឮ ប៉ះពាល់ ឬគប្បីដឹង គឺមិនអាស្រ័យនៅព្រម
មិនពួនសម្ងំ មិនចូលទៅជិត មិនជ្រុលជ្រប់ មិនចុះចិត្តស៊ប់ ជាអ្នក
ចេញទៅ រលាស់ចេញ រួចស្រឡះ ប្រាសចេញ មានចិត្តប្រាសចាក
សេចក្តីសល់រាល់ ហេតុនោះ (ទ្រង់ត្រាស់ថា) មុនិ មិនអាស្រ័យនៅ
ក្នុងវត្ថុទាំងពួង ។

[២១២] អធិប្បាយពាក្យថា មិនធ្វើសេចក្តីស្រឡាញ់ ទាំងមិន
ធ្វើសេចក្តីស្អប់ ត្រង់ពាក្យថា សេចក្តីស្រឡាញ់ បានដល់ សេចក្តី
ស្រឡាញ់ ២ គឺ ពួកសត្ត ១ សង្ខារ ១ ។

ពួកសត្តជាទីស្រឡាញ់ តើដូចម្តេច ។ ពួកជនណាក្នុងលោក
នេះ ជាអ្នកប្រាថ្នាសេចក្តីចម្រើន ប្រាថ្នាប្រយោជន៍ ប្រាថ្នាសប្បាយ
ប្រាថ្នាសេចក្តីក្សេមចាកយោគៈ ដល់មុនិនោះ ទោះជាមាតាក្តី បិតាក្តី
បងប្អូនប្រុសក្តី បងប្អូនស្ត្រីក្តី បុត្តក្តី ធីតាក្តី មិត្តក្តី អាមាត្យក្តី ញាតិ
ក្តី សាលោហិតក្តី នេះពួកសត្តជាទីស្រឡាញ់ ។

កតមេ សង្ខារា បិយា ។ មនាបិកា រូបា មនាបិកា សទ្ទា មនាបិកា គន្ធា មនាបិកា រសា មនាបិកា ផោដ្ឋព្វា ឥមេ សង្ខារា បិយា ។

អប្បិយានិ ទ្វេ អប្បិយា សត្តា វា សង្ខារា វា ។

កតមេ សត្តា អប្បិយា ។ ឥធ យស្ស តេ ហោន្តិ អនត្ថកាមា អហិតកាមា អផាសុកាមា អយោគក្ខេមកាមា ជីវិតា វោរោបេតុកាមា ឥមេ សត្តា អប្បិយា ។

កតមេ សង្ខារា អប្បិយា ។ អមនាបិកា រូបា អមនាបិកា សទ្ទា អមនាបិកា គន្ធា អមនាបិកា រសា អមនាបិកា ផោដ្ឋព្វា ឥមេ សង្ខារា អប្បិយា ។

ន បិយំ កុព្វតិ នោបិ អប្បិយន្តិ អយំ មេ សត្តោ បិយោ ឥមេ ច មេ សង្ខារា មនាបាតិ រាគវសេន[១] បិយំ ន ករោតិ អយំ មេ សត្តោ អប្បិយោ ឥមេ ច មេ សង្ខារា អមនាបាតិ បដិឃវសេន អប្បិយំ ន ករោតិ ន ជនេតិ ន សញ្ជនេតិ ន និព្វត្តេតិ នាភិនិព្វត្តេតីតិ ន បិយំ កុព្វតិ នោបិ អប្បិយំ ។

១ ឱ. ភង្គវសេន ។

ពួកសង្ខារជាទីស្រឡាញ់ តើដូចម្តេច ។ រូបជាទីពេញចិត្ត សំ-ឡេងជាទីពេញចិត្ត ក្លិនជាទីពេញចិត្ត រសជាទីពេញចិត្ត ផ្សព្វជាទីពេញចិត្ត នេះពួកសង្ខារជាទីស្រឡាញ់ ។ ពាក្យថា ស្អប់ បានដល់សេចក្តីស្អប់ ២ គឺពួកសត្ត ១ សង្ខារ ១ ។

ពួកសត្តជាទីស្អប់ តើដូចម្តេច ។ ពួកជនណា ក្នុងលោកនេះ ជាអ្នកមិនប្រាថ្នាសេចក្តីចម្រើន មិនប្រាថ្នាប្រយោជន៍ មិនប្រាថ្នាសប្បាយ មិនប្រាថ្នាសេចក្តីក្សេម ចាកយោគៈ ជាអ្នកប្រាថ្នា ដើម្បីឲ្យវិនាសចាកជីវិត ដល់មុនិនោះ នេះពួកសត្តជាទីស្អប់ ។

ពួកសង្ខារជាទីស្អប់ តើដូចម្តេច ។ រូបមិនជាទីពេញចិត្ត សំឡេងមិនជាទីពេញចិត្ត ក្លិនមិនជាទីពេញចិត្ត រសមិនជាទីពេញចិត្ត ផ្សព្វមិនជាទីពេញចិត្ត នេះពួកសង្ខារជាទីស្អប់ ។

ពាក្យថា មិនធ្វើសេចក្តីស្រឡាញ់ ទាំងមិនធ្វើសេចក្តីស្អប់ បានសេចក្តីថា បុគ្គលមិនធ្វើសេចក្តីស្រឡាញ់ ដោយអំណាចរាគៈថា សត្តនេះជាទីស្រឡាញ់របស់អញ សង្ខារទាំងនេះ ជាទីពេញចិត្តរបស់អញ បុគ្គលមិនធ្វើ មិនបង្កើត មិនឲ្យកើត មិនឲ្យកើតព្រម មិនឲ្យកើតឡើង មិនឲ្យកើតចំពោះ នូវសេចក្តីស្អប់ ដោយអំណាចបដិឃៈថា សត្តនេះជាទីស្អប់របស់អញ សង្ខារទាំងនេះ ជាទីស្អប់របស់អញ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនធ្វើសេចក្តីស្រឡាញ់ ទាំងមិនធ្វើសេចក្តីស្អប់ ។

[២១៤] តស្មឹ បរិទេវមច្ឆរំ បណ្ណេ វារិ យថា ន លិម្បតីតិ តស្មិន្តិ តស្មឹ បុគ្គលេ អរហន្តេ ខីណាសវេ ។ បរិទេវោតិ ញាតិព្យសនេន វា ផុដ្ឋស្ស ភោគព្យសនេន វា ផុដ្ឋស្ស រោគព្យសនេន វា ផុដ្ឋស្ស សីលព្យសនេន វា ផុដ្ឋស្ស ទិដ្ឋិព្យសនេន វា ផុដ្ឋស្ស អញ្ញតរញ្ញតរេន វា ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន វា ទុក្ខធម្មេន ផុដ្ឋស្ស អាទេវោ បរិទេវោ អាទេវនា បរិទេវនា អាទេវិតត្តំ បរិទេវិតត្តំ វាចា បលាបោ វិប្បលាបោ លាលប្បោ លាលប្បាយនា លាលប្បាយិតត្តំ ។ មច្ឆរិយន្តិ បញ្ច មច្ឆរិយានិ អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ ធម្មមច្ឆរិយំ យំ ឯវរូបំ មច្ឆរិយំ មច្ឆរាយនា មច្ឆរាយិតត្តំ វេវិច្ឆំ កទរិយំ កដុកញ្ចុកតា អគ្គហិតត្តំ ចិត្តស្ស ឥទំ វុច្ចតិ មច្ឆរិយំ អបិច ខន្ធមច្ឆរិយម្បិ មច្ឆរិយំ ធាតុមច្ឆរិយម្បិ មច្ឆរិយំ

ជរាសុត្តនិទ្ទេស ទី ៦

[២១៥] *អធិប្បាយពាក្យថា សេចក្តីខ្សឹកខ្ជួល និងសេចក្តីកំណាញ់ មិនជាប់នៅ ក្នុងមុនិនោះ ដូចជាវាវិមិនជាប់នៅលើស្វឹក(ឈូក) ត្រង់ពាក្យ ថា ក្នុងមុនិនោះ គឺក្នុងបុគ្គលជាព្រះអរហន្តខីណាស្រព ។ ពាក្យថាសេច-ក្តីខ្សឹកខ្ជួល គឺ ការយំ ការយំរៀបរាប់ អាការយំ អាការយំអណ្តើតអណ្តក ភាពនៃការយំ ភាពនៃការយំរៀបរាប់ ការនិយាយ ការពោលប៉ាច់ប៉-ប៉ោច ការពោលរវើរវាយ ការពោលរឿយៗ អាការជាទីពោលរឿយៗ ភាពនៃការពោលរឿយៗ របស់សត្វដែលត្រូវសេចក្តីវិនាសញាតិប៉ះពាល់ ក្តី ត្រូវសេចក្តីវិនាសភោគ:ប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសគឺរោគប៉ះពាល់ ក្តី ត្រូវសេចក្តីវិនាសសីលប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសទិដ្ឋិប៉ះពាល់ក្តី ប្រកបព្រមដោយសេចក្តីវិនាសណាមួយ ឬត្រូវទុក្ខធម៌ណាមួយប៉ះពាល់ ក្តី ។ ពាក្យថា សេចក្តីកំណាញ់ បានដល់សេចក្តីកំណាញ់ ៥ យ៉ាង គឺសេចក្តីកំណាញ់អាវាស ១ សេចក្តីកំណាញ់ត្រកូល ១ សេចក្តីកំណាញ់ លាភ ១ សេចក្តីកំណាញ់វណ្ណ: ១ សេចក្តីកំណាញ់ធម៌ ១ សេចក្តីកំណាញ់ អាការកំណាញ់ ភាពនៃចិត្តកំណាញ់ សេចក្តីចង់មានហួសហេតុ ស្នូរកន្ត្រឹស ភាពនៃចិត្តរួញ ភាពនៃការមិនយកចិត្តគេ ណា មានសភាពយ៉ាងនេះ នេះហៅថា សេចក្តីកំណាញ់ មួយទៀត សូម្បីសេចក្តីកំណាញ់ខន្ធ ក៏ ឈ្មោះថា កំណាញ់ សូម្បីសេចក្តីកំណាញ់ធាតុ ក៏ឈ្មោះថា កំណាញ់*

អាយតនមច្ឆរិយំបិ មច្ឆរិយំ គាហោ ឥទំ វុច្ចតិ មច្ឆរិយំ ។ បណ្ណេ ភរិ យថា ន លិម្បតីតិ បណ្ណំ វុច្ចតិ បទុមបត្តំ ។ ភរិ វុច្ចតិ ឧទកំ ។ យថា ភរិ បទុមបត្តេ ន លិម្បតិ ន សំលិម្បតិ ឩបលិម្បតិ អលិត្តំ អសំលិត្តំ អនុបលិត្តំ ឯវមេវ តស្មឹ បុគ្គលេ អរហន្តេ ខីណាសវេ បរិទេវោ ច មច្ឆរិយញ្ច ន លិម្បតិ ន សំលិម្បតិ[១] ឩបលិម្បតិ អលិត្តា អសំលិត្តា[២] អនុបលិត្តា សោ ច បុគ្គលោ តេហិ កិលេសេហិ ន លិម្បតិ ន សំលិម្បតិ ឩបលិម្បតិ អលិត្តោ អសំលិត្តោ អនុបលិត្តោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ តស្មឹ បរិទេវមច្ឆរំ បណ្ណេ ភរិ យថា ន លិម្បតិ ។ តេនាហ ភគវា

សព្វត្ថ មុនិ អនិស្សិតោ
ន បិយំ កុព្វតិ នោបិ អប្បិយំ
តស្មឹ បរិទេវមច្ឆរំ
បណ្ណេ ភរិ យថា ន លិម្បតីតិ ។

១ ម. បលិម្បតិ ។ ២ ម. អបលិត្តា ។

សូម្បីសេចក្ដីកំណាញ់អាយតនៈ ក៏ឈ្មោះថា កំណាញ់ ការគិតតែកាន់យក នេះលោកហៅថា សេចក្ដីកំណាញ់ ។ ពាក្យថា មិនជាប់នៅដូចជាវារិ មិនជាប់លើស្វឹក(ឈូក) សេចក្ដីថា ស្វឹកឈូក លោកហៅថា ស្វឹក ។ ទឹក លោកហៅថា វារិ ។ វារិមិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ គឺ មិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ហើយនឹងស្វឹកឈូក យ៉ាងណាមិញ សេចក្ដីខ្សឹកខ្សួល និងសេចក្ដីកំណាញ់ មិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ គឺ មិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ហើយ ក្នុងបុគ្គលនោះ គឺក្នុងព្រះអរហន្តខីណាស្រព ក៏យ៉ាងនោះដែរ ទាំងបុគ្គលនោះ មិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ គឺមិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ ចេញរួចហើយ រលាស់ចេញហើយ រួចស្រឡះហើយ ប្រាសចេញហើយ ចាកកិលេសទាំងនោះ ជាអ្នកមានចិត្តប្រាសចាកសេចក្ដីសល់រាល់ ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្ដីខ្សឹកខ្សួល និងសេចក្ដីកំណាញ់ មិនជាប់ក្នុងបុគ្គលនោះ ដូចជាវារិ មិនជាប់លើស្វឹក (ឈូក) ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

> *មុនិ មិនអាស្រ័យនៅក្នុងវត្ថុទាំងពួង មិនធ្វើសេចក្ដីស្រឡាញ់ ទាំងមិនធ្វើសេចក្ដីស្អប់ (ចំពោះសត្វនិងសង្ខារ) សេចក្ដីខ្សឹកខ្សួលនិងសេចក្ដីកំណាញ់ មិនជាប់នៅក្នុងមុនិនោះ ដូចជាវារិ មិនជាប់នៅលើស្វឹក (ឈូក) ។*

[២១៦] ឧឌវិន្ទុ យថាបិ ចោក្ខ្ជរេ
បឧមេ ភរិ យថា ន លិម្ពតិ
ឯវំ មុនិ ឧោបលិម្ពតិ
យនិធំ ឧិជ្ជសុតំ មុតេសុ ភ ។

[២១៧] ឧឌវិន្ទុ យថាបិ ចោក្ខ្ជរេតិ ឧឌវិន្ទូតិ រុច្ចតិ ឧឌកាថេរោ ។ ចោក្ខ្ជរំ រុច្ចតិ បឧុមបត្តំ ។ យថា ឧឌកាវិន្ទុ បឧុមបត្តេ ន លិម្ពតិ ន សំលិម្ពតិ ឧុប-លិម្ពតិ អលិត្តំ អសំលិត្តំ អនុបលិត្តន្តិ ឧឌវិន្ទុ យ-ថាបិ ចោក្ខ្ជរេ ។

[២១៨] បឧុមេ ភរិ យថា ន លិម្ពតីតិ បឧុមំ រុច្ចតិ បឧុមបុប្ផំ ។ ភរិ រុច្ចតិ ឧឌកំ ។ យថា ភរិ បឧុមបុប្ផេ ន លិម្ពតិ ន សំលិម្ពតិ ឧុបលិម្ពតិ អលិត្តំ អសំលិត្តំ អនុបលិត្តន្តិ បឧុមេ ភរិ យថា ន លិម្ពតិ ។

[២១៩] ឯវំ មុនិ ឧោបលិម្ពតិ យនិធំ ឧិជ្ជសុតំ មុតេសុ ភតិ ឯវន្តិ ឧិបម្មសម្ជដិចាឧនា ។ មុនីតិ មោនំ រុច្ចតិ ញាណំ យា បញ្ញា បជានឧនា ។ បេ ។

ជរាសុត្តនិទ្ទេស ទី ៦

[២១៦] *តំណក់ទឹក មិនជាប់នៅលើស្ងឹកឈូក យ៉ាងណា វារិមិន ជាប់នៅលើផ្ការឈូក យ៉ាងណា មុនិ មិនជាប់ក្នុងអារម្មណ៍ ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ ក៏យ៉ាងនោះដែរ ។*

[២១៧] *ពាក្យថា តំណក់ទឹកមិនជាប់លើស្ងឹកឈូក យ៉ាងណា សេចក្តីថា គ្រាប់ទឹក លោកហៅថា តំណក់ទឹក ។ ស្ងឹកឈូកលោកហៅថាឈូក ។ តំណក់ទឹកមិនជាប់នៅ មិនជ្រួតជ្រាប មិនប្រឡាក់ គឺមិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ហើយ លើស្ងឹកឈូកយ៉ាងណា ហេតុនោះ (ទ្រង់ត្រាស់ថា) តំណក់ទឹកមិនជាប់លើស្ងឹកឈូក យ៉ាងណា ។*

[២១៨] *ពាក្យថា វារិ មិនជាប់នៅលើផ្ការឈូក យ៉ាងណា សេចក្តីថា ផ្ការឈូក លោកហៅថា ឈូក ។ ទឹក លោកហៅថា វារិ ។ វារិ មិនជាប់នៅ មិនជ្រួតជ្រាប មិនប្រឡាក់ គឺមិនជាប់នៅ មិនជ្រួតជ្រាប មិនប្រឡាក់ហើយ លើផ្ការឈូក យ៉ាងណា ហេតុនោះ (ទ្រង់ត្រាស់ថា) វារិ មិនជាប់នៅលើផ្ការឈូក យ៉ាងណា ។*

[២១៩] *អធិប្បាយពាក្យថា មុនិមិនជាប់នៅក្នុងអារម្មណ៍ ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ ក៏យ៉ាងនោះ ត្រង់ពាក្យថា យ៉ាងនោះ គឺជាពាក្យផ្តល់សេចក្តីឧបមា ។ ពាក្យថា មុនិ សេចក្តីថា ញាណលោក ហៅថា មោនៈ បានខាងប្រាជ្ញា ការដឹងច្បាស់ ។ បេ ។*

សង្ខ្លជាលមតិចូ សោ មុនិ ។ លេចាតិ ទ្វេ លេចា
តណ្ហាលេចោ ច ទិដ្ឋិលេចោ ច ។ បេ ។ អយំ
តណ្ហាលេចោ ។ បេ ។ អយំ ទិដ្ឋិលេចោ ។ មុនិ
តណ្ហាលេបំ បហាយ ទិដ្ឋិលេបំ បដិនិស្សជ្ជិត្វា ទិដ្ឋេ ន
លិម្ពតិ សុតេ ន លិម្ពតិ មុតេ ន លិម្ពតិ វិញ្ញា-
តេ ន លិម្ពតិ ន សំលិម្ពតិ ឧបលិម្ពតិ អលិត្តោ
អសំលិត្តោ អនុបលិត្តោ និក្ខន្តោ និស្សដ្ឋো វិប្ប-
មុត្តো វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរ-
តីតិ ឯវំ មុនិ ឧោបលិម្ពតិ យទិទំ ទិដ្ឋសុតំ មុតេ-
សុ វា ។ តេនាហ ភគវា

ឧទកម្ហិ យថាបិ ទោណ្ហរេ
បទុមេ វារិ យថា ន លិម្ពតិ
ឯវំ មុនិ ឧោបលិម្ពតិ
យទិទំ ទិដ្ឋសុតំ មុតេសុ វាតិ ។

[២២០] ឧោឧោ ន ហិ តេន មញ្ញតិ
យទិទំ ទិដ្ឋសុតំ មុតេសុ វា
ញាណេន វិសុទ្ធិមិច្ឆតិ
ន ហិ សោ រជ្ជតិ ឧោ វិរជ្ជតិ ។

បុគ្គលណា កន្ទងបណ្ដាញគឺគ្រឿងជាប់ចំពាក់ បុគ្គលនោះ ឈ្មោះថា មុនិ ។ ពាក្យថា ជាប់ បានដល់ការជាប់ ២ គឺការជាប់គឺតណ្ហា ១ ការជាប់គឺទិដ្ឋិ ១ ។ បេ ។ នេះការជាប់គឺតណ្ហា ។ បេ ។ នេះការជាប់គឺទិដ្ឋិ ។ មុនិ លះបង់ការជាប់គឺតណ្ហា រលាស់ចេលការជាប់គឺទិដ្ឋិ មិនជាប់ក្នុងរូបដែលឃើញ មិនជាប់ក្នុងសំឡេងដែលឮ មិនជាប់ក្នុងផស្ស: ដែលប៉ះពាល់ មិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ គឺមិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ ចេញទៅ រលាស់ចេញ រួចស្រឡះ ប្រាសចេញហើយ ក្នុងអារម្មណ៍ដែលដឹង ជាអ្នកមានចិត្តប្រាសចាកសេចក្ដីសល់រាល់ ហេតុនោះ (ទ្រង់ត្រាស់ថា) មុនិមិនជាប់ក្នុងអារម្មណ៍ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ យ៉ាងនោះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

តំណក់ទឹក មិនជាប់នៅលើស្លឹកឈូក យ៉ាងណា រ៉ាវ៉ា មិនជាប់នៅលើផ្ការឈូក យ៉ាងណា មុនិ មិនជាប់ក្នុងអារម្មណ៍ ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ ក៏យ៉ាងនោះ ។

[២២០] បុគ្គលមានប្រាជ្ញាកម្ចាត់ មិនសម្គាល់នូវអារម្មណ៍ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ ដោយវត្ថុនោះ មិនប្រាថ្នាសេចក្ដីបរិសុទ្ធដោយហេតុដទៃ បុគ្គលមានប្រាជ្ញាកម្ចាត់នោះរមែងមិនត្រេក មិនទ្រាន់ ។

ឆដ្ឋោ ជរាសុត្តនិទ្ទេសោ

[២២១] ជោជោ ន ហិ តេន មញ្ញតិ យទិទំ ទិដ្ឋ-
សុតំ មុតេសុ ភាតិ ជោជោតិ ជោជា រុច្ចតិ បញ្ញា
យ បញ្ញា បជានតា ។ បេ ។ អមោហោ ធម្មវិ-
ចយោ សម្មាទិដ្ឋិ ។ កឹការណា ជោជា រុច្ចតិ បញ្ញា ។
តាយ បញ្ញាយ កាយទុច្ចរិតំ ជុតញ្ច ជោតញ្ច សង្ខោ-
តញ្ច និង្ខោតញ្ច ។ វចីទុច្ចរិតំ ជុតញ្ច ជោតញ្ច សង្ខោ-
តញ្ច និង្ខោតញ្ច ។ មនោទុច្ចរិតំ ជុតញ្ច ជោតញ្ច
សង្ខោតញ្ច និង្ខោតញ្ច ។ ភាគោ ជុតោ ច ជោតោ
ច សង្ខោតោ ច និង្ខោតោ ច ។ ជោសោ មោហោ
ពោធោ ឧបនាហោ មក្ខោ បឬាសោ ឥស្សា
មច្ឆរិយំ មាយា សាឋេយ្យំ ថម្ភោ សារម្ភោ មានោ
អតិមានោ មទោ បមាទោ សព្វេ កិលេសា សព្វេ
ទុច្ចរិតា សព្វេ ទរថា សព្វេ បរិឬាហា សព្វេ សន្ដាបា
សព្វាកុសលាភិសង្ខារា ជុតា ច ជោតា ច សង្ខោតា
ច និង្ខោតា ច ។ តំការណា ជោជា រុច្ចតិ បញ្ញា ។
អថវា សម្មាទិដ្ឋិយា មិច្ឆាទិដ្ឋិ ជុតា ច ជោតា ច
សង្ខោតា ច និង្ខោតា ច ។

ជរាសុត្តនិទ្ទេស ទី ៦

[២២១] *អធិប្បាយពាក្យថា បុគ្គលមានប្រាជ្ញាកម្ចាត់ មិនសម្គាល់ចំពោះអារម្មណ៍ដែលខ្ជួនឃើញ ឮ ឬប៉ះពាល់ ដោយវត្ថុនោះ ត្រង់ពាក្យថា បុគ្គលមានប្រាជ្ញាកម្ចាត់ សេចក្តីថា បញ្ញា លោកហៅថា ប្រាជ្ញាកម្ចាត់ បានខាងប្រាជ្ញា សេចក្តីដឹងច្បាស់ ។ បេ ។ សេចក្តីមិនវង្វេង ការពិចារ-ណាធម៌ សេចក្តីយល់ត្រូវ ។ បញ្ញា លោកហៅថាប្រាជ្ញាកម្ចាត់ តើព្រោះហេតុដូចម្តេច ។ កាយទុច្ចរិត លោកកម្ចាត់បង់ហើយ លាងហើយ សម្អាតហើយ ជម្រះឲ្យស្អាតហើយ ដោយបញ្ញានោះ ។ វចីទុច្ចរិតលោកកម្ចាត់បង់ហើយ លាងហើយ សម្អាតហើយ ជម្រះឲ្យស្អាតហើយ ។ មនោ-ទុច្ចរិត លោកកម្ចាត់បង់ហើយ លាងហើយ សម្អាតហើយ ជម្រះឲ្យស្អាតហើយ ។ រាគ:លោកកម្ចាត់បង់ហើយ លាងហើយ សម្អាតហើយ ជម្រះឲ្យស្អាតហើយ ។ ទោស: មោហ: កោធ: ឧបនាហ: មក្ខ: បឡាស: ឥស្សា មច្ឆរិយ: មាយា សាឋេយ្យ: ថម្ភ: សារម្ភ: មានៈ អតិមានៈ មទ: បមាទ កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រ-វល់ក្រវាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ ការតាក់តែងអកុសលទាំងអស់ លោកកម្ចាត់បង់ហើយ លាងហើយ សម្អាតហើយ ជម្រះឲ្យស្អាតហើយ ។ ហេតុនោះ បញ្ញា លោកហៅថាប្រាជ្ញាកម្ចាត់ ។ មួយទៀតមិច្ឆាទិដ្ថិ លោកកម្ចាត់បង់ហើយ លាងហើយ សម្អាតហើយ ជម្រះឲ្យស្អាតហើយ ដោយសម្មាទិដ្ថិ ។*

សម្មាសង្ខប្បេន មិច្ឆាសង្ខប្បា ជុតោ ច ជោតោ ច
សង្ខោតោ ច និង្ខោតោ ច ។ សម្មាវាចាយ មិច្ឆាវាចា
ជុតា ច ។ សម្មាកម្មន្តេន មិច្ឆាកម្មន្តា ជុតោ ច ។
សម្មាអាជីវេន មិច្ឆាអាជីវោ ជុតោ ច ។ សម្មាវាយា-
មេន មិច្ឆាវាយាមោ ជុតោ ច ។ សម្មាសតិយា មិច្ឆា-
សតិ ជុតា ច ។ សម្មាសមាធិនា មិច្ឆាសមាធិ ជុតោ
ច ។ សម្មាញ្ញាណេន មិច្ឆាញ្ញាណំ ជុតញ្ច ។ សម្មាវិ-
មុត្តិយា មិច្ឆាវិមុត្តិ ជុតា ច ជោតា ច សង្ខោតា ច
និង្ខោតា ច ។ អថវា អរិយេន អដ្ឋង្គិកេន មគ្គេន សព្វេ
កិលេសា សព្វេ ទុច្ចរិតា សព្វេ ឌរថា សព្វេ បរិ-
ឡាហា សព្វេ សន្តាបា សព្វាកុសលាភិសង្ខារា
ជុតា ច ជោតា ច សង្ខោតា ច និង្ខោតា ច ។
អរហា ឥមេហិ ជោនេយ្យេហិ ឆម្ភេហិ ឧបេតោ
សមុបេតោ ឧបគតោ សមុបគតោ ឧបបន្នោ សមុប-
បន្នោ សមង្គីភូតោ តស្មា អរហា ជោនោ ។ សោ
ជុតរាគោ ជុតទោសោ ជុតក្លិលេសោ ជុតបរិឡាហោតិ
ជោនោ ។

មិច្ឆាសङ្កប្ប: លោកកម្ចាត់បង់ហើយ លាងហើយ សម្អាតហើយ ជម្រះឲ្យស្អាតហើយ ដោយសម្មាសङ្កប្ប: ។ មិច្ឆាវាចា លោកកម្ចាត់បង់ហើយ ដោយសម្មាវាចា ។ មិច្ឆាកម្មន្ត: លោកកម្ចាត់បង់ហើយ ដោយសម្មាកម្មន្ត: ។ មិច្ឆាអាជីវ: លោកកម្ចាត់បង់ហើយ ដោយសម្មាអាជីវ: ។ មិច្ឆាវាយាម: លោកកម្ចាត់បង់ហើយ ដោយសម្មាវាយាម: ។ មិច្ឆាសតិ លោកកម្ចាត់បង់ហើយ ដោយសម្មាសតិ ។ មិច្ឆាសមាធិ លោកកម្ចាត់បង់ហើយ ដោយសម្មាសមាធិ ។ មិច្ឆ-ញ្ញាណ: លោកកម្ចាត់បង់ហើយ ដោយសម្មាញ្ញាណ: ។ មិច្ឆាវិមុត្តិ លោកកម្ចាត់បង់ហើយ លាងហើយ សម្អាតហើយ ជម្រះឲ្យស្អាតហើយ ដោយសម្មាវិមុត្តិ ។ មួយទៀត កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ ការតាក់តែងអកុសលទាំងអស់ លោកកម្ចាត់បង់ហើយ លាងហើយ សម្អាតហើយ ជម្រះឲ្យស្អាតហើយ ដោយអរិយ-មគ្គមានអङ្គ ៨ ប្រការ ។ ព្រះអរហន្ត ចូលទៅ ចូលទៅព្រម ចូលទៅជិត ផ្តេកផ្ចិត កើត កើតឡើងជាមួយ ប្រកបដោយធោនេយ្យធម៌ទាំងនេះ ព្រោះហេតុនោះ ព្រះអរហន្តឈ្មោះថាអ្នកមានប្រាជ្ញាកម្ចាត់ ។ ព្រះអរហន្តនោះ កម្ចាត់បង់ភគ: កម្ចាត់បង់បាប កម្ចាត់បង់កិលេស កម្ចាត់បង់សេចក្តីអន្ទះអន្ទែង ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមានប្រាជ្ញាកម្ចាត់ ។

ឆោឆោ ន ហិ តេន មញ្ញតិ យទិទំ ទិដ្ឋសុតំ
មុតេសុ វាតិ ឆោឆោ ទិដ្ឋំ ន មញ្ញតិ ទិដ្ឋស្មឹ ន មញ្ញតិ
ទិដ្ឋតោ ន មញ្ញតិ ទិដ្ឋំ មេតិ ន មញ្ញតិ ។ សុតំ ន
មញ្ញតិ សុតស្មឹ ន មញ្ញតិ សុតតោ ន មញ្ញតិ សុតំ
មេតិ ន មញ្ញតិ ។ មុតំ ន មញ្ញតិ មុតស្មឹ ន មញ្ញតិ
មុតតោ ន មញ្ញតិ មុតំ មេតិ ន មញ្ញតិ ។ វិញ្ញាតំ
ន មញ្ញតិ វិញ្ញាតស្មឹ ន មញ្ញតិ វិញ្ញាតតោ ន មញ្ញតិ
វិញ្ញាតំ មេតិ ន មញ្ញតិ ។ រុត្តំ ហោតំ ភគវតា អស្មីតិ
ភិក្ខវេ មញ្ញិតមេតំ អនស្មីតិ[1] មញ្ញិតមេតំ ភវិស្សន្តិ
មញ្ញិតមេតំ ន ភវិស្សន្តិ មញ្ញិតមេតំ រូបី ភវិស្សន្តិ
មញ្ញិតមេតំ អរូបី ភវិស្សន្តិ មញ្ញិតមេតំ សញ្ញី ភវិ-
ស្សន្តិ មញ្ញិតមេតំ អសញ្ញី ភវិស្សន្តិ មញ្ញិតមេតំ

---

១ ឱ. ម. អយមហាមស្មីតិ ។

ជរាសុត្តនិទ្ទេស ទី ៦

ពាក្យថា បុគ្គលមានប្រាជ្ញាកម្ចាត់ មិនសម្គាល់នូវអារម្មណ៍ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ ដោយវត្ថុនោះ បានសេចក្ដីថា បុគ្គលមានប្រាជ្ញាកម្ចាត់ មិនសម្គាល់រូបដែលឃើញ មិនសម្គាល់ក្នុងរូបដែលឃើញ មិនសម្គាល់ដោយរូបដែលឃើញ មិនសម្គាល់ថារូបដែលអញឃើញហើយ ។ មិនសម្គាល់សំឡេងដែលឮ មិនសម្គាល់ក្នុងសំឡេងដែលឮ មិនសម្គាល់ដោយសំឡេងដែលឮ មិនសម្គាល់ថា សំឡេងដែលអញឮហើយ ។ មិនសម្គាល់អារម្មណ៍ដែលប៉ះពាល់ មិនសម្គាល់ក្នុងអារម្មណ៍ដែលប៉ះពាល់ មិនសម្គាល់ដោយអារម្មណ៍ដែលប៉ះពាល់ មិនសម្គាល់ថា អារម្មណ៍ដែលអញប៉ះពាល់ហើយ ។ មិនសម្គាល់ហេតុដែលដឹង មិនសម្គាល់ក្នុងហេតុដែលដឹង មិនសម្គាល់ដោយហេតុដែលដឹង មិនសម្គាល់ថា ហេតុដែលអញដឹងហើយ ។ សមដូចពាក្យនុ៎ះ ដែលព្រះមានព្រះភាគ ត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ អ្នកសម្គាល់ហេតុនុ៎ះថា អាត្មាអញកំពុងមាន អ្នកសម្គាល់ហេតុនុ៎ះថា អាត្មាអញកំពុងមិនមាន អ្នកសម្គាល់ហេតុនុ៎ះថា អាត្មាអញនឹងមាន អ្នកសម្គាល់ហេតុនុ៎ះថា អាត្មាអញនឹងមិនមាន អ្នកសម្គាល់ហេតុនុ៎ះថា អាត្មាអញនឹងមានរូប អ្នកសម្គាល់ហេតុនុ៎ះថា អាត្មាអញនឹងមិនមានរូប អ្នកសម្គាល់ហេតុនុ៎ះថា អាត្មាអញនឹងមានសញ្ញា អ្នកសម្គាល់ហេតុនុ៎ះថា អាត្មាអញនឹងមិនមានសញ្ញា

ដេវសញ្ញីជាសញ្ញី ភវិស្សន្តិ មញ្ញិតមេតំ មញ្ញិតំ ភិក្ខវេ ហោតោ មញ្ញិតំ ឥណ្ហោ មញ្ញិតំ សល្ងំ មញ្ញិតំ ឧបទ្ទ-ហោ ឥស្មាតិហ ភិក្ខវេ អមញ្ញមានេន ចេតសា វិហ-រិស្សាមាតិ ឯវញ្ហិ ហោ ភិក្ខវេ សិក្ខិតព្វន្តិ ។ ដោដោ ន ហិ តេន មញ្ញតិ យទិទំ ទិដ្ឋសុតំ មុតេសុ វា ។

[២២២] ជាញ្ញេន វិសុទ្ធិមិច្ឆតីតិ ដោដោ អញ្ញេន អសុទ្ធិមត្តេន មិច្ឆាបដិបជ្ជាយ អនិយ្យានិកបថេន អញ្ញត្រ សតិប្បដ្ឋានេហិ អញ្ញត្រ សម្មប្បធានេហិ អញ្ញត្រ ឥទ្ធិបាទេហិ អញ្ញត្រ ឥន្ទ្រិយេហិ អញ្ញត្រ ព-លេហិ អញ្ញត្រ ពោជ្ឈង្គេហិ អញ្ញត្រ អរិយា អដ្ឋ-ង្គិកា មក្គា សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ ន ឥច្ឆតិ ន សាធិយតិ ន បត្ថេតិ ន បិហេតិ ជាភិជ្ឌប្ឌតីតិ ជាញ្ញេន វិសុទ្ធិមិច្ឆតិ ។

អ្នកសម្គាល់ហេតុនុ៎ះថា អាត្មាអញនឹងមានសញ្ញាក៏ទេ មិនមានសញ្ញាក៏ទេ ម្នាលភិក្ខុទាំងឡាយ អ្នកសម្គាល់ថាជារោគ អ្នកសម្គាល់ថាជាបូស អ្នកសម្គាល់ថាជាសរ អ្នកសម្គាល់ថាជាឧបទ្រព ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ (ចូរសិក្សា)ថា យើងទាំងឡាយ គប្បីនៅដោយចិត្តមិនបានសម្គាល់ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងហ្នឹងឯង ។ បុគ្គលមានប្រាជ្ញាកម្ចាត់ មិនសម្គាល់អារម្មណ៍ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ ដោយវត្ថុនោះ ។

[២២២] *ពាក្យថា មិនប្រាថ្នាសេចក្តីបរិសុទ្ធ ដោយហេតុដទៃ គឺបុគ្គលមានប្រាជ្ញាកម្ចាត់ រមែងមិនចង់បាន មិនត្រេកអរ មិនប្រាថ្នា មិនស្រឡាញ់ មិនជាប់ចំពោះនូវសេចក្តីស្អាត ការហ្មត់ចត់ ការបរិសុទ្ធ ការរួច ការរួចស្រឡះ ការផុតស្រឡះ ដោយមគ្គមិនបរិសុទ្ធ ដោយសេចក្តីប្រតិបត្តិខុស ដោយគន្ធងមិនមែនជានិយ្យានិកធម៌ដទៃ រៀរចាកសតិប្បដ្ឋាន រៀរចាកសម្មប្បធាន រៀរចាកឥទ្ធិបាទ រៀរចាកឥន្ទ្រិយ រៀរចាកពល: រៀរចាកពោជ្ឈង្គ រៀរចាកអរិយមគ្គមានអង្គ ៨ ឡើយ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនប្រាថ្នាសេចក្តីបរិសុទ្ធ ដោយហេតុដទៃ ។*

ឆដ្ឋោ ជរាសុត្តនិទ្ទេសោ

[២២៣] ន ហិ សោ រជ្ជតិ យោ វិរជ្ជតីតិ សព្ពេ ពាលបុថុជ្ជនា រជ្ជន្តិ កល្យាណបុថុជ្ជនំ ឧចាជាយ សត្ត សេក្ខា វិរជ្ជន្តិ អរហា នេវ រជ្ជតិ យោ វិរជ្ជតិ ។ វិរត្តោ សោ ទ្វយា ភាគស្ស រាគភាគត្តា ទ្វយា ទោសស្ស រាគទោសត្តា ទ្វយា មោហស្ស រាគមោហត្តា ។ សោ រុជ្ជវាសោ ចិណ្ណាចរណោ ។ បេ ។ ឧត្តិ តស្ស បុនព្ភវោ-តិ ន ហិ សោ រជ្ជតិ យោ វិរជ្ជតិ ។ តេនាហ ភគវា

យោ យោ ន ហិ តេន មញ្ញតិ
យទិទំ ទិដ្ឋសុតំ មុតេសុ វា
ជាញ្ញេន វិសុទ្ធិមិច្ឆតិ
ន ហិ សោ រជ្ជតិ យោ វិរជ្ជតីតិ ។

ឆដ្ឋោ ជរាសុត្តនិទ្ទេសោ និដ្ឋិតោ ។

ជរាសុត្តនិទ្ទេស ទី ៦

[២២៣] *ពាក្យថា បុគ្គលមានប្រាជ្ញាកម្ចាត់នោះ រមែងមិនត្រេក មិនទ្រាន់ សេចក្ដីថា ពាលបុថុជ្ជនទាំងអស់ រមែងត្រេក សេក្ខបុគ្គល ៧ ពួក រាប់ទាំងកល្យាណបុថុជ្ជនផង រមែងទ្រាន់ ព្រះអរហន្ត រមែងមិនត្រេក មិនទ្រាន់ ។ ព្រះអរហន្តនោះ ប្រាសចាកតម្រេក ព្រោះអស់រាគ: ព្រោះប្រាសចាករាគ: ព្រោះអស់ទោស: ព្រោះប្រាសចាកទោស: ព្រោះអស់មោហ: ព្រោះប្រាសចាកមោហ:ហើយ ។ ព្រះអរហន្តនោះ មានការអប់រំព្រហ្មចរិយធម៌ស្រេចហើយ មានការប្រព្រឹត្ត ប្រព្រឹត្តរួចហើយ ។ បេ ។ ភពថ្មីរបស់ព្រះអរហន្តនោះ មិនមានទេ ហេតុនោះ (ទ្រង់ត្រាស់) ថា បុគ្គលមានប្រាជ្ញាកម្ចាត់នោះ រមែងមិនត្រេក មិនទ្រាន់ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា*

បុគ្គលមានប្រាជ្ញាកម្ចាត់ មិនសម្គាល់នូវអារម្មណ៍ ដែលខ្ជួនឃើញ ឮ ឬប៉ះពាល់ ដោយវត្ថុនោះ មិនប្រាថ្នាសេចក្ដីបរិសុទ្ធ ដោយហេតុដទៃ បុគ្គលមានប្រាជ្ញាកម្ចាត់នោះ រមែងមិនត្រេក មិនទ្រាន់ ។

ចប់ ជរាសុត្តនិទ្ទេស ទី ៦ ។

សត្តមោ តិស្សមេត្តេយ្យសុត្តនិទ្ទេសោ

[២២៤] មេថុនមនុយុត្តស្ស (ឥច្ចាយស្មា
តិស្សេ្ច មេត្តេយ្យោ)
វិយាតំ ព្រូហិ មារិស
សុត្វាន តវ សាសនំ
វិវេកេ សិក្ខិសាមសេ ។

[២២៥] មេថុនមនុយុត្តស្សាតិ មេថុនធម្មោ ជាមយោ សោ អសទ្ធម្មោ ការាមធម្មោ រសលធម្មោ ឧដ្ឋណ្ណោ ឱធកន្តិកោ រហស្សោ ទ្វយទ្វយសមាបត្តិ ។ ឯកាការណា រុច្ចតិ មេថុនធម្មោ ។ ឧភិន្នំ រត្តានំ សារត្តានំ អវស្សុតានំ បរិយុដ្ឋិតានំ បរិយាទិន្នចិត្តានំ ឧភិន្នំ ស-ទិសានំ ធម្មោតិ តំការណា រុច្ចន្តិ មេថុនធម្មោ ។ យថា ឧភោ ឧណ្ហការការ មេថុនការាតិ រុច្ចន្តិ ឧភោ ភណ្ឌនការការ មេថុនការាតិ រុច្ចតិ ឧភោ ភស្សការការ មេថុនការាតិ រុច្ចន្តិ ឧភោ ១ារ-ការ មេថុនការាតិ រុច្ចន្តិ ឧភោ អធិការណការការ មេថុនការាតិ រុច្ចន្តិ ឧភោ ១ានិ មេថុនការាតិ រុច្ចន្តិ ឧភោ សណ្ឋាបការ មេថុនការាតិ រុច្ចន្តិ

តិស្សមេត្តេយ្យសុត្តនិទ្ទេស ទី ៧

[២២៦] (ព្រះតិស្សមេត្តេយ្យ: មានអាយុក្រាបទូលយ៉ាងនេះថា)
*បពិត្រព្រះអង្គទ្រង់និរទុក្ខ សូមព្រះអង្គពោលសេចក្ដីចង្អៀត
ចង្អ្ល់ របស់បុគ្គលដែលប្រកបរឿយ ៗ ក្នុងមេថុន យើង
ខ្ញុំស្ដាប់ពាក្យប្រដៅរបស់ព្រះអង្គហើយ នឹងសិក្សាក្នុងវិវេក ។*

[២២៥] *ពាក្យថា បុគ្គលប្រកបរឿយៗក្នុងមេថុន អធិប្បាយថា ឈ្មោះថា មេថុនធម្ម បានដល់ ធម៌របស់អសប្បុរស ធម៌របស់អ្នកស្រុក ធម៌របស់ជនថោកទាប ធម៌អាក្រក់ មានទឹកជាទីបំផុត ធម៌កើតក្នុងទីកំបាំង ការចួបជុំរបស់បុគ្គលពីរ ៗ នាក់ ។ ដែលលោកហៅថា មេថុនធម្ម តើព្រោះហេតុអ្វី ។ ធម៌របស់បុគ្គលពីរនាក់ ដែលត្រេកអរ ត្រេកអរខ្លាំង ជោក (ដោយរាគ:) រួបរឹត (ដោយរាគ:) មានចិត្តត្រូវកិលេសគ្របសង្កត់ស្មើគ្នាទាំងពីរនាក់ ព្រោះហេតុនោះ ទើបលោកហៅថា មេថុនធម្ម ។ ជនពីរនាក់ ធ្វើជម្ងោ លោកហៅថា គូជម្ងោ ជនពីរនាក់ ធ្វើសេចក្ដីប្រកួតប្រកាន់ លោកហៅថា គូប្រកួតប្រកាន់ ជនពីរនាក់ធ្វើការនិយាយគ្នា លោកហៅថា គូនិយាយគ្នា ជនពីរនាក់ធ្វើការជជែកគ្នា លោកហៅថា គូជជែកគ្នា ជនពីរនាក់ ធ្វើអធិករណ៍ លោកហៅថា គូអធិករណ៍ ជនពីរនាក់ ចរចាគ្នាជាប្រក្រតី លោកហៅថា គូចរចា ជនពីរនាក់ និយាយធ្វើយធ្ងន់គ្នា លោកហៅថា គូធ្វើយធ្ងន់*

ឯវមេវ ឧកិន្នំ រត្តានំ សារត្តានំ អវស្សុតានំ បរិយុ-
ដ្ឋិតានំ បរិយោនិន្នចិត្តានំ ឧកិន្នំ សនិសានំ ឆម្ហោតិ
តំការណា រុច្ចតិ មេថុនធម្មោ ។ មេថុនមនុយុត្ត-
ស្ឆាតិ មេថុនធម្មេ យុត្តស្ស បយុត្តស្ស អាយុត្តស្ស
សមាយុត្តស្ស តច្ចរិតស្ស តព្ភហុលស្ស តក្ករុកស្ស
តន្និន្នស្ស តប្ភោណស្ស តប្ភារស្ស តធជិមុត្តស្ស
តជាធិបតេយ្យស្ឆាតិ មេថុនមនុយុត្តស្ស ។

[២២៦] ឥច្ចាយស្មា តិស្សោ មេត្តេយ្យោតិ ឥច្ចាតិ
បទសន្ធិ បទសំសគ្គោ បទចារិម្ភូ អក្ខរសមវាយោ
ព្យញ្ជនសិលិដ្ឋតា បទានុបុព្ភកមេតំ ឥច្ចាតិ ។ អា-
យស្មាតិ បិយវចនំ ករុវចនំ សការវចនំ សម្ផតិស្ស-
វចនមេតំ អាយស្មាតិ ។ តិស្សោតិ តស្ស ថេរស្ស
ជាមំ សង្ខ្យា សមញ្ញា បញ្ញត្តិ ហោហោ ជាមំ ជាម-
កម្មំ ជាមធេយ្យំ និរុត្តិ ព្យញ្ជនំ អភិលាបោ ។

យ៉ាងណា ធម៌របស់ជនពីរនាក់ ដែលត្រេកអរ ត្រេកអរខ្លាំង ជោក (ដោយរាគ:) រួបរឹត (ដោយរាគ:) មានចិត្តត្រូវកិលេសគ្របសង្កត់ស្មើគ្នាទាំងពីរនាក់ ព្រោះហេតុនោះ ទើបលោកហៅថា មេថុនធម្ម យ៉ាងនោះដែរ ។ ពាក្យថា ប្រកបរឿយៗ ក្នុងមេថុន បានសេចក្តីថា ប្រកបតាក់តែង ប្រដុងប្រជា ប្រកបព្រមក្នុងមេថុនធម្ម ប្រព្រឹត្តមេថុនធម្មនោះ ក្រាស់ដោយមេថុនធម្មនោះ គោរពមេថុនធម្មនោះ ខ្ជិនទៅក្នុងមេថុន-ធម្មនោះ ទោរទៅក្នុងមេថុនធម្មនោះ ឈមមុខទៅក្នុងមេថុនធម្មនោះ ចុះចិត្តស៊ប់ទៅក្នុងមេថុនធម្មនោះ ធ្វើមេថុនធម្មនោះឲ្យជាធំ ហេតុនោះ (លោកពោលថា) ប្រកបរឿយៗ ក្នុងមេថុន ។

[២២៦] *អធិប្បាយពាក្យថា* ព្រះតិស្សមេតេយ្យ:មានអាយុ ក្រាបទូលយ៉ាងនេះ ត្រង់ពាក្យថា យ៉ាងនេះ គឺជាពាក្យភ្ជាប់បទ ជាប់ដោយបទ បំពេញបទ ប្រជុំនៃអក្ខរ: សម្រួលព្យញ្ជន: ពាក្យថា យ៉ាងនេះ នុ៎ះជាលំដាប់នៃបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ពាក្យជាទីគោរព ពាក្យប្រកបដោយសេចក្តីគោរព ពាក្យថា មានអាយុ នុ៎ះ ជាពាក្យប្រកបដោយសេចក្តីកោតក្រែង ។ ពាក្យថា តិស្ស: គឺជានាមការរាប់ ឈ្មោះ បញ្ញត្តិ វោហារ ជានាម អំពើរបស់នាម ពាក្យទ្រទ្រង់ទុកនូវនាម ភាសា ព្យញ្ជន: ការហៅរក នៃព្រះថេរ:នោះ ។

មេត្តេយ្យោតិ តស្ស ថេរស្ស គោត្តំ សង្ខ្យា សមញ្ញា
បញ្ញត្តិ ហោហោតិ ឥច្ចាយស្មា តិស្សោ មេត្តេយ្យោ ។

[២២៧] វិឃាតំ ព្រូហិ មារិសាតិ វិឃាតំ ឧបឃាតំ
បីឬ្ជនំ ឃដ្ដនំ ឧបទ្ទវំ ឧបសគ្គំ ព្រូហិ អាចិក្ខ ទេ-
សេហិ បញ្ញាបេហិ បដ្ឋបេហិ វិវរ វិភជ ឧត្តានីកហោហិ
បកាសេហិ ។ មារិសាតិ បិយវចនំ ឥសុវចនំ សគា-
រវវចនំ សប្បតិស្សវចនមេតំ មារិសាតិ វិឃាតំ ព្រូហិ
មារិស ។

[២២៨] សុត្វាន ឥវ សាសនន្តិ ឥមិ ១ យ-
ថ ២ ទេសនំ ១ អនុសិដ្ឋី ១ សុត្វា ១ សុណិត្វា ១ ឧគ្គហិត្វា ១ ឧប-
ធារយិត្វា ១ ឧបលក្ខយិត្វាតិ ១ សុត្វាន ១ ឥវ ១ សាសនំ ១ ។

[២២៩] វិវេកេ សិក្ខិ សាមសេតិ វិវេកោតិ ១ តយោ
វិវេកា ១ កាយវិវេកោ ១ ចិត្តវិវេកោ ១ ឧបធិវិវេកោ ១ ។

ពាក្យថា មេត្តេយ្យៈ គឺជាគោត្រ ការរាប់ ឈ្មោះ បញ្ញត្តិ រៀហារ របស់ព្រះថេរៈនោះ ហេតុនោះ (លោកពោល) ថា ព្រះតិស្សមេត្តេយ្យៈ មានអាយុ ក្រាបទូលយ៉ាងនេះ ។

[២២៧] ពាក្យថា បពិត្រព្រះអង្គទ្រង់និរទុក្ខ សូមព្រះអង្គពោល សេចក្តីចង្អៀតចង្អល់ សេចក្តីថា សូមព្រះអង្គពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែករលែក ធ្វើឲ្យរាក់ ប្រកាស នូវសេចក្តី ចង្អៀតចង្អល់ សេចក្តីតានតឹង សេចក្តីបៀតបៀន សេចក្តីលំបាក សេចក្តីឧបទ្រព សេចក្តីខ្ជាំងខ្ជាស់ ឲ្យទាន ។ ពាក្យថា បពិត្រព្រះ អង្គទ្រង់និរទុក្ខ នុ៎ះ គឺពាក្យជាទីស្រឡាញ់ ពាក្យជាទីគោរព ពាក្យប្រកប ដោយសេចក្តីគោរព ពាក្យថា ព្រះអង្គទ្រង់និរទុក្ខ នុ៎ះជាពាក្យប្រកប ដោយសេចក្តីកោតក្រែង ហេតុនោះ (លោកពោលថា) បពិត្រព្រះអង្គ ទ្រង់និរទុក្ខ សូមព្រះអង្គពោលសេចក្តីចង្អៀតចង្អល់ ។

[២២៨] ពាក្យថា ខ្ញុំស្តាប់ពាក្យប្រដៅរបស់ព្រះអង្គ គឺខ្ញុំស្តាប់ ត្រងត្រាប់ រៀន ចំណាំ កំណត់ នូវពាក្យ គន្ថៈនៃពាក្យ ទេសនា ការ ប្រៀនប្រដៅរបស់ព្រះអង្គ ហេតុនោះ (លោកពោលថា) ខ្ញុំស្តាប់ពាក្យ ប្រៀនប្រដៅរបស់ព្រះអង្គ ។

[២២៩] អធិប្បាយពាក្យថា សិក្សាក្នុងវិវេក ត្រង់ពាក្យថា វិវេក បានដល់ វិវេក ៣ គឺ កាយវិវេក ចិត្តវិវេក ឧបធិវិវេក ។

សត្តមោ តិស្សមេត្តេយ្យសុត្តនិទ្ទេសោ

កតមោ កាយវិវេកោ ។ ឥធ ភិក្ខុ រីតិ្តំ សេនាសនំ ភជតិ អរញ្ញं រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថं អព្ភោកាសំ បលាលបុញ្ជं កាយេន ច រីតោ វិហរតិ សោ ឯកោ គច្ឆតិ ឯកោ តិដ្ឋតិ ឯកោ និសីទតិ ឯកោ សេយ្យं កប្បេតិ ឯកោ គामं បិណ្ឌាយ បវិសតি ឯកោ បដិក្ក្រមតি ឯកោ រহো និសីদতি ឯកো চঙ্কমং অধিট্ঠাতি ឯកো ចរតি វិহরতি ឥរិយតি វត্ততি ចালেতি យপেতি যাপেতি អយំ កាយវិវেকো ។

កតមោ ចិត្តវិវেকো ។ បឋមំ ঝানং সমাপন্নস্স নীবরণেহি চিত্তং রীতং হোতি দুতিযং ঝানং সমাপন্নস্স বিতক্কবিচারেহি চিত্তং রীতং হোতি ততিযং ঝানং সমাপন্নস্স পীতিযা চিত্তং রীতং হোতি চতুত্থং ঝানং সমাপন্নস্স সুখদুক্খেহি চিত্তং রীতং হোতি আকাসানঞ্চাযতনং সমাপন্নস্স রূপসঞ্ঞায় পটিঘসঞ্ঞায় নানত্তসঞ্ঞায় চিত্তং রীতং হোতি বিঞ্ঞাণঞ্চাযতনং সমাপন্নস্স আকাসানঞ্চাযতনসঞ্ঞায়

កាយវិវេក តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ គប់រកសេនាស-ន:ស្ងាត់ គឺព្រៃ គល់ឈើ ភ្នំ ជ្រោះ គុហាក្នុងភ្នំ ព្រៃស្មសាន ព្រៃធំ ទីវាល គំនរចំបើង ជាអ្នកស្ងាត់ ដោយកាយ ភិក្ខុនោះ ដើរម្នាក់ឯង ឈរម្នាក់ឯង អង្គុយម្នាក់ឯង សម្រេចកិរិយាដេកម្នាក់ឯង ចូលទៅកាន់ស្រុកបិណ្ឌបាតម្នាក់ឯង ត្រឡប់មកវិញម្នាក់ឯង អង្គុយក្នុងទីស្ងាត់ម្នាក់ឯង អធិដ្ឋានចង្ក្រមម្នាក់ឯង ត្រាច់ទៅ នៅ សម្រេចឥរិយាបថ ប្រព្រឹត្តទៅ រក្សា រស់នៅ ញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅតែម្នាក់ឯងនេះ កាយវិវេក ។

ចិត្តវិវេក តើដូចម្តេច ។ ចិត្តរបស់ភិក្ខុអ្នកចូលបឋមជ្ឈាន ជាចិត្តស្ងាត់ចាកនីវរណៈ ចិត្តរបស់ភិក្ខុអ្នកចូលទុតិយជ្ឈាន ជាចិត្តស្ងាត់ចាកវិតក្ក:និងវិចារ: ចិត្តរបស់ភិក្ខុ អ្នកចូលតតិយជ្ឈាន ជាចិត្តស្ងាត់ចាកបីតិ ចិត្តរបស់ភិក្ខុ អ្នកចូលចតុត្ថជ្ឈាន ជាចិត្តស្ងាត់ចាកសុខនិងទុក្ខ ចិត្តរបស់ភិក្ខុ អ្នកចូលអាកាសានញ្ចាយតន: ជាចិត្តស្ងាត់ចាករូបសញ្ញា ចាកបដិឃសញ្ញា ចាកនានត្តសញ្ញា ចិត្តរបស់ភិក្ខុ អ្នកចូលវិញ្ញាណញ្ចាយតន: ជាចិត្តស្ងាត់ ចាកអាកាសានញ្ចាយតនសញ្ញា

ចិត្តំ ឋិតំ ហោតិ អាកិញ្ចញ្ញាយតនំ សមាបន្នស្ស
វិញ្ញាណញ្ចាយតនសញ្ញាយ ចិត្តំ ឋិតំ ហោតិ នេវ-
សញ្ញានាសញ្ញាយតនំ សមាបន្នស្ស អាកិញ្ចញ្ញាយ-
តនសញ្ញាយ ចិត្តំ ឋិតំ ហោតិ សោតាបន្នស្ស សក្កា-
យទិដ្ឋិយា វិចិកិច្ឆាយ សីលព្ពតបរាមាសា ទិដ្ឋានុ-
សយា វិចិកិច្ឆានុសយា តទេកដ្ឋេហិ ច កិលេ-
សេហិ ចិត្តំ ឋិតំ ហោតិ សកទាគាមិស្ស ឱឌ្ឍរិកា
កាមរាគសញ្ញោជនា បដិឃសញ្ញោជនា ឱឌ្ឍរិកា
កាមរាគានុសយា បដិឃានុសយា តទេកដ្ឋេហិ
ច កិលេសេហិ ចិត្តំ ឋិតំ ហោតិ អនាគាមិស្ស
អណុសហគតា កាមរាគសញ្ញោជនា បដិឃសញ្ញោ-
ជនា អណុសហគតា កាមរាគានុសយា បដិឃានុសយា
តទេកដ្ឋេហិ ច កិលេសេហិ ចិត្តំ ឋិតំ ហោតិ អរ-
ហតោ រូបរាគា អរូបរាគា មានា ឧទ្ធច្ចា អវិជ្ជាយ
មានានុសយា ភវរាគានុសយា អវិជ្ជានុសយា តទេ-
កដ្ឋេហិ ច កិលេសេហិ ពហិទ្ធា ច សព្ពនិមិត្តេហិ
ចិត្តំ ឋិតំ ហោតិ អយំ ចិត្តវិវេកោ ។

ចិត្តរបស់ភិក្ខុ អ្នកចូលអាកិញ្ចញ្ញាយតនៈ ជាចិត្តស្ងាត់ចាកវិញ្ញាណញ្ចាយតនសញ្ញា ចិត្តរបស់ភិក្ខុ អ្នកចូលនេវសញ្ញានាសញ្ញាយតនៈ ជាចិត្តស្ងាត់ចាកអាកិញ្ចញ្ញាយតនសញ្ញា ចិត្តរបស់ភិក្ខុអ្នកដល់សោតៈ ជាចិត្តស្ងាត់ចាកសក្កាយទិដ្ឋិ ចាកវិចិកិច្ឆា ចាកសីលព្វតបរាមាសៈ ចាកទិដ្ឋានុស័យ ចាកវិចិកិច្ឆានុស័យ ចាកកិលេសទាំងឡាយ ដែលតាំងនៅជាមួយគ្នានឹងសញ្ញោជនៈទាំងនោះ ចិត្តរបស់ភិក្ខុជាសកទាគামិ ជាចិត្តស្ងាត់ចាកកាមរាគសញ្ញោជនៈ ចាកបដិឃសញ្ញោជនៈ ដ៏គ្រាតគ្រាត ចាកកាមរាគានុស័យ ចាកបដិឃានុស័យ ដ៏គ្រាតគ្រាត ចាកកិលេសដែលតាំងនៅ ជាមួយនឹងសញ្ញោជនៈទាំងនោះ ចិត្តរបស់ភិក្ខុជាអនាគামি ជាចិត្តស្ងាត់ចាកកាមរាគសញ្ញោជនៈ និងបដិឃសញ្ញោជនៈ ដែលលាយឡំនៅដ៏ស្អិត ចាកកាមរាគានុស័យ ចាកបដិឃានុស័យ ដែលលាយឡំនៅដ៏ស្អិត ចាកកិលេសដែលតាំងនៅ ជាមួយនឹងសញ្ញោជនៈទាំងនោះ ចិត្តរបស់ភិក្ខុជាព្រះអរហន្ត ជាចិត្តស្ងាត់ចាករូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ ចាកកិលេសដែលតាំងនៅ ជាមួយនឹងសញ្ញោជនៈទាំងនោះ ចាកនិមិត្តទាំងពួងជាខាងក្រៅ នេះ ចិត្តវិវេក ។

សត្តមោ តិស្សមេត្តេយ្យសុត្តនិទ្ទេសោ

កតមោ ឧបធិវិវេកោ ។ ឧបធី រុច្ចន្តិ កិលេ-
សា ច ខន្ធា ច អភិសង្ខារា ច ។ ឧបធិវិវេកោ
រុច្ចតិ អមតំ និព្ពានំ យោ សោ សព្វសង្ខារសមថោ
សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ
និព្ពានំ អយំ ឧបធិវិវេកោ ។

កាយវិវេកោ ច រូបកដ្ឋកាយានំ[1] ឌេក្ខម្ម-
ភិរតានំ ចិត្តវិវេកោ ច បរិសុទ្ធចិត្តានំ បរមវោទាន-
ប្បត្តានំ ឧបធិវិវេកោ ច និរូបធីនំ បុគ្គលានំ វិសង្ខា-
រគតានំ ។

វិវេកេ សិក្ខិសាមសេតិ សោ ថេរោ បកតិយា
សិក្ខិតសិក្ខោ អបិច ធម្មទេសនំ យាចន្តោ[2] ឯវ-
មាហ វិវេកេ សិក្ខិសាមសេតិ ។ តេនាហ ថេរោ
តិស្សោ មេត្តេយ្យោ

មេថុនមនុយុត្តស្ស (ឥច្ចាយស្មា តិស្សោ មេត្តេយ្យោ)
ឱឃាតំ ព្រូហិ មារិស
សុត្វាន តវ សាសនំ
វិវេកេ សិក្ខិសាមសេតិ ។

---

១ ម. វិវេកដ្ឋកាយានំ ។ ២ ម. អបិច ធម្មទេសនំ ឧបាទាយ ធម្មទេសនំ សាវេន្តោ ។

ឧបធិវិវេក តើដូចម្តេច ។ កិលេស ខន្ធ និងអភិសង្ខារទាំងឡាយ លោកហៅថា ឧបធិ ។ អមតនិព្វាន លោកហៅថា ឧបធិវិវេក បានខាងការរម្ងាប់សង្ខារទាំងពួង ការរលាស់ចេញនូវឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ និព្វាន នេះ ឧបធិវិវេក ។

កាយវិវេក សម្រាប់អ្នកមានកាយគេចចេញ (ចាកពួក) អ្នកត្រេកអរចំពោះនេក្ខម្ម: ចិត្តវិវេក សម្រាប់អ្នកមានចិត្តបរិសុទ្ធ អ្នកដល់សេចក្តីផ្ទរផង់ដ៏ក្រៃលែង ឯឧបធិវិវេក សម្រាប់បុគ្គលមិនមានឧបធិ អ្នកដល់នូវវិសង្ខារ គឺព្រះនិព្វាន ។

ពាក្យថា សិក្សាក្នុងវិវេក គឺព្រះថេរៈនោះ មានសិក្ខាសិក្សាហើយដោយប្រក្រតី តែ លោកសូមធម្មទេសនា បានពោលយ៉ាងនេះថា នឹងសិក្សាក្នុងវិវេក ។ ហេតុនោះ ព្រះថេរៈឈ្មោះតិស្សមេត្តេយ្យ: ពោលថា

(ព្រះតិស្សមេត្តេយ្យ:មានអាយុក្រាបទូលយ៉ាងនេះថា) បពិត្រ
ព្រះអង្គទ្រង់និរទុក្ខ សូមព្រះអង្គពោលសេចក្តីចង្អៀតចង្អល់
របស់បុគ្គលដែលប្រកបរឿយ ៗ ក្នុងមេថុន យើងខ្ញុំស្តាប់
ពាក្យប្រដៅរបស់ព្រះអង្គហើយ នឹងសិក្សាក្នុងវិវេក ។

[២៣០] មេថុនមនុយុត្តស្ស (មេត្តេយ្យាតិ ភគវា)
មុស្សតេ វាបិ សាសនំ
មិច្ឆា ច បដិបជ្ជតិ
ឯតំ តស្មឹ អនារិយំ ។

[២៣១] មេថុនមនុយុត្តស្សាតិ មេថុនធម្មោ ជាមយោ សោ អសទ្ធម្មោ តាមធម្មោ រសលធម្មោ ឧដ្ឋណ្ណោ ឱធកន្តិកោ រហាស្សោ ទ្វយទ្វយសមាបត្តិ ។ កីការណា រុច្ចតិ មេថុនធម្មោ ។ ឧភិន្នំ រត្តានំ សារត្តានំ អវស្សុតានំ បរិយុដ្ឋិតានំ បរិយាទិន្នចិត្តានំ ឧភិន្នំ សនិសានំ ធម្មោតិ តំការណា រុច្ចតិ មេថុនធម្មោ ។ យថា ឧភោ កលហការកា មេថុនកាតិ រុច្ចន្តិ ឧភោ ភណ្ឌនការកា មេថុនកាតិ រុច្ចន្តិ ឧភោ ភស្សការកា មេថុនកាតិ រុច្ចន្តិ ឧភោ វិវាទការកា មេថុនកាតិ រុច្ចន្តិ ឧភោ អធិការណការកា មេថុនកាតិ រុច្ចន្តិ ឧភោ ភាឌិនោ មេថុនកាតិ រុច្ចន្តិ ឧភោ សល្ហាបកា មេថុនកាតិ រុច្ចន្តិ

[២៣០] (ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តេយ្យ:) សាសនារបស់បុគ្គលអ្នកប្រកបរឿយៗ ក្នុងមេថុនធម្ម រមែងវិនាសដោយពិត ទាំងបុគ្គលនោះ ក៏រមែងប្រតិបត្តិខុស អំពើនុ៎ះ មិនមែនជាអំពើប្រសើរ ចំពោះបុគ្គលនោះទេ ។

[២៣១] ពាក្យថា បុគ្គលអ្នកប្រកបរឿយៗ ក្នុងមេថុនធម្ម អធិប្បាយថា ឈ្មោះថា មេថុនធម្ម បានខាងធម៌របស់អសប្បុរស ធម៌របស់អ្នកស្រុក ធម៌របស់ជនថោកទាប ធម៌អាក្រក់ មានទឹកជាទីបំផុត ធម៌កើតក្នុងទីកំបាំង ការចូលជុំរបស់បុគ្គលពីរ ៗ នាក់ ។ ដែលលោកហៅថា មេថុនធម្ម តើព្រោះហេតុអ្វី ។ ធម៌របស់បុគ្គលពីរនាក់ ដែលត្រេកអរ ត្រេកអរខ្លាំង ជោក(ដោយរាគ:) រួបរឹត(ដោយរាគ:) មានចិត្តត្រូវកិលេសគ្របសង្កត់ស្មើគ្នាទាំងពីរនាក់ ព្រោះហេតុនោះ ទើបលោកហៅថា មេថុនធម្ម ដូច្នេះ ។ ជនពីរនាក់ធ្វើជម្ងោ: លោកហៅថា គូជម្ងោ: ជនពីរនាក់ធ្វើសេចក្តីប្រកួតប្រកាន់ លោកហៅថា គូប្រកួតប្រកាន់ ជនពីរនាក់ធ្វើការនិយាយគ្នា លោកហៅថា គូនិយាយគ្នា ជនពីរនាក់ធ្វើការជជែកគ្នា លោកហៅថា គូជជែកគ្នា ជនពីរនាក់ធ្វើអធិករណ៍ លោកហៅថា គូអធិករណ៍ ជនពីរនាក់ចរចាជាប្រក្រតី លោកហៅថា គូចរចា ជនពីរនាក់និយាយធ្វើយធ្វងគ្នា លោកហៅថា គូធ្វើយធ្វង យ៉ាងណា

ឯវមេវ ឧភិន្នំ រត្តានំ សារត្តានំ អវស្សុតានំ បរិយុដ្ឋិតានំ បរិយាទិន្នចិត្តានំ ឧភិន្នំ សនិសានំ ឆម្ហោតិ តំការណា រុច្ចតិ មេថុនធម្មោ ។ មេថុនមនុយុត្តស្សាតិ មេថុនធម្មេ យុត្តស្ស បយុត្តស្ស អាយុត្តស្ស សមាយុត្តស្ស តច្ចរិតស្ស តព្ភហុលស្ស តក្ករុកស្ស តន្និន្នស្ស តប្ភោណស្ស តប្ភារស្ស តទធិមុត្តស្ស តទាធិបតេយ្យស្សាតិ មេថុនមនុយុត្តស្ស ។ មេត្តេយ្យាតិ ភគវា តំ ថេរំ គោត្តេន អាលបតិ ។ ភគវាតិ ការណជ្ជិវចនំ ។ អបិច ភក្ខភោគេ ភគវា ។ ភក្ខោ ភោ សោ ភគវា ។ ភក្ខ មោ ហោ ភគវា ។ ភក្ខ មា ធោ ភគវា ។ ភក្ខ ធិ ជ្ជ ភគវា ។ ភក្ខ ភណ្ឌ ភោ ភគវា ។

ធម៌របស់បុគ្គលពីរនាក់ ដែលត្រេកអរ ត្រេកអរខ្លាំង ជោក (ដោយរាគ:) រួបរឹត (ដោយរាគ:) មានចិត្តត្រូវកិលេសគ្របសង្កត់ស្មើគ្នាទាំងពីរនាក់ ព្រោះហេតុនោះ ទើបលោកហៅថា មេថុនធម្ម យ៉ាងនោះដែរ ។ ពាក្យ ថា ប្រកបរឿយៗក្នុងមេថុន គឺប្រកប តាក់តែង ប្រជុំងប្រជា ប្រកបព្រម ក្នុងមេថុនធម្ម ប្រព្រឹត្តមេថុនធម្មនោះ ក្រាស់ដោយមេថុន-ធម្មនោះ គោរពមេថុនធម្មនោះ ខ្ជិនទៅក្នុងមេថុនធម្មនោះ ទោរទៅក្នុង មេថុនធម្មនោះ ឈមមុខទៅក្នុងមេថុនធម្មនោះ ចុះចិត្តស៊ីប់ក្នុងមេថុនធម្ម នោះ ធ្វើមេថុនធម្មនោះឲ្យជាធំ ហេតុនោះ(ទ្រង់ត្រាស់ថា) បុគ្គលអ្នកប្រ-កបរឿយៗក្នុងមេថុនធម្ម ។ ព្រះមានព្រះភាគ ត្រាស់ហៅព្រះថេរៈនោះ តាមគោត្រថា ម្នាលមេត្តេយ្យ: ។ ពាក្យថា ព្រះមានព្រះភាគ ជា ពាក្យពោលដោយគោរព ។ មួយទៀត ព្រះពុទ្ធ មានរាគ:បំបាក់បង់ ហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានទោស:បំបាក់ បង់ហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានមោហ:បំបាក់ បង់ហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានមានៈបំបាក់ បង់ហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានទិដ្ឋិបំបាក់ បង់ហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានបន្ទាគឺកិលេស បំបាក់បង់ហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។

ភគ្គក្កិលេសោតិ ភគវា ។ ភជិ វិភជិ បដិវិភជិ ធម្មរតនន្តិ ភគវា ។ ភវានំ អន្តករោតិ ភគវា ។ ភាវិតកាយោតិ ភគវា ។ ភាវិតសីលោ ភាវិតចិត្តោ ភាវិតប្បញ្ញោតិ ភគវា ។ ភជិ វា ភគវា អរញ្ញវន-បត្ថានិ បន្តានិ សេនាសនានិ អប្បសទ្ទានិ អប្បនិ-គ្ឃោសានិ វិជនវាតានិ មនុស្សរាហសេយ្យកានិ បដិ-សល្លានសារុប្បានីតិ ភគវា ។ ភាគី វា ភគវា ចីវរបិណ្ឌា-ចាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ភ-គវា ។ ភាគី វា ភគវា អត្ថរសស្ស ធម្មរសស្ស វិមុត្តិរសស្ស អធិសីលស្ស អធិចិត្តស្ស អធិប្បញ្ញាយាតិ ភគវា ។ ភាគី វា ភគវា ចតុន្នំ ឈានានំ ចតុន្នំ អប្បមញ្ញានំ ចតុន្នំ អរូបសមាបត្តីនន្តិ ភគវា ។ ភាគី វា ភគវា អដ្ឋន្នំ វិមោក្ខានំ អដ្ឋន្នំ អភិភាយតនានំ

មានកិលេសបំបាក់បង់ហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ ទ្រង់បែងចែក រំលែកធម្មរតន: ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ ជាអ្នកធ្វើនូវទីបំផុតនៃភព ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានព្រះកាយចម្រើនហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានសីលចម្រើនហើយ មានចិត្តចម្រើនហើយ មានប្រាជ្ញាចម្រើនហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ទ្រង់គប់រកសេនាសន:ស្ងាត់ គឺព្រៃតូច និងព្រៃធំ មិនមានសំឡេង មិនមានការគឹកកង ជាទីប្រាសចាកខ្យល់ដែលកើត អំពីកាយនៃជន ជាទីស្ងាត់កំបាំងរបស់មនុស្ស ជាទីសមគួរដល់ការពួនសម្ងំ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែកចីវរ បិណ្ឌបាត សេនាសន: និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែកអត្ថរស ធម្មរស វិមុត្តិរស អធិសីល អធិចិត្ត និងអធិប្បញ្ញា ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែកឈាន ៤ អប្បមញ្ញា ៤ អរូប-សមាបត្តិ ៤ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែកវិមោក្ខ ៨ អភិភាយតន: ៨

ធវន្នំ អនុបុព្វវិហារសមាបត្តីនន្តិ ភគវា ។ ភាគី វា ភគវា ទសន្នំ សញ្ញាភាវនានំ ទសន្នំ កសិណសមាបត្តីនំ អានាបានស្សតិសមាធិស្ស អសុភសមាបត្តិយាតិ ភគវា ។ ភាគី វា ភគវា ចតុន្នំ សតិប្បដ្ឋានានំ ចតុន្នំ សម្មប្បធានានំ ចតុន្នំ ឥទ្ធិបាទានំ បញ្ចន្នំ ឥន្ទ្រិយានំ បញ្ចន្នំ ពលានំ សត្តន្នំ ពោជ្ឈង្គានំ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្សាតិ ភគវា ។ ភាគី វា ភគវា ទសន្នំ តថាគតពលានំ ចតុន្នំ វេសារជ្ជានំ ចតុន្នំ បដិសម្ភិទានំ ឆន្នំ អភិញ្ញានំ ឆន្នំ ពុទ្ធធម្មានន្តិ ភគវា ។ ភគវាតិ នេតំ នាមំ មាតរា កតំ ន បិតរា កតំ ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន សមណព្រាហ្មណេហិ កតំ ន ទេវតាហិ កតំ វិមោក្ខន្តិកមេតំ ពុទ្ធានំ ភគវន្តានំ ពោធិយា មូលេ សហ សព្វញ្ញុតញ្ញាណស្ស បដិលាភា សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ មេត្តេយ្យាតិ ភគវា ។

អនុបុព្វវិហារសមាបត្តិ ៩ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែកសញ្ញាភាវនា ១០ កសិណសមាបត្តិ ១០ អានាបានស្សតិសមាធិ និងអសុភសមាបត្តិ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែកសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែកតថាគតពល ១០ វេសារជ្ជៈ ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ ធម៌របស់ព្រះពុទ្ធ ៦ យ៉ាង ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ ព្រះនាមថាមានព្រះភាគ នុ៎ះ មិនមែនព្រះមាតាធ្វើ មិនមែនព្រះបិតាធ្វើ មិនមែនបងប្អូនប្រុសធ្វើ មិនមែនបងប្អូនស្រីធ្វើ មិនមែនមិត្រនិងអាមាត្យធ្វើ មិនមែនញាតិសាលោហិតធ្វើ មិនមែនសមណៈនិងព្រាហ្មណ៍ធ្វើ មិនមែនទេវតាធ្វើទេ (ព្រះនាមថា មានព្រះភាគ) នុ៎ះ របស់ព្រះពុទ្ធទាំងឡាយមានព្រះភាគ ជាព្រះនាមកើតក្នុងទីបំផុតវិមោក្ខ គឺសេចក្តីបញ្ញត្តថា មានព្រះភាគនេះ (កើត) អំពីការបានត្រាស់ ដំណាលគ្នានឹងការបានចំពោះសព្វញ្ញុតញ្ញាណទៀបគល់ពោធិព្រឹក្ស ហេតុនោះ (លោកពោលថា) ព្រះមានព្រះភាគ ត្រាស់ថា ម្នាលមេត្តេយ្យៈ ។

[២៣២] មុស្ឍតេ ភាបិ សាសនន្តិ ទ្វីហិ ការ-ណេហិ សាសនំ មុស្ឍតិ បរិយត្តិសាសនម្ឪ មុស្ឍតិ បដិបត្តិសាសនម្ឪ មុស្ឍតិ ។

កតមំ បរិយត្តិសាសនំ ។ យំ តស្ស បរិយា-បុដំ សុត្តំ គេយ្យំ វេយ្យាការណំ គាថា ឧទានំ ឥតិ-វុត្តកំ ជាតកំ អព្ភូតធម្មំ វេទល្លំ ឥទំ បរិយត្តិសា-សនំ ។ តម្ឪ មុស្ឍតិ បរិមុស្ឍតិ បរិពាហិរេ ហោតី-តិ ឯវម្ឪ មុស្ឍតេ ភាបិ សាសនំ ។

កតមំ បដិបត្តិសាសនំ ។ សម្មាបដិបទា អនុ-លោមប្ឪដិបទា អប្ឪចូនិកប្ឪដិបទា អនូត្តប្ឪដិបទា ធម្មានុធម្មប្ឪដិបទា សីលេសុ បរិបូរិការិតា ឥន្ទ្រិយេ-សុ គុត្តទ្វារតា ភោជនេ មត្តញ្ញុតា ជាគរិយានុយោ-គោ សតិសម្ឪជញ្ញ ចត្តារោ សតិប្ឪដ្ឋានា ចត្តារោ សម្ផ្ឪប្ឪធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ឥទំ បដិបត្តិសាសនំ ។ តម្ឪ មុស្ឍតិ បរិមុស្ឍតি[1] បដិពាហិរេ ហោតីតិ ឯវម្ឪ មុស្ឍតេ ភាបិ សាសនំ ។

---

១ ម. សំមុស្ឍតិ បមុស្ឍតិ សំបមុស្ឍតិ ។

[២៣២] ពាក្យថា សាសនា វិនាស បានដល់សាសនាវិនាស ដោយហេតុ ២ គឺ បរិយត្តិសាសនា ក៏វិនាស បដិបត្តិសាសនា ក៏វិនាស ។

បរិយត្តិសាសនា តើដូចម្តេច ។ ពុទ្ធវចនៈណាគឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ ដែលបុគ្គលនោះរៀនហើយ នេះបរិយត្តិសាសនា ។ បរិយត្តិសាសនាវិនាស បាត់បង់ទៅ (បុគ្គលនោះ) ទៅជាបុគ្គលខាងក្រៅ ហេតុនោះ (ទ្រង់ត្រាស់ថា) សាសនាវិនាស យ៉ាងនេះខ្លះ ។

បដិបត្តិសាសនា តើដូចម្តេច ។ សេចក្តីប្រតិបត្តិដោយប្រពៃ សេចក្តីប្រតិបត្តិដ៏សមគួរ សេចក្តីប្រតិបត្តិមិនជាសឹកសត្រូវ សេចក្តីប្រតិបត្តិចំពោះប្រយោជន៍តាមលំដាប់ សេចក្តីប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ភាពបុគ្គលអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ភាពបុគ្គលមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ ភាពបុគ្គលអ្នកដឹងប្រមាណក្នុងភោជន សេចក្តីប្រកបរឿយៗ ក្នុងការភ្ញាក់រលឹក សតិនិងសម្បជញ្ញៈ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ នេះបដិបត្តិសាសនា ។ បដិបត្តិសាសនានោះ រមែងវិនាស បាត់បង់ទៅ (បុគ្គលនោះ) ទៅជាបុគ្គលខាងក្រៅ ហេតុនោះ (ទ្រង់ត្រាស់ថា) សាសនាវិនាស យ៉ាងនេះខ្លះ ។

សត្តមោ តិស្សមេត្តេយ្យសុត្តនិទ្ទេសោ

[២៣៣] មិច្ឆា ច បដិបជ្ជតីតិ ចាណម្បិ ហនតិ អទិន្នម្បិ អាទិយតិ សន្ធិម្បិ ឆិន្ទតិ ជិណ្ណម្បិ ហរតិ ឯកាគារិកម្បិ ឃាតេតិ បរិបន្ថេបិ តិដ្ឋតិ បរទារម្បិ គច្ឆតិ មុសាបិ ភណតីតិ មិច្ឆា ច បដិបជ្ជតិ ។

[២៣៤] ឯតំ តស្មឹ អនារិយន្តិ ឯតំ តស្មឹ បុគ្គលេ អនរិយធម្មោ ពាលធម្មោ មូឡ្ហធម្មោ អញ្ញាណធម្មោ អមការិកេ្ខ្ចបធម្មោ យទិទំ មិច្ឆា បដិបជ្ជតិ ឯតំ តស្មឹ អនារិយំ ។ តេនាហ ភគវា

មេថុនមនុយុត្តស្ស (មេត្តេយ្យាតិ ភគវា)
មុស្សតេ វាបិ សាសនំ
មិច្ឆា ច បដិបជ្ជតិ
ឯតំ តស្មឹ អនារិយន្តិ ។

[២៣៥] ឯកោ បុព្វេ ចរិត្វាន
មេថុនំ យោ និសេវតិ
យានំ ភន្តំ វ តំ លោកេ
ហីនមាហុ បុថុជ្ជនំ ។

[២៣៣] ពាក្យថា រមែងប្រតិបត្តិខុស គឺបុគ្គលសម្ងាប់សត្វខ្លះ កាន់យកទ្រព្យដែលគេមិនបានឲ្យខ្លះ កាត់ទី-តខ្លះ វាយប្រហារ ទាំងប្លន់ជំខ្លះ ធ្វើការបៀតបៀនទ្រព្យក្នុងផ្ទះមួយខ្លះ ចាំនៅកែ្បរផ្ទះរឹបជាន់ខ្លះ គប់រកប្រពន្ធបុគ្គលដទៃខ្លះ ពោលកុហកខ្លះ ហេតុនោះ (ទ្រង់ត្រាស់ថា) រមែងប្រតិបត្តិខុស ។

[២៣៤] ពាក្យថា អំពើនុ៎ះ មិនមែនជាអំពើប្រសើរ ចំពោះបុគ្គលនោះទេ គឺ អំពើនុ៎ះ ជាធម៌មិនប្រសើរ ជាធម៌របស់បុគ្គលពាល ជាធម៌របស់បុគ្គលលួងខ្ចៅ ជាធម៌របស់បុគ្គលមិនមានបញ្ញា ជាធម៌របស់បុគ្គលបោះទៅនូវពាក្យមិនឲ្យស្ងាប់សម្តី គឺជាសេចក្តីប្រតិបត្តិខុស ចំពោះបុគ្គលនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) អំពើនុ៎ះមិនមែនជាអំពើប្រសើរ ក្នុងបុគ្គលនោះទេ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

(ព្រះមានព្រះភាគ ត្រាស់ថា ម្នាលមេត្តេយ្យ:) សាសនារបស់បុគ្គលអ្នកប្រកបរឿយៗ ក្នុងមេថុនធម្ម រមែងវិនាសទៅដោយពិត ទាំងបុគ្គលនោះ ក៏រមែងប្រតិបត្តិខុស អំពើនុ៎ះ មិនមែនជាអំពើប្រសើរ ចំពោះបុគ្គលនោះទេ ។

[២៣៥] បុគ្គលណា ប្រព្រឹត្តម្នាក់ឯងក្នុងកាលមុន ហើយសេពមេថុនធម្ម អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះថាជាបុថុជ្ជនថោកទាប ក្នុងលោក ដូចជាយានដែលកូ្ចកហើយ ។

[២៣៦] ឯកោ បុព្វេ ចរិត្វានាតិ ទ្វីហិ ការ-ណេហិ ឯកោ បុព្វេ ចរិត្វាន បព្វជ្ជាសង្ខាតេន វា គណាវវស្សគ្គដ្ឋេន វា ។

កថំ បព្វជ្ជាសង្ខាតេន ឯកោ បុព្វេ ចរិត្វាន ។ សព្វំ ឃរាវាសបលិពោធំ ឆិន្ទិត្វា បុត្តទារបលិពោធំ ឆិន្ទិត្វា ញាតិបលិពោធំ ឆិន្ទិត្វា មិត្តាមច្ចបលិពោធំ ឆិន្ទិត្វា សន្និធិបលិពោធំ ឆិន្ទិត្វា កេសមស្សុំ ឱហា-រេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អន-គារិយំ បព្វជិត្វា អាកិញ្ចនភាវំ ឧបគន្ត្វា ឯកោ ចរតិ វិហរតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតិ ឯវំ បព្វជ្ជាសង្ខាតេន ឯកោ បុព្វេ ចរិត្វាន ។

កថំ គណាវវស្សគ្គដ្ឋេន ឯកោ បុព្វេ ចរិត្វា-ន ។ សោ ឯវំ បព្វជិតោ សមានោ ឯកោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនិ បដិសេវតិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហសេយ្យកានិ បដិសល្លានសារុប្បានិ ។

[២៣៦] ពាក្យថា ប្រព្រឹត្តម្នាក់ឯង ក្នុងកាលមុន អធិប្បាយថា បុគ្គលប្រព្រឹត្តម្នាក់ឯង ក្នុងកាលមុន ដោយហេតុ ២ គឺ ដោយចំណែកបព្វជ្ជា ឬដោយការលះបង់ពួក ។

បុគ្គលប្រព្រឹត្តម្នាក់ឯង ក្នុងកាលមុន ដោយចំណែកបព្វជ្ជា តើដូចម្តេច ។ បុគ្គលកាត់បង់កង្វល់ គឺយរាវាសទាំងអស់ កាត់បង់កង្វល់ គឺបុត្តភរិយា កាត់បង់កង្វល់ គឺញាតិ កាត់បង់កង្វល់គឺមិត្តនិងអាមាត្យ កាត់បង់កង្វល់ គឺការសន្សំ ការសក់និងពុកមាត់ ស្លៀកដណ្តប់សំពត់ដែលជ្រលក់ដោយទឹកចត់ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ដល់នូវភាពជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ត្រាច់ទៅ សម្រាក សម្រាន្ត សម្រេចឥរិយាបថ ប្រព្រឹត្តទៅ រក្សា រស់នៅ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅតែម្នាក់ឯង បុគ្គលប្រព្រឹត្តម្នាក់ឯង ក្នុងកាលមុន ដោយចំណែកបព្វជ្ជា យ៉ាងនេះ ។

បុគ្គលប្រព្រឹត្តម្នាក់ឯង ក្នុងកាលមុន ដោយការលះបង់ពួក តើដូចម្តេច ។ បុគ្គលនោះ លុះបួសយ៉ាងនេះហើយ ជាបុគ្គលម្នាក់ឯងតែងគប់រកសេនាសនៈស្ងាត់ គឺព្រៃតូចនិងព្រៃធំ មិនមានសំឡេង មិនមានការគឹកកង ជាទីប្រាសចាកខ្យល់ ដែលកើតអំពីកាយនៃជន ជាទីស្ងាត់កំបាំង របស់មនុស្ស សមគួរដល់ការពួនសម្ងំ ។

សោ ឯកោ គច្ឆតិ ឯកោ តិដ្ឋតិ ឯកោ និសីទតិ ឯកោ សេយ្យំ កប្បេតិ ឯកោ គាមំ បិណ្ឌាយ បវិសតិ ឯកោ បដិក្កមតិ ឯកោ រហោ និសីទតិ ឯកោ ចង្កមំ អធិដ្ឋាតិ ឯកោ ចរតិ វិហរតិ ឥរិយតិ វត្តតិ ចាលេតិ យបេតិ យាបេតិ ឯវំ គណាវាសេ-ក្ខេន ឯកោ បុព្វេ ចរិត្វាន ។

[២៣៧] មេថុនំ យោ និសេវតីតិ មេថុនធម្មោ នាម យោ សោ អសទ្ធម្មោ ។ បេ ។ តំការណា វុច្ចតិ មេថុនធម្មោ ។ មេថុនំ យោ និសេវតីតិ សោ អបរេន សមយេន ពុទ្ធំ ធម្មំ សង្ឆំ សិក្ខំ បច្ច-ក្ខាយ ហីនាយាវត្តិត្វា មេថុនធម្មំ សេវតិ និសេវតិ សំសេវតិ បដិសេវតីតិ មេថុនំ យោ និសេវតិ ។

[២៣៨] យានំ ភន្តំ តំ លោកេតិ យានន្តិ ហត្ថិយានំ អស្សយានំ គោយានំ អជយានំ

បុគ្គលនោះ ដើរតែម្នាក់ឯង ឈរតែម្នាក់ឯង អង្គុយតែម្នាក់ឯង សម្រេចការដេកតែម្នាក់ឯង ចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាតតែម្នាក់ឯង ត្រឡប់មកវិញតែម្នាក់ឯង អង្គុយក្នុងទីស្ងាត់តែម្នាក់ឯង អធិដ្ឋានចង្ក្រមតែម្នាក់ឯង ត្រាច់ទៅ សម្រាក សម្រាន្ត សម្រេចឥរិយាបថ ប្រព្រឹត្តទៅ រក្សា រស់នៅ ញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅតែម្នាក់ឯង បុគ្គលប្រព្រឹត្តតែម្នាក់ឯង ក្នុងកាលមុនដោយការលះបង់ពួក យ៉ាងនេះ ។

[២៣៧] អធិប្បាយពាក្យថា បុគ្គលណា សេពមេថុនធម្ម ឈ្មោះថា មេថុនធម្ម បានខាង ធម៌របស់អសប្បុរស ។ បេ ។ ព្រោះហេតុនោះ ទើបលោកហៅថា មេថុនធម្ម ។ ពាក្យថា បុគ្គលណា សេពមេថុនធម្ម បានសេចក្ដីថា បុគ្គលនោះ ពោលលាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឆ និងសិក្ខា ត្រឡប់ដើម្បីកាពជាបុគ្គលថោកទាប ហើយគប់រក សេពគប់ សេពសម្ពព សេពចំពោះមេថុនធម្ម ក្នុងសម័យដទៃ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលណា សេពមេថុនធម្ម ។

[២៣៨] អធិប្បាយពាក្យថា ដូចជាយានដែលភ្ជួរហើយ ក្នុងលោក ត្រង់ពាក្យថា យាន គឺ យានទឹម ដោយដំរី យានទឹម ដោយសេះ យានទឹម ដោយគោ យានទឹម ដោយពពែ

មេណ្ឌកយានំ ឱដ្ឋយានំ ខរយានំ ភគ្គំ អភគ្គំ អការិតំ អវិជីតំ ឧប្បថំ គណ្ហាតិ វិសមំ ខាណុម្បិ បាសាណម្បិ អភិរូហតិ[១] អាពេហាកម្បិ ភញ្ជតិ បបាតេបិ បបតតិ ។ យថា តំ ភគ្គំ យានំ អភគ្គំ អការិតំ អវិជីតំ ឧប្បថំ គណ្ហាតិ ឯវមេវ សោ វិព្ភន្តកោ ភគ្គយានប្បដិភាគោ ឧប្បថំ គណ្ហាតិ មិច្ឆាទិដ្ឋឹ គណ្ហាតិ ។ បេ ។ មិច្ឆាសមាធឹ គណ្ហាតិ ។ យថា តំ ភគ្គំ យានំ អភគ្គំ អការិតំ អវិជីតំ វិសមំ ខាណុម្បិ បាសាណម្បិ អភិរូហតិ ឯវមេវ សោ វិព្ភន្តកោ ភគ្គយានប្បដិភាគោ វិសមំ កាយកម្មំ អភិរូហតិ វិសមំ វចីកម្មំ អភិរូហតិ វិសមំ មនោកម្មំ អភិរូហតិ វិសមំ បាណាតិបាតំ អភិរូហតិ វិសមំ អទិន្នាទានំ អភិរូហតិ វិសមំ កាមេសុ មិច្ឆាចារំ អភិរូហតិ វិសមំ មុសាវាទំ អភិរូហតិ វិសមំ បិសុណំ វាចំ អភិរូហតិ វិសមំ ផរុសំ វាចំ អភិរូហតិ វិសមំ សម្ផប្បលាបំ អភិរូហតិ វិសមំ អភិជ្ឈំ អភិរូហតិ វិសមំ ព្យាបាទំ អភិរូហតិ វិសមំ មិច្ឆាទិដ្ឋឹ អភិរូហតិ

---

១ ឱ. ម. ឯត្ថន្តរេ យានម្បីតិ អត្ថិ ។

យានទឹមដោយចៀម យានទឹមដោយឱ្ឋ យានទឹមដោយលា ជាយានក្ងូកហើយ ដែលគេមិនបានទូន្មាន មិនបានធ្វើ មិនបានបង្ហាត់ រមែងកាន់យកផ្លូវខុស ឡើងកាន់ទីមានដង្គត់ និងថ្ម រដិបរដុបខ្លះ កិនជនអ្នកបរខ្លះ ក្ងូកជ្ងាក់ទៅក្នុងជ្រោះខ្លះ ។ យានក្ងូកហើយ ដែលគេមិនបានទូន្មាន មិនបានធ្វើ មិនបានបង្ហាត់នោះ រមែងកាន់យកផ្លូវខុស យ៉ាងណា បុគ្គលជាអ្នកភ្ងាត់នោះ (សឹក) ប្រៀបដោយយានក្ងូកហើយ រមែងកាន់យកផ្លូវខុស គឺកាន់យកទិដ្ឋិខុស ។ បេ ។ កាន់យកសមាធិខុស យ៉ាងនោះដែរ ។ យានក្ងូកហើយ ដែលគេមិនបានទូន្មាន មិនបានធ្វើ មិនបានបង្ហាត់នោះ រមែងឡើងកាន់ទីមានដង្គត់ និងថ្ម រដិបរដុប យ៉ាងណា បុគ្គលអ្នកភ្ងាត់នោះ ប្រៀបដោយយានក្ងូកហើយ រមែងឡើងកាន់កាយកម្មមិនស្មើ ឡើងកាន់វចីកម្មមិនស្មើ ឡើងកាន់មនោកម្មមិនស្មើ ឡើងកាន់បាណាតិបាតមិនស្មើ ឡើងកាន់អទិន្នាទានមិនស្មើ ឡើងកាន់កាមេសុមិច្ឆាចារមិនស្មើ ឡើងកាន់មុសាវាទមិនស្មើ ឡើងកាន់បិសុណាវាចាមិនស្មើ ឡើងកាន់ផរុសវាចាមិនស្មើ ឡើងកាន់សម្ផប្បលាប:មិនស្មើ ឡើងកាន់អភិជ្ឌាមិនស្មើ ឡើងកាន់ព្យាបាទមិនស្មើ ឡើងកាន់មិច្ឆាទិដ្ឋិមិនស្មើ

វិសមេ សង្ខារេ អភិរូហតិ វិសមេ បញ្ច កាមគុណេ អភិរូហតិ វិសមេ នីវរណេ អភិរូហតិ ។ យថា តំ ភន្តំ យានំ អនន្តំ អកាវិតំ អវិនីតំ អាពេហកម្ប្យ ភញ្ជតិ ឯវមេវ សោ វិញ្ញូតោ ភន្តយានប្ប្ដិកាតោ ជិរយេ អត្ដានំ ភញ្ជតិ តិរច្ឆានយោនិយា អត្ដានំ ភញ្ជតិ បិត្ដិវិសយេ អត្ដានំ ភញ្ជតិ មនុស្ស្ដលោកេ អត្ដានំ ភញ្ជតិ ទេវលោកេ អត្ដានំ ភញ្ជតិ ។ យថា តំ ភន្តំ យានំ អនន្តំ អកាវិតំ អវិនីតំ បចាតេបិ បបតតិ ឯវមេវ សោ វិញ្ញូតោ ភន្តយានប្ប្ដិកាតោ ជាតិបចាតម្ហិបិ បបតតិ ជរាបចាតម្ហិបិ បបតតិ ព្យា-ធិបចាតម្ហិបិ បបតតិ មរណបចាតម្ហិបិ បបតតិ សោក-បរិទេវទុក្ខទោមនស្ស្ដុចាយាសបចាតម្ហិបិ បបតតិ ។ លោកេតិ អចាយលោកេ ។ បេ ។ មនុស្ស្ដលោ-កេតិ យានំ ភន្តំ តំ លោកេ ។

[២៣៩] ហីនមាហុ បុថុជ្ជនន្ដិ បុថុជ្ជនាតិ កេនត្ដ-ន បុថុជ្ជនា ។ បុថុ កិលេសេ ជនេន្ដីតិ បុថុជ្ជនា ។

ឡើងកាន់សង្ខារទាំងឡាយមិនស្មើ ឡើងកាន់កាមគុណ ៥ មិនស្មើ ឡើងកាន់នីវរណៈទាំងឡាយមិនស្មើ យ៉ាងនោះដែរ ។ យានភ្ជុកហើយ ដែលគេមិនបានទូន្មាន មិនបានធ្វើ មិនបានបង្ហាត់នោះ រមែងកិនជនអ្នកបរ យ៉ាងណា បុគ្គលអ្នកភ្ជាត់នោះ ប្រៀបដោយយានភ្ជុកហើយ រមែងកិនខ្ជួនក្នុងនរក កិនខ្ជួនក្នុងកំណើតតិរច្ឆាន កិនខ្ជួនក្នុងបិត្តិវិស័យ កិនខ្ជួនក្នុងមនុស្សលោក កិនខ្ជួនក្នុងទេវលោក យ៉ាងនោះដែរ ។ យានភ្ជុកហើយ ដែលគេមិនបានទូន្មាន មិនបានធ្វើ មិនបានបង្ហាត់នោះ រមែងភ្ជុកធ្លាក់ទៅក្នុងជ្រោះ យ៉ាងណា បុគ្គលអ្នកភ្ជាត់នោះ ប្រៀបដោយយានភ្ជុកហើយ រមែងធ្លាក់ចុះក្នុងជ្រោះ គឺជាតិខ្ជះ ធ្លាក់ចុះក្នុងជ្រោះគឺជរាខ្ជះ ធ្លាក់ចុះក្នុងជ្រោះគឺព្យាធិខ្ជះ ធ្លាក់ចុះក្នុងជ្រោះគឺមរណៈខ្ជះ ធ្លាក់ចុះក្នុងជ្រោះគឺសោកៈ សោកៈ ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ខ្ជះ យ៉ាងនោះដែរ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។ បេ ។ ក្នុងមនុស្សលោក ហេតុនោះ (ទ្រង់ត្រាស់ថា) ដូចជាយាន ដែលភ្ជុកហើយ ក្នុងលោក ។

[២៣៩] អធិប្បាយពាក្យថា អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះថាជាបុថុជ្ជន ថោកទាប ត្រង់ពាក្យថា បុថុជ្ជន គឺឈ្មោះថាបុថុជ្ជន ដោយសេចក្ដីដូចម្ដេច ។ ឈ្មោះថាបុថុជ្ជន ព្រោះញ៉ាំងកិលេសក្រាស់ឲ្យកើត ។

បុថុ អវិហតសក្កាយទិដ្ឋិកាតិ បុថុជ្ជនា ។ បុថុ សត្ថារានំ មុខុល្លោកិកាតិ បុថុជ្ជនា ។ បុថុ សព្វ-គតីហិ អវុដ្ឋាតិ បុថុជ្ជនា ។ បុថុ នានាភិសង្ខារេហិ អភិ-សង្ខរោន្តីតិ បុថុជ្ជនា ។ បុថុ នានាឱឃេហិ វុយ្ហន្តីតិ បុថុជ្ជនា ។ បុថុ នានាសន្តាបេហិ សន្តប្បន្តីតិ បុថុជ្ជនា ។ បុថុ នានាបរិឡាហេហិ បរិឌយ្ហន្តីតិ បុថុជ្ជនា ។ បុថុ បញ្ចសុ កាមគុណេសុ រត្តា គិទ្ធា គធិតា មុច្ឆិតា អជ្ឈោបន្នា លគ្គា លគ្គិតា បលិ-ពុទ្ធាតិ បុថុជ្ជនា ។ បុថុ បញ្ចហិ នីវរណេហិ អាវុដា និវុដា ឱផុដា បិហិតា បដិច្ឆន្នា បដិកុជ្ជិតាតិ បុថុជ្ជនា ។ ហីនមាហុ បុថុជ្ជនត្តិ បុថុជ្ជនំ ហីនំ និហីនំ ឱមកំ លាមកំ ឆតុក្កំ បរិត្តន្តិ ឯវមាហុ ឯវ-មាហំសុ ឯវំ កថេន្តិ ឯវំ ភណន្តិ ឯវំ ទីបយន្តិ ឯវំ វោហរន្តីតិ ហីនមាហុ បុថុជ្ជនំ ។ តេជាហា ភគវា

ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកមានសក្កាយទិដ្ឋិដ៏ក្រាស់មិនទាន់លះបង់ ។ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកពោលប្ដេជ្ញា ចំពោះមុខសាស្ដាទាំងឡាយ ច្រើន ។ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកត្រូវគតិទាំងពួងដ៏ក្រាស់ចាក់ស្រែះ ។ ឈ្មោះថា បុថុជ្ជន ព្រោះតាក់តែងដោយអកិសង្ខារផ្សេងៗ ដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រូវឱ្ឃ:ផ្សេងៗ ដ៏ក្រាស់បន្សាត់ទៅ ។ ឈ្មោះថា បុថុជ្ជន ព្រោះក្ដៅក្រហាយ ដោយកម្ដៅផ្សេងៗ ដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះរោលរាលដោយកម្ដៅរោលរាលផ្សេងៗដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រេកអរ ញ៉ាម ជាប់ចិត្ត ជ្រប់ ងល់ងប់ ជាប់ចំពាក់ ចាក់ស្រែះ រួបរឹតក្នុងកាមគុណ ៥ ដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រូវនីវរណៈ ៥ ដ៏ក្រាស់ ចាក់ស្រែះ រួបរឹត គ្របសង្កត់ សន្ធប់ បិទបាំង សណ្ដំជាប់ ។ ពាក្យថា អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះ ថាជាបុថុជ្ជនថោកទាប គឺ អ្នកប្រាជ្ញទាំងឡាយ ពោលយ៉ាងនេះ បានពោលហើយយ៉ាងនេះ សម្ដែងយ៉ាងនេះ និយាយយ៉ាងនេះ បំភ្ញីយ៉ាងនេះ បញ្ជេញយ៉ាងនេះ នូវបុគ្គលនោះ ថាជាមនុស្សបុថុជ្ជនថោកទាប ទន់ថយ ជ្រោកជ្រាក លាមក អាក្រក់ រំកាច់រំកោច ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកប្រាជ្ញទាំងឡាយ ពោលនូវបុគ្គលនោះ ថាជាបុថុជ្ជន ថោកទាប ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ឯកោ បុព្វេ ចរិត្វាន មេថុនំ យោ និសេវតិ
យានំ ភន្តំ តំ លោកេ ហីនមាហុ បុថុជ្ជនន្តិ ។

[២៤០] យសោ កិត្តី ច យា បុព្វេ ហាយតេ ភាបិ តស្ស សា
ឯតម្ប្យ ជិស្វា សិក្ខេថ មេថុនំ វិប្ប្ហាតវ ។

[២៤១] យសោ កិត្តី ច យា បុព្វេ ហាយតេ ភាបិ តស្ស សាតិ ភតមោ យសោ ។ ឥធេកច្ចោ បុព្វេ សមណាភាវ សក្ខ្ហតោ ហោតិ ភរុភតោ មានិតោ ឫជិតោ អបចិតោ លាភី ចីវរបិណ្ឌ្ហបាតសេនាសន-ភិលានប្ប្ចយភេសជ្ជបរិក្ខ្ហារនំ អយំ យសោ ។ ភតមា ភិត្តិ ។ ឥធេកច្ចោ បុព្វេ សមណាភាវ ភិត្តិវណ្ណ្ហភតោ ហោតិ បណ្ឌ្ហិតោ វ្យត្តោ មេ-ធាវី ពហុស្ស្ហុតោ ចិត្តកថី ភលាណប្ប្ដិ-ភាណោ សុត្តន្ដ្ដិភោតិ ភ វ្ដ្ដ្ដ្ដ ភ

បុគ្គលណា ប្រព្រឹត្តតែម្នាក់ឯង ក្នុងកាលមុន ហើយសេពមេថុនធម្ម អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះ ថាជាបុថុជ្ជន ថោកទាប ក្នុងលោក ដូចជាយានដែលក្ងូកហើយ ។

[២៦០] *យសនិងកេរ្តិ៍ឈ្មោះណា (ធ្លាប់មាន) ក្នុងកាលមុន យសនិងកេរ្តិ៍ឈ្មោះនោះ របស់បុគ្គលនោះ ក៏សាបសូន្យទៅ បព្វជិតឃើញនូវដំណើរនុ៎ះហើយ គប្បីសិក្សា ដើម្បីលះបង់មេថុនធម្ម ។*

[២៦១] *ពាក្យថា យសនិងកេរ្តិ៍ឈ្មោះ ណា ធ្លាប់មាន ក្នុងកាលមុន យសនិងកេរ្តិ៍ឈ្មោះនោះ របស់បុគ្គលនោះ រមែងសាបសូន្យទៅ មានសេចក្តីអធិប្បាយដូចតទៅនេះ ចុះយស តើដូចម្តេច ។ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកដែលគេធ្វើសក្ការ: គោរព រាប់អាន បូជា កោតក្រែង ជាអ្នកបានចីវរ បិណ្ឌបាត សេនាសន: និងគិលានប្បច្ចយ-ភេសជ្ជបរិក្ខារ ក្នុងភាពជាសមណ:ក្នុងកាលមុន នេះ ឈ្មោះថា យស ។ ចុះកេរ្តិ៍ឈ្មោះ តើដូចម្តេច ។ បុគ្គលពួកខ្លះក្នុងលោកនេះ កាលនៅក្នុងភាពជាសមណ:ក្នុងកាលមុន ជាអ្នកពេញដោយកេរ្តិ៍ឈ្មោះ និងសេចក្តីសរសើរ ជាបណ្ឌិត រ៉ាងវៃ មានប្រាជ្ញា ជាពហុស្សូត មានពាក្យដ៏វិចិត្រ មានប្រាជ្ញាល្អ ជាអ្នកទ្រទ្រង់ព្រះសូត្រក្តី ជាអ្នកទ្រទ្រង់វិន័យក្តី*

ធម្មកថិកោតិ វា អារញ្ញិកោតិ វា បិណ្ឌចារិកោតិ
វា បំសុកូលិកោតិ វា តេចីវរិកោតិ វា សបទាន-
ចារិកោតិ វា ខលុបច្ឆាភត្តិកោតិ វា នេសជ្ជិកោ-
តិ វា យថាសន្ថតិកោតិ វា បឋមស្ស ឈានស្ស
លាភីតិ វា ទុតិយស្ស ឈានស្ស លាភីតិ វា តតិ-
យស្ស ឈានស្ស លាភីតិ វា ចតុត្ថស្ស ឈានស្ស
លាភីតិ វា អាកាសានញ្ចាយតនសមាបត្តិយា លាភី-
តិ វា វិញ្ញាណញ្ចាយតនសមាបត្តិយា លាភីតិ វា
អាកិញ្ចញ្ញាយតនសមាបត្តិយា លាភីតិ វា នេវស-
ញ្ញានាសញ្ញាយតនសមាបត្តិយា លាភីតិ វា អយំ
កិត្តិ ។ យសោ កិត្តី ច យា បុព្វេ ហាយតេ
វាបិ ឥស្ស សាតិ ឥស្ស អបរេ សមយេ ពុទ្ធំ
ធម្មំ សង្ឆំ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តស្ស សោ
ច យសោ សា ច កិត្តិ ហាយតិ បរិហាយតិ បរិ-
ជ្ជំសតិ បរិបតតិ អន្តរធាយតិ វិប្ផលុជ្ជតីតិ យសោ
កិត្តី ច យា បុព្វេ ហាយតេ វាបិ ឥស្ស សា ។

ជាធម្មកថិកក្តី ជាអ្នកកាន់អារញ្ញិកធុតង្គក្តី ជាអ្នកកាន់បិណ្ឌបាតិក-ធុតង្គក្តី ជាអ្នកកាន់បង្សុកូលិកធុតង្គក្តី ជាអ្នកកាន់តេចីវរិកធុតង្គ-ក្តី ជាអ្នកកាន់សបទានចារិកធុតង្គក្តី ជាអ្នកកាន់ខលុបច្ឆាភត្តិក-ធុតង្គក្តី ជាអ្នកកាន់នេសជ្ជិកធុតង្គក្តី ជាអ្នកកាន់យថាសន្ថតិកធុតង្គក្តី ជាអ្នកបានបឋមជ្ឈានក្តី ជាអ្នកបានទុតិយជ្ឈានក្តី ជាអ្នកបានតតិយ-ជ្ឈានក្តី ជាអ្នកបានចតុត្ថជ្ឈានក្តី ជាអ្នកបានអាកាសានញ្ចាយតន-សមាបត្តិក្តី ជាអ្នកបានវិញ្ញាណញ្ចាយតនសមាបត្តិក្តី ជាអ្នកបានអា-កិញ្ចញ្ញាយតនសមាបត្តិក្តី ជាអ្នកបាននេវសញ្ញានាសញ្ញាយតនសមា-បត្តិក្តី នេះឈ្មោះថា កេរ្តិ៍ឈ្មោះ ។ ពាក្យថា យសនិងកេរ្តិ៍ឈ្មោះ ណា ធ្លាប់មានក្នុងកាលមុន យសនិងកេរ្តិ៍ឈ្មោះនោះ របស់បុគ្គលនោះ រមែងសាបសូន្យទៅ បានសេចក្តីថា កាលបពូជិតនោះ ពោលលា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឆ និងសិក្ខា ក្នុងសម័យដទៃ ហើយត្រ-ឡប់ ដើម្បីកេទថោកទាប យសនិងកេរ្តិ៍ឈ្មោះនោះ រមែងសូន្យ សាបរលាប ខ្ជាត់ចេញ ជ្រុះចេញ បាត់បង់ វិនាស ហេតុនោះ (ទ្រង់ត្រាស់ថា) យសនិងកេរ្តិ៍ឈ្មោះ ណា ធ្លាប់មាន ក្នុងកាលមុន យសនិងកេរ្តិ៍ឈ្មោះនោះ របស់បុគ្គលនោះ រមែងសាបសូន្យទៅ ។

[២៤២] ឯតម្បិ ឥស្វា សិក្ខេថ មេថុនំ វិប្ប-
ហាតវេតិ ឯតន្តិ បុព្វេ សមណភាវេ យសោ ច កិត្តិ
ច អបរភាគេ ពុទ្ធំ ធម្មំ សង្ឃំ សិក្ខំ បច្ចក្ខាយ
ហីនាយាវត្តស្ស អយសោ ច អកិត្តិ ច ឯតំ សម្បត្តិ-
វិបត្តឹ ឥស្វា បស្សិត្វា តុលយិត្វា តិរយិត្វា វិភាវយិត្វា
វិភូតំ កត្វាតិ ឯតម្បិ ឥស្វា ។ សិក្ខេថាតិ តិស្សោ
សិក្ខា អធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញា-
សិក្ខា ។

កតមា អធិសីលសិក្ខា ។ ឥធ ភិក្ខុ សីលវា
ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរ-
សម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមា-
ទាយ សិក្ខតិ សិក្ខាបទេសុ ខុទ្ទកោ សីលក្ខន្ធោ
មហន្តោ សីលក្ខន្ធោ សីលំ បតិដ្ឋា អាទិ ចរណំ
សំយមោ សំវរោ មុខំ បមុខំ កុសលានំ ធម្មានំ
សមាបត្តិយា អយំ អធិសីលសិក្ខា ។

កតមា អធិចិត្តសិក្ខា ។ ឥធ ភិក្ខុ វិវិច្ចេវ
កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ

[២៦២] *អធិប្បាយពាក្យថា បពុជិតឃើញ នូវដំណើរនុ៎ះហើយ គប្បីសិក្សា ដើម្បីលះបង់មេថុនធម្ម ត្រង់ពាក្យថា នូវដំណើរនុ៎ះ សេចក្តីថា យសនិងកេរ្តិ៍ឈ្មោះក្នុងភាពជាសមណៈ ក្នុងកាលមុន ការមិនមានយស និងការមិនមានកេរ្តិ៍ឈ្មោះ របស់បពុជិត ដែលពោលលា នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឆ និងសិក្ខា ហើយត្រឡប់ដើម្បីកេទថោកទាប ក្នុងកាលជាចំណែកខាងក្រោយ បពុជិតឃើញ ចួប ប្រទះ ជ្ងឹង ពិចារណា ឈ្ងេងយល់ ធ្វើឲ្យជាក់ច្បាស់ នូវសម្បត្តិនិងវិបត្តិនុ៎ះ ហេតុនោះ (ទ្រង់ត្រាស់ថា) បពុជិតឃើញ នូវដំណើរនុ៎ះ ។ ពាក្យថា គប្បីសិក្សា បានដល់សិក្ខា ៣ គឺ អធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។*

អធិសីលសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រ្ដួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោចរៈ ឃើញភ័យក្នុងទោសមានប្រមាណបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ សីលក្នុងតូច សីលក្នុងធំ សីល ទីតាំងខាងដើម ការប្រព្រឹត្ត ការសង្រ្ដួម ការរារាំង ប្រធាន ប្រមុខ នៃការបានធម៌ជាកុសលទាំងឡាយ នេះ អធិសីលសិក្ខា ។

អធិចិត្តសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ ចូលបឋមជ្ឈាន ប្រកបដោយវិតក្ក:

សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ អធិចិត្តសិក្ខា ។

កតមា អធិប្បញ្ញាសិក្ខា ។ ឥធ ភិក្ខុ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឥមេ អាសវាតិ យថាភូតំ បជានាតិ អយំ អាសវសមុទយោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ អយំ អធិប្បញ្ញាសិក្ខា ។

មេថុនន្តិ មេថុនធម្មោ នាម យោ សោ អសទ្ធម្មោ

ប្រកបដោយវិចារៈ មានបីតិនិងសុខៈ កើតអំពីវិវេក ចូលទុតិយជ្ឈាន មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខៈ ដែលកើតអំពីសមាធិ ប្រព្រឹត្តទៅខាងក្នុងសន្តាន ជាទីជ្រះថ្លាស៊ប់ គឺសទ្ធា មានសភាពជាចិត្តដ៏ខ្ពស់ឯក ព្រោះការរម្ងាប់នូវវិតក្កៈ និងវិចារៈ ចូលតតិយជ្ឈាន ចូលចតុត្ថជ្ឈាន នេះ អធិចិត្តសិក្ខា ។

[២៣៩] ពាក្យថា ឬក៏សមណព្រាហ្មណ៍ ទាំងនោះ ភវរក ដោយសេចក្តីត្រិះរិះ សេចក្តីថា ឬក៏ (សមណព្រាហ្មណ៍ ទាំងនោះ) ត្រូវសេចក្តីត្រិះរិះ សេចក្តីត្រិះរិះផ្សេងៗ សេចក្តីត្រិះរិះព្រម ឲ្យទៅ ឲ្យនាំទៅ ឲ្យរសាត់ទៅ ឲ្យកួចទៅ ហេតុនោះ (ទ្រង់ត្រាស់សួរថា) ឬក៏ សមណព្រាហ្មណ៍ ទាំងនោះ ភវរក ដោយសេចក្តីត្រិះរិះ ។ មួយទៀត សមណព្រាហ្មណ៍ ទាំងឡាយ ពោល ថ្វែង ពណ៌នា ពន្យល់ អធិប្បាយ នូវប្រាជ្ញា ដែលស្រាវជ្រាវ ដោយសេចក្តីត្រិះរិះ ដែលរិះរក ដោយការពិចារណា ដោយខ្លួនឯង ហេតុនោះ (ទ្រង់ត្រាស់សួរថា) ឬក៏ សមណព្រាហ្មណ៍ទាំងនោះ ភវរកដោយ សេចក្តីត្រិះរិះ ។ ហេតុនោះ ព្រះពុទ្ធនិម្មិតនោះ ត្រាស់សួរថា

ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ

កស្មា នុ សច្ចានិ វទន្តិ ធីរា
បវាទិយាសេ កុសលាវទានា
សច្ចានិ សុត្តានិ ពហូនិ ធីរា
ឧទាហុ តេ តក្កមនុស្សរន្តីតិ ។

[២៤០] ន ហេវ សច្ចានិ ពហូនិ ធីរា
អញ្ញត្រ សញ្ញាយ និច្ចានិ លោកេ
តក្កញ្ច ទិដ្ឋីសុ បកប្បយិត្វា
សច្ចំ មុសាតី ទ្វយធម្មមាហុ ។

[២៤១] ន ហេវ សច្ចានិ ពហូនិ ធីរាតិ ន ហេវ សច្ចានិ ពហុកានិ ធីរានិ វិវិធានិ អញ្ញោញ្ញានិ បុថូនីតិ ន ហេវ សច្ចានិ ពហូនិ ធីរា ។

[២៤២] អញ្ញត្រ សញ្ញាយ និច្ចានិ លោកេតិ អញ្ញត្រ សញ្ញាយ និច្ចតាហ ឯកញ្ហេ សច្ចំ លោកេ ឋិយតិ ភណ្ឌិយតិ ជីរិយតិ ហាយតិ

ព្រោះហេតុអ្វី ពួកសមណព្រាហ្មណ៍ ជាអ្នកប្រកាន់ថា ឈ្វាសវៃ ពោល ពោលជជែក នូវសច្ចៈទាំងឡាយ ផ្សេងៗ គ្នា សច្ចៈទាំងឡាយ ច្រើន ផ្សេងៗ តើ (សមណ-ព្រាហ្មណ៍ទាំងនោះ) បានឮឬ ឬក៏ សមណព្រាហ្មណ៍ទាំងនោះ រាវរកដោយសេចក្តីត្រិះរិះទេ ។

[២៦០] (ព្រះមានព្រះភាគ ត្រាស់ថា) សច្ចៈទាំងឡាយ ក្នុងលោក រឿងលែងតែសេចក្តីប្រកាន់ថាទៀងដោយសញ្ញាចេញ មិនមែនមានច្រើន ផ្សេងៗ គ្នាទេ មួយវិញទៀត ជនទាំងឡាយ តែងតាំងនូវសេចក្តីត្រិះរិះ ក្នុងទិដ្ឋិទាំងឡាយ ហើយពោល នូវធម៌ ជាគូ ថាពិត ថាកុហក ។

[២៦១] ពាក្យថា សច្ចៈទាំងឡាយ មិនមែនមានច្រើន ផ្សេងៗ គ្នាទេ គឺសច្ចៈទាំងឡាយមិនមែនមានច្រើន ផ្សេងៗ មានប្រការផ្សេងៗ ដោយឡែកពីគ្នាច្រើនទេ ហេតុនោះ (ទ្រង់ត្រាស់ថា) សច្ចៈទាំងឡាយ មិនមែនមានច្រើន ផ្សេងៗ គ្នាទេ ។

[២៦២] អធិប្បាយពាក្យថា ក្នុងលោក រឿងលែងតែសេចក្តីប្រកាន់ថាទៀង ដោយសញ្ញាចេញ សេចក្តីថា ក្នុងលោករឿងលែងតែសេចក្តីប្រកាន់ថាទៀង ដោយសញ្ញាចេញ សច្ចៈ ដែលលោក ថ្វែង ពណ៌នា ពន្យល់

ទុក្ខនិរោធោ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វុបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។ អថវា ឯកំ សច្ចំ វុច្ចតិ មគ្គសច្ចំ និយ្យានសច្ចំ ទុក្ខនិរោធគាមិនី បដិបទា អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធីតិ អញ្ញត្រ សញ្ញាយ និច្ចានិ លោកេ ។

[២៤៣] តក្កញ្ច ទិដ្ឋីសុ បកប្បយិត្វា សច្ចំ មុសាតី ទ្វយធម្មមាហូតិ តក្កំ វិតក្កំ សង្កប្បំ តក្កយិត្វា វិតក្កយិត្វា សង្កប្បយិត្វា ទិដ្ឋិគតានិ ជនេន្តិ សញ្ជនេន្តិ និព្វត្តេន្តិ អភិនិព្វត្តេន្តិ ទិដ្ឋិគតានិ ជនេត្វា សញ្ជនេត្វា និព្វត្តេត្វា អភិនិព្វត្តេត្វា មយ្ហំ សច្ចំ តុយ្ហំ មុសាតិ ឯវមាហំសុ ឯវំ កថេន្តិ ឯវំ ភណន្តិ ឯវំ ទីបយន្តិ ឯវំ វោហរន្តីតិ តក្កញ្ច ទិដ្ឋីសុ បកប្បយិត្វា សច្ចំ មុសាតី ទ្វយធម្មមាហុ ។ តេនាហ ភគវា

អធិប្បាយថា មានតែមួយ គឺទុក្ខនិរោធនិព្វាន បានដល់ កិរិយារម្ងាប់នូវសង្ខារទាំងពួង កិរិយាកម្ចាត់បង់នូវឧបធិទាំងពួង កិរិយាអស់តណ្ហា កិរិយាប្រាសចាករាគៈ កិរិយារលត់ទុក្ខ ព្រះនិព្វាន ។ មួយទៀត សច្ចៈ មួយ លោកពោលសំដៅយក មគ្គសច្ចៈ និយ្យានសច្ចៈ ទុក្ខនិរោធ-គាមិនីបដិបទា មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ គឺសម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ហេតុនោះ (ទ្រង់ត្រាស់ថា) ក្នុងលោក រៀរលែងតែសេចក្តីប្រកាន់ថាទៀង ដោយសញ្ញា ។

[២៦៣] *ពាក្យថា មួយទៀត ជនទាំងឡាយ តែងតាំងនូវសេចក្តីត្រិះរិះ ក្នុងទិដ្ឋិទាំងឡាយ ហើយពោលនូវធម៌ជាគូ ថាពិត ថាកុហក សេចក្តីថា ជនទាំងឡាយ ត្រិះរិះ ត្រិះរិះផ្សេងៗ ត្រិះរិះព្រមនូវសេចក្តីត្រិះរិះ នូវសេចក្តីត្រិះរិះផ្សេងៗ នូវសេចក្តីត្រិះរិះព្រម ហើយញ្ចាំងទិដ្ឋិទាំងឡាយឲ្យកើត ឲ្យកើតព្រម ឲ្យកើតឡើង ឲ្យកើតចំពោះ លុះញ្ចាំងទិដ្ឋិទាំងឡាយ ឲ្យកើត ឲ្យកើតព្រម ឲ្យកើតឡើង ឲ្យកើតចំពោះ ហើយ ក៏ពោលយ៉ាងនេះ ថ្លែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ ពន្យល់យ៉ាងនេះ អធិប្បាយយ៉ាងនេះថា ពាក្យរបស់ខ្ញុំ ជាពាក្យពិត ពាក្យរបស់អ្នក ជាពាក្យកុហក ហេតុនោះ (ទ្រង់ត្រាស់ថា) ជនទាំងឡាយ តែងតាំងនូវសេចក្តីត្រិះរិះ ក្នុងទិដ្ឋិទាំងឡាយហើយពោល នូវធម៌ជាគូ ថាពិត ថាកុហក ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ហើយថា*

ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ

ឆហេវ សច្ចានិ ពហូនិ ជានា
អញ្ញត្រ សញ្ញាយ ជិច្ចានិ លោកេ
តក្ការ ជិដ្ឋីសុ បកប្បយិត្វា
សច្ចំ មុសាតី ទ្វយធម្មមាហូតិ ។

[២៤៤] ជិដ្ឋេ សុតេ សីលវតេ មុតេ វា
ឯតេ ច និស្សាយ វិមានឧស្សី
រិនិច្ចយេ ឋត្វា ឋហាសច្ចមានោ[1]
ពាលោ ឋហេ អកុសលោតិ ចាហ ។

[២៤៥] ជិដ្ឋេ សុតេ សីលវតេ មុតេ វា ឯតេ ច និស្សាយ វិមានឧស្សីតិ ជិដ្ឋំ វា ជិដ្ឋសុទ្ធិ វា សុតំ វា សុតសុទ្ធិ វា សីលំ វា សីលសុទ្ធិ វា វត្តំ វា វត្តសុទ្ធិ វា មុតំ វា មុតសុទ្ធិ វា និស្សាយ ឧបនិស្សាយ តណ្ហាត្វា ឋាមសិត្វា អភិនិវិសិត្វាតិ ជិដ្ឋេ សុតេ សីលវតេ មុតេ វា ។

---

1 ម. ឋហាសមានោ ។

សច្ចៈទាំងឡាយ ក្នុងលោក រៀរលែងតែសេចក្តីប្រកាន់ថា ទៀងដោយសញ្ញាចេញ មិនមែនមានច្រើន ផ្សេងៗ គ្នាទេ មួយទៀត ជនទាំងឡាយ តែងតាំងនូវសេចក្តីត្រិះរិះ ក្នុងទិដ្ឋិទាំងឡាយ ហើយពោលនូវធម៌ជាគូ ថាពិត ថាកុហក ។

[២២២] បុគ្គលអាស្រ័យទិដ្ឋិធម៌ ទាំងនេះ គឺការឃើញក្តី ការឮក្តី សីលនិងវ័ត្តក្តី ការប៉ះពាល់ក្តី ហើយជាអ្នកឃើញនូវការមើលងាយ បិតនៅក្នុងវិនិច្ឆ័យ ហើយរីករាយ បានពោលថា បុគ្គលពាល ថោកទាប មិនឈ្វាសវៃ ។

[២២៥] អធិប្បាយពាក្យថា បុគ្គលអាស្រ័យទិដ្ឋិធម៌ទាំងនេះ គឺការឃើញក្តី ការឮក្តី សីលនិងវ័ត្តក្តី ការប៉ះពាល់ក្តី ហើយជាអ្នកឃើញនូវការមើលងាយ សេចក្តីថា បុគ្គលអាស្រ័យ ចូលទៅអាស្រ័យ កាន់យក បណ្ដោសអង្អែល ជាប់ចិត្ត នូវការឃើញ ឬនូវសេចក្តីបរិសុទ្ធ ព្រោះការឃើញក្តី នូវការឮ ឬនូវសេចក្តីបរិសុទ្ធព្រោះការឮក្តី នូវសីល ឬនូវសេចក្តីបរិសុទ្ធព្រោះសីលក្តី នូវវ័ត ឬនូវសេចក្តីបរិសុទ្ធព្រោះវ័ត្តក្តី នូវការប៉ះពាល់ ឬនូវសេចក្តីបរិសុទ្ធព្រោះការប៉ះពាល់ក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) ការឃើញក្តី ការឮក្តី សីលនិងវ័ត្តក្តី ការប៉ះពាល់ក្តី ។

ឯតេ ច[១] និស្សាយ វិមានទស្សីតិ ន សម្មានេតីតិបិ វិមានទស្សី ។ អថវា លោមទស្សំ ជនេតីតិបិ វិមានទស្សីតិ ធិរ្ជេ សុតេ សីលវតេ មុតេ វា ឯតេ ច និស្សាយ វិមានទស្សី ។

[២៤៦] វិនិច្ឆយេ ឋត្វា បហស្សមានោតិ វិនិច្ឆយា វុច្ចន្តិ ទ្វាសដ្ឋី ទិដ្ឋិគតានិ[២] វិនិច្ឆិតទិដ្ឋិយា[៣] ឋត្វា បតិដ្ឋហិត្វា គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វា វិនិច្ឆយេ ឋត្វា ។ បហស្សមានោតិ តុដ្ឋោ ហោតិ ហដ្ឋោ បហដ្ឋោ អត្តមនោ បរិបុណ្ណសង្កប្បោ ។ អថវា ទន្តវិទំសកំ ហស្សមានោតិ វិនិច្ឆយេ ឋត្វា បហស្សមានោ ។

១ ម. ឯតេសុ ។ ២ ឱ. ម. ឯត្ថន្តរេ ទិដ្ឋិវិនិច្ឆយេតិ ទិស្សតិ ។ ៣ ម. វិនិច្ឆយទិដ្ឋិយា ។

ពាក្យថា បុគ្គលអាស្រ័យទិដ្ឋិទាំងនេះ ហើយជាអ្នកឃើញនូវការមើលងាយ គឺ ឈ្មោះថា អ្នកឃើញនូវការមើលងាយ ព្រោះហេតុមិនរាប់អានខ្ជះ ។ ឬថា ឈ្មោះថា អ្នកមើលងាយ ព្រោះហេតុញ៉ាំងទោម-នស្សឲ្យកើតខ្ជះ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលអាស្រ័យទិដ្ឋិធម៌ទាំងនេះ គឺការឃើញក្តី ការឮក្តី សីលនិងវ័ត្តក្តី ការប៉ះពាល់ក្តី ហើយជាអ្នកឃើញ នូវការមើលងាយ ។

[២២៦] *ពាក្យថា ឋិតនៅក្នុងវិនិច្ឆ័យ ហើយរីករាយ សេចក្តីថា ដែលហៅថា វិនិច្ឆ័យ បានដល់ទិដ្ឋិ ៦២ (បុគ្គល) ឋិតនៅ ឋិតនៅស៊ីប់ កាន់យក បបោសអង្អែល ជាប់ចិត្ត ក្នុងទិដ្ឋិដែលខ្លួនសម្រេចហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលឋិតនៅក្នុងវិនិច្ឆ័យ ។ ពាក្យថា រីករាយ គឺជាអ្នកត្រេកអរ រីករាយ រីក-រាយទូទៅ មានចិត្តជារបស់ខ្លួន មានសេចក្តីត្រិះរិះបរិបូណ៌ ។ ឬថា សើចបញ្ចេញធ្មេញ ហេតុនោះ (ទ្រង់ត្រាស់ថា) ឋិតនៅក្នុងវិនិច្ឆ័យ ហើយរីករាយ ។*

ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ

[២៤៧] ពាលោ បវេ អកុសលោតិ ចាហាតិ បវេ ពាលោ ហីនោ និហីនោ ឌិមកោ លាមកោ ជតុក្កោ បរិត្តោ អកុសលោ អវិជ្ជា អវិជ្ជាគតោ អញ្ញាណី អវិភាវី[1] ឧប្ប្ញ្ញោតិ ឯវមាហ ឯវំ ភាសតិ ឯវំ ភណតិ ឯវំ ទីបយតិ ឯវំ ភេហារតីតិ ពាលោ បវេ អកុសលោតិ ចាហ ។ តេនាហ ភគវា

ទ្ធិដ្ឋេ សុតេ សីលវតេ មុតេ វា
ឯតេ ច និស្សាយ វិមានឧស្ស្ស
រ្ធិនិច្ចយេ បត្វា បហាសមានោ
ពាលោ បវេ អកុសលោតិ ចាហាតិ ។

[២៤៨] យេនេវ ពាលោតិ បវំ ឧហាតិ
តេនាតុមានំ ភុសលោតិ ចាហ
សយមត្តនា សោ ភុសលោវជានោ
អញ្ញ្ញ វិមានេតិ តថេវ ចាវ[2] ។

---

១ ឱ. ម. ឯត្ថន្ត្ថរ អមេធាវីតិ ទិស្សតិ ។ ២ ម. តទេវ ចាវ ។

ចូឡវិយូហសុត្តនិទ្ទេស ទី ១២

[២៦៧] ពាក្យថា បានពោលថា បុគ្គលពាល ថោកទាប មិនឈ្វាសវៃ គឺ ពោលយ៉ាងនេះ ថ្លែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ ពន្យល់យ៉ាងនេះ អធិប្បាយយ៉ាងនេះថា បុគ្គលអន់ លួង ថោកទាប សាប-សូន្យ ថោកថយ លាមក គម្រក់ ជាមនុស្សកម្ទេចកម្ទី មិនឈ្វាសវៃ មិនមានប្រាជ្ញាជាគ្រឿងចាក់ធ្លុះ លុះក្នុងសេចក្តីលួង មិនមានញាណ មិនមានប្រាជ្ញាជាគ្រឿងបំភ្ញ ឥតបញ្ញា ហេតុនោះ (ទ្រង់ត្រាស់ថា) បានពោលថា បុគ្គលពាល ថោកទាប មិនឈ្វាសវៃ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

> បុគ្គលអាស្រ័យទិដ្ឋិធម៌ទាំងនេះ គឺការឃើញក្តី ការឮក្តី សីល និងវ័ត្តក្តី ការប៉ះពាល់ក្តី ហើយជាអ្នកឃើញនូវការមើលងាយ ឋិតនៅក្នុងវិនិច្ឆ័យហើយរីករាយ បានពោលថា បុគ្គលពាល ថោកទាប មិនឈ្វាសវៃ ។

[២៦៨] បុគ្គលយល់បុគ្គលដទៃ ថាជាបុគ្គលពាល ដោយអំពើណា ហើយពោលចំពោះអាត្មាឯង ថាជាបុគ្គលឈ្វាសវៃ ដោយអំពើនោះ បុគ្គលនោះប្រកាន់ថាខ្លួនជាអ្នកឈ្វាសវៃ ដោយខ្លួនឯង មើលងាយបុគ្គលដទៃ ទាំងពោលយ៉ាងនោះដែរ ។

[២៤៩] យេនេវ ពាលោតិ បវំ ឧហាតីតិ យេន[១] ហេតុនា យេន បច្ចយេន យេន ការណេន យេន បភវេន បវំ ពាលតោ ហីនតោ និហីនតោ ឋិមកតោ លាមកតោ ជតុក្ក្ហតោ បរិត្តតោ ឧហតិ បស្សតិ ឧក្ខិតិ ឋិលោកេតិ និជ្ឌាយតិ ឧបបរិក្ខតីតិ យេនេវ ពាលោតិ បវំ ឧហាតិ ។

[២៥០] តេនាតុមានំ កុសលោតិ ចាហាតិ អាតុមា[២] រុច្ចតិ អត្តា ។ សោបិ តេនេវ ហេតុនា តេន បច្ចយេន តេន ការណេន តេន បភវេន អត្តានំ អាហ អហមស្មិ កុសលោ បណ្ឌិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវីតិ តេនាតុមានំ កុសលោតិ ចាហ ។

---

១ ម. យេនេវ ។ ២ ម. អាតុមានោ ។

[២៤៩] ពាក្យថា បុគ្គលយល់បុគ្គលដទៃ ថាជាបុគ្គលពាល ដោយអំពើណា គឺបុគ្គលយល់ឃើញ មើលឃើញ ក្រឡេកឃើញ សម្ងឹងឃើញ រំពឹងឃើញ នូវបុគ្គលដទៃ ថាជាបុគ្គលពាល ថោកទាប ថោកថយ ទន់ទាប លាមក គម្រក់ ជាមនុស្សកម្ទេចកម្ទី ដោយហេតុណា ដោយបច្ច័យណា ដោយដំណើរណា ដោយហេតុផ្តើមណា ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលយល់បុគ្គលដទៃ ថាជាបុគ្គលពាល ដោយហេតុណា ។

[២៥០] ពាក្យថា ពោលចំពោះអាត្មាឯង ថាជាបុគ្គលឈ្វាសវៃ ដោយអំពើនោះ អធិប្បាយថា អត្តា លោកហៅថា អាត្មា ។ បុគ្គលនោះឯង រមែងហៅខ្លួនឯងថា អាត្មាអញ ជាអ្នកឈ្វាសវៃ ជាបណ្ឌិត មានប្រាជ្ញា មានប្រាជ្ញាជាគ្រឿងដឹង មានញាណ មានប្រាជ្ញាជាគ្រឿងបំភ្ញឹ ជាមេធាវី ដោយហេតុនោះ ដោយបច្ច័យនោះ ដោយដំណើរនោះ ដោយហេតុផ្តើមនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលពោលចំពោះអាត្មាឯង ថាជាបុគ្គលឈ្វាសវៃ ដោយអំពើនោះ ។

ទ្វាសមោ ចូឡវិយូហសុត្តនិទ្ទេសោ

[២៥១] សយមត្តនា សោ កុសលោវនាគោតិ សយំ[1] អត្តានំ កុសលវាគោ បណ្ឌិតវាគោ ធីរវាគោ ញាណវាគោ ហេតុវាគោ លក្ខណវាគោ ការណវាគោ ឋានវាគោ សកាយ លជ្ជិយាតិ សយមត្តនា សោ កុសលោវនាគោ ។

[២៥២] អញ្ញ វិមានេតិ តថេវ ចាវាតិ ន សម្ផានេតីតិ-បិ អញ្ញ វិមានេតិ ។ អថវា ឧោមនស្ស ជនេតីតិបិ អញ្ញ វិមានេតិ ។ តថេវ ចាវាតិ តថេវ តំ ឧិដ្ឋិកតំ ចាវនតិ ឥតិចាយំ បុក្ខលោ មិច្ឆាឧិដ្ឋិកោ វិបរីតឧ-ស្ឍនោតិ អញ្ញ វិមានេតិ តថេវ ចាវ ។ ឧេនាហ ភគវា

---

1 ម. សយមេវ ។

ចូឡវិយូហសុត្តនិទ្ទេស ទី ១២

[២៥១] ពាក្យថា បុគ្គលនោះ ប្រកាន់ថាខ្លួនជាអ្នកឈ្វាសវៃ ដោយខ្លួនឯង គឺពោលថាឈ្វាសវៃ ពោលថាជាបណ្ឌិត ពោលថាជាអ្នកប្រាជ្ញ ពោលថាប្រកបដោយញាណ ពោលថា ត្រូវទំនង ពោលថាប្រកបដោយលក្ខណៈ ពោលថាប្រកបដោយហេតុ ពោលថាគួរដល់ឋានៈ នូវខ្លួន ដោយខ្លួនឯង តាមលទ្ធិរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ ប្រកាន់ថាខ្លួនជាអ្នកឈ្វាសវៃ ។

[២៥២] ពាក្យថា មើលងាយ បុគ្គលដទៃ ទាំងពោលយ៉ាងនោះដែរ គឺមើលងាយបុគ្គលដទៃ ព្រោះហេតុមិនរាប់អានខ្លះ ។ ឬមើលងាយបុគ្គលដទៃ ព្រោះហេតុញ៉ាំងទោមនស្សឲ្យកើតខ្លះ ។ ពាក្យថា ទាំងពោលយ៉ាងនោះដែរ គឺបុគ្គលរមែងពោលប្រកាន់ នូវទិដ្ឋិនោះ ដោយប្រការដូច្នោះថា បុគ្គលនេះ ជាមិច្ឆាទិដ្ឋិ មានការយល់ខុស ដោយប្រការដូច្នេះ ហេតុនោះ (ទ្រង់ត្រាស់ថា) មើលងាយបុគ្គលដទៃ ទាំងពោលយ៉ាងនោះដែរ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

យេនេវ ពាលោតិ បវុំ ឧហាតិ
តេនាតុមានំ កុសលោតិ ចាហ
សយមត្តនា សោ កុសលោវនានោ
អញ្ញ្ញ វិមានេតិ តថេវ ចាវាតិ ។

[២៨៣] អតីសរំនិដ្ឋិយា[1] សោ សមត្តោ
មានេន មត្តោ បរិបុណ្ណមានី
សយមេវ សាមំ មនសាកិសិត្តោ
ទិដ្ឋី ហិ សា តស្ស តថា សមត្តា ។

[២៨៤] អតីសរំនិដ្ឋិយា សោ សមត្តោតិ អតិសារ-ទិដ្ឋិយោ រុច្ចន្តិ ទ្វាសដ្ឋី ទិដ្ឋិកតានិ ។ កិំការណា អតិសារទិដ្ឋិយោ រុច្ចន្តិ ទ្វាសដ្ឋី ទិដ្ឋិកតានិ ។ សព្វា តា ទិដ្ឋិយោ ការណាតិក្កន្តា លក្ខណាតិក្កន្តា ហីនាតិ-ក្កន្តា[2] តំការណា អតិសារទិដ្ឋិយោ រុច្ចន្តិ ទ្វាសដ្ឋី ទិដ្ឋិកតានិ ។ សព្ពេបិ តិត្ថិយា អតិសារទិដ្ឋិយា ។ កិំការណា សព្ពេបិ តិត្ថិយា អតិសារទិដ្ឋិយា ។ អញ្ញមញ្ញ អតិក្កមិត្វា សមតិក្កមិត្វា រីតិវត្តេត្វា

---

១ ម. អតិសារទិដ្ឋិយា ។ ២ ម. ឋានាតិក្កន្តា ។ ម. សព្ពាបិ ទិដ្ឋិយោ អតិសារទិដ្ឋិយោ ។ កិំការណា សព្ពាបិ ទិដ្ឋិយោ រុច្ចន្តិ អតិសារទិដ្ឋិយោ ។

បុគ្គលយល់ បុគ្គលដទៃ ថាជាបុគ្គលពាល ដោយអំពើណា ហើយពោល ចំពោះអាត្មាឯង ថាជាបុគ្គលឈ្វាសវៃ ដោយអំពើនោះ បុគ្គលនោះ ប្រកាន់ថាខ្លួនជាអ្នកឈ្វាសវៃ ដោយខ្លួនឯង រមែងមើលងាយបុគ្គលដទៃ ទាំងពោលយ៉ាងនោះដែរ ។

[២៥៣] បុគ្គលនោះ សម្រេចដោយទិដ្ឋិមានសារៈដ៏ក្រៃលែង ជាអ្នកស្រវឹងដោយមានៈ មានមានៈបរិបូណ៌ អភិសេកខ្លួនដោយចិត្តខ្លួនឯង ព្រោះថា ទិដ្ឋិនោះ បុគ្គលនោះសម្រេចហើយ ដោយប្រការដូច្នោះ ។

[២៥៤] ពាក្យថា បុគ្គលនោះសម្រេចដោយទិដ្ឋិ មានសារៈដ៏ក្រៃលែង អធិប្បាយថា ទិដ្ឋិ ៦២ ហៅថាទិដ្ឋិមានសារៈដ៏ក្រៃលែង ។ ទិដ្ឋិ ៦២ ហេតុអ្វីក៏លោកហៅថា ទិដ្ឋិមានសារៈដ៏ក្រៃលែង ។ ទិដ្ឋិទាំងអស់នោះ កន្ធ៦នូវហេតុ កន្ធ៦នូវលក្ខណៈ កន្ធ៦នូវការថោកទាប ហេតុនោះ ទិដ្ឋិទាំង ៦២ ហៅថាទិដ្ឋិមានសារៈដ៏ក្រៃលែង ។ ពួកតិរ្ថិយទាំងអស់ មានទិដ្ឋិ មានសារៈដ៏ក្រៃលែង ។ ហេតុអ្វីក៏ពួកតិរ្ថិយទាំងអស់ មានទិដ្ឋិ មានសារៈដ៏ក្រៃលែង ។ ពួកតិរ្ថិយទាំងនោះ កន្ធ៦ កន្ធ៦ព្រម ប្រព្រឹត្តកន្ធ៦ នូវគ្នានិងគ្នា

ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ

ឧដ្ឋិតតានិ ជនេន្តិ សញ្ជនេន្តិ ជិព្ភនេ្តន្តិ អភិជិព្ភនេ្តន្តិ តំការណា សព្ពេបិ តិត្ថិយា អតិសារឧដ្ឋិយា ។ សោ សមត្តោតិ អតិសារឧដ្ឋិយា សមត្តោ បរិបុណ្ណោ អនោមោតិ អតីសារំឧដ្ឋិយា សោ សមត្តោ ។

[២៥៥] មានេន មត្តោ បរិបុណ្ណមានីតិ សកាយ ឧដ្ឋិយា[1] មានេន មត្តោ បមត្តោ ឧម្មត្តោ អធិមត្តោតិ មានេន មត្តោ ។ បរិបុណ្ណមានីតិ បរិបុណ្ណមានី សមត្ត-មានី អនោមមានីតិ មានេន មត្តោ បរិបុណ្ណមានី ។

[២៥៦] សយមេវ សាមំ មនសាកិសិត្តោតិ សយមេវ អត្តានំ ចិត្តេន អកិសិញ្ចតិ អហមស្មិ កុសលោ បណ្ឌិតោ បញ្ញវា ពុទ្ធិមា ញាណី វិការី មេធាវីតិ សយមេវ សាមំ មនសាកិសិត្តោ ។

---

1 ម. ឯត្ថន្តរេ ទិដ្ឋីតិ ទិស្សតិ ។

ហើយញ៉ាំងទិដ្ឋិទាំងឡាយ ឲ្យកើត ឲ្យកើតព្រម ឲ្យបង្កើត ឲ្យបង្កើតចំពោះ ហេតុនោះបានជា ពួកតិរ្ថិយទាំងអស់ មានទិដ្ឋិ មានសារៈដ៏ក្រៃលែង ។ ពាក្យថា បុគ្គលនោះសម្រេច គឺសម្រេច បរិបូណ៌ មិនខ្វះខាតដោយទិដ្ឋិមានសារៈដ៏ក្រៃលែង ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះសម្រេច ដោយទិដ្ឋិ មានសារៈដ៏ក្រៃលែង ។

[២៥៥] ពាក្យថា ជាអ្នកស្រវឹងដោយមាន៖ មានមានៈបរិបូណ៌ គឺជាអ្នកស្រវឹង ប្រមាទ ធ្ពត ស្រវឹងលើសលុប ដោយសេចក្ដីប្រកាន់ទិដ្ឋិរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកស្រវឹងដោយមាន៖ ។ ពាក្យថា មានមានៈបរិបូណ៌ គឺមានមានៈពេញលេញ មានមានៈសម្រេច មានមានៈមិនខ្វះខាត ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកស្រវឹងដោយមាន៖ មានមានៈបរិបូណ៌ ។

[២៥៦] ពាក្យថា អកិសេកខ្លួន ដោយចិត្តខ្លួនឯង គឺអកិសេកខ្លួនដោយចិត្តខ្លួនឯងថា អាត្មាអញ ជាបុគ្គលឈ្វាសវៃ ជាបណ្ឌិត មានបញ្ញា មានប្រាជ្ញាជាគ្រឿងដឹង មានញាណ មានប្រាជ្ញាជាគ្រឿងបំភ្ញ ជាមេធាវី ហេតុនោះ (ទ្រង់ត្រាស់ថា) អកិសេកខ្លួន ដោយចិត្តខ្លួនឯង ។

[២៨៧] ឧិដ្ឋី ហិ សា តស្ស តថា សមត្តាតិ តស្ស សា ឧិដ្ឋិ តថា សមត្តា សមាឧិដ្ឋា ឧហិតា បរាមដ្ឋា អភិនិវិដ្ឋា អជ្ឈោសិតា អធិមុត្តាតិ ឧិដ្ឋី ហិ សា តស្ស តថា សមត្តា ។ តេនាហ ភគវា

អតីសរំឧិដ្ឋិយា សោ សមត្តោ
មានេន មត្តោ បរិបុណ្ណមានី
សយមេវ សាមំ មនសាភិសិត្តោ
ឧិដ្ឋី ហិ សា តស្ស តថា សមត្តា ។

[២៨៨] បរស្ស ចេ ហិ វចសា ឧិហីនោ
តុមោ[1] សហា ហោតិ ឧិហីនបញ្ញោ
អថវា សយំ វេឧតូ ហោតិ ធីរោ
ន ឧោចិ ពាលោ សមណេសុ អត្តិ ។

---

១ ម. តុម្ហោ ។

[២៥៧] ពាក្យថា ព្រោះថា ទិដ្ឋិនោះ បុគ្គលនោះ សម្រេចដោយប្រការដូច្នោះ គឺទិដ្ឋិនោះ បុគ្គលនោះ សម្រេច សមាទាន កាន់យក បក្ខាសអង្អែល ជាប់ចិត្ត ចុះចិត្ត ចុះចិត្តស៊ប់ ដោយប្រការដូច្នោះ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះថា ទិដ្ឋិនោះ បុគ្គលនោះ សម្រេចដោយប្រការដូច្នោះ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

បុគ្គលនោះ សម្រេចដោយទិដ្ឋិ មានសារៈដ៏ក្រៃលែង ជាអ្នកស្រវឹងដោយមានៈ មានមានៈបរិបូណ៌ អភិសេកខ្លួនដោយចិត្តខ្លួនឯង ព្រោះថា ទិដ្ឋិនោះ បុគ្គលនោះសម្រេចដោយប្រការដូច្នោះ ។

[២៥៨] ប្រសិនបើ បុគ្គលទន់អន់ដោយសារសម្ដី របស់បុគ្គលដទៃ (បុគ្គលនោះ) នឹងមានបញ្ញាថោកទាបជាមួយ មួយទៀតបុគ្គលជាវេទគូ ជាអ្នកប្រាជ្ញ ដោយខ្លួនឯងបាន ឥតមានអ្នកណាមួយ ជាបុគ្គលពាល ក្នុងពួកសមណៈទេ ។

ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ

[២៥៩] បរិស្សេ ចេ ហិ វចសា និហីនោតិ បរិស្សេ ចេ ឱ្យាយ វចនេន និន្ទិតការណា តរហិតការណា ឧបវទិតការណា បរេ ពាលេ ហោតិ ហីនោ និហីនោ ឧិមកោ លាមកោ ជតុក្ក្លោ បរិត្តោតិ បរិស្សេ ចេ ហិ វចសា និហីនោ ។

[២៦០] តុមោ សហ ហោតិ និហីនបញ្ញោតិ សោបិ តេនេវ សហ ហោតិ ហីនប្ប្ញោ និហីនប្ប-ញ្ញោ ឧិមកប្ប្ញោ លាមកប្ប្ញោ ជតុក្ក្លប្ប្ញោ បរិត្តប្ប្ញោតិ តុមោ សហ ហោតិ និហីនប្ប្ញោ ។

[២៦១] អថ(១) សយំ ឧ្ចកូ ហោតិ ជីវោតិ(២) ជីវោ បណ្ឌិតោ បញ្ញ្ចា ពុទ្ធិមា ញ្ចាណ្ចី ១ិការ្ចី ១ិមជ្ចារ្ចីតិ អថ-ា សយំ ឧ្ចកូ ហោតិ ជីវោ ។

[២៦២] ន ១ោ្ចិ ពាលេ សមណ្ចេសុ អត្ថ្ចីតិ សមណ្ចេសុ ន ១ោ្ចិ ពាលេ ហ្ចីនោ និហ្ចីនោ ១ិមកោ លាមកោ ជតុក្ក្លោ បរិត្តោ អត្ថ្ចិ

---

១ ម. អថ ចេ ។ ២ ឱ. ឯត្ថន្តរ អថ្ចា សយំ ឧ្ចទ្ចូ ហ្ចោ្ចតីតិ ទិស្ស្ចន្ថ ។ ម. អថ ចេ ។

ចូឡវិយូហសុត្តនិទ្ទេស ទី ១២

[២៥៩] ពាក្យថា ប្រសិនបើ បុគ្គលទន់អន់ដោយសារសម្ដី របស់បុគ្គលដទៃ គឺប្រសិនបើ បុគ្គលជាអ្នកអាប់ឱិន ជាបុគ្គលពាល ថោកទាប អន់ ទន់ទាប លាមក គម្រក់ ជាមនុស្សកម្ទេចកម្ទី ព្រោះហេតុនៃសេចក្ដីនិន្ទា ព្រោះហេតុ នៃសេចក្ដីតិះដៀល ព្រោះហេតុនៃសេចក្ដីរិះគន់ ដោយសារសម្ដី ដោយសារពាក្យ របស់បុគ្គលដទៃ ហេតុនោះ (ទ្រង់ត្រាស់ថា) ប្រសិនបើ បុគ្គលទន់អន់ដោយសារសម្ដី របស់បុគ្គលដទៃ ។

[២៦០] ពាក្យថា (បុគ្គលនោះ) នឹងមានបញ្ញាថោកទាបជាមួយ គឺបុគ្គលនោះឯង ជាអ្នកមានបញ្ញាថោកទាប មានបញ្ញាថោកថយ មានបញ្ញាទន់ទាប មានបញ្ញាលាមក មានបញ្ញាគម្រក់ មានបញ្ញាស្ពួចស្ដើង ជាមួយនឹងបុគ្គលនោះឯង ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ នឹងជាបុគ្គលមានបញ្ញាថោកទាបជាមួយ ។

[២៦១] ពាក្យថា មួយទៀត បុគ្គលជាវេទគូ ជាអ្នកប្រាជ្ញដោយខ្លួនឯងបាន គឺបុគ្គលជាអ្នកប្រាជ្ញ ជាបណ្ឌិត មានបញ្ញា មានបញ្ញាជាគ្រឿងដឹង មានញាណ មានបញ្ញាជាគ្រឿងបំភ្ញ ជាមេធាវី ហេតុនោះ (ទ្រង់ត្រាស់ថា) មួយទៀត បុគ្គលជាវេទគូ ជាអ្នកប្រាជ្ញដោយខ្លួនឯងបាន ។

[២៦២] ពាក្យថា ឥតមានអ្នកណាមួយ ជាបុគ្គលពាលក្នុងពួកសមណៈទេ គឺឥតមានអ្នកណាមួយ ជាបុគ្គលពាល ថោកទាប ថោកថយ ទន់ទាប លាមក គម្រក់ ជាមនុស្សកម្ទេចកម្ទី ក្នុងពួក

សព្វេវ អគ្គប្បញ្ញា សេដ្ឋប្បញ្ញា វិសេដ្ឋប្បញ្ញា ចាមោក្ខ-ប្បញ្ញា ឧត្តមប្បញ្ញា បវរប្បញ្ញាតិ ន កោចិ ពាលោ សមណេសុ អត្ថិ ។ តេនាហ ភគវា

បរស្ស ចេ ហិ វចសា និហីនោ
តុមោ សហា ហោតិ និហីនបញ្ញោ
អថវា សយំ វេទគូ ហោតិ ធីរោ
ន កោចិ ពាលោ សមណេសុ អត្ថីតិ ។

[២៦៣] អញ្ញំ ឥតោ យាភិវទន្តិ ធម្មំ
អបរទ្ធា សុទ្ធិមកេវលី តេ
ឯវម្បិ តិត្ថ្យា បុថុសោ វទន្តិ
សន្ទិដ្ឋិរាគេន ហិ ត្យាភិរត្តា ។

[២៦៤] អញ្ញំ ឥតោ យាភិវទន្តិ ធម្មំ អបរទ្ធា សុទ្ធិមកេវលីតេតិ ឥតោ អញ្ញំ ធម្មំ ទិដ្ឋឹ បដិបទំ មគ្គំ

សមណៈទេ គឺថា ទាំងអស់គ្នា សុទ្ធតែជាបុគ្គលមានបញ្ញាដ៏លើស មានបញ្ញាប្រសើរ មានបញ្ញាវិសេស មានបញ្ញាជាប្រធាន មានបញ្ញាដ៏ឧត្តម មានបញ្ញាដ៏ឋវរ ហេតុនោះ (ទ្រង់ត្រាស់ថា) ឥតមានអ្នកណាមួយ ជាបុគ្គលពាល ក្នុងពួកសមណៈទេ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ប្រសិនបើ បុគ្គលទន់អន់ដោយសារសម្ដី របស់បុគ្គលដទៃ (បុគ្គលនោះ) នឹងមានបញ្ញាថោកទាបជាមួយ មួយទៀត បុគ្គលជាវេទគូ ជាអ្នកប្រាជ្ញដោយខ្លួនឯងបាន ឥតមានអ្នកណាមួយ ជាបុគ្គលពាល ក្នុងពួកសមណៈទេ ។

[២៦៣] បុគ្គលទាំងឡាយណា សរសើរធម៌ដទៃ អំពីធម៌នេះ បុគ្គលទាំងឡាយនោះឈ្មោះថា អ្នកភ្ជាត់ចាកសេចក្ដីបរិសុទ្ធ ជាបុគ្គលមិនពេញលេញ បុគ្គលអ្នកមានលទ្ធិដូចជាកំពង់ទាំងឡាយ តែងពោលដោយច្រើន យ៉ាងនេះឯង ព្រោះថា បុគ្គលទាំងឡាយនោះ ត្រេកអរក្រៃលែង ដោយសេចក្ដីត្រេកអរនឹងទិដ្ឋិរបស់ខ្លួន ។

[២៦២] ពាក្យថា បុគ្គលទាំងឡាយណា សរសើរធម៌ដទៃ អំពីធម៌នេះ បុគ្គលទាំងឡាយនោះ ឈ្មោះថា អ្នកភ្ជាត់ចាកសេចក្ដីបរិសុទ្ធ ជាបុគ្គលមិនពេញលេញ គឺបុគ្គលទាំងឡាយណា សរសើរធម៌ ទិដ្ឋិ បដិបទា

ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ

យេ អភិវទន្តិ តេ សុទ្ធិមក្តំ វិសុទ្ធិមក្តំ បរិសុទ្ធិមក្តំ ភោជាតមក្តំ បរិយោជាតមក្តំ រិត្តា អបរទ្ធា ១លិតា ១ជ្ឈិតា អញ្ញាយ អបរទ្ធា អ១ោ១លី តេ អ១ាមត្តា តេ អ១ារិបុ១ណ្ណា តេ ហីនា ១ិហីនា ១ិមកា ១ាមកា ១ តុ១ណ្ណា ១ារិត្តាតិ អ១ញ្ញ ១តោ ១ាភិ១ន្តិ ១ ១ម្ម អ១ទ្ធា ១ុ១ទ្ធិ១ោ១លី ១ ។

[២៦៥] ១ារ១ម្ប៉ា ១ិ១ត្ត្យ ១ុ១ុ១ោ ១ន្ត្ដ១ិ ១ិ១ត្ត ១ុ១ូ១ិ ១ិ១ដ្ឋ១ត ។ ១ិ១ត្ត្យ ១ុ១ូ១ិ ១ិ១ដ្ឋ១ត១ា ។ ១ុ១ុ ១ិ១ដ្ឋ១ា ១ុ១ុ១ិ១ដ្ឋ១ត១ា១ ១ន្ត ១ ១ា១ ១ណ១ ១ ១ីប១ ១ ១ា១ ១ន្ត១ិ ១ារ១ម្ប៉ ១ិ១ត្ត្យ ១ុ១ុ១ោ ១ន្ត ។

មគ្គដទៃ អំពីធម៌នេះ បុគ្គលទាំងឡាយនោះ ឈ្មោះថា អ្នកខុស អ្នកប្រាស អ្នកភ្ជាត់ អ្នកឃ្លាត ចាកផ្លូវស្អាត ផ្លូវស្អាតវិសេស ផ្លូវបរិសុទ្ធ ផ្លូវហ្មត់ចត់ ផ្លូវផ្ទូរផង់ ជាបុគ្គលខុស មិនពេញលេញ ព្រោះមិនមានញាណ បុគ្គលទាំងឡាយនោះ មិនបានសម្រេច បុគ្គលទាំងឡាយនោះ មិនបានបរិ-បូណ៌ បុគ្គលទាំងឡាយនោះ ជាបុគ្គលថោកទាប ថោកថយ ទន់ទាប លាមក គម្រក់ ជាមនុស្សកម្ទេចកម្ទី ហេតុនោះ (ទ្រង់ត្រាស់) បុគ្គលទាំងឡាយណា សរសើរធម៌ដទៃ អំពីធម៌នេះ បុគ្គលទាំងឡាយនោះ ឈ្មោះថា អ្នកភ្ជាត់ចាកសេចក្តីបរិសុទ្ធ ជាបុគ្គលមិនពេញលេញ ។

[២៦៥] ពាក្យថា បុគ្គលអ្នកមានលទ្ធិ ដូចជាកំពង់ទាំងឡាយ តែងពោលដោយច្រើន យ៉ាងនេះឯង អធិប្បាយថា ទិដ្ឋិ លោកហៅថា កំពង់ ។ ពួកបុគ្គលអ្នកលុះក្នុងទិដ្ឋិ លោកហៅថា បុគ្គលអ្នកមានលទ្ធិដូចជាកំពង់ ។ បុគ្គលអ្នកប្រកប ដោយទិដ្ឋិច្រើន តែងពោល ថ្វែង ពណ៌នា ពន្យល់ អធិប្បាយ នូវទិដ្ឋិដ៏ច្រើនទាំងឡាយ ដោយទិដ្ឋិមានប្រមាណច្រើន ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលអ្នកមានលទ្ធិដូចជាកំពង់ទាំងឡាយ តែងពោលដោយច្រើនយ៉ាងនេះខ្លះ ។

[២៦៦] សន្ធិដ្ឋិកេន ហិ ត្យាកិរត្ថាតិ សកាយ ឧដ្ឋិយា[១] ឧកេន រត្ថា អកិរត្ថាតិ សន្ធិដ្ឋិកេន ហិ ត្យាកិរត្ថា ។ តេនាហ ភគវា

អញ្ញ ឥតោ យាកិរឥន្ត ធម្មំ
អបរន្ធ សុទ្ធិមកេវលី តេ
ឯវម្ជ្ជ តិត្ថ្យ បុថុសោ រឥន្ត
សន្ធិដ្ឋិកេន ហិ ត្យាកិរត្ថាតិ ។

[២៦៧] ឥធេវ សុទ្ធឺ ឥតិ ឧាឥយន្ត
ជាញ្ញេសុ ធម្មេសុ វិសុទ្ធិមាហុ
ឯវម្ជ្ជ តិត្ថ្យ បុថុសោ ឧិវិដ្ឋ
សកាយនេ ឥត្ត ឥជ្ជ្ជ រជ្ជ ។

---

១ ឱ. ម. ឯត្ថន្ត្ត ទិដ្ឋីតិ ទិស្ស្ត ។

[២៦៦] ពាក្យថា ព្រោះថា បុគ្គលទាំងឡាយនោះ ត្រេកអរ ក្រៃលែង ដោយសេចក្តីត្រេកអរ នឹងទិដ្ឋិរបស់ខ្លួន គឺ (បុគ្គលនោះ) ត្រេកអរ ត្រេកអរក្រៃលែង ដោយសេចក្តីត្រេកអរ នឹងទិដ្ឋិរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះថា បុគ្គលទាំងឡាយនោះ ត្រេកអរក្រៃលែង ដោយសេចក្តីត្រេកអរ នឹងទិដ្ឋិរបស់ខ្លួន ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

> បុគ្គលទាំងឡាយ ណា សរសើរធម៌ដទៃ អំពីធម៌នេះ បុគ្គលទាំងឡាយនោះ ឈ្មោះថា អ្នកភ្ជាត់ ចាកសេចក្តីបរិសុទ្ធ ជាបុគ្គលមិនពេញលេញ បុគ្គលអ្នកមានលទ្ធិ ដូចជាកំពង់ ទាំងឡាយ តែងពោលដោយច្រើន យ៉ាងនេះឯង ព្រោះថា បុគ្គលទាំងឡាយនោះ ត្រេកអរក្រៃលែង ដោយសេចក្តី ត្រេកអរ នឹងទិដ្ឋិរបស់ខ្លួន ។

[២៦៧] បុគ្គលទាំងឡាយ រមែងពោលនូវសេចក្តីបរិសុទ្ធក្នុងធម៌នេះឯងដូច្នេះ មិនពោលនូវសេចក្តីបរិសុទ្ធ ក្នុងធម៌ទាំងឡាយឯទៀតទេ ពួកបុគ្គលអ្នកមានលទ្ធិដូចជាកំពង់ តាំងនៅស៊ីប់ក្នុងទិដ្ឋិដ៏ច្រើន យ៉ាងនេះឯង ប្រកាន់មាំ ក្នុងសកាយនៈ (ផ្លូវរបស់ខ្លួន) នោះ ។

ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ

[២៦៨] ឥធេវ សុទ្ធឺ ឥតិ ភាឧយន្តីតិ ឥធ សុទ្ធឺ វិសុទ្ធឺ បរិសុទ្ធឺ មុត្តឺ វិមុត្តឺ បរិមុត្តឺ វេឧន្តិ ភាវេន្តិ ភណ្ឌន្តិ ឋីបយន្តិ ហារន្តិ សស្សតោ លោកោ ឥធមេវ សច្ចំ មោឃមញ្ញន្តិ ឥធ សុទ្ធឺ វិសុទ្ធឺ បរិសុទ្ធឺ មុត្តឺ វិមុត្តឺ បរិមុត្តឺ វេឧន្តិ ភាវេន្តិ ភណ្ឌន្តិ ឋីបយន្តិ ហារន្តិ អសស្សតោ លោកោ ។ បេ ។ ឥធេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥធមេវ សច្ចំ មោឃ-មញ្ញន្តិ ឥធ សុទ្ធឺ វិសុទ្ធឺ បរិសុទ្ធឺ មុត្តឺ វិមុត្តឺ បរិមុត្តឺ វេឧន្តិ ភាវេន្តិ ភណ្ឌន្តិ ឋីបយន្តិ ហារន្តីតិ ឥធេវ សុទ្ធឺ ឥតិ ភាឧយន្តិ ។

[២៦៩] ជាញ្ញេសុ ឧម្មេសុ វិសុទ្ធិមាហូតិ អត្តនោ សត្ថារំ ឧម្មក្ខានឺ ឧណ្ហ ឧដ្ឋ បដិបទំ មក្ខ បវេត្វា សព្ពេ ឋារាឧ ទ្ធិបន្តិ ឧក្ខិបន្តិ បរិក្ខិបន្តិ សោ សត្ថា

ចូឡវិយូហសុត្តនិទ្ទេស ទី ១២

[២៦៨] ពាក្យថា បុគ្គលទាំងឡាយ រមែងពោលនូវសេចក្តីបរិ-សុទ្ធ ក្នុងធម៌នេះឯងដូច្នេះ សេចក្តីថា បុគ្គលទាំងឡាយ តែងពោល ថ្វែង ពណ៌នា ពន្យល់ អធិប្បាយ នូវការស្អាត ស្អាតវិសេស ស្អាតដោយជុំវិញ ការរួច រួចស្រឡះ រួចដោយជុំវិញ ក្នុងធម៌របស់ខ្លួន នេះ តែងពោល ថ្វែង ពណ៌នា ពន្យល់ អធិប្បាយ នូវការ ស្អាត ស្អាតវិសេស ស្អាតដោយជុំវិញ ការរួច រួចស្រឡះ រួចដោយ ជុំវិញ ក្នុងធម៌នេះថា លោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃ ជាមោឃៈ តែងពោល ថ្វែង ពណ៌នា ពន្យល់ អធិប្បាយ នូវ ការស្អាត ស្អាតវិសេស ស្អាតដោយជុំវិញ ការរួច រួចស្រឡះ រួច ដោយជុំវិញ ក្នុងធម៌នេះថា លោកមិនទៀង ។ បេ ។ សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះ ជាពាក្យពិត ពាក្យដទៃជាមោឃៈ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលទាំងឡាយ រមែងពោលនូវសេចក្តីបរិសុទ្ធ ក្នុងធម៌នេះឯងដូច្នេះ ។

[២៦៩] ពាក្យថា មិនពោលនូវសេចក្តីបរិសុទ្ធ ក្នុងធម៌ទាំងឡាយ ឯទៀតទេ សេចក្តីថា លើកទុកនូវសាស្តា នូវធម៌ដែលសាស្តាប្រាប់ នូវគណៈ នូវទិដ្ឋិ នូវបដិបទា នូវមគ្គ របស់ខ្លួនចេញ ហើយ ចោះចោល ចោះបង់ បដិសេធ នូវវាទៈ របស់ជនដទៃ ទាំងអស់

ន សព្វញ្ញូ ធម្មោ ន ស្វាក្ខាតោ គណោ ន សុប្បដិបន្នោ ទិដ្ឋិ ន ភទ្ទិកា បដិបទា ន សុបញ្ញត្តា មគ្គោ ន និយ្យានិកោ នត្ថេត្ថ សុទ្ធិ វា វិសុទ្ធិ វា បរិសុទ្ធិ វា មុត្តិ វា វិមុត្តិ វា បរិមុត្តិ វា នត្ថេត្ថ សុជ្ឈន្តិ វា វិសុជ្ឈន្តិ វា បរិសុជ្ឈន្តិ វា មុច្ចន្តិ វា វិមុច្ចន្តិ វា បរិមុច្ចន្តិ វា ហីនា និហីនា ឱមកា លាមកា ឆតុក្កា បរិត្តាតិ ឯវមាហំសុ ឯវំ កថេន្តិ ឯវំ ភណន្តិ ឯវំ ទីបយន្តិ ឯវំ វោហរន្តីតិ នាញ្ញេសុ ធម្មេសុ វិសុទ្ធិមាហុ ។

[២៧០] ឯវម្បិ តិត្ថ្យា បុថុសោ និវិដ្ឋាតិ តិត្ថំ វុច្ចតិ ទិដ្ឋិគតំ ។ តិត្ថ្យា វុច្ចន្តិ ទិដ្ឋិគតិកា ។ បុថុទិដ្ឋិយា បុថុទិដ្ឋិគតេសុ និវិដ្ឋា បតិដ្ឋិតា អល្លីនា ឧបគតា អជ្ឈោសិតា អធិមុត្តាតិ ឯវម្បិ តិត្ថ្យា បុថុសោ និវិដ្ឋា ។

គឺពោលហើយយ៉ាងនេះ ថ្នែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ ពន្យល់យ៉ាងនេះ អធិប្បាយយ៉ាងនេះថា សាស្តានោះមិនមែនជាសព្វញ្ញូទេ ធម៌មិនមែនសាស្តាសម្តែងល្អទេ គណៈមិនមែនប្រតិបត្តិត្រូវទេ ទិដ្ឋិមិនចម្រើនទេ បដិបទា មិនមែនសាស្តាបញ្ញត្តល្អទេ មគ្គមិនមែនជាផ្លូវស្រោចស្រង់សត្វទេ ការស្អាតក្តី ការស្អាតវិសេសក្តី ការស្អាតដោយជុំវិញក្តី ការរួចក្តី ការរួចស្រឡះក្តី ការរួចដោយជុំវិញក្តី មិនមានក្នុងលទ្ធិនេះទេ ជនទាំងឡាយ ស្អាតក្តី ស្អាតវិសេសក្តី ស្អាតដោយជុំវិញក្តី រួចក្តី រួចវិសេសក្តី រួចដោយជុំវិញក្តី ក្នុងលទ្ធិនេះមិនមានទេ ពួកជននេះជាអ្នកថោកទាប ថោកថយ ទន់ទាប លាមក គម្រក់ អាប់ឱន ហេតុនោះ (ទ្រង់ត្រាស់ថា) មិនពោលនូវសេចក្តីបរិសុទ្ធ ក្នុងធម៌ទាំងឡាយឯទៀតទេ ។

[២៧០] *ពាក្យថា ពួកបុគ្គល អ្នកមានលទ្ធិដូចជាកំពង់ តាំងស៊ប់ក្នុងទិដ្ឋិដ៏ច្រើន យ៉ាងនេះឯង អធិប្បាយថា ទិដ្ឋិ លោកហៅថា កំពង់ ។ ពួកបុគ្គលអ្នកលុះក្នុងទិដ្ឋិ លោកហៅថា អ្នកមានលទ្ធិដូចជាកំពង់ ។ (ពួកបុគ្គលនោះ) តាំងនៅស៊ប់ តាំងនៅមាំ ជាប់ ដល់ស៊ប់ ជក់ចិត្ត ចុះចិត្តស៊ប់ ក្នុងទិដ្ឋិដ៏ក្រាស់ទាំងឡាយ ព្រោះទិដ្ឋិដ៏ក្រាស់ ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកបុគ្គលអ្នកមានទិដ្ឋិដូចជាកំពង់ តាំងនៅស៊ប់ ក្នុងទិដ្ឋិដ៏ច្រើន យ៉ាងនេះឯង ។*

[២៧១] សកាយនេ តត្ថ ទឡ្ហំ វទានាតិ ធម្មោ សកាយនំ ទិដ្ឋិ សកាយនំ បដិបទា សកាយនំ មគ្គោ សកាយនំ ។ សកាយនេ ទឡ្ហវាទា ថិរវាទា ពលិកវាទា អវដ្ឋិតវាទាតិ សកាយនេ តត្ថ ទឡ្ហំ វទានា ។ តេនាហ ភគវា

ឥធេវ សុទ្ធឹ ឥតិ វាទយន្តិ
នាញ្ញេសុ ធម្មេសុ វិសុទ្ធិមាហុ
ឯវម្បិ តិត្ថ្យា បុថុសោ និវិដ្ឋា
សកាយនេ តត្ថ ទឡ្ហំ វទានាតិ ។

[២៧២] សកាយនេ វាបិ ទឡ្ហំ វទានោ
កមេត្ថ[១] ពាលោតិ បរំ ទហេយ្យ
សយមេវ សោ មេធគំ អាវហេយ្យ
បរំ វទំ ពាលមសុទ្ធិធម្មំ ។

[២៧៣] សកាយនេ វាបិ ទឡ្ហំ វទានោតិ ធម្មោ សកាយនំ ទិដ្ឋិ សកាយនំ បដិបទា សកាយនំ មគ្គោ សកាយនំ ។ សកាយនេ ទឡ្ហវាទោ ថិរវាទោ

១ ម. កំ តត្ថ ។

ចូឡវិយូហសុត្តនិទ្ទេស ទី ១២

[២៧១] ពាក្យថា ប្រកាន់មាំក្នុងសកាយនៈនោះ គឺ ធម៌ឈ្មោះថាសកាយនៈ ទិដ្ឋិឈ្មោះថាសកាយនៈ បដិបទាឈ្មោះថាសកាយនៈ មគ្គឈ្មោះថាសកាយនៈ ។ ជនទាំងឡាយ មានវាទៈមាំមួន មានវាទៈរឹងត្អឹង មានវាទៈដ៏មានកម្ទាំង មានវាទៈខ្ជាប់ខ្ជួន ក្នុងសកាយនៈ ហេតុនោះ (ទ្រង់ត្រាស់ថា) ប្រកាន់មាំក្នុងសកាយនៈនោះ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

> បុគ្គលទាំងឡាយរមែងពោលថា សេចក្ដីបរិសុទ្ធក្នុងធម៌នេះ ឯង មិនពោលនូវសេចក្ដីបរិសុទ្ធ ក្នុងធម៌ទាំងឡាយឯទៀត ទេ ពួកបុគ្គលអ្នកមានលទ្ធិដូចជាកំពង់ តាំងនៅស៊ីប់ក្នុង ទិដ្ឋិដ៏ច្រើន យ៉ាងនេះឯង ប្រកាន់មាំក្នុងសកាយនៈនោះ ។

[២៧២] មួយទៀត បុគ្គលប្រកាន់មាំក្នុងសកាយនៈ តែងយល់ នូវបុគ្គលដទៃណាមួយ ថាជាបុគ្គលពាល ក្នុងសកាយនៈនុ៎ះ បុគ្គលនោះ កាលពោលនូវបុគ្គលដទៃថាពាល ថាមានធម៌ មិនបរិសុទ្ធ តែងនាំមកនូវជម្លោះខ្លួនឯង ។

[២៧៣] ពាក្យថា មួយទៀត បុគ្គលប្រកាន់មាំ ក្នុងសកាយនៈ គឺ ធម៌ឈ្មោះថាសកាយនៈ ទិដ្ឋិឈ្មោះថាសកាយនៈ បដិបទាឈ្មោះថាសកា-យនៈ មគ្គឈ្មោះថាសកាយនៈ ។ បុគ្គលមានវាទៈមាំមួន មានវាទៈរឹងត្អឹង

ពលិកភាវោ អវដ្ឋិតភាវោតិ សកាយនេ ភាបិ ឧជ្ជុ
ភាវោ ។

[២៧៤] កមេត្ត ពាលោតិ បរំ ឧហេយ្យាតិ ឯត្ថាតិ
សកាយ ទិដ្ឋិយា សកាយ ខន្តិយា សកាយ រុចិយា
សកាយ លទ្ធិយា បរំ ពាលតោ ហីនតោ និហីនតោ
ឋិមកតោ លាមកតោ ជតុក្ក្ហតោ បរិត្តតោ កំ
ឧហេយ្យ កំ បស្សេយ្យ កំ ឧក្ខេយ្យ កំ
ឱលោកេយ្យ កំ ឧជ្ឈាយេយ្យ កំ ឧបបរិក្ខេយ្យាតិ
កមេត្ត ពាលោតិ បរំ ឧហេយ្យ ។

[២៧៥] សយមេវ សោ មេធកំ អាវហេយ្យ បរំ វជ
ពាលមសុទ្ធិធម្មន្តិ បភេ ពាលោ ហីនោ និហីនោ ឋិមកោ
លាមកោ ជតុក្ក្ហោ បរិត្តោ អសុទ្ធិធម្មោ អវិសុទ្ធិធម្មោ

មានវាទ:ដ៏មានកម្ទាំង មានវាទ:ខ្ជាប់ខ្ជួន ក្នុងសកាយន: ហេតុនោះ (ទ្រង់ត្រាស់ថា) មួយទៀត បុគ្គលប្រកាន់មាំ ក្នុងសកាយន: ។

[២៧៤] ពាក្យថា តែងយល់ នូវបុគ្គលដទៃណាមួយ ថាជាបុគ្គលពាល ក្នុងសកាយន:នុ៎ះ ត្រង់ពាក្យថា នុ៎ះ គឺតែងយល់អ្នកណា ឃើញអ្នកណា មើលអ្នកណា ក្រឡេកឃើញអ្នកណា សម្ងឹងឃើញអ្នកណា រំពឹងឃើញអ្នកណា ដទៃ ថាជាបុគ្គលពាល ថោកទាប ថោកថយ ទន់ទាប លាមក គម្រក់ អាប់ឱន តាមទិដ្ឋិរបស់ខ្លួន តាមសេចក្ដីគួរ របស់ខ្លួន តាមសេចក្ដីគាប់ចិត្តរបស់ខ្លួន តាមលទ្ធិ របស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) តែងយល់នូវបុគ្គលដទៃណាមួយ ថាជាបុគ្គលពាល ក្នុងសកាយន:នុ៎ះ ។

[២៧៥] ពាក្យថា បុគ្គលនោះ កាលពោលនូវបុគ្គលដទៃ ថាជាបុគ្គលពាល ថាមានធម៌មិនបរិសុទ្ធ តែងនាំមកនូវជម្លោះខ្លួនឯង សេចក្ដីថា បុគ្គលកាលពោលយ៉ាងនេះ ថ្ងៃងយ៉ាងនេះ ពណ៌នាយ៉ាងនេះ ពន្យល់យ៉ាងនេះ អធិប្បាយយ៉ាងនេះថា បុគ្គលនេះអាប់ឱន ពាល ថោកទាប ថោកថយ ទន់ទាប លាមក គម្រក់ កម្ទេចកម្ទី មានធម៌មិនស្អាត មានធម៌មិនស្អាតស្ងុ

អបរិសុទ្ធិធម្មោ អភាវិតធម្មោតិ ឯវំ វិធន្តោ ឯវំ កាថេន្តោ ឯវំ ភណន្តោ ឯវំ ទីបយន្តោ ឯវំ វោហរន្តោ សយមេវ កលហំ ភណ្ឌនំ វិគ្គហំ វិវាទំ មេធគំ អាវហេយ្យ សមាវហេយ្យ អាហរេយ្យ សមាហរេយ្យ អាកឌ្ឍេយ្យ សមាកឌ្ឍេយ្យ គណ្ហេយ្យ បរាមសេយ្យ អភិនិវិសេយ្យាតិ សយមេវ សោ មេធគំ អាវហេយ្យ បរំ វទំ ពាលមសុទ្ធិធម្មំ ។ តេនាហ ភគវា

សកាយនេ វាបិ ទឡ្ហំ វទានោ
កមេត្ថ ពាលោតិ បរំ ទហេយ្យ
សយមេវ សោ មេធគំ អាវហេយ្យ
បរំ វទំ ពាលមសុទ្ធិធម្មន្តិ ។

[២៧៦] វិនិច្ឆយេ ឋត្វា សយំ បមាយ
ឧទ្ធំ សោ លោកស្មឹ វិវាទមេតិ
ហិត្វាន សព្វានិ វិនិច្ឆយានិ
ន មេធគំ កុព្វតេ[១] ជន្តុ លោកេ ។

១ ម. កុព្វតិ ។

ចូឡវិយូហសុត្តនិទ្ទេស ទី ១២

មានធម៌មិនបរិសុទ្ធ មានធម៌មិនផ្ទរផង់ គប្បីនាំមក នាំមកព្រម ប្រមូលមក ប្រមូលមកព្រម ទាញមក ទាញមកព្រម ប្រកាន់ បណ្ដោសអង្អែលអាស្រ័យ នូវជម្ងោ នូវសេចក្ដីប្រកួតប្រកាន់ នូវសេចក្ដីប្រកាន់ខុស នូវជម្ងោ នូវការប្រណាំងប្រជែង ដោយខ្លួនឯង ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ កាលពោលនូវបុគ្គលដទៃ ថាជាបុគ្គលពាល ថាមានធម៌មិនបរិសុទ្ធ តែងនាំមកនូវជម្ងោះខ្លួនឯង ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

មួយទៀត បុគ្គលប្រកាន់មាំ ក្នុងសកាយនៈ តែងយល់នូវបុគ្គលដទៃណាមួយ ថាជាបុគ្គលពាល ក្នុងសកាយនៈ នុ៎ះ បុគ្គលនោះ កាលពោលនូវបុគ្គលដទៃ ថាជាបុគ្គលពាល ថាមានធម៌មិនបរិសុទ្ធ តែងនាំមកនូវជម្ងោះខ្លួនឯង ។

[២៧៦] *ជននោះតាំងនៅក្នុងវិនិច្ឆ័យ ប្រមាណយកដោយខ្លួនឯងហើយ រមែងដល់ នូវការទាស់ទែង ក្នុងលោកតទៅ ជនលះបង់ នូវវិនិច្ឆ័យទាំងពួង រមែងមិនធ្វើ នូវជម្ងោះ ក្នុងលោក ។*

[២៧៧] វិជិច្ឆយេ បត្វា សយំ បមាយាតិ វិជិច្ឆយា វុច្ចន្តិ ទ្វាសដ្ឋី ទិដ្ឋិគតានិ[១] វិនិច្ឆិតទិដ្ឋិយា បត្វា បតិដ្ឋ-ហិត្វា គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វាតិ វិជិច្ឆយេ បត្វា ។ សយំ បមាយាតិ សយំ បមាយ បមិនិត្វា អយំ សត្ថា សព្វញ្ញូតិ សយំ បមាយ បមិនិត្វា អយំ ធម្មោ ស្វាក្ខាតោ អយំ គណោ សុប្បដិបន្នោ អយំ ទិដ្ឋិ ភទ្ទិកា អយំ បដិបទា សុប្បញ្ញត្តា អយំ មគ្គោ និយ្យា-និកោតិ សយំ បមាយ បមិនិត្វាតិ វិជិច្ឆយេ បត្វា សយំ បមាយ ។

[២៧៨] ឧទ្ធំ សោ[២] លោកស្មឹ វិវាទមេតីតិ ឧទ្ធំ[៣] វុច្ចតិ អនាគតំ ។ អត្តនោ វាទំ ឧទ្ធំ បបេត្វា សយមេវ កលហំ ភណ្ឌនំ វិគ្គហំ វិវាទំ មេធគំ ឯតិ ឧបេតិ ឧបគច្ឆតិ គណ្ហាតិ បរាមសតិ អភិនិវិសតីតិ ឯវម្បិ ឧទ្ធំ សោ លោកស្មឹ វិវាទមេតិ ។

១ ឱ. ឯត្ថន្តរេ វិនិច្ឆយេតិ ទិស្សតិ ។ ២ ម. ស ។ ៣ ម. ឧទ្ធំ សោ ។

[២៧៧] ពាក្យថា ជនតាំងនៅក្នុងវិនិច្ឆ័យ ប្រមាណយកដោយខ្លួនឯងហើយ សេចក្តីថា ទិដ្ឋិ ៦២ លោកហៅថា វិនិច្ឆ័យ ជនតាំងនៅ តាំងនៅស៊ប់ ប្រកាន់ បង្ហាសអង្ហែល អាស្រ័យ ក្នុងទិដ្ឋិដែលខ្លួនសម្រេចហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ជនតាំងនៅក្នុងវិនិច្ឆ័យ ។ ពាក្យថា ប្រមាណយកដោយខ្លួនឯងហើយ គឺប្រមាណយក ស្មានយកដោយខ្លួនឯង គឺប្រមាណយក ស្មានយក ដោយខ្លួនឯងថា សាស្តានេះជាសព្វញ្ញូ ប្រមាណយក ស្មានយក ដោយខ្លួនឯងថា ធម៌នេះ ដែលសាស្តាសម្តែងល្អហើយ ពួកនេះប្រតិបត្តិត្រូវ ទិដ្ឋិនេះចម្រើន បដិបទានេះ សាស្តាបញ្ញត្តល្អហើយ មគ្គនេះ ជាទីស្រោចស្រង់សត្ត ហេតុនោះ (ទ្រង់ត្រាស់ថា) ជនតាំងនៅក្នុងវិនិច្ឆ័យ ប្រមាណយកដោយខ្លួនឯងហើយ ។

[២៧៨] ពាក្យថា ជននោះរមែងដល់នូវការទាស់ទែង ក្នុងលោកតទៅ សេចក្តីថា អនាគត លោកហៅថា តទៅ ។ ជនតាំងទុកនូវវាទៈរបស់ខ្លួនតទៅ ហើយដល់ ចូលដល់ ចូលទៅជិត កាន់យក បង្ហាសអង្ហែលអាស្រ័យ នូវជម្លោះ នូវការប្រកួតប្រកាន់ នូវការប្រកាន់ខុស នូវការទាស់ទែង នូវការប្រណាំងប្រជែង ដោយខ្លួនឯង ហេតុនោះ (ទ្រង់ត្រាស់ថា) ជននោះ រមែងដល់នូវការទាស់ទែង ក្នុងលោកតទៅ យ៉ាងនេះខ្លះ ។

អថវា អញ្ញេន ឧទ្ធំ វាទេន សទ្ធឹ កលហំ ករោតិ ភណ្ឌនំ ករោតិ វិគ្គហំ ករោតិ វិវាទំ ករោតិ មេធគំ ករោតិ ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ ។ បេ ។ និព្ពេឋេហិ វា សចេ បហោសីតិ ឯវម្បិ ឧទ្ធំ សោ លោកស្មឹ វិវាទមេតិ ។

[២៧៩] ហិត្វាន សព្វានិ វិនិច្ឆយានីតិ វិនិច្ឆយា វុច្ចន្តិ ទ្វាសដ្ឋី ទិដ្ឋិគតានិ ។ សព្វា វិនិច្ឆិតទិដ្ឋិយោ ហិត្វា ចជិត្វា បរិច្ចជិត្វា ជហិត្វា បជហិត្វា វិនោទិត្វា ព្យន្តីករិត្វា អនភាវង្គមេត្វាតិ ហិត្វាន សព្វានិ វិនិច្ឆយានិ ។

[២៨០] ន មេធគំ កុព្វេថ ជន្តុ លោកេតិ ន កលហំ ករោតិ ន ភណ្ឌនំ ករោតិ ន វិគ្គហំ ករោតិ ន វិវាទំ ករោតិ ន មេធគំ ករោតិ ។ វុត្តំ ហេតំ ភគវតា ឯវំ វិមុត្តចិត្តោ ខោ អគ្គិវេស្សន ភិក្ខុ ន កេនចិ សំវទតិ ន កេនចិ វិវទតិ យញ្ច លោកេ វុត្តំ តេន ច វោហរតិ អបរាមសន្តិ ។

មួយទៀត (បុគ្គលនោះ) តែងធ្វើជម្លោះ ធ្វើសេចក្តីប្រកួតប្រកាន់ ធ្វើសេចក្តីប្រកាន់ខុស ធ្វើការទាស់ទែង ធ្វើការប្រណាំងប្រជែង ជាមួយនឹងវាទ:នៃជនដទៃ តទៅ ថា អ្នកមិនចេះធម្មវិន័យនេះទេ ។ បេ ។ ឬបើអ្នកអាច ចូរអ្នកដោះស្រាយចុះ ហេតុនោះ (ទ្រង់ត្រាស់ថា) ជននោះរមែងដល់នូវការទាស់ទែង ក្នុងលោកតទៅ យ៉ាងនេះខ្ទះ ។

[២៧៩] *ពាក្យថា ជនលះបង់នូវវិនិច្ឆ័យទាំងពួង សេចក្តីថា ទិដ្ឋិ ៦២ លោកហៅថា វិនិច្ឆ័យ ។ ជនលះបង់ លះលែង លះចោល កម្ចាត់បង់ កម្ចាត់បង់ស្រឡះ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាពតទៅទៀត នូវទិដ្ឋិដែលខ្ជូនវិនិច្ឆ័យទាំងអស់ ហេតុនោះ (ទ្រង់ត្រាស់ថា) ជនលះបង់នូវវិនិច្ឆ័យទាំងពួង ។*

[២៨០] *ពាក្យថា ជនរមែងមិនធ្វើជម្លោះក្នុងលោក សេចក្តីថា រមែងមិនធ្វើជម្លោះ មិនធ្វើសេចក្តីប្រកួតប្រកាន់ មិនធ្វើសេចក្តីប្រ-កាន់ខុស មិនធ្វើសេចក្តីទាស់ទែង មិនធ្វើនូវសេចក្តីប្រណាំងប្រជែង ។ សមដូចព្រះតម្រាស់នេះ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលអគ្គិ-វេស្សន: ភិក្ខុដែលមានចិត្តផុតស្រឡះ យ៉ាងនេះហើយ រមែងមិនពោលប្រកាន់ជាមួយបុគ្គលណាមួយ មិនជជែកជាមួយបុគ្គលណាមួយ និយាយតែពាក្យណា ដែលគេនិយាយក្នុងលោកនោះ តែមិនប្រកាន់ ។*

ជន្តូតិ សត្តោ ជនោ មានវោ ចោសោ បុគ្គលោ ជីវោ ជាតុ ជន្តុ ឥន្ទ្រកូ មនុជោ ។ លោកោតិ អចាយលោកោ មនុស្សលោកោ ទេវលោកោ ខន្ធ-លោកោ ជាតុលោកោ អាយតនលោកោតិ ន មេ ឆកំ ក្ករុតេ ជន្តុ លោកោ ។ តេនាហ ភគវា

វិនិច្ឆយេ ឋត្វា សយំ ឋមាយ
ឧទ្ធំ សោ លោកស្មឹ វិវាទមេតិ
ហិត្វាន សញ្ញានិ វិនិច្ឆយានិ
ន មេ ឆកំ ក្ករុតេ ជន្តុ លោកោតិ ។

ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ និដ្ឋិតោ ។

ពាក្យថា ជន បានដល់សត្ត្ว នរ: មាណព បុរស បុគ្គល ជនមានជីវិត ជនមានជាតិ ជនអ្នកកើត ជនទៅដោយឥន្ទ្រិយ ជនអ្នកកើតអំពីមនុស្ស ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) ជនរមែងមិនធ្វើនូវជម្លោះ ក្នុងលោក ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ជននោះតែងនៅក្នុងវិនិច្ឆ័យ ប្រមាណយកដោយខ្លួនឯងហើយ រមែងដល់នូវការទាស់ទែង ក្នុងលោកតទៅ ជនលះបង់នូវវិនិច្ឆ័យទាំងពួង រមែងមិនធ្វើ នូវជម្លោះ ក្នុងលោក ។

ចប់ ចូឡវិយូហសុត្តនិទ្ទេស ទី ១២ ។

តេរសមោ មហាវិយូហសុត្តនិទ្ទេសោ

[២៨១] យេកេចិមេ ទិដ្ឋិបរិព្វុសានា
ឥធមេវ សច្ចន្តិ បវាទយន្តិ[1]
សព្វេ តេ ទិន្នមជ្ឌានយន្តិ
អថោ បសំសម្ជិ លភន្តិ ឥត្ត ។

[២៨២] យេកេចិមេ ទិដ្ឋិបរិព្វុសានាតិ យេកេចីតិ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្ស្ជសំ បរិយាទាយវចនមេតំ[2] យេកេចីតិ ។ ទិដ្ឋិបរិព្វុសានាតិ សន្តេកេ សមណាព្រាហ្មណា ទិដ្ឋិគតិកា តេ ទ្វាសដ្ឋិយា ទិដ្ឋិគតានំ អញ្ញតរញ្ញតរំ ទិដ្ឋិគតំ គហេត្វា ឧគ្គហេត្វា គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វា សកាយ សកាយ ទិដ្ឋិយា វសន្តិ សំវសន្តិ អាវសន្តិ បរិវសន្តិ ។ យថា អាការិកា វ ឃរេសុ វសន្តិ សាបត្តិកា វ អាបត្តីសុ វសន្តិ សកិលេសោ វ កិលេសេសុ វសន្តិ ឯវមេវ សន្តេកេ សមណាព្រាហ្មណា ទិដ្ឋិគតិកា តេ ទ្វាសដ្ឋិយា ទិដ្ឋិគតានំ អញ្ញតរញ្ញតរំ ទិដ្ឋិគតំ គហេត្វា ឧគ្គហេត្វា គណ្ហិត្វា បរាមសិត្វា

---

១ ម. សច្ចន្តិ ច វាទយន្តិ ។ ២ ម. បរិយាទិយនវចនមេតំ ។

មហាវិយូហសុត្តនិទ្ទេស ទី ១៣

[២៨១] (ព្រះពុទ្ធនិម្មិតត្រាស់សួរថា) ពួកសមណព្រាហ្មណ៍ណាមួយត្រាំនៅក្នុងទិដ្ថិ តែងសម្តែងថា ពាក្យនេះឯង ជាពាក្យពិត តើសមណព្រាហ្មណ៍ទាំងអស់នោះ នឹងនាំមកនូវពាក្យនិន្ទាតែម្យ៉ាងឬ ឬក៏បានពាក្យសរសើរក្នុងហេតុនោះដែរ ។

[២៨២] *អធិប្បាយពាក្យថា ពួកសមណព្រាហ្មណ៍ណាមួយ ត្រាំនៅក្នុងទិដ្ថិ ពាក្យថា ណាមួយ គឺ គ្រប់ទាំងអស់ សព្វទាំងមូល មិនសេសសល់ ឥតសេសសល់ ពាក្យថា ណាមួយ នេះជាពាក្យអស់រលីង ។ ពាក្យថា ត្រាំនៅក្នុងទិដ្ថិ សេចក្តីថា មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកលុះក្នុងទិដ្ថិ សមណព្រាហ្មណ៍ទាំងនោះ កាន់ ក្ជប-កាន់ ប្រកាន់ ស្ទាបអង្អែល ប្រកាន់ស្អិត បណ្តាទិដ្ថិ ៦២ នូវទិដ្ថិណាមួយ ហើយនៅ នៅរួម នៅទួទៅ នៅត្រាំ ក្នុងទិដ្ថិរបស់ខ្លួន ។ ។ ពួកជនអ្នកគ្រប់គ្រងផ្ទះក្តី រមែងនៅក្នុងផ្ទះ ពួកភិក្ខុអ្នកត្រូវអាបត្តិក្តី រមែងនៅក្នុងអាបត្តិ ពួកជនមានកិលេសក្តី តែងនៅក្នុងកិលេស យ៉ាងណាមិញ មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកលុះក្នុងទិដ្ថិ ក៏យ៉ាងនោះដែរ សមណព្រាហ្មណ៍ទាំងនោះ កាន់ ក្ជបកាន់ ប្រកាន់ ស្ទាបអង្អែល*

អកិនិវិសិត្វា សកាយ សកាយ ទិដ្ឋិយា វសន្តិ សំវសន្តិ អាវសន្តិ បរិវសន្តីតិ យេកេចិមេ ទិដ្ឋិបរិព្ភូសាធ ។

[២៨៣] ឥធមេវ សច្ចន្តិ បវាទយន្តីតិ សស្សតោ លោកោ ឥធមេវ សច្ចំ មោឃមញ្ញន្តិ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ ភោវន្តិ អសស្សតោ លោកោ ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្ម-រណា ឥធមេវ សច្ចំ មោឃមញ្ញន្តិ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ ភោវន្តីតិ ឥធមេវ សច្ចន្តិ បវាទយន្តិ ។

[២៨៤] សព្វេ តេ ទិដ្ឋមជ្ឌានយន្តីតិ សព្វេ តេ សមណាព្រាហ្មណា ទិដ្ឋមេវ អនេន្តិ ករហាមេវ អនេន្តិ អកិត្តិមេវ អនេន្តិ សព្វ ទិដ្ឋិតាយេវ ហោន្តិ ករហិតាយេវ ហោន្តិ អកិត្តិតាយេវ ហោន្តីតិ សព្វេ តេ ទិដ្ឋមជ្ឌាន-យន្តិ ។

ប្រកាន់ស្អិត បណ្ដាទិដ្ឋិ ៦២ នូវទិដ្ឋិណាមួយ ហើយនៅ នៅរួម នៅ ទ្ទូទៅ នៅត្រាំ ក្នុងទិដ្ឋិរបស់ខ្លួន ។ ។ ហេតុនោះ (ទ្រង់ត្រាស់សួរថា) ពួកសមណព្រាហ្មណ៍ណាមួយ ត្រាំនៅក្នុងទិដ្ឋិ ។

[២៨៣] ពាក្យថា តែងសម្ដែងថា ពាក្យនេះឯង ជាពាក្យពិត គឺ តែងពោល សម្ដែង ពណ៌នា បំភ្ញ ថ្លែងថា លោកទ្ទៀង ពាក្យ នេះឯងពិត ពាក្យដទៃជាមោឃ: តែងពោល សម្ដែង ពណ៌នា បំភ្ញ ថ្លែងថា លោកមិនទ្ទៀង ។ បេ ។ សត្វស្ទាប់ទៅ កើតទ្ទៀតក៏មិនមែន មិនកើតទ្ទៀតក៏មិនមែន ពាក្យនេះឯងពិត ពាក្យដទៃជាមោឃ: ហេតុ នោះ (ទ្រង់ត្រាស់សួរថា) តែងសម្ដែងថា ពាក្យនេះឯងជាពាក្យពិត ។

[២៨៤] ពាក្យថា តើសមណព្រាហ្មណ៍ទាំងអស់នោះ នឹងនាំមក នូវពាក្យនិន្ទាតែម្យ៉ាងឬ សេចក្ដីថា តើសមណព្រាហ្មណ៍ទាំងអស់នោះ នឹងនាំមកនូវនិន្ទា នាំមកនូវពាក្យតិះដ្ទៀល នាំមកនូវការសរសើរតែម្យ៉ាង គឺសមណព្រាហ្មណ៍ទាំងអស់នោះ ជាអ្នកត្រូវគេនិន្ទា ត្រូវគេតិះដ្ទៀល ត្រូវគេមិនសរសើរតែម្យ៉ាងឬ ហេតុនោះ (ទ្រង់ត្រាស់សួរថា) តើ សមណព្រាហ្មណ៍ទាំងអស់នោះ នឹងនាំមកនូវពាក្យនិន្ទាតែម្យ៉ាងឬ ។

[២៨៥] អថោ បសំសម្បិ លភន្តិ តត្ថាតិ តត្ថ សកាយ ទិដ្ឋិយា សកាយ ខន្តិយា សកាយ រុចិយា សកាយ លទ្ធិយា បសំសំ ថោមនំ កិត្តឹ វណ្ណហារិកំ លភន្តិ បដិលភន្តិ អធិគច្ឆន្តិ[១] វិន្ទន្តីតិ អថោ បសំសម្បិ លភន្តិ តត្ថ ។ តេនាហ សោ និម្មិតោ

យេកេចិមេ ទិដ្ឋិបរិព្វសានា
ឥទមេវ សច្ចន្តិ បវាទយន្តិ
សព្វេវ តេ និន្ទិមន្វានយន្តិ
អថោ បសំសម្បិ លភន្តិ តត្ថាតិ ។

[២៨៦] អប្បំ ហិ ឯតំ ន អលំ សមាយ
ទុវេ វិវាទស្ស ផលានិ ព្រូមិ
ឯតម្បិ ទិស្វា ន វិវាទយេថ
ខេមាភិបស្សំ អវិវាទភុម្មំ ។

១ ម. ឧបគច្ឆន្តិ ។

[២៨៥] ពាក្យថា ឬក៏បាននូវពាក្យសរសើរ ក្នុងហេតុនោះដែរ សេចក្ដីថា ឬក៏បាន បានចំពោះ បានប្រាកដ តែងបាន នូវពាក្យសរសើរ ពាក្យស្ងើច កិត្តិសព្ទ ពាក្យនាំមកនូវសេចក្ដីសរសើរ ក្នុងហេតុនោះ គឺ ក្នុងទិដ្ឋិរបស់ខ្លួន ក្នុងសេចក្ដីរបស់ខ្លួន ក្នុងសេចក្ដីពេញចិត្តរបស់ខ្លួន ក្នុងលទ្ធិរបស់ខ្លួននោះដែរ ហេតុនោះ (ទ្រង់ត្រាស់សួរថា) ឬក៏បាននូវពាក្យសរសើរ ក្នុងហេតុនោះដែរ ។ ហេតុនោះ ព្រះពុទ្ធនិម្មិត ត្រាស់សួរថា

> ពួកសមណព្រាហ្មណ៍ណាមួយ ត្រាំនៅក្នុងទិដ្ឋិ តែងសម្ដែងថា ពាក្យនេះឯង ជាពាក្យពិត តើសមណព្រាហ្មណ៍ទាំងអស់នោះ នឹងនាំមកនូវពាក្យនិន្ទាតែម្យ៉ាងឬ ឬក៏បាននូវពាក្យសរសើរ ក្នុងហេតុនោះដែរ ។

[២៨៦] (ព្រះមានព្រះភាគត្រាស់ថា) ផលគឺសេចក្ដីសរសើរ ន៏ុះ មានបន្ដិចបន្ដួច មិនអាចដើម្បីស្ងប់រម្ងាប់បានទេ តថាគតពោលនូវផលនៃវិវាទ ថាមាន ២ ប្រការ បុគ្គលកាលឃើញទោសនេះ ហើយឃើញច្បាស់នូវព្រះនិព្វាន ជាកូមិមិនមានវិវាទ ជាទីក្សេមក្សាន្ត រមែងមិនទាស់ទែងទេ ។

[២៨៧] អប្បំ ហិ ឯតំ ន អលំ សមាយាតិ អប្បំ ហិ ឯតន្តិ អប្បកំ ឯតំ ឱមកំ ឯតំ ថោកំ ឯតំ លាមកំ ឯតំ ឆតុក្កំ ឯតំ បរិត្តកំ ឯតន្តិ អប្បំ ហិ ឯតំ ។ ន អលំ សមាយាតិ នាលំ រាគស្ស សមាយ ទោសស្ស សមាយ មោហស្ស សមាយ កោធស្ស ឧបនាហស្ស មក្ខស្ស បឡាសស្ស ឥស្សាយ មច្ឆរិយស្ស មាយាយ សាឋេយ្យស្ស ថម្ភស្ស សារម្ភស្ស មានស្ស អតិមានស្ស មទស្ស បមាទស្ស សព្វក្កិលេសានំ សព្វទុច្ចរិតានំ សព្វទរថានំ សព្វបរិឡាហានំ សព្វសន្តាបានំ សព្វាកុសលាភិសង្ខារានំ សមាយ ឧបសមាយ វូបសមាយ និព្វានាយ បដិនិស្សគ្គាយ បដិប្បស្សទ្ធិយាតិ អប្បំ ហិ ឯតំ ន អលំ សមាយ ។

[២៨៨] ទុវេ វិវាទស្ស ផលានិ ព្រូមីតិ ទិដ្ឋិកលហស្ស ទិដ្ឋិភណ្ឌនស្ស ទិដ្ឋិវិគ្គហស្ស ទិដ្ឋិវិវាទស្ស ទិដ្ឋិមេធគស្ស ទ្វេ ផលានិ ហោន្តិ ជយបរាជយោ ហោតិ លាភាលាភោ ហោតិ យសាយសោ ហោតិ

[២៨៧] *អធិប្បាយពាក្យថា ផលគឺសេចក្តីសរសើរនុ៎ះ មានបន្ទិចបន្ទួច មិនអាចដើម្បីស្ងប់រម្ងាប់បានទេ ត្រង់ពាក្យថា ផលគឺសេចក្តីសរសើរនុ៎ះ មានបន្ទិចបន្ទួចទេ គឺផលនុ៎ះមានប្រមាណតិច ផលនុ៎ះអូនថយ ផលនុ៎ះថោក ផលនុ៎ះលាមក ផលនុ៎ះអាក្រក់ ផលនុ៎ះស្ពួចស្ពើង ហេតុនោះ (ទ្រង់ត្រាស់ថា) ផលនុ៎ះមានបន្ទិចបន្ទួច ។ ពាក្យថា មិនអាចដើម្បីរម្ងាប់បានទេ គឺមិនអាចដើម្បីរម្ងាប់រាគៈ ដើម្បីរម្ងាប់ទោសៈ ដើម្បីរម្ងាប់មោហៈ ដើម្បីរម្ងាប់កោធៈ ដើម្បីរម្ងាប់ ដើម្បីស្ងប់ស្ងាត់ ដើម្បីរលត់ ដើម្បីលះបង់ ដើម្បីគ្របសង្កត់ នូវឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង សេចក្តីអន្ទះអន្ទែងទាំងពួង អកុសលាភិ-សង្ខារទាំងពួង ហេតុនោះ (ទ្រង់ត្រាស់ថា) ផលគឺសេចក្តីសរសើរនុ៎ះ មានបន្ទិចបន្ទួច មិនអាចដើម្បីស្ងប់រម្ងាប់បានទេ ។*

[២៨៨] *ពាក្យថា តថាគតពោលនូវផលនៃវិវាទ ថាមាន ២ ប្រការ គឺតថាគតពណ៌នា ប្រាប់ សម្តែង បញ្ញត្ត ផ្តើម បើក ចែក ធ្វើឲ្យរាក់ ប្រកាសថា ជម្ងោះព្រោះទិដ្ឋិ ការប្រកាន់ព្រោះទិដ្ឋិ ការទាស់ទែងព្រោះទិដ្ឋិ ការវិវាទព្រោះទិដ្ឋិ ការបែកខ្ញែកព្រោះទិដ្ឋិ រមែងមានផល ២ ប្រការ គឺការឈ្នះនិងការចាញ់ លាភនិងឥតលាភ យសនិងឥតយស*

ជិជ្ជាបសំសោ ហោតិ សុខទុក្ខំ ហោតិ សោមនស្ស-ទោមនស្សំ ហោតិ ឥដ្ឋានិដ្ឋំ ហោតិ អនុនយប្បដិឆំ ហោតិ ឧក្ខ្លាតិនិក្ខ្លាតិ ហោតិ អនុរោធវិរោធো ហោតិ ។ អថវា តំ កម្មំ និរយសំវត្តនិកំ តិរច្ឆានយោនិកសំវត្ត-និកំ បិត្តិវិសយិកសំវត្តនិកន្តិ ព្រូមិ អាចិក្ខামি ទេសេមិ បញ្ញាបេមិ បដ្ឋបេមិ វិវរামি វិភជামি ឧត្តានីករোমি បការាសেমীতি ទុវে វিপাকস্স ফলানি ព្រូមি ។

[២៨៩] ឯតម្ជិ ជិស្វា ន វិបាកយេថាតិ ឯតម្ជិ ជិស្វាតិ ឯតំ អាទីនវំ ជិស្វា បស្ជិត្វា តុលយិត្វា តីរយិត្វា វិការយិត្វា វិភូតំ កត្វា ជិជ្ជិកលហេសុ ជិជ្ជិភណ្ឌនេសុ ជិជ្ជិវិត្តហេសុ ជិជ្ជិវិវាទេសុ ជិជ្ជិមេធគេសូតি ឯតម្ជិ ជិស្វា ។ ន វិបាកយេថាតি ন কলহং করেয্য ন ភណ្ឌនំ ការយ្យ ন វិត្តហং ការយ្យ ন វិវាទំ ការយ្យ ন មេធគំ ការយ្យ ការលហភណ្ឌនវិត្តហាវិវាទមេធគំ បជহেয্য វিনোদেয্য ব্যন্তীকরেয্য អនភাবংগমেয্য ការលហភណ្ឌនវិត្តហាវិវាទមេធគা អារតো អস্স বিরতো পটিবিরতো নিক্খন্তো নিস্সট্ঠো[1] বিপ্পমুত্তো

1. ឱ. បដិនិស្សដ្ឋោ ។ ម. និស្សដ្ឋោ ។

និន្ទានិងសរសើរ សុខនិងទុក្ខ សោមនស្សនិងទោមនស្ស អារម្មណ៍ជាទីប្រាថ្នានិងមិនជាទីប្រាថ្នា សេចក្តីអាណិតនិងការថ្នាំងថ្នាក់ ធូរចិត្តនិងតឹងចិត្ត ការត្រេកអរនិងក្រេវក្រោធ ម្យ៉ាងទៀត អំពើនោះ ជាអំពើប្រព្រឹត្តទៅដើម្បីនរក ប្រព្រឹត្តទៅដើម្បីកំណើតសត្វតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីប្រេតវិស័យ ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតពោលនូវផលនៃវិាទ ថាមាន ២ ប្រការ ។

[២៨៩] អធិប្បាយពាក្យថា បុគ្គលកាលឃើញទោសនេះហើយ រមែងមិនទាស់ទែងទេ ត្រង់ពាក្យថា ឃើញទោសនេះ គឺឃើញ ជួបជ្ជឹង ពិចារណា ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដ នូវទោស ក្នុងជម្លោះ ព្រោះទិដ្ឋិ ក្នុងការប្រកាន់ព្រោះទិដ្ឋិ ក្នុងការទាស់ទែងព្រោះទិដ្ឋិ ក្នុងការវិាទព្រោះទិដ្ឋិ ក្នុងការបែកខ្ញែកព្រោះទិដ្ឋិនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ឃើញនូវទោសនេះ ។ ពាក្យថា រមែងមិនទាស់ទែងទេ គឺរមែងមិនធ្វើនូវជម្លោះ មិនធ្វើនូវការប្រកាន់ មិនធ្វើនូវការទាស់ទែង មិនធ្វើនូវការវិាទ មិនធ្វើនូវការបែកខ្ញែក គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ដល់នូវការមិនកើតមាននូវជម្លោះ នូវការប្រកាន់ នូវការទាស់ទែង នូវវិាទ និងការបែកខ្ញែក ជាអ្នកធ្វាយ រៀរបង់ ជៀសវាង ឃ្លាតចេញ រលាស់ចេញ រួចស្រឡះ

វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យាតិ ឯតម្បិ ទិស្វា ន វិវាទយេថ ។

[២៩០] ខេមាភិបស្សំ អវិវាទភុម្មន្តិ អវិវាទភុម្មំ វុច្ចតិ អមតនិព្វានំ យោ សោ សព្វសង្ខារសមថោ សព្វុបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។ ឯតំ អវិវាទភុម្មំ ខេមតោ តាណតោ លេណតោ សរណតោ អភយតោ អច្ចុតតោ អមតតោ និព្វានតោ បស្សន្តោ ទក្ខន្តោ ឱលោកេន្តោ និជ្ឈាយន្តោ ឧបបរិក្ខន្តោតិ ខេមាភិបស្សំ អវិវាទភុម្មំ ។ តេនាហ ភគវា

អប្បំ ហិ ឯតំ ន អលំ សមាយ
ទុវេ វិវាទស្ស ផលានិ ព្រូមិ
ឯតម្បិ ទិស្វា ន វិវាទយេថ
ខេមាភិបស្សំ អវិវាទភុម្មន្តិ ។

ប្រាសចេញ ចាកជម្ងោ ចាកការប្រកាន់ ចាកការទាស់ទែង ចាកវិវាទ និងការបែកខ្ញែក តែងនៅដោយចិត្តដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលកាលឃើញទោសនេះហើយ រមែងមិនទាស់ទែងទេ ។

[២៩០] ពាក្យថា ឃើញច្បាស់នូវព្រះនិព្វាន ជាភូមិមិនមានវិវាទ ជាទីក្សេមក្សាន្ត អធិប្បាយថា អមតនិព្វាន ហៅថា ភូមិមិនមានវិវាទ បានខាង ការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់ទុក្ខ និព្វាន ។ បុគ្គលកាលឃើញ ប្រទះ រមិលមើល សម្ងឹងមើល ពិនិត្យមើល នូវភូមិមិនមានវិវាទនុ៎ះ ថាជាទីក្សេមក្សាន្ត ជាទីពំនាក់ ជាទីជ្រកកោន ជាទីរឭក ជាទីមិនមានភ័យ ជាទីទៀងទាត់ ជាទីមិនស្ងាប់ ជាទីមិនមានកិលេសជាគ្រឿងចាក់ស្រេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ឃើញច្បាស់នូវព្រះនិព្វាន ជាភូមិមិនមានវិវាទ ជាទីក្សេមក្សាន្ត ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ផលគឺសេចក្តីសរសើរនុ៎ះ មានបន្ទិចបន្ទួច មិនអាចដើម្បីរម្ងាប់
បានទេ តថាគតពោលនូវផលនៃវិវាទថាមាន២ប្រការ បុគ្គល
កាលឃើញទោសនេះហើយ ឃើញច្បាស់នូវព្រះនិព្វាន ជា
ភូមិមិនមានវិវាទ ជាទីក្សេមក្សាន្ត រមែងមិនទាស់ទែងទេ ។

[២៩១] យាកាចិមា សម្មតិយោ[1] បុថុជ្ជា
សញ្ញាវ ឯតា ន ឧបេតិ វិទ្ធា[2]
អនូបយោ សោ ឧបយំ កិមេយ្យ
ឥធ ្ឌ សុតេ ១ត្តិមកុព្ជមានោ ។

[២៩២] យាកាចិមា សម្មតិយោ បុថុជ្ជាតិ យា-
កាចីតិ សព្ជេន សព្ជំ សព្ជថា សព្ជំ អសេសំ និស្សេសំ
បរិយាឧាយវចនមេតំ យាកាចីតិ ។ សម្មតិយោតិ
សម្មតិយោ រុចូត្ត ្ជាសជ្ជ ឥជ្ជិកតានិ[3] ។ បុថុជ្ជាតិ
បុថុជ្ជនេហិ ជនិតា ្ជ តា សម្មតិយោតិ បុថុជ្ជា ។
បុថុជ្ជានជនេហិ ជនិតា ្ជ តា សម្មតិយោតិ បុថុជ្ជាតិ
យាកាចិមា សម្មតិយោ បុថុជ្ជា ។

[២៩៣] សញ្ញាវ ឯតា ន ឧបេតិ វិទ្ធាតិ វិទ្ធា
វិជ្ជាកតោ ញ្ជាណី វិការី មេជាវី សញ្ញាវ ឯតា
ឥជ្ជិសម្មតិយោ   នេតិ ន ឧបេតិ ន ឧបកច្ជតិ

---

១ ឱ. ម. សម្មុតិយោ ។ ២ ឱ. ម. វិទ្ធា ។ ៣ ឱ. ទិដ្ឋិគតានិ ទិដ្ឋិសម្មុតិយោ ។

[២៩១] *សម្មតិទាំងឡាយណាមួយ ដែលកើតអំពីបុថុជ្ជន អ្នកប្រាជ្ញរមែងមិនប្រកាន់នូវសម្មតិទាំងអស់ន៏ុះទេ (ព្រោះ) លោកមិនមានធម៌ជាគ្រឿងប្រកាន់ មិនធ្វើសេចក្តីចូលចិត្ត ក្នុងអារម្មណ៍ដែលខ្លួនឃើញហើយ ឮហើយទេ ធ្វើម្តេច នឹងដល់នូវធម៌ជាគ្រឿងប្រកាន់ ។*

[២៩២] *អធិប្បាយពាក្យថា សម្មតិទាំងឡាយណាមួយ ដែលកើតអំពីបុថុជ្ជន ត្រង់ពាក្យថា ណាមួយ គឺ គ្រប់ទាំងអស់ សព្វទាំងមូល មិនសេសសល់ ឥតសេសសល់ ពាក្យថា ណាមួយ នេះជាពាក្យអស់រលីង ។ ពាក្យថា សម្មតិទាំងឡាយ គឺ ទិដ្ឋិ ៦២ លោកហៅថា សម្មតិទាំងឡាយ ។ ពាក្យថា កើតអំពីបុថុជ្ជន គឺសម្មតិទាំងនោះ កើតអំពីបុថុជ្ជនទាំងឡាយ ហេតុនោះ ទើបឈ្មោះថា កើតអំពីបុថុជ្ជន ។ ឬថា សម្មតិទាំងនោះ កើតហើយអំពីជនផ្សេងៗ ដ៏ច្រើន ហេតុនោះ ទើបឈ្មោះថា កើតអំពីបុថុជ្ជន ហេតុនោះ (ទ្រង់ត្រាស់ថា) សម្មតិទាំង-ឡាយណាមួយ កើតអំពីបុថុជ្ជន ។*

[២៩៣] *ពាក្យថា អ្នកប្រាជ្ញរមែងមិនប្រកាន់នូវសម្មតិទាំងអស់ន៏ុះទេ គឺអ្នកប្រាជ្ញជាអ្នកដល់នូវវិជ្ជា មានញាណ មានប្រាជ្ញាភ្ញឺច្បាស់ មានប្រាជ្ញាជាគ្រឿងកម្ចាត់កិលេស មិនដល់ មិនចូលទៅជិត មិនចូលទៅរក*

ន គណ្ហាតិ ន បរាមសតិ នាភិនិវិសតីតិ សញ្ញាវ ឯតា ន ឧបេតិ វិទ្វា ។

[២៩៤] អនូបយោ សោ ឧបយំ កិមេយ្យាតិ ឧបយោតិ ទ្វេ ឧបយា តណ្ហូបយោ ច ទិដ្ឋូបយោ ច ។ បេ ។ អយំ តណ្ហូបយោ ។ បេ ។ អយំ ទិដ្ឋូបយោ ។ តស្ស តណ្ហូបយោ បហីនោ ទិដ្ឋូបយោ បដិនិស្សដ្ឋោ តណ្ហូបយស្ស បហីនត្តា ទិដ្ឋូបយស្ស បដិនិស្សដ្ឋត្តា អនុបយោ បុគ្គលោ កឹ រូបំ ឧបេយ្យ ឧបគច្ឆេយ្យ គណ្ហេយ្យ បរាមសេយ្យ អភិនិវិសេយ្យ អត្តា មេតិ ។ កឹ វេទនំ កឹ សញ្ញំ កឹ សង្ខារេ កឹ វិញ្ញាណំ កឹ គតឹ កឹ ឧបបត្តឹ កឹ បដិសន្ធឹ កឹ ភវំ កឹ សំសារំ កឹ វដ្តំ

មិនប្រកាន់ មិនស្ទាបអង្អែល មិនប្រកាន់ស្អិត នូវសម្មតិគឺទិដ្ឋិទាំងអស់ នុ៎ះទេ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកប្រាជ្ញរមែងមិនប្រកាន់ នូវសម្មតិទាំងអស់នុ៎ះទេ ។

[២៩២] *អធិប្បាយពាក្យថា លោកមិនមានធម៌ជាគ្រឿងប្រកាន់ ធ្វើម្តេចនឹងដល់នូវធម៌ជាគ្រឿងប្រកាន់ ត្រង់ពាក្យថា ធម៌ជាគ្រឿងប្រកាន់ បានដល់ធម៌ជាគ្រឿងប្រកាន់ ២ យ៉ាងគឺ ធម៌ជាគ្រឿងប្រកាន់គឺតណ្ហា ១ ធម៌ជាគ្រឿងប្រកាន់គឺទិដ្ឋិ ១ ។ បេ ។ នេះធម៌ជាគ្រឿងប្រកាន់គឺតណ្ហា ។ បេ ។ នេះធម៌ជាគ្រឿងប្រកាន់គឺទិដ្ឋិ ។ បុគ្គលនោះ លះបង់ធម៌ជាគ្រឿងប្រកាន់គឺតណ្ហា រលាស់ចោលធម៌ជាគ្រឿងប្រកាន់គឺទិដ្ឋិ បុគ្គលមិនមានធម៌ជាគ្រឿងប្រកាន់ ព្រោះលះបង់ធម៌ជាគ្រឿងប្រកាន់គឺតណ្ហា ព្រោះរលាស់ចោលធម៌ជាគ្រឿងប្រកាន់គឺទិដ្ឋិ គប្បីចូលទៅជិត ចូលទៅរកប្រកាន់ ស្ទាបអង្អែល ប្រកាន់ស្អិត នូវរូបថាជាខ្លួនរបស់អញដូចម្តេចកើត ។ គប្បីចូលទៅជិត ចូលទៅរក ប្រកាន់ ស្ទាបអង្អែលប្រកាន់ស្អិត នូវវេទនាដូចម្តេចកើត នូវសញ្ញាដូចម្តេចកើត នូវសង្ខារដូចម្តេចកើត នូវវិញ្ញាណដូចម្តេចកើត នូវគតិដូចម្តេចកើត នូវឧបបត្តិដូចម្តេចកើត នូវបដិសន្ធិដូចម្តេចកើត នូវភពដូចម្តេចកើត នូវសង្សារដូចម្តេចកើត នូវវដ្ដៈដូចម្តេចកើត*

ឧបេយ្យ ឧបគច្ឆេយ្យ គណ្ហេយ្យ បរាមសេយ្យ អភិនិ-វិសេយ្យាតិ អទ្វយោ សោ ឧបយំ កិមេយ្យ ។

[២៩៥] និដ្ឋេ សុតេ ខន្តិមកុព្វមានោតិ និដ្ឋេ វា និដ្ឋសុទ្ធិយា វា សុតេ វា សុតសុទ្ធិយា វា មុតេ វា មុត-សុទ្ធិយា វា ខន្តឹ អកុព្វមានោ ឆន្ទំ អកុព្វមានោ បេមំ អកុព្វមានោ រាគំ អកុព្វមានោ អជនយមានោ អស-ញ្ជនយមានោ អនិព្វត្តយមានោ នាភិនិព្វត្តយមានោតិ និដ្ឋេ សុតេ ខន្តិមកុព្វមានោ ។ តេនាហ ភគវា

យានីធ សម្មុតិយោ បុថុជ្ជា

សព្វាវ ឯតា ន ឧបេតិ វិទ្វា

អទ្វយោ សោ ឧបយំ កិមេយ្យ

និដ្ឋេ សុតេ ខន្តិមកុព្វមានោតិ ។

ហេតុនោះ (ទ្រង់ត្រាស់ថា) លោកមិនមានធម៌ជាគ្រឿងប្រកាន់ ធ្វើម្តេច នឹងដល់នូវធម៌ជាគ្រឿងប្រកាន់ ។

[២៩៥] ពាក្យថា មិនធ្វើនូវសេចក្តីចូលចិត្ត ក្នុងអារម្មណ៍ដែលខ្លួនឃើញហើយ ឮហើយទេ គឺមិនធ្វើសេចក្តីចូលចិត្ត មិនធ្វើសេចក្តីពេញចិត្ត មិនធ្វើសេចក្តីស្រឡាញ់ មិនធ្វើ មិនឲ្យកើត មិនឲ្យកើតព្រម មិនឲ្យលូតលាស់ មិនឲ្យដុះដាលឡើង នូវតម្រេកក្នុងអារម្មណ៍ ដែលឃើញ ឬក្នុងសេចក្តីបរិសុទ្ធព្រោះឃើញ ក្នុងអារម្មណ៍ដែលឮ ឬក្នុងសេចក្តីបរិសុទ្ធព្រោះឮ ក្នុងអារម្មណ៍ដែលប៉ះពាល់ ឬក្នុងសេចក្តីបរិសុទ្ធព្រោះប៉ះពាល់ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនធ្វើនូវសេចក្តីចូលចិត្ត ក្នុងអារម្មណ៍ដែលខ្លួនឃើញហើយ ឮហើយទេ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> សម្មតិទាំងឡាយណាមួយ ដែលកើតអំពីបុថុជ្ជន អ្នកប្រាជ្ញ
> រមែងមិនប្រកាន់នូវសម្មតិទាំងអស់ន៏ុះទេ (ព្រោះ) លោក
> មិនមានធម៌ជាគ្រឿងប្រកាន់ មិនធ្វើសេចក្តីចូលចិត្ត ក្នុង
> អារម្មណ៍ដែលខ្លួនឃើញហើយ ឮហើយទេ ធ្វើម្តេច នឹង
> ដល់នូវធម៌ជាគ្រឿងប្រកាន់ ។

[២៥៦] សីលុត្តមា សញ្ញមេជាហុ សុទ្ធឺ
រត្តំ សមាជាយ ឧបដ្ឋិតាសេ
ឥធេវ សិក្ខេម អថស្ស សុទ្ធឺ
ភវូបនីតា កុសលាវជាជា ។

[២៥៧] សីលុត្តមា សញ្ញមេជាហុ សុទ្ធិន្តិ សន្តេកេ សមណាព្រាហ្មណា សីលុត្តមវាជា តេ សីលមត្តេន សញ្ញមត្តេន សំវរមត្តេន អរីតិក្ខមមត្តេន សុទ្ធឺ វិសុទ្ធឺ បរិសុទ្ធឺ មុត្តឺ វិមុត្តឺ បរិមុត្តឺ អាហុ[១] វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ ជោតេន្តិ ។ សមណមុណ្ដិកាបុត្តោ ឯវមាហ ចតូហិ ខោ អហំ ថបតិ[២] ឆម្ភេហិ សមន្ទ្ធាតតំ បុរិស-បុគ្គលំ បញ្ញាបេមិ សម្ឆន្ទកុសលំ ឧបាយកុសលំ ឧត្តម-ប្ឆត្តិប្ឆត្តំ សមណំ អយោជ្ឈ៌ កតមេហិ ចតូហិ ឥធ ថបតិ ន ការយេន ចាបកម្ម៌ កវោតិ ន ចាបិកំ ជ្ជ៌ ការតិ ន ចាបកំ សន្ត្ថ្ជ៌ សន្ត្ថ្ជ៌ តិ ន ចាបកំ អាជ៌ីវ៌ អាជ៌ីវតិ

---

១ ម. អាហ៌ាសុ ។ ២ ម. ឧបាបតិ ។

[២៩៦] *សមណព្រាហ្មណ៍ទាំងឡាយ (ណា) ជាអ្នកប្រកាន់ថា សីលឧត្តម ប្រកាន់ស្ថិតនូវវត្ត បានពោលនូវសេចក្តីបរិសុទ្ធ ដោយការសង្រួមថា យើងសិក្សានូវសេចក្តីបរិសុទ្ធរបស់គ្រូ នោះ ក្នុងទិដ្ឋិនេះតែម្យ៉ាង (សមណព្រាហ្មណ៍ទាំងនោះ) ជាអ្នកប្រកាន់ថាខ្ជូនណ្ងាសវ៉ៃ រមែងជាអ្នកចូលទៅរកកត ។*

[២៩៧] *ពាក្យថា សមណព្រាហ្មណ៍ទាំងឡាយ (ណា) ជាអ្នកប្រកាន់ថាសីលឧត្តម បានពោលនូវសេចក្តីបរិសុទ្ធ ដោយការសង្រួមសេចក្តីថា មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកពោលថាសីលឧត្តម សមណព្រាហ្មណ៍ទាំងនោះ ពោល និយាយ សម្តែង ពណ៌នា បំភ្ញឹ ថ្វែងនូវសេចក្តីស្អាត ស្អាតវិសេស បរិសុទ្ធិ នូវការរួច រួចវិសេស រួចស្រឡះ ដោយគុណត្រឹមតែសីល ត្រឹមតែការសង្រួម ត្រឹមតែការរារាំង ត្រឹមតែការមិនប្រព្រឹត្តកន្ទង ។ (តួយ៉ាងដូច) សមណមុណ្ឌិកាបុត្ត បានពោលយ៉ាងនេះថា ម្នាលជាងឈើ ខ្ញុំបញ្ញត្តបុរសបុគ្គលដែលប្រកបដោយធម៌ ៤ ថាជាអ្នកមានកុសលបរិបូណ៌ មានកុសលដ៏ឧត្តម ដល់នូវគុណដែលគួរដល់ដ៏ខ្ពង់ខ្ពស់ ជាសមណៈដែលគេផ្ចាញ់មិនបាន ចុះធម៌ ៤ តើដូចម្តេច ម្នាលជាងឈើ បុគ្គលក្នុងលោកនេះ មិនធ្វើបាបកម្មដោយកាយ ១ មិនពោលពាក្យអាក្រក់ ១ មិនត្រិះរិះនូវតម្រិះអាក្រក់ ១ មិនចិញ្ចឹមជីវិតអាក្រក់ ១*

ឥមេហិ ខោ អហំ ចតូហិ ធម្មេហិ សមន្នាគតំ បុរិសបុគ្គលំ បញ្ញាបេមិ សម្បន្នកុសលំ បរមកុសលំ ឧត្តមប្បត្តិប្បត្តំ សមណំ អយោជ្ឈំ ។ ឯវមេវ សន្តេកេ សមណព្រាហ្មណា សីលុត្តមវាទា តេ សីលមត្តេន សញ្ញមមត្តេន សំវរមត្តេន អវីតិក្កមមត្តេន សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ អាហុ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ សីលុត្តមា សញ្ញមេនាហុ សុទ្ធឹ ។

[២៩៨] វត្តំ សមាទាយ ឧបដ្ឋិតាសេតិ វត្តន្តិ ហត្ថិវត្តំ វា អស្សវត្តំ វា គោវត្តំ វា អជវត្តំ វា កុក្កុរវត្តំ វា កាកវត្តំ វា វាសុទេវវត្តំ វា បុណ្ណភទ្ទវត្តំ វា មណិភទ្ទវត្តំ វា អគ្គិវត្តំ វា នាគវត្តំ វា សុបណ្ណវត្តំ វា យក្ខវត្តំ វា អសុរវត្តំ វា គន្ធព្វវត្តំ វា មហារាជវត្តំ វា ចន្ទវត្តំ វា សុរិយវត្តំ វា ឥន្ទវត្តំ វា ព្រហ្មវត្តំ វា ទេវវត្តំ វា ទិសវត្តំ វា អាទាយ សមាទាយ អាទយិត្វា[១] គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វា ឧបដ្ឋិតា បច្ចុបដ្ឋិតា អល្លីនា ឧបគតា អជ្ឈោសិតា អធិមុត្តាតិ វត្តំ សមាទាយ ឧបដ្ឋិតាសេ ។

១ ម. អាទិយិត្វា សមាទិយិត្វា ។

ម្នាលជាងឈើ ខ្ញុំបញ្ញត្តបុរសបុគ្គល ដែលប្រកបដោយធម៌ ៤ នេះឯងថា ជាអ្នកមានកុសលបរិបូណ៌ មានកុសលដ៏ឧត្តម ដល់នូវគុណដែលគួរដល់ដ៏ខ្ពង់ខ្ពស់ ជាសមណៈដែលគេផ្ចាញ់មិនបាន ។ មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកពោលថាសីលឧត្តម សមណព្រាហ្មណ៍ទាំងនោះ ពោលនិយាយ សម្តែង ពណ៌នា បំភ្ញឹ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ នូវការរួច រួចវិសេស រួចស្រឡះ ដោយគុណត្រឹមតែសីល ត្រឹមតែការសង្រួម ត្រឹមតែការរារាំង ត្រឹមតែការមិនប្រព្រឹត្តកន្ទង យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) សមណព្រាហ្មណ៍ទាំងឡាយជាអ្នកប្រកាន់ថាសីលឧត្តម បានពោលនូវសេចក្តីបរិសុទ្ធ ដោយការសង្រួម ។

[៣៤៥] ន ហិ តេន សុទ្ធឺ កុសលា វទន្តីតិ កុសលាតិ យេ តេ ខន្ធកុសលា ជាតុកុសលា អាយតនកុសលា បដិចូសមុប្ប្ធានកុសលា សតិប្ឆដ្ឋានកុសលា សម្ម្ធប្ឆជានកុសលា ឥទ្ធិចានកុសលា ឥន្ទ្រិយកុសលា ពលកុសលា ពោជ្ឆ្ជង្គកុសលា មគ្គកុសលា ផលកុសលា ជិញ្ជានកុសលា តេ កុសលា ឃ្ឆតិត្តញ្ញាណេន វ បុព្ជេជិវាសានុស្ឆតិញ្ញាណេន វ មំសចក្ខុជា វ ជិព្ជេន វ ចក្ខុជា ជាមរូបជស្ឆនេន សុទ្ធឺ ឃ្ឆសុទ្ធឺ ឃ្ឆសុទ្ធឺ មុត្តឺ ឃ្ឆមុត្តឺ ឃ្ឆមុត្តឺ ន ឃ្ឆទ្ធិ ន ភ្ជេន្ធិ ន ភណ្ឌន្ធិ ន ជីឃយន្ធិ ន ហ្ជេ ហ្ជ្ជ ន ហិ តេន សុទ្ធឺ កុសលា ឃ្ឆទ្ធិ ។ តេជាហ ភគ្ជ

ហេតុនោះ (ទ្រង់ត្រាស់ថា) លុះឃើញហើយ តែងដឹងនូវនាមរូបនោះឯង ។

[៣៥៤] ពាក្យថា បុគ្គលឃើញកាមច្រើន ក៏មាន ឃើញនាម-រូបតិច ក៏មាន គឺ ឃើញកាមច្រើនក្តី នាមរូបតិចក្តី ថាទៀង ថាសុខ ថាខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) ឃើញកាមច្រើនក៏មាន ឃើញនាមរូបតិចក៏មាន ។

[៣៥៥] អធិប្បាយពាក្យថា ចំណែកជនអ្នកឈ្វាសទាំងឡាយ មិនពោល នូវសេចក្តីបរិសុទ្ធ ដោយការឃើញនោះទេ ត្រង់ពាក្យថា ជនអ្នកឈ្វាស គឺជនណា ជាអ្នកឈ្វាសក្នុងខន្ធ អ្នកឈ្វាសក្នុងធាតុ អ្នកឈ្វាសក្នុងអាយតនៈ អ្នកឈ្វាសក្នុងបដិច្ចសមុប្បាទ អ្នកឈ្វាសក្នុងសតិប្បដ្ឋាន អ្នកឈ្វាសក្នុងសម្មប្បធាន អ្នកឈ្វាសក្នុងឥទ្ធិបាទ អ្នកឈ្វាសក្នុងឥន្ទ្រិយ អ្នកឈ្វាសក្នុងពលៈ អ្នកឈ្វាសក្នុងពោជ្ឈង្គៈ អ្នកឈ្វាសក្នុងមគ្គ អ្នកឈ្វាសក្នុងផល អ្នកឈ្វាសក្នុងព្រះនិព្វាន ជនអ្នកឈ្វាសទាំងនោះ រមែងមិនពោល មិនសម្តែង មិនពណ៌នា មិនបំភ្ញឹ មិនថ្លែង នូវសេចក្តីស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រ-ឡះ ដោយការឃើញនាមរូប ដោយបរចិត្តញ្ញាណក្តី ដោយបុព្វនិវាសា-នុស្សតិញ្ញាណក្តី ដោយមំសចក្ខុក្តី ដោយទិព្វចក្ខុក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) ចំណែកជនអ្នកឈ្វាសទាំងឡាយ មិនពោលនូវសេចក្តីបរិ-សុទ្ធ ដោយការឃើញនោះទេ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បស្សំ នហេ ឧក្ខិតិ ជាមរូបំ
ឧិស្ងាន ភាញ្ញសួតិ តានិមេវ
ការាមំ ពហុំ បស្ស្ពតុ អប្ប្ពកំ ភ
ន ហិ ត្ថេន សុទ្ធ្ធ ការុសលា ភ្ជន្ត្ដីតិ ។

[៣៤៦] ជិវិស្ស្ពាជ ន ហិ សុទ្ធ្ធិជាយោ
បកប្ប្ពិតំ[1] ជិជ្ជ្ជ បុរេក្ខ្ជ្ជ្ជ្ជ
យំ ជិសិ្ស្ពិតោ ត្ដ្ត សុកំ្ជ្ជ្ជ
សុទ្ធ្ធ្ជ្ជ[2] ត្ដ្ត ត្ដ្ជ[3] ។

[៣៤៧] ជិវិស្ស្ពាជ ន ហិ សុទ្ធ្ធិជាយោតិ ស្ស្ពតោ លោកោ ឥជមេ សច្ចំ មោ្ជ្ជ្ជ្ជ ជិវិស្ស្ពាជ ។ អ្ជ្ជ្ជ្ជ លោកោ ។ ។ ។ ជេ ហោតិ ជ ជ ហោតិ ត្ដ្ជ្ជ ប្ជ្ជ្ជ ឥជមេ សច្ចំ មោ្ជ្ជ្ជ្ជ ជិវិស្ស្ពាជ ។ ជ ហិ សុទ្ធ្ធិជាយោតិ ជិវិស្ស្ពាជ ជុទ្ធ្ធ-ជយោ ជុ្ជ្ជ្ជ្ជ[4] ជុ្ជ្ជ្ជ ជុ្ជ្ជ ជុ្ជ្ជ ជុ្ជ្ជ ជ ហិ សុទ្ធ្ធិជាយោ ។

---

1 ម. បកប្ជ្ជ ។ 2 ម. សុទ្ធ្ធ្ជ ។ 3 ម. ត្ដ្ជ ។ 4 ម. ជុ្ជ្ជ ។

នរជនកាលឃើញ តែងឃើញនាមរូប លុះឃើញហើយ រមែងដឹងនូវនាមរូបនោះឯង បុគ្គលឃើញកាមច្រើនក៏មាន ឃើញនាមរូបតិចក៏មាន ចំណែកជនអ្នកឈ្វាសទាំងឡាយ មិនពោលនូវសេចក្តីបរិសុទ្ធ ដោយការឃើញនោះទេ ។

[៣៥៦] *បុគ្គលណាជាអ្នកមានវាទ:តាំងនៅមាំ ដែលគេមិនអាចទូន្មានបានងាយ អ្នកធ្វើទិដ្ឋិដែលតែងតាំងហើយឲ្យជាប្រធាន បុគ្គលនោះអាស្រ័យសភាវ:ណា ជាអ្នកពោលថាល្អ ពោលថាបរិសុទ្ធ ក្នុងសភាវ:នោះ ឃើញថាពិតក្នុងសភាវ:នោះ ។*

[៣៥៧] *ពាក្យថា បុគ្គលណាជាអ្នកមានវាទ:តាំងនៅមាំ ដែលគេមិនអាចទូន្មានបានងាយ គឺជាអ្នកមានវាទ:តាំងនៅមាំថា លោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃ: ។ ជាអ្នកមានវាទ:តាំងនៅមាំថា លោកមិនទៀង ។ បេ ។ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃ: ។ ពាក្យថា ដែលគេមិនអាចទូន្មានបានងាយ គឺបុគ្គលអ្នកមានវាទ:តាំងនៅមាំ គេទូន្មានបានដោយក្រ ឲ្យដឹងបានដោយក្រ ឲ្យយល់បានដោយក្រ ឲ្យឃើញបានដោយក្រ ឲ្យជ្រះថ្លាបានដោយក្រ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលណាជាអ្នកមានវាទ:តាំងនៅមាំ ដែលគេមិនអាចទូន្មានបានងាយ ។*

[៣៤៨] បកប្បិតំ ទិដ្ឋិ បុរេក្ខរានោតិ បកប្បិតំ អភិសង្ខតំ សណ្ឋាបិតំ[១] ទិដ្ឋី បុរក្ខតោ បុរតោ កត្វា ចរតិ ទិដ្ឋិធជោ ទិដ្ឋិកេតុ ទិដ្ឋាធិបតេយ្យោ ទិដ្ឋិយា បរិវារិតោ ចរតីតិ បកប្បិតំ ទិដ្ឋិ បុរេក្ខរានោ ។

[៣៤៩] យំ និស្សិតោ តត្ថ សុភំវទានោតិ យំ និស្សិតោតិ យំ សត្ថារំ ធម្មក្ខានំ គណំ ទិដ្ឋី បដិបទំ មគ្គំ និស្សិតោ សន្និស្សិតោ[២] អល្លីនោ ឧបគតោ អជ្ឈោ-សិតោ អធិមុត្តោតិ យំ និស្សិតោ ។ តត្ថាតិ សកាយ ទិដ្ឋិយា សកាយ ខន្តិយា សកាយ រុចិយា សកាយ លទ្ធិយា ។ សុភំវទានោតិ សុភវាទោ សោភនវាទោ បណ្ឌិតវាទោ ធីរវាទោ ញាណវាទោ[៣] ហេតុវាទោ លក្ខណវាទោ ការណវាទោ ឋានវាទោ សកាយ លទ្ធិយាតិ យំ និស្សិតោ តត្ថ សុភំវទានោ ។

---

១ ម. កប្បិតាបកប្បិតា អភិសង្ខតា សណ្ឋបិតា ។ ២ ម. អានិស្សិតា ។ ៣ ម. ថិរវាទោ ញាយវាទោ ។

[៣៥៨] ពាក្យថា អ្នកធ្វើទិដ្ឋិដែលតែងតាំងហើយឲ្យជាប្រធាន គឺប្រព្រឹត្តធ្វើឲ្យជាប្រមុខ ធ្វើឲ្យជាប្រធាន នូវទិដ្ឋិដែលតែងតាំងហើយ តាក់តែងហើយ តម្កល់ទុកហើយ គឺថា ជាអ្នកមានទិដ្ឋិជាទង់ជ័យ មានទិដ្ឋិជាទង់ មានទិដ្ឋិជាអធិបតី ត្រូវទិដ្ឋិរួបរឹត ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកធ្វើនូវទិដ្ឋិដែលតែងតាំងហើយឲ្យជាប្រធាន ។

[៣៥៩] អធិប្បាយពាក្យថា អាស្រ័យនូវសការៈណា ជាអ្នកពោលថាល្អ ក្នុងសការៈនោះ ត្រង់ពាក្យថា អាស្រ័យនូវសការៈណា គឺអាស្រ័យ អាស្រ័យព្រម ជាប់ស្អិត ចូលទៅរក ជ្រុលជ្រប់ ខ្ជិនទៅរក នូវសាស្តា នូវធម៌ដែលសាស្តាពោលហើយ នូវគណៈ នូវទិដ្ឋិ នូវបដិបទា នូវមគ្គ ណា ហេតុនោះ (ទ្រង់ត្រាស់ថា) អាស្រ័យនូវសការៈណា ។ ពាក្យថា ក្នុងសការៈនោះ គឺក្នុងទិដ្ឋិរបស់ខ្លួន ក្នុងសេចក្តីចូលចិត្តរបស់ខ្លួន ក្នុងការពេញចិត្តរបស់ខ្លួន ក្នុងលទ្ធិរបស់ខ្លួន ។ ពាក្យថា ជាអ្នកពោលថាល្អ គឺជាអ្នកពោលថាល្អ ពោលថាស្អាត ពោលថាជាបណ្ឌិត ពោលថាជាអ្នកប្រាជ្ញ ពោលប្រកបដោយញាណ ពោលប្រកបដោយហេតុ ពោលប្រកបដោយលក្ខណៈ ពោលប្រកបដោយការណ៍ ពោលប្រកបដោយឋានៈ ក្នុងលទ្ធិរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) អាស្រ័យនូវសការៈណា ជាអ្នកពោលថាល្អ ក្នុងសការៈនោះ ។

[៣៦០] សុទ្ធីវគោ តត្ត តថទ្ធសា សោតិ សុទ្ធីវគោតិ សុទ្ធិវាគោ វិសុទ្ធិវាគោ បរិសុទ្ធិវាគោ ភោគាតវាគោ បរិយោគាតវាគោ ។ អថវា សុទ្ធិឧស្សគោ វិសុទ្ធិ-ឧស្សគោ បរិសុទ្ធិឧស្សគោ ភោគាតឧស្សគោ បរិយោ-គាតឧស្សគោតិ សុទ្ធីវគោ ។ តត្ថាតិ សកាយ ឋិដ្ឋិយា សកាយ ១ន្តិយា សកាយ រុចិយា សកាយ លទ្ធិយា ។ តថទ្ធសា សោតិ តថំ តច្ចំ ភូតំ យាថាវំ អវិបរីតន្តិ អទ្ធស អទ្ធក្ខិ អបស្ឃ បជិវិជ្ឈីតិ សុទ្ធីវគោ តត្ត តថទ្ធសា សោ ។ តេនាហ ភគវា

ជិវិស្ឃ្ភាឍ ន ហិ សុញ្ញិនាយោ
បកប្ឃិតំ ឋិដ្ឋិ បុរេក្ខ្ភាគោ
យំ ជិស្ឃ្ឃិតោ តត្ត សុកំវគាគោ
សុទ្ធីវគោ តត្ត តថទ្ធសា សោតិ ។

[៣៦០] *អធិប្បាយពាក្យថា បុគ្គលនោះ ជាអ្នកពោលថាបរិសុទ្ធ ឃើញថាពិត ក្នុងសភាវៈនោះ ត្រង់ពាក្យថា ជាអ្នកពោលថាបរិសុទ្ធ គឺជាអ្នកពោលថាស្អាត ពោលថាស្អាតវិសេស ពោលថាបរិសុទ្ធ ពោលថាផូរផង់ ពោលថាផូរផង់ក្រៃលែង ។ ឬថា ជាអ្នកឃើញថាស្អាត ឃើញថាស្អាតវិសេស ឃើញថាបរិសុទ្ធ ឃើញថាផូរផង់ ឃើញថាផូរផង់ក្រៃលែង ហេតុនោះ (ទ្រង់ត្រាស់ថា) ពោលថាបរិសុទ្ធ ។ ពាក្យថា ក្នុងសភាវៈនោះ គឺក្នុងទិដ្ឋិរបស់ខ្លួន ក្នុងការចូលចិត្តរបស់ខ្លួន ក្នុងការពេញចិត្តរបស់ខ្លួន ក្នុងលទ្ធិរបស់ខ្លួន ។ ពាក្យថា បុគ្គលនោះឃើញ ថាពិត គឺឃើញ មើលឃើញ យល់ចាក់ធ្ងុះ ថាពិត មិនឃ្យៀងឃ្លាត ប្រាកដ ពិតប្រាកដ មិនប្រែប្រួល ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ ជាអ្នកពោលថាបរិសុទ្ធ ឃើញថាពិតក្នុងសភាវៈនោះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា*

បុគ្គលណាជាអ្នកមានវាទៈតាំងនៅមាំ ដែលគេមិនអាចទូន្មានបានងាយ អ្នកធ្វើទិដ្ឋិដែលតែងតាំងហើយ ឲ្យជាប្រធាន បុគ្គលនោះអាស្រ័យសភាវៈណា ជាអ្នកពោលថាល្អ ពោលថាបរិសុទ្ធ ក្នុងសភាវៈនោះ ឃើញថាពិតក្នុងសភាវៈនោះ ។

[៣៦១] ន ព្រាហ្មណោ កប្បមុបេតិ សង្ខ្យំ
ន ទិដ្ឋិសារី ន បិ ញាណពន្ធុ
ញត្វា ច សោ សម្មតិយោ[1] បុថុជ្ជា
ឧបេក្ខតី ឧក្តហាណន្តិ មញ្ញេ ។

[៣៦២] ន ព្រាហ្មណោ កប្បមុបេតិ សង្ខ្យន្តិ ជាតិ បដិក្ខេបោ ។ ព្រាហ្មណោតិ សត្តន្នំ ធម្មានំ ពាហិ-តត្តា ព្រាហ្មណោ ។ បេ ។ អនិស្សិតោ តានិ បវុច្ចតេ ស ព្រហ្ម ។ កប្បាតិ ទ្វេ កប្បា តណ្ហាកប្បោ ច ទិដ្ឋិកប្បោ ច ។ បេ ។ អយំ តណ្ហាកប្បោ ។ បេ ។ អយំ ទិដ្ឋិកប្បោ ។ សង្ខ្យា វុច្ចតិ ញាណំ យា បញ្ញា បជានតា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ ន ព្រាហ្មណោ កប្បមុបេតិ សង្ខ្យន្តិ ព្រាហ្មណោ សង្ខ្យាយ ជានិត្វា តុលយិត្វា តីរយិត្វា វិការយិត្វា វិភូតំ កត្វា សព្វេ សង្ខ្យារា អនិច្ចាតិ សព្វេ សង្ខ្យារា ទុក្ខាតិ

---

1 ម. សម្មុតិយោ ។

[៣៦១] ព្រាហ្មណ៍ពិចារណាហើយ រមែងមិនដល់នូវការ
កំណត់ មិនលុះក្នុងទិដ្ឋិ ទាំងមិនមានផៅពង្សដោយញាណ
ព្រោះព្រាហ្មណ៍នោះ ដឹងសម្មតិទាំងឡាយ ដែលកើត
អំពីបុថុជ្ជន លោកព្រងើយកន្តើយ នឹងទិដ្ឋិដែលជនទាំង-
ឡាយដទៃ កំពុងប្រកាន់ ។

[៣៦២] *អធិប្បាយពាក្យថា ព្រាហ្មណ៍ពិចារណាហើយ រមែង
មិនដល់នូវការកំណត់ ត្រង់ពាក្យថា មិន គឺជាពាក្យហាមឃាត់ ។ ពាក្យថា
ព្រាហ្មណ៍ គឺបុគ្គលដែលឈ្មោះថាព្រាហ្មណ៍ ព្រោះបន្សាត់បង់នូវធម៌
ទាំង ៧ ។ បេ ។ ជាអ្នកមិនអាស្រ័យតណ្ហា ជាបុគ្គលនឹងនួន បុគ្គល
នោះ លោកហៅថា ព្រាហ្មណ៍ ។ ពាក្យថា ការកំណត់ បានដល់
ការកំណត់ ២ ការកំណត់គឺតណ្ហា ១ ការកំណត់គឺទិដ្ឋិ ១ ។ បេ ។ នេះ
ការកំណត់គឺតណ្ហា ។ បេ ។ នេះ ការកំណត់គឺទិដ្ឋិ ។ ញាណ
លោកហៅថា ការពិចារណា បានដល់បញ្ញា ការដឹងច្បាស់ ។ បេ ។
ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ។ ពាក្យថា ព្រាហ្មណ៍
ពិចារណាហើយ រមែងមិនដល់នូវការកំណត់ គឺព្រាហ្មណ៍ពិចារណា
ហើយ ដឹងហើយ ច្ងឹងហើយ ត្រិះរិះហើយ ធ្វើឲ្យច្បាស់ហើយ ធ្វើ
ឲ្យប្រាកដហើយ ថាសង្ខារទាំងពួងមិនទៀង ថាសង្ខារទាំងពួងជាទុក្ខ*

។ បេ ។ យញ្ហិ ញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ សង្ខ្យាយ ជានិត្វា តុលយិត្វា តីរយិត្វា វិការយិត្វា វិភូតំ កត្វា តណ្ហាកប្បំ វា ទិដ្ឋិកប្បំ វា[1] ន ឧបេតិ ន ឧបកប្ចតិ ន កណ្ហាតិ ន បរាមសតិ ជាកិនិវិសតីតិ ន ព្រាហ្មណោ កប្បមុបេតិ សង្ខ្យំ ។

[៣៦៣] ន ទិដ្ឋិសារី ន‌ បិ ញ្ញាណពន្ធូតិ តស្ស ទ្វាសដ្ឋី ទិដ្ឋិគតានិ បហីនានិ សមុច្ឆិន្នានិ រូបសន្ធានិ បដិប្ប‌ស្ស‌ទ្ធានិ អភព្ធុ‌ប្ប‌ត្តិ‌ការ‌ានិ ញ្ញាណ‌ក្ខ‌ិ‌ន‌ា ‌ឧ‌ឌ្ឍ‌ានិ ‌ស‌ោ ‌ទ‌ិ‌ដ្ឋ‌ិ‌យ‌ា ‌ន ‌យ‌ាយ‌ត‌ិ ‌ន ‌ន‌ិ‌យ‌ត‌ិ ‌ន ‌រ‌ុ‌យ្ហ‌ត‌ិ ‌ន ‌ស‌ំ‌ហ‌ារ‌ិ‌យ‌ត‌ិ ‌ន‌ិ‌ប‌ិ ‌ត‌ំ ‌ទ‌ិ‌ដ្ឋ‌ិ‌ក‌ត‌ំ ‌ស‌ារ‌ត‌ោ ‌ប‌ច្ចេ‌ត‌ិ ‌ប‌ច្ចា‌-ក‌ប្ច‌ត‌ីត‌ិ ‌ន ‌ទ‌ិ‌ដ្ឋ‌ិ‌ស‌ារ‌ី ។ ‌ន‌ិ‌ប‌ិ ‌ញ្ញ‌ាណ‌ព‌ន្ធ‌ូ‌ត‌ិ ‌អ‌ដ្ឋ‌ស‌មា‌-ប‌ត្ត‌ិ‌ញ្ញ‌ណេ‌ន ‌វ‌ា ‌ប‌ញ្ចា‌ភ‌ិ‌ញ្ញ‌ាញ‌ាណ‌េ‌ន ‌វ‌ា ‌ម‌ិ‌ច្ឆ‌ាញ‌ា‌-ណ‌េ‌ន ‌វ‌ា ‌ត‌ណ្ហ‌ាព‌ន្ធ‌ុ‌ំ ‌វ‌ា ‌ទ‌ិ‌ដ្ឋ‌ិ‌ព‌ន្ធ‌ុ‌ំ ‌វ‌ា ‌ន ‌ក‌ោ‌ត‌ិ ‌ន ‌ជ‌ន‌េ‌ត‌ិ ‌ន ‌ស‌ញ្ជ‌ន‌េ‌ត‌ិ ‌ន ‌ន‌ិ‌ព្ធ‌ត្ត‌េ‌ត‌ិ ‌ជ‌ាក‌ិ‌ន‌ិ‌ព្ធ‌ត្ត‌ីត‌ិ ‌ន ‌ទ‌ិ‌ដ្ឋ‌ិ‌ស‌ារ‌ី ‌ន‌ិ‌ប‌ិ ‌ញ្ញ‌ាណ‌ព‌ន្ធ‌ុ ។

---

១ ម. ឯត្ថន្តរេ នេតីតិ ទិស្សតិ ។

។ បេ ។ ពិចារណាហើយ ដឹងហើយ ច្ងឹងហើយ ត្រិះរិះហើយ ធ្វើ
ឲ្យច្បាស់ហើយ ធ្វើឲ្យប្រាកដហើយថា របស់ណាមួយ មានកិរិយា
កើតឡើងជាធម្មតា របស់ទាំងអស់នោះ មានសេចក្តីរលត់ទៅវិញជា
ធម្មតា រមែងមិនដល់ មិនចូលទៅជិត មិនប្រកាន់ មិនស្ទាបអង្អែល
មិនប្រកាន់ស្អិត នូវការកំណត់គឺតណ្ហាក្តី នូវការកំណត់គឺទិដ្ឋិក្តី ហេតុនោះ
(ទ្រង់ត្រាស់ថា) ព្រាហ្មណ៍ពិចារណាហើយ រមែងមិនដល់នូវការកំណត់ ។

[៣៦៣] ពាក្យថា មិនលុះក្នុងទិដ្ឋិ ទាំងមិនមានផៅពង្សដោយ
ញាណ សេចក្តីថាទិដ្ឋិ ៦២ បុគ្គលនោះ បានលះបង់ ផ្តាច់ផ្តិល ឲ្យសូប
ឲ្យសូបរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ
បុគ្គលនោះ ទិដ្ឋិឲ្យទៅមិនបាន នាំទៅមិនបាន បន្សាត់ទៅមិនបាន ក្លួច
យកទៅមិនបាន មិនមក មិនត្រឡប់មក កាន់ទិដ្ឋិនោះថា មានខ្ជឹម
ហេតុនោះ (ទ្រង់ត្រាស់ថា) មិនលុះក្នុងទិដ្ឋិ ។ ពាក្យថា ទាំងមិនមានផៅ-
ពង្សដោយញាណ គឺមិនធ្វើ មិនឲ្យកើត មិនឲ្យកើតព្រម មិនបង្កើត
មិនបង្កើតចំពោះ នូវផៅពង្សគឺតណ្ហាក្តី នូវផៅពង្សគឺទិដ្ឋិក្តី ដោយ
សមាបត្តិញាណ ៨ ក្តី ដោយអភិញ្ញាញាណ ៥ ក្តី ដោយមិច្ឆាញាណ
ក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) មិនលុះក្នុងទិដ្ឋិ ទាំងមិនមានផៅពង្ស
ដោយញាណ ។

[៣៦៤] ញត្វា ច សោ សម្មតិយោ បុថុជ្ជាតិ ញត្វាតិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា សព្វេ សង្ខារា អនិច្ចាតិ សព្វេ សង្ខារា ទុក្ខាតិ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធ-ធម្មន្តិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ ញត្វា ច សោ ។ សម្មតិយោតិ រុច្ចន្តិ ទ្ធាសដ្ឋី ទិដ្ឋិគតានិ[១] ។ បុថុជ្ជាតិ បុថុជ្ជនេហិ ជនិតា វា តា សម្មតិយោតិ បុថុជ្ជា ។ បុថុជានាជនេហិ ជនិតា វា[២] តា សម្មតិយោតិ បុថុជ្ជាតិ ញត្វា ច សោ សម្មតិយោ បុថុជ្ជា ។

[៣៦៥] ឧបេក្ខតី ឧក្កហាណន្តិ មញ្ញេតិ អញ្ញេ តណ្ហា-វសេន ទិដ្ឋិវសេន កណ្ហាន្តិ បរាមសន្តិ អភិនិវិសន្តិ អរហា ឧបេក្ខាតិ ន កណ្ហាតិ ន បរាមសតិ ជាភិនិវិសតីតិ

---

១ ម. ឯត្ថន្តរេ ទិដ្ឋិសមុទយោតិ ទិស្សតិ ។ ២ ម. បុថុនានាជាតិយា វា ។

[៣៦២] *អធិប្បាយពាក្យថា ព្រាហ្មណ៍នោះ ដឹងសម្មតិទាំង-ឡាយ ដែលកើតអំពីបុថុជ្ជន ត្រង់ពាក្យថា ដឹង គឺដឹង យល់ ច្ចឹង ត្រិះរិះ ធ្វើឲ្យច្បាស់ ធ្វើឲ្យប្រាកដហើយថា សង្ខារទាំងពួងមិនទៀង ថាសង្ខារទាំងពួងជាទុក្ខ ។ បេ ។ ដឹង យល់ ច្ចឹង ត្រិះរិះ ធ្វើឲ្យច្បាស់ ធ្វើឲ្យប្រាកដហើយថា របស់ណាមួយមានកិរិយាកើតឡើង ជាធម្មតា របស់ទាំងអស់នោះ មានកិរិយារលត់ទៅវិញ ជាធម្មតា ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រាហ្មណ៍នោះដឹង ។ ទិដ្ឋិ ៦២ លោកហៅថា សម្មតិ ។ ពាក្យថា ដែលកើតអំពីបុថុជ្ជន គឺសម្មតិទាំងនោះកើតអំពីបុថុជ្ជនទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ដែលកើតអំពីបុថុជ្ជន ។ ម្យ៉ាងទៀត សម្មតិទាំងនោះ កើតអំពីជនផ្សេងៗ ហេតុនោះ (ទ្រង់ត្រាស់ថា) ដែលកើតអំពីបុថុជ្ជន ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រាហ្មណ៍នោះដឹងថា សម្មតិទាំងឡាយ ដែលកើតអំពីបុថុជ្ជន ។*

[៣៦៥] *ពាក្យថា រមែងព្រងើយកន្តើយ នឹងទិដ្ឋិដែលជនទាំងឡាយដទៃ កំពុងប្រកាន់ គឺជនទាំងឡាយដទៃ ប្រកាន់ ស្ទាបអង្អែល ប្រកាន់ស្អិត ដោយអំណាចតណ្ហា ដោយអំណាចទិដ្ឋិ ព្រះអរហន្តព្រងើយកន្តើយ មិនប្រកាន់ មិនស្ទាបអង្អែល មិនប្រកាន់ស្អិត*

ឧបេក្ខតី ឧគ្គហណន្តិ មញ្ញេ ។ តេនាហ ភគវា

ន ព្រាហ្មណោ កប្បមុបេតិ សង្ខំ
ន ទិដ្ឋិសារី នបិ ញាណពន្ធុ
ញត្វា ច សោ សម្មុតិយោ បុថុជ្ជា
ឧបេក្ខតី ឧគ្គហណន្តិ មញ្ញេតិ ។

[៣៦៦] វិសជ្ជ គន្ថានិ មុនីធ លោកេ
វិវាទជាតេសុ ន វគ្គសារី
សន្តោ អសន្តេសុ ឧបេក្ខកោ សោ
អនុគ្គហោ ឧគ្គហណន្តិ មញ្ញេ ។

[៣៦៧] វិសជ្ជ គន្ថានិ មុនីធ លោកេតិ គន្ថាតិ ចត្តារោ គន្ថា អភិជ្ឈា កាយគន្ថោ ព្យាបាទោ កាយគន្ថោ សីលព្វតបរាមាសោ កាយគន្ថោ ឥទំសច្ចាភិនិវេសោ កាយគន្ថោ ។ អត្តនោ ទិដ្ឋិយា រាគោ អភិជ្ឈា កាយគន្ថោ ។

ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រងើយកន្តើយ នឹងទិដ្ឋិដែលជនទាំងឡាយដទៃ កំពុងប្រកាន់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ព្រាហ្មណ៍ពិចារណាហើយ រមែងមិនដល់នូវការកំណត់ មិនលុះក្នុងទិដ្ឋិ ទាំងមិនមានផៅពង្សដោយញាណ ព្រោះព្រាហ្មណ៍នោះដឹងសម្មតិទាំងឡាយ ដែលកើតអំពីបុថុជ្ជន លោកព្រងើយកន្តើយនឹងទិដ្ឋិ ដែលជនទាំងឡាយដទៃកំពុងប្រកាន់ ។

[៣៦៦] មុនិក្នុងលោកនេះ លះបង់នូវគន្ថៈទាំងឡាយ កាលវិវាទទាំងឡាយកើតឡើងហើយ លោកជាអ្នកមិនលុះ ក្នុងពួក កាលពួកជនមិនស្ងប់ លោកជាអ្នកស្ងប់ ជាអ្នកព្រងើយ ជាអ្នកមិនប្រកាន់ នូវលទ្ធិដែលជនទាំងឡាយដទៃកំពុងប្រកាន់ ។

[៣៦៧] អធិប្បាយពាក្យថា មុនិក្នុងលោកនេះ លះបង់នូវគន្ថៈទាំងឡាយ ត្រង់ពាក្យថា គន្ថៈ បានដល់គន្ថៈ ៤ គឺ អភិជ្ឈាកាយគន្ថៈ ព្យាបាទកាយគន្ថៈ សីលព្វតបរាមាសកាយគន្ថៈ ឥទំសច្ចាភិនិវេសកាយគន្ថៈ ។ តម្រេកក្នុងទិដ្ឋិរបស់ខ្លួន ហៅថា អភិជ្ឈាកាយគន្ថៈ ។

បរភាវេសុ អាឃាតោ អប្បច្ចយោ ព្យាបាទោ កាយ-កន្ថោ ។ អត្តនោ សីលំ វា វត្តំ វា សីលព្វតំ វា បរាមសតិ សីលព្វតបរាមាសោ កាយកន្ថោ ។ អត្តនោ ទិដ្ឋិ ឥទំ-សច្ចាភិនិវេសោ កាយកន្ថោ ។ វិសជ្ជាតិ កន្ថេ វោស្សជ្ជិត្វា វា វិសជ្ជ ។ អថវា កន្ថេ គធិតេ គន្ថិតេ ពន្ធេ វិពន្ធេ អាពន្ធេ លគ្គេ លគ្គិតេ បលិពុទ្ធេ ពន្ធនេ ផោដយិត្វា វា វិសជ្ជ ។ យថា វយ្ហំ វា រថំ វា សកដំ វា សន្ទមានិកំ វា សជ្ជំ វិសជ្ជំ ករោន្តិ វិកោបេន្តិ ឯវមេវ កន្ថេ វោស្សជ្ជិត្វា វា វិសជ្ជ អថវា កន្ថេ គធិតេ គន្ថិតេ ពន្ធេ វិពន្ធេ អាពន្ធេ លគ្គេ លគ្គិតេ បលិពុទ្ធេ ពន្ធនេ ផោដយិត្វា វា វិសជ្ជ ។ មុនីតិ មោនំ វុច្ចតិ ញាណំ យា បញ្ញា បជានា ។ បេ ។ សង្គជាលមតិច្ច សោ មុនិ ។ ឥធាតិ ឥមស្សា ទិដ្ឋិយា ។ បេ ។ ឥមស្មឹ មនុស្សលោកេតិ វិសជ្ជ កន្ថានិ មុនីធ លោកេ ។

ការគុំកួន ការអាក់អន់ ក្នុងវាទ:របស់បុគ្គលដទៃ ហៅថា ព្យា- បាទកាយគន្ថ: ។ បុគ្គលស្ទាបអង្អែលសីលឬវត្ត ឬក៏សីលវត្តរបស់ខ្លួន ហៅថា សីលព្វតបរាមាសកាយគន្ថ: ។ សេចក្តីយល់ឃើញ របស់ខ្លួន ហៅថា ឥទំសច្ចាភិនិវេសកាយគន្ថ: ។ ពាក្យថា លះបង់ គឺបោះបង់ ឬលះចោលនូវគន្ថ:ទាំងឡាយ ។ ឬថា ស្រាយ ឬត្រ-ដោះចេញ នូវគន្ថ:ទាំងឡាយ ដែលចាក់ស្រេះ ក្រង ធ្វាក់ ពាក់ ព័ន្ធ ពាក់មាំ ជាប់ ជំពាក់ ចងមាំ ចងជាប់ ។ ជនទាំងឡាយរុះ រើ ធ្វើឲ្យខ្ទេចខ្ទី នូវវក្តី រថក្តី រទេះក្តី រថទ្រង់គ្រឿងក្តី យ៉ាងណា មិញ មុនិបោះបង់ ឬលះចោលនូវគន្ថ:ទាំងឡាយ ឬថាស្រាយ ឬ ត្រដោះចេញនូវគន្ថ:ទាំងឡាយ ដែលចាក់ស្រេះ ក្រង ធ្វាក់ ពាក់ព័ន្ធ ជាប់មាំ ជាប់ ជំពាក់ ចងមាំ ចងជាប់ យ៉ាងនោះដែរ ។ ពាក្យថាមុនិ សេចក្តីថា ញាណ បញ្ញា ការដឹងច្បាស់ លោកហៅថា មោន: ។ បេ ។ មុនិនោះ កន្ធងនូវសំណាញ់ គឺកិលេសជាគ្រឿងចំពាក់ ។ ពាក្យ ថា ក្នុងលោកនេះ គឺក្នុងទិដ្ឋិនេះ ។ បេ ។ ក្នុងមនុស្សលោកនេះ ហេតុ នោះ (ទ្រង់ត្រាស់ថា) មុនិក្នុងលោកនេះ លះបង់នូវគន្ថ:ទាំងឡាយ ។

[៣៦៨] វិវេកជាតេសុ ន វក្ខសារីតិ វិវេកជាតេសុ សញ្ញាតេសុ និព្ទត្តេសុ អភិនិព្ទត្តេសុ ចាតុភូតេសុ ឆន្ទ-កតឹ កច្ឆន្តេសុ ទោសាកតឹ កច្ឆន្តេសុ មោហាកតឹ កច្ឆន្តេសុ ភយាកតឹ កច្ឆន្តេសុ ន ឆន្ទាកតឹ កច្ឆតិ ន ទោសាកតឹ កច្ឆតិ ន មោហាកតឹ កច្ឆតិ ន ភយាកតឹ កច្ឆតិ ន ភាតវសេន កច្ឆតិ ន ទោសវសេន កច្ឆតិ ន មោហវសេន កច្ឆតិ ន មានវសេន កច្ឆតិ ន ទិដ្ឋិវសេន កច្ឆតិ ន ឧទ្ធច្ចវសេន កច្ឆតិ ន វិចិកិច្ឆាវសេន កច្ឆតិ ន អនុសយវសេន កច្ឆតិ ន រាគេហិ ឆម្ភេហិ យាយតិ និយ្យតិ រុយ្ហតិ សំហរិយតីតិ វិវេកជាតេសុ ន វក្ខសារី ។

[៣៦៩] សន្ធោ អសន្ធេសុ ឧបេក្ខកោ សោតិ សន្ធោតិ ភាតស្ស សន្ធត្តា សន្ធោ ទោសស្ស សន្ធ-ត្តា សន្ធោ មោហស្ស សន្ធត្តា សន្ធោ ។ បេ ។ សព្ព-កុសលាភិសង្ខារានំ សន្ធត្តា សមិតត្តា រូបសមិតត្តា វិជ្ឌាតត្តា និព្ទុតត្តា រិតត្តា បដិប្ឌស្ឌទ្ធត្តា សន្ធោ ឧប-សន្ធោ រូបសន្ធោ និព្ទុតោ បដិប្ឌស្ឌទ្ធោតិ សន្ធោ ។

[៣៦៨] ពាក្យថា កាលវិវាទទាំងឡាយ (កើតហើយ) លោកជាអ្នកមិនលុះក្នុងពួក គឺកាលវិវាទទាំងឡាយកើតព្រមហើយ លេចឡើង លេចឡើងចំពោះ កើតប្រាកដ កាលដល់នូវឆន្ទាគតិ ដល់នូវទោ-សាគតិ ដល់នូវមោហាគតិ ដល់នូវភយាគតិ លោកក៏មិនដល់នូវ ឆន្ទាគតិ មិនដល់នូវទោសាគតិ មិនដល់នូវមោហាគតិ មិនដល់នូវ ភយាគតិ មិនលុះដោយអំណាចរាគ: មិនលុះដោយអំណាចទោស: មិនលុះដោយអំណាចមោហ: មិនលុះដោយអំណាចមានៈ មិនលុះ ដោយអំណាចទិដ្ឋិ មិនលុះដោយអំណាចឧទ្ធច្ច: មិនលុះដោយអំណាច វិចិកិច្ឆា មិនលុះដោយអំណាចអនុស័យ គឺមិនត្រូវធម៌ជាពួក ឲ្យទៅ នាំ ទៅ បន្សាត់ទៅ ក្ងេចយកទៅ ហេតុនោះ (ទ្រង់ត្រាស់ថា) កាលវិវាទ ទាំងឡាយ (កើតហើយ) លោកជាអ្នកមិនលុះក្នុងពួក ។

[៣៦៩] អធិប្បាយពាក្យថា កាលបើពួកជនមិនសូប់ លោកជាអ្នក សូប់ ជាអ្នកព្រងើយកន្តើយ ត្រង់ពាក្យថា ជាអ្នកសូប់ គឺជាអ្នកសូប់ ព្រោះសូប់រាគ: ជាអ្នកសូប់ ព្រោះសូប់ទោស: ជាអ្នកសូប់ ព្រោះសូប់ មោហ: ។ បេ ។ ជាអ្នកសូប់ រម្ងាប់ សូប់ស្ងៀម រលត់ សូប់រម្ងាប់ ព្រោះសូប់ រម្ងាប់ សូប់ស្ងៀម រលាយ រលត់ ទៅប្រាស សូប់រម្ងាប់ នូវអកុសលាកិសង្ខារទាំងពួង ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកសូប់ ។

អសន្តេសូតិ អសន្តេសុ អនុបសន្តេសុ អវូបសន្តេសុ អនិព្ពុតេសុ អប្បដិប្ប‌ស្ស‌ទ្ធេ‌សូ‌តិ ‌ស‌ន្តោ ‌អ‌ស‌ន្តេ‌សុ ។ ‌ឧ‌ប‌ក្ខ‌ោ‌ កោ ‌ស‌ោ‌តិ ‌អ‌ាហ ‌ឆ‌ឬ‌ជ្ជ‌ុ‌ប‌ក្ខ‌ាយ ‌ស‌ម‌ន្ន‌ា-‌ ‌ក‌ត‌ោ ‌ច‌ក្ខ‌ុ‌ជ‌ា ‌រ‌ូ‌ប‌ំ ‌ជ‌ិ‌ស្វ‌ា ‌ន‌េ‌វ ‌ស‌ុ‌ម‌ោ‌ ‌ហ‌ោ‌តិ ‌ន ‌ទ‌ុ‌ម្ម‌ោ‌ ‌ឧ‌ប‌ក្ខ‌ោ‌ កោ ‌វ‌ិ‌ហ‌រ‌តិ ‌ស‌ត‌ោ ‌ស‌ម្ប‌ជ‌ា‌ណ‌ោ ។ ‌ស‌ោ‌ត‌េ‌ន ‌ស‌ទ្ធ‌ំ ‌ស‌ុ‌ត្វ‌ា ។ ‌ប‌េ ។ ‌ក‌ាល‌ំ ‌ក‌ង្ខ‌ូ‌តិ ‌ភ‌ាវ‌ិ‌ត‌ោ ‌ស‌ុ‌ឧ‌ណ្ហ‌ោ‌តិ ‌ស‌ន្ត‌ោ ‌អ‌ស‌ន្តេ‌សុ ‌ឧ‌ប‌ក្ខ‌ោ‌ កោ ‌ស‌ោ ។

[៣៧០] ‌អ‌ន‌ុ‌ក្ក‌ហ‌ោ ‌ឧ‌ក្ក‌ហ‌ណ‌ន្តិ ‌ម‌ញ្ញ‌តិ ‌អ‌ញ្ញ‌ ‌ត‌ណ្ហ‌ា‌វ‌ស‌េ‌ន ‌ទ‌ិ‌ដ្ឋ‌ិ‌វ‌ស‌េ‌ន ‌ក‌ណ្ហ‌ន្តិ ‌ប‌ាម‌ស‌ន្តិ ‌អ‌ភ‌ិ‌ន‌ិ‌វ‌ិ‌ស‌ន្តិ ‌អ‌ាហ ‌ឧ‌ប‌ក្ខ‌ូ‌តិ ‌ន ‌ក‌ណ្ហ‌ា‌តិ ‌ន ‌ប‌ាម‌ស‌តិ ‌ន‌ាភ‌ិ‌ន‌ិ‌វ‌ិ‌ស‌ត‌ីតិ ‌អ‌ន‌ុ‌ក្ក‌ហ‌ោ ‌ឧ‌ក្ក‌ហ‌ណ‌ន្តិ ‌ម‌ញ្ញ ។ ‌ត‌េ‌ន‌ាហ ‌ភ‌គ‌វ‌ា

ពាក្យថា កាលពួកជនមិនស្ងប់ គឺកាលពួកជនមិនស្ងប់ មិនរម្ងាប់ មិនស្ងប់ស្ងៀម មិនរលត់ មិនស្ងប់រម្ងាប់ ហេតុនោះ (ទ្រង់ត្រាស់ថា) កាលពួកជនមិនស្ងប់ លោកជាអ្នកស្ងប់ ។ ពាក្យថា លោកជាអ្នកព្រងើយកន្តើយ សេចក្តីថា ព្រះអរហន្តប្រកបដោយឆន្ទៈ ក្តីបេក្ខា ឃើញរូបដោយភ្នែក ជាអ្នកមានចិត្តមិនរីករាយ មានចិត្តមិនអាក់អន់ នៅព្រងើយ មានសតិសម្បជញ្ញៈ ។ ឮសំឡេងដោយត្រចៀក ។ បេ ។ ជាអ្នកអប់រំទូន្មានខ្ជួនល្អ រង់ចាំតែមរណកាល ហេតុនោះ (ទ្រង់ត្រាស់ថា) កាលពួកជនមិនស្ងប់ លោកជាអ្នកស្ងប់ ជាអ្នកព្រងើយកន្តើយ ។

[៣៧០] ពាក្យថា ជាអ្នកមិនប្រកាន់ នូវលទ្ធិដែលជនទាំង-ឡាយដទៃ កំពុងប្រកាន់ គឺជនដទៃ រមែងប្រកាន់ ស្ទាបអង្អែលប្រកាន់ស្អិត ដោយអំណាចតណ្ហា ដោយអំណាចទិដ្ឋិ ព្រះអរហន្ត តែងព្រងើយ មិនប្រកាន់ មិនស្ទាបអង្អែល មិនប្រកាន់ស្អិត ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកមិនប្រកាន់ នូវលទ្ធិដែលជនទាំងឡាយដទៃ កំពុងប្រកាន់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

វិសជ្ជ គន្ថានិ មុនីធ លោកេ
វិវាទជាតេសុ ន វគ្គសារី
សន្តោ អសន្តេសុ ឧបេក្ខកោ សោ
អនុគ្គហោ ឧគ្គហណន្តិ មញ្ញតិ ។

[៣៧១] បុព្វាសវេ ហិត្វា នវេ អកុព្វំ[១]
ន ឆន្ទគូ នោបិ និវិស្សវាទី
ស វិប្បមុត្តោ ទិដ្ឋិគតេហិ ធីរោ
ន លិម្បតី លោកេ អនត្តគរហី ។

[៣៧២] បុព្វាសវេ ហិត្វា នវេ អកុព្វន្តិ បុព្វាសវា[២] វុច្ចន្តិ អតីតា រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណំ ។ អតីតេ សង្ខារេ អារព្ភ យេ កិលេសា ឧប្បជ្ជេយ្យុំ តេ កិលេសេ ហិត្វា ចជិត្វា បរិច្ចជិត្វា បជហិត្វា វិនោទិត្វា ព្យន្តីករិត្វា អនភាវង្គមិត្វាតិ បុព្វាសវេ ហិត្វា ។

១ ម. អក្រុព្វំ ។ ២ ម. អក្រុព្វិន្តិ ។

មុនិ ក្នុងលោកនេះ លះបង់នូវគន្ថៈទាំងឡាយ កាលវិវាទ ទាំងឡាយ (កើតហើយ) លោកជាអ្នកមិនលុះក្នុងពួក កាលពួកជនមិនសូប់ លោកជាអ្នកសូប់ ជាអ្នកព្រងើយកន្តើយ ជាអ្នកមិនប្រកាន់ នូវលទ្ធិដែលជនទាំងឡាយដទៃ កំពុងប្រកាន់ ។

[៣៧១] *អ្នកប្រាជ្ញនោះ លះបង់អាសវៈខាងដើម មិនធ្វើអាសវៈថ្មី មិនដល់នូវឆន្ទាគតិ ជាអ្នកមិនមានវាទៈតាំងមាំ រួចស្រឡះ ចាកទិដ្ឋិទាំងឡាយ ជាអ្នកមិនតិះដៀលខ្លួនឯង មិនប្រឡាក់ក្នុងលោក ។*

[៣៧២] *ពាក្យថា លះបង់អាសវៈខាងដើម មិនធ្វើអាសវៈថ្មី សេចក្ដីថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាអតីត លោកហៅថា អាសវៈខាងដើម កិលេសណា ប្រារព្ធសង្ខារទាំងឡាយ ជាអតីត ហើយកើតឡើង (អ្នកប្រាជ្ញ) លះបង់ លះចោល លះស្រឡះ លះផ្ដាច់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវកិលេសទាំងនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) លះបង់អាសវៈខាងដើម ។*

នវេ អកុព្វន្តិ ន វា វុច្ចន្តិ បច្ចុប្បន្នា រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណំ ។ បច្ចុប្បន្នេ សង្ខារេ អារព្ភ ឆន្ទំ អកុព្វមានោ បេមំ អកុព្វមានោ រាគំ អកុព្វមានោ អជនយមានោ អសញ្ជនយមានោ អនិព្វត្តយមានោ នាភិនិព្វត្តយមានោតិ បុព្វាសវេ ហិត្វា នវេ អកុព្វំ ។

[៣៧៣] ន ឆន្ទគូ នោបិ និវិស្សវាទីតិ ន ឆន្ទគូតិ[១] ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ ន រាគវសេន គច្ឆតិ ន ទោសវសេន គច្ឆតិ ន មោហវសេន គច្ឆតិ ន មានវសេន គច្ឆតិ ន ទិដ្ឋិវសេន គច្ឆតិ ន ឧទ្ធច្ចវសេន គច្ឆតិ ន វិចិកិច្ឆាវសេន គច្ឆតិ ន អនុសយវសេន គច្ឆតិ ន វគ្គេហិ ធម្មេហិ យាយតិ និយ្យតិ វុយ្ហតិ សំហារិយតីតិ[២] ន ឆន្ទគូ ។ នោបិ និវិស្សវាទីតិ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ន និវិស្សវាទី អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា

១ ម. ឆន្ទគូតីតិ នត្ថិ ។ ២ ម. នសំហារិយ្យតីតិ ។

ពាក្យថា មិនធ្វើអាសវៈថ្មី សេចក្ដីថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាបច្ចុប្បន្ន លោកហៅថា អាសវៈថ្មី ។ លោកមិនធ្វើ ធនូ: មិនធ្វើសេចក្ដីស្រឡាញ់ មិនធ្វើតម្រេក មិនឲ្យកើត មិនឲ្យកើតព្រម មិនឲ្យលេចឡើង មិនឲ្យលេចឡើងចំពោះ ព្រោះប្រារព្ធសង្ខារជាបច្ចុប្បន្ន ហេតុនោះ (ទ្រង់ត្រាស់ថា) លះបង់អាសវៈខាងដើម មិនធ្វើអាសវៈថ្មី ។

[៣៧៣] *អធិប្បាយពាក្យថា មិនដល់នូវឆន្ទាគតិ មិនមានវាទ: តាំងមាំ ត្រង់ពាក្យថា មិនដល់នូវឆន្ទាគតិ គឺមិនដល់នូវឆន្ទាគតិ មិនដល់នូវទោសាគតិ មិនដល់នូវមោហាគតិ មិនដល់នូវភយាគតិ មិនលុះដោយអំណាចរាគ: មិនលុះដោយអំណាចទោស: មិនលុះដោយអំណាចមោហ: មិនលុះដោយអំណាចមាន: មិនលុះដោយអំណាចទិដ្ឋិ មិនលុះដោយអំណាចឧទ្ធច្ច: មិនលុះដោយអំណាចវិចិកិច្ឆា មិនលុះដោយអំណាចអនុស័យ មិនត្រូវធម៌ជាពួកឲ្យទៅ នាំទៅ បន្សាត់ទៅ ក្ងួចយកទៅទេ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនដល់នូវឆន្ទាគតិ ។ ពាក្យថា ជាអ្នកមិនមានវាទ:តាំងមាំ គឺជាអ្នកមិនមានវាទ:តាំងមាំថា លោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃ: ថាលោកមិនទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃ: ។ បេ ។ ជាអ្នកមិនមានវាទ:តាំងមាំថា សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀត ក៏មិនមែន*

ឥធមេវ សចំ្ចំ មោឃមញ្ញន្តិ ន និវិស្សវាទីតិ ន ធម្មកូ ធោបិ និវិស្សវាទី ។

[៣៧៤] ស វិឃ្ឃមុត្តោ ទិដ្ឋិកតេហិ ជីវោតិ តស្ស ទ្វាសដ្ឋី ទិដ្ឋិកតានិ បហីនានិ សមុច្ឆិន្នានិ រូបសន្ធានិ បដិឃ្ឃស្សន្ធានិ អភព្ពុប្ផត្តិកានិ ញាណាគ្គិនា ឌឌ្ឍានិ សោ ទិដ្ឋិកតេហិ វិឃ្ឃមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ ។ ជីវោតិ ជីវោ បណ្ហិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវីតិ ស វិឃ្ឃមុត្តោ ទិដ្ឋិកតេហិ ជីវោ ។

[៣៧៥] ន លិម្ពតី លោកេ អនត្តការហីតិ លេ-ចាតិ ទ្វេ លេចា តណ្ហាលេចោ ច ទិដ្ឋិលេចោ ច ។ បេ ។ អយំ តណ្ហាលេចោ ។ បេ ។ អយំ ទិដ្ឋិលេចោ ។ តស្ស តណ្ហាលេចោ បហីនោ ទិដ្ឋិលេចោ បដិនិស្ស-ដ្ឋោ តណ្ហាលេបស្ស[1] បហីនត្តា ទិដ្ឋិលេបស្ស បដិនិ-ស្សដ្ឋត្តា អនុបលិត្តោ អចាយលោកេ ន លិម្ពតិ មនុស្សលោកេ ន លិម្ពតិ ទេវលោកេ ន លិម្ពតិ ខន្ធលោកេ ន លិម្ពតិ ធាតុលោកេ ន លិម្ពតិ

១ ម. តស្ស តណ្ហាលេបស្ស ។

ពាក្យនេះ ជាពាក្យពិត ពាក្យដទៃជាមោឃៈ ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកមិនដល់នូវឆន្ទាគតិ មិនមានវាទៈតាំងមាំ ។

[៣៧៤] អ្នកប្រាជ្ញនោះ រួចស្រឡះចាកទិដ្ឋិទាំងឡាយ គឺទិដ្ឋិ ៦២ អ្នកប្រាជ្ញនោះ លះបង់ ផ្តាច់ផ្តិល ឲ្យសូប ឲ្យសូបរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ អ្នកប្រាជ្ញនោះ រួចស្រឡះ ប្រាសចាកទិដ្ឋិទាំងឡាយ មានចិត្តប្រាសចាកដែន គឺកិលេស ។ ពាក្យថា អ្នកប្រាជ្ញ គឺអ្នកប្រាជ្ញ បណ្ឌិត អ្នកមានប្រាជ្ញា មានកិរិយាដឹង មានញាណ មានប្រាជ្ញាធ្ងុះ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកប្រាជ្ញនោះ រួចស្រឡះចាកទិដ្ឋិទាំងឡាយ ។

[៣៧៥] អធិប្បាយពាក្យថា ជាអ្នកមិនតិះដៀលខ្លួនឯង មិនប្រឡាក់ក្នុងលោក ត្រង់ពាក្យថា ប្រឡាក់ បានដល់ការប្រឡាក់ ២ គឺការប្រឡាក់គឺតណ្ហា ១ ការប្រឡាក់គឺទិដ្ឋិ ១ ។ បេ ។ នេះការប្រឡាក់គឺតណ្ហា ។ បេ ។ នេះការប្រឡាក់គឺទិដ្ឋិ ។ បុគ្គលនោះ លះបង់ការប្រឡាក់គឺតណ្ហា រលាស់ចោលការប្រឡាក់គឺទិដ្ឋិ បុគ្គលនោះ ជាអ្នកមិនប្រឡាក់ ព្រោះលះបង់ការប្រឡាក់គឺតណ្ហា រលាស់ចោលការប្រឡាក់គឺទិដ្ឋិ រមែងមិនប្រឡាក់ក្នុងអបាយលោក មិនប្រឡាក់ក្នុងមនុស្សលោក មិនប្រឡាក់ក្នុងទេវលោក មិនប្រឡាក់ក្នុងខន្ធលោក

អាយតនលោកេ ន លិម្ពតិ ន សំលិម្ពតិ ឧបលិម្ពតិ អលិត្តោ អសំលិត្តោ អនុបលិត្តោ និក្ខន្តោ និស្សដ្ឋោ វិប្ប មុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ ន លិម្ពតិ លោកេ ។ អនត្តករហីតិ ទ្វីហិ ការណេហិ អត្តានំ ករហតិ កតត្តា ច អកតត្តា ច ។ កថំ កតត្តា ច អកតត្តា ច អត្តានំ ករហតិ ។ កតំ មេ កាយឧជ្ជុវិតំ អកតំ មេ កាយសុចរិតន្តិ អត្តានំ ករ-ហតិ កតំ មេ វចីឧជ្ជុវិតំ កតំ មេ មនោឧជ្ជុវិតំ កតោ មេ ចាណាតិចាតោ ។ បេ ។ កតា មេ មិច្ឆាទិដ្ឋិ អកតា មេ សម្មាទិដ្ឋីតិ អត្តានំ ករហតិ ។ ឯវំ កតត្តា ច អកតត្តា ច អត្តានំ ករហតិ ។ អថវា សីលេសុម្ហិ ន បរិបូរិការីតិ អត្តានំ ករហតិ ឥន្ទ្រិយេ-សុម្ហិ អគុត្តទ្វារោតិ ភោជនេ អមត្តញ្ញុម្ហីតិ ជាគរិយ-មនុយុត្តោតិ ន សតិសម្ប ជញ្ញេន សមន្ទ្ធាគតោតិ អការិតា មេ ចត្តារោ សតិប្ប ដ្ឋានាតិ អការិតា មេ ចត្តារោ សម្ម ប្ប ជានាតិ អការិតា មេ ចត្តារោ ឥទ្ធិចា-ជាតិ អការិតានិ មេ បញ្ចិន្ទ្រិយានីតិ អការិតានិ មេ

មិនប្រឡាក់ក្នុងធាតុលោក មិនប្រឡាក់ មិនប្រឡាក់ព្រម មិនចូលទៅប្រឡាក់ ក្នុងអាយតនលោក ជាអ្នកមិនប្រឡាក់ មិនប្រឡាក់ព្រម មិនចូលទៅជិតប្រឡាក់ ឃ្លាតចេញ រលាស់ចេញ រួចស្រឡះ មិនប្រកបសម្រេចនៅដោយចិត្តដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) មិនប្រឡាក់ក្នុងលោក ។ ពាក្យថា ជាអ្នកមិនតិះដៀលខ្លួនឯង សេចក្តីថា បុគ្គលរមែងតិះដៀលខ្លួនឯងដោយហេតុ ២ គឺ អំពើដែលខ្លួនធ្វើហើយ ១ មិនធ្វើហើយ ១ ។ តិះដៀលខ្លួនឯង ព្រោះអំពើដែលខ្លួនធ្វើហើយ និងមិនធ្វើហើយ តើដូចម្តេច ។ តិះដៀលខ្លួនឯងថា កាយទុច្ចរិតអញធ្វើហើយ កាយសុចរិតអញមិនបានធ្វើ តិះដៀលខ្លួនឯងថា វចីទុច្ចរិតអញធ្វើហើយ មនោទុច្ចរិតអញធ្វើហើយ បាណាតិបាតអញធ្វើហើយ ។ បេ ។ មិច្ឆាទិដ្ឋិ អញធ្វើហើយ សម្មាទិដ្ឋិអញមិនបានធ្វើ ។ តិះដៀលខ្លួនឯង ព្រោះអំពើដែលខ្លួនធ្វើហើយ និងមិនធ្វើហើយយ៉ាងនេះឯង ។ ម្យ៉ាងទៀត តិះដៀលខ្លួនឯងថា អញមិនបានបំពេញក្នុងសីលទាំងឡាយ តិះដៀលខ្លួនឯងថា អញមិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ថាអញមិនដឹងប្រមាណក្នុងភោជន ថាអញមិនប្រកបរឿយៗ នូវការភ្ញាក់រឭក ថាអញមិនប្រកបដោយសតិនិងសម្បជញ្ញៈ ថាសតិប្បដ្ឋានទាំង ៤ អញមិនបានចម្រើន ថាសម្មប្បធាន ៤ អញមិបាន ចម្រើនថាឥទ្ធិបាទ៤ អញមិនបានចម្រើនថា ឥន្ទ្រិយ៥ អញមិនបានចម្រើន

បញ្ហ ពលានីតិ អភាវិតា មេ សត្ត ពោជ្ឈង្គាតិ អភាវិតោ មេ អរិយោ អដ្ឋង្គិកោ មគ្គោតិ ទុក្ខំ មេ អបរិញ្ញាតន្តិ ទុក្ខសមុទយោ មេ អប្បហីនោតិ មគ្គោ មេ អភាវិតោតិ និរោធោ មេ អសច្ឆិកតោតិ អត្តានំ គរហតិ ។ ឯវំ កតត្តា ច អកតត្តា ច អត្តានំ គរហតិ ។ ឯវំ អត្តគរហិយំ កម្មំ[១] អកុព្វមានោ អជនយមានោ អសញ្ជនយមានោ អនិព្វត្តយមានោ នាភិនិព្វត្តយមានោ អនត្តគរហីតិ ន លិម្បតី លោកេ អនត្តគរហី ។ តេនាហ ភគវា

បុញ្ញាសវេ ហិត្វា នវេ អកុព្វំ
ន ឆន្ទគូ នោបិ និវិស្សវាទី
ស វិប្បមុត្តោ ទិដ្ឋិគតេហិ ធីរោ
ន លិម្បតី លោកេ អនត្តគរហីតិ ។

[៣៧៦] ស សព្វធម្មេសុ វិសេនិភូតោ
យង្កិញ្ចិ ទិដ្ឋំវ[២] សុតំ មុតំ វា
ស បន្នភារោ មុនិ វិប្បមុត្តោ
ន កប្បិយោ នូបរតោ ន បត្ថិយោ(តិ ភគវា ។

១ ម. ឯវំ អត្តគរហី តយិនំ កម្មំ ។ ២ ម. ទិដ្ឋញ្ច ។

ឋាពល: ៥ អញមិនបានចម្រើន ឋាពោជ្ឈង្គ ៧ អញមិនបានចម្រើន ឋាអដ្ឋង្គិកមគ្គដ៏ប្រសើរ អញមិនបានចម្រើន ឋាទុក្ខអញមិនបានកំណត់ដឹង ឋាទុក្ខសមុទ័យ អញមិនបានលះបង់ ឋាមគ្គ អញមិនបានចម្រើន ឋានិរោធ អញមិនបានធ្វើឲ្យជាក់ច្បាស់ ។ តិះដៀលខ្លួនឯង ព្រោះអំពើដែលខ្លួនធ្វើនិងមិនធ្វើហើយ យ៉ាងនេះឯង ។ មិនធ្វើ មិនឲ្យកើតព្រម មិនឲ្យលេចឡើង មិនឲ្យលេចឡើងចំពោះ នូវអំពើដែលគួរតិះដៀលខ្លួនយ៉ាងនេះ ឈ្មោះថាជាអ្នកមិនតិះដៀលខ្លួនឯង ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកមិនតិះដៀលខ្លួន រមែងមិនប្រឡាក់ក្នុងលោក ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

> អ្នកប្រាជ្ញនោះ លះបង់អាសវ:ខាងដើម មិនធ្វើអាសវ:ថ្មី មិនដល់នូវឆន្ទាគតិ ជាអ្នកមិនមានវាទ:តាំងមាំ រួចស្រឡះ ចាកទិដ្ឋិទាំងឡាយ ជាអ្នកមិនតិះដៀលខ្លួនឯង មិនប្រឡាក់ក្នុងលោក ។

[៣៧៦] (ព្រះមានព្រះភាគទ្រង់ត្រាស់ថា) បុគ្គលនោះធ្វើសេនាណាមួយ ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ហើយ ឲ្យវិនាសក្នុងធម៌ទាំងពួង បុគ្គលនោះមានការ:ដាក់ចុះហើយ ជាមុនិ រួចស្រឡះហើយ ជាអ្នកមិនមានការកំណត់ មិនត្រេកអរ មិនមានសេចក្ដីប្រាថ្នា ។

[៣៧៧] ស សព្វធម្មេសុ វិសេនិភូតោ យង្កិញ្ចិ ទិដ្ឋំវ សុតំ មុតំ វាតិ សេនា វុច្ចតិ មារសេនា ។ កាយទុច្ចរិតំ មារសេនា វចីទុច្ចរិតំ មារសេនា មនោទុច្ចរិតំ មារសេនា រាគោ ទោសោ មោហោ កោធោ ឧបនាហោ មក្ខោ បឡាសោ ឥស្សា មច្ឆរិយំ មាយា សាឋេយ្យំ ថម្ភោ សារម្ភោ មានោ អតិមានោ មទោ បមាទោ សព្វេ កិលេសា សព្វេ ទុច្ចរិតា សព្វេ ទរថា សព្វេ បរិឡាហា សព្វេ សន្តាបា សព្វាកុសលាភិសង្ខារា មារសេនា ។ វុត្តំ ហេតំ ភគវតា

កាមា តេ បឋមា សេនា ទុតិយារតិ វុច្ចតិ
តតិយា ខុប្បិបាសា តេ ចតុត្ថី តណ្ហា បវុច្ចតិ
បញ្ចមំ ថីនមិទ្ធន្តេ ឆដ្ឋា ភីរូ[១] បវុច្ចតិ
សត្តមី វិចិកិច្ឆា តេ មក្ខោ ថម្ភោ តេ អដ្ឋមោ
លាភោ សិលោកោ សក្ការោ មិច្ឆាលទ្ធោ ច យោ យសោ
យោ ចត្តានំ សមុក្កំសេ បរេ ច អវជានតិ

១ ឱ. ម. ភីរូ ។

[៣៧៧] ពាក្យថា បុគ្គលនោះធ្វើសេនាណាមួយ ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ហើយ ឲ្យវិនាសក្នុងធម៌ទាំងពួង អធិប្បាយថា មារ-សេនា លោកហៅថា សេនា ។ កាយទុច្ចរិត ជាមារសេនា វចីទុច្ចរិត ជាមារសេនា មនោទុច្ចរិត ជាមារសេនា រាគ: ទោស: មោห: កោធ: ឧបនាห: មក្ខ: បឡាស: ឥស្សា មច្ឆរិយ: មាយា សាឋেয্য: ថម្ភ: សារម្ភ: មាន: អតិមាន: មទ: បមាទ: កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង ការអន្ទះអន្ទែងទាំងពួង អកុសលាកិសង្ខារទាំងពួង ជាមារសេនា ។ សមដូចព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

> *កាមទាំងឡាយ ជាសេនាទី ១ របស់អ្នក សេចក្តីមិនត្រេកអរ គេហៅថា សេនាទី ២ សេចក្តីស្រេកឃ្ងាន ជាសេនាទី ៣ របស់អ្នក តណ្ហា គេហៅថា សេនា ទី ៤ ថីនមិទ្ធ: ជាសេនា ទី ៥ របស់អ្នក សេចក្តីខ្ជាច គេហៅថា សេនាទី ៦ វិចិកិច្ឆា ជាសេនាទី ៧ របស់អ្នក ការលុបគុណគេ ការរឹងរូស ជាសេនាទី៨ របស់អ្នក លាភ: សេចក្តីសរសើរ សក្ការ: យស ដែលបុគ្គលបានខុសហើយក្តី បុគ្គលលើកខ្លួនក្តី បុគ្គលបង្អាប់អ្នកដទៃក្តី*

ឯសា នមុចិ តេ សេនា កណ្ហស្សាភិប្បហារិណី
ន នំ អសូរោ ជិនាតិ ជេត្វា ច លភតេ សុខន្តិ ។

យតោ ចតូហិ អរិយមគ្គេហិ សព្វា ច មារសេនា សព្វេ ច បដិសេនិករា កិលេសា ជិតា ច បរាជិតា ច ភគ្គា វិប្បលុគ្គា បរម្មុខា សោ វុច្ចតិ វិសេនិកត្វា ។ សោ ទិដ្ឋេ វិសេនិកត្វា សុតេ មុតេ វិញ្ញាតេ វិសេនិកត្វាតិ ស សព្វធម្មេសុ វិសេនិកត្វា យង្កិញ្ចិ ទិដ្ឋំវ សុតំ មុតំ វា ។

[៣៧៨] ស បន្នភារោ[១] មុនិ វិប្បមុត្តោតិ ភារោតិ តយោ ភារា ខន្ធភារោ កិលេសភារោ អភិសង្ខារភារោ ។ កតមោ ខន្ធភារោ ។ បដិសន្ធិយា រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណំ អយំ ខន្ធភារោ ។ កតមោ កិលេសភារោ ។ រាគោ ទោសោ មោហោ ។ បេ ។

១ ម. សម្បន្នភារោ ។

ម្នាលមារ នុ៎ះជាសេនារបស់អ្នក ដែលនាំមកនូវធម៌ខ្មៅ
បុគ្គលមិនក្ងៀវក្ងា មិនឈ្នះ នូវសេនានោះទេ បុគ្គលលុះ
ឈ្នះនូវសេនានោះ ទើបបានសុខ ។

មារសេនាទាំងអស់ផង កិលេសជាទីទំនាស់ទាំងអស់ផង ដែលបុគ្គលផ្ចាញ់ហើយ ទាំងធ្វើឲ្យចាញ់ហើយ បំបាត់បង់ រំលត់រំលាយ ក្នុងទីកំចាំងមុខ ដោយអរិយមគ្គ ៤ ក្នុងកាលណា ក្នុងកាលនោះ បុគ្គលនោះ លោកហៅថា អ្នកធ្វើសេនាឲ្យវិនាស ។ បុគ្គលនោះជាអ្នកធ្វើសេនាឲ្យវិនាស ក្នុងធម៌ដែលខ្លួនឃើញ ជាអ្នកធ្វើសេនាឲ្យវិនាសក្នុងធម៌ដែលខ្លួនឮ ដែលប៉ះពាល់ ដែលដឹងច្បាស់ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ ជាអ្នកធ្វើសេនាណាមួយទាំងពួង ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ហើយ ឲ្យវិនាសក្នុងធម៌ទាំងពួង ។

[៣៧៨] អធិប្បាយពាក្យថា បុគ្គលនោះ មានការៈដាក់ចុះ ហើយ ជាមុនិ រួចស្រឡះហើយ ត្រង់ពាក្យថា ការៈ បានដល់ការៈ ៣ គឺខន្ធការៈ ១ កិលេសការៈ ១ អភិសង្ខារការៈ ១ ។ ខន្ធការៈ តើដូចម្តេច ។ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ អំពីបដិសន្ធិ នេះ ខន្ធ-ការៈ ។ កិលេសការៈ តើដូចម្តេច ។ រាគៈ ទោសៈ មោហៈ ។ បេ ។

សញ្ញាកុសលាកិសង្ខារា អយំ កិលេសភាវោ ។ កតមោ
អកិសង្ខារភាវោ ។ បុញ្ញាភិសង្ខារោ អបុញ្ញាភិសង្ខារោ
អានេញ្ជាភិសង្ខារោ អយំ អកិសង្ខារភាវោ ។ យតោ
ខន្ធភាវោ ច កិលេសភាវោ ច អកិសង្ខារភាវោ ច
បហីនា ហោន្តិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្គតា
អាយតឺ អនុប្បាទធម្មា សោ រុច្ចតិ បន្ធភាវោ បតិតភាវោ
ឱរោបិតភាវោ សមោរោបិតភាវោ ឆិក្ខិត្តភាវោ បដិ-
ប្ឆស្សទ្ធភាវោ ។ មុនីតិ មោនំ រុច្ចតិ ញាណំ យា បញ្ញា
បជានតា វិចយោ បវិចយោ ធម្មវិចយោ សល្ខក្ខណា
ឧបលក្ខណា បច្ចុបលក្ខណា បណ្ឌិច្ចំ កោសល្លំ នេ-
បុញ្ញំ វេភព្យា ចិន្តា ឧបបរិក្ខា ភូរី មេធា បរិណាយិកា
វិបស្សនា សម្ផជញ្ញំ បតោទោ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញា-
ពលំ បញ្ញាសត្ថំ បញ្ញាចាសាទោ បញ្ញាអាលោកោ
បញ្ញាឱភាសោ បញ្ញាបជ្ជោតោ បញ្ញារតនំ អមោហោ
ធម្មវិចយោ សម្មាទិដ្ឋិ តេន ញាណេន សមន្ធាគតោ

អកុសលាកិសង្ខារទាំងអស់ នេះ កិលេសការ: ។ អកិសង្ខារការ: តើដូចម្តេច ។ បុញ្ញាកិសង្ខារ អបុញ្ញាកិសង្ខារ អានេញ្ជាកិសង្ខារ នេះ អកិសង្ខារការ: ។ ខន្ធការ: កិលេសការ: និងអកិសង្ខារ-ការ: បុគ្គលលះបង់ហើយ ផ្តាច់បង់ឫសគល់ហើយ ធ្វើមិនឲ្យមានទីនៅ ដូចជាទីនៅនៃដើមត្នោត ដល់នូវការមិនមាន មានការមិនកើតទៅទៀត ជាធម្មតា ក្នុងកាលណា (ក្នុងកាលនោះ) បុគ្គលនោះ លោកហៅថា អ្នកមានការ:ដាក់ចុះហើយ ជាអ្នកមានការ:ធ្លាក់ចុះ ទម្លាក់ការ:ចោល ជម្រុះការ:ចេញ ដាក់ការ:ចេញ មានការ:សូប់រម្ងាប់ហើយ ។ ពាក្យថា ជាមុនិ សេចក្តីថា ញាណ លោកហៅថា មោន: បានដល់បញ្ញា ការដឹងច្បាស់ ការសន្សំ ការជ្រើសរើស ការពិចារណាធម៌ ការកំណត់ព្រម ការចូលទៅកំណត់ ការកំណត់ចំពោះ ភាពជាអ្នកប្រាជ្ញ ភាពជាអ្នកឈ្លាស ភាពជាអ្នកមានប្រាជ្ញាស្អិត ភាពជាអ្នកចេះចែករំលែក ការគិត ការពិ-ចារណា ប្រាជ្ញាដូចផែនដី ប្រាជ្ញាអាចកម្ចាត់បង់កិលេស ប្រាជ្ញាជាគ្រឿងត្រួតត្រា ការឃើញច្បាស់ ការដឹងព្រម បញ្ញាដូចជាជន្ធញ បញ្ញាជាធំ បញ្ញាជាកម្លាំង បញ្ញាជាសស្ត្រាវុធ បញ្ញាដូចប្រាសាទ បញ្ញាជាពន្ធឿ បញ្ញាជារស្មី បញ្ញាជាគ្រឿងបំភ្លឺ បញ្ញាជាកែវ ការមិនវង្វេង ការសន្សំធម៌ ការយល់ត្រូវ បុគ្គលអ្នកប្រកបដោយញាណនោះ

មុនិ មោនប្បត្តោតិ ។ តីណិ មោនេយ្យានិ កាយមោ-
នេយ្យំ វចីមោនេយ្យំ មនោមោនេយ្យំ ។

កតមំ កាយមោនេយ្យំ ។ តិវិធានំ កាយទុច្ចរិតានំ
បហានំ កាយមោនេយ្យំ ។ តិវិធំ កាយសុចរិតំ
កាយមោនេយ្យំ ។ កាយារម្មណំ ញាណំ[(១)] កាយ-
មោនេយ្យំ ។ កាយបរិញ្ញា កាយមោនេយ្យំ ។ បរិញ្ញា-
សហគតោ មគ្គោ កាយមោនេយ្យំ ។ កាយេ ឆន្ទ-
រាគស្ស បហានំ កាយមោនេយ្យំ កាយសង្ខារនិរោធោ
ចតុត្ថជ្ឈានសមាបត្តិ កាយមោនេយ្យំ ។ ឥទំ កាយ-
មោនេយ្យំ ។

កតមំ វចីមោនេយ្យំ ។ ចតុព្ពិធានំ វចីទុច្ចរិតានំ
បហានំ វចីមោនេយ្យំ ។ ចតុព្ពិធំ វចីសុចរិតំ វចីមោ-
នេយ្យំ ។ វាចារម្មណំ ញាណំ វចីមោនេយ្យំ ។
វាចាបរិញ្ញា វចីមោនេយ្យំ ។ បរិញ្ញាសហគតោ មគ្គោ
វចីមោនេយ្យំ ។ វាចាយ ឆន្ទរាគស្ស បហានំ
វចីមោនេយ្យំ ។ វចីសង្ខារនិរោធោ ទុតិយជ្ឈាន-
សមាបត្តិ វចីមោនេយ្យំ ។ ឥទំ វចីមោនេយ្យំ ។

---

១ ម. កាយារម្មណា ។

ឈ្មោះថា មុនិ ជាអ្នកដល់នូវមោន: ។ មោនេយ្យ: មាន ៣ គឺ កាយមោនេយ្យ: ១ វចីមោនេយ្យ: ១ មនោមោនេយ្យ: ១ ។

កាយមោនេយ្យ: តើដូចម្តេច ។ ការលះបង់កាយទុច្ចរិត ៣ ប្រការ ឈ្មោះថា កាយមោនេយ្យ: ។ កាយសុចរិត ៣ ប្រការ ឈ្មោះថា កាយ-មោនេយ្យ: ។ ញាណមានកាយជាអារម្មណ៍ ឈ្មោះថា កាយមោនេយ្យ: ការកំណត់ដឹងកាយ ឈ្មោះថា កាយមោនេយ្យ: ។ មគ្គប្រកបដោយ ការកំណត់ដឹង ឈ្មោះថា កាយមោនេយ្យ: ។ ការលះបង់ឆន្ទរាគក្នុង កាយ ឈ្មោះថា កាយមោនេយ្យ: ។ ចតុត្ថជ្ឈានសមាបត្តិជាគ្រឿង រលត់កាយសង្ខារ ឈ្មោះថា កាយមោនេយ្យ: ។ នេះ កាយមោនេយ្យ: ។

វចីមោនេយ្យ: តើដូចម្តេច ។ ការលះវចីទុច្ចរិត ៤ ប្រការ ឈ្មោះថា វចីមោនេយ្យ: ។ វចីសុចរិត ៤ ប្រការឈ្មោះថា វចីមោនេយ្យ: ។ ញាណមានវាចាជាអារម្មណ៍ ឈ្មោះថា វចីមោនេយ្យ: ។ ការកំណត់ ដឹងដោយវាចា ឈ្មោះថា វចីមោនេយ្យ: ។ មគ្គប្រកបដោយការ កំណត់ដឹង ឈ្មោះថា វចីមោនេយ្យ: ។ ការលះបង់ឆន្ទរាគក្នុងវាចា ឈ្មោះថា វចីមោនេយ្យ: ។ ទុតិយជ្ឈានសមាបត្តិ ជាគ្រឿងរលត់ វចីសង្ខារ ឈ្មោះថា វចីមោនេយ្យ: ។ នេះ វចីមោនេយ្យ: ។

កតមំ មនោមោនេយ្យំ ។ វិតិធានំ មនោទុច្ចរិតានំ បហានំ មនោមោនេយ្យំ ។ តិវិធំ មនោសុចរិតំ មនោមោនេយ្យំ ។ ចិត្តារម្មណំ ញាណំ មនោមោនេយ្យំ ។ ចិត្តបរិញ្ញា មនោមោនេយ្យំ ។ បរិញ្ញាសហគតោ មគ្គោ មនោមោនេយ្យំ ។ ចិត្តេ ឆន្ទរាគស្ស បហានំ មនោមោនេយ្យំ ។ ចិត្តសង្ខារនិរោធោ សញ្ញាវេទយិតនិរោធសមាបត្តិ មនោមោនេយ្យំ ។ ឥទំ មនោមោនេយ្យំ

កាយមុនឹ វាចាមុនឹ មនោមុនិមនាសវំ
មុនឹ មោនេយ្យសម្បន្នំ អាហុ សព្វប្បហាយិនំ ។
កាយមុនឹ វាចាមុនឹ មនោមុនិមនាសវំ
មុនឹ មោនេយ្យសម្បន្នំ អាហុ និន្ហាតបាបកំ ។

ឥមេហិ មោនេយ្យេហិ ធម្មេហិ សមន្នាគតា ឆ មុនយោ អាគារមុនយោ អនាគារមុនយោ សេក្ខមុនយោ អសេក្ខមុនយោ បច្ចេកមុនយោ មុនិមុនយោ ។ កតមេ អាគារមុនយោ ។ យេ តេ អាគារិកា ទិដ្ឋបទា វិញ្ញាតសាសនា ឥមេ អាគារមុនយោ ។

មនោមោនេយ្យ:តើដូចម្តេច ។ ការលះបង់មនោទុច្ចរិត ៣ ប្រការ ឈ្មោះ ថា មនោមោនេយ្យ: ។ មនោសុចរិត ៣ ប្រការ ឈ្មោះថា មនោ-មោនេយ្យ: ។ ញាណមានចិត្តជាអារម្មណ៍ ឈ្មោះថា មនោមោនេយ្យ: ។ ការកំណត់ដោយចិត្ត ឈ្មោះថា មនោមោនេយ្យ: ។ មគ្គប្រកបដោយ ការកំណត់ដឹង ឈ្មោះថា មនោមោនេយ្យ: ។ ការលះឆន្ទរាគក្នុងចិត្ត ឈ្មោះថា មនោមោនេយ្យ: ។ សញ្ញាវេទយិតនិរោធសមាបត្តិជាគ្រឿង រលត់ចិត្តសង្ខារ ឈ្មោះថា មនោមោនេយ្យ: ។ នេះ មនោមោនេយ្យ: ។

បណ្ឌិតទាំងឡាយ ពោលនូវអ្នកប្រាជ្ញផ្លូវកាយ អ្នកប្រាជ្ញផ្លូវ វាចា អ្នកប្រាជ្ញផ្លូវចិត្ត អ្នកប្រាជ្ញមិនមានអាសវ: ដែលបរិបូណ៌ ដោយមោនេយ្យធម៌ ថាជាអ្នកលះបង់នូវបាបទាំងពួង ។

បណ្ឌិតទាំងឡាយ ពោលនូវអ្នកប្រាជ្ញផ្លូវកាយ អ្នកប្រាជ្ញផ្លូវ វាចា អ្នកប្រាជ្ញផ្លូវចិត្ត អ្នកប្រាជ្ញមិនមានអាសវ: ដែលបរិ-បូណ៌ ដោយមោនេយ្យធម៌ ថាជាអ្នកលាងបាប ។

មុនិប្រកបដោយមោនេយ្យធម៌ទាំងនេះ មាន ៦ ពួក គឺ អាគារ-មុនិ អនាគារមុនិ សេក្ខមុនិ អសេក្ខមុនិ បច្ចេកមុនិ មុនិមុនិ ។ ពួក អាគារមុនិ តើដូចម្តេច ។ ពួកគ្រហស្ថណា បានឃើញនូវបទ គឺព្រះនិព្វាន បានដឹងច្បាស់នូវសាសនា ពួកនេះ ឈ្មោះអាគារមុនិ ។

កតមេ អជាតារមុនយោ ។ យេ តេ បព្ជិតា ជិដ្ឋបជា
វិញ្ញាតសាសនា ឥមេ អជាតារមុនយោ ។ សត្ត សេក្ខា
សេក្ខមុនយោ ។ អរហន្តោ អសេក្ខមុនយោ ។
បច្ចេកពុទ្ធា បច្ចេកមុនយោ ។ មុនិមុនយោ តថាគតា
អរហន្តោ សម្មាសម្ពុទ្ធា ។

ន មោនេន មុនិ ហោតិ មូឡ្ហរូបោ អវិទ្ទសុ
យោ ច តុលំវ បគ្គយ្ហ វរមាទាយ បណ្ឌិតោ
បាបានិ បរិវជ្ជេតិ ស មុនិ តេន សោ មុនិ
យោ មុនាតិ ឧភោ លោកេ មុនិ តេន បវុច្ចតិ

អសតញ្ច សតញ្ច ញត្វា ធម្មំ
អជ្ឈត្តំ ពហិទ្ធា ច សព្ជលោកេ
ទេវមនុស្សេហិ ឬជិតោ
យោ សោ[1] សង្គជាលមតិច្ច សោ មុនិ ។

---

១ ម. សោតិ នត្ថិ ។

ពួកអនាគារមុនិ តើដូចម្តេច ។ ពួកបព្វជិតណា បានឃើញនូវបទ គឺព្រះនិព្វាន បានដឹងច្បាស់នូវសាសនា ពួកនេះ ឈ្មោះអនាគារមុនិ ។ សេក្ខបុគ្គល ៧ ពួក ឈ្មោះសេក្ខមុនិ ។ ពួកព្រះអរហន្ត ឈ្មោះអសេក្ខ-មុនិ ។ ពួកព្រះបច្ចេកពុទ្ធ ឈ្មោះបច្ចេកមុនិ ។ ព្រះតថាគតទាំងឡាយ ជាអរហន្ត សម្មាសម្ពុទ្ធ ឈ្មោះមុនិមុនិ ។

បុគ្គលមានសភាពជាអ្នកវង្វេង មិនមានការចេះដឹង មិនមែនឈ្មោះថាមុនិ ដោយការស្ងៀមទេ លុះតែបុគ្គលណា ជាបណ្ឌិត កាន់យកធម៌ដ៏ប្រសើរ ហើយវៀរបង់ នូវបាបទាំងឡាយ ដូចបុគ្គល ផ្ទង់ នូវជញ្ជីង (ហើយថ្លឹង) បុគ្គលនោះ ឈ្មោះថាមុនិ បុគ្គលនោះ ឈ្មោះថាមុនិ ដោយហេតុនោះ បុគ្គលណា ដឹងនូវប្រយោជន៍ទាំងពីរក្នុងលោក បុគ្គលនោះ ទើបតថាគតហៅថា មុនិ ដោយហេតុនោះ បុគ្គលណា ដឹងធម៌របស់ពួកអសប្បុរសផង របស់ពួកសប្បុរសផង ទាំងខាងក្នុង ទាំងខាងក្រៅ ក្នុងលោកទាំងអស់ ជាបុគ្គលដែលទេវតានិងមនុស្សទាំងឡាយបូជាហើយ បានធ្វើនូវសំណាញ់ គឺកិលេសជាគ្រឿងចំពាក់ បុគ្គលនោះ ឈ្មោះថា មុនិ ។

វិប្ផមុត្តោតិ មុនិនោ ភាតា ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ នោសា ចិត្តំ មោហា ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ ។ បេ ។ សព្វាកុសលាភិសង្ខារេហិ ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តន្តិ ស បន្ធភាវោ[1] មុនិ វិប្ផមុត្តោ ។

[៣៧៩] ន ឥកប្ជិយោ ន្ជូបរតោ ន បត្តិយោតិ ភតវាតិ ឥកប្ជោតិ ទ្វេ ឥកប្ជា តណ្ហាឥកប្ជោ ច ទិដ្ឋិ-ឥកប្ជោ ច ។ បេ ។ អយំ តណ្ហាឥកប្ជោ ។ បេ ។ អយំ ទិដ្ឋិ-ឥកប្ជោ ។ តស្ស តណ្ហាឥកប្ជោ បហីនោ ទិដ្ឋិឥកប្ជោ បដិនិស្សដ្ឋោ តណ្ហាឥកប្ជស្ស បហីនត្តា ទិដ្ឋិឥកប្ជស្ស បដិនិស្សដ្ឋត្តា តណ្ហាឥកប្ជំ វា ទិដ្ឋិឥកប្ជំ វា ន ឥកប្ជតិ ន ជនេតិ ន សញ្ជនេតិ ន និព្ជត្តេតិ ជាកិនិព្ជត្តេតីតិ ន ឥកប្ជិយោ ។ ន្ជូបរតោតិ សព្ជេ ពាលបុថុជ្ជនា រជ្ជន្តិ ឥកល្យាណបុថុជ្ជនំ ឧចាជាយ សត្ត សេក្ខា

---

1 ម. សម្ប្ជន្ធភាវោ ។

ពាក្យថា រួចស្រឡះ គឺ ចិត្តរបស់មុនិ រួច រួចវិសេស រួចស្រ-ឡះ ចាករាគៈ ចិត្ត (រួចស្រឡះ) ចាកទោសៈ ចិត្ត រួច រួចវិសេស រួចស្រឡះ ចាកមោហៈ ។ បេ ។ ចិត្ត រួច រួចវិសេស រួចស្រឡះ ចាកអកុសលាភិសង្ខារទាំងអស់ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ មានការៈដាក់ចុះហើយ ជាមុនិរួចស្រឡះហើយ ។

[៣៧៩] *អធិប្បាយពាក្យថា ព្រះមានព្រះភាគ (ទ្រង់ត្រាស់ថា) ជាអ្នកមិនមានការកំណត់ មិនត្រេកអរ មិនមានសេចក្តីប្រាថ្នា ត្រង់ពាក្យថា ការកំណត់ បានដល់ការកំណត់ ២ គឺ ការកំណត់គឺតណ្ហា ១ ការកំណត់គឺទិដ្ឋិ ១ ។ បេ ។ នេះ ការកំណត់គឺតណ្ហា ។ បេ ។ នេះ ការកំណត់គឺទិដ្ឋិ ។ បុគ្គលនោះ លះបង់នូវការកំណត់គឺតណ្ហា រលាស់ចោលនូវការកំណត់គឺទិដ្ឋិ ព្រោះបានលះបង់ការកំណត់គឺតណ្ហា រលាស់ចោលការកំណត់គឺទិដ្ឋិ បុគ្គលនោះ មិនកំណត់ មិនឲ្យកើត មិនឲ្យកើតព្រម មិនឲ្យលេចឡើង មិនឲ្យលេចឡើងចំពោះ នូវការកំណត់គឺតណ្ហា ឬការកំណត់គឺទិដ្ឋិ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនមានការកំ-ណត់ ។ ពាក្យថា ជាអ្នកមិនត្រេកអរ សេចក្តីថា ពាលបុថុជ្ជនទាំងអស់ រមែងត្រេកអរ សេក្ខបុគ្គលទាំង ៧ ពួក រាប់យកកល្យាណបុថុជ្ជនផង*

អបត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ អារមន្តិ វិរមន្តិ បដិវិរមន្តិ អវហារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យាតិ(១) ន កប្បិយោ ឆូបរតោ ។ ន បត្ថិយោតិ បត្ថនា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ យស្សេសា បត្ថនា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ វុច្ចតិ ន បត្ថិយោ ។ ភគវាតិ គារវាធិវចនំ ។ អបិច ភគ្គរាគោតិ ភគវា ។ ភគ្គទោសោតិ ភគវា ។ ភគ្គមោហោតិ ភគវា ។ ភគ្គមានោតិ ភគវា ។ ភគ្គទិដ្ឋីតិ ភគវា ។

១ ម. វិហរតីតិ ។

រមែងត្រេកអរទូទៅ ត្រេកអរចំពោះ ដើម្បីដល់នូវគុណដែលខ្លួនមិនទាន់ដល់ ដើម្បីបាននូវគុណដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ ឯព្រះអរហន្តជាអ្នកធ្វាយ រៀរបង់ រៀរចំពោះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ មិនប្រកប មានចិត្តប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) មិនមានការកំណត់ មិនត្រេកអរ ។ ពាក្យថា មិនមានសេចក្តីប្រាថ្នា សេចក្តីថា តណ្ហា លោកហៅថា សេចក្តីប្រាថ្នា បានដល់សេចក្តីត្រេកអរ សេចក្តីត្រេកអរដ៏មានកម្ទាំង ។ បេ ។ អកិញ្ចា លោកៈ អកុសលមូល ។ សេចក្តីប្រាថ្នានុ៎ះ បុគ្គលណា លះបង់ហើយ ផ្តាច់ផ្តិលហើយ ឲ្យសូប ឲ្យសូបរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមិនមានសេចក្តីប្រាថ្នា ។ ពាក្យថា ព្រះមានព្រះភាគ ជាពាក្យពោលដោយគោរព ។ ម្យ៉ាងទៀត ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បង់រាគៈ ។ ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បង់ទោសៈ ។ ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំ-បាក់បង់មោហៈ ។ ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បង់មានៈ ។ ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បង់ទិដ្ឋិ ។

ភត្តកណ្ណោកោតិ ភតវា ។ ភត្តកិលេសោតិ ភតវា ។ ភជិ វិភជិ បជិវិភជិ ធម្មរតនន្តិ ភតវា ។ ភវានំ អន្តកោ-តិ ភតវា ។ ភាវិតកាយោតិ ភតវា ។ ភាវិតសីលោតិ ភាវិតចិត្តោតិ ភាវិតប្បញ្ញោតិ ភតវា ។ ភជិ វា ភតវា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ អប្បសទ្ទានិ អប្បនិគ្ឆោសានិ វិជនវាតានិ មនុស្សរាហាសេយ្យកានិ បដិសល្លានសារ្ប្បានីតិ ភតវា ។ ភាគី វា ភតវា ចីវរ-បិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ភតវា ។ ភាគី វា ភតវា អត្ថរសស្ស ធម្មរសស្ស វិមុត្តិរសស្ស អធិសីលស្ស អធិចិត្តស្ស អធិប្បញ្ញា-យាតិ ភតវា ។ ភាគី វា ភតវា ចតុន្នំ ឈានានំ ចតុន្នំ អប្បមញ្ញានំ ចតុន្នំ អារូបសមាបត្តីនន្តិ ភតវា ។

ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បង់នូវចម្រូង ។ ឈ្មោះ
ថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បង់នូវកិលេស ។ ឈ្មោះ
ថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់ចែក រំលែក ញែក នូវធម្មរតន: ។
ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់ធ្វើទីបំផុតនៃភពទាំងឡាយ ។
ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់ចម្រើនព្រះកាយ ។ ឈ្មោះ
ថា ព្រះមានព្រះភាគ ព្រោះហេតុទ្រង់ចម្រើនសីល ចម្រើនចិត្ត ចម្រើន
បញ្ញា ។ មួយទៀត ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់គប់
រកនូវសេនាសន:ទាំងឡាយដ៏ស្ងាត់ គឺព្រៃតូចនិងព្រៃធំ ជាព្រៃមិនមាន
សំឡេង មិនមានការគឹកកង ជាព្រៃប្រាសចាកខ្យល់កាយនៃជន ជា
ព្រៃសូ្ងត់ស្ងាត់ចាកមនុស្ស សមគួរដល់ការពួនសម្ងំ ។ មួយទៀត
ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគ
នៃចីវរ បិណ្ឌបាត សេនាសន: និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។
មួយទៀត ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ
ទ្រង់មានភាគ នៃអត្ថរស ធម្មរស វិមុត្តិរស អធិសីល អធិចិត្ត
អធិប្បញ្ញា ។ មួយទៀត ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុព្រះ
មានព្រះភាគ ទ្រង់មានភាគនៃឈាន ៤ អប្បមញ្ញា ៤ អរូបសមាបត្តិ ៤ ។

ភាគី វា ភគវា អដ្ឋន្នំ វិមោក្ខានំ អដ្ឋន្នំ អភិភាយតនានំ ឆន្នំ អនុបុព្វវិហារសមាបត្តីនន្តិ ភគវា ។ ភាគី វា ភគវា ឧសន្នំ សញ្ញាការានានំ ឧសន្នំ កសិណសមាបត្តីនំ អនាចានស្ឆតិសមាធិស្ស អសុភសមាបត្តិយាតិ ភគវា ។ ភាគី វា ភគវា ចតុន្នំ សតិប្បដ្ឋានានំ ចតុន្នំ សម្មប្បធានានំ ចតុន្នំ ឥទ្ធិចានានំ បញ្ចន្នំ ឥន្ទ្រិយានំ បញ្ចន្នំ ពលានំ សត្តន្នំ ពោជ្ឈង្គានំ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ឆតិ ភគវា ។ ភាគី វា ភគវា ឧសន្នំ តថាគតពលានំ ចតុន្នំ វេសារជ្ជានំ ចតុន្នំ បដិសម្ភិទានំ ឆន្នំ អភិញ្ញានំ ឆន្នំ ពុទ្ធធម្មានន្តិ ភគវា ។ ភគវាតិ ដេតំ ឆាមំ មាតរា កតំ ន បិតរា កតំ ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន សមណាព្រាហ្មណេហិ កតំ ន ដេវតាហិ កតំ វិមោក្ខន្តិកមេតំ ពុទ្ធានំ ភគវន្តានំ ពោធិយា មូលេ សហ សព្ពញ្ញុតញ្ញាណស្ស បដិលាភា សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ន ភាយ្ឆិយោ ន ជូបរតោ ន ឆត្តិយោតិ ភគវា ។ ដេតានាហ ភគវា

មួយទៀត ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃវិមោក្ខ ៨ អភិភាយតន: ៨ អនុបុព្វវិហារសមាបត្តិ ៩ ។ មួយទៀត ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគទ្រង់មានភាគនៃសញ្ញាភាវនា ១០ កសិណសមាបត្តិ ១០ អានាបានស្សតិ-សមាធិ អសុភសមាបត្តិ ។ មួយទៀត ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល: ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ។ មួយវិញទៀត ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃតថាគតពល: ១០ វេសារជ្ជ: ៤ បដិ-សម្ភិទា ៤ អភិញ្ញា ៦ ពុទ្ធធម៌ ៦ ។ ព្រះនាមថាព្រះមានព្រះភាគ នេះមិនមែនមាតាធ្វើ មិនមែនបិតាធ្វើ មិនមែនបងប្អូនប្រុសធ្វើ មិនមែនបងប្អូនស្រីធ្វើ មិនមែនពួកមិត្តអាមាត្យធ្វើ មិនមែនពួកញាតិសាលោហិតធ្វើ មិនមែនពួកសមណព្រាហ្មណ៍ធ្វើ មិនមែនពួកទេវតាធ្វើទេ ព្រះនាមថាព្រះមានព្រះភាគនេះ របស់ព្រះពុទ្ធទាំងឡាយ ដ៏មានព្រះភាគ ជាព្រះនាមកើតក្នុងទីបំផុតវិមោក្ខ ការបញ្ញត្តថា មានព្រះភាគ នេះ(កើត) អំពីការត្រាស់ដឹង ព្រមដោយការបានចំពោះនូវសព្វញ្ញុតញ្ញាណ ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគ (ត្រាស់ថា) មិនមានការកំណត់ មិនត្រេកអរ មិនមានសេចក្ដីប្រាថ្នា ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ស សព្វធម្មេសុ វិសេនិភូតោ
យង្កិញ្ចិ ទិដ្ឋំវ សុតំ មុតំ វា
ស បន្នភារោ មុនិ វិប្បមុត្តោ
ន កប្បិយោ នូបរតោ ន បត្ថិយោតិ
ភគវាតិ ។

តេរសមោ មហាវិយូហសុត្តនិទ្ទេសោ និដ្ឋិតោ ។

ព្រះមានព្រះភាគ (ទ្រង់ត្រាស់ថា) បុគ្គលនោះ ធ្វើសេនាណាមួយ ដែលឃើញ ឮ ឬប៉ះពាល់ហើយ ឲ្យវិនាសក្នុងធម៌ទាំងពួង បុគ្គលនោះមានការៈដាក់ចុះហើយ ជាមុនិ រួចស្រឡះហើយ ជាអ្នកមិនមានការកំណត់ មិនត្រេកអរ មិនមានសេចក្តីប្រាថ្នា ។

ចប់ មហាវិយូហសុត្តនិទ្ទេស ទី ១៣ ។

រៀបចំវាយអក្សរឡើងវិញនិងពិនិត្យតាមច្បាប់ដើមដោយ

គណៈកម្មការពុទ្ធិកវប្ប:ធម៌អត្ថការមូលនិធិវត្តបញ្ញាធំ

ការវាយអក្សរ និងបោះពុម្ពសាឡើងវិញនូវសៀវភៅព្រះត្រៃបិដកបាលី និងសេចក្តីប្រែជាភាសាខ្មែរ ដែលជាស្នាដៃ របស់លោកអ្នកប្រាជ្ញជំនាន់មុន គឺអាស្រ័យដោយការមើលឃើញនូវកត្តាចាំបាច់ មួយចំនួនដូចខាងក្រោម ៖

- ឯកសារដើម ត្រូវបានថតចម្លងច្រើនសា ធ្វើឲ្យមានលក្ខណៈមិនច្បាស់ពិបាកក្នុងការអាន
- រក្សាស្នាដៃវប្ប:ធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុងរឿងក្នុងលោក

ដោយកុសលផលបុណ្យទាំងអម្បាលមាណ ដែលកើតអំពីធម្មទាននេះ
សូមឲ្យព្រះពុទ្ធសាសនាផ្សាយទៅគ្រប់ទិសទីទូទាំងសកលលោក
សូមឲ្យសព្វសត្វទាំងឡាយទាំងពួងបាននូវសេចក្តីសុខសួស្តី
សូមឲ្យមនុស្សគ្រប់ជាតិសាសន៍មានភាតរភាពនឹងគ្នា
សូមឲ្យពិភពលោកទាំងមូលមានសុខសន្តិភាព ។

ក្នុងករណីដែលលោកអ្នកអានបានពើបប្រទះនូវកំហុសឆ្គងណាមួយ ចង់ឲ្យយើងកែតម្រូវ ឬចង់បានសៀវភៅធម៌យកទៅអាន សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោម:

វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទ: (៨៥៥) ១២ ៩៦១ ៤២៩, (៨៥៥) ៨៨៧ ៩៦១ ៤២៩

អ៊ីមែល: maha.panna@gmail.com

គេហទំព័រ: http://www.mahapanna.org

DEDICATION OF MERIT

May the merit and virtue
accrued from this work
adorn Amitabha Buddha's Pure Land,
repay the four great kindnesses above,
and relieve the suffering of
those on the three paths below.
May those who see or hear of these efforts
generate Bodhi-mind,
spend their lives devoted to the Buddha Dharma,
and finally be reborn together in
the Land of Ultimate Bliss.
Homage to Amita Buddha!

NAMO AMITABHA

南無阿彌陀佛

《柬埔寨巴利文：小部阿含經：大義釋》

財團法人佛陀教育基金會 印贈

台北市杭州南路一段五十五號十一樓

Printed and donated for free distribution by

The Corporate Body of the Buddha Educational Foundation

11F, No. 55, Sec. 1, Hang Chow South Road, Taipei, Taiwan, R.O.C.

Tel: 886-2-23951198 , Fax: 886-2-23913415

Email: overseas@budaedu.org

Website: http://www.budaedu.org

Mobile Web: m.budaedu.org

This book is strictly for free distribution, it is not to be sold.

សម្រាប់ចែកជាធម្មទាន

Printed in Taiwan

200 copies; September 2019

CA087 - 17053